ប្រជុំគារណនាវរៈ

បាលី~ខ្មែរ

ព្រមទាំងសេចក្តីពន្យល់



ផ្សាយចេញពីវត្តវិសុទ្ធិមគ្គ

រៀបចំកែសម្រួលថ្មី

ដោយភិក្ខុរតនបុប្ផោ បុប្ផ~សំបាន

សៀមរាប ថ្ងៃចន្ទ ១៥កើត ខែមាឃ ឆ្នាំមមែ សប្តស័ក ព.ស.២៥៥៩

ប្រជុំគាណានាវះ

បាលី-ប្រែ

និងសេចក្តីពន្យល់



ផ្សាយចេញពីវត្តវិសុទ្ធិមគ្គ

ច្បាប់ដើមបុរាណនិពន្ធ

ពន្យល់ និងរៀបចំកែសម្រួលថ្មី

ដោយភិក្ខុរតនបុប្ផោ បុប្ផ-សំបាន

សៀមរាប ថ្ងៃចន្ទ ១៥ កើត ខែមាឃ ឆ្នាំមមែ សប្តស័ក

ព.ស. ២៥៥៩ គ.ស.២០១៦

ឈ្មោះសៀវភៅ **ប្រជុំតាណានារ: ចាលី-ប្រែ** និងសេចក្តីពន្យល់

ច្បាប់ដើមបុរាណនិពន្ធ **ពន្យល់ និងរៀបចំកែសម្រួលថ្មី**

ដោយភិក្ខុរតនបុប្ផោ បុប្ផ-សំបាន

អ្នកមានឧបការៈក្នុងការធ្វើសៀវភៅនេះ

-លោកម្ចាស់គ្រូ **ធម្មចារ្យោ សាន-សប្បាយ** ផ្តើមគំនិត និងអនុញ្ញាត ឱ្យប្រើប្រាស់កុំព្យូទ័ររបស់សង្ឃ,

-ព្រះធម្មាចារ្យ ធម្មកាម **មិត្ត-សាន** ពិនិត្យខ្លឹមសារ និងអក្ខរាវិរុទ្ធ

-ភិក្ខុចន្ទប្បញ្ញោ **ខាន់-សុចិន្ត** ពិនិត្យខ្លឹមសារ និងអក្ខរាវិរុទ្ធ

-ភិក្ខុ អច្ចិន្តវីរិយោ **យ៉ាវ-យឿន** ពិនិត្យខ្លឹមសារ និងអក្ខរាវិរុទ្ធ

-សាមណេរ វិនយបាលោ **ជា-សុផល** ជួយប្រែជីកា

-ឧបាសក **ស៊ឹម-រតនៈ** គ្រូពុទ្ធិកបឋមសិក្សា វត្តឃោសិតារាម ពិនិត្យខ្លឹសារ អក្ខរាវិរុទ្ធ និងជួយខ្វល់ខ្វាយក្នុងការធ្វើសៀវភៅនេះ

-យុវជន **ហ៊ឹម-ចាន់កុសល** ជួយចម្លងអត្ថបទពីច្បាប់ដើម

-យុវជន **កាន់-ចន្ត្រា** រចនាក្រប និងជំនួយបច្ចេកទេសកុំព្យូទ័រ

ទីកន្លែងធ្វើ វត្តវិសុទ្ធិមគ្គ ភូមិបំពេញរាជ្យ ឃុំលាងដែ ស្រុកអង្គរធំ ខេត្តសៀមរាប

កាលបរិច្ឆេទ ថ្ងៃចន្ទ ១៥ កើត ខែមាឃ ឆ្នាំមមែ សប្តស័ក ពុទ្ធសករាជ ២៥៥៩

ផ្សាយចេញពី វត្តវិសុទ្ធិមគ្គ (ភិនវីទ្ធារាម) សម្រាប់ជាធម្មទាន

ឧប្បត្តិកថា

ដើមហេតុដែលនាំឱ្យខ្ញុំរៀបចំធ្វើសៀវភៅ “**ប្រជុំគាណាវារៈ**” នេះឡើងជាថ្មីនោះ ដោយបានឮកិក្ខុសាមណេរ និងឧបាសក ឧបាសិកាជាច្រើនរូប មានការតួញតែ្អរអ្អែរទាំថា “សៀវភៅប្រជុំភាណវារៈខ្លះ ដែលឈ្មួញយកទៅវាយចម្លងបោះពុម្ពថ្មីសព្វថ្ងៃនេះ មានខុសអក្ខរាវិរុទ្ធច្រើន លំបាកដល់ការរៀនសូត្រ ដូចជាទន្ទេញបានចេះចាំហើយ តែសូត្រមិនត្រូវនឹងគេ គឺសូត្រមិនត្រូវគ្នា . . .” ។

ហេតុដូច្នេះហើយ ទើបធ្វើឱ្យខ្ញុំមានគំនិតកើតឡើងថា ប្រសិនបើមានឱកាសសមគួរណាមួយ នឹងរៀបចំកែសម្រួលនូវសៀវភៅប្រជុំភាណវារៈជាថ្មីឡើងវិញ ដោយយកសៀវភៅប្រជុំភាណវារៈដែលមានទាំងប៉ុន្មានមកផ្ទឹងផ្ទាត់គ្នា ហើយកែតម្រូវនូវអក្ខរាវិរុទ្ធដែលមានខុសខ្លះនោះ ឱ្យបានត្រឹមត្រូវឡើងវិញ ព្រមទាំងសរសេរសេចក្តីពន្យល់ត្រង់ចំណុចនីមួយៗ ដើម្បីយកទៅប្រើឱ្យបានត្រឹមត្រូវតាមពិធីនោះៗ ។

គំនិតនេះ ចេះតែប្រាកដឡើងៗ មិនរលុបរលាយឡើយ ។ គាប់ចួនថ្ងៃមួយជាឱកាសឱ្យបំណងរបស់ខ្ញុំបានសម្រេច ទទួលលោកម្ចាស់គ្រូ **ធម្មចារ្យោ សាន ៘ សប្បាយ** ជាព្រះគ្រូចៅអធិការនៃវត្តវិសុទ្ធិមគ្គ បានសន្ទនាអំពីរឿងនេះជាមួយនឹងខ្ញុំ ហើយលោកក៏បានមានថេរដីកាថា “សូម្បីលោក ក៏មានបំណងចង់រៀបចំធ្វើសៀវភៅប្រជុំភាណវារៈនេះជាថ្មីដែរ”, ដោយលោកបានឱ្យឃុវជន **ហ៊ឹម-ចាន់កុសល** ជាអតីតសមណសិស្សវត្តវិសុទ្ធិមគ្គ ចម្លងអត្ថបទសៀវភៅ

ប្រជុំភាណវារៈច្បាប់ដើម ដោយវាយជាអក្សរកុំព្យូទ័ររួចចប់សព្វគ្រប់ហើយដែរ លោកក៏បានប្រគល់នូវការនេះឱ្យមកជាការៈរបស់ខ្ញុំ ដែលជាដំណើរស្របចួនទៅលើពន្ធកគំនិតរបស់ខ្ញុំ ដែលបម្រុងនឹងលួតលាស់ស្រាប់ ខ្ញុំក៏ទទួលធ្វើដោយសោមនស្ស និងវីរិយភាពជ័មុតមាំដរាបជល់បានសម្រេច ។

សូមបញ្ជាក់ថា ដើមឡើយខ្ញុំគិតថា ចាំខ្ជិនសិក្សាស្រាវជ្រាវឱ្យបានច្រើនជាមុនសិន សឹមរៀបចំធ្វើជាខាងក្រោយ នោះទើបជាការងាយស្រួល មិនសូវលំបាក, ម្យ៉ាងក៏កំពុងតែនៅសិក្សាផង តែដោយលោកមានថេរដីកាថាចង់បានឱ្យសៀវភៅនេះចេញឆាប់ ៗ ទើបខ្ញុំខំព្យាយាមស្រាវជ្រាវ និងសាកសួរសព្រហ្ម-ចារីខ្លះថែមទៀតផ្សំផង ទើបធ្វើបានត្រឹមតែប៉ុណ្ណេះសិន ដោយផ្តងចិត្តទុកថាតទៅថ្ងៃខាងមុខបើជីវិតនៅមានទឹងបំពេញបន្ថែមត្រង់ចំណុចណាដែលនៅខ្វះខាត, ម្យ៉ាងទៀតក៏សង្ឃឹមទុកថាវិញ្ញូជនទាំងឡាយនឹងអនុគ្រោះ ជួយកែតម្រូវ និងជួយផ្តល់ជាគំនិត និងចំណេះដឹងល្អៗបន្ថែមទៀត ដើម្បីធ្វើឱ្យសៀវភៅនេះកាន់តែល្អប្រសើរឡើងថែមទៀត ។

ខ្ញុំសូមអភ័យទោសរាល់កំហុសឆ្គង ដែលនឹងអាចកើតមានដោយការចេះមិនដល់ យល់មិនជ្រៅ ដៅមិនចំ ព្រោះសតិបញ្ញានៅទន់ខ្ចីនៅឡើយ, និងសូមអរព្រះគុណ និងអរគុណទុកជាមុន រាល់មតិយោបល់ទាំងឡាយគ្រប់យ៉ាងក្នុងន័យដើម្បីជួយស្តាបនា ។

រតនបុត្តោ បុត្ត សំបាន

អារម្ភកថា

ប្រជុំតារណនារៈ *គឺជាសៀវភៅប្រជុំនូវធម៌សូធ្យផ្សេងៗ ដែលបូរាណាចារ្យ លោកបានប្រមូលដកស្រង់នូវគោលធម៌ពីគម្ពីរផ្សេងៗ មានព្រះត្រៃបិដកជាដើម យកមករៀបទុកជារបៀបតាមលំដាប់លំដោយសម្រាប់ ឱ្យពុទ្ធសាសនិកជនមានភិក្ខុសាមណេរជាដើមយកទៅទន្ទេញឱ្យបានចេះចាំស្ទាត់រត់មាត់ ដើម្បីប្រើសូធ្យជាកិច្ចវត្តប្រចាំថ្ងៃផង និងសម្រាប់សូធ្យក្នុងកម្មវិធីបុណ្យផ្សេងៗ ក្នុងសាសនាផង។*

ឯរបៀបសេចក្តីនៃកាណាវារៈដែលលោករៀបរៀងនោះ គឺមានក្នុងសៀវភៅប្រជុំកាណាវារៈនោះស្រាប់ហើយ ខ្ញុំសូមមិនរៀបរាប់ទៀតទេ។

*ចំណែកសៀវភៅ “**ប្រជុំតារណនារៈ**” ច្បាប់ថ្មីនេះ ខ្ញុំបានយកសៀវភៅ **ប្រជុំកាណាវារៈ របស់បណ្ឌិត សែម-សួរ** ជាគោល ហើយយកទៅផ្ទៀងផ្ទាត់ជាមួយនឹង**ប្រជុំកាណាវារៈរបស់បណ្ឌិត កៅ-ឈឺន, កាណាវារបាលីរបស់ពុទ្ធសាសនបណ្ឌិត្យ** និង**សត្តបរិត្ត-ទ្វាទសបរិត្តរបស់ព្រះវិសុទ្ធិវង្ស ហួត-តាត** ដើម្បីឱ្យត្រូវគ្នាតែបែបមួយ លុះផ្ទៀងផ្ទាត់គ្នារួចហើយ ក៏យកទៅប្រៀបធៀបជាមួយនឹងច្បាប់ដើមមួយសាទៀត គឺបើធម៌ណាដែលបានដកមកពីបិដក ឬអដ្ឋកថាណា ក៏កែឱ្យត្រូវតាមច្បាប់នោះវិញ, គឺកែទាំងបាលី និងសេចក្តីប្រែតែត្រង់ណាដែលមានការភ្ញាំងក្ងាត់ឱ្យបានត្រឹមត្រូវតាមច្បាប់ដើម ឬតាមន័យដែលព្រះអដ្ឋកថាចារ្យលោកបានពន្យល់ទុក។ ឯរបៀបសូធ្យ គឺសូធ្យតាមលំនាំប្រជុំកាណាវារៈនោះឯង មិនខុសគ្នាឡើយ ។ ត្រង់ចំណុចដែលប្លែកគ្នានោះ គឺខ្ញុំបានកែនូវរបៀបលំដាប់*

នៃគោលធម៌ខ្លះដែលមានស្រាប់ហើយ ដោយដាក់ជាក្រុម ជាពួកជាមួយគ្នា ដូចខាងក្រោម ៖

- *យកធម៌ទមស្ការមកដាក់ជាមួយគ្នាតែមួយក្រុម,*
- *យកអនុមោទនាវិធីមកដាក់ជាមួយគ្នាតែមួយក្រុមហើយចែកជា៣,*
- *យកសំវេជនីយគាថាមកដាក់បន្ទាប់ពីអនុមោទនាវិធី,*
- *យកព្រះបរិត្តមកដាក់ជាមួយគ្នាតែមួយក្រុម,*
- *យកព្រះសូត្រផ្សេងៗ មកដាក់ជាមួយគ្នាតែមួយក្រុមបន្ទាប់ពីព្រះបរិត្ត។*

និងបានជក់ស្រង់យកសូត្រ និងព្រះគាថាមួយចំនួនមកដាក់បន្ថែមខ្លះទៀត ដូចជាធម៌សម្រាប់ធ្វើកត្តានុមោទនាជាដើម ដើម្បីនឹងឱ្យមានធម៌ច្រើន កាន់តែសម្បូរក្នុងការរៀនសូត្រ ព្រមទាំងបានពន្យល់នយត្រង់ពិធីឬគោលនីមួយៗ ដើម្បីឱ្យអ្នកសិក្សាបានយល់ ហើយយកទៅប្រើឱ្យបានត្រឹមត្រូវតាមវិធីនោះ។ ព្រមទាំងបានប្រាប់ឈ្មោះគម្ពីរដែលបានជក់ស្រង់យកមកផងដែរ ដូចជា បើជកមកពីបិដកលេខប៉ុន្មាន ក៏ដាក់លេខ និងទំព័រនោះ, តែធម៌ខ្លះក៏មិនបានប្រាប់ ពីព្រោះមិនទាន់បានជួប និងខ្លះទៀតគឺជាពាក្យនិពន្ធខាងក្រោយ ដូចជាបកិណ្ណកបរិត្តជាដើម។ និងចំណុចមួយទៀត ត្រង់ធម៌សូត្រផ្សេងៗ មានព្រះវិនយ ព្រះសូត្រនិងព្រះអភិធម្មសង្ខេប ដែលសម្រាប់សូត្រក្រោយពេលចប់ទេសនាសង្គាយនានោះ ខ្ញុំមិនបានដាក់ទេ ព្រោះគិតឃើញថាមិនសូវជាចាំបាច់។

ហេតុដែលខ្ញុំរៀបចំធ្វើយ៉ាងនេះ គឺដើម្បីជួយសម្រួលដល់អ្នកសិក្សាឱ្យ

កាន់តែងាយស្រួលក្នុងការទន្ទេញ និងយកទៅប្រើឱ្យបានត្រឹមត្រូវប៉ុណ្ណោះ ពុំមែនមានបំណងចង់លុបបំបាត់ស្នាដៃរបស់ម្ចាស់ដើមឡើយ ។

អាស្រ័យហេតុដូចបានរៀបរាប់មកខាងលើនេះ ប្រសិនបើសៀវភៅនេះមានខុសទាស់ត្រង់ណានីមួយ គឺទាំងដោយអក្ខរាវិរុទ្ធ និងដោយរបៀបសេចក្តី ខ្ញុំសូមលោកអ្នកឈ្លាសទាំងឡាយធ្វើនូវសេចក្តីអនុគ្រោះជួយកែតម្រូវ និងជួយណែនាំផង ដើម្បីឱ្យសៀវភៅនេះបានជាក្បួនច្បាប់ដ៏ត្រឹមត្រូវ និងជាដៃគូដ៏ល្អរបស់ព្រះភិក្ខុសាមណេរ និងពុទ្ធសាសនិកទាំងឡាយ។

ខ្ញុំសូមលើកនូវមហាកុសលដ៏ប្រសើរ ដែលកើតអំពីធម្មទាននេះ ថ្វាយប្រគេន ចែកជូន ចំពោះ ដល់ព្រះមហាក្សត្រគ្រប់ជំនាន់ ក្រុមជំនុំព្រះត្រៃបិដក និងម្ចាស់ដើមនៃសៀវភៅនេះផង បុព្វការីជន មានមាតាបិតា គ្រូឧបជ្ឈាយាចារ្យ ព្រមទាំងញាតិកាក្នុងសង្ឃារាវដ្ត និងអ្នកមានឧបការៈក្នុងការធ្វើសៀវភៅនេះផង និងលោកអ្នកដែលកំពុងតែសិក្សាទាំងឡាយផង សូមបានជាបច្ច័យនៃព្រះនិព្វានក្នុងកាលអនាគត កុំបីឃ្លាតក្លាយទៅជាបការៈជំនៃឡើយ។

យំ យំ ឥច្ឆិតំ តំ តំ សមិជ្ឈតុ

សូមអនុមោទនាធម្មទាន !!!

ថ្ងៃសុក្រ ១៥ កើត ខែអាសាឍ ឆ្នាំមមី ឆស័ក ព.ស. ២៥៥៨

ភិក្ខុវតនបុប្ផោ បុត្ត-សំបាន

សេចក្តីជូនដំណឹង

សៀវភៅប្រជុំភាណវារៈនេះ ខ្ញុំបានបោះពុម្ពផ្សាយពីរដងរួចមកហើយ តែក៏នៅមានខុសអក្ខរាវិរុទ្ធ និងសេចក្តីខ្លះ ។ ចំពោះការបោះពុម្ពផ្សាយលើកទី ៣ នេះ ខ្ញុំបានកែតម្រូវនូវអក្ខរាវិរុទ្ធទាំងនោះអស់ជាច្រើនហើយ ព្រមទាំងបានសម្រួលនិងបន្ថែមសេចក្តីខ្លះៗទៀត ដើម្បីឱ្យបានត្រឹមត្រូវតាមព្រះត្រៃបិដក ដែលជាព្រះពុទ្ធដីកា និងអដ្ឋកថាដែលលោកបានពន្យល់ទុក តែបើនៅមានខុសទៀត សូមលោកអ្នកសិក្សាជួយកែឱ្យផង ។

សូមអរគុណ

ប្រជុំតារាងនិង ចាលី រំប្រែ

សន្លឹករបាប់មាតិកា

មាតិកាឆ្មុក្រម **ទំព័រ**

រតនប្បណាមវិធី *(វិធីនៃការថ្វាយបង្គំព្រះរតនត្រ័យ)*

សេចក្តីពន្យល់..... ១

ការថ្វាយបង្គំ មាន ៣ យ៉ាង..... ១

អានិសង្សនៃការនមស្ការថ្វាយបង្គំព្រះរតនត្រ័យ..... . ៣

ត្រែបណាមពិស្តារ

រតនត្តយបូជា (ការថ្វាយគ្រឿងសក្ការៈដល់ព្រះរតនត្រ័យ) ១១

ពុទ្ធរតនប្បណាម (ការថ្វាយបង្គំព្រះពុទ្ធរតនៈ).....១១

ធម្មរតនប្បណាម (ការថ្វាយបង្គំព្រះធម្មរតនៈ)..... ១៥

សង្ឃរតនប្បណាម (ការថ្វាយបង្គំព្រះសង្ឃរតនៈ) ១៨

ត្រែបណាមសង្ខេប

ព្រះពុទ្ធគុណ (ឥតិបិ សោ...) ២៣

ព្រះធម្មគុណ (ស្វាក្ខាតោ...) ២៤

ព្រះសង្ឃគុណ (សុបដិបន្នោ...) ២៦

បណាមគាថា (យោ កប្បកោដីហិ...) ២៨

នមស្ការបូជនីយវត្ថុជាទីគោរព (វន្ទាមិ ចេតិយំ...).....២៩

ពុទ្ធបាទនមក្ការគាថា (គាថានមស្ការស្នាមព្រះពុទ្ធបាទ) ៣០
ធាតុចេតិយនមស្ការគាថា (គាថានមស្ការព្រះធាតុចេតិយ).....៣២
សុភមង្គលគាថា (គាថាសូមសិរីសួស្តី) ៣៦
សច្ចកិរិយា (ឥច្ចេវមច្ចន្ត...) ៣៧

បត្តិទានវិធី (វិធីឧទ្ទិសបុណ្យជល់ពួកញាតិ និងសព្វសត្វ)

សេចក្តីពន្យល់.....៣៩
បត្តិទានគាថា គាថាចែកចំណែកបុណ្យ (យំ កិញ្ចិ...).....៤២
បត្តិទានគាថា (យោទេវតា...).....៤៣
បត្តិទានគាថា (ឥមិនា...).....៤៥
បត្តនាគាថា គាថាតាំងសេចក្តីប្រាថ្នា (ឥមិនា...).....៤៧
ខមាបនគាថា គាថាសូមខមាទោស (យេ កេចិ...) ៤៨
សុខាភិយាចនគាថាសង្ខេប(បសន្នា ហោន្តុ...).....៤៩
អនុមោទនាវក្ខាយាចនគាថា(អាកាសដ្ឋា...) ៥០
តេជះខ្ញុំសាង ៥១
ពាក្យឧទ្ទិទានសសង្ខេប(ឥទំ ភោ...) ៥២
ពាក្យឧទ្ទិសរបស់ជាណុស្សេរាណិព្រាហ្មណ៍.....៥២
សព្វទិសាសុ មេត្តាផរណំ ការផ្សាយមេត្តាចិត្តជល់សព្វសត្វគ្រប់ទិស(សព្វេ បុរត្ថិមា) ...៥៣
ផ្សាយមេត្តាចិត្តជល់សព្វសត្វសង្ខេប.....៥៦
ពាក្យអធិដ្ឋានទាន.....៥៦
មួយបែបទៀតថា.....៥៦

ពាក្យអធិដ្ឋាន.....*៥៧*

ចតុប្បច្ចវេក្ខណវិធី *(វិធីពិចារណាបច្ច័យ ៤)*

សេចក្តីពន្យល់.....*៥៨*
ធាតុប្បច្ចវេក្ខណៈ (យថា បច្ចយំ...) *៥៩*
បដិកូលប្បច្ចវេក្ខណៈ (សព្វានិ ...) *៦០*
តទ្ធណិកប្បច្ចវេក្ខណៈ(បដិសង្ខា...) *៦២*
អតីតប្បច្ចវេក្ខណៈ(អជ្ជ មយា...) *៦៤*
សេចក្តីបញ្ជាក់ *៦៧*

អនុមោទនាវិធី *(វិធីធ្វើអនុមោទនាទាន)*

សេចក្តីពន្យល់.....*៧១*
ការអនុមោទនាមាន ៣ យ៉ាង.....*៦៩*
ការអនុមោទនាមាន ២ បែប..... .....*៦៩*

អនុមោទនាក្នុងពិធីសង្ឃទាន

និធិកណ្ឌសូត្រ (កំណាប់ទ្រព្យ គឺបុណ្យ) *៧៦*
កេណិយានុមោទនាគាថា (អគ្គិហុត្តមុខា...) *៨០*
កាលទានប្បកាសនគាថា គាថាប្រកាសនូវកាលទាន (កណិស្សាម...).....*៨១*
កាលទានសូត្រ (កាលទាន ៥ យ៉ាង) *៨១*
វិហារទានសុត្តគាថា (គាថាអនុមោទនាសេនាសនទាន) *៨៣*

ទេវតោទ្ទិស្សទក្ខិណានុមោទនាគាថា.....៨៥
អគ្គប្បសាទសុត្តគាថា *ការជ្រះថ្លាក្នុងវត្តជ័ប្រសើរ (អគ្គតោ វេ...)* ៨៦
ភោជនទានានុមោទនាគាថា *(អាយុទោ...)* ៨៧
យានទានានុមោទនាគាថា *(អន្នំ បានំ...)* ៨៨
យាគុអនុមោទនាគាថា *អានិសង្សបបវ១០ យ៉ាង (យោ សញ្ញតានំ...)* ៨៩
ទានានិសង្សសូត្រ *(អានិសង្សនៃទាន ៥ យ៉ាង)*.....៩០
ភោជនទានសូត្រ *(ឱ្យភោជនាហារឈ្មោះថាឱ្យនូវស្ថាន ៥ យ៉ាង)*.....៩២
អន្នសូត្រ *(ផលនៃការឱ្យនូវអាហារ)* ៩៣
មច្ឆរិយសុត្តគាថា *(វិបាកនៃបុគ្គលកំណាញ់)*.....៩៤
វនរោបសូត្រ *(បុណ្យច្រើនទាំងយប់ទាំងថ្ងៃ)* ៩៨
គិហិសាមីចិសូត្រ *(បដិបទាដ៏សមគួរបស់គ្រហស្ថ)*.....៩៩
ពហុការសូត្រ *(គ្រហស្ថ និងបព្វជិតអាស្រ័យគ្នានឹងគ្នា)*.....១០១
ទុទ្ទលវិមានវត្ថុគាថា *(គាថាក្នុងទុទ្ទលវិមានវត្ថុ)* ១០៣
អង្គរបេតវត្ថុគាថា *(គាថាក្នុងអង្គរបេតវត្ថុ)*.....១០៥
វិហារទានានុមោទនាគាថា *(គាថាអនុមោទនាវិហារទាន)* ១០៦
អនុមោទនាគាថារបស់ព្រះពុទ្ធទីបង្គរ..... ១០៩
យទិហីនេ..... ១១២

អនុមោទនាក្នុងការចារមង្គល

មង្គលសូត្រ *(មង្គល ៣៨ ប្រការ)* ១១៤
បុព្វណ្ហសូត្រ *(ពេលវេលាដែលជាទក្ខត្តប្បក្សល្អ)* ១១៤

សប្បុរិសសូត្រ (ទានរបស់សប្បុរស ៥ យ៉ាង) ๑๑๖
អាទិយសុត្តគាថា (គោលការណ៍ប្រើទ្រព្យឱ្យជាប្រយោជន៍) ๑๒๙
សង្គហវត្ថុគាថា (សង្គហវត្ថុ ๔ យ៉ាង) ๑๒๒
ខេមាខេមសរណទីបិកគាថា(ទីពឹងជ័ក្សេម និងមិនក្សេម) ๑๒๑
អទន្ធិទ្ធសុត្តគាថា (ភាពជាអ្នកមិនទ័លក្រ, ជីវិតមិនឥតប្រយោជន៍) ๑๒๓
អនុមោទនាវគ្គគាថានិងបច្ចេកពុទ្ធានុមោទនាគាថា.....๑๒๔
សព្ពីតិយោ.....๑๒๔
មង្គលចក្កវាឡ (សព្វពុទ្ធា..., អាយុវឌ្ឍកោ...) ๑๒๕
សិទ្ធិយាចនគាថា (សិទ្ធមត្ថ...).....๑๒๘
តេអត្ថលទ្ធា.....๑๒๙

អនុមោទនាក្នុងការងារអភិវឌ្ឍន៍

តិរោកុឌ្ឌសូត្រ (តិរោកុឌ្ឌ...) ๑๓๐
ខេត្តូបមាបេតគាថា (ព្រះអរហន្តដូចស្រែ ទាយកដូចកសិករ)..... ๑๓๔
បុព្វបេតពលិទានានុមោទនាគាថា(យំ កិញ្ចា...).....๑๓๕
ជីវកត្ថានុមោទនាគាថា (បណ្ឌបលាសោវ...) ๑๓๖
ឧបនេយ្យសូត្រ (អាយុរបស់សត្វមានប្រមាណតិច) ๑๓๗
អច្ចេន្តិសូត្រ (កាលទាំងឡាយតែងកន្លងផុតទៅ).....๑๓๘
អាទិត្តសុត្តគាថា (ផលនៃការឱ្យទាន) ๑๓๙
បព្វតោបមសុត្តគាថា (ឧបមាដោយភ្នំថ្មតាន់) ๑๔๑

សំវេជនីយគាថា

សេចក្តីពន្យល់ ១៨៣

កិសាគោតមីថេរីគាថា (*ន គាមធម្មោ...*) ១៨៥

មហាសុទស្សនសុត្តគាថា (*អនិច្ចា...*) ១៨៦

អយ្យិកាសុត្តគាថា *បុណ្យជាទីពឹងរបស់សត្វលោក* (*សព្ពេ សត្តា...*) ១៨៧

ផេណបិណ្ឌបមសុត្តគាថា *ខន្ធ ៥ ឥតខ្លឹមសារ* (*ផេណបិណ្ឌ...*) ១៨៨

អាយុ ឧស្មា ១៨៨

ព្រះធម្មបទគាថា (*អចិរំ...,យថា ទណ្ឌេ ..., សព្ពេសង្ខារា...*) ១៨៩

គាថាក្នុងមហាបរិនិព្វានសូត្រ (*ទហរាបិ ...*) ១៩២

ធម្មុទ្ទេស ៤ យ៉ាង ១៩៣

រដ្ឋបាលសុត្តគាថា (*គាថារបស់ព្រះរដ្ឋបាល*) ១៩៤

អភិណ្ហប្បច្ចវេក្ខណធម្មោ (*ធម៌គួរពិចារណារឿយៗ*) ១៩៦

បព្វជិតអភិណ្ហប្បច្ចវេក្ខណធម្មោ (*ធម៌ ១០ យ៉ាងដែលបព្វជិតគប្បីពិចារណា*) ១៩៧

កទ្ទេកវត្តគាថា (*អ្នកមានរាត្រីមួយជីចម្រើន*) ១៩៨

ជជាសុត្តគាថា (*ការកាប់ឆ្ការនូវជជា គឺតណ្ហា*) ២០០

អច្ឆរាសុត្តគាថា (*ឃានទៅព្រះនិព្វាន*) ២០១

ព្រាហ្មណសុត្តគាថា (*ព្រហ្មយាន គឺអរិយមគ្គមានអង្គ ៨*) ២០២

តាយនសុត្តគាថា (*គាថារបស់តាយនទេវបុត្រ*) ២០៣

ការសុត្តគាថា (*ខន្ធ ៥ ជារបស់ធ្ងន់*) ២០៤

ទុត្តិសាការ (*អាការៈ ៣២ ក្នុងរាងកាយ*) ២០៥

បដិច្ចសមុប្បាទ *ធម៌អាស្រ័យគ្នានឹងគ្នាកើតឡើង (អវិជ្ជាបច្ចយា...)*.....*១៦៥*
អនេកជាតិ *(ឧទានគាថា ជាបឋមពុទ្ធវចនៈ)* *១៦៨*

សត្តប្បករណាភិធម្មបាលី *(ព្រះអភិធម្ម ៧ គម្ពីរ)*

សេចក្តីពន្យល់.....*១៦៩*
ធម្មសង្គណី *តិកមាតិកា ២២ (កុសលា ធម្មា)* *១៧០*
វិភង្គ *ក្នុងអដ្ឋកថា*.....*១៧១*
ធាតុកថា *ក្នុងអដ្ឋកថា*.....*១៧១*
បុគ្គលប្បញ្ញត្តិ *ក្នុងអដ្ឋកថា*.....*១៧២*
កថាវត្ថុ *ក្នុងអដ្ឋកថា*.....*១៧២*
យមកៈ *ក្នុងអដ្ឋកថា*.....*១៧២*
បដ្ឋាន *ក្នុងអដ្ឋកថា*.....*១៧៣*
វិភង្គ *ក្នុងព្រះបាលី* *១៧៣*
ធាតុកថា *ក្នុងព្រះបាលី*.....*១៧៤*
បុគ្គលប្បញ្ញត្តិ *ក្នុងព្រះបាលី*.....*១៧៥*
កថាវត្ថុ *ក្នុងព្រះបាលី* *១៧៧*
យមក *ក្នុងព្រះបាលី* *១៧៨*
បដ្ឋាន *ក្នុងព្រះបាលី* *១៧៩*
សត្តប្បករណាភិធម្ម *បាលី-ប្រែ* *១៨០*

ពុទ្ធមន្តពិធី (វិធីសូត្រព្រះពុទ្ធមន្ត)

សេចក្តីពន្យល់.....២០៧
ចំនួនព្រះបរិត្តក្នុងគម្ពីរផ្សេងៗ.....២០៨
ការកើតឡើងនៃព្រះបរិត្ត.....២០៩
វិធីសូត្រអាជានាជិយបរិត្ត.....២១៦
អង្គរបស់អ្នកសូត្រ និងអ្នកស្តាប់នូវព្រះបរិត្ត.....២២០
ពាក្យនិមន្តព្រះសង្ឃសូត្រនូវព្រះបរិត្ត.....២២២
សេចក្តីគួរយល់ដឹងអំពីការសូត្រនូវព្រះពុទ្ធមន្ត.....២២៣

ព្រះបរិត្ត

អញ្ជើញពួកទេវតា.....២២៥
នមស្ការ.....២២៦
សរណាគមន៍.....២២៧
សម្ពុទ្ធេ.....២២៨
រតនបរិត្តារម្ភោ (បណិធានតោ...).....២៣០
រតនបរិត្ត (យានីធ ភូតា...).....២៣១
មេត្តបរិត្តារម្ភោ (យស្សា...).....២៤០
មេត្តបរិត្ត (ករណីយមត្ថ...).....២៤១
ខន្ធបរិត្តារម្ភោ (សព្ពាសី...).....២៤៥
ខន្ធបរិត្ត (វិរូបក្ខេហិ).....២២៥

មោរបរិត្តារម្ភោ (បុរេន្តម្ភោ...) *២៤៨*
មោរបរិត្ត (ឧទេតយញ្ច) *២៤៨*
ធជគ្គបរិត្តារម្ភោ (យស្សានុស្សរណានាបិ...) *២៥០*
ធជគ្គបរិត្ត *២៥១*
អាដានាដិយបរិត្តារម្ភោ (អប្បសន្នេហិ...) *២៦១*
អាដានាដិយបរិត្ត (វិបស្សិស្ស...).....*២៦២*
អង្គុលិមាលបរិត្តារម្ភោ.....*២៧៦*
អង្គុលិមាលបរិត្ត ឬមហាបរិត្ត.....*២៧៧*
ពោជ្ឈង្គបរិត្ត.....*២៧៩*
ឥសិគិលិបរិត្ត.....*២៨១*

ព្រះសូត្រ

សេចក្តីពន្យល់.....*២៩២*
អញ្ជើញទេវតា (យេ សន្តា...) *២៩៤*
មង្គលសុត្តារម្ភោ (យញ្ច ទ្វាទស...).....*២៩៥*
មង្គលសូត្រ (ឯវម្មេ សុតំ...) *២៩៦*
បរាភវសូត្រ.....*៣០១*
មហាសមយសុត្តារម្ភោ.....*៣០៨*
មហាសមយសូត្រ.....*៣០៩*
ធម្មចក្កប្បវត្តនសុត្តារម្ភោ.....*៣៣០*
ធម្មចក្កប្បវត្តនសូត្រ.....*៣៣១*

អនត្តលក្ខណសុត្តវណ្ណោ.....*៣៤៦*
អនត្តលក្ខណសូត្រ.....*៣៤៧*
អាទិត្តបរិយាយសុត្តវណ្ណោ.....*៣៥៩*
អាទិត្តបរិយាយសូត្រ.....*៣៦០*
គិរិមានន្ទសូត្រ.....*៣៧០*

វិវិធគាថា *(គាថាផ្សេងៗ)*

បកិណ្ណកបរិត្តគាថា

ឆទ្ទន្តបរិត្តគាថា (វិធិស្សមេនន្ទិ...) *៣៨៧*
វដ្តកបរិត្តវណ្ណោ.....*៣៨៨*
វដ្តកបរិត្ត *៣៨៨*
អាដានាដិយបរិត្តគាថា (នមោ មេ...) *៣៩០*
អកយបរិត្តគាថាវណ្ណោ (បុញ្ញលាភំ...) *៤០១*
អកយបរិត្តគាថា (យន្តុន្ទិមិត្តំ...) *៤០១*
ជយបរិត្តគាថាវណ្ណោ (ជយំ ទេវមនុស្សានំ...) *៤០៣*
ជយបរិត្តគាថា (មហាការុណិកោ...) *៤០៤*
អាដានាដិយបរិត្តគាថា (សក្កត្វា...) *៤០៧*
មង្គលចក្កវាឡ (សិរីធិតិ...) *៤០៩*
ពុទ្ធជយមង្គលគាថា ជ័យជម្នះរបស់ព្រះពុទ្ធ (ពាហុំ...) *៤១៤*

គារវសុត្តគាថា (*យេ ច អតីតា...*) ๔๑๙
កាសិតោវាទសង្ខេប ๔๒๐
វិធីបកសរាជ ๔๒๘
ពាក្យសម្រាប់ក្រើនកឋិនទី ๑ ..... ๔๒๙
ពាក្យសម្រាប់ក្រើនកឋិនទី ๒ ..... ๔๓๐
បាលីសម្រាប់សូធ្យប្រគល់សំពត់កឋិន ๔๓๑
ឯពិធីដកត្រៃចីវរ ๔๓๓
ឯពិធីពន្ធុកប្បត្រៃចីវរ ๔๓๓
វិធីក្រាលកឋិន ๔๓๔
ឯកសារស្រាវជ្រាវ ពិគ្រោះ ដកស្រង់ ๔๓๖



តេជោពលេន មហតា រតនត្តយស្ស
លោកុត្តយំ សមធិកច្ចតិ យេន មោក្ខំ
រក្ខា ន ចត្តិ ច សមា រតនត្តយស្ស
តស្មា សធា ភជថ តំ រតនត្តយំ ភោ។

ការគ្រប់គ្រងរក្សា ស្មើដោយគុណព្រះរតនត្រ័យ ដែលអាចធ្វើឱ្យលោកទាំង ៣ ដល់នូវភាពក្សេមក្សាន្ត ដោយតេជានុភាពដ៏ធំក្រៃលែងនៃព្រះរតនត្រ័យ នោះ ពុំមានសោះឡើយ ព្រោះហេតុនោះ ចូរអ្នកទាំងឡាយសេពគប់នូវព្រះ រតនត្រ័យនោះជានិច្ចចុះ ។

(ចាកតេលកដាហគាថា)

ប្រជុំគាណាវារៈ ចារលើ ៤ប្រូ

រតនប្បណាមវិធី

(វិធីនៃការថ្វាយបង្គំព្រះរតនត្រ័យ)

សេចក្តីពន្យល់

បណាម ឬ **ប្រណាម** ប្រែថា ការបង្ខោនកាយ ឬការបង្ខោនកាយ វាចា ចិត្ត គោរព (ថ្វាយបង្គំ)។

ឯការថ្វាយបង្គំនេះមាន ៣ យ៉ាង ដូចមានព្រះបាលី ក្នុងព្រះសុត្តន្តបិដក អង្គុត្តរនិកាយ តិកនិបាត (លេខ ៤១ ទំព័រ ៤៧៥) ថា:

តិសេ្សា ឥមា ភិក្ខវេ វន្ទនា ។ កតមា តិសេ្សា ។ កាយេន វាចាយ មនសា វន្ទនា ។ ឥមា ខោ ភិក្ខវេ តិសេ្សា វន្ទនាតិ ។ *ម្នាលភិក្ខុទាំងឡាយ ការថ្វាយបង្គំនេះមាន ៣ យ៉ាង ។ ការថ្វាយបង្គំ ៣ យ៉ាង ដូចម្តេចខ្លះ ។ គឺការថ្វាយបង្គំដោយកាយ ១ ដោយវាចា ១ ដោយចិត្ត ១។ ម្នាលភិក្ខុទាំងឡាយ ការថ្វាយបង្គំមាន ៣ យ៉ាងនេះឯង។*

ក្នុងគម្ពីរបរមត្ថទីបនី ដីកាអភិធម្មត្ថសង្គហៈ ទំព័រ ១៥០ លោកពន្យល់ថា:

តត្ថ សេដ្ឋចិត្តំ បច្ចុបដ្ឋាបេត្វា ជាណុទ្វយកប្បរទ្វយនលាដសន្ថានានិ បញ្ច អង្គានិ ភូមិយំ បតិដ្ឋាបេត្វា វន្ទនេយ្យានំ គិមុខំ និប្បជ្ជន្តោ កាយេន វន្ទតីនាម ។

បណ្តាការថ្វាយបង្គំទាំង ៣ នោះ បុគ្គលអ្នកញ៉ាំងចិត្តជ្រះថ្លាតាំងចំពោះមុខ ហើយញ៉ាំងអវយវៈទាំង ៥ គឺជង្គង់ ២, ដៃ ២, កា្បាល ១, ឱ្យតាំងនៅលើផ្ទៃរាប លុតជង្គង់ទាំង ២ ដាក់ដៃទាំង ២ លើផ្ទៃរាប ឱនកា្បាលចុះលើផ្ទៃរាប រួមជា ៥ ហៅថា ថ្វាយបង្គំដោយបញ្ចង្គ ឬដោយបញ្ចង្គប្រតិស្ឋ ហើយក្រាបចុះចំពោះមុខបុគ្គលដែលគួរដល់ការថ្វាយបង្គំ ឈ្មោះថា ***ថ្វាយបង្គំដោយកាយ***។

គុណបទានិ វាចាយ បឋវ្តេន្តោ វាចាយ វន្ទតិ នាម ។ “នមោ ពុទ្ធស្ស, នមត្ថុ ពុទ្ធស្ស, នមោ វិមុត្តានំ, នមោ វិមុត្តិយា, វិបស្សិស្ស នមត្ថុ”តិ ឯវមាទីសុបិ វាចា វន្ទនាយេវ ។

អ្នកពោលស្វាធ្យាយនូវពាក្យដែលសម្តែងសរសើរអំពីគុណសម្បត្តិ ដោយវាចា ឈ្មោះថា ***ថ្វាយបង្គំដោយវាចា***។ *ដូចជាថ្វាយបង្គំដោយពោលថា “* **នមោ ពុទ្ធស្ស** *ខ្ញុំសូមថ្វាយបង្គំចំពោះព្រះពុទ្ធជាម្ចាស់,* **នមត្ថុ ពុទ្ធស្ស** *កិរិយាថ្វាយបង្គំនៃខ្ញុំចូរមានចំពោះព្រះពុទ្ធ,* **នមោ វិមុត្តានំ** *សូមថ្វាយបង្គំចំពោះ (ព្រះពុទ្ធទាំងឡាយ) ដែលទ្រង់រួចផុតហើយ,* **នមោ វិមុត្តិយា** *សូមថ្វាយបង្គំចំពោះវិមុត្តិធម៌ (នៃព្រះពុទ្ធទាំងឡាយនោះ),* **វិបស្សិស្ស នមត្ថុ** *សូមថ្វាយបង្គំចំពោះព្រះសម្ពុទ្ធទ្រង់ព្រះនាមវិបស្សី” ជួច្នេះជាដើម ឈ្មោះថា* ***ថ្វាយបង្គំដោយវាចា***។

គុណបទានិ អនុគន្ធាគុណោ អនុស្សរន្តោ មនសា វន្ទតិ នាម ។ *ចំណែកអ្នករឭកដល់គុណសម្បត្តិជារឿយ ៗ ដោយធ្វើតាមពាក្យសម្តែងគុណសម្បត្តិនោះ ឈ្មោះថា* ***ថ្វាយបង្គំដោយចិត្ត***។

ក្នុងគម្ពីរបុល្លគណ្ឋិមហាវគ្គថា: **តេសុ កាយបណាមោ នាម បញ្ចប្បតិដ្ឋិតេ ឥន្ទ្រិយេ ។** *បណ្តាបណាមទាំង ៣ នោះ កិរិយាថ្វាយបង្គំដោយអវយវៈមានអង្គ ៥ គឺ ក្បាល ១, ដៃ ២, ជង្គង់ ២ ឈ្មោះថា* ***កាយបណាម,*** *ប្លែកអំពីកិរិយាថ្វាយបង្គំរបស់តិរ្ថិយទាំងឡាយ ។*

ឯពួកតិរ្ថិយទាំងឡាយ តែងថ្វាយបង្គំប្រកបដោយអង្គ ៣ គឺក្បាល ១, ដៃ ២, ក្រាបចុក៏ប្រកបដោយអង្គ ៣ ងើបឡើងក៏ប្រកបដោយអង្គ ៣ ឬថ្វាយបង្គំដោយក្រាបទ្រាលសន្ធឹងកាយទាំងស្រុង ឈ្មោះថា ***សព្វកាយវន្ទនា ។***

សព្វកាយវន្ទនា ពុទ្ធសាសនេ ន ហោតិ *កិរិយាថ្វាយបង្គំដោយកាយទាំងអស់យ៉ាងនេះ ក្នុងពុទ្ធសាសនាមិនមានឡើយ ។*

ក្នុងគម្ពីរសារត្ថទីបនី ដីកាព្រះវិនយ ភាគ ១ ទំព័រ ៣ លោកសម្តែងថា:

មង្គលភាវតោ សព្វកិរិយាសុ បុព្វកិច្ចភាវតោ បណ្ឌិតេហិ សមាចរិតភាវតោ អាយតឹ បរេសំ ទិដ្ឋានុគតិអាបជ្ជនតោ ច រតនវន្ទនបណាមកិរិយា ។

កិរិយានមស្ការថ្វាយបង្គំព្រះរតនត្រ័យ ជាមង្គលផង ជាខាងដើមនៃការងារគ្រប់យ៉ាងផង ជាទំនៀមដែលបណ្ឌិតទាំងឡាយធ្លាប់ប្រព្រឹត្តមកដោយល្អផង និងជាគំរូដល់ពួកជនជំនែក្នុងកាលជាខាងក្រោយផង ។

អានិសង្សនៃការនមស្ការថ្វាយបង្គំព្រះរតនត្រ័យ

ការនមស្ការថ្វាយបង្គំរំឭកដល់គុណព្រះរតនត្រ័យ គឺជាកិច្ចដ៏សំខាន់មួយរបស់ពុទ្ធសាសនិកជន ព្រោះជាការសម្តែងនូវសេចក្តីគោរពក្នុងសរណាគមន៍របស់

ខ្លួន, ដូច្នេះពុទ្ធសាសនិកជនមិនគួរសូធ្យ ឬស្វាធ្យាយនមស្ការចំពោះតែក្នុងពេលមានកម្មវិធីបុណ្យប៉ុណ្ណោះទេ តែគួរនមស្ការរំឭកឱ្យបានគ្រប់ពេលវេលា ឬឱ្យជាប្រចាំតាមដែលអាចធ្វើទៅបាន ព្រោះថា បុគ្គលណាដែលបានធ្វើការគោរពបូជាដល់បុគ្គលដែលគួរបូជា រមែងប្រសព្វនូវបុណ្យជ្រើន។ ដូចមានគាថា ដែលបូរាណាចារ្យពោលទុកថា:

បុញ្ញាភុដ្ឋិ ចាបហានិ រតនត្តយវន្ទនា
សាបិ ទេតិ ឥដ្ឋផលំ ច ទេតិ អនិដ្ឋកំ ។

កិរិយានមស្ការថ្វាយបង្គំព្រះរតនត្រ័យ ជាគុណជាតិចម្រើនឡើងនៃបុណ្យ ជាគុណជាតិសូន្យទៅនៃបាប តែងតែឱ្យផលជាទីប្រាថ្នា គឺមិនមែនឱ្យផលដែលមិនជាទីប្រាថ្នាឡើយ។

នៅក្នុងគម្ពីរអបទាន និងធម្មបទជាដើម មានសម្តែងអំពីអានិសង្សនៃបុគ្គលអ្នកគោរពបូជា នមស្ការថ្វាយបង្គំចំពោះព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃថា ក្រោយអំពីស្លាប់ទៅក៏បានទៅកើតជាទេវតា សោយនូវសម្បត្តិជាទិព្វក្នុងទេវលោក លុះអស់ជីវិតអំពីទេវលោក មកកើតជាមនុស្សក្នុងត្រកូលក្សត្រ ឬសេដ្ឋីមហាសាលជាដើម ។

សម្រាប់បុគ្គលអ្នកប្រាថ្នានូវបុណ្យទាំងឡាយ ដោយគ្រាន់តែលើកដៃទាំងពីរប្រណម្យ បង្អោនកាយ វាចា ចិត្ត ឆ្ពោះទៅរកគុណព្រះរតនត្រ័យ ដោយសេចក្តីជ្រះថ្លារបស់ខ្លួនប៉ុណ្ណោះ ក៏រមែងបានសម្រេចនូវបុណ្យជ្រើន ដូចជារឿងមជ្ជ-កុណ្ឌលីជាដើម ។ នៅក្នុងព្រះធម្មបទ ត្រង់សហស្សវគ្គ ព្រះដ៏មានព្រះភាគទ្រង់

សម្តែងនូវព្រះគាថាប្រារព្ធនឹងព្រាហ្មណ៍ជាសំឡាញ់របស់ព្រះសារីបុត្រ អំពីអានិសង្សនៃការថ្វាយបង្គំដូច្នេះថា:

យទ្ធិញ្ជិ យិដ្ឋំ ឥ ហុតំ ឥ លោកេ សំវច្ឆរំ យជេថ បុញ្ញាបេក្ខោ
សព្ពំបិ តំ ន ចតុភាគមេតិ អភិវាទនា ឧជុគតេសុ សេយ្យោ ។

បុគ្គលអ្នកប្រាថ្នាបុណ្យ គប្បីបូជាគ្រឿងសក្ការបូជាធំតូចណាមួយក្នុងលោកអស់មួយឆ្នាំ ការបូជាទាំងអស់នោះឯង រមែងមិនដល់នូវចំណែកទី ៤ នៃការអភិវាទន៍ចំពោះលោកទាំងឡាយដែលប្រព្រឹត្តត្រង់ហើយ ការអភិវាទន៍នេះប្រសើរជាង។

ម្យ៉ាងទៀត មិនមែនឱ្យសម្រេចបុណ្យកុសលតែក្នុងអនាគតកាលប៉ុណ្ណោះទេ ថែមទាំងអាចជួយការពារនូវអន្តរាយច្រើនយ៉ាងមិនឱ្យកើតមានដោយអំណាចនៃឧបត្ថម្ភកកម្មចូលទៅជួយឧបត្ថម្ភដល់ជនកកម្ម ។

ក្នុងកាលជាខាងក្រោយនៃពុទ្ធសម័យព្រះគន្ថរចនាចារ្យទាំងឡាយ មានព្រះពុទ្ធឃោសាចារ្យជាដើម មុននឹងរចនាគម្ពីរណាមួយតែងតែនមស្ការព្រះរតនត្រ័យជាដំបូងទើបផ្តើមរចនាគម្ពីរជាខាងក្រោយ ។ ប្រយោជន៍ដើម្បីបានបុណ្យផង និងដើម្បីការពារនូវអន្តរាយមានអន្តរាយនៃជីវិតជាដើមផង ព្រោះការនមស្ការជាកុសលកម្មប្រភេទឧបបីឡកកម្ម គឺកម្មដែលចូលទៅបៀតបៀននូវអកុសលកម្មដែលអាចនឹងកើតឡើងក្នុងវារៈនោះ ។ ដូចមានក្នុងគម្ពីរបរមត្ថទីបនីដីកា ព្រះញាណធជមហាថេរៈ ពណ៌នាទុកថាចេតនាក្នុងការនមស្ការថ្វាយបង្គំព្រះរតនត្រ័យជាឧបត្ថម្ភកកម្មចូលទៅជួយទំនុកបម្រុងដល់ជនកកម្ម ដែលជាកុសលបង្កឱ្យកើតខន្ធជាវិបាក និងកដត្តារូប(កម្មជរូប)ក្នុងបដិសន្ធិកាល និងបវត្តិកាល។ ការឧបត្ថម្ភ

ជាល់ខន្ធដែលកើតអំពីកម្ម គឺការធ្វើឱ្យពួកខន្ធមានការប្រព្រឹត្តទៅបានយូរជាងមុន ព្រោះកម្មាត់នូវអន្តរាយនៃជីវិតរបស់ក្រសែខន្ធដែលកើតអំពីអកុសលកម្ម ដោយការនាំគ្រឿងឧបត្ថម្ភជីវិតចូលទៅដោយល្អ ។

សួរថា: ការថ្វាយបង្គំព្រះរតនត្រ័យ អាចកម្ចាត់ឧបសគ្គបានយ៉ាងណា ?

ឆ្លើយថា: ការថ្វាយបង្គំព្រះរតនត្រ័យ ជាក្រសែបុណ្យដ៏ធំ ដែលញុំាងកិរិយានមស្ការថ្វាយបង្គំឱ្យសម្រេចប្រព្រឹត្តទៅគ្រប់ ៗ ជវនចិត្ត ៧ ខណៈ រហូតច្រើនសែនកោដិខណៈ។

ក្រសែបុណ្យនោះ ជាបុណ្យធំទូលាយ មានអានុភាពច្រើនមានផលច្រើន ព្រោះចម្រើនក្នុងស្រែបុណ្យដ៏ប្រសើរ មានព្រះពុទ្ធជាដើម និងបានអប់រំទុកដោយគុណ គឺឆន្ទៈសទ្ធា និងបញ្ញាដ៏ធំមហាសាល។ បុណ្យដ៏ធំធេងនោះ តាំងនៅក្នុងការដល់ព្រមដោយសេចក្តីព្យាយាម កម្ចាត់ហេតុវិបត្តិខាងក្រៅជាហេតុឱ្យបានទទួលសម្បត្តិធ្វើសេចក្តីចម្រើនដល់ធាតុទាំង ៤ ដែលស្ថិតនៅក្នុងរាងកាយ ដែលកើតអំពីឧតុ ចិត្តនិងអាហារជំប្រណីតឧបត្ថម្ភដល់ជនកកម្មដែលបានទទួលឱកាសតាំងអំពីបដិសន្ធិកាល ទាំងបើកឱកាសដល់កុសលជំទៃដែលនៅមិនទាន់មានឱកាសឱ្យផល ។

លំដាប់នោះ ក្រសែរូបធម៌ នាមធម៌ដែលកើតអំពីបុណ្យទាំង ២ ដែលបានទទួលកម្លាំងឧបត្ថម្ភ និងបានឱកាសហុចផលឱ្យមានកម្លាំងខ្លាំងបន្តដំណើរជីវិតឱ្យប្រព្រឹត្តទៅដូចស្ទឹងធំ ២ ខ្សែក្នុងក្រសែចិត្តធ្វើឱ្យឧបសគ្គ គឺរោគជាដើមដែលជាផលមិនល្អ មិនមានឱកាសកើតក្នុងក្រសែចិត្តដែលពេញព្រៀបដោយផលល្អ

ដូច្នោះ អកុសលកម្មដែលនឹងទម្លាយផលល្អ និងបង្កឱ្យកើតផលមិនល្អ ទើបត្រូវកម្ចាត់ទៅព្រោះកុសលកម្ម និងអកុសលកម្មរមែងមិនហុចផលឱ្យ កាលបើមិនមានឱកាសនឹងឱ្យផលទេនោះ ។ ដោយហេតុនោះ ធម៌ដែលជាផលល្អមានអាយុ និងវណ្ណៈជាដើម ទើបតាំងនៅក្នុងផ្នែកចម្រើនក្នុងក្រសែចិត្តថែមទាំងតែងគម្ពីរសម្រេច ឬសូម្បីទីបំផុតនៃអាយុកប្ប ដូចព្រះពុទ្ធវចនៈថា:

អភិវាទនសីលិស្ស និច្ចំ វុឌ្ឍាបចាយិនោ
ចត្តារោ ធម្មា វឌ្ឍន្តិ អាយុ វណ្ណោ សុខំ ពលំ ។

ធម៌ ៤ ប្រការគឺ អាយុ ១ វណ្ណៈ ១ សុខៈ ១ ពលៈ ១ រមែងចម្រើនដល់អ្នកដែលមានសេចក្តីឱនកាយថ្វាយបង្គំជាប្រក្រតី មានសេចក្តីគោតក្រែងដល់បុគ្គលដែលចម្រើនជាងខ្លួនអស់កាលជានិច្ច ។

ចំណែកនៅក្នុងអដ្ឋកថាធម្មបទ បកិណ្ណកវគ្គ មាននិទានរឿងកុមារសម្មាទិដ្ឋិម្នាក់ជាអ្នកជ្រះថ្លាចំពោះព្រះពុទ្ធគុណា កូននោះតែងបញ្ចេញវាចាថ្វាយបង្គំព្រះពុទ្ធជារឿយ ៗ ថា **នមោ ពុទ្ធស្ស ។** ខ្ញុំសូមថ្វាយបង្គំព្រះពុទ្ធ ។ ។ សូម្បីពេលវាលេងបោះអង្គញ់ជាមួយពួកក្មេងជំទែ មុននឹងបោះអង្គញ់ទៅ វាតែងតែពោលថា **នមោ ពុទ្ធស្ស ។** ហើយគាត់លេងឈ្នះគេរាល់លើក ។ ថ្ងៃមួយវាបានជិះរទេះទៅកាប់ឧសក្នុងព្រៃជាមួយនឹងឪពុក លុះវេលាល្ងាចពេលជិតនឹងត្រឡប់មកផ្ទះវិញ គោទាំង ២ ក៏រត់ទៅផ្ទះមុន ឪពុកក៏ទៅតាមចាប់គោមកទឹមរទេះតែកាលចាប់គោបានហើយ មិនអាចនឹងចេញមកបានព្រោះត្រូវគេបិទទ្វារព្រះនគរក៏នៅខាងក្នុងកំពែងនោះទៅ ។ ឯកូននៅចាំរទេះតែម្នាក់ឯង ចេះតែទន្ទេញថា **នមោ ពុទ្ធស្ស ។** មិនដាច់ពីមាត់កំពុងតែទន្ទេញនោះឯងក៏ដេកលក់ទៅ ។ ក្នុងព្រៃនោះមានយក្សពីរ

នាក់ ១ ជាសម្មាទិដ្ឋិ ១ ជាមិច្ឆាទិដ្ឋិ យក្សទាំងពីរនាក់នោះនាំគ្នាចេញទៅរកចំណីអាហារក្នុងវេលាយប់ ក៏បានឃើញកុមារនោះដេកក្រោមរនេះម្នាក់ឯង យក្សមិច្ឆាទិដ្ឋិប្រថាប់ស៊ី តែត្រូវយក្សសម្មាទិដ្ឋិឃាត់ តែយក្សនោះមិនស្តាប់ហើយក៏ចូលទៅចាប់ទាញជើងកុមារ កុមារក៏ស្រែកឡើងថា **នមោ ពុទ្ធស្ស ។។** យក្សនោះក៏ភ័យញ័រខ្លាត់ ទន់ជើងទន់ដៃស្ទើរស្តាប់រកចាប់ស៊ីក៏ពុំកើត ។ យក្សទាំងពីរក៏នៅចាំរក្សាការពារកុមារនោះអស់មួយយប់ យក្សជាសម្មាទិដ្ឋិបានបង្គាប់យក្សមិច្ឆាទិដ្ឋិឱ្យទៅយកក្រយាស្វាព្រះរាជាក្រុងរាជគ្រឹះមកឱ្យកុមារបរិភោគ លុះព្រឹកឡើងពួករាជបុរសតាមរកភាជន៍ក្រយាស្វាយ ក៏ឃើញក្នុងរនេះ បាននាំភាជន៍និងកុមារទៅថ្វាយព្រះរាជា ។ កុមារបានទូលរឿងនោះសព្វគ្រប់ ព្រះរាជាក៏ទ្រង់នឹកស្ងើចហើយបាននាំកុមារទៅថ្វាយបង្គំព្រះសម្មាសម្ពុទ្ធ...។ លំដាប់នោះព្រះរាជាក៏ទ្រង់ទូលសួរថា “បពិត្រព្រះអង្គដ៏ចម្រើន មានតែពុទ្ធានុស្សតិប៉ុណ្ណោះឬ ទើបជាគ្រឿងរក្សាការពារ ឬថាអនុស្សតិដទៃក៏ជាគ្រឿងរក្សាការពារបានដែ ?” ។ ព្រះសាស្តាត្រាស់តបនឹងព្រះរាជាថា “បពិត្រមហារាជ មិនមែនមានតែពុទ្ធានុស្សតិតែម្យ៉ាងប៉ុណ្ណោះទេដែលជាគ្រឿងរក្សាការពារនោះ, ក៏ពួកជនណា បានអប់រំចិត្តល្អហើយក្នុងឋាន: ៦ យ៉ាង កិច្ចដោយការរក្សា និងការការពារយ៉ាងដទៃ ឬដោយមន្ត និងឱសថ រមែងមិនមានដល់ជនទាំងនោះឡើយ” ហើយក៏ត្រាស់នូវគាថាដែលនឹងដកយកតែ ៣ ព្រះគាថា ដូចមានខាងក្រោមនេះ ៖

សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច និច្ចំ ពុទ្ធគតា សតិ ។

សតិរបស់ជនពួកណា ដែលឋិតនៅក្នុងព្រះពុទ្ធគុណ អស់កាលជានិច្ច ទាំងថ្ងៃ ទាំងយប់ ជនពួកនោះឈ្មោះថា សាវ័កបស់ព្រះគោតម រមែងក្រាក់រឭក ដោយប្រពៃសព្វកាល ។

សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច និច្ចំ ពុទ្ធគតា សតិ ។

សតិរបស់ជនពួកណា ដែលឋិតនៅក្នុងព្រះធម្មគុណ អស់កាលជានិច្ច ទាំងថ្ងៃ ទាំងយប់ ជនពួកនោះឈ្មោះថា សាវ័កបស់ព្រះគោតម រមែងក្រាក់រឭក ។ ដោយប្រពៃសព្វកាល ។

សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច និច្ចំ ធម្មគតា សតិ ។

សតិរបស់ជនពួកណា ដែលឋិតនៅក្នុងព្រះសង្ឃគុណ អស់កាលជានិច្ច ទាំងថ្ងៃ ទាំងយប់ ជនពួកនោះឈ្មោះថា សាវ័កបស់ព្រះគោតម រមែងក្រាក់រឭក។ ដោយប្រពៃសព្វកាល ។

សុប្បពុទ្ធំ បពុជ្ឈន្តិ សទា គោតមសាវកា
យេសំ ទិវា ច រត្តោ ច និច្ចំ សង្ឃគតា សតិ ។

សតិរបស់ជនពួកណា ដែលឋិតនៅក្នុងព្រះសង្ឃគុណ អស់កាលជានិច្ច ទាំងថ្ងៃ ទាំងយប់ ជនពួកនោះឈ្មោះថា សាវ័កបស់ព្រះគោតម រមែងក្រាក់រឭក។ ដោយប្រពៃសព្វកាល ។

*អដ្ឋកថាពន្យល់ទុក (នឹងស្រង់យកតែសេចក្តីមក) ថា ពួកជនណាដែលមានសតិរឭកដល់ព្រះពុទ្ធគុណ មានពាក្យថា “**ឥតិបិ សោ ភគវា**...” រឭកដល់ព្រះធម្មគុណថា “**ស្វាក្ខាតោ ភគវតា ធម្មោ**...” និងរឭកដល់ព្រះសង្ឃគុណថា “**សុបដិបន្នោ ភគវតោ សាវកសង្ឃោ**...” ដូច្នេះ អស់កាលជានិច្ចហើយលង់លក់ទៅកាលក្រាក់ឡើងហើយជនទាំងនោះឈ្មោះថា ក្រាក់ហើយដោយល្អគ្រប់កាលទាំងពួង។ តែកាលបើមិនអាចដើម្បីនឹងរឭកបានជានិច្ចទេ ដោយគ្រាន់តែរឭកក្នុងមួយថ្ងៃ ៣ ដង ២ ដង ឬសូម្បីត្រឹមតែម្តងក៏ឈ្មោះថាក្រាក់ហើយដោយល្អដែរ។*

ក្នុងធជគ្គសូត្រ បិដកលេខ ៣០ ទំព័រ ២៤៣ ព្រះមានព្រះភាគទ្រង់ដាស់តឿនដល់ភិក្ខុទាំងឡាយថា បើពួកអ្នកនៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី ឬក៏នៅក្នុងផ្ទះស្ងាត់ក្តី កាលបើសេចក្តីខ្លាចក្តី សេចក្តីរន្ធត់ក្តី សេចក្តីព្រឺរោមក្តី កើតឡើងដល់អ្នកទាំងឡាយៗ គប្បីរឭកឡើយៗនូវព្រះពុទ្ធថា **ឥតិបិ សោ ភគវា**..., *បើមិនរឭកនូវព្រះពុទ្ធទេ គប្បីរឭកនូវព្រះធម៌ថា* **স্বাক্খাតো ភគវតា ធម្មោ**..., *បើមិនរឭកនូវព្រះធម៌ទេ គប្បីរឭកនូវព្រះសង្ឃថា* **សុបដិបន្នោ ភគវតោ សាវក-សង្ឃោ**...,។ *ហើយនៅខាងចុងនៃព្រះសូត្រ ព្រះអង្គទ្រង់ត្រាស់នូវព្រះគាថានេះថា*

ឯវំ ពុទ្ធំ សរន្តានំ ធម្មំ សង្ឃញ្ច កិត្តយោ
ភយំ វា ឆម្ភិតត្តំ វា លោមហំសោ ន ហេស្សតិ ។

ម្នាលភិក្ខុទាំងឡាយ កាលបើអ្នករាល់គ្នារឭកនូវព្រះពុទ្ធ ព្រះធម៌ព្រះសង្ឃយ៉ាងនេះ ភ័យក្តី សេចក្តីរន្ធត់ក្តី សេចក្តីព្រឺរោមក្តី នឹងមិនកើតមានឡើយ ។

រតនប្បណាមវិធី *គឺវិធីនមស្ការថ្វាយបង្គំនូវព្រះរតនត្រ័យនេះ ចែកជា ២ បែប គឺបែបពិស្តារ ១ យ៉ាង បែបសង្ខេប ១ យ៉ាង។ អ្នកដែលមានសេចក្តីជ្រះថ្លាប្រាថ្នានឹងនមស្ការព្រះរតនត្រ័យនោះ ទោះនៅក្នុងទីកន្លែងរបស់ខ្លួន ឬនៅកន្លែងកម្មវិធីបុណ្យណាក៏ដោយបើមានពេលឱកាសល្មមនឹងសូធ្យនមស្ការទាំង ៣ បទឱ្យបានចប់សព្វគ្រប់ ដោយសេចក្តីពិស្តារដូចបែបទី ១ ក៏ជាការប្រពៃពេកណាស់តែបើពេលខ្វីមិនអាចសូធ្យឱ្យចប់សព្វគ្រប់បានទេ ក៏គ្រាន់តែសូធ្យដោយសង្ខេបខ្វីៗ តាមបែបទី ២ ក៏បានដែរ ។*



ត្រៃបណាមពិស្តារ

រតនត្តយបូជា

(ថ្វាយគ្រឿងសក្ការៈដល់ព្រះរតនត្រ័យ)

ឥមេហិ ទីបធូបាទិសក្ការេហិ ពុទ្ធំ ធម្មំ សង្ឃំ អភិបូជយាមិ មាតាបិតានីនំ គុណវន្តានញ្ច មយ្ហញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។

ប្រែថា: ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាម្ចាស់ ដោយគ្រឿងសក្ការៈទាំងឡាយ មានទៀន និងធូបជាដើមនេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់អ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់ខ្ញុំព្រះករុណាផង អស់កាលជាអង្វែងទៅហោង។

ពុទ្ធរតនប្បណាម

(ថ្វាយបង្គំព្រះពុទ្ធរតនៈ)

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ប្រែថា: វីតិវិយានមស្ការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃ ចំពោះព្រះអង្គឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។

(ក្រាបថ្វាយបង្គំម្តង)

(សូធ្យបាលី ៣ ចប់ សម្រាយតែ ១ ចប់ក៏បាន)

យោ សន្ធិសិង្ឃោ ភវពោធិមូលេ
មារំ សសេនំ មហតឹ វិជេយ្យោ
សម្ពោធិមាគច្ឆិ អនន្តញ្ញាណោ
លោកុត្តមោ តំ បនមាមិ ពុទ្ធំ ៗ

ប្រែថា: ព្រះសម្មាសម្ពុទ្ធអង្គឯណា ទ្រង់គង់ចម្រើនវូវព្រះអានាបានសតិកម្មដ្ឋាន លើរតនបល្ល័ង្ក ក្រោមម្លប់ពោធិព្រឹក្សដ៏ប្រសើរ បានផ្ចាញ់នូវមារាធិរាជ ព្រមទាំងសេនាដ៏ច្រើន ហើយទ្រង់ត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ មានប្រាជ្ញារកទីបំផុតគ្មាន ព្រះអង្គប្រសើរជាងសត្វលោក ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំ នូវព្រះសម្មាសម្ពុទ្ធអង្គនោះដោយគោរព ។

(ក្រាបថ្វាយបង្គំម្តង)

ថ្វាយបង្គំព្រះពុទ្ធគ្រប់កាលទាំង ៣

យេ ច ពុទ្ធា អតីតា ច យេ ច ពុទ្ធា អនាគតា
បច្ចុប្បន្នា ច យេ ពុទ្ធា អហំ វន្ទាមិ សព្វទា ៗ

ប្រែថា: ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធនិព្វានកន្លងទៅហើយក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលនឹងបានត្រាស់ជាព្រះពុទ្ធក្នុងកាលខាងមុខក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់ជាព្រះពុទ្ធក្នុងភទ្រកប្បនេះក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធទាំងឡាយនោះគ្រប់កាលទាំងពួង ។

(ក្រាបថ្វាយបង្គំម្តង)

ពុទ្ធគុណ៣ប ១០ ព្រះនាម

(បិដកលេខ ១៦ ទំព័រ ២០១)

ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។

ប្រែថា: **ឥតិបិ សោ ភគវា អរហំ** *ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា* ***អរហំ*** *ព្រោះព្រះអង្គផ្លាយចាកសឹកសត្រូវ ពោលគឺកិលេស ព្រមទាំងវាសនា គឺកាយបយោគ និងវចីបយោគ,* **សម្មាសម្ពុទ្ធោ** *ទ្រង់ព្រះនាមថា* ***សម្មាសម្ពុទ្ធោ*** *ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ,* **វិជ្ជាចរណសម្បន្នោ** *ទ្រង់ព្រះនាមថា* ***វិជ្ជាចរណសម្បន្នោ*** *ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជា ៣ និងវិជ្ជា ៨ និងចរណៈ ១៥,* **សុគតោ** *ទ្រង់ព្រះនាមថា* ***សុគតោ*** *ព្រោះព្រះអង្គមានដំណើរល្អយាងទៅកាន់សុន្ទរស្ថាន គឺអមតៈមហានិព្វាន,* **លោកវិទូ** *ទ្រង់ព្រះនាមថា* ***លោកវិទូ*** *ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក,* **អនុត្តរោ** *ទ្រង់ព្រះនាមថា* ***អនុត្តរោ*** *ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន,* **បុរិសទម្មសារថិ** *ទ្រង់ព្រះនាមថា* ***បុរិសទម្មសារថិ*** *ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរសដែលមានឧបនិស្ស័យគួរនឹងទូន្មានបាន,* **សត្ថា ទេវមនុស្សានំ** *ទ្រង់ព្រះនាមថា* ***សត្ថា ទេវមនុស្សានំ*** *ព្រោះព្រះអង្គជាសាស្ដាចារ្យនៃទេវតា និងមនុស្សទាំងឡាយ,* **ពុទ្ធោ** *ទ្រង់ព្រះនាមថា* ***ពុទ្ធោ*** *ព្រោះព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ចហើយញុំាងអ្នក-

ជនៃឱ្យត្រាស់ដឹងផង, **ភគវា** *ទ្រង់ព្រះនាមថា* **ភគវា** *ព្រោះព្រះអង្គមានជំណើរទៅកាន់ត្រែកពខ្ជាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ ។*

(ក្រាបថ្វាយបង្គំម្តង)

រំឭកដល់ពុទ្ធគុណរួចហើយ
គប្បីប្រកាសប្តេជ្ញាខ្លួនដោយពាក្យសច្ចៈថា:

ន‍ត្ថិ មេ សរណំ អ‍ញ្ញំ ពុទ្ធោមេ សរណំ ឥវរំ
ឯតេន សច្ចវជ្ជេន ហោតុ មេ ជ‍យមង្គ‍ល ។

ប្រែថា: **ន‍ត្ថិ មេ សរណំ អ‍ញ្ញំ** *វត្ថុជនៃជាទីពឹងទីរឭកនៃខ្ញុំព្រះករុណាមិនមានឡើយ,* **ពុទ្ធោ មេ សរណំ ឥវរំ** *មានតែព្រះពុទ្ធជាម្ចាស់ជាទីពឹងទីរឭកដ៏ប្រសើរបស់ខ្ញុំព្រះករុណា,* **ឯតេន សច្ចវជ្ជេន ហោតុ មេ ជ‍យមង្គ‍លំ** *សូមសិរីសួស្តីជ‍យមង្គ‍ល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។*

(ក្រាបថ្វាយបង្គំម្តង)

ប្តេជ្ញាដូច្នេះហើយ
គប្បីសូមខមាទោសនឹងព្រះពុទ្ធថា:

ខ‍ន្តិមេ‍ត្ថេន ឥ‍ន្ទ្រិយំ ឋានឋបំសុំ ឥរុ‍ត្តមំ
ពុ‍ទ្ធេ យោ ខ‍លិតោ ទោសោ ពុទ្ធោ ខមតុ តំ មមំ ។

ប្រែថា: **ខត្តមន្តេន ខមេាហំ ឆានបំសុំ ខមុត្តមំ** *ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវល្អងធូលីព្រះបាទនៃព្រះសម្មាសម្ពុទ្ធជ៏ប្រសើរខ្ពង់ខ្ពស់ ដោយអវយវៈជ៏ឧត្តម គឺ ត្បូង,* **ពុទ្ធេ យោ ខលិតោ ទោសោ** *ទោសឯណា ដែលខ្ញុំព្រះករុណាធ្វើឱ្យក្រាំង-ក្រាត់ ហើយក្នុងព្រះពុទ្ធជាម្ចាស់,* **ពុទ្ធោ ខមតុ តំ មមំ** *សូមព្រះពុទ្ធជាម្ចាស់អត់នូវទោសនោះដល់ខ្ញុំព្រះករុណា ។*

(ក្រាបថ្វាយបង្គំម្តង)

ធម្មរតនប្បណាម

(ថ្វាយបង្គំព្រះធម្មរតនៈ)

អដ្ឋង្គិការិយបថេា ជនានំ
មេាក្ខប្បវេសា យខ្ញុ ច មគ្គេា
ធម្មេា អយំ សន្តិករេា បណីតេា
និយ្យានិកេា តំ បនមាមិ ធម្មំ ។

ប្រែថា: ព្រះសទ្ធម្មឯណា ជាធម៌ប្រកបដោយអង្គ ៨ ប្រការ ជាគន្លងដំណើរនៃព្រះអរិយបុគ្គលជាម្ចាស់ ជាផ្លូវដ៏ត្រង់ក្នុងកិរិយាញ៉ាំងជនដែលប្រាថ្នានូវព្រះនិព្វាន ឱ្យចូលទៅកាន់ព្រះនិព្វានបាន ព្រះធម៌នេះជាធម៌ធ្វើឱ្យត្រជាក់រំងាប់បង់នូវភ្លើងទុក្ខ ភ្លើងកិលេស ជាធម៌ជ៏ឧត្តម ជាគុណញ៉ាំងសត្វឱ្យចេញចាកសង្សារទុក្ខ ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសទ្ធម្មនោះដោយគោរព ។

(ក្រាបថ្វាយបង្គំម្តង)

ថ្វាយបង្គំព្រះធម៌គ្រប់កាលទាំង ៣

យេ ច ធម្មា អតីតា ច យេ ច ធម្មា អនាគតា
បច្ចុប្បន្នា ច យេ ធម្មា អហំ វន្ទាមិ សព្វទា ។

ប្រែថា: ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធ ដែលនិព្វានកន្លងទៅហើយក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធនឹងមានមកក្នុងកាលខាងមុខក្តី ព្រះធម៌ទាំងឡាយឯណា ដែលជាធម៌របស់ព្រះសម្មាសម្ពុទ្ធទ្រង់ប្រតិស្ឋានទុកក្នុងកាលសព្វថ្ងៃនេះក្តី ខ្ញុំព្រះករុណាសូមក្រាបថ្វាយបង្គំនូវព្រះធម៌ទាំងឡាយនោះគ្រប់កាលទាំងពួង ។

(ក្រាបថ្វាយបង្គំម្តង)

ព្រះធម្មគុណទាំង ៦ បទ

(បិដកលេខ ១៦ ទំព័រ ២០១)

ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្ពោ វិញ្ញូហីតិ ។

ប្រែថា: **ស្វាក្ខាតោ ភគវតា ធម្មោ** *ព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដកជាធម៌គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងហើយដោយល្អ, (***ធម្មោ** *ព្រះនព្វលោកុត្តរធម៌មាន ៩ ប្រការ គឺមគ្គ ៤ ផល ៤ និព្វាន ១)* **សន្ទិដ្ឋិកោ** *ជាធម៌ គឺព្រះអរិយបុគ្គលទាំងពួងដឹងពិត ឃើញពិតដោយបច្ចវេក្ខណាញ្ញាណ គឺថានឹងបានដឹងដោយស្តាប់ដោយជឿបុគ្គលដទៃនោះៗក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង,* **អកាលិកោ** *ជាធម៌*

ឱ្យនូវផលមិនរង់ចាំកាលគឺថាកាលបើព្រះអរិយមគ្គកើតឡើងហើយ ព្រះអរិយផលក៏កើតក្នុងលំដាប់គ្នាមិនបានយឺតយូរឡើយ, **ឯហិបស្សិកោ** *ជាធម៌គួរដល់ឯហិបស្សវិធី គឺថាបើព្រះអរិយបុគ្គលដែលបានសម្រេចមគ្គផលហើយ ក៏គួរនឹងហៅបុគ្គលដទៃឱ្យចូលមកមើលបាន ,* **ឱបនយិកោ** *ជាធម៌ គឺព្រះអរិយបុគ្គលគប្បីបង្អោនចូលមកទុកក្នុងខ្លួនដោយអំណាចនៃការនា,* **បច្ចត្តំ វេទិតព្វោ វិញ្ញូហិ** *ជាធម៌ គឺអ្នកប្រាជ្ញទាំងឡាយមានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីដឹង គប្បីឃើញ ច្បាស់ក្នុងចិត្តនៃខ្លួន ។*

(ក្រាបថ្វាយបង្គំម្តង)

រឭកដល់ធម្មគុណរួចហើយ
គប្បីប្រកាសប្តេជ្ញាខ្លួនដោយពាក្យសច្ចៈថា:

ឧត្ថិ មេ សរណំ អញ្ញំ ធម្មោ មេ សរណំ វរំ
ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ ៗ

ប្រែថា: **ឧត្ថិ មេ សរណំ អញ្ញំ** *វត្ថុដទៃជាទីពឹង ទីរឭកនៃខ្ញុំព្រះករុណាមិនមានឡើយ,* **ធម្មោ មេ សរណំ វរំ** *មានតែព្រះធម៌ជាម្ចាស់ជាទីពឹងទីរឭកដ៏ប្រសើរបស់ខ្ញុំព្រះករុណា* **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** *សូមសិរីសួស្តីជយមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។*

(ក្រាបថ្វាយបង្គំម្តង)

ម្តេចជាដូច្នេះហើយ
គប្បីសូមខមាទោសនឹងព្រះធម៌ថាៈ

ខន្តមន្តេន ភន្តេហំ ធម្មញ្ច ទុវិធំ ភវរំ
ធម្មេ យោ ខលិតោ ទោសោ ធម្មោ ខមតុ តំ មមំ ។

ប្រែថាៈ **ខន្តមន្តេន ភន្តេហំ ធម្មញ្ច ទុវិ ធំភវរំ** *ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះធម៌ដ៏ប្រសើរមានពីរប្រការ គឺព្រះបរិយត្តិធម៌ និងព្រះនព្វលោកុត្តរធម៌ ដោយអវយវៈដ៏ឧត្តមគឺត្បូង,* **ធម្មេ យោ ខលិតោ ទោសោ** *ទោសឯណា ដែលខ្ញុំព្រះករុណា ធ្វើឱ្យក្លាំងក្លាត់ហើយក្នុងព្រះធម៌ជាម្ចាស់,* **ធម្មោ ខមតុ តំ មមំ** *សូមព្រះធម៌ជាម្ចាស់អត់នូវទោសនោះដល់ខ្ញុំព្រះករុណា ។*

(ក្រាបថ្វាយបង្គំម្តង)

សង្ឃរតនប្បណាម

(ថ្វាយបង្គំព្រះសង្ឃរតនៈ)

សឡេ្ឋា ទិសុទ្ធោ ភវទក្ខិណេយ្យោ
សន្តិន្ទ្រិយោ សព្វមលប្បហីនោ
គុណេហិនេកេហិ សមិទ្ធិបត្តោ
អនាសវោ តំ បនមាមិ សង្ឃំ ។

ប្រែថាៈ ព្រះអរិយសង្ឃឯណា ដ៏បរិសុទ្ធវិសេស ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ មានឥន្ទ្រីយ៍រំងាប់ហើយ មានមន្ទិល គឺរាគាទិក្កិលេសទាំងពួងបន្សាត់បង់ហើយ ជាព្រះសង្ឃដល់ហើយនូវកិរិយាសម្រេចដោយគុណទាំងឡាយដ៏ច្រើន ជា

ព្រះសង្ឃមានអាសវធម៌មិនមាន គឺថាជាព្រះខីណាស្រព ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះអរិយសង្ឃនោះ ដោយគោរព ។

(ក្រាបថ្វាយបង្គំម្តង)

ថ្វាយបង្គំព្រះសង្ឃគ្រប់កាលទាំង ៣

យេ ច សង្ឃា អតីតា ច យេច សង្ឃាអនាគតា

បច្ចុប្បន្នា ច យេ សង្ឃា អហំ វន្ទាមិ សព្វទា ។

ប្រែថា: ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គ និងផលកន្លងទៅហើយក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃនឹងបានសម្រេចមគ្គ និងផលក្នុងកាលខាងមុខក្តី ព្រះសង្ឃទាំងឡាយឯណា ដែលជាព្រះសង្ឃបានសម្រេចមគ្គ និងផលក្នុងកាលជាបច្ចុប្បន្ននេះក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសង្ឃទាំងឡាយនោះគ្រប់កាលទាំងពួង ។

(ក្រាបថ្វាយបង្គំម្តង)

សង្ឃគុណទាំង ៩ បទ

(បិដកលេខ ១៦ ទំព័រ ២០១)

សុបដិបន្នោ ភគវតោ សាវកសង្ឃោ

ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ

ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ

សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ

យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា
ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ
ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

ប្រែថា: **សុបដិបន្នោ ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃជាសាវ័កនៃព្រះ-ជ័មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្ធង់ព្រះនព្វ-លោកុត្តរធម៌,* **ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃជាសាវ័កនៃព្រះជ័មានព្រះភាគលោកប្រតិបត្តិដោយត្រង់ គឺប្រតិបត្តិជាមជ្ឈិមប្បដិបទា,* **ញាយ-បដិបន្នោ ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃជាសាវ័កនៃព្រះជ័មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ជាស្ថានក្សេមផុតចាកទុក្ខទាំងពួង,* **សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃជាសាវ័កនៃព្រះជ័មានព្រះ-ភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម គឺប្រតិបត្តិគួរដល់សីល សមាធិ បញ្ញា,* **យទិទំ ចត្តារិ បុរិសយុគានិ** *ព្រះសង្ឃឯណា បើរាប់ជាគូនៃបុរសទាំង-ឡាយមាន ៤ គូ គឺព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គ និងសោតាបត្តិ-ផលជាគូ ១ សកទាគាមិមគ្គ និងសកទាគាមិផលជាគូ ១ អនាគាមិមគ្គ និងអនា-គាមិផលជាគូ ១ អរហត្តមគ្គ និងអរហត្តផលជាគូ ១,* **អដ្ឋបុរិសបុគ្គលា** *បើរាប់រៀងជាបុរសបុគ្គលមាន ៨ គឺព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គ ១ សោតាបត្តិផល ១ សកទាគាមិមគ្គ ១ សកទាគាមិផល ១ អនាគាមិមគ្គ ១ អនាគាមិផល ១ អរហត្តមគ្គ ១ អរហត្តផល ១,* **ឯស ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃទាំងនោះ ជាសង្ឃសាវ័កនៃព្រះជ័មានព្រះភាគ,* **អាហុនេយ្យោ** *លោកគួរ*

ទទួលនូវចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីលហើយ នាំមកអំពីចម្ងាយបង្អោនចូលមកបូជា, **ឋាឋុនេយ្យោ** *លោកគួរទទួលនូវអាគន្តុកទាន គឺទានដែលបុគ្គលតាក់តែងដើម្បីញាតិ និងមិត្រ ដែលមកអំពីទិសផ្សេង ៗ ហើយបង្អោនចូលមកបូជា,* **ទក្ខិណេយ្យោ** *លោកគួរទទួលនូវទានដែលបុគ្គលជឿនូវកម្ម និងផលនៃកម្មហើយបូជា,* **អញ្ជលិករណីយោ** *លោកគួរដល់អញ្ជលិកម្មដែលសត្វលោកគប្បីធ្វើ,* **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** *លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជ គឺបុណ្យនៃសត្វលោករកខេត្តជទៃក្រៃលែងជាងគ្មាន ។*

(ក្រាបថ្វាយបង្គំម្តង)

រឭកដល់សង្ឃគុណរួចហើយ
គប្បីប្រកាសបូជាខ្លួនដោយពាក្យសច្ចៈថា

ឧត្ថិ មេ សរណំ អញ្ញំ សង្ឃោ មេ សរណំ ឥវរំ
ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ ៗ

ប្រែថា: **ឧត្ថិ មេ សរណំ អញ្ញំ** *វត្ថុជទៃជាទីពឹង ទីរឭក នៃខ្ញុំព្រះករុណាមិនមានឡើយ,* **សង្ឃោ មេ សរណំ ឥវរំ** *មានតែព្រះសង្ឃជាម្ចាស់ ជាទីពឹង ទីរឭកដ៏ប្រសើរវរបស់ខ្ញុំព្រះករុណា,* **ឯតេន សច្ចវជ្ជេន ហោតុ មេ ជយមង្គលំ** *សូមសិរីសួស្តីជយមង្គល ចូរមានដល់ខ្ញុំព្រះករុណា ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ ។*

ល្អជ្វាដូច្នេះហើយ
គប្បីសូមខមាទោសនឹងព្រះសង្ឃថា

ខ្ញុំ ភន្តេ ឥទ្ធេ សង្ឃំ ខមាបេមិ
យំ យំ ខលិតំ តស្ស តស្ស សង្ឃោ ខមតុ

ប្រែថា: **ខ្ញុំ ភន្តេ ឥទ្ធេ សង្ឃំ ខមាបេមិ** *ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះសង្ឃដ៏ប្រសើរមានពីរប្រការ គឺសម្មតិសង្ឃ និងអរិយសង្ឃ ដោយអាយាៈដ៏ខ្ពង់, **យំ យំ ខលិតំ តស្ស តស្ស** ទោសឯណា ដែលខ្ញុំព្រះករុណាធ្វើឱ្យភ្ញាំងក្ងាត់ហើយក្នុងព្រះសង្ឃជាម្ចាស់, **សង្ឃោ ខមតុ** សូមព្រះសង្ឃជាម្ចាស់អត់នូវទោសនោះដល់ខ្ញុំព្រះករុណា ។*

(ក្រាបថ្វាយបង្គំម្តង)

ចប់ត្រៃបណាមពិស្តារ



ត្រៃបណាមសទ្ធេប

ព្រមទាំងបូជាគ្រឿងសក្ការៈ

ព្រះពុទ្ធគុណ

ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។

តំ អរហាទិគុណសំយុត្តំ ពុទ្ធំ សិរសា នមាមិ តញ្ច ពុទ្ធំ ឥមេហិ សក្ការេហិ អភិបូជយាមិ ។

ប្រែថា: **ឥតិបិ សោ ភគវា អរហំ** *ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា* ***អរហំ*** *ព្រោះព្រះអង្គផ្លាយចាកសឹកសត្រូវ ពោលគឺកិលេស ព្រមទាំងវាសនា គឺកាយបយោគ និងវចីបយោគ,* **សម្មាសម្ពុទ្ធោ** *ទ្រង់ព្រះនាមថា* ***សម្មាសម្ពុទ្ធោ*** *ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ,* **វិជ្ជាចរណសម្បន្នោ** *ទ្រង់ព្រះនាមថា* ***វិជ្ជាចរណសម្បន្នោ*** *ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជា ៣ និងវិជ្ជា ៨ និងចរណៈ ១៥,* **សុគតោ** *ទ្រង់ព្រះនាមថា* ***សុគតោ*** *ព្រោះព្រះអង្គមានដំណើរល្អយាងទៅកាន់សុន្ទរស្ថាន គឺអមតៈមហានិព្វាន,* **លោកវិទូ** *ទ្រង់ព្រះនាមថា* ***លោកវិទូ*** *ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក,* **អនុត្តរោ** *ទ្រង់ព្រះនាមថា* ***អនុត្តរោ*** *ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន,* **បុរិសទម្មសារថិ** *ទ្រង់ព្រះនាមថា* ***បុរិសទម្មសារថិ*** *ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរសដែលមាន*

ឧបនិស្សយគួរនឹងទទួលានបាន, **សត្ថា ទេវមនុស្សានំ** *ទ្រង់ព្រះនាមថា* ***សត្ថា ទេវ-មនុស្សានំ*** *ព្រោះព្រះអង្គជាសាស្តាចារ្យនៃទេវតា និងមនុស្សទាំងឡាយ,* **ពុទ្ធោ** *ទ្រង់ព្រះនាមថា* **ពុទ្ធោ** *ព្រោះព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ចហើយញុំាងអ្នក-ដទៃឱ្យត្រាស់ដឹងផង,* **ភគវា** *ទ្រង់ព្រះនាមថា* **ភគវា** *ព្រោះព្រះអង្គមានជំណើរទៅកាន់ត្រែកពង្ហក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ ។*

តំ អរហាទិគុណសំយុត្តំ ពុទ្ធំ សិរសា នមាមិ *ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គប្រកបព្រមហើយដោយគុណ មានគុណថា* **អរហំ** *ជាដើមនោះ ដោយសិរសាគឺត្បូង,* **តញ្ចា ពុទ្ធំ ឥមេហិ សក្ការេហិ អភិបូជយាមិ** *ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះសម្មាសម្ពុទ្ធជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយ មានប្រមាណប៉ុណ្ណេះ ។*

(ក្រាបថ្វាយបង្គំម្តង)

ព្រះធម្មគុណ

ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្ពោ វិញ្ញូហីតិ ។

តំ ស្វាក្ខាតាទិគុណសំយុត្តំ ធម្មំ សិរសា នមាមិ តញ្ចា ធម្មំ ឥមេហិ សក្ការេហិ អភិបូជយាមិ ។

ប្រែថា: **ស្វាក្ខាតោ ភគវតា ធម្មោ** *ព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដកជាធម៌គឺព្រះជ័មានព្រះភាគទ្រង់ត្រាស់សម្តែងហើយដោយល្អ, (***ធម្មោ** *ព្រះនព្វលោកុត្តរ

ធម៌មាន ៩ ប្រការ គឺមគ្គ ៤ ផល ៤ និព្វាន ១) **សន្ទិដ្ឋិកោ** ជាធម៌ គឺព្រះអរិយបុគ្គលទាំងពួងដឹងពិត ឃើញពិតដោយបច្ចវេក្ខណាញ្ញាណ គឺថាទ័ងបានដឹងដោយស្តាប់ដោយជឿបុគ្គលដទៃនោះៗក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង, **អកាលិកោ** ជាធម៌ឱ្យនូវផលមិនរង់ចាំកាលគឺថាកាលបើព្រះអរិយមគ្គកើតឡើងហើយ ព្រះអរិយផលក៏កើតក្នុងលំដាប់គ្នាមិនបានយឺតយូរឡើយ, **ឯហិបស្សិកោ** ជាធម៌គួរដល់ឯហិបស្សវិធី គឺថាបើព្រះអរិយបុគ្គលដែលបានសម្រេចមគ្គផលហើយ ក៏គួរទ័ងហៅបុគ្គលដទៃឱ្យចូលមកមើលបាន, **ឱបនយិកោ** ជាធម៌ គឺព្រះអរិយបុគ្គលគប្បីបង្អោនចូលមកទុកក្នុងខ្លួនដោយអំណាចនៃការនា, **បច្ចត្តំ វេទិតព្វោ វិញ្ញូហិ** ជាធម៌ គឺអ្នកប្រាជ្ញទាំងឡាយមានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីដឹង គប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន ។

តំ ស្វាក្ខាតាទិគុណសំយុត្តំ ធម្មំ សិរសា នមាមិ ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះធម៌ជាម្ចាស់ ដ៏ប្រកបព្រមហើយដោយគុណ មានគុណថា **ស្វាក្ខាតោ** ជាដើមនោះ ដោយសិរសាគឺក្បាល, **តញ្ច ធម្មំ ឥមេហិ សក្ការេហិ អភិបូជយាមិ** ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះធម្មជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយ មានប្រមាណប៉ុណ្ណោះ ។

(ក្រាបថ្វាយបង្គំម្តង)

ព្រះសង្ឃគុណ

សុបដិបន្នោ ភគវតោ សាវកសង្ឃោ
ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ
ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ
សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ
យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា
ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ
ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំបុញ្ញក្ខេត្តំ លោកស្សាតិ ។
តំ សុបដិបន្នាទិគុណសំយុត្តំ សង្ឃំ សិរសា នមាមិ តញ្ច សង្ឃំ ឥមេហិ សក្ការេហិ អភិបូជយាមិ ។

ប្រែថា: **សុបដិបន្នោ ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃជាសាវ័កនៃព្រះជ័មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្ធង់ព្រះនព្វ-លោកុត្តរធម៌,* **ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃជាសាវ័កនៃព្រះជ័មានព្រះភាគលោកប្រតិបត្តិដោយត្រង់ គឺប្រតិបត្តិជាមជ្ឈិមប្បដិបទា,* **ញាយ-បដិបន្នោ ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃជាសាវ័កនៃព្រះជ័មានព្រះភាគ លោកប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ជាស្ថានក្សេមផុតចាកទុក្ខទាំងពួង,* **សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃជាសាវ័កនៃព្រះជ័មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមីចិកម្ម គឺប្រតិបត្តិគួរដល់សីល សមាធិ បញ្ញា,* **យទិទំ ចត្តារិ បុរិសយុគានិ** *ព្រះសង្ឃឯណា បើរាប់ជាគូនៃបុរសទាំង-ឡាយមាន ៤ គូ គឺព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គ និងសោតាបត្តិ*

ផលជាគូ ១ សកទាគាមិមគ្គ និងសកទាគាមិផលជាគូ ១ អនាគាមិមគ្គ និងអនាគាមិផលជាគូ ១ អរហត្តមគ្គ និងអរហត្តផលជាគូ ១, **អដ្ឋបុរិសបុគ្គលា** *បើរាប់រៀងជាបុរសបុគ្គលមាន ៨ គឺព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គ ១ សោតាបត្តិផល ១ សកទាគាមិមគ្គ ១ សកទាគាមិផល ១ អនាគាមិមគ្គ ១ អនាគាមិផល ១ អរហត្តមគ្គ ១ អរហត្តផល ១,* **ឯស ភគវតោ សាវកសង្ឃោ** *ព្រះសង្ឃទាំងនោះ ជាសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ,* **អាហុនេយ្យោ** *លោកគួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីលហើយ នាំមកអំពីចម្ងាយបង្អោនចូលមកបូជា,* **បាហុនេយ្យោ** *លោកគួរទទួលនូវអាគន្តុកទាន គឺទានដែលបុគ្គលតាក់តែងដើម្បីញាតិ និងមិត្រ ដែលមកអំពីទិសផ្សេង ៗ ហើយបង្អោនចូលមកបូជា,* **ទក្ខិណេយ្យោ** *លោកគួរទទួលនូវទានដែលបុគ្គលជឿនូវកម្ម និងផលនៃកម្មហើយបូជា,* **អញ្ជលិករណីយោ** *លោកគួរដល់អញ្ជលិកម្មដែលសត្វលោកគប្បីធ្វើ,* **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** *លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជ គឺបុណ្យនៃសត្វលោករកខេត្តដទៃក្រៃលែងជាងគ្មាន ។*

តំ សុបដិបន្នាទិគុណសំយុត្តំ សង្ឃំ សិរសា នមាមិ *ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះសង្ឃជាម្ចាស់ ជាប្រកបព្រមហើយដោយគុណ មានគុណថា* **សុបដិបន្នា** *ជាដើមនោះ ដោយសិរសាគឺក្បាល,* **តញ្ហា សង្ឃំ ឥមេហិ សក្ការេហិ អភិបូជយាមិ** *ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះសង្ឃជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយ មានប្រមាណប៉ុណ្ណេះ ។*

(ក្រាបថ្វាយបង្គំម្តង)

បណាមគាថា

(សមន្តប្បាសាទិកាបាលី ភាគ ១ ទំព័រ ១)

យោ កប្បកោដីហិបិ អប្បមេយ្យំ
កាលំ កវោន្តោ អតិទុក្ករានិ
ខេមំ គតោ លោកហិតាយ នាថោ
នមោ មហាការុណិកស្ស តស្ស ។

ព្រះពុទ្ធជាទីពឹង ជាពំនឹងសព្វសត្តា
ព្រះអង្គកាលប្រាថ្នា ធ្វើកសាងអស់កាលយូរ។
រាប់ដោយកោដិកប្បា ច្រើនគណនាហួសគិតគូរ
បានត្រាស់ជាសព្វញ្ញូ ច្បាស់ជាគ្រូលើភពហាន។
ធ្វើកម្មជាកម្រ មនុស្សនិករត្រាប់ពុំបាន
តោកយ៉ាកលំបាកប្រាណ ព្រោះប្រយោជន៍ដល់សព្វសត្វ។
ខ្ញុំសូមឱនសិរសា ចិត្តប្រាថ្នាបង្គំថ្វាត់
ព្រះពុទ្ធករុណាសត្វ នោះជាទីពឹងសព្វកាល ។

អសម្ភធំ ពុទ្ធនិសេវិតំ យំ
តវាតវំ គច្ឆតិ ជីវលោកោ
នមោ អវិជ្ជាទិកិលេសជាលំ (១)
វិទ្ធំសិនោ ធម្មវរស្ស តស្ស ។

សត្វតែងកើតស្លាប់បង់ ព្រោះចំណង់កម្មជាគោល

១-បាលីក្នុងអដ្ឋកថា ជា "... **សជាល- វិទ្ធំសិនោ**..." ដូច្នេះ ។

ឱ្យវិលវល់អន្ទោល ក្នុងភពតូចនិងភពធំ ។
ហេតុតែមិនដឹងធម៌ ជាម្ចាស់ល្អស្អាតសុខុម
គឺព្រះពុទ្ធសេពសម ចិត្តខ្ញុំសូមនមស្ការ ។
នូវធម៌ប្រពៃពិត វិសេសសុទ្ធនោះឯងណា
កាត់បង់នូវអវិជ្ជា គឺបណ្តាញកិលេសហើយ។

គុណេហិ យោ សីលសមាធិបញ្ញា
វិមុត្តិញ្ញាណប្បភូតីហិ យុត្តោ
ខេត្តញ្ញានំ កុសលត្តិកានំ
តមរិយសង្ឃំ សិរសា នមាមិ ។

ព្រះសង្ឃអង្គសាវ័ក មានសំវរៈសទ្ធាទ្រង់
កបដោយគុណសីលត្រង់ និងសមាធិបញ្ញា ។
និងវិមុត្តិញ្ញាណ កិលេសគ្មានក្នុងអាត្មា
ជាបុញ្ញក្ខេត្តា ជនត្រូវការជាកុសល។
ខ្ញុំសូមឱនសិរសី ដល់ព្រះអរិយបុគ្គល
ជាបុត្រព្រះទសពល ជាមង្គលដល់សព្វសត្វ។

នមស្សារបូជនីយវត្ថុជាទីគោរព

វន្ទាមិ ចេតិយំ សព្វំ សព្វដ្ឋានេ សុបតិដ្ឋិតំ
សារីរិកធាតុមហាពោធឹ ពុទ្ធរូបំ សកលំ សទា ។

ខ្ញុំសូមថ្វាយបង្គំ ឆ្ពោះព្រះបរមចេតិយ
ព្រមទាំងព្រះសារី- រិកធាតុនៃព្រះពុទ្ធ។
និងមហាពោធិព្រឹក្ស ដែលគួរនឹកដោយលំអុត
លំអិនចិត្តបរិសុទ្ធ លើកកម្ពង់អញ្ជលី។
និងព្រះពុទ្ធរូប តំណាងអង្គព្រះមុនី
ដែលបិតនៅគ្រប់ទី ឋាននានានោះទាំងអស់។
ដោយតេជៈនៃគុណ ព្រះមានបុណ្យប្រសើរខ្ពស់
ដែលតែងតែរំលស់ រំដោះទុក្ខភ័យអន្តរាយ។
សូមឱ្យខ្ញុំបានសុខ ឃ្លាតចាកទុក្ខផងទាំងឡាយ
សត្រូវទោះជិតឆ្ងាយ សូមឱ្យក្លាយមកជាមិត្ត។
សូមទាន់ព្រះអរី- យមេត្រេយ្យថ្ងៃវិសិដ្ឋ
សូមបានឃើញធម៌ពិត សមដូចចិត្តប្រាថ្នាហោង។

(ពាក្យកាព្យសម្រាយ តែងដោយសម្តេចព្រះសង្ឃរាជ ជួន-ណាត)

ពុទ្ធបាទនមក្ការគាថា

ឥទ្ធាមិ ពុទ្ធំឥថារតិណ្ណ
តិលោកកេតុំ តិភវេកនាថំ
យោ លោកសេដ្ឋោ សកលំកិលេសំ
ឆេត្វាន ពោធេសិ ជនំអនន្តំ ។

ព្រះសម្មាសម្ពុទ្ធឯណា ព្រះអង្គប្រសើរក្នុងលោក ទ្រង់កាត់បង់នូវកិលេសទាំងអស់បានហើយ ញុំាងជនជាអនន្តឱ្យត្រាស់ដឹងហើយ ខុំសូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធនោះ ព្រះអង្គឆ្ងងផុតអំពីប្រាំងនៃកពហើយ ព្រះអង្គជាទង់ជ័យនៃត្រៃលោក មានតែព្រះអង្គមួយ ជាទីពឹងនៃសព្វសត្វក្នុងត្រៃភព។

យំ ទម្មាយ ទន្ទិយា បុលិនេ ច តីរេ
យំ សច្ចពន្ធគិរិកេ សុមនា ច លង្កេយំ
តត្ត យោនកបុរេ មុនិនោ ច ឋានំ
តំ ឋានលញ្ញានមហំ សិរសា នមាមិ ។

ស្នាមព្រះបាទឯណា (ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុក) លើផ្ទរខ្សាច់ទៀបឆ្នេរនៃស្ទឹងឈ្មោះនម្មទា ស្នាមព្រះបាទឯណា ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុកលើភ្នំសច្ចពន្ធ និងលើភ្នំសុមនកូដ ស្នាមព្រះបាទឯណា ដែលព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានទុកក្នុងយោនកបុរី ខុំសូមក្រាបថ្វាយបង្គំដោយគ្បួងចំពោះទៅព្រះបាទ និងស្នាមព្រះបាទទាំងនោះនៃព្រះសក្យមុនី។

សុវណ្ណមាលិកេ សុវណ្ណបព្វតេ សុមនកូដេ
យោនកបុរេ ទម្មាយ ទន្ទិយា បញ្ចាឋានវរំ ឋានំ
អហំ វន្ទាមិ ទូរតោ ។

ខុំសូមនមស្ការអំពីចម្ងាយ នូវឋានដែលមានព្រះបាទដ៏ប្រសើរ ៥ កន្លែង គឺ ឋានលើភ្នំសុវណ្ណមាលិក: ១ លើភ្នំសុវណ្ណបព៌ត ១ លើភ្នំសុមនកូដ ១ ក្នុងយោនកបុរី ១ ក្បែរស្ទឹងនម្មទា ១ ។

ធាតុចេតិយនមស្ការគាថា

មហាគោតមសម្ពុទ្ធោ កុសិនារាយ និព្វុតោ
ធាតុវិត្ថារកំ កត្វា តេសុ តេសុ វិសេសតោ ៗ

ព្រះគោតមបរមសម្ពុទ្ធជ័ប្រសើរ ព្រះអង្គបរិនិព្វានហើយជិតក្រុងកុសិនារា ធ្វើនូវកិរិយាផ្សាយនូវព្រះសារីរិកធាតុក្នុងទីទាំងឡាយនោះៗ ដោយផ្សេងៗ គ្នា។

ខណ្ហីសំ ចតសេឡា ឆាឋា អក្ខកា ទ្វេ ច សត្តមា
អសម្ហិន្លា ឲ តា សត្ត សេសា តិន្លា ឲ ធាតុយោ ៗ

ព្រះសារីរិកធាតុទាំងឡាយនោះ ដែលមិនបែកចេញមាន ៧ អង្គគឺ ព្រះខណ្ហីសធាតុ[1]១ ព្រះទាឋធាតុ[2]៤ ព្រះអក្ខកធាតុ[3]២ ព្រះសារីរិកធាតុជ័សេសក្រៅពីនោះសុទ្ធតែបែងចេញ (ជាចំណែកតូចៗ)។

មហន្លា បញ្ច ឆាឡិយោ ឆាឡិយោ បញ្ច មជ្ឈិមា
ខុទ្ទកា ឆ ឆាឡិ ចេវ[4] សម្ហិន្លា តិវិធា មតា ៗ

ព្រះបរមធាតុទាំងឡាយដែលបែកចេញ លោកពោលថាមាន ៣ យ៉ាង គឺ ព្រះធាតុខ្នាតធំ រាល់បានចំនួន ៥ នាឡិ ព្រះធាតុខ្នាតកណ្តាល រាល់បានចំនួន ៥ នាឡិ ព្រះធាតុខ្នាតតូច រាល់បានចំនួន ៦ នាឡិ។

មហន្លា មុគ្គមត្តា ច មជ្ឈិមា តិន្លតណ្ឌុលា
ខុទ្ទកា សាសបមត្តា ច ឆាឆាវណ្ណា ច ធាតុយោ ៗ

ព្រះបរមធាតុទាំងឡាយ មានខ្នាតផ្សេងគ្នាយ៉ាងនេះគឺ ព្រះធាតុខ្នាតធំ មានទំហំប៉ុនកំណាត់គ្រាប់សណ្តែកបាយ ព្រះធាតុខ្នាតកណ្តាល មានទំហំប៉ុនកំណាត់

១-ឆ្អឹងថ្ងាស ។ ២-ព្រះចង្អូមកែវ ។ ៣-ឆ្អឹងដងកាំបិត ។ ៤-បិដកលេខ ៧៧ / ២៣៧ ។

គ្រាប់អង្ករ ព្រះធាតុខ្មាតតូច មានទំហំប៉ុនគ្រាប់ស្ពៃ។

មហន្តា សុវណ្ណវណ្ណា ច មុត្តាវណ្ណា ច មជ្ឈិមា
ខុទ្ទកា មក្កុលវណ្ណា ច[1] តាបិ ឥទ្ធាមិ ធាតុយោ ៤

ព្រះបរមធាតុទាំងឡាយ មានពណ៌ផ្សេងគ្នាយ៉ាងនេះគឺ ព្រះធាតុខ្មាតធំ មានពណ៌ដូចមាស ព្រះធាតុខ្មាតកណ្តាល មានពណ៌ដូចកែវមុក្តា ព្រះធាតុខ្មាតតូច មានពណ៌ដូចផ្កាម្ទិះ ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះបរមធាតុទាំងឡាយនោះ។

ឯកោ ថូបោ រាជគហេ ឯកោ វេសាលិយា អហុ
ឯកោ កបិលវត្ថុស្មឹ ឯកោ ច អលកប្បកេ
ឯកោ ច រាមគាមស្មឹ ឯកោ ច វេដ្ឋទីបកេ
ឯកោ ច បាវេយ្យកេ មល្លេ ឯកោ ច កុសិនារកេ ៤

ព្រះស្តូប ១ ប្រតិស្ឋាននៅក្នុងក្រុងរាជគ្រឹះ ព្រះស្តូប ១ ប្រតិស្ឋាននៅក្នុងក្រុងវេសាលី ព្រះស្តូប ១ ប្រតិស្ឋាននៅក្នុងក្រុងកបិលភ័ស្តុ ព្រះស្តូប ១ ប្រតិស្ឋាននៅក្នុងក្រុងអលកប្បក: ព្រះស្តូប ១ ប្រតិស្ឋាននៅក្នុងរាមគ្រាម ព្រះស្តូប ១ ប្រតិស្ឋាននៅក្នុងវេដ្ឋទីបក: ព្រះស្តូប ១ ប្រតិស្ឋាននៅក្រុងបាវេយ្យក: ក្នុងមល្លរដ្ឋជនបទ ព្រះស្តូប ១ ប្រតិស្ឋាននៅក្នុងក្រុងកុសិនារា ។

ឯតេ សារីរិកា ថូបា ជម្ពុទីបេ បតិដ្ឋិតា
បូជិតា នរទេវេហិ អហំ ឥទ្ធាមិ ធាតុយោ ៤

ព្រះស្តូប (ទាំង ៨)នុ៎ះ ជាព្រះស្តូបបញ្ចុះព្រះបរមសារីរិកធាតុ ប្រតិស្ឋាន

១- បិដកលេខ ៧៧ ទំព័រ ២៣៧ និងអដ្ឋកថាមហាបរិនិព្វានសូត្រ ។

នៅក្នុងជម្ពូទ្វីប ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះបរមធាតុទាំងឡាយ (ក្នុងព្រះស្តូបទាំង ៨ នោះ) ដែលទេវតា និងមនុស្សទាំងឡាយតែងបូជា។

ឯកា ឆាឋា តិទសបុរេ ឯកា នាគបុរេ អហុ
ឯកា គន្ធារទិសយេ ឯកា សីហឡទីបកេ ៤

ព្រះទាឋធាតុអង្គ ១ ប្រតិស្ឋាននៅក្នុងឋានត្រៃត្រឹង្ស ព្រះទាឋធាតុអង្គ ១ ប្រតិស្ឋាននៅក្នុងពិភពនាគ ព្រះទាឋធាតុអង្គ ១ ប្រតិស្ឋាននៅក្នុងគន្ធាររដ្ឋ ព្រះទាឋធាតុអង្គ ១ ប្រតិស្ឋាននៅក្នុងសីហឡទ្វីប។

ឥមា ចតូសុ ឋានេសុ សត្ថុ ឆាឋា បតិដ្ឋិតា
បូជិតា នរទេវេហិ អហំ វន្ទាមិ ឆាតុយោ ៤

ព្រះទាឋធាតុទាំងឡាយនេះ របស់ព្រះបរមសាស្តា ប្រតិស្ឋាននៅក្នុងទីទាំងឡាយ ៤ កន្លែង ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះធាតុទាំងឡាយ ដែលទេវតា និងមនុស្សទាំងឡាយតែងបូជា។

ទ្វេ្ធ ទក្ខិណទាឋា ច តាវត្តឹសេ បតិដ្ឋិតា
អធោ ទក្ខិណទាឋា ច សីហឡទីបេ បតិដ្ឋិតា
វាមទាឋា ច ទ្វេ្ធ គន្ធារេ បតិដ្ឋិតា
វាមទាឋា ច អធោបិ នាគលោកេ បតិដ្ឋិតា
បូជិតា នរទេវេហិ អហំ វន្ទាមិ ឆាតុយោ ៤

ព្រះទាឋធាតុស្តាំខាងលើ ប្រតិស្ឋាននៅក្នុងឋានតាវត្តឹង្ស ព្រះទាឋធាតុស្តាំខាងក្រោម ប្រតិស្ឋាននៅក្នុងសីហឡទ្វីប ព្រះទាឋធាតុឆ្វេងខាងលើ ប្រតិស្ឋាននៅក្នុងដែនគន្ធារៈ ព្រះទាឋធាតុឆ្វេងខាងក្រោម ប្រតិស្ឋាននៅក្នុងពិភពនាគ ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះធាតុទាំងឡាយដែលទេវតា និងមនុស្ស

ទាំងឡាយតែងបូជា។

ព្រហ្មលោកេ ទុស្សធាតុ- ឥាមអក្ខកធាតុយោ
សព្វេ ព្រហ្មានិបូជេន្តិ ថូបំ ទ្វាទសយោជនំ ។

ព្រះទុស្សធាតុ[1] និងព្រះអក្ខកធាតុខាងឆ្វេង ប្រតិស្ឋាននៅក្នុងព្រហ្មលោក ព្រហ្មទាំងឡាយទាំងអស់គ្នា តែងបូជានូវព្រះស្តូបកម្ពស់ ១២ យោជន៍ (ដែលបញ្ចុះនូវព្រះធាតុទាំងនោះ)។

តាវត្តឹសម្ហិ ទេវានំ ចុឡ្លាមណិម្ហិ កេសកំ
សព្វេ ទេវានិបូជេន្តិ បសន្នា ពុទ្ធសាសនេ
បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ ។

ទេវតាទាំងឡាយទាំងពួង ដែលជាអ្នកជ្រះថ្លាក្នុងព្រះពុទ្ធសាសនា តែងបូជានូវព្រះកេសធាតុ ដែលប្រតិស្ឋាននៅក្នុងចូឡាមណីចេតិយ របស់ទេវតាទាំងឡាយក្នុងឋានត្រៃត្រឹង្ស ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះធាតុទាំង-ឡាយ ដែលទេវតា និងមនុស្សទាំងឡាយតែងបូជា។

ចត្តាឡីស សមា ទន្តា កេសា លោមា នខាបិ ច
ទេវា ហរន្តិ ឯកេកំ ចក្កវាឡេបរម្បរា
បូជិតា នរទេវេហិ អហំ វន្ទាមិ ធាតុយោ ។

ព្រះទន្តធាតុទាំងឡាយ ៤០ គត់ផង ព្រះកេសធាតុទាំងឡាយផង ព្រះលោមធាតុទាំងឡាយផង ព្រះនខធាតុទាំងឡាយផង ទេវតាទាំងឡាយនាំទៅ

១- ព្រះទុស្សធាតុ គឺព្រះពស្ត្រដែលព្រះអង្គផ្លាស់ចេញហើយទ្រង់សំពត់កាសាវៈដែលឃដិកាមហាព្រហ្មយកមកថ្វាយ រួចទ្រង់ប្រទានព្រះពស្ត្រនោះទៅឃដិកាមហាព្រហ្ម។ បានទទួលយកទៅប្រតិស្ឋានឯព្រហ្មលោក ។

នូវព្រះជាតុ ១ អង្គៗ កាន់ចក្រវាឡដទៃ និងដទៃ គឺព្រះជាតុ ១ អង្គ ៗ ក្នុងចក្រវាឡមួយ ៗ ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះជាតុទាំងឡាយ ដែលទេវតា និងមនុស្សទាំងឡាយតែងបូជា ។

អដ្ឋារស ទ្វេ វស្សសតេ ធម្មាសោកោ តទា អហុ
ចតុរាសីតិសហស្សា ចេតិយោ ច ការាបិតា
បូជិតា ឆរទេវេហិ អហំ វន្ទាមិ ធាតុយោ ៗ

នាកាលព្រះពុទ្ធសករាជបាន ២១៨ ឆ្នាំ មានព្រះមហាក្សត្រមួយអង្គទ្រង់ព្រះនាមធម្មាសោក ក្នុងកាលនោះ ព្រះអង្គបានកសាងព្រះចេតិយចំនួន ៨ ម៉ឺន ៤ ពាន់ ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះជាតុទាំងឡាយ (ក្នុងព្រះចេតិយទាំងនោះ) ដែលទេវតា និងមនុស្សទាំងឡាយតែងបូជា[1] ។

សុភមង្គលគាថា

ហោតុ សព្វំ សុមង្គលំ រក្ខន្តុ សព្វទេវតា
សព្វពុទ្ធានុភាវេន សោត្ថិ ហោតុ និរន្តរំ ៗ

ប្រែថា: **ហោតុ សព្វំ សុមង្គលំ** *សុមង្គល គឺសេចក្តីចម្រើនដ៏ល្អគ្រប់យ៉ាង ចូរមានដល់ខ្ញុំ,* **រក្ខន្តុ សព្វទេវតា** *ទេវតាទាំងពួងទាំងឡាយចូររក្សានូវខ្ញុំ,* **សព្វពុទ្ធានុភាវេន** *ដោយអានុភាពនៃព្រះពុទ្ធគ្រប់ព្រះអង្គ,* **សោត្ថិ ហោតុ និរន្តរំ** *សូមសិរីសួស្តីចូរមានដល់ខ្ញុំឱ្យបានគ្រប់ពេល កុំបីមានចន្លោះឡើយ ។*

១-ដកពីសត្តបរិត្ត-ទ្វាទសបរិត្តរបស់ព្រះវិសុទ្ធវង្ស ហួត-តាត និងកែតម្រូវតាមបិដកលេខ ៧៧ ទំព័រ ២៣៧ ។

ហោតុ សព្វំ សុមង្គលំ រក្ខន្តុ សព្វទេវតា
សព្វធម្មានុភាវេន សោត្ថិ ហោតុ និរន្តរំ ។

ប្រែថា: **ហោតុ សព្វំ សុមង្គលំ** *សុមង្គល គឺសេចក្តីចម្រើនដ៏ល្អគ្រប់យ៉ាង ចូរមានដល់ខ្ញុំ,* **រក្ខន្តុ សព្វទេវតា** *ទេវតាទាំងពួងទាំងឡាយចូររក្សានូវខ្ញុំ,* **សព្វ-ធម្មានុភាវេន** *ដោយអានុភាពនៃព្រះធម៌ទាំងពួង,* **សោត្ថិ ហោតុ និរន្តរំ** *សូមសិរីសួស្តីចូរមានដល់ខ្ញុំឱ្យបានគ្រប់ពេល កុំបីមានចន្លោះឡើយ។*

ហោតុ សព្វំ សុមង្គលំ រក្ខន្តុ សព្វទេវតា
សព្វសង្ឃានុភាវេន សោត្ថិ ហោតុ និរន្តរំ ។

ប្រែថា: **ហោតុ សព្វំ សុមង្គលំ** *សុមង្គល គឺសេចក្តីចម្រើនដ៏ល្អគ្រប់យ៉ាង ចូរមានដល់ខ្ញុំ,* **រក្ខន្តុ សព្វទេវតា** *ទេវតាទាំងពួងទាំងឡាយចូររក្សានូវខ្ញុំ,* **សព្វ-សង្ឃានុភាវេន** *ដោយអានុភាពនៃព្រះសង្ឃទាំងពួង,* **សោត្ថិ ហោតុ និរន្តរំ** *សូមសិរីសួស្តីចូរមានដល់ខ្ញុំឱ្យបានគ្រប់ពេល កុំបីមានចន្លោះឡើយ។*

សច្ចកិរិយា

(សមន្តប្បាសាទិកាបាលី ភាគ ១ ទំព័រ ២)

ឥមេ្ចវមច្ចន្តនមស្សនេយ្យោ
នមស្សមានោ រតនត្តយំ យំ
បុញ្ញាភិសន្ទំ វិបុលំ អលត្ថំ
តស្សានុភាវេន ហតន្តរាយោ ។

ខ្ញុំសូមនមស្ការ លើកហត្ថាឱនសិរសី
បង្គំគុណទាំងបី ខ្ពស់លើសលប់ត្រៃលោកា។
សូមបុណ្យកងកុសល ឱ្យបានដល់យើងខ្ញុំណា
ពេញពោរស្មើធារា ដូចជលសាធំទូលាយ។
សូមឱ្យកម្ចាត់បង់ អពមង្គលទាំងឡាយ
ឱ្យចៀសចេញចាកឆ្ងាយ ក្តីអន្តរាយកុំបីមាន។
ដោយកម្លាំងអានុភាព បុញ្ញលាភជាប្រធាន
កងបុញ្ញារាសីមាន សូមបានក្សាន្តកុំមានមោះ។
ដោយគុណនមស្ការ ត្រៃរតនាប្រសើរខ្ពស់
សូមអានិសង្សនោះ ជាក់ដល់ឋាននិព្វានហោង។

ចប់ត្រៃបណាមសង្ខេប

ចប់ត្រៃបណាមតែប៉ុណ្ណោះ

បត្តិទានវិធី

(វិធីឧទ្ទិសបុណ្យដល់ពួកញាតិ និងសព្វសត្វ)

****

សេចក្តីពន្យល់

ពុទ្ធសាសនិកជន ដែលបានធ្វើបុណ្យកុសលឯណានីមួយ បណ្តាបុញ្ញកិរិ-យាវត្ថុទាំង ១០ យ៉ាង មានទានជាដើមរួចហើយ គប្បីឧទ្ទិសបុណ្យនោះដល់ពួកញាតិ មានមាតាបិតាជាដើម។

ឯការឧទ្ទិសទានដែលនាំឱ្យសម្រេចផលដល់ញាតិនោះ លោកសម្តែងប្រាប់ក្នុងគម្ពីរបរមត្ថជោតិកា អដ្ឋកថានៃតិរោកុឌ្ឌសូត្រថា:

បេតានញ្ហិ អត្តនោ អនុមោទនេន, ទាយកានំ ទ្វេសេន, ទក្ខិណេយ្យ សម្បទាយ ចាតិ តីហិ អង្គេហិ ទក្ខិណា សមិជ្ឈតិ, តទុណេ ផលនិព្វត្តិកា ហោតិ ។

មែនពិត ទក្ខិណាវមែងសម្រេចផល គឺឱ្យកើតផលក្នុងខណៈនោះបានដោយអង្គ ៣ គឺ:

១- បេតានំ អត្តនោ អនុមោទនេន *ប្រេត[1] ទាំងឡាយមកអនុមោទនាដោយខ្លួនឯង,*

២- ទាយកានំ ទ្វេសេន *ទាយកទាំងឡាយបានឧទ្ទិសឱ្យ,*

១-គឺអ្នកដែលធ្វើមរណកាលទៅកាន់បរលោកហើយ។

៣- ទក្ខិណេយ្យ សម្បទាយ ដោយការដល់ព្រមដោយទក្ខិណេយ្យបុគ្គល (គឺបុគ្គលអ្នកញុំាងទក្ខិណាទានឱ្យមានផលច្រើន បានដល់ព្រះសង្ឃ និងលោកអ្នកមានសីល)។

ក្នុងចំណុចនេះបញ្ជាក់ឱ្យឃើញថាមិនមែនដោយគ្រាន់តែយើងបានប្រគេនចង្ហាន់ជាដើមដល់ព្រះសង្ឃ ឬជូនដល់លោកអ្នកមានសីលរួចហើយជាការស្រេចនោះទេ ហើយក៏មិនមែនព្រះសង្ឃលោកសូធ្យធម៌ឧទ្ទិសបុណ្យឱ្យដល់ញាតិរបស់យើងដែរ គឺលោកសូធ្យឱ្យយើងស្តាប់ទេតើ ឯការឧទ្ទិសបុណ្យដល់ញាតិគឺជាកិច្ចរបស់យើងផ្ទាល់។

ក្នុងគម្ពីរដដែលលោកបានបញ្ជាក់ថែមទៀតថា: **តត្ថ ឆាយកា វិសេស-ហេតុ** បណ្តាអង្គទាំង ៣ នោះ ទាយកទាំងឡាយជាអង្គពិសេស។

ចំណុចនេះបានសេចក្តីថា បើពួកប្រេតក៏បានមកហើយ ឯបដិគ្គាហក: គឺអ្នកទទួលទានក៏ជាអ្នកមានសីលដែរ តែបើទាយកជាម្ចាស់ទានមិនបានឧទ្ទិសឱ្យទេ ក៏ពួកប្រេតមិនអាចទទួលផលនោះបានដែរ ដូចរឿងប្រេតជាញាតិរបស់ព្រះបាទពិម្ពិសារដូច្នោះឯង, ដូច្នេះ ទាយកជាម្ចាស់ទានទាំងឡាយចាំបាច់ត្រូវតែចេះចាំនិងយល់ដឹងនូវពាក្យឧទ្ទិសនេះឱ្យបានគ្រប់ៗ បើមិនបានច្រើន ក៏ឱ្យបានខ្លះដែរ។ ព្រោះថាបើពុំដូច្នោះទេ ពួកញាតិមិនអាចទទួលផលបានឡើយ, តែប្រសិនបើទាយកទាយិកាមិនបានចេះពាក្យឧទ្ទិសទេ គួរឱ្យមានអ្នកដឹកនាំ មានលោកអាចារ្យជាដើមបង្គាប់ឱ្យគាត់ថាតាមនោះទើបជាការត្រឹមត្រូវ មិនមែនសូធ្យតែម្នាក់ឯងទេ។

ឯពាក្យសម្រាប់ឧទ្ទិសនោះ មាន ២ ប្រភេទ គឺពាក្យឧទ្ទិសដែលមានមកនៅ

ក្នុងគម្ពីរ មាន “**យំ កិញ្ចិ**..., និង **ឥមំ ភោ** ...,” ជាដើម ១ និងពាក្យដែលគេតែងជាខាងក្រោយ មាន **តេជះខ្ញុំសាង** ជាដើម ១ ។ ហើយពាក្យដែលតែងនោះទៀតសោត ភាគច្រើនគឺជាពាក្យកាព្យ ។

សម្រាប់ទាយកជាម្ចាស់ទាន ឬលោកអាចារ្យអ្នកដឹកនាំ បើពេលវេលាវែងលោកអាចសូធ្យទាំងពីរបែបបានក៏តាមអធ្យាស្រ័យចុះ, តែបើពេលវេលាខ្លីមិនអាចសូធ្យបានទាំងពីរទេសូធ្យត្រឹមតែ **ឥមំ ភោ**...,និង **យំ កិញ្ចិ**... , ក៏គ្រប់គ្រាន់ហើយ។ មួយទៀត បើសូធ្យទាំងពីរក៏សូធ្យចុះ តែគួរសូធ្យ **ឥមំ ភោ**..., និង **យំ កិញ្ចិ**... , ក្រោយគេបង្អស់ ព្រោះក្នុងធម៌ **យំ កិញ្ចិ**. . . មានឃ្លាមួយបានពឹងពាក់ដល់ទេវតាឱ្យជួយនាំដំណឹងទៅប្រាប់ដល់ពួកញាតិណាដែលមិនបានដឹងឱ្យដឹង ហើយទទួលត្រេកអរនឹងបុណ្យទាំងនោះចុះ (**ទេវា គន្ធា និវេទយុំ**) ។

នេះជាមតិរបស់ខ្ញុំ សូមអ្នកសិក្សាទាំងឡាយពិចារណាសិនចុះ។

បត្តិទានគាថា

(បិដកលេខ ៧២ ទំព័រ ៩)

យំ កិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម
ការយេន វាចាមនសា តិទសេ សុគតំ កតំ ។
យេ សត្តា សញ្ញិនោ អត្ថិ យេ ច សត្តា អសញ្ញិនោ
កតំ បុញ្ញផលំ មយ្ហំ សព្ពេ ភាគី ភវន្តុ តេ ។
យេ តំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា
យេ ច តត្ត ន ជានន្តិ ទេវា គន្ត្វា និវេទយុំ ។
សព្ពេ លោកម្ហិយេ សត្តា ជីវន្តាហារហេតុកា
មនុញ្ញំ ភោជនំ សព្ពេ លភន្តុ មម ចេតសាតិ ។

ប្រែថា: **យំ កិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម** *អំពើជាកុសលឯណាមួយ ដែលខ្ញុំគប្បីធ្វើ,* **ការយេន វាចា មនសា** *ដោយទ្វារទាំង ៣ គឺកាយ វាចា បិត្ត,* **តិទសេ សុគតំ កតំ** *អំពើជាកុសលទាំងអស់នោះ ដែលខ្ញុំបានធ្វើហើយជាកុសលអាចនឹងនាំឱ្យទៅកើតក្នុងឋានត្រៃត្រិង្សសួគ៌បាន,* **យេ សត្តា សញ្ញិនោ អត្ថិ** *សត្វទាំងឡាយឯណា គឺមនុស្ស ឬទេវតា ឬព្រហ្មដែលជាសត្វមានសញ្ញាក្តី,* **យេ ច សត្តា អសញ្ញិនោ** *សត្វទាំងឡាយឯណា ជាអសញ្ញិសត្វ គឺសត្វដែលឥតសញ្ញាក្តី,* **កតំ បុញ្ញផលំ មយ្ហំ សព្ពេ ភាគី ភវន្តុ តេ** *សត្វទាំងឡាយទាំងអស់នោះ ចូរឱ្យបាននូវចំណែកផលនៃបុណ្យដែលខ្ញុំបានធ្វើហើយ បានឧទ្ទិសផ្សាយឱ្យទៅនេះចុះ,* **យេ តំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា** *បុណ្យដែលខ្ញុំបានធ្វើហើយនោះ បើសត្វទាំងឡាយឯណាបានដឹងច្បាស់ហើយ សត្វ*

ទាំងឡាយនោះ ចូរឱ្យបានសោយនូវផលនៃបុណ្យដែលខ្ញុំបានឧទ្ទិសឱ្យទៅនោះចុះ, **យេ ច តត្ត ន ជានន្តិ** *ម្យ៉ាងទៀត បណ្តាអស់សត្វទាំងនោះ បើសត្វទាំងឡាយឯណាមិនបានដឹងនូវបុណ្យដែលខ្ញុំបានធ្វើហើយនោះ,* **ទេវា តញ្ហា និវេឋយុំ** *សូមទេវតាទាំងឡាយ អញ្ជើញទៅឱ្យដំណឹងដល់សត្វទាំងឡាយនោះឱ្យបានដឹងផងថា ជនឯណោះគេបានធ្វើបុណ្យហើយគេឧទ្ទិសផ្សាយផលបុណ្យនោះមកដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ចូរអនុមោទនាត្រេកអរនឹងបុណ្យគេទាំងនោះចុះ,* **សព្វេ លោកម្ហិយេ សត្តា ជីវន្តាហារហេតុកា** *សត្វទាំងឡាយឯណាក្នុងលោកទាំងអស់ដែលអាស្រ័យនូវអាហារហើយរស់នៅ,* **មនុញ្ញំ រោជនំ សព្វេ លភន្តុ មម ចេតសាតិ** *សត្វទាំងឡាយទាំងអស់នោះ ចូរឱ្យបាននូវភោជនជាទីគាប់ចិត្ត ដែលសម្រេចដោយបុញ្ញរឹទ្ធិតាមចិត្តដែលខ្ញុំឧទ្ទិសផ្សាយទៅឱ្យនេះចុះ។*

បត្តិទានគាថា

(សូធ្យក្រោយចប់ធម៌ទេសនា ឬសូធ្យធម៌ណាចប់ហើយ)

យា ទេវតា សន្តិ វិហារវាសិនី
ថូបេ ឃរេ ពោធិឃរេ តហីតហិំ
តា ធម្មទានេន តវន្តុ បូជិតា
សោត្តិំ ករោន្តេធ វិហារមណ្ឌលេ
ថេរា ច មជ្ឈា នវកា ច ភិក្ខវោ
សារាមិកា ទានបតី ឧបាសកា
គាមា ច ទេសា និគមា ច ឥស្សរា

សប្បាណភូតា សុខិតា ភវន្តុ តេ
ជលាពុជា យេបិ ច អណ្ឌសម្ភវា
សំសេទជាតា អថវោបបាតិកា
និយ្យានិកំ ធម្មវរំ បដិច្ចតេ
សព្ពេបិ ទុក្ខស្ស ករោន្តុ សំខយំ ។
ឋានុ ចិរំ សតំ ធម្មោ ធម្មធរា ច បុគ្គលា
សង្ឃោ ហោតុ សមគ្គោ ច អត្ថាយ ច ហិតាយ ច
អម្ហេ រក្ខតុ សទ្ធម្មោ សព្ពេបិ ធម្មចារិនោ
ភុញ្ជឹ សម្បាបុណោយ្យាម ធម្មារិយប្បវេទិ តេ ។

ប្រែថា: **យា ទេវតា សន្តិ វិហារទាសិនី ថូបេយរេ ពោធិយរេ តហឹតហឹ** *ទេវតាទាំងឡាយឯណា មានប្រក្រតីនៅក្នុងវត្តជាទីនៅនៃសង្ឃ ឰដ៏ខឿនព្រះស-ថូប ឰដ៏ខឿនព្រះពោធិព្រឹក្សក្នុងទីនោះៗ,* **តា ធម្មធានេន ភវន្តុ បូជិតា** *ទេវតាទាំងឡាយនោះ ជាបុគ្គល គឺយើងទាំងឡាយបូជាហើយដោយធម្មទាន,* **សោត្ថឹ ករោន្តេ ច វិហារមណ្ឌលេ** *ចូរធ្វើនូវសួស្តីក្នុងមណ្ឌលនៃវត្ត ជាទីនៅនៃសង្ឃនេះ,* **ថេរ ច មជ្ឈ នវកា ច តិក្ខោ** *កិក្ខុទាំងឡាយជាថេរៈក្តី ជាកណ្តាលក្តី ទើបនឹងបួសក្តី,* **សារមិកា ទានបតី ឧបាសកា** *ឧបាសក និងឧបាសិកាទាំងឡាយដែលជាម្ចាស់នៃទានព្រមទាំងអារាមិកជន គឺញោមវត្តក្តី,* **គាមា ច ទេសា និគមា ច តស្ស** *រាជនទាំងឡាយដែលជាអ្នកស្រុកក្តី ជាអ្នកប្រទេសក្តី ជាអ្នកនិគមក្តី ដែលជាតស្សរៈជាធំក្តី,* **សប្បាណភូតា សុខិតា ភវន្តុ តេ** *សត្វទាំងឡាយនោះៗ ចូរឱ្យបានដល់នូវសេចក្តីសុខ,* **ជលាពុជា យេបិ ច អណ្ឌសម្ភវា សំសេទជាតា**

អថវោបឋាតិកា *មួយវិញទៀត សត្វទាំងឡាយឯណា ដែលជាជលាពុជៈកំណើតក្តី ដែលជាអណ្ឌជៈកំណើតក្តី ដែលជាសំសេទជៈកំណើតក្តី ដែលជាឧបបាតិកៈកំណើតក្តី,* **និយ្យានិកំ ធម្មវរំ បដិច្ច តេ សព្ពេបិ ទុក្ខស្ស ករោន្តុ សំខយំ** *សត្វទាំងឡាយទាំងអស់នោះ កាលបើបានអាស្រ័យនូវធម៌ដ៏ប្រសើរ ជានិយ្យានិកធម៌ហើយ ចូរធ្វើនូវធម៌ជាគ្រឿងអស់ទៅនៃទុក្ខចុះ,* **ឋាតុ ចិរំ សតំ ធម្មោ** *សូមឱ្យធម៌របស់សប្បុរសទាំងឡាយឋិតនៅអស់កាលយូរអង្វែងទៅ,* **ធម្មធរា ច បុគ្គលា** *បុគ្គលអ្នកទ្រទ្រង់នូវធម៌ទាំងឡាយ (ចូរស្ថិតនៅអស់កាលយូរ អង្វែងតទៅ)* **សង្ឃោ ហោតុ សមគ្គោ ឥ** *សូមព្រះសង្ឃព្រមព្រៀងគ្នា,* **អត្ថាយ ច ហិតាយ ច** *ដើម្បីសេចក្តីចម្រើនផង ដើម្បីសេចក្តីសម្រេចផលប្រយោជន៍ផង* **អម្ហេ រក្ខតុ សទ្ធម្មោ សព្ពេបិ ធម្មចារិនោ** *សូមព្រះសទ្ធម្មរក្សានូវយើងទាំងឡាយ សូមរក្សានូវអ្នកដែលប្រព្រឹត្តធម៌ទាំងឡាយទាំងអស់ផង,* **ខុឌ្ឌឹ សម្បាបុណេយ្យាម ធម្មាភិយុប្បវេទិ តេ** *សូមឱ្យយើងទាំងឡាយ បានដល់នូវសេចក្តីចម្រើនក្នុងធម៌ដែលព្រះអរិយៈទាំងឡាយលោកសម្តែងហើយ ។*

បត្តិទានគាថា

(គាថាចែកចំណែកបុណ្យ)

ឥមិនា បុញ្ញកម្មេន ខ្យបជ្ឈាយា គុណុត្តរា
អាចរិយូបការា ច មាតាបិតា បិយា មមំ
សុរិយោ ចន្ទិមា រាជា គុណវន្តា នរាបិ ច

ព្រហ្មា មារ ច ឥន្ទា ច លោកបាលា ច ទេវតា
យមោ មិត្តា មនុស្សា ច មជ្ឈត្តា វេរិកាបិ ច
សព្វេ សត្តា សុខី ហោន្តុ បុញ្ញានិ បកតានិ មេ
សុខញ្ច តិវិធំ ទេន្តុ ខិប្បំ បាបេថ នោ មតំ ។

ប្រែថា: **ឥមិនា បុញ្ញកម្មេន** *ដោយបុញ្ញកម្មនេះ* **ខ្ញុបជ្ឈាយាគុណុត្តរ** *ឧបជ្ឈាយ៍ទាំងឡាយ មានគុណដ៏ខ្ពង់ខ្ពស់ក្តី* **អាចរិយូបការា ច** *អាចារ្យទាំងឡាយ មានឧបការៈក្តី* **មាតា បិតា ចិយា មមំ** *មាតា និងបិតាជាទីស្រឡាញ់នៃខ្ញុំក្តី* **សុរិយោ ចន្ទិមា រាជា** *ព្រះអាទិត្យ ព្រះចន្ទ និងព្រះរាជាក្តី* **គុណវន្តា ឧរាបិ ច** *មួយវិញទៀត ជនទាំងឡាយដែលជាអ្នកមានគុណក្តី* **ព្រហ្មា មារ ច ឥន្ទា ច** *ពួកព្រហ្មក្តី មារក្តី ព្រះឥន្ទទាំងឡាយក្តី* **លោកបាលា ច** *ទេវតាទេវតាទាំងឡាយ ជាអ្នករក្សានូវលោកក្តី* **យមោមិត្តា មនុស្សា ច** *យមរាជក្តី ពួកមនុស្សជាទីរាប់អានគ្នាក្តី* **មជ្ឈត្តា វេរិកាបិ ច** *មួយវិញទៀត សត្វទាំងឡាយដែលមានចិត្តជាឧបេក្ខាក្តី មានពៀរនឹងគ្នាក្តី* **សព្វេ សត្តា សុខី ហោន្តុ** *សព្វសត្វទាំងឡាយ ចូរឱ្យបាននូវសេចក្តីសុខ* **បុញ្ញានិ បកតានិ មេ** *បុណ្យទាំងឡាយដែលខ្ញុំបានធ្វើហើយ* **សុខញ្ច តិវិធំ ទេន្តុ** *សូមឱ្យបាននូវសេចក្តីសុខទាំង ៣ ប្រការ (គឺសុខក្នុងមនុស្ស ទេវតា និងព្រះនិព្វាន)* **ខិប្បំ បាបេថ នោ មតំ** *អ្នកទាំងឡាយចូរដល់នូវព្រះនិព្វានឈ្មោះអមត: ដោយឆាប់រួសរាន់ទាន់ចិត្ត។*

បត្តនាគាថា

(គាថាតាំងសេចក្តីប្រាថ្នា)

ឥមិនា បុញ្ញកម្មេន ឥមិនា ឧទ្ទិសេន ច
ខិប្បាហំ សុលភេ ចេវ តណ្ហុប្បាទាឧភេទនំ
យេ សន្តានេ ហីនាធម្មា យាវ និព្ពានតោ មមំ
នស្សន្តុ សព្ពទាយេវ យត្ត ជាតោ ភវាភវេ
ឧជុចិត្តោ សតិប្បញ្ញោ សល្លេខោ វីរិយោម្ហិ ភា
មារ លភន្តុ នោការំ ការុញ្ញា វីរិយេសុ មេ
ពុទ្ធោ ទីបង្ករោ នាថោ ធម្មោ នាថោ វរុត្តមោ
នាថោ បច្ចេកពុទ្ធោ ច សង្ឃោ នាថោត្តរោ មមំ
តេ សោត្តមានុភាវេន មារោការំ លភន្តុ មា ៚

ប្រែថា: **ឥមិនា បុញ្ញកម្មេន** *ដោយបុញ្ញកម្មនេះផង* **ឥមិនា ឧទ្ទិសេន ច** *ដោយពាក្យឧទ្ទិសនេះផង* **ខិប្បាហំ សុលភេ ចេវ តណ្ហុប្បាទាឧភេទនំ** *ខ្ញុំគប្បីបានដោយងាយនូវការកាត់ផ្តាច់តណ្ហា និងឧបាទានដោយឆាប់រួសរាន់* **យេ សន្តានេ ហីនា ធម្មា** *ធម៌ទាំងឡាយណា ដែលហោចទាបមានក្នុងសន្តាន(នៃខ្ញុំ)* **យាវ និព្ពានតោ មមំ នស្សន្តុ សព្ពទាយេវ** *ធម៌ហោចទាំងនោះ ចូរវិនាសទៅ(ចាកសន្តាន)នៃខ្ញុំសព្វកាល ដរាបដល់ព្រះនិព្វាន* **យត្ត ជាតោ ភវា ភវេ** *ខ្ញុំកើតហើយក្នុងភពតូច និងភពធំណា ៗ* **ឧជុចិត្តោ សតិប្បញ្ញោ សល្លេខោ វីរិយោម្ហិ ភា** *សូមឱ្យជាអ្នកមានចិត្តត្រង់ មានស្មារតី និងប្រាជ្ញា ទាំងសូមឱ្យមានចិត្តផូរផង់*

និងសេចក្តីព្យាយាមផង (ក្នុងភពនោះៗ) **មារ លភន្តុ នោកាសំ កាតុញ្ញា តីរិយេ-សុ មេ** *មារទាំងឡាយ ចូរកុំបាននូវឱកាសដើម្បីធ្វើ (នូវសេចក្តីអន្តរាយ) ក្នុងព្យា-យាមទាំងឡាយនៃខ្ញុំ* **ពុទ្ធោ ទីបឥវោ នាថោ** *ព្រះពុទ្ធដូចជាប្រទីបដ៏ប្រសើរ ព្រះអង្គជាទីពឹង (របស់ខ្ញុំ)* **ធម្មោ នាថោ វរុត្តមោ** *ព្រះធម៌ដ៏ឧត្តមបវរជាទីពឹង (របស់ខ្ញុំ)* **នាថោ បច្ចេកពុទ្ធោ ច** *ព្រះបច្ចេកពុទ្ធក៏ជាទីពឹង (របស់ខ្ញុំ)* **សង្ឃោ នាថោត្តរោ មមំ** *ព្រះសង្ឃជាទីពឹងដ៏ប្រសើរ (របស់ខ្ញុំ)* **តេ សោត្តមានុភាវេន** *ដោយឧត្តមភាពនៃព្រះពុទ្ធ ព្រះធម៌ ព្រះបច្ចេកពុទ្ធ និងព្រះសង្ឃទាំងឡាយនោះ* **មារោកាសំ លភន្តុ មា** *មារចូរកុំបាននូវឱកាសឡើយ។*

ខមាបនគាថា

(គាថាសូមខមាទោស)

យេកេចិ ខុទ្ទកា បាណា មហន្តាបិ
មយា ហតា យេ បាណេកេ បមាទេន
កាយវាចាមនេហិ វា បុញ្ញំ មេ
អនុមោទន្តុ គណ្ហន្តុ ឆលភុត្តមំ
ភវិនោ ចេ បមុញ្ចន្តុ សព្វទោសំខមន្តុ មេ ៗ

ប្រែថា: **យេកេចិ ខុទ្ទកា បាណា មហន្តាបិ មយា ហតា** *សត្វទាំងឡាយណាមួយ ជាសត្វតូចក្តី ធំក្តី ដែលខ្ញុំសម្លាប់ហើយ* **យេ បាណេកេ បមាទេន កាយ វាចា មនេហិ វា** *ទោះសត្វទាំងឡាយណាពួកខ្លះ (ដែលខ្ញុំបៀតបៀនហើយ)*

ដោយកាយវាចាចិត្ត ព្រោះសេចក្តីប្រមាទ **បុញ្ញំ មេ អនុមោទន្តុ** *(សត្វទាំងនោះ) ចូរអនុមោទនាត្រេកអរចំពោះបុណ្យរបស់ខ្ញុំ* **គណ្ហន្តុ ឆលភុត្តមំ** *ចូរទទួលយកនូវផលដ៏ឧត្តមចុះ* **វេរិនោ ចេ បមុញ្ចន្តុ** *បើ (សត្វទាំងឡាយណា) មានពៀរនឹងគ្នា* **សព្វទោសំ ខមន្តុ មេ** *សូមសត្វទាំងឡាយអត់នូវទោសទាំងពួងដល់ខ្ញុំៗ*

សុខាភិយាចនគាថាសង្ខេប

(សូត្រក្នុងកាលចប់ធម៌ទេសនា ឬចប់ព្រះបរិត្ត)

បសន្នា ហោន្តុ សព្វេបិ ឋាណិនោ ពុទ្ធសាសនេ
សម្មា ធារំ បវេច្ឆន្តោ ការេ ទេវោ បវស្សតុ ។
ភុឌ្ឍិភាវាយ សត្តានំ សមិទ្ធំ នេតុ មេទនឹ
មាតា បិតា ច អត្រជំ និច្ចំ រក្ខន្តិ បុត្តកំ
ឯវំ ធម្មេន រាជានោ បជំ រក្ខន្តុ សព្វទា ។

ប្រែថា: **បសន្នា ហោន្តុ សព្វេបិ ឋាណិនោ ពុទ្ធសាសនេ** *សត្វទាំងឡាយទាំងពួង ចូរជ្រះថ្លាក្នុងព្រះពុទ្ធសាសនា,* **សម្មា ធារំ បវេច្ឆន្តោ ការេ ទេវោ បវស្សតុ ភុឌ្ឍិភាវាយ សត្តានំ សមិទ្ធំ នេតុ មេទនឹ** *សូមឱ្យភ្លៀងបង្អុរនូវធារទឹកដោយប្រពៃ ចូរបង្អុរចុះក្នុងកាលដ៏គួរ ចូរបណ្តាលឱ្យផែនដីសំរឹទ្ធី គឺថាឱ្យមានជីជាតិល្អឡើង ដើម្បីឱ្យកើតសេចក្តីចម្រើនដល់សត្វទាំងឡាយ,* **មាតា បិតា ច អត្រជំ និច្ចំ រក្ខន្តិ បុត្តកំ** *មាតាក្តី បិតាក្តី បីបាច់រក្សាជានិច្ចនូវកូនបង្កើតយ៉ាងណាមិញ,* **ឯវំ ធម្មេន រាជានោ បជំ រក្ខន្តុសព្វទា** *សូមព្រះបរមក្សត្រទាំងឡាយ*

រក្សានូវប្រជាជនតាមគន្ធង៍ធម៌ ដូចជាមាតាបិតាបីបាច់រក្សាកូនដូច្នោះ ឱ្យបានសព្វ កាលទៅហោង។

អនុមោទនារក្ខាយាចនគាថា

អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា
បុញ្ញំ នោ[1] អនុមោទន្តុ ចិរំ រក្ខន្តុ សាសនំ ។

ប្រែថា: ទេវតាទាំង៍ឋាយ ដែលឋិតឰដ៏អាកាសក្តី ដែលឋិតលើផែនដីក្តី នាគទាំង៍ឋាយដែលមានឫទ្ធិច្រើនក្តី សូមអនុមោទនានូវបុណ្យរបស់យើង៍ ទាំង៍ឋាយ សូមរក្សានូវព្រះពុទ្ធសាសនាឱ្យឋិតថេរ និង៍ឱ្យរង់រឿងយូរអង្វែង៍ទៅ។

អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា
បុញ្ញំ នោអនុមោទន្តុ ចិរំ រក្ខន្តុ រាជានោ ។

ប្រែថា: ទេវតាទាំង៍ឋាយដែលឋិតឰដ៏អាកាសក្តី ដែលឋិតលើផែនដីក្តី នាគទាំង៍ឋាយដែលមានឫទ្ធិច្រើនក្តី សូមអនុមោទនានូវបុណ្យរបស់យើង៍ទាំង៍ឋាយ សូមរក្សានូវព្រះរាជាទាំង៍ឋាយឱ្យឋិតក្នុង៍រាជ្យ និង៍ឱ្យមានជ័យជាយូរអង្វែង៍ទៅ។

អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា
បុញ្ញំ នោអនុមោទន្តុ ចិរំ រក្ខន្តុ ញាតយោ ។

ប្រែថា: ទេវតាទាំង៍ឋាយដែលឋិតឰដ៏អាកាសក្តី ដែលឋិតលើផែនដីក្តី នាគទាំង៍ឋាយដែលមានឫទ្ធិច្រើនក្តី សូមអនុមោទនានូវបុណ្យរបស់យើង៍ទាំង៍ឋាយ សូមរក្សានូវពួកញាតិទាំង៍ឋាយ (ឱ្យចម្រុង៍ចម្រើន និង៍ឱ្យសុខសាន្ត)ជាអង្វែង៍ទៅ។

១-**បុញ្ញំ នោ** បើសូធ្យម្នាក់ឯងត្រូវថា **បុញ្ញំ មេ** ប្រែថា បុណ្យរបស់ខ្ញុំ។

អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា
បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ ចាណិនោ ៗ

ប្រែថា: ទេវតាទាំងឡាយ ដែលឋិតឰដ៏អាកាសក្តី ដែលឋិតលើផែនដីក្តី នាគទាំងឡាយដែលមានឫទ្ធិច្រើនក្តី សូមអនុមោទនានូវបុណ្យរបស់យើងទាំង-ឡាយសូមរក្សានូវសត្វទាំងឡាយឱ្យចម្រុងចម្រើន និងឱ្យសុខសាន្តជាអង្វែងទៅ។

អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា
បុញ្ញំ នោ អនុមោទន្តុ ចិរំ រក្ខន្តុ នោសទា ៗ

ប្រែថា: ទេវតាទាំងឡាយ ដែលឋិតឰដ៏អាកាសក្តី ដែលឋិតលើផែនដីក្តី នាគទាំងឡាយដែលមានឫទ្ធិច្រើនក្តី សូមអនុមោទនានូវបុណ្យរបស់យើងទាំងឡាយ សូមរក្សានូវយើងទាំងឡាយ (ឱ្យចម្រុងចម្រើន និងឱ្យសុខសាន្ត) យូរយារគ្រប់កាលទាំងពួង។

តេជៈខ្ញុំសាង

តេជៈខ្ញុំសាង សំអិតសំអាង ឱនកាយវាចា
សូមសុខសុភាព រួចពីទុក្ខា ឆ្ងងដល់ត្រើយមហា
ពោលគឺនិព្វាន ។

គ្រប់ជាន់គ្រប់ជាតិ កុំឱ្យខ្ញុំឃ្លាត ពីសីលនិងទាន
គំនិតខ្ញុំកើត កំណើតខ្ញុំមាន មគ្គផលជាស្ពាន
ដល់ស្ថានថ្លៃថ្លា។

ខ្ញុំជូនមគ្គផល ចំពោះទៅដល់ មាតាបិតា
គុណគ្រូឧប- ជ្ឈាយាចារ្យ គុណញាតិកា
ប្រាំពីរសន្តាន។
ជីដូនជីតា រស់នៅក្តីណា លោកម្ចាស់ចែកឋាន
ខ្ញុំជូនមគ្គផល កុសលប្តើងប្តាន សូមសុខក្សេមក្សាន្ត
ដល់ស្ថានផុតទុក្ខ។

ពាក្យឧទ្ទិទានសសង្ខេប

ឥទំ ខោ ញាតីនំ ហោតុ សុខិតា ហោន្តុ ញាតយោ ។

វីទាននេះ ចូរមានដល់ញាតិទាំងឡាយ សូមញាតិទាំងឡាយ បានដល់នូវសេចក្តីសុខចុះ។ (បិដកលេខ ៥២ ទំព័រ ១៣ និងលេខ ៥៦ ទំព័រ ៤, ៧១)

ពាក្យឧទ្ទិសរបស់ជាណុសេឡ្ឋាណីព្រាហ្មណ៍

ឥទំ ទានំ មេតានំ ញាតិសាលោហិតានំ ខ្ឋបកប្បតុ ឥទំ ទានំ មេតា ញាតិសាលោហិតា បរិភុញ្ជន្តុ ។ *ទាននេះសូមឱ្យសម្រេចផលដល់ប្រេតទាំងឡាយ ជាញាតិសាលោហិត ពួកប្រេតទាំងឡាយជាញាតិសាលោហិត សូមបរិភោគនូវទាននេះ។*

(ពាក្យឧទ្ទិសរបស់ជាណុស្សោណិព្រាហ្មណ៍ ស្រង់ចាកជាណុស្សោណិសូត្រ
សុត្តន្តបិដក អង្គុត្តរនិកាយ ទសកនិបាត លេខ ៥១ ទំព័រ ១៣៥)

សព្វទិសាសុមេត្តាផរណា

(ការផ្សាយមេត្តាចិត្តដល់សព្វសត្វគ្រប់ទិស)

សព្វេ បុរត្ថិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ
សព្វេ បុរត្ថិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ
សព្វេ ទក្ខិណាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ
សព្វេ ទក្ខិណាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ
សព្វេ បច្ឆិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ
សព្វេ បច្ឆិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ
សព្វេ ឧត្តរាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ
សព្វេ ឧត្តរាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ
សព្វេ ឧបរិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ
សព្វេ ហេដ្ឋិមាយ[1] ទិសាយ សត្តា អវេរា សុខី ហោន្តុ
សព្វេ សត្តា អវេរា ហោន្តុ សុខិតា ហោន្តុ និទ្ទុក្ខា ហោន្តុ
អព្យាបជ្ឈា ហោន្តុ អនីឃា ហោន្តុ ទីឃាយុកា ហោន្តុ អរោគា ហោន្តុ
សម្បត្តីហិ សមិជ្ឈន្តុ សុខី អត្តានំ បរិហរន្តុ ។

ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា
សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ ។

(បិដកលេខ ៧១ ទំព័រ ៩៨)

(ពាក្យដើមមានក្នុង ហើយបុរាណលោកនិពន្ធបន្ថែមផង)

១-ក្នុងស្បៃវរភៅខ្លះ លោករៀបរៀងដាក់ **ហេដ្ឋិមាយ** មុន **ឧបរិមាយ** ។

ប្រែថា: **សព្វេ បុរត្ថិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ** *សូមពួកសត្វទាំងអស់ក្នុងទិសខាងកើត មិនមានពៀរនឹងគ្នា មានតែសេចក្តីសុខ។*

សព្វេ បុរត្ថិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ *សូមពួកសត្វទាំងអស់ក្នុងទិសអាគ្នេយ៍ មិនមានពៀរនឹងគ្នា មានតែសេចក្តីសុខ។*

សព្វេ ទក្ខិណាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ *សូមពួកសត្វទាំងអស់ក្នុងទិសខាងត្បូង មិនមានពៀរនឹងគ្នា មានតែសេចក្តីសុខ។*

សព្វេ ទក្ខិណាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ *សូមពួកសត្វទាំងអស់ក្នុងទិសនិរតី មិនមានពៀរនឹងគ្នា មានតែសេចក្តីសុខ។*

សព្វេ បច្ឆិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ *សូមពួកសត្វទាំងអស់ក្នុងទិសខាងលិច មិនមានពៀរនឹងគ្នា មានតែសេចក្តីសុខ។*

សព្វេ បច្ឆិមាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ *សូមពួកសត្វទាំងអស់ក្នុងទិសពាយ័ព្យ មិនមានពៀរនឹងគ្នា មានតែសេចក្តីសុខ។*

សព្វេ ឧត្តរាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ *សូមពួកសត្វទាំងអស់ក្នុងទិសខាងជើង មិនមានពៀរនឹងគ្នា មានតែសេចក្តីសុខ។*

សព្វេ ឧត្តរាយ អនុទិសាយ សត្តា អវេរា សុខី ហោន្តុ *សូមពួកសត្វទាំងអស់ក្នុងទិសឦសាន មិនមានពៀរនឹងគ្នា មានតែសេចក្តីសុខ។*

សព្វេ ឧបរិមាយ ទិសាយ សត្តា អវេរា សុខី ហោន្តុ *សូមពួកសត្វទាំងអស់ក្នុងទិសខាងលើ មិនមានពៀរនឹងគ្នា មានតែសេចក្តីសុខ។*

សព្ពេ ហេដ្ឋិមាយ[1] **ទិសាយ សត្តា អវេរា សុខី ហោន្តុ** *សូមពួកសត្វទាំងអស់ក្នុងទិសខាងក្រោម មិនមានពៀរនឹងគ្នា មានតែសេចក្តីសុខ។*

សព្ពេ សត្តា អវេរា ហោន្តុ សុខិតា ហោន្តុ និទ្ទុក្ខា ហោន្តុ *សូមពួកសត្វទាំងអស់កុំមានពៀរនឹងគ្នា សូមឱ្យបានសុខ សូមឱ្យប្រាសចាកទុក្ខ។*

អព្យាបជ្ឈា ហោន្តុ អនីឃា ហោន្តុ ទីឃាយុកា ហោន្តុ អរោគា ហោន្តុ សម្បត្តីហិ សមិជ្ឈន្តុ សុខី អត្តានំ បរិហរន្តុ *សូមកុំឱ្យព្យាបាទគ្នា សូមកុំឱ្យមានសេចក្តីចង្អៀនចង្អល់ចិត្ត សូមឱ្យមានអាយុវែង សូមកុំឱ្យមានរោគ សូមឱ្យសម្រេងដោយសម្បត្តិទាំងឡាយ សូមរក្សានូវខ្លួនឱ្យនៅជាសុខ(តទៅ)។*

ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា
សោកប្បត្តា ច និស្សោកា ហោន្តុ សព្ពេបិ បាណិនោ ៚

សត្វទាំងឡាយទាំងពួង ដែលកំពុង[2]*ដល់នូវសេចក្តីទុក្ខ សូមឱ្យជាសត្វបាត់សេចក្តីទុក្ខទៅ, ដែលកំពុងដល់នូវភ័យ សូមឱ្យជាសត្វបាត់ភ័យទៅ, ដែលកំពុងដល់នូវសេចក្តីសោក សូមឱ្យជាសត្វបាត់សេចក្តីសោកទៅ!។*

(បិដក ៧១ ទំព័រ ៩៨)

១-ក្នុងស្បៃវរភៅខ្លះ លោករៀបរៀងដាក់ **ហេដ្ឋិមាយ** “ទិសខាងក្រោម” មុន **ឧបរិមាយ** “ទិសខាងលើ” ។

២-សេចក្តីប្រែត្រង់នេះ ដែលធ្លាប់សូត្រកន្លងមកថា **“សត្វទាំងឡាយទាំងពួង ដែលដល់ហើយនូវសេចក្តីទុក្ខ ..., ដែលដល់ហើយនូវភ័យ..., ដែលដល់ហើយនូវសេចក្តីសោក”**។ តែក្នុងទីនេះខ្ញុំសរសេរតាមស្បៃវរភៅគហិបដិបត្តិ របស់ព្រះគ្រូវិមលប្បញ្ញា អ៊ុំ ស៊ូរ និងព្រះគ្រូសង្ឃសត្ថា ជួន ណាត ការផ្សាយរបស់ក្រសួងធម្មការ និងសាសនា ព.ស. ២៥៤៧ គ.ស. ២០០៣, ស្បៃវរភៅប្រជុំធម៌កិច្ចវត្ត ព្រឹក-ល្ងាច របស់សម្តេចព្រះសង្ឃរាជ ជួន ណាត (ជោតញ្ញាណោ) និងស្បៃវរភៅភិក្ខុប្បាតិមោក្ខ បាលី-ប្រែ របស់ព្រះគ្រូវិនយមុនី ប៉ុណ្យ សុម្ភាជ (ធម្មារាមោ) ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ព.ស.២៥៣៨ គ.ស.១៩៩៤ ។

ផ្សាយមេត្តាចិត្តដល់សព្វសត្វសព្វេប

ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា
សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ ៚

សត្វទាំងឡាយទាំងពួង ដែលកំពុងដល់នូវសេចក្តីទុក្ខ សូមឱ្យជាសត្វបាត់សេចក្តីទុក្ខទៅ, ដែលកំពុងដល់នូវភ័យ សូមឱ្យជាសត្វបាត់ភ័យទៅ, ដែលកំពុងដល់នូវសេចក្តីសោក សូមឱ្យជាសត្វបាត់សេចក្តីសោកទៅ!។

ពាក្យអធិដ្ឋានទាន

សុទិន្នំ វត នោ ទានំ សព្វសម្បត្តិសិទ្ធកំ និព្វានសច្ឆាតំ អាសវក្ខយាវហំ ហោតុ អនាគតេ កាលេ ៚

វិទានៃយើងទាំងឡាយនេះ ដែលបានបូជាហើយដោយប្រពៃ សូមឱ្យបានសម្រេចនូវសម្បត្តិទាំងពួង ទាំងសូមឱ្យបានជាបច្ច័យនាំមកនូវធម៌ ជាទីអស់ទៅនៃអាសវក្កិលេស គឺព្រះនិព្វាន ឰដ៏អនាគតកាលទៅខាងមុខនោះហោង។

មួយបែបទៀតថា


ឥទំ វត នោ បុញ្ញំ អាសវក្ខយាវហំ ហោតុ អនាគតេ កាលេ ៚

វិបុណ្យៃនៃយើងទាំងឡាយនេះ សូមឱ្យបានជាបច្ច័យ នាំមកនូវធម៌ ជាទីអស់ទៅនៃអាសវក្កិលេស គឺព្រះនិព្វាន ឰដ៏អនាគតកាលទៅខាងមុខនោះហោង។

ពាក្យអធិដ្ឋាន

*សូមឱ្យព្រះពុទ្ធសាសនារុងរឿងចម្រើន សូមឱ្យព្រះពុទ្ធសានាផ្សាយទូទៅពេញសកលលោក សូមឱ្យលោកទាំងមូលបានប្រកបដោយសន្តិភាព ព្រះសក្យមុនីសម្ពុទ្ធទ្រង់ត្រាស់ថា “***ន‌ត្ថិ សន្តិ បរំ សុខំ** ពុំមានសេចក្តីសុខដទៃ ក្រៅអំពីសេចក្តីស្ងប់ឡើយ”។*

ពាក្យឧទ្ទិសបុណ្យ
និងធម៌ផ្សាយមេត្តាចិត្តដល់សព្វសត្វ ចប់



ចតុប្បច្ចវេក្ខណវិធី

(វិធីពិចារណានូវបច្ច័យ ៤)

សេចក្តីពន្យល់

កុលបុត្រដែលបួសក្នុងព្រះពុទ្ធសាសនា ត្រូវសិក្សាក្នុង ***បច្ចវេក្ខណៈ*** *គឺធម៌សម្រាប់ពិចារណានូវបច្ច័យដែលខ្លួនត្រូវអាស្រ័យ ឱ្យចេះចាំស្ទាត់ទាំងបាលី និងសេចក្តីប្រែជាសម្រាយ, ឯបច្ច័យដែលបព្វជិតត្រូវអាស្រ័យនោះមាន ៤ គឺ* ***ចីវរប្បច្ច័យ*** *សំពត់ដែលបព្វជិតស្បៀកដណ្តប់ ប្រើប្រាស់បាន មានត្រៃចីវរជាដើម ១,* ***បិណ្ឌបាតប្បច្ច័យ*** *ភោជនាហារដែលបព្វជិតត្រូវបរិភោគបានតាំងពីអរុណរះឡើងដរាបថ្ងៃត្រង់ មានបាយ នំជាដើម១,* ***សេនាសនប្បច្ច័យ*** *ទីសេនាសនៈដែលបព្វជិតត្រូវអាស្រ័យប្រើប្រាស់បាន មានកុដិ សាលាជាដើម ១,* ***គិលានប្បច្ច័យ*** *ថ្នាំសម្រាប់មនុស្សមានជំងឺដែលបព្វជិតត្រូវបរិភោគប្រើប្រាស់បាន មានសប្បិជាដើម ។*

ក្នុងបច្ច័យមួយ ៗ នោះពោលដោយបច្ចវេក្ខណៈ គឺធម៌សម្រាប់ពិចារណាមានបួន ៗ គឺ ***ធាតុប្បច្ចវេក្ខណៈ១ បដិកូលប្បច្ចវេក្ខណៈ១ តង្វណិកប្បច្ចវេក្ខណៈ ១ អតីតប្បច្ចវេក្ខណៈ១*** *។*

ធាតុប្បច្ចវេក្ខណៈ

ធាតុប្បច្ចវេក្ខណៈនោះ គឺឱ្យពិចារណាក្នុងកាលដែលទទួលនូវបច្ច័យ ៤ ឱ្យឃើញថាជាធាតុ ។

កាលដែលទទួលនូវចីវរប្បច្ច័យ ឱ្យពិចារណាដូច្នេះថា:

យថា បច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ
យទិទំ ចីវរំ តទុបភុញ្ជកោ ច បុគ្គលោ
ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ ។

សំពត់ចីវរឯណានេះ សំពត់ចីវរនេះគ្រាន់តែជាធាតុពិត ប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ ទុកជាបុគ្គល គឺអាត្មាដែលជាអ្នកប្រើប្រាស់សំពត់ចីវរនោះក្តី ក៏គ្រាន់តែជាធាតុ មិនមែនសត្វ មិនមែនខ្លួនប្រាណមានសភាពសោះសូន្យទទេ ។

កាលដែលទទួលនូវបិណ្ឌបាតប្បច្ច័យ ឱ្យពិចារណាដូច្នេះថា:

យថាបច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ យទិទំ
បិណ្ឌបាតោ តទុបភុញ្ជកោ ច បុគ្គលោ
ធាតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ ។

ចង្ហាន់បិណ្ឌបាតឯណានេះ ចង្ហាន់បិណ្ឌបាតនេះ គ្រាន់តែជាធាតុពិត ប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ ទុកជាបុគ្គល គឺអាត្មាដែលជាអ្នកបរិភោគចង្ហាន់បិណ្ឌបាតនោះក្តី ក៏គ្រាន់តែជាធាតុ មិនមែនសត្វមិនមែនខ្លួនប្រាណមានសភាពសោះសូន្យទទេ។

កាលដែលទទួលនូវសេនាសនប្បច្ច័យ ឱ្យពិចារណាដូច្នេះថា:

យថាបច្ចយំ បវត្តមានំ ធាតុមត្តមេវេតំ យទិទំ

សេនាសនំ តទុបភុញ្ជាកោ ច បុគ្គលោ
ចតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ ៗ

ទីសេនាសនៈឯណានេះ ទីសេនាសនៈនេះ គ្រាន់ជាធាតុពិត ប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ ទុកជាបុគ្គល គឺអាត្មាដែលជាអ្នកបរិភោគប្រើប្រាស់ទីសេនាសនៈនោះក្តី ក៏គ្រាន់តែជាធាតុមិនមែនសត្វ មិនមែនខ្លួនប្រាណ មានសភាពសោះសូន្យទទេ។

កាលដែលទទួលនូវគិលានប្បច្ច័យ ឱ្យពិចារណាដូច្នេះថា:

យថាបច្ចយំ បវត្តមានំ ចតុមត្តមេវេតំ យទិទំ
គិលានប្បច្ចយភេសជ្ជបរិក្ខារោ តទុបភុញ្ជាកោ ច
បុគ្គលោ ចតុមត្តកោ និស្សត្តោ និជ្ជីវោ សុញ្ញោ ៗ

គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺឯណានេះ គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺនេះ គ្រាន់តែជាធាតុពិត ប្រព្រឹត្តទៅតាមសមគួរដល់បច្ច័យ ទុកជាបុគ្គល គឺអាត្មាដែលជាអ្នកបរិភោគគ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺនោះក្តី ក៏គ្រាន់តែជាធាតុមិនមែនសត្វ មិនមែនខ្លួនប្រាណ មានសភាពសោះសូន្យទទេ។

បដិកូលប្បច្ចវេក្ខណៈ

បដិកូលប្បច្ចវេក្ខណៈនោះគឺឱ្យពិចារណាក្នុងខណៈដែលប្រារព្ធនឹងបរិភោគនូវបច្ច័យ ៤ ឱ្យឃើញថាជារបស់បដិកូលគួរខ្ពើមរអើម។

កាលដែលប្រារព្ធនឹងប្រើប្រាស់នូវចីវរប្បច្ច័យ ឱ្យពិចារណាដូច្នេះថា:

សព្វានិ បនិមានិ ចីវរានិ អជិគុច្ឆនីយានិ ឥមំ
បូតិកាយំ បត្វា អតិវិយ ជិគុច្ឆនីយានិ ជាយន្តិ ។

សំពត់ចីវរទាំងឡាយទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើមឡើយ លុះពាល់ត្រូវដល់កាយស្អុយនេះកាលណាហើយ ក៏កើតជារបស់គួរខ្ពើមរអើមក្រៃពេក។

កាលដែលប្រារព្ធនឹងបរិភោគនូវបិណ្ឌបាតប្បច្ចយឱ្យពិចារណាដូច្នេះថា:

សព្ពោ បនាយំ បិណ្ឌបាតោ អជិគុច្ឆនីយោ ឥមំ
បូតិកាយំ បត្វា អតិវិយ ជិគុច្ឆនីយោ ជាយតិ ។

ចង្ហាន់បិណ្ឌបាតទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើមឡើយ លុះពាល់ត្រូវដល់កាយស្អុយនេះកាលណាហើយ ក៏កើតជារបស់គួរខ្ពើមរអើមក្រៃពេក។

កាលដែលប្រារព្ធនឹងបរិភោគប្រើប្រាស់នូវសេនាសនប្បច្ច័យ ឱ្យពិចារណាដូច្នេះថា:

សព្វានិ បនិមានិ សេនាសនានិ អជិគុច្ឆនីយានិ
ឥមំ បូតិកាយំ បត្វា អតិវិយ ជិគុច្ឆនីយានិ ជាយន្តិ ។

ទីសេនាសន:ទាំងឡាយទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើមឡើយ លុះពាល់ត្រូវដល់កាយស្អុយនេះកាលណាហើយ ក៏កើតជារបស់គួរខ្ពើមរអើមក្រៃពេក។

កាលដែលប្រារព្ធនឹងបរិភោគនូវគិលានប្បច្ច័យឱ្យពិចារណាដូច្នេះថា:

សព្ពោ បនាយំ គិលានប្បច្ចយភេសជ្ជ-
បរិក្ខារោ អជិគុច្ឆនីយោ ឥមំ បូតិកាយំ
បត្វា អតិវិយ ជិគុច្ឆនីយោ ជាយតិ ។

គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺទាំងពួងនេះ ជារបស់មិនគួរខ្ពើមរអើមឡើយ លុះពាល់ត្រូវដល់កាយស្អុយនេះកាលណាហើយ ក៏កើតជារបស់គួរខ្ពើមរអើមក្រៃពេក។

តទុណិកប្បច្ចវេក្ខណៈ

(បិដកលេខ ២០ ទំព័រ ៣១)

តទុណិកប្បច្ចវេក្ខណៈនោះ គឺឱ្យពិចារណាក្នុងខណៈដែលបរិភោគនូវបច្ច័យ ៤។

កាលដែលប្រើប្រាស់នូវចីវរប្បច្ច័យឱ្យពិចារណាដូច្នេះថា:

បដិសង្ខា យោនិសោ ចីវរំ បដិសេវាមិ យាវទេវ
សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ
ឌំស មកស វាត តប សិរីសប សម្ផស្សានំ បដិ-
ឃាតាយ យាវទេវ ហិរិកោបីនប្បដិច្ឆាទនត្ថំ ។

បព្វជិតគប្បីពិចារណាដោយឧបាយថា អញអាស្រ័យសេព គឺប្រើប្រាស់នូវសំពត់ចីវរកំណត់ទុក ដើម្បីនឹងការពារនូវត្រជាក់ ដើម្បីនឹងការពារនូវកម្តៅ ដើម្បីនឹងការពារនូវសម្ផស្ស នៃរបោមមូសខ្យល់ កម្តៅថ្ងៃ និងពស់តូចពស់ធំទាំងឡាយ កំណត់ទុកដើម្បីនឹងបិទបាំងនូវអវយវៈដែលធ្វើនូវសេចក្តីខ្មាសឱ្យកម្រើក។

កាលដែលបរិភោគនូវបិណ្ឌបាតប្បច្ច័យឱ្យពិចារណាដូច្នេះថា

បដិសង្ខា យោនិសោ បិណ្ឌបាតំ បដិសេវាមិ នេវ
ទវាយ ន មទាយ ន មណ្ឌនាយ ន វិភូសនាយ

យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ
វិហឹសុបរតិយា ព្រហ្មចរិយានុគ្គហាយ ឥតិបុរាណញ្ច
វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បាទេស្សាមិ
យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ ។

បព្វជិតគប្បីពិចារណាដោយឧបាយថា អញអាស្រ័យសេពគឺបរិភោគចង្ហាន់បិណ្ឌបាត ដើម្បីនឹងលេងដូចក្មេងអ្នកស្រុកក៏ទេ ដើម្បីនឹងឱ្យកើតបុរិសមានះស្រវឹងដូចអ្នកប្រដាល់ក៏ទេ ដើម្បីនឹងប្រដាប់តាក់តែងរាងកាយដូចស្ត្រីក្នុងបុរីក៏ទេ ដើម្បីនឹងធ្វើឱ្យផ្ទរផង់សម្បុរដូចអ្នកលេងរបាំក៏ទេ បរិភោគកំណត់ទុកដើម្បីនឹងឱ្យតាំងនៅនៃកាយនេះ ដើម្បីនឹងញ៉ាំងជីវិតន្ទ្រើយ៍ឱ្យប្រព្រឹត្តទៅ ដើម្បីនឹងបំបាត់បង់នូវសេចក្តីលំបាក ដើម្បីនឹងអនុគ្រោះដល់ព្រហ្មចរិយធម៌ អញនឹងកម្ចាត់បង់នូវវេទនាចាស់ គឺសេចក្តីឃ្លានដែលមានហើយផង នឹងញ៉ាំងវេទនាថ្មី គឺឆ្អែតហួសប្រមាណមិនឱ្យកើតឡើងបានផង កិរិយាប្រព្រឹត្តទៅនៃឥរិយាបថទាំង ៤ក្តី សេចក្តីមិនមានទោស មានមិនច្រអូសកាយ មិនច្រអូសចិត្តជាដើមក្តី កិរិយានៅសប្បាយក្នុងឥរិយាបថទាំង ៤ ក្តី នឹងមានដល់អញដោយបានបរិភោគនូវចង្ហាន់បិណ្ឌបាតនេះ។

កាលដែលបរិភោគប្រើប្រាស់នូវសេនាសនប្បច្ច័យឱ្យពិចារណាដូច្នេះថា:

បដិសង្ខា យោនិសោ សេនាសនំ បដិសេវាមិ
យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស
បដិឃាតាយ ឌំស មកស វាត តប សិរឹសប

សម្ផស្សានំ បដិឃាតាយ យាវទេវ ខុតុបរិស្សយ
ភិនោទនំ បដិសល្លានារាមត្តំ ៗ

បពូជិតគប្បីពិចារណាដោយឧបាយថា អញអាស្រ័យសេព គឺបរិភោគប្រើ-ប្រាស់នូវទីសេនាសន:កំណត់ទុក ដើម្បីនឹងការពារនូវត្រជាក់ ដើម្បីនឹងការពារនូវកម្តៅ ដើម្បីនឹងការពារនូវសម្ផស្សនៃរបោម មូស ខ្យល់ កម្តៅថ្ងៃ និងពស់តូចពស់ធំទាំងឡាយ កំណត់ទុកដើម្បីនឹងបន្ទោបង់នូវក្រវល់ក្រវាយ ដែលកើតអំពីរដូវហើយអភិរម្យសម្ងំនៅក្នុងកម្មដ្ឋាន ។

កាលដែលបរិភោគនូវគិលានប្បច្ច័យ ឱ្យពិចារណាដូច្នេះថា:

បដិសង្ខា យោនិសោ គិលានប្បច្ចយភេសជ្ជបរិក្ខារំ
បដិសេវាមិ យាវទេវ ឧប្បន្នានំ វេយ្យាពាធិកានំ
វេទនានំ បដិឃាតាយ អព្យាបជ្ឈបរមតាយាតិ ៗ

បពូជិតគប្បីពិចារណាដោយឧបាយថា អញអាស្រ័យសេព គឺបរិភោគនូវគ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺ កំណត់ទុកដើម្បីនឹងការពារនូវវេទនាទាំងឡាយ ដែលបៀតបៀនផ្សេង ។ ដែលកើតឡើងហើយ ដើម្បីប្រាសចាកទុក្ខខ្លាំងជាធម្មតា ។

អតីតប្បច្ចវេក្ខណៈ

អតីតប្បច្ចវេក្ខណ:នោះ គឺឱ្យពិចារណានូវបច្ច័យ ៤ ក្នុងអតីតកាល គឺកាលដែលបរិភោគរួចហើយ ដែលត្រូវពិចារណាបានតែក្នុងថ្ងៃនោះ គឺក្នុងវេលាយប់ ១ ថ្ងៃ ១ កុំឱ្យអរុណរះឡើងទាន់, ក្នុងបច្ចវេក្ខណ:មួយ ។ ពិចារណា ១ ចប់ ឬ ២ ចប់

៣ ចប់ក៏បាន។

កាលដែលនឹងពិចារណានូវចីវរប្បច្ចុយ្យ ឱ្យពិចារណាដូច្នេះថា៖

អជ្ជ មយា អប្បច្ចវេក្ខិត្វា យំ ចីវរំ បរិភុត្តំ តំ យាវទេវ សីតស្ស បដិឃាតាយ ឧណ្ហស្ស បដិឃាតាយ ឌំស មកស វាត តប សិរីសប សម្ផស្សានំ បដិឃាតាយ យាវទេវ ហិរិកោបី-ន្ទប្បដិច្ឆាទនត្ថំ ។

សំពត់ចីវរឯណា ដែលអញមិនបានពិចារណា ហើយប្រើប្រាស់ ហើយក្នុងថ្ងៃនេះ សំពត់ចីវរនោះ អញប្រើប្រាស់កំណត់ទុក ដើម្បីនឹងការពារនូវត្រជាក់ ដើម្បីនឹងការពារនូវកម្តៅ ដើម្បីនឹងការពារនូវសម្ផស្សនៃរបោម មូស ខ្យល់ កម្តៅថ្ងៃ និងពស់តូចពស់ធំទាំងឡាយកំណត់ទុក ដើម្បីនឹងបិទបាំងនូវអវយវៈ ដែលធ្វើនូវសេចក្តីខ្មាសឱ្យកម្រើក។

កាលដែលនឹងពិចារណានូវបិណ្ឌបាតប្បច្ចុយ្យ ឱ្យពិចារណាដូច្នេះថា៖

អជ្ជ មយា អប្បច្ចវេក្ខិត្វា យោ បិណ្ឌបាតោ បរិភុត្តោ សោ នេវ ទវាយ ន មទាយ ន មណ្ឌនាយ ន វិភូសនាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ វិហឹសុបរតិយា ព្រហ្មចរិយានុគ្គហាយ ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បា-ទេស្សាមិ យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ ។

ចង្ហាន់បិណ្ឌបាតឯណា ដែលអញមិនបានពិចារណាហើយ បរិភោគ ហើយក្នុងថ្ងៃនេះ ចង្ហាន់បិណ្ឌបាតនោះ អញបរិភោគដើម្បីនឹងលេងដូចក្មេងអ្នក-ស្រុកក៏ទេ ដើម្បីនឹងឱ្យកើតបុរិសមានៈស្រឹងដូចអ្នកប្រដាល់ក៏ទេ ដើម្បីនឹងប្រដាប់តាក់តែងពងកាយដូចស្ត្រីក្នុងបុរីក៏ទេ ដើម្បីនឹងធ្វើឱ្យផូរផង់សម្បុរដូចអ្នកលេងរបាំក៏ទេ បរិភោគកំណត់ទុក ដើម្បីនឹងឱ្យតាំងនៅនៃកាយនេះ ដើម្បីនឹងញុំាងជីវិត-ន្ទ្រីយ៍ឱ្យប្រព្រឹត្តទៅ ដើម្បីនឹងបំបាត់បង់នូវសេចក្តីលំបាក ដើម្បីនឹងអនុគ្រោះដល់ព្រហ្មចរិយធម៌ អញនឹងកម្ចាត់បង់នូវវេទនាចាស់ គឺសេចក្តីឃ្លានដែលមានហើយផង នឹងញុំាងវេទនាថ្មី គឺឆ្អែតហួសប្រមាណមិនឱ្យកើតឡើងបានផង កិរិយាប្រព្រឹត្តទៅនៃឥរិយាបថទាំង ៤ ក្តី សេចក្តីមិនមានទោស មានមិនច្រអូសកាយ មិនច្រអូសចិត្តជាដើមក្តី កិរិយានៅសប្បាយក្នុងឥរិយាបថទាំង ៤ ក្តី នឹងមានដល់អញ ដោយបានបរិភោគនូវចង្ហាន់បិណ្ឌបាតនោះ។

កាលដែលនឹងពិចារណានូវសេនាសនប្បច្ច័យឱ្យពិចារណាដូច្នេះថា:

អជ្ជ មយា អប្បច្ចវេក្ខិត្វា យំ សេនាសនំ
បរិភុត្តំ តំ យាវទេវ សីតស្ស បដិឃាតាយ
ឧណ្ហស្ស បដិឃាតាយ ឌំស មកស វាតាតប
សិរីសប សម្ផស្សានំប ដិឃាតាយ យាវទេវ
ឧតុបរិស្សយវិនោទនំ បដិសល្លានារាមត្ថំ ។

ទីសេនាសនៈឯណា ដែលអញមិនបានពិចារណា ហើយបរិភោគប្រើប្រាស់ ហើយក្នុងថ្ងៃនេះ ទីសេនាសនៈនោះ អញបរិភោគកំណត់ទុក ដើម្បីនឹងការពារនូវ

ត្រជាក់ ដើម្បីនឹងការពារនូវកម្តៅ ដើម្បីនឹងការពារនូវសម្ផស្សនៃរបោម មូសខ្យល់ កម្តៅថ្ងៃ និងពស់តូចពស់ធំទាំងឡាយ កំណត់ទុកដើម្បីនឹងបន្ទោបង់នូវក្រវល់ក្រវាយដែលកើតអំពីរដូវហើយអភិរម្យសម្ងំនៅក្នុងកម្មដ្ឋាន។

កាលដែលនឹងពិចារណានូវគិលានប្បច្ចយ ឱ្យពិចារណាដូច្នេះថា:

អជ្ជ មយា អប្បច្ចវេក្ខិត្វា យោ គិលានប្បច្ចយ-
តេសជ្ជបរិក្ខារោ បរិភុត្តោ សោ យាវទេវ
ឧប្បន្នានំ វេយ្យាពាធិកានំ វេទនានំ បដិឃាតាយ
អព្យាបជ្ឈបរមតាយាតិ។

គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺឯណា ដែលអញមិនបានពិចារណាហើយ បរិភោគហើយក្នុងថ្ងៃនេះ គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺនោះ អញបរិភោគកំណត់ទុក ដើម្បីនឹងការពារនូវវេទនាទាំងឡាយ ដែលបៀតបៀនផ្សេងៗ ដែលកើតឡើងហើយ ដើម្បីប្រាសចាកទុក្ខខ្លាំងជាធម្មតា។

សេចក្តីបញ្ជាក់

បើកាលដែលទទួល និងកាលដែលប្រារព្ធដើម្បីនឹងបរិភោគ និងកាលដែលបរិភោគនោះបានពិចារណាដោយ***ជាតុប្បច្ចវេក្ខណៈ*** ដោយ***បដិកូលប្បច្ចវេក្ខណៈ*** ដោយ***តទ្ធណិកប្បច្ចវេក្ខណៈ*** រួចសព្វគ្រប់ហើយ នឹងមិនបាច់ពិចារណាក្នុង***អតីតប្បច្ចវេក្ខណៈ***ទៀតក៏បានដែរ។

ក្នុងការបរិភោគប្រើប្រាស់នូវបច្ច័យទាំង ៤ នេះ ត្រូវពិចារណាក្នុងកាលទាំង ៣ គឺ **បដិលាភកាល** កាលដែលកំពុងបាន ឬកំពុងទទួលនូវបច្ច័យ ១ **បរិភោគកាល** កាលដែលកំពុងបរិភោគប្រើប្រាស់នូវបច្ច័យ ១ **បច្ឆាកាល** ឬ **អតីតកាល** កាលជាខាងក្រោយអំពីកាលដែលបរិភោគប្រើប្រាស់នូវបច្ច័យរួចហើយ ១ ។

បណ្តាកាលទាំង ៣ នោះ ក្នុងបដិលាភកាល គឺកាលដែលបាន ឬទទួលបច្ច័យមក ត្រូវពិចារណាដោយជាតុប្បច្ចវេក្ខណៈថា **យថា បច្ចយំ បវត្តមានំ** ។ល។ ដូច្នេះក៏បាន, ឬពិចារណាដោយបដិកូលប្បច្ចវេក្ខណៈថា **សព្វានិ បនិមានិ ចីវរានិ** ។ល។ ដូច្នេះក៏បាន, ពិចារណាបែបនេះសូម្បីតែ ១ ចប់ក៏បានដែរ ។

មែនពិត បច្ច័យដែលភិក្ខុទទួលមក ដោយបានពិចារណាយ៉ាងនេះ ដល់វេលាបរិភោគតទៅមិនមានទោសឡើយ ដូចជាការប្រើប្រាស់បាត្រ និងចីវរដែលភិក្ខុបានអធិដ្ឋានរួចហើយដូច្នោះដែរ បាត្រ និងចីវរដែលភិក្ខុបានអធិដ្ឋានតែ ១ លើកដំបូងហើយ កាលបើមិនមានហេតុដែលគួរឱ្យដាច់អធិដ្ឋានទេ ភិក្ខុត្រូវប្រើប្រាស់រហូតតទៅមិនបាច់អធិដ្ឋានទៀតឡើយ ។ ពាក្យដែលពោលមកនេះ គ្រាន់តែជាប្រធាន ក្នុងការសម្តែងឱ្យឃើញសេចក្តីបរិសុទ្ធិក្នុងខាងដើមនៃការពិចារណាប៉ុណ្ណោះ មិនមែនជាប្រធានក្នុងការហាមឃាត់មិនឱ្យពិចារណាក្នុងបរិភោគកាលទេ ។ ព្រោះហេតុនោះ ក្នុងបរិភោគកាលក៏ត្រូវឱ្យភិក្ខុពិចារណាថែមទៀត ។ ក្នុងបរិភោគកាលនោះ ត្រូវភិក្ខុពិចារណាដំណាលគ្នានឹងការបរិភោគប្រើប្រាស់ដោយតំខណិកប្បច្ចវេក្ខណៈថា **បដិសង្ខា យោនិសោ ចីវរំ បដិសេវាមិ** ។ល។ ដូច្នេះជា

ដើម។

ក្នុងតំខណិកប្បវេក្ខណៈនេះ ត្រូវឱ្យភិក្ខុពិចារណាក្នុងចីវរប្បច្ច័យឱ្យរាល់ៗ ប្រយោគដែលប្រើប្រាស់, ក្នុងបិណ្ឌបាតប្បច្ច័យឱ្យរាល់ពំនូត ឬរាល់ម៉ាត់ដែលបរិភោគ, ក្នុងសេនាសនប្បច្ច័យ ឱ្យរាល់ប្រយោគដែលប្រើប្រាស់ ឬរាល់វារៈដែលចូលទៅ គឺត្រូវពិចារណាក្នុងកាលជាទីចូលទៅខាងក្នុង តាំងពីត្រឹមរងទឹកវៀងទៅនិងក្នុងកាលជាទីអង្គុយ ឬកាលដែលដេក។

បើក្នុងបរិភោគកាល ភិក្ខុមិនអាចពិចារណាបានទេ តអំពីបរិភោគកាលនោះទៅ ត្រូវពិចារណាក្នុងបច្ចាកាលដោយអតីតបច្ចវេក្ខណៈថា **អជ្ជ មយា អប្បច្ច-វេក្ខិត្វា យំ ចីវរំ បរិភុត្តំ** ។ល។ ដូច្នេះជាដើម សូម្បីពិចារណាត្រឹមតែ ១ ចប់ក៏បាន។

នៃយមួយទៀត លោកសម្តែងថា បើភិក្ខុមិនអាចពិចារណាក្នុងបរិភោគកាលដោយតំខណិកប្បច្ចវេក្ខណៈបានទេ គប្បីពិចារណាដោយអតីតប្បច្ចវេក្ខណៈតាមកាលពិសេសផ្សេងអំពីកាលដែលបានពោលមកហើយ គឺតាំងពីត្រឹមបរិភោគកាលទៅខាងនាយទោះកាលមុនភត្តក្តី កាលក្រោយភត្តក្តី យាម ៣ នៃរាត្រីក្តី ឱ្យតែនៅក្នុងរវាងថ្ងៃមួយនោះ ហើយពិចារណា ៤ ចប់ក៏បាន ៣ ចប់ក៏បាន ២ ចប់ក៏បាន ឬត្រឹមតែ ១ ចប់ក៏បាន ប៉ុន្តែធ្វើបែបនេះ គួរតែក្នុងបច្ច័យ ៣ ខាងដើមប៉ុណ្ណោះ, ឯភេសជ្ជប្បច្ច័យវិញ ក្នុងបដិលាភកាល ទោះបីភិក្ខុបានពិចារណាក្តី មិនបានពិចារណាក្តី ដល់មកបរិភោគកាលត្រូវតែពិចារណាខានមិនបាន ដ្បិត

កេសជ្ជប្បច្ច័យនេះ លោកលើកយកតំខណិកប្បច្ចវេក្ខណៈជាធំក្នុងការពិចារណា។ ព្រោះព្រះអដ្ឋកថាចារ្យលោកពោលទុកថា កេសជ្ជប្បច្ច័យ ត្រូវតែភិក្ខុផ្ចង់ស្មារតីពិចារណាក្នុងកាលដែលទទួលផង ក្នុងកាលដែលបរិភោគផងទើបគួរ, កាលបើភិក្ខុពិចារណាតែក្នុងកាលដែលទទួល ដល់មកក្នុងកាលដែលបរិភោគមិនបានពិចារណាសោះនឹងត្រូវអាបត្តិទុក្កដ។ បើបែរជាមិនបានពិចារណាក្នុងកាលដែលទទួលទេ ហើយបានពិចារណាក្នុងកាលដែលបរិភោគ នឹងមិនត្រូវអាបត្តិឡើយ, តែថ្វីបើដូច្នោះ ក៏គួរតែភិក្ខុប្រុងស្មារតីពិចារណាក្នុងកាលទាំងពីរនោះកុំខាន។

*ពាក្យថា "**បច្ចវេក្ខណៈ** ការពិចារណា" នេះ មានសេចក្តីថា ការរំពឹង ត្រឹះរិះ សង្កេតពិនិត្យ ឈ្ងុចឈ្ងី លំអិតសេចក្តីឱ្យយល់ជាក់ដោយបញ្ញា គឺការឃើញទោស និងអានិសង្សនៃបច្ច័យនោះៗ មិនមែនគ្រាន់តែសូត្យ ឬថាដោយពុំដឹងសេចក្តីថាអ្វីជាអ្វីនោះទេ។ ដូច្នេះទើបត្រូវសិក្សាឱ្យបានចេះចាំទាំងបាលី និងសេចក្តីប្រែផងទើបយល់ន័យសេចក្តីបានល្អ, បើពុំដូច្នោះទេ ទោះបីខំសូត្យមួយថ្ងៃដប់ដង ឬទាំងរយទាំងពាន់ដង ក៏មិនកើតជាការដែរ ព្រោះថា **បច្ចយសន្និស្សិតសីល** នេះ បរិសុទ្ធិដោយបញ្ញា។*

(ដកស្រង់ពីសាមណេរវិនិយ របស់ព្រះគ្រូសង្ឃសត្ថា ជួន-ណាត
ព្រះគ្រូសង្ឃវិជ្ជា ហួត-តាត និងព្រះគ្រូវិមលប្បញ្ញោ អ៊ុំ-ស៊ូរ
និងស្បៃវរៅអធិប្បាយចតុប្បារិសុទ្ធិសីល
របស់ព្រះចន្ទមង្គលោ កិម-តួរ ដើម

ចប់ចតុប្បច្ចវេក្ខណវិធី

អនុមោទនាវិធី

(វិធីធ្វើអនុមោទនាទាន)

សេចក្តីពន្យល់

*ការធ្វើអនុមោទនាកត្ត គឺជាវត្ត ឬជាទំនៀមដែលព្រះសង្ឃត្រូវធ្វើ ក្រោយពេលដែលទទួល ឬឆាន់នូវភត្តស្រេចហើយ តាមដែលព្រះពុទ្ធអង្គទ្រង់អនុញ្ញាតទុកក្នុងវត្តក្ខន្ធក: បិដកលេខ ១១ ទំព័រ ១០៦ ដូច្នេះថា "**អនុជានាមិ ភិក្ខវេ ភត្តគ្គេ អនុមោទិតុំ** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុធ្វើអនុមោទនាក្នុងរោងភត្ត" ។ ហើយកិច្ចដែលត្រូវធ្វើអនុមោទនានេះ ព្រះអង្គទ្រង់អនុញ្ញាតឱ្យជាការ:របស់ភិក្ខុជាថេរ: តែបើព្រះថេរ:អនុញ្ញាតឱ្យអនុថេរក៏គួរដែរ ឥតមានទោសទេ ។ សេចក្តីលម្អិតសូមមើលក្នុងបិដកអដ្ឋកថា និងដីកាបន្ថែមទៀតចុះ។*

*ក៏ការធ្វើអនុមោទនានោះទៀតសោត គឺត្រូវធ្វើឱ្យត្រូវទៅតាមកិច្ចពិធីរបស់ម្ចាស់ទានផង គឺថាបើគេធ្វើពិធីអ្វីក៏ត្រូវធ្វើអនុមោទនានូវធម៌ណាដែលទាក់ទងនឹងពិធីនោះ ព្រោះការធ្វើអនុមោទនានេះព្រះអដ្ឋកថាចារ្យលោកសម្តែងទុកក្នុងសមន្តប្បាសាទិកា ត្រង់ឱវាទវគ្គ ក្នុងសិក្ខាបទទី ១ ថា "**សច្ឆភត្តមង្គលាមង្គលេសុ អនុមោទនត្ថាយ តិសេ្សា អនុមោទនា** ភិក្ខុជាពហុស្សូត គប្បីរៀនគាថា ៣ យ៉ាង ដើម្បីប្រយោជន៍អនុមោទនាក្នុងសង្ឃភត្ត ការងារមង្គល និងអវមង្គល" ។ ហើយព្រះដីកាចារ្យទាំងឡាយក៏ពន្យល់បន្ថែមទៀត ដូចមានសេចក្តីខាងក្រោមនេះ។*

ក្នុងគម្ពីរសារត្ថទីបនីដីកា ពាលី ភាគ ៣ ទំព័រ ៤៩ ពន្យល់ថា:

តិសេ្ឋ អនុមោទនាតិ សច្ឆវតេ្តនានានិសំសប្បដិសំយុត្តអនុមោទនា, ទិហារាទិមណ្ឌលេ មណ្ឌលសុត្តាទិអនុមោទនា, មតកភត្តាទិអវមណ្ឌលេ តិរោកុឌ្ឌាទិ-អនុមោទនាតិ ឥមា តិសេ្ឋ អនុមោទនា ។

ពាក្យថា អនុមោទនា ៣ យ៉ាង គឺអនុមោទនាប្រកបដោយអានិសង្សនៃទាន ក្នុងសង្ឃភត្ត ១, អនុមោទនាដោយមង្គលសូត្រជាដើមក្នុងការងារមង្គល មាន មង្គលទាក់ទងនឹងវិហារជាដើម ១, អនុមោទនាដោយតិរោកុឌ្ឌសូត្រជាដើម ក្នុង ការងារអពមង្គល មានមតកភត្ត (ភត្តសម្រាប់អ្នកស្លាប់) ជាដើម ១។

ក្នុងគម្ពីរវិមតិវិនោទនីដីកា ពាលី ភាគ ២ ទំព័រ ២៦ ពន្យល់ថា

តិសេ្ឋ អនុមោទនាតិ សច្ឆវតា្តទីសុ ទានានិសំសប្បដិយុត្តា និធិកណ្ឌ-សុត្តាទិអនុមោទនា, គេហប្បវេសមណ្ឌលាទីសុ មណ្ឌលសុត្តាទិអនុមោទនា, មតកភ-ត្តាទិអមណ្ឌលេសុ តិរោកុឌ្ឌាទិអនុមោទនាតិ ឥមា តិសេ្ឋ អនុមោទនា ។

ពាក្យថា អនុមោទនា ៣ យ៉ាង បានដល់អនុមោទនាទាំង ៣ យ៉ាងនេះ គឺ ការអនុមោទនាដោយនិធិកណ្ឌសូត្រជាដើម ដែលប្រកបដោយអានិសង្សនៃទាន ក្នុងភត្តទាំងឡាយ មានសង្ឃភត្តជាដើម ១, ការអនុមោទនាដោយមង្គលសូត្រ ជាដើម ក្នុងមង្គលទាំងឡាយ មានគេហប្បវេសមង្គល (មង្គលជាទីចូលទៅកាន់ ផ្ទះ គឺឡើងផ្ទះថ្មី) ជាដើម ១, ការអនុមោទនាដោយតិរោកុឌ្ឌសូត្រជាដើម ក្នុង ការងារមិនមែនជាមង្គលទាំងឡាយ មានមតកភត្តជាដើម ១។

ក្នុងគម្ពីរវិនយវិនិច្ឆយដីកា ឈ្មោះវិនយត្ថសារសន្ទីបនី ពាលី ភាគ ១ ទំព័រ

៣៨២ ពន្យល់បន្ថែមទៀតថា:

មង្គល ៗ បេ ៗ អនុមោទនាតិ អត្ថស្ស ឥតិ ឥមិនា មង្គលេសុ តត្ថានុមោទនា-សទ្ទោ តានកថា ច, កុមារមង្គលាទីសុ មហាមង្គលសុត្តាទិមង្គលានុមោទនា ច, អមង្គលំ នាម ការណកិរិយា, តត្ថ មតកភត្តាទីសុ តិរោកុដ្ដាទិកថាចាតិ ឯវំ តិសេ្សាយេវានុមោទនាៗ

ពាក្យថា អនុមោទនា (ជាមង្គល និងអមង្គល) បានដល់អនុមោទនាតែ ៣ យ៉ាងនេះប៉ុណ្ណោះគឺ ទានកថា (រាថាជាគ្រឿងពោលអំពីទាន) ពោលគឺការអនុមោ-ទនានូវកត្តក្នុងមង្គលទាំងឡាយមានការឱ្យទានជាដើមដល់បុគ្គលដ៏ប្រសើរ ១, ការ អនុមោទនានូវមង្គលដោយមហាមង្គលសូត្រជាដើម ក្នុងមង្គលទាំងឡាយ មាន មង្គលនៃកុមារ (ដូចជាការដាក់ឈ្មោះ, ចោះត្រចៀក, ធ្វើនូវជុក ឬបង្កក់កួន) ជា ដើម ១, ការធ្វើនូវមរណកាល ឈ្មោះថា អមង្គល, ការពោលនូវសូត្រ មានតិរោ-កុឌ្ដសូត្រជាដើម ក្នុងភត្តទាំងឡាយ មានមតកភត្តជាដើម ក្នុងទីមិនមែនជាមង្គល ១ៗ

សូមបញ្ជាក់ថា ការធ្វើអនុមោទនានេះ យើងអាចធ្វើបាន ២ បែប គឺ ៖

*១-**បែបសម្តែងជាទេសនា** ដោយលើកយកនូវសូត្រ ឬគាថាណាមួយមក សម្តែង,*

*២-**បែបសាធ្យាយ (សូធ្យ)** ដូចដែលធ្លាប់សូធ្យសព្វថ្ងៃនេះ ។*

ក្នុងការធ្វើទាំងពីរបែបខាងលើនេះ ត្រូវធ្វើឱ្យត្រូវនឹងកិច្ចពិធីបុណ្យគេផង កុំ ឱ្យដូចជារឿងលោឡុទាយិកិក្ខុដែលមានសម្តែងក្នុងគម្ពីរធម្មបទត្រង់ជាវគ្គនោះ ។

ក្នុងសេចក្តីខាងលើនេះមិនមែនមានន័យថា មិនអាចធ្វើអនុមោទនាដោយធម៌ដទៃបាននោះទេ គឺថាសូម្បីធ្វើអនុមោទនាដោយធម៌ដទៃទៀតក៏បានខ្លះដែរ គឺ:

-*ដោយតម្រូវទៅតាមអធ្យាស្រ័យ គឺការពេញចិត្តរបស់ម្ចាស់ទាន,*

-*ដោយតម្រូវទៅតាមប្រភេទនៃបុគ្គល,*

ដូចដែលមានសម្តែងក្នុងបឋមសមន្តប្បាសាទិកា ត្រង់រឿងព្រះបាទធម្មាសោក និងព្រះនិគ្រោធសាមណេរថា«កាលដែលលោកធ្វើភត្តកិច្ចស្រេចហើយបានពោលនូវអប្បមាទវគ្គក្នុងធម្មបទដែលមានជាអាទិ៍ថា "**អប្បមាទ អមតំ បទំ បមាទោ មច្ចុនោ បទំ**" តាមសមគួរដល់ព្រះរាជា ដើម្បីប្រយោជន៍ដល់ការអនុមោទនា» ។

ក្នុងសារត្ថទីបនីដីកាពន្យល់ថា "***ពាក្យថា តាមសមគួរដល់ព្រះរាជា មានន័យថា ព្រះនិគ្រោធសាមណេរលោកជ្រាបថា ព្រះរាជាអង្គនេះ មានប្រក្រតីនៅដោយសេចក្តីប្រមាទ...***, ទើបបានជាសម្តែងអប្បមាទវគ្គក្នុងព្រះធម្មបទតាមសមគួរដល់ព្រះរាជានោះ" ។

ឯក្នុងរឿងព្រះមហិន្ទត្ថេរ ដែលទៅផ្សាយព្រះសាសនាក្នុងកោះលង្កា ក៏ដូចគ្នា គឺក្រោយពេលធ្វើភត្តកិច្ចស្រេចហើយ ព្រះថេរៈក៏សម្តែង **បេតវត្ថុ វិមានវត្ថុ** និង**សច្ចសំយុត្ត** ដល់ព្រះរាជាព្រមទាំងបរិវារ ។ សូម្បីក្នុងសម័យពុទ្ធកាល ក៏មានដូចគ្នាដែរ, សូមមើលក្នុងគម្ពីរផ្សេងៗ មានគម្ពីរធម្មបទជាដើម ហើយពិចារណាធ្វើតាមលំនាំរបស់ព្រះថេរៈទាំងឡាយតាមសមគួរផងចុះ។

សេចក្តីដែលលើកមកនេះ គឺចង់បញ្ជាក់ឱ្យឃើញថា ការធ្វើអនុមោទនា ត្រូវធ្វើឱ្យត្រូវតាមបែបបទផង ហើយក៏អាចធ្វើទៅតាមហេតុការណ៍ជាក់ស្តែងនោះៗ បានផងដែរ គឺដោយភាពធ្នាតវៃរបស់ខ្លួន ព្រោះប្រយោជន៍នៃការធ្វើអនុ-មោទនា គឺដើម្បីឱ្យម្ចាស់ទានបានយល់អំពីផលរបស់ទាន និងដើម្បីញុំាងសេចក្តីជ្រះថ្លារបស់ម្ចាស់ទានឱ្យកាន់តែជ្រះថ្លាថែមទៀត ដូច្នេះ សូមអ្នកសិក្សាទាំងឡាយពិចារណាហើយធ្វើទៅតាមសេចក្តីធ្នាតឈ្លាសរបស់ខ្លួនចុះ។



អនុមោទនាក្នុងពិធីសប្បទាន

****

កាលដែលភិក្ខុ ឬសាមណេរ បានទទួលនូវបច្ច័យណានីមួយអំពីទាយក ឬទាយិកាហើយ ឬក៏កាលដែលសម្រេចកត្តកិច្ច គឺធាន់ហើយ គ្រាកាលវេលាសមគួរហើយ គប្បីអនុមោទនាដោយសូត្រ ឬគាថាណាមួយក៏បាន តាមការគាប់ចិត្តដូចខាងក្រោមនេះ ៖

និធិកណ្ឌសូត្រ

កំណប់ទ្រព្យ គឺបុណ្យ

១. និធឹ និធេតិ បុរិសោ គម្ភីរេ ឧទកន្តិកេ
អត្ថេ កិច្ចេ សមុប្បន្នេ អត្ថាយ មេ ភវិស្សតិ ។

បុរសកប់កំណប់ទ្រព្យទុកក្នុងទីជិតទឹកដ៏ជ្រៅ ដោយគិតថា កាលបើកិច្ចដែលត្រូវការកើតឡើងហើយ ទ្រព្យនេះនឹងបានជាប្រយោជន៍ដល់អាត្មាអញ ។

២. រាជតោ វា ទុរុត្តស្ស ចោរតោ បីឡិតស្ស វា
ឥណស្ស វា បមោក្ខាយ ទុព្ភិក្ខេ អាបទាសុ វា
ឯតទត្ថាយ លោកស្មឹ និធិ នាម និធិយ្យតិ ។

ដែលត្រូវពួកបច្ចាមិត្រពោលបង្កាច់ នឹងបានដោះខ្លួនចេញពីស្តេច ឬត្រូវចោរបៀតបៀន នឹងបានដោះខ្លួនចេញពីចោរ នឹងបានដោះបំណុល ឬក្នុងពេលទុរ្ភិក្ស ឬក៏ក្នុងកាលអន្តរាយទាំងឡាយ ធម្មតាកំណប់ដែលគេកប់ទុកក្នុងលោកដើម្បីប្រយោជន៍នោះឯង។

៣. តាវស្សុ និហិតោ សង្កោ គម្ភីរេ ខ្ទកវ្តិកេ
ន សព្ពោ សព្ពទាយេវ តស្សុតំ ខ្យបកប្បតិ ៚

កំណប់ដែលបុគ្គលកប់ក្នុងទីជ្រៅ មានទីបំផុតទល់នឹងទឹកដល់ម្ល៉ោះ កំណប់ទ្រព្យទាំងអស់នោះ ក៏មិនសម្រេចដល់បុគ្គលនោះសព្វកាលទេ។

៤. និធិ វា ឋានា ចវតិ សញ្ញា វាស្ស វិមុយ្ហតិ
នាគា វា អបនាមេន្តិ យក្ខា វា បិហរន្តិ នំ ៚

ដ្បិតថាកំណប់ទ្រព្យរមែងឃ្លាតទៅចាកទីខ្លះ សេចក្តីចំណាំរបស់បុគ្គលនោះរមែងវង្វេងទៅខ្លះ នាគទាំងឡាយរមែងនាំជញ្ជូនទៅខ្លះ ពុំនោះសោតពួកយក្សនាំយកទ្រព្យនោះទៅខ្លះ។

៥. អប្បិយា វាបិ ទាយាទា ខ្ទន្ធរន្តិ អបស្សតោ
យទា បុញ្ញក្ខយោ ហោតិ សព្វមេតំ វិនស្សតិ ៚

អ្នកទទួលមត៌កដែលមិនជាទីស្រឡាញ់ រមែងគាស់យកនូវកំណប់ទ្រព្យនោះកាលខ្លួនមិនបានឃើញខ្លះ ខ្លួនអស់បុណ្យទៅវេលាណា កំណប់ទ្រព្យទាំងអស់នោះ រមែងវិនាសបាត់បង់ទៅក្នុងវេលានោះ។

៦. យស្ស ទានេន សីលេន សញ្ញមេន ទមេន ច
និធិ សុនិហិតោ ហោតិ ឥត្ថិយា បុរិសស្ស វា ៚

កំណប់ទ្រព្យដែលស្ត្រី ឬបុរសណា បានកប់ទុកល្អហើយ ដោយទាន សីល ដោយការសង្រួម នឹងដោយការទូន្មានខ្លួន។

៧. ចេតិយម្ហិ ច សង្ឃេ វា បុគ្គលេ អតិថី សុវា
មាតរិ បិតរិ វាបិ អថោ ជេដ្ឋម្ហិ ភាតរិ ៚

ក្នុងចេតិយ ឬក្នុងសង្ឃ ឬក្នុងបុគ្គល ឬក្នុងពួកភ្ញៀវ ឬមួយក្នុងមាតា ក្នុងបិតា ឬថាក្នុងបងប្រុស-ស្រីដែលជាច្បង។

៨. ឯសោ និធិ សុនិហិតោ អដេយ្យោ អនុគាមិកោ
បហាយ គមនីយេសុ ឯតំ អាទាយ គច្ឆតិ ៘

កំណប់ទ្រព្យនុ៎ះ ចាត់ជាកំណប់ទ្រព្យដែលកប់ទុកប្រពៃហើយ នរណា ៗ មិនគប្បីផ្ចាញ់បាន ជាកំណប់ទ្រព្យដែលជាប់តាមខ្លួនទៅ កាលកោគៈទាំងឡាយ ដែលខ្លួនត្រូវលះបង់ហើយទៅ ខ្លួនរមែងកាន់យកនូវកំណប់ទ្រព្យគឺបុណ្យនុ៎ះទៅ។

៩. អសាធារណមញ្ញេសំ អចោរាហារណោ និធិ
កយិរាថ ធីរោ បុញ្ញានិ យោ និធិ អនុគាមិកោ ៘

កំណប់ទ្រព្យ គឺបុណ្យមិនទូទៅដល់ពួកជនដទៃ ជារបស់ដែលចោរលួចទៅមិនបាន កំណប់ទ្រព្យ គឺបុណ្យណា ជាប់តាមខ្លួនទៅបាន អ្នកប្រាជ្ញគួរធ្វើនូវកំណប់ទ្រព្យ គឺបុណ្យនោះ។

១០. ឯស ទេវមនុស្សានំ សព្វកាមទទោ និធិ
យំ យំ ទេវាភិបត្ថេន្តិ[1] សព្វមេតេន លព្ភតិ ៘

កំណប់ទ្រព្យ គឺបុណ្យនុ៎ះ ឱ្យនូវសេចក្តីប្រាថ្នាគ្រប់យ៉ាង ដល់ទេវតា និងមនុស្សទាំងឡាយ ពួកទេវតា និងមនុស្សទាំងឡាយ ប្រាថ្នាណាស់នូវផលណា ៗ ផលទាំងពួងនោះ ៗ រមែងបានដោយកំណប់ទ្រព្យ គឺបុណ្យនុ៎ះ។

១១. សុវណ្ណតា សុសរតា សុសណ្ឋានំ សុរូបតា
អាធិបច្ចំ បរិវារោ សព្វមេតេន លព្ភតិ ៘

១-បាលីក្នុងច្បាប់រដ្ឋសង្គាយនាថា **យំ យទេវាភិបត្ថេន្តិ** ។

ភាពជាអ្នកមានសម្បុរផូរផង់ មានសំឡេងពីរោះ ទ្រង់ទ្រាយល្អ រូបល្អ ជាអធិបតី មានយសបរិវារ ផលទាំងអស់ រមែងបានដោយកំណប់ទ្រព្យ គឺបុណ្យនុ៎ះ។

១២. បទេសរជ្ជំ ឥស្សរិយំ ចក្កវត្តិសុខំ បិយំ
ទេវរជ្ជម្បិ ទិព្វេសុ សព្វមេតេន លព្ភតិ ៚

ភាពជាស្តេចប្រទេសរាជ ឥស្សរិយយស សេចក្តីសុខរបស់ស្តេចចក្រពត្តិ ជាទីស្រឡាញ់ ភាពជាស្តេចនៃទេវតាក្នុងទេពនិកាយទាំងឡាយ ផលទាំអស់ រមែងបានដោយកំណប់ទ្រព្យ គឺបុណ្យនុ៎ះ។

១៣. មានុសិកា ច សម្បត្តិ ទេវលោកេ ច យា រតិ
យា ច និព្វានសម្បត្តិ សព្វមេតេន លព្ភតិ ៚

សម្បត្តិជារបស់មនុស្សណាផង សេចក្តីត្រេកអរក្នុងទេវលោកណាផង សម្បត្តិ គឺព្រះនិព្វានណាផង សម្បត្តិទាំងអស់ រមែងបានដោយកំណប់ទ្រព្យ គឺបុណ្យនុ៎ះ។

១៤. មិត្តសម្បទមាគម្ម យោនិសោ ចេ បយុញ្ជតោ
វិជ្ជាវិមុត្តិផលីភាវោ សព្វមេតេន លព្ភតិ ៚

ភាពនៃបុគ្គលកាលអាស្រ័យមិត្តសម្បទា បើប្រកបសេចក្តីព្យាយាមដោយឧបាយដែលត្រូវ ជាអ្នកស្ទាត់ក្នុងវិជ្ជា និងវិមុត្តិ ឥដ្ឋផលទាំងអស់ បានដោយកំណប់ទ្រព្យ គឺបុណ្យនុ៎ះ។

១៥. បដិសម្ភិទា វិមោក្ខា ច យា ច សាវកបារមី
បច្ចេកពោធិ ពុទ្ធភូមិ សព្វមេតេន លព្ភតិ ៚

បដិសម្ភិទា វិមោក្ខ សាវកបារមីញាណ បច្ចេកពោធិញ្ញាណ និងពុទ្ធភូមិ ណាៗ ឥដ្ឋផលទាំងអស់ រមែងបានដោយកំណប់ទ្រព្យ គឺបុណ្យនុ៎ះៗ

១៦. ឯវំ មហត្ថិកា ឯសា យទិទំ បុញ្ញសម្បទា
តស្មា ធីរា បសំសន្តិ បណ្ឌិតា កតបុញ្ញតំ ៗ

បុញ្ញសម្បទានេះ ឱ្យសម្រេចប្រយោជន៍ដ៏ធំ ដោយប្រការដូច្នេះ ព្រោះហេតុនោះអ្នកប្រាជ្ញទាំងឡាយជាធីរជន ទើបសរសើរនូវភាពនៃបុគ្គលជាអ្នកមានបុណ្យធ្វើទុកហើយ។

(បិដកលេខ ៥២ ទំព័រ ១៥)

កេណិយាទុមោទនាគាថា

(បិដកលេខ ៧ ទំព័រ ៣៦៦)

អគ្គិហុត្តមុខា យញ្ញា *គ្រឿងបូជាទាំងឡាយមានការបូជាភ្លើង ជាប្រធាន (ក្នុងសាសនាព្រាហ្មណ៍)*

សាវិត្តី ឆន្ទសោ មុខំ *គម្ពីរសាវិត្តិសាស្ត្រ ជាប្រធាននៃគម្ពីរឆន្ទសាស្ត្រ*

រាជា មុខំ មនុស្សានំ *ស្តេចទ្រង់រាជ្យ ជាប្រធានរបស់មនុស្សទាំងឡាយ*

នទីនំ សាគរោ មុខំ *សាគរ គឺសមុទ្រ ជាប្រធានរបស់ទន្លេ និងស្ទឹងទាំង-ឡាយ*

នក្ខត្តានំ មុខំ ចន្ទោ *ព្រះចន្ទ ជាប្រធានរបស់នក្សត្រ គឺផ្កាយទាំងឡាយ (ឰដ៏អាកាស)*

អាទិច្ចោ តបតំ មុខំ *ព្រះអាទិត្យ ជាប្រធានរបស់កម្តៅទាំងឡាយ (ដូចម្តេចមិញ)*

បុញ្ញាភិកង្ខមានានំ សង្ឃោ វេ យជតំ មុខំ *ព្រះសង្ឃ ជាប្រធានរបស់ជនទាំងឡាយអ្នកប្រាថ្នានូវបុណ្យ ប្រគេនទាន(ក៏ដូច្នោះឯង)។*

ការឲទានប្បកាសនគាថា

(គាថាសម្រាប់ប្រកាសកាលទាន)

តណិសង្ឃម មយំ គាថា ការឲទានប្បទីបិកា *យើងទាំងឡាយនឹងសូត្រនូវព្រះគាថាទាំងឡាយដែលសម្តែងនូវកាលទាន*

ឯតា សុណន្តុ សក្កច្ចំ ទាយកា បុញ្ញកាមិនោ *ទាយកទាយិកាទាំងឡាយជាអ្នកប្រាថ្នានូវបុណ្យចូរស្តាប់នូវព្រះគាថាទាំងនេះដោយគោរពចុះ។*

*(ត្រង់ពាក្យថា “**ការឲទានប្បទីបិកា**” នេះ បើប្រកាសពីវិហារទានវិញ ត្រូវផ្ទាស់ថា “**វិហារទានប្បទីបិកា**” ដូច្នេះ)។*

ការឲទានសូត្រ

(កាលទាន ៥ យ៉ាង)

បញ្ចិមានិ ភិក្ខវេ ការឲទានានិ *ម្នាលភិក្ខុទាំងឡាយ កាលទាននេះមាន ៥ យ៉ាង។*

កតមានិ បញ្ច *៥ យ៉ាងដូចម្តេចខ្លះ?*

- **អាគន្តុកស្ស ទានំ ទេតិ** *គឺឱ្យទានដល់អ្នកមកថ្មី ១,*
- **គមិកស្ស ទានំ ទេតិ** *ឱ្យទានដល់អ្នកមានដំណើរ ១,*
- **គិលានស្ស ទានំ ទេតិ** *ឱ្យទានដល់អ្នកមានជំងឺ ១,*
- **ទុព្ភិក្ខេ ទានំ ទេតិ** *ឱ្យទានក្នុងពេលអត់បាយ ១,*
- **យានិ តានិ ទទសស្សានិ ទទថលានិ តានិ បឋមំ សីលទឡ្ហេសុ បតិដ្ឋាបេតិ** *បានតម្កល់ស្រូវថ្មី ផ្លែឈើដំបូងដល់បុគ្គលមានសីលទាំងឡាយជាដំបូង១។*

ឥមានិ ខោ គហបតេ បញ្ច កាលទានានិ *ម្នាលគហបតីទាំងឡាយ នេះឯងជាកាលទាន ៥ យ៉ាង។*

កាលេ ទទន្តិ សប្បញ្ញា ទទញ្ញា ទីតមច្ឆរា
កាលេនទិន្នំ អរិយេសុ ទ្ធជុភូតេសុ តាទិសុ
វិប្បសន្នមនា តស្ស វិបុលា ហោតិ ទក្ខិណា ។

ពួកជនអ្នកមានបញ្ញា ជាអ្នកដឹងនូវបំណងរបស់ស្នូម មានសេចក្តីកំណាញ់ប្រាសចេញហើយ មានចិត្តជ្រះថ្លាហើយ រមែងឱ្យទានក្នុងកាលគួរ ទានដែលបុគ្គលឱ្យតាមកាលគួរ ចំពោះព្រះអរិយបុគ្គលទាំងឡាយ ដែលជាបុគ្គលមានកាយ និងចិត្តប្រកបដោយតាទិគុណ ទក្ខិណាទានរបស់បុគ្គលនោះ ជាទានមានផលបរិបូណ៌។

យេ តត្ថ អនុមោទន្តិ វេយ្យាវច្ចំ ករោន្តិ វា
ន តេន ទក្ខិណា ទ្ធនា តេបិ បុញ្ញស្ស ភាគិនោ ។

ពួកជនណាអនុមោទនា ឬធ្វើសេចក្តីខ្វល់ខ្វាយក្នុងទក្ខិណាទាននោះ ទក្ខិ-ណាទានរបស់អ្នកទាំងនោះ នឹងបានឈ្មោះថាជាទានថយថោក ព្រោះតែអនុមោ-ទនា ឬធ្វើសេចក្តីខ្វល់ខ្វាយនោះន៏ទេ ពួកជនទាំងនោះ ជាអ្នកបានចំណែក បុណ្យដែរ។

តស្មា ទទេ អប្បដិវាណចិត្តោ យត្ថ ទិន្នំ មហប្ផលំ
បុញ្ញានិ បរលោកស្មឹ បតិដ្ឋា ហោន្តិ បាណិនំ ។

ព្រោះហេតុនោះ ទានដែលបុគ្គលឱ្យហើយដល់បុគ្គលណាជាទានមានផលច្រើន បុគ្គលមានចិត្តមិនបានរួញរា គប្បីឱ្យទានចំពោះបុគ្គលនោះ ព្រោះថាបុណ្យទាំងឡាយរមែងជាទីពឹងនៃសត្វក្នុងលោកខាងមុខ។

(បិដកលេខ ៤៤ ទំព័រ ៨១)

ទិហារទានសុត្តគាថា

(គាថាអនុមោទនាសេនាសនទាន)

សីតំ ឧណ្ហំ បដិហន្តិ តតោ ពាឡមិគានិ ច
សិរីសបេ ច មកសេ សិសិរេ ចាបិ វុដ្ឋិយោ ។

(វិហារ គឺទីអាវាស ឬទីសេនាសន:ជាទីនៅនៃសង្ឃទាំងឡាយ) រមែងការ-ពារនូវរងាផង នូវក្តៅផង នូវម្រឹគសាហាវទាំងឡាយផង នូវពស់តូចពស់ធំ គឺសត្វល្អិតទាំងឡាយផង នូវមូសទាំងឡាយផង នូវត្រជាក់ផង នូវគ្រាប់ភ្លៀងទាំងឡាយផងក្នុងទីនោះ។

តតោ ទាតាតចោ យោគោ សព្ពាគតោ បដិហញ្ញតិ *ខ្យល់និងកម្តៅថ្ងៃដ៏ក្លាខ្លាំងដែលកើតហើយ រមែងត្រឡប់បាត់ទៅព្រោះវិហារនោះ។*

លេណត្ថញ្ច សុខត្ថញ្ច ឈាយិតុំ ច វិបស្សិតុំ
វិហារទានំ សង្ឃស្ស អគ្គំ ពុទ្ធេហិ វណ្ណិតំ ៥

វិហារទាន គឺកិរិយាឱ្យនូវអាវាស ឬទីសេនាសនៈជាទីនៅ (ដែលបុគ្គលបានឱ្យហើយ) ដល់សង្ឃ ដើម្បីជាទីជ្រកកោនផង ដើម្បីសេចក្តីសុខកាយសុខចិត្តផង ដើម្បីដុតបង់នូវបាបធម៌ផង ដើម្បីឃើញច្បាស់នូវសង្ខារ គឺចម្រើនវិបស្សនាផង ព្រះពុទ្ធជាម្ចាស់ទាំងឡាយទ្រង់ត្រាស់សរសើរថា ជាទានដ៏ប្រសើរ។

តស្មា ហិ បណ្ឌិតោ ចោសោ សម្បស្សំ អត្តមត្តនោ *ព្រោះហេតុនោះ បុរសស្ត្រីជាបណ្ឌិត កាលបើបានឃើញច្បាស់នូវប្រយោជន៍នៃខ្លួន។*

វិហារេ ការយេ រម្មេ វាសយេត្ថ ពហុស្សុតេ *គប្បីកសាងវិហារ គឺទីអាវាស ឬទីសេនាសនៈទាំងឡាយ ឱ្យជាទីគួររីករាយហើយគប្បីញុំាងលោកជាពហុស្សូត គឺលោកអ្នកចេះដឹងច្រើនទាំងឡាយឱ្យនៅក្នុងទីនោះ។*

តេសំ អន្នញ្ច បានញ្ច វត្ថសេនាសនានិ ច
ទទេយ្យ ឧជុភូតេសុ វិប្បសន្នេន ចេតសា ៥

គប្បីមានចិត្តជ្រះថ្លាក្នុងលោកទាំងឡាយ ដែលមានកាយនិងចិត្តត្រង់ហើយ ឱ្យនូវម្ហូបចំណីផង នូវទឹកផង នូវសំពត់និងសេនាសនៈទាំងឡាយផង ដល់លោកទាំងនោះ។

តេ តស្ស ធម្មំ ទេសេន្តិ សព្ពទុក្ខាបនូទនំ *លោកទាំងឡាយនោះ រមែង*

សម្តែងនូវធម៌ជាគ្រឿងបន្ទោបង់នូវសេចក្តីទុក្ខទាំងពួងដល់អ្នកនោះ ។

យំ សោ ធម្មំ ឥធញ្ញាយ បរិនិព្ពាតិ អនាសវោ *អ្នកនោះដឹងច្បាស់នូវធម៌មានសភាពដូច្នោះហើយ រមែងជាព្រះអរហន្ត មិនមានអាសវៈ បរិនិព្វានក្នុងលោកនេះ ។*

(បិដកលេខ ១០ ទំព័រ ២៦៣)

ទេវតោទ្ទិស្សទក្ខិណានុមោទនាគាថា

(បិដកលេខ ៧ ទំព័រ ៣១១ និងលេខ ១៦ ទំព័រ ១៩១)

យស្មឹ បទេសេ កប្បេតិ វាសំ បណ្ឌិតជាតិយោ *ជនមានជាតិជាបណ្ឌិតសម្រេចនូវទីលំនៅក្នុងប្រទេសឯណា*

សីលវន្តេត្ថ ភោជេត្វា សញ្ញតេ ព្រហ្មចារិនោ *បានញ៉ាំងលោកអ្នកមានសីលជាព្រហ្មចារីបុគ្គល ដែលជាអ្នកសង្រួមទាំងឡាយឱ្យឆាន់ក្នុងទីនោះ*

យា តត្ថ ទេវតា អាសុំ តាសំ ទក្ខិណមាទិសេ *ទេវតាទាំងឡាយឯណាមានហើយក្នុងទីនោះ (ជនមានជាតិជាបណ្ឌិតនោះ) គួរឧទ្ទិសផ្សាយនូវផលនៃទក្ខិណាទានដល់ទេវតាទាំងឡាយនោះផង*

តា បូជិតា បូជយន្តិ មានិតា មានយន្តិ នំ *ទេវតាទាំងឡាយនោះ ជាបុគ្គល គឺបណ្ឌិតនោះបូជាហើយ រាប់អានហើយ (ដោយផលនៃទក្ខិណាទាននោះ) រមែងបូជា រមែងរាប់អាននូវបណ្ឌិតនោះវិញ។*

តតោ នំ អនុកម្បន្តិ មាតា បុត្តំវ ឱរសំ *ព្រោះហេតុដែលបណ្ឌិតនោះបានឧទ្ទិសផលនៃទក្ខិណាទានដល់ខ្លួន (ទេវតាទាំងឡាយនោះ) រមែងអនុគ្រោះនូវបណ្ឌិតនោះ ដូចជាមាតាអនុគ្រោះនូវកូនបង្កើតដែលធំធាត់លើទ្រូង។*

ទេវតានុកម្បិតោ ចោសោ សទា ភទ្រានិ បស្សតិ *បុរស(ស្ត្រី) ដែលទេវតាបានអនុគ្រោះហើយ រមែងឃើញនូវកម្មដ៏ចម្រើនទាំងឡាយ ក្នុងកាលទាំងពួង។*

អគ្គប្បសាទសុត្តគាថា

(បិដកលេខ ៤៤ ទំព័រ ៧១ និងលេខ ៥៣ ទំព័រ ១១៨)

អគ្គតោ វេ បសន្នានំ អគ្គំ ធម្មំ វិជានតំ
អគ្គេ ពុទ្ធេ បសន្នានំ ទក្ខិណេយ្យេ អនុត្តរេ
អគ្គេ ធម្មេ បសន្នានំ វិរគូបសមេ សុខេ
អគ្គេ សង្ឃេ បសន្នានំ បុញ្ញក្ខេត្តេ អនុត្តរេ
អគ្គស្មឹ ទានំ ទទតំ អគ្គំ បុញ្ញំ បវឌ្ឍតិ
អគ្គំ អាយុ ច វណ្ណោ ច យសោ កិត្តិ សុខំ ពលំ ។

បុណ្យដ៏ប្រសើរ រមែងចម្រើន អាយុដ៏ប្រសើរផង សម្បុរកាយដ៏ប្រសើរផង យសស័ក្តិដ៏ប្រសើរផង កេរ្តិ៍ឈ្មោះដ៏ប្រសើរផង សេចក្តីសុខដ៏ប្រសើរផង កម្លាំងដ៏ប្រសើរផង រមែងចម្រើនដល់ជនទាំងឡាយ ដែលដឹងច្បាស់នូវធម៌ដ៏ប្រសើរ ដែលជាអ្នកជ្រះថ្លាក្នុងវត្ថុដ៏ប្រសើរដោយពិត ដែលជ្រះថ្លាក្នុងព្រះពុទ្ធជា

បុគ្គលដ៏ប្រសើរលើសលុប ជាទក្ខិណេយ្យបុគ្គលរកអ្នកឯណាមួយឱ្យស្មើនឹងព្រះអង្គគ្មាន ដែលជ្រះថ្លាក្នុងព្រះធម៌ដ៏ប្រសើរ ជាធម៌រំងាប់បង់នូវរាគាទិក្កិលេស ជាធម៌នាំមកនូវសេចក្តីសុខដល់អ្នកប្រតិបត្តិដែលជ្រះថ្លាក្នុងព្រះសង្ឃដ៏ប្រសើរ ជាស្រែបុណ្យ រកស្រែបុណ្យឯទៀតឱ្យក្រៃលែងជាងគ្មាន ដែលជាអ្នកឱ្យនូវទានដល់បុគ្គលដ៏ប្រសើ។

អគ្គស្ស ទាតា មេធាវី អគ្គធម្មសមាហិតោ *បុគ្គលមានប្រាជ្ញាដែលមានចិត្តតម្កល់ក្នុងធម៌ដ៏ប្រសើរហើយ ជាអ្នកឱ្យនូវទានដល់បុគ្គលដ៏ប្រសើរ។*

ទេវភូតោ មនុស្សោ វា អគ្គប្បត្តោ បមោទតិ *តែងនឹងបានទៅហើយជាទេវតា ឬមនុស្ស ក៏រមែងបានដល់នូវភាវៈជាអ្នកប្រសើរហើយរីករាយសប្បាយ។*

ភោជនទានានុមោទនាគាថា

(បិដកលេខ ៤៤ ទំព័រ ៨៣)

អាយុទោ ពលទោ ធីរោ ទត្តោ បដិភាណទោ *ជនអ្នកមានបញ្ញា ជាអ្នកឱ្យនូវអាយុ ជាអ្នកឱ្យនូវកម្លាំង ជាអ្នកឱ្យនូវសម្បុរកាយ ជាអ្នកឱ្យនូវប្រាជ្ញា។*

សុខស្ស ទាតា មេធាវី សុខំ សោ អធិគច្ឆតិ *អ្នកមានប្រាជ្ញា ជាអ្នកឱ្យនូវសេចក្តីសុខ (ដល់អ្នកឯទៀតហើយ) រមែងបាននូវសេចក្តីសុខ (នោះមកខ្លួនវិញ)*

អាយុំ ទត្វា ពលំ វណ្ណំ សុខញ្ច បដិភាណទោ *(បុគ្គលឯណា) បានឱ្យ*

នូវអាយុផង នូវកម្លាំងផង នូវសម្បុរកាយផង នូវសេចក្តីសុខផង នូវប្រាជ្ញាផង (ដល់អ្នកឯទៀត)ហើយ ឈ្មោះថាឱនូវប្រាជ្ញា

ឥធាយុ យសវា ហោតិ យត្ថ យត្ថ បបជ្ជតិ *បុគ្គលនោះលុះបានកើតក្នុងកពណាៗ រមែងមានអាយុវែង មានយសបរិវារក្នុងកពនោះៗ។*

យានទានានុមោទនាគាថា

អន្នំ បានំ វត្ថំ យានំ មាលា គន្ធំ វិលេបនំ

សេយ្យាវសថំ បទីបេយ្យំ[1] ទានវត្ថូ ឥមេទស ។

ទានវត្ថុទាំងឡាយ ១០ យ៉ាងនេះគឺ បាយ ទឹកសំពត់ យានជំនិះ ផ្កាកម្រងគ្រឿងក្រអូប គ្រឿងលាប ទីដេក ទីសម្នាក់អាស្រ័យ គ្រឿងប្រទីបគឺចង្កៀងគោម។

អន្នទោ ពលទោ ហោតិ *អ្នកឱ្យរបស់បរិភោគ ឈ្មោះថាឱ្យកម្លាំង។*

វត្ថទោ ហោតិ វណ្ណទោ *អ្នកឱ្យសំពត់ ឈ្មោះថាឱ្យពណ៌។*

យានទោ សុខទោ ហោតិ *អ្នកឱ្យយាន ឈ្មោះថាឱ្យសេចក្តីសុខ។*

ទីបទោ ហោតិ ចក្ខុទោ *អ្នកឱ្យប្រទីប ឈ្មោះថាឱ្យចក្ខុគឺភ្នែក[2]។*

មនាបទាយី លភតេ មនាបំ *អ្នកឱ្យរបស់ដែលគាប់ចិត្ត រមែងបានរបស់ដែលគាប់ចិត្ត។*

អគ្គស្ស ទាតា លភតេ បុនគ្គំ *អ្នកឱ្យវត្ថុដ៏លើសរមែងបាននូវវត្ថុដ៏លើស។*

១- បិដកលេខ ១៩ ទំព័រ ២២៤ និងលេខ ៥៣ ទំព័រ ៨៧ ។ ២-បិដកលេខ ២៩ ទំព័រ ៨០។

វរស្ស ទាតា វរលាភី ច ហោតិ *អ្នកឱ្យរបស់ល្អរមែងបានរបស់ល្អ។*

សេដ្ឋន្តទោ សេដ្ឋមុបេតិ ឋានំ *អ្នកឱ្យទីស្ថានដ៏ប្រសើរ រមែងចូលទៅកាន់ទីស្ថាដ៏ប្រសើរ។*

អគ្គទាយី វរទាយី សេដ្ឋទាយី ច យោនរោ *នរជនប្រុសស្រីឯណា ឱ្យរបស់ដែលលើស ឱ្យរបស់ដែលល្អ និងទីស្ថានដ៏ប្រសើរ។*

ទីឃាយុ យសវា ហោតិ យត្ថ យត្ថូបបជ្ជតិ *នរជនប្រុសស្រីនោះ កើតក្នុងកពណាៗ រមែងជាអ្នកមានអាយុយឺនយូរ មានយសក្នុងកពនោះៗ[1]។*

ឯតេន សច្ចវជ្ជេន *ដោយភាសិតសច្ចៈវាចានេះ*

សុវត្ថិ ហោតុ សព្ពទា អរោគិយសុខញ្ចេវ កុសលញ្ច អនាមយំ *សូមឱ្យសេចក្តីសួស្តី និងសេចក្តីសុខដែលកើតអំពីសេចក្តីមិនមានរោគ និងអនាម័យ គឺសេចក្តីប្រាសចាកទុក្ខព្យាធិ ស្រួលងាយ ចូរមានដល់អ្នកទាំងឡាយឱ្យបានគ្រប់កាល។*

យាគុអនុមោទនាគាថា

(បិដកលេខ ៧ ទំព័រ ២៨៧)

យោ សញ្ញាតានំ បរទត្តភោជិនំ ការេន សក្កច្ច ទទាតិ យាគុំ ។
ទសស្ស ឋានានិ អនុប្បវេច្ឆតិ អាយុញ្ច វណ្ណញ្ច សុខំ ពលញ្ច ។
បដិភាណមស្ស ឧបជាយតេ តតោ ខុទំ បិបាសំ ព្យបនេតិ ឋានំ ។

១-បិដកលេខ ៤៤ ទំព័រ ១០៣។

សោឆេតិ ឥត្តឺ បរិណាមេតិ ឥត្តំ តេសជ្ជមេតំ សុគតេន ឥណ្ណិតំ ។
តស្មា ហិ យាគុំ អលមេវ ឆាតុំ និច្ចំ មនុស្សេន សុខត្តិកេន ។
និព្វានិ ឥា បត្ថយតា សុខានិ មនុស្សសោ តគ្គតមិច្ឆតា ឥា ។

ជនឯណា បានឱ្យបបរដោយគោរព ដល់ពួកសមណៈដែលជាអ្នកសង្រួម អ្នកបរិភោគភោជន ដែលអ្នកដទៃឱ្យក្នុងកាលដ៏គួរ (ជននោះ) ឈ្មោះថាឱ្យនូវហេតុនៃអានិសង្សទាំង ១០ យ៉ាង គឺអាយុ ១ ពណ៌សម្បុរ ១ សេចក្តីសុខ ១ កម្លាំងកាយ ១ ប្រាជ្ញារបស់បុគ្គលនោះតែងកើតឡើង ១ បបរនោះតែងកម្ចាត់បង់សេចក្តីឃ្លាន ១ សេចក្តីស្រេក ១ និងញ៉ាំងខ្យល់ (ឱ្យបានដើរស្រួល) ១ ញ៉ាំងសរសៃឱ្យបានស្អាត ១ ញ៉ាំងកត្តឱ្យរលួយ ១ នេះជាកេសជ្ជៈដែលព្រះសុគតទ្រង់សរសើរហើយ។ ព្រោះហេតុនោះ អ្នកមានសេចក្តីត្រូវការ ចង់បានសេចក្តីសុខជារបស់មនុស្សក្តី ប្រាថ្នាសេចក្តីសុខជារបស់ទិព្វក្តី ចង់បានសេចក្តីល្អរុងរឿងក្នុងមនុស្សក្តី គួរឱ្យបបរជានិច្ចចុះ។

ឆានានិសង្សសូត្រ

(អានិសង្សនៃទាន ៥ យ៉ាង)

បញ្ចិមេ ភិក្ខវេ ឆានេ អានិសំសា *ម្នាលភិក្ខុទាំងឡាយ អានិសង្សក្នុងទាននេះ មាន៥ យ៉ាង។*

កតមេ បញ្ច *៥ យ៉ាងដូចម្តេចខ្លះ?*

ពហុនោ ជនស្ស បិយោ ហោតិ មនាបោ *គឺជាទីស្រឡាញ់ ជាទីគាប់ចិត្ត នៃជនច្រើន ១,*

សន្តោ សប្បុរិសា តជ្ជេន្តិ *ពួកសប្បុរសអ្នកស្ងប់រមែងរាប់រក ១,*

កណ្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ *មានកិត្តិសព្ទដ៏ពីរោះខ្ចរខ្ចាយទៅ ១,*

គិហិធម្មោ អនបគតោ ហោតិ *មិនបានច្រាសចាកធម៌របស់គ្រហស្ថ ១,*

កាយស្ស តេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ *លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ១ ។*

ឥមេ ខោ គិហ្ងវេ បញ្ច ឋានេ អានិសំសា *ម្នាលគហបតីទាំងឡាយ នេះអានិសង្សក្នុងទានទាំង ៥ យ៉ាង ។*

ទទមានោ បិយោ ហោតិ សតំ ធម្មំ អនុក្កមំ
សន្តោ នំ សទ្ធា តជ្ជន្តិ សញ្ញតា ព្រហ្មចារិយោ
តេ តស្ស ធម្មំ ទេសេន្តិ សព្វទុក្ខាបនូទនំ
យំ សោ ធម្មំ ឥធញ្ញាយ បរិនិព្វាតិ អនាសវោ ។

បុគ្គលកាលឱ្យទាន រមែងជាទីស្រឡាញ់ ជាអ្នកអនុកូលទៅតាមធម៌របស់ពួកសប្បុរស ពួកសព្រហ្មចារី អ្នកសង្រួម មានចិត្តស្ងប់រំងាប់ រមែងរាប់រកបុគ្គលនោះសព្វកាល លោកទាំងឡាយនោះ រមែងសម្តែងនូវធម៌ជាគ្រឿងបន្ទោបង់ នូវសេចក្តីទុក្ខទាំងពួងដល់អ្នកនោះ អ្នកនោះលុះដឹងនូវធម៌មានសភាពដូច្នេះហើយ រមែងជាព្រះអរហន្ត មិនមានអាសវៈបរិនិព្វានក្នុងលោកនេះ ។

(បិដកលេខ ៤៤ ទំព័រ ៨0)

ភោជនទានសូត្រ

(ឱ្យភោជនាហារ ឈ្មោះថាឱ្យនូវស្ថាន ៥ យ៉ាង)

ភោជនំ ភិក្ខវេ ទទមានោ ទាយកោ បដិគ្គាហកានំ បញ្ច ឋានានិ ទេតិ *ម្នាលភិក្ខុទាំងឡាយ ទាយកកាលឱ្យភោជនាហារឈ្មោះថា ឱ្យស្ថាន ៥ យ៉ាងដល់បដិគ្គាហក:ទាំងឡាយ។*

កតមានិ បញ្ច *ស្ថាន ៥ យ៉ាងដូចម្តេចខ្លះ?*

អាយុំ ទេតិ *គឺឱ្យអាយុ ១,*

វណ្ណំ ទេតិ *ឱ្យពណ៌សម្បុរ ១,*

សុខំ ទេតិ *ឱ្យសេចក្តីសុខ ១,*

ពលំ ទេតិ *ឱ្យកម្លាំង ១,*

បដិភាណំ ទេតិ *ឱ្យបដិភាណ គឺប្រាជ្ញាវាងវៃ ១។*

អាយុំ ខោ បន ទត្វា អាយុស្ស ភាគី ហោតិ ទិព្វស្ស វា មានុសស្ស វា *បុគ្គលដែលបានឱ្យអាយុហើយ រមែងបានចំណែកអាយុទិព្វ ឬអាយុជារបស់មនុស្ស,*

វណ្ណំ ទត្វា វណ្ណស្ស ភាគី ហោតិ ទិព្វស្ស វា មានុសស្ស វា *ឱ្យពណ៌សម្បុររមែងបានចំណែកពណ៌សម្បុរទិព្វ ឬសម្បុររបស់មនុស្ស,*

សុខំ ទត្វា សុខស្ស ភាគី ហោតិ ទិព្វស្ស វា មានុសស្ស វា *ឱ្យសុខរមែងបាចំណែកសុខទិព្វ ឬសុខជារបស់មនុស្ស,*

ពលំ ទត្វា ពលស្ស ភាគី ហោតិ ទិព្វស្ស វា មានុសស្ស វា *ឱ្យកម្លាំង*

រមែងបានចំណែកកម្លាំងទិព្វ ឬកម្លាំងជារបស់មនុស្ស,

បដិភាណំ ទត្វា បដិភាណស្ស ភាគី ហោតិ ទិព្វស្ស វា មានុសស្ស វា

ឱ្យបដិភាណរមែងបានចំណែកបដិភាណជារបស់ទិព្វឬបដិភាណជារបស់មនុស្សៗ

អាយុទោ ពលទោ ធីរោ វណ្ណទោ បដិភាណទោ[1]

សុខស្ស ទាតា មេធាវី សុខំ សោ អធិគច្ឆតិ ៗ

ជនអ្នកមានបញ្ញាជាអ្នកឱ្យនូវអាយុ ជាអ្នកឱ្យនូវកម្លាំង ជាអ្នកឱ្យនូវសម្បុរកាយ ជាអ្នកឱ្យនូវប្រាជ្ញា អ្នកមានប្រាជ្ញា ជាអ្នកឱ្យនូវសេចក្តីសុខ (ដល់អ្នកឯទៀត) ហើយ រមែងបាននូវសេចក្តីសុខ (នោះមកខ្លួនវិញ)

អាយុំ ទត្វា ពលំ វណ្ណំ សុខញ្ច បដិភាណទោ[2]

ទីឃាយុ យសវា ហោតិ យត្ថ យត្ថូបបជ្ជតិ ៗ

(បុគ្គលឯណា) បានឱ្យនូវអាយុផង នូវកម្លាំងផង នូវសម្បុរកាយផង នូវសេចក្តីសុខផង (ដល់អ្នកឯទៀត)ហើយ ឈ្មោះថាឱ្យនូវប្រាជ្ញា បុគ្គលនោះ លុះបានកើតក្នុងកំពណាៗ រមែងមានអាយុវែង មានយសបរិវារក្នុងកំពនោះៗ ។

(បិកដលេខ ៤៤ ទំព័រ ៨២)

អន្ធសូត្រ

ព្រះមានព្រះភាគទ្រង់ត្រាស់ថា:

យេ នំ ទទន្តិ សទ្ធាយ វិប្បសន្នេន ចេតសា

១-២-បាលីក្នុងច្បាប់ឆដ្ឋសង្គាយនាថា **បដិភាណកំ** ។

តមេវ អន្ធំ តជតិ អស្មឹ លោកេ បរម្ហិ ច ។

ជនទាំងឡាយណា មានចិត្តជ្រះថ្លា ឱ្យបាយនោះដោយសទ្ធា បាយនោះរមែងចូលទៅរកជនទាំងនោះវិញក្នុងលោកនេះ និងលោកខាងមុខ ។

តស្មា ទិន្នេយ្យ មច្ឆេរំ ទជ្ជា ទានំ មលាតិគូ
បុញ្ញានិ បរលោកស្មឹ បតិដ្ឋា ហោន្តិ បាណិនំ ។

ព្រោះហេតុដូច្នោះហើយ សាធុជនគួរតែកម្ចាត់បង់នូវសេចក្តីកំណាញ់ចេញ ជាអ្នកគ្របសង្កត់នូវមន្ទិលហើយឱ្យទានចុះ (ព្រោះថា) បុណ្យទាំងឡាយតែងជាទីពឹងពំនាក់របស់សត្វទាំងឡាយក្នុងបរលោក ។

(បិដកលេខ ២៩ ទំព័រ ៨១)

មច្ឆរិយសុត្តគាថា

(បិដកលេខ ២៩ ទំព័រ ៤៧)

ពួកសតុល្លបកាយិកាទេវតាពោលគាថានេះ ក្នុងសម្នាក់នៃព្រះមានព្រះភាគថា:

មច្ឆេរា ច បមាទា ច ឯវំ ទានំ ន ទីយតិ
បុញ្ញាភកង្ខមានេន ទេយ្យំ ហោតិ វិជានតា ។

ព្រោះសេចក្តីកំណាញ់ និងសេចក្តីប្រមាទ បានជានរជនឱ្យទានមិនកើតយ៉ាងនេះ ទានកាលបើបុគ្គលដឹងច្បាស់ ជាអ្នកប្រាថ្នានូវបុណ្យ គួរតែឱ្យ។

លំដាប់នោះ ទេវតាមួយអង្គទៀតបានពោលគាថានេះថា

យស្សេវ តីរតោ ន ទទាតិ មច្ឆរី តទេវ អទទតោ តយំ
ឯឃច្ចា ច បិបាសា ច យស្ស តាយតិ មច្ឆរី

តមេវ ពាលំ ភុសតិ អស្មឹ លោកេ បរម្ហិ ច ។

មនុស្សកំណាញ់ ភ័យចំពោះហេតុណា ហើយមិនឱ្យទាន ហេតុនោះឯង ជាភ័យរបស់អ្នកមិនឱ្យ បុគ្គលកំណាញ់ ខ្លាចចំពោះហេតុណា ព្រោះសេចក្តីឃ្លាន និងស្រេក ហេតុនោះឯង តែងពាល់ត្រូវបុគ្គលពាលក្នុងលោកនេះ និងលោកខាងមុខ។

តស្មា ទិន្នេយ្យ មច្ឆេរំ ទជ្ជា ទានំ មហាតិភូ
បុញ្ញានិ បរលោកស្មឹ បតិដ្ឋា ហោន្តិ បាណិនំ ។

ព្រោះហេតុដូច្នោះហើយ សាធុជនគួរតែកម្ចាត់បង់នូវសេចក្តីកំណាញ់ចេញ ជាអ្នកគ្របសង្កត់នូវមន្ទិលហើយឱ្យទានចុះ (ព្រោះថា) បុណ្យទាំងឡាយ តែងជាទីពឹងពំនាក់របស់សត្វទាំងឡាយក្នុងបរលោក។

ទេវតាមួយអង្គទៀតបានពោលគាថានេះថា:

តេ មតេសុ ន មិយ្យន្តិ អង្ខានំវ សហាវជំ (១)
អប្បស្មឹ យេ បវេច្ឆន្តិ ឯស ធម្មោ សនន្តនោ ។

ពួកជនណា កាលទ្រព្យមានតិចក៏នៅតែឱ្យទានបាន ដូចជាអ្នកដើរផ្លូវធ្វាយ (ចែកស្បៀងដែលមានតិចតួចដល់គ្នាបាន) កាលបើគេស្លាប់រាល់គ្នា ជននោះឈ្មោះថាមិនស្លាប់ ធម៌នេះ ជាធម៌របស់បុរាណាចារ្យ។

អប្បស្មេកេ បវេច្ឆន្តិ ពហុនេកេ ន ទិច្ឆរេ
អប្បស្មា ទក្ខិណា ទិន្នា សហស្សេន សមំ មិតា ។

១- បាលីក្នុងច្បាប់ឆដ្ឋសង្គាយនាថា **បន្ថារំវ សហាវជំ**។

ជនពួកខ្លះ កាលទ្រព្យមានតិចក៏នៅតែឱ្យទានបាន ជនពួកខ្លះ សូម្បីសម្បូណ៌ទ្រព្យច្រើនក៏ឱ្យទានមិនកើត ទក្ខិណាទានដែលគេបែងអំពីទ្រព្យតិចហើយឱ្យរមែងមានផលស្មើគ្នានឹងទានរាប់ពាន់។

ទេវតាមួយអង្គទៀតបានពោលគាថានេះថា:

ទុទ្ធំ ទទមានានំ ទុក្ករំ កម្មកុព្វតំ
អសន្តោ នានុកុព្វន្តិ សតំ ធម្មោ ទុរន្វយោ ៗ

កាលបើពួកសប្បុរសកំពុងឱ្យរបស់ដែលឱ្យបានដោយកម្រ កំពុងធ្វើអំពើដែលធ្វើបានដោយកម្រ ពួកអសប្បុរសធ្វើតាមមិនបាន (ព្រោះ) ធម៌របស់ពួកសប្បុរស គឺពួកអសប្បុរសប្រព្រឹត្តតាមបានដោយកម្រ។

តស្មា សតញ្ច អសតំ នានា ហោតិ ឥតោ គតិ
អសន្តោ និរយំ យន្តិ សន្តោ សគ្គបរាយនា ៗ

ព្រោះហេតុនោះ គតិរបស់ពួកសប្បុរស និងអសប្បុរសរមែងផ្សេងគ្នា អំពីលោកនេះទៅ គឺពួកអសប្បុរសទៅកាន់នរក ពួកសប្បុរសទៅកាន់ឋានសួគ៌។

ព្រះមានព្រះភាគទ្រង់ត្រាស់ថា:

ធម្មំ ចរេ យោបិ សមុញ្ញាកំ ចរេ
ទារំ ច ឋោសំ ទទំ អប្បកស្មឹ
សតំ សហស្សាន សហស្សយាគិនំ
កលំបិ នាគ្ឃន្តិ តថាវិធស្ស តេតិ ៗ

ជនណាចិញ្ចឹមភរិយាផង កាលបើទ្រព្យមានតិច នៅតែឱ្យទានបានផង

ប្រព្រឹត្តធម៌បានផង ធ្វើនូវសេចក្តីខ្វល់ខ្វាយ (ក្នុងការងារ) ផង ពួកជនដែលមានការបូជារាប់ពាន់ដល់បុគ្គលមួយសែននាក់ ក៏នៅតែមិនដល់មួយចំណិតរបស់បុគ្គលយ៉ាងនោះបានឡើយ។

លំដាប់នោះ ទេវតាមួយអង្គទៀតបានទូលសួរព្រះមានព្រះភាគថា:

កេនេស យញ្ញោ វិបុលោ មហគ្គតោ
សមេន ទិន្នស្ស ន អគ្ឃមេតិ
កថំ សហស្សាន សហស្សយាគិនំ[1]
កលំបិ នាគ្ឃន្តិ តថាវិធស្ស តេតិ ។

យញ្ញានុ៎ះ មានផលជំទូលាយច្រើនដែរ នៅតែមិនដល់ទានដែលបុគ្គលឱ្យហើយដោយធម៌ដ៏ស្មើ តើដោយហេតុដូចម្តេច បុគ្គលមានការបូជារាប់ពាន់ដល់បុគ្គលមួយពាន់នាក់នោះ ក៏នៅតែមិនដល់មួយចំណិតរបស់បុគ្គលយ៉ាងនោះបាន តើដូចម្តេច ? ។

ព្រះមានព្រះភាគទ្រង់ត្រាស់នឹងទេវតានោះដោយគាថា ថា:

ទទន្តិ ហេកេ វិសមេ និវិដ្ឋា
យត្ថា[2] ឥធិត្ថា អថ សោចយិត្ថា
សា ទក្ខិណា អស្សុមុខា សទណ្ឌា
សមេន ទិន្នស្ស ន អគ្ឃមេតិ

១-បាលីក្នុងច្បាប់ឆដ្ឋសង្គាយនាថា **កថំ សតំ សហស្សានំ សហស្សយាគិនំ** ។ ២-បាលីក្នុងច្បាប់ឆដ្ឋសង្គាយនាថា **យេត្ថា** ។

ឯវំ សហស្សាន[1] សហស្សយាគិនំ

ករំបិ នាគ្ឆន្តិ តថាវិធស្ស តេតិ ។

បុគ្គលពួកមួយ បានបិតនៅស៊ប់ក្នុងធម៌មិនស្មើ ហើយបៀតបៀន សម្លាប់ពុំនោះសោត ធ្វើបុគ្គលដទៃឱ្យសោកសៅ ទើបឱ្យទាន ទក្ខិណាទាននោះឈ្មោះថា មានមុខទទឹកដោយទឹកភ្នែក ប្រកបដោយអាជ្ញា មិនដល់នូវតម្លៃនៃទាន ដែលបុគ្គលឱ្យហើយដោយធម៌ដ៏ស្មើទេ បុគ្គលមានការបូជារាប់ពាន់ដល់បុគ្គលមួយពាន់នាក់នោះ នៅតែមិនដល់មួយចំណិតរបស់បុគ្គលយ៉ាងនោះដូច្នេះឯង។

ឥន្ទកវនសូត្រ

(បុណ្យចម្រើនទាំងថ្ងៃទាំងយប់)

ទេវតាទូលសួរព្រះមានព្រះភាគថា

កេសំ ទិវា ច រត្តោ ច សទ្ធា បុញ្ញំ បវឌ្ឍតិ

ធម្មដ្ឋា សីលសម្បន្នា កេ ជនា សគ្គគាមិនោ ។

បុណ្យរមែងចម្រើនមិនដាច់ទាំងថ្ងៃ ទាំងយប់ គ្រប់វេលា ដល់ជនពួកណា ជនពួកណាឈ្មោះថា តាំងនៅក្នុងធម៌ ឈ្មោះថា បរិបូណ៌ដោយសីល គួរទៅកាន់ឋានសួគ៌បាន ។

ព្រះមានព្រះភាគទ្រង់ត្រាស់ថា:

អារាមរោបា វនរោបា យេ ជនា សេតុការកា

---

១ - បាលីក្នុងច្បាប់ឆដ្ឋសង្គាយនាថា **ឯវំ សតំ សហស្សានំ** ។

បបញ្ញា ខ្ញុចានញ្ញា យេ ទទន្តិ ខ្ញុបស្សយំ ។

ជនណា ដាំច្បារឈើមានផ្កាផ្លែ ដាំច្បារឈើមានម្លប់ សាងស្ពាន សាងពោង ឱ្យទានទឹក ទាំងជីកស្រះ ជនទាំងឡាយណា ឱ្យនូវទីសម្នាក់អាស្រ័យ ។

តេសំ ទិវា ច រត្តោ ច សទា បុញ្ញំ បវឌ្ឍតិ
ធម្មដ្ឋា សីលសម្បន្នា តេ ជនា សគ្គគាមិនោ ។

បុណ្យរមែងចម្រើនមិនដាច់ទាំងថ្ងៃទាំងយប់គ្រប់វេលា ដល់ជនទាំងឡាយនោះ ជនទាំងនោះឈ្មោះថា ជាអ្នកតាំងនៅក្នុងធម៌ ឈ្មោះថាបរិបូណ៌ដោយសីល គួរទៅកាន់ឋានសួគ៌បាន ។

(បិដកលេខ ២៩ ទំព័រ ៨៤)

គិហិសាមីចិសូត្រ

(បដិបទាដ៏សមគួររបស់គ្រហស្ថ)

អថខោ អនាថបិណ្ឌិកោ គហបតិ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។

គ្រានោះ អនាថបិណ្ឌិកគហបតី ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ អង្គុយក្នុងទីដ៏សមគួរ។

ឯកមន្តំ និសិន្នំ ខោ អនាថបិណ្ឌិកំ គហបតឹ ភគវា ឯតទវោច ចតូហិ ខោ គហបតិ ធម្មេហិ សមន្នាគតោ អរិយសាវកោ គិហិសាមីចិប្បដិបទំ បដិបន្នោ ហោតិ យសប្បដិលាភិនឹ សគ្គសំវត្តនិកំ ។

លុះអនាថបិណ្ឌិកគហបតីអង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគ

ទ្រង់ត្រាស់ថា ម្នាលគហបតី អរិយសាវ័កប្រកបដោយធម៌ ៤ យ៉ាង ឈ្មោះថា ប្រតិបត្តិនូវបដិបទាដ៏សមគួររបស់គ្រហស្ថ មានប្រក្រតីបាននូវយស ប្រព្រឹត្តទៅដើម្បីកើតក្នុងស្ថានសួគ៌ ។

កតមេហិ ចតូហិ *អរិយសាវ័កប្រកបដោយធម៌ ៤ យ៉ាង តើដូចម្តេច?*

ឥធ គហបតិ អរិយសាវកោ តិក្ខសទ្ធ្ឱ បច្ចុបដ្ឋិតោ ហោតិ ចីវរេន តិក្ខសទ្ធ្ឱ បច្ចុបដ្ឋិតោ ហោតិ បិណ្ឌបាតេន តិក្ខសទ្ធ្ឱ បច្ចុបដ្ឋិតោ ហោតិ សេនាសនេន តិក្ខសទ្ធ្ឱ បច្ចុបដ្ឋិតោ ហោតិ គិលានប្បច្ចយភេសជ្ជបរិក្ខារេន ។

ម្នាលគហបតី អរិយសាវ័កក្នុងសាសនានេះ ទំនុកបម្រុងកិក្ខុសង្ឃដោយចីវរ ១ ទំនុកបម្រុងកិក្ខុសង្ឃដោយបិណ្ឌបាត ១ ទំនុកបម្រុងកិក្ខុសង្ឃដោយសេនាសនៈ ១ ទំនុកបម្រុងកិក្ខុសង្ឃដោយភេសជ្ជបរិក្ខារជាបច្ច័យដល់មនុស្សមានជំងឺ ១ ។

ឥមេហិ ខោ គហបតិ ចតូហិ ធម្មេហិ សមន្នាគតោ អរិយសាវកោ គិហិសាមីចិប្បដិបទំ បដិបន្នោ ហោតិ យសប្បដិលាភិនឹ សគ្គសំវត្តនិកំ ។

ម្នាលគហបតី អរិយសាវ័កប្រកបដោយធម៌ ៤ យ៉ាងនេះឯង ឈ្មោះថា ប្រតិបត្តិនូវបដិបទាដ៏សមគួររបស់គ្រហស្ថ មានប្រក្រតីបាននូវយស ប្រព្រឹត្តទៅដើម្បីកើតក្នុងស្ថានសួគ៌ ។

គិហិសាមីចិប្បដិបទំ បដិបជ្ជន្តិ បណ្ឌិតា
សមគ្គតេ សីលវន្តេ ចីវរេន ឧបដ្ឋិតា
បិណ្ឌបាតសយនេន គិលានប្បច្ចយេន ច
តេសំ ទិវា ច រត្តោ ច សទា បុញ្ញំ បវឌ្ឍតិ
សគ្គញ្ច កមតិដ្ឋានំ កម្ម៉ំ កត្វាន តទ្ទកំ ។

បណ្ឌិតទាំងឡាយ តែងប្រតិបត្តិនូវបដិបទាដ៏សមគួររបស់គ្រហស្ថ គឺការទំនុកបម្រុងភិក្ខុដែលមានសីល ជាអ្នកព្រមព្រៀងគ្នា ដោយចីវរ ដោយបិណ្ឌបាត ដោយសេនាសនៈ និងគិលានប្បច្ចយ បុណ្យរមែងចម្រើនមិនដាច់ទាំងថ្ងៃទាំងយប់ គ្រប់វេលា ដល់បណ្ឌិតទាំងឡាយនោះ លុះធ្វើកម្មដ៏ចម្រើនហើយ រមែងទៅកាន់ឋានសួគ៌បាន ។

(បិដកលេខ ៤២ ទំព័រ ១៥៨)

ពហុការសូត្រ

(គ្រហស្ថនិងបព្វជិតអាស្រ័យគ្នានឹងគ្នា)

ពហុការ ភិក្ខវេ ព្រាហ្មណគហបតិកា តុម្ហាកំយេ តេ[1] បច្ចុបដ្ឋិតា ចីវរ បិណ្ឌបាតសេនាសនគិលានបច្ចយភេសជ្ជបរិក្ខារេហិ ។

ម្នាលភិក្ខុទាំងឡាយ ពួកព្រាហ្មណ៍និងគហបតីណា បានទំនុកបម្រុងអ្នកទាំងឡាយ ដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខារ ព្រាហ្មណ៍ និងគហតីទាំងនោះ ឈ្មោះថា មានឧបការៈច្រើនដល់អ្នកទាំងឡាយ។

តុម្ហេបិ ភិក្ខវេ ពហុការ ព្រាហ្មណគហបតិកានំ យំ ឆេសំ ធម្មំ ឆេសេ-ថ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេថ ។

ម្នាលភិក្ខុទាំងឡាយ ឯអ្នកទាំងឡាយ ក៏ឈ្មោះថាមានឧបការៈច្រើន ដល់

១-ក្នុងច្បាប់ឆដ្ឋសង្គាយនាថា **នោ** ។

ពួកព្រាហ្មណ៍និងគហបតីដែរ ព្រោះអ្នកទាំងឡាយសម្តែងធម៌ មានលម្អបទដើម លម្អបទកណ្តាល លម្អបទចុង ប្រកាសនូវព្រហ្មចរិយធម៌ព្រមទាំងអត្ថ និងព្យញ្ជនៈដ៏បរិបូណ៌ បរិសុទ្ធទាំងអស់។

ឯវមិទំ ភិក្ខវេ អញ្ញាមញ្ញំ និស្សាយ ព្រហ្មចរិយំ ទុស្សតិ ឱឃស្ស និត្តរណត្ថាយ សម្មា ទុក្ខស្ស អន្តកិរិយាយាតិ ។

ម្នាលភិក្ខុទាំងឡាយ ព្រហ្មចរិយធម៌នេះ ដែលបុគ្គលប្រព្រឹត្តដើម្បីប្រយោជន៍រើចេញចាកឱឃៈ និងធ្វើឱ្យផុតទុក្ខដោយប្រពៃបាន ក៏ព្រោះតែអាស្រ័យគ្នាទៅវិញទៅមកយ៉ាងនេះឯង។

សាគារា អនាគារា ច ឧភោ អញ្ញោញ្ញនិស្សិតា
អារាធយន្តិ សទ្ធម្មំ យោគក្ខេមំ អនុត្តរំ ។

ពួកគ្រហស្ថ និងបព្វជិតទាំងពីរពួក អាស្រ័យគ្នាទៅវិញទៅមក ទើបញុំាងព្រះសទ្ធម្មដែលជាទីក្សេមចាកយោគៈដ៏ប្រសើរឱ្យសម្រេចបាន។

សាគារេសុ ច ចីវរំ បច្ចយំ សយនាសនំ
អនាគារា បដិច្ឆន្តិ បរិស្សយវិនោទនំ ។

ឯពួកបព្វជិតតែងទទួលចីវរប្បច្ច័យ បិណ្ឌបាតប្បច្ច័យ សេនាសនប្បច្ច័យ និងភេសជ្ជប្បច្ច័យ ជាគ្រឿងបន្ទោបង់សេចក្តីអន្តរាយអំពីពួកគ្រហស្ថ។

សុគតំ បន និស្សាយ គហដ្ឋា ឃរមេសិនោ
សទ្ធហានា អរហតំ អរិយប្បញ្ញាយ ឈាយិនោ
ឥធ ធម្មំ ចរិត្វាន មគ្គំ សុគតិគាមិនំ
ឆន្ទិនោ ទេវលោកស្មឹ មោទន្តិ កាមកាមិនោ ។

ឯពួកគ្រហស្ថអ្នកស្វែងរកប្រយោជន៍ក្នុងផ្ទះ បានអាស្រ័យសង្ឃជាសាវ័កនៃព្រះសុគតហើយ ជឿសេចក្តីប្រតិបត្តិនិងពាក្យរបស់ព្រះអរហន្តទាំងឡាយ ដោយប្រាជ្ញាដ៏ប្រសើរ ជាអ្នកពិនិត្យ (ដោយអារម្មណូបនិជ្ឈាន និងលក្ខណូបនិជ្ឈាន) បានប្រព្រឹត្តធម៌ក្នុងសាសនានេះ ដែលជាផ្លូវប្រព្រឹត្តទៅកាន់សុគតិ រមែងជាអ្នកមានអំណររីករាយក្នុងទេវលោក បានសម្រេចតាមសេចក្តីប្រាថ្នា។

(បិដកលេខ ៥៣ ទំព័រ ១៤៣)

ឧទ្ទលវិមានវត្ថុគាថា

(បិដកលេខ ៥៥ ទំព័រ ៧៤)

ចត្តារោ ច បដិបន្នា ចត្តារោ ច ផលេ ឋិតា
ឯស សង្ឃោ ឧជុភូតោ បញ្ញាសីលសមាហិតោ ។
ជយមានានំ មនុស្សានំ បុញ្ញាបេក្ខាន បាណិនំ
កតេតំ ទ្វិបទិកំ បុញ្ញំ សង្ឃេទិន្នំ មហប្ផលំ ។

បុគ្គល ៤ ពួកអ្នកដល់នូវមគ្គ និងបុគ្គល ៤ ពួកតាំងនៅក្នុងផលនេះឯង ហៅថាសង្ឃ លោកប្រតិបត្តិត្រង់ប្រកបដោយប្រាជ្ញានិងសីល ព្រះពុទ្ធបានសម្តែងនូវបុណ្យដែលឱ្យផលក្នុងបច្ចុប្បន្នរបស់មនុស្សទាំងឡាយអ្នកឱ្យទាន ជាសត្វប្រាថ្នានូវបុណ្យ កាលធ្វើចំពោះសង្ឃដែលគេឱ្យទានទៅមានផលច្រើន ។

ឯសោ ហិ សង្ឃោ វិបុលោ មហគ្គតោ
ឯសប្បមេយ្យោ ឧទធីវ សាគរោ
ឯតេ ហិ សេដ្ឋា នរវីរិយសាវកា

បតង្គរ ធម្មកថំ ទ្វនីរយន្តិ ។

ព្រោះថាសង្ឃនុ៎ះ ជាសង្ឃមានគុណដ៏ធំទូលាយ សង្ឃនុ៎ះដូចជាសាគរ ដែលទ្រទ្រង់នូវទឹកមានជម្រៅរាប់មិនបាន ពួកសាវ័កអ្នកមានសេចក្តីព្យាយាមជាងនរៈទាំងនេះ ជាអ្នកប្រសើរមែនពិត អ្នកធ្វើនូវពន្ធឺ គឺញាណដល់សត្វលោក ហើយសម្តែងនូវធម្មកថា ។

តេសំ សុទិន្នំ សុហុតំ សុយិដ្ឋំ
យេ សង្ឃមុទ្ទិស្ស ទទន្តិ ទានំ
សា ទក្ខិណា សង្ឃគតា បតិដ្ឋិតា
មហប្ផលា លោកវិទូហិ វណ្ណិតា ។

ពួកសត្វណា បានឱ្យទានឧទ្ទិសចំពោះសង្ឃ (ទាននោះ) ឈ្មោះថាពួកសត្វទាំងនោះបានឱ្យល្អហើយបូជាតូចល្អហើយបូជាធំល្អហើយ សង្ឃគតាទក្ខិណាទាននោះឈ្មោះថា បុគ្គលតម្កល់ទុកល្អហើយ ជាទានមានផលច្រើន ព្រះសម្មាសម្ពុទ្ធទាំងឡាយជ្រាបច្បាស់នូវលោក ទ្រង់សរសើរហើយថា ។

ឯតានិសំ បុញ្ញមនុស្សរន្តា
យេ វេទជាតា ចិចរន្តិ លោកេ
វិនេយ្យ មច្ឆេរមលំ សមូលំ
អនិន្ទិតា សគ្គមុបេន្តិ ឋានំ ។

ជនទាំងឡាយណា កាលរឭកនូវបុណ្យដែលខ្លួនបានធ្វើហើយ ឧទ្ទិសចំពោះសង្ឃច្រាកដដូច្នោះ ហើយកើតមានសេចក្តីត្រេកអរ រមែងត្រាច់ទៅក្នុងលោក ជនទាំងឡាយនោះ ឈ្មោះថាកម្ចាត់បង់នូវមន្ទិល គឺសេចក្តីកំណាញ់

ព្រមទាំងឫស មិនមានគេតិះដៀលរមែងទៅកាន់ឋានសួគ៌។

អដ្ឋរបេតវត្ថុគាថា

(បិដកលេខ ៥៦ ទំព័រ ៥៥)

ឯដ្ឋលេ យថា ខេត្តេ ពីជំ ពហុំបិ រោបិតំ
ន ផលំ វិបុលំ ហោតិ ន បិ តោសេតិ កស្សកំ ។
តថេវ ទានំ ពហុកំ ទុស្សីលេសុ បតិដ្ឋិតំ
ន ផលំ វិបុលំ ហោតិ ន បិ តោសេតិ ទាយកំ ។

ពូជដែលបុគ្គលព្រោះហើយ សូម្បីមានប្រមាណច្រើនក្នុងស្រែទួលផល រមែងមិនបរិបូណ៌ ទាំងមិនញុំាងអ្នកស្រែឱ្យត្រេកអរបាន ដូចម្តេចមិញ ទានដែលបុគ្គលតម្កល់ទុកហើយមានប្រមាណច្រើន ក្នុងបុគ្គលទ្រុស្តសីលទាំងឡាយ ផលរមែងមិនបរិបូណ៌ទាំងមិនបានញុំាងទាយកឱ្យត្រេកអរបាន ក៏ដូច្នោះឯង។

យថាបិ តង្ខកេ ខេត្តេ ពីជំ អប្បម្បិ រោបិតំ
សម្មាធារំ បវេច្ឆន្នោ ផលំ តោសេតិ កស្សកំ ។
តថេវ សីលវន្តេសុ គុណវន្តេសុ តាទិសុ
អប្បកំបិ កតំ ការំ បុញ្ញំ ហោតិ មហប្ផលំ ។

ពូជដែលបុគ្គលព្រោះហើយ សូម្បីតិចក្នុងស្រែដ៏ល្អ កាលភ្លៀងធ្លាក់ស្រួល ផលរមែងញុំាងអ្នកស្រែឱ្យត្រេកអរបាន ដូចម្តេចមិញ សក្ការៈដែលបុគ្គលធ្វើហើយសូម្បីតិចតួចក្នុងតាទិបុគ្គលទាំងឡាយ អ្នកមានសីល មានគុណ បុណ្យរមែងមានផលច្រើនក៏ដូច្នោះឯង។

ទិចេយ្យ ទានំ ទាតព្វំ យត្ត ទិន្នំ មហប្ផលំ
ទិចេយ្យទានំ ទត្វាន សគ្គំ គច្ឆន្តិ ទាយកា ៗ

ទានដែលបុគ្គលឱ្យហើយដល់បុគ្គលណា រមែងមានផលច្រើន បុគ្គលគួរពិចារណាហើយសឹមឱ្យទាន ទាយកទាំងឡាយពិចារណាហើយឱ្យនូវទាន តែងទៅកាន់ឋានសួគ៌។

ទិចេយ្យ ទានំ សុគតប្បសដ្ឋំ
យេ ទក្ខិណេយ្យា ឥធ ជីវលោកេ
ឯតេសុ ទិន្នានិ មហប្ផលានិ
ពីជានិ ខុត្តានិ យថា សុខេត្តេ ៗ

ទានដែលបុគ្គលពិចារណាហើយទើបឱ្យ ព្រះសុគតទ្រង់សរសើរហើយទក្ខិណេយ្យបុគ្គលណា ដែលមាននៅក្នុងជីវលោកនេះ ទានដែលបុគ្គលឱ្យហើយដល់ទក្ខិណេយ្យបុគ្គលទាំងនោះ រមែងមានផលច្រើន ដូចពូជដែលបុគ្គលព្រោះហើយក្នុងស្រែល្អ។

ទិហារទានានុមោទនាគាថា

(ចាកមធុរត្ថវិលាសិនី អដ្ឋកថាពុទ្ធវង្ស)

អាទាសទានស្ស បទានិសំសំ

កោ នាម ឥត្ថំ បុរិសោ សមត្ថោ
អញ្ញាត្រ ពុទ្ធា បន លោកនាថា
យុត្តោ មុខានំ ទហុតេន ចាបិ ៗ

ក្រៅអំពីព្រះពុទ្ធជាម្ចាស់ទាំងឡាយ ដែលជាទីពឹងនៃលោក បុគ្គលមានមាត់ ១ នហុត បុរសណានឹងអាចពោលនូវអានិសង្សនៃការឱ្យអាវាស គឺទីស្នាក់អាស្រ័យបាន។

អាយុញ្ហោ វណ្ណញ្ហោ សុខំ ពលញ្ហោ
ឋានំ បសត្ថំ បដិភាណមេវ
ទទាតិ ឆាមាតិ បវុច្ចតេ សោ
យោ ទេតិ សប្បុរិសេ ឆរោ វិហារំ ។

នរជនណា ឱ្យទីស្នាក់អាស្រ័យដល់សង្ឃ នរជននោះ លោកពោលថា ឈ្មោះថាឱ្យនូវរបស់ដ៏ប្រសើរ គឺអាយុផង វណ្ណៈផង សុខៈផង ពលៈ និង បដិភាណផង ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សរសើរហើយ។

ឆាតា និវាសស្ស និវារណស្ស
សីតាទិនោ ជីវិតុបទ្ទវស្ស
បវេតិ អាយុំ បន តស្ស យស្មា
អាយុប្បទោ ហោតិ តមាហុ សន្តោ ។

ព្រោះហេតុដែលអ្នកឱ្យនូវទីស្នាក់អាស្រ័យ ដែលការពារនូវអន្តរាយនៃជីវិត មានសេចក្តីត្រជាក់ជាដើម រមែងរក្សានូវអាយុរបស់គេបាន ព្រោះដូច្នោះ ទើបសប្បុរសទាំងឡាយហៅអ្នកនោះថា ជាអ្នកឱ្យនូវអាយុ។

អច្ចុណ្ហសីតេ វសតោ និវាសេ
ពលញ្ហោ វណ្ណោ បដិភា ន ហោតិ
តស្មា ហិ សោ ទេតិ វិហារឆាតា

ពលញ្ច វណ្ណំ បដិភាណមេវ ៗ

ពលៈ វណ្ណៈ និងបដិភាណៈ រមែងមិនមានដល់អ្នកដែលនៅក្នុងទីក្តៅ និងត្រជាក់ យ៉ាងណាមិញ ព្រោះដូច្នោះឯង អ្នកឱ្យវិហារ គឺទីស្នាក់អាស្រ័យនោះ ទើបបានឈ្មោះថា ឱ្យពលៈផង វណ្ណៈ និងបដិភាណផងមែនពិត។

ទុក្ខស្ស សីតុណ្ហសិរីសបា ច ឥតាតបាធិប្បភវស្ស លោកេ
និវារណា នេកវិធស្ស និច្ចំ សុខប្បទោ ហោតិ វិហារទានា ៗ

អ្នកឱ្យវិហារ គឺទីលំនៅ រមែងឈ្មោះថាឱ្យនូវសេចក្តីសុខជានិច្ច ព្រោះការពារនូវសេចក្តីទុក្ខច្រើនយ៉ាង ដែលកើតអំពីត្រជាក់ ក្តៅ សត្វលូនវា គឺពស់ខ្យល់ និងកម្តៅថ្ងៃក្នុងលោក។

សីតុណ្ហាតាតបឌំសភុដ្ឋិ សិរីសបាវាឡមិគាធិទុក្ខំ
យស្មា និវារេតិ វិហារទានា តស្មា សុខំ វិន្ទតិ សោ បរត្ថ ៗ

ព្រោះហេតុដែលអ្នកឱ្យវិហារ រមែងការពារនូវសេចក្តីទុក្ខ មានត្រជាក់ ក្តៅ ខ្យល់ កម្តៅថ្ងៃ របោម ក្ងែង សត្វលូន និងសត្វសាហាវជាដើមបាន ព្រោះដូច្នោះ បុគ្គលនោះទើបឈ្មោះថា បានឱ្យនូវសេចក្តីសុខក្នុងលោកខាងមុខ។

បសន្នចិត្តោ ភវភោគហេតុំ មនោភិរាមំ មុទិតោ វិហារំ
យោ ទេតិ សីលាធិគុណោធិតានំ សព្ពំ ទទោ ឆាម បភុច្ចតេ សោ ៗ

បុគ្គលណា មានចិត្តជ្រះថ្លា ត្រេកអរហើយ បានឱ្យនូវវិហារដែលជាហេតុនៃភព និងភោគៈ ដែលគួរជាទីរីករាយនៃចិត្ត ដល់លោកអ្នកដែលមានគុណ មានសីលគុណជាដើមហើយ បុគ្គលនោះលោកហៅថា ឈ្មោះថា ជាអ្នកឱ្យគ្រប់យ៉ាង។

បហាយ មច្ឆេរមលំ សលោភំ គុណាលយានំ និលយំ ទទាតិ
ខិត្តោ‌ឥ សោ តត្ថ បរេហិ សង្គេ យថាភតំ ជាយតិ ទីឃសោកោ ៤

បុគ្គលណា លះនូវមន្ទិល គឺសេចក្តីកំណាញ់ ព្រមទាំងលោភៈហើយឱ្យនូវវិហារ គឺទីលំនៅ ដល់ពួកលោកអ្នកមានគុណ ជាទីនៅស្នាក់អាស្រ័យ បុគ្គលនោះដូចជាត្រូវអ្នកដទៃលើកទៅដាក់ក្នុងឋានសួគ៌ រមែងជាអ្នកប្រាសចាកសេចក្តីសោកសៅ ដល់ព្រមដោយសម្បត្តិដែលរួបរួមទុក។

អនុមោទនាគាថារបស់ព្រះពុទ្ធទីបង្ករ

(ចាកអដ្ឋកថាពុទ្ធវង្ស លេខ ៤៦ ទំព័រ ២៩៤)

ទានំ ទាម សុខាទីនំ និទានំ បរមំ មតំ
និព្វានំ បន សោឃានំ បតិដ្ឋាតិ បវុច្ចតិ ៤

ធម្មតាទាន លោកតែងពោលទុកថា ជាមូលហេតុសំខាន់នៃសេចក្តីសុខជាដើមនោះ និងជាទីតម្កល់នៃកាំជណ្តើរទាំងឡាយ ដែលតម្រង់ឆ្ពោះទៅកាន់ព្រះនិព្វាន។

ទានំ តាណំ មនុស្សានំ ទានំ ពន្ធុ បរាយនំ
ទានំ ទុក្ខាធិបន្នានំ សត្តានំ បរមា គតិ ៤

ទាន គឺជាគ្រឿងការពាររបស់ពួកមនុស្ស ជាផៅពង្ស ជាគ្រឿងដឹកនាំមុខ ទានជាគតិសំខាន់របស់សត្វដែលដល់នូវសេចក្តីទុក្ខ។

ទុក្ខូទិត្តរណេ ជ្ជេន ទានំ ទាទាតិ ទីបិតំ
តយរក្ខណតោ ទានំ ទគរន្តិ ច វណ្ណិតំ ៤

ទាន លោកពោលសរសើរថាគឺជានាវា ព្រោះអត្ថថា ជាយានជួយចម្លង អំពីទុក្ខ និងជានគរដែលអាចការពារភយន្តរាយបាន។

ទានំ ទុរាសទជ្ជេន ឥត្តមាសិវិសោតិ ច
ទានំ លោតមលាទីហិ បទុមំ អនុបលិត្តតោ ៗ

ទាន លោកពោលថា ជាអសិរពិស ព្រោះអត្ថថា បុគ្គលចូលទៅជិតបាន ដោយលំបាក ទាន ប្រៀបដូចជាផ្កាបទុម ព្រោះតែមន្ទិល ពោលគឺលោភៈជាដើម នោះ មិនអាចជាប់ប្រឡាក់បានទេ។

ឯត្ថិ ទានសមោ លោកេ បុរិសស្ស អទស្សយោ
បដិបជ្ជថ តស្មា តំ កិរិយាជ្ឈាសយេន ច ៗ

ទីពឹងពំនាក់របស់បុរស ដែលប្រាជកស្មើដោយទាន ឥតមានក្នុងលោក ព្រោះហេតុនោះហើយ អ្នកទាំងឡាយចូរបំពេញនូវទានតាមអធ្យាស្រ័យចុះ។

សគ្គលោកនិទានានិ ទានានិ បតិមា ឥធ
កោ ហិ នាម នរោ លោកេ ន ទទេយ្យ ហិតេ រតោ ៗ

នរជនរូបណា ដែលប្រកបដោយបញ្ញាគុណ តែងត្រេកអរចំពោះប្រយោជន៍ក្នុងលោកនេះ និងមិនឱ្យទានទាំងឡាយដែលជាហេតុនាំមកនូវឋានសួគ៌នោះសោត។

សុត្វា ទេវេសុ សម្បត្តឹ កោ នរោ ទានសម្ភវំ
ន ទជ្ជា សុខប្បទំ ទានំ ទានំ ចិត្តប្បមោទនំ ៗ

នរជនរូបណា បានឮមកថា ទានជាដែនកើតសម្បត្តិក្នុងទេវលោកទាំងឡា-

យនោះហើយ នឹងមិនឱ្យទានដែលអាចឱ្យដល់សេចក្តីសុខនោះ ទានជាគ្រឿងញុំាងសន្តានចិត្តឱ្យរីករាយ។

ទានេន បដិបន្នេន អច្ឆរាបរិវារិតោ
រមតេ សុចិរំ កាលំ នន្ទនេ សុរនន្ទនេ ៥

នរជនដែលបានបំពេញ (បុណ្យ) ហើយ គឺជាបុគ្គលដែលពួកនាងទេព-អប្សរតែងហែហម សប្បាយអភិរម្យក្នុងឧទ្យានឈ្មោះនន្ទវន ជាទីកន្លែងគួររីករាយរបស់ទេវតានោះរហូតអស់កាលជានិច្ច។

បីតិមុឡ្ហារំ ទិន្នតិ ទានា គារវមស្មឹ កច្ឆតិ លោកេ
កិត្តិមនន្តំ យាតិ ច ទានា ទិស្សរនីយោ ហោតិ ច ទានា ៥

បុគ្គល (អ្នកឱ្យទាន) តែងបាននូវបីតិដ៏ឱឡារិក រមែងត្រូវគេគោរពកោតក្រែងក្នុងលោកនេះ ទាយកនោះ តែងមានកិត្តិយសធំធេង និងជាបុគ្គលដែលមហាជនយកចិត្តទុកដាក់។

ទត្វា ទានំ យាតិ នរោ សោ ភោគសមិទ្ធឹ ឆឌ្ឍាយុ
សុស្សរតម្បិ ច ទិន្នតិ រូបំ សគ្គេ សទ្ធឹ កីឡតិ ទេវេហិ
ទិព្ពានេសុ ឋត្វា នានា មត្តមយូរាភិរុតេសុ ៥

នរជននោះឯង ឱ្យទានរួចហើយ ក៏ដល់នូវសេចក្តីសម្រេចនៃភោគសម្បត្តិ និងមានអាយុវែង តែងមានសូរសៀងពីរោះ និងមានរូបសម្បត្តិស្អាត អាស្រ័យនៅក្នុងវិមានទាំងឡាយដែលពួកហ្វូងសត្វក្ងោកគួរឱ្យពេញចិត្តច្រើនប្រភេទ បន្ទឺសំឡេងរាឱ្យរងំ ទាយកនោះ តែងលេងកម្សាន្តជាមួយពួកទេវតាក្នុងឋានសួគ៌។

ចោររិវរាជោទកឆាទកានំ ធនំ អសាធារណមេវ ទានំ
ទទាតិ តំ សាទកញ្ញាណភូមិ បច្ចេកភូមិ បន ពុទ្ធភូមិ ៤

ទាននោះមិនជាទ្រព្យសាធារណៈដល់ចោរ សត្រូវ ព្រះរាជា ទឹក និងភ្លើង ទាំងឡាយទេ ទាននោះ គឺតែងឱ្យសម្រេចសាវ័កបារមីភូមិ និងបច្ចេកភូមិ និងពុទ្ធ-បារមីភូមិទៀត។

យទិហីនេ

យទិ ហីនេ គតោ ឋានេ កាយទុច្ចរិតេន វា *បើញាតិណាមួយ ទៅកើតក្នុងទីដ៏ថោកទាប ព្រោះកាយទុច្ចរិតក្តី (វចីទុច្ចរិតក្តី មនោទុច្ចរិតក្តី),*

ឥមិនា បុញ្ញតេជេន តម្ហា ឋានា បមុញ្ចតុ *ក៏សូមឱ្យរួចរដោះចាកទី (ដ៏-ថោកទាប) នោះ ដោយតេជៈគឺបុណ្យនេះ,*

យទិ ទេវបុរេ រម្មេ វិមានេ រតនសោភិតេ *ឬបើទៅកើតក្នុងទេវបុរី ជាវិមានគួររីករាយ ដែលជាស្ថានមានលម្អដោយរតនៈផ្សេងៗ ស្រាប់ហើយ,*

ឥមិនា បុញ្ញតេជេន អិយ្យោ អិយ្យោ បវឌ្ឍតុ *ក៏សូមឱ្យរឹងរឹតតែចម្រើនជាកិយ្យោភាព ដោយតេជៈគឺបុណ្យនេះ,*

ឯវំ មហិទ្ធិយា ឯសា យទិទំ បុញ្ញសម្បទា *បុញ្ញសម្បទា គឺគុណជាតិជាហេតុដល់ព្រមដោយបុណ្យឯណា បុញ្ញសម្បទានេះ មានឫទ្ធិដ៏ធំក្រៃលែងដោយប្រការយ៉ាងនេះ,*

តស្មា ធីរា បសំសន្តិ បណ្ឌិតា កតបុញ្ញតំ *ព្រោះហេតុនោះ បណ្ឌិតទាំង-ទ្បាយអ្នកមានប្រាជ្ញា រមែងសរសើរនូវភាពនៃបុគ្គលអ្នកមានបុណ្យធ្វើទុកហើយ,*

សុខោ វិបាកោ បុញ្ញានំ *ផលរបស់បុណ្យទាំងឡាយ រមែងនាំមកនូវសេចក្តីសុខ,*

អធិប្បាយោ សមិជ្ឈតិ *សេចក្តីប្រាថ្នារមែងសម្រេច,*

ខិប្បញ្ហា បរិយោសានេ និព្វានំ សមធិគច្ឆតិ *ម្យ៉ាងទៀត ក្នុងកាលជាទីបំផុត បុគ្គលរមែងបាននូវព្រះនិព្វានដ៏ធាប់រហ័ស,*

យោ តាជនសហស្សេហិ បូរណំ ទរភោជនំ
ទទេយ្យាបរិមាណានំ ឯកបត្តម្បិ ទាលភេ
ពុទ្ធុប្បាទេ សារីបុត្តោ យេ ចញ្ញោ អគ្គសាវកា

បុគ្គលគប្បីឱ្យនូវវរភោជនដ៏ពេញដោយភាជន:មួយពាន់ ក៏មិនបានស្មើនឹងភោជនមួយបាត្រ ដែលគេបានឱ្យហើយដល់ព្រះសារីបុត្រ និងពួកអគ្គសាវ័កដទៃក្នុងពុទ្ធុប្បាទ(នេះ) ដែលមានគុណប្រមាណមិនបាន,

បត្តបូរនុភាវេន មាតាបិតា បមុញ្ចរេ *(ព្រោះហេតុនោះ) បានជាមាតានិងបិតារមែងរួច(ចាកទីដ៏ថោកទាប)ដោយអានុភាពនៃបាយដែលពេញក្នុងបាត្រ។*

អនុមោទនាក្នុងការចារមង្គល

(មានពិធីឡើងផ្ទះថ្មីជាដើម)

****

មង្គលសូត្រ

(មង្គល ៣៨ ប្រការ)

អសេវនា ច ពាលានំ ឯ ល ឯ *កិរិយាមិនសេពគប់នូវបុគ្គលពាលទាំង-ឡាយ ១ ។ ល ។* (បិដកលេខ ៥២ ទំព័រ ៤ និងលេខ ៥៤ ទំព័រ ៨៥)

(គប្បីសូត្យឱ្យពិស្តារផងចុះ ក្នុងទីនេះមិនបានដាក់ទាំងស្រុងទេ ព្រោះមាន នៅទំព័រខាងមុខហើយ)

បុព្វណ្ហសូត្រ

(ពេលវេលាដែលជានក្ខត្តឫក្សល្អ)

យេ ភិក្ខវេ សត្តា បុព្វណ្ហសមយំ កាយេន សុចរិតំ ចរន្តិ វាចាយ សុចរិតំ ចរន្តិ មនសា សុចរិតំ ចរន្តិ សុបុព្វណ្ហោ ភិក្ខវេតេសំ សត្តានំ ឯ

ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយណា ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត ក្នុងបុព្វណ្ហសម័យ ម្នាលភិក្ខុទាំងឡាយ សត្វទាំងនោះ ឈ្មោះថា មានបុព្វណ្ហសម័យដ៏ល្អ ។

យេ ភិក្ខវេ សត្តា មជ្ឈន្ហិកសមយំ[1] **កាយេន សុចរិតំ ចរន្តិ វាចាយ**

១-បាលីក្នុងច្បាប់ឆដ្ឋសង្គាយនាថា **មជ្ឈន្ហិកសមយំ** ។

សុចរិតំ ចរន្តិ មនសា សុចរិតំ ចរន្តិ សុមជ្ឈន្តិកោ ភិក្ខវេ តេសំ សត្តានំ ។

ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយណា ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត ក្នុងមជ្ឈន្តិកសម័យ ម្នាលភិក្ខុទាំងឡាយ សត្វទាំងនោះ ឈ្មោះថា មានមជ្ឈន្តិកសម័យដ៏ល្អ។

យេ ភិក្ខវេ សត្តា សាយណ្ហសមយំ កាយេន សុចរិតំ ចរន្តិ វាចាយ សុចរិតំ ចរន្តិ មនសា សុចរិតំ ចរន្តិ សុសាយណ្ហោ ភិក្ខវេ តេសំ សត្តានំ ។

ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយណា ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត ក្នុងសាយណ្ហសម័យ ម្នាលភិក្ខុទាំងឡាយ សត្វទាំងនោះឈ្មោះថា មានសាយណ្ហសម័យដ៏ល្អ។

សុទក្ខិណំ សុមនំ សុបភាតំ សុហុដ្ឋិតំ
សុខណោ សុមុហុត្តោ ច សុយិដ្ឋំ ព្រហ្មចារិសុ

(ពេលណាដែលសត្វទាំងឡាយ ប្រព្រឹត្តល្អដោយកាយ វាចា ចិត្ត ពេលនោះ) ឈ្មោះថា ជានក្ខត្តឫក្សល្អ ជាមង្គលល្អ ជាពេលភ្ញីស្វាងល្អ ជាពេលនៃអរុណរះល្អ ជាខណៈល្អ ជាយាមល្អ (ទានដែលបុគ្គលបានបូជាហើយ) ដល់ព្រហ្មចារីបុគ្គលទាំងឡាយ (ក្នុងពេលនោះ) ឈ្មោះថា ជាគ្រឿងបូជាល្អ,

បទក្ខិណំ កាយកម្មំ វាចាកម្មំ បទក្ខិណំ
បទក្ខិណំ មនោកម្មំ បណិធីតេ បទក្ខិណា

(ក្នុងថ្ងៃនោះ) កាយកម្មក៏ឈ្មោះថានាំឱ្យមានសេចក្តីចម្រើន វចីកម្មក៏ឈ្មោះថានាំឱ្យមានសេចក្តីចម្រើន មនោកម្មក៏ឈ្មោះថានាំឱ្យមានសេចក្តីចម្រើន

សេចក្តីប្រាថ្នាទាំងឡាយរបស់អ្នកទាំងនោះ ក៏ឈ្មោះថានាំឱ្យមានសេចក្តីចម្រើន,

បឋវិណានិ កត្វាន លភន្តេ បឋវិណេ *បុគ្គលដែលបានធ្វើនូវកាយកម្ម វចីកម្ម មនោកម្ម គួរដល់សេចក្តីចម្រើន(យ៉ាងនេះ)ហើយក៏រមែងបាននូវប្រយោជន៍ដ៏ចម្រើនទាំងឡាយ។*

តេ អត្តលទ្ធា សុខិតា ទិរុទ្ធា ពុទ្ធសាសនេ
អរោគា សុខិតា ហោថ សហ សព្ពេហិ ញាតិភិ ៚

អ្នកទាំងឡាយ (ទាំងបុរស ទាំងស្ត្រី) នោះ ចូរបាននូវប្រយោជន៍ បាននូវសេចក្តីសុខ ចូរចម្រើនក្នុងព្រះពុទ្ធសាសនា ចូរកុំឱ្យមានរោគ ឱ្យបាននូវសេចក្តីសុខ ព្រមទាំងញាតិទាំងឡាយគ្រប់គ្នា។

(បិដកលេខ ៤១ ទំព័រ ៤៧៥)

សប្បុរិសសូត្រ

(បិដកលេខ ៤៥ ទំព័រ ៨៨)

បញ្ចិមានិ ភិក្ខវេ សប្បុរិសទានានិ ៚ *ម្នាលភិក្ខុទាំងឡាយ សប្បុរិសទាននេះ មាន ៥ យ៉ាង ។* **កតមានិ បញ្ច ៚** *សប្បុរិសទាន ៥ យ៉ាងដូចម្តេចខ្លះ?*

សទ្ធាយ ទានំ ទេតិ *គឺឱ្យទានដោយសទ្ធា ១,*

សក្កច្ចំ ទានំ ទេតិ *ឱ្យទានដោយគោរព ១,*

កាលេន ទានំ ទេតិ *ឱ្យទានតាមកាលគួរ ១,*

អនុគ្គហិតចិត្តោ[1] **ទានំ ទេតិ** *ឱ្យទានដោយចិត្តមិនជាប់ជំពាក់ ១,*

អត្តានញ្ច បរញ្ច អនុបហច្ច ទានំ ទេតិ *ឱ្យទានដោយមិនបានបៀតបៀនខ្លួនឯង និងអ្នកដទៃ ១ ។*

សទ្ធាយ ខោ បន ភិក្ខវេ ទានំ ទត្វា យត្ត យត្ត តស្ស ទានស្ស វិបាកោ និព្វត្តតិ អឌ្ឍោ ច ហោតិ មហទ្ធនោ មហាភោគោ អភិរូបោ ច ហោតិ ទស្សនីយោ បាសាទិកោ បរមាយ វណ្ណបោក្ខរតាយ សមន្នាគតោ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលឱ្យទានដោយសទ្ធា ដោយផលទាននោះ កើតក្នុងទីណា ៗ ជាបុគ្គលស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើនផង ជាបុគ្គលមានរូបល្អគួរមិលមើល ជាទីជ្រះថ្លា ប្រកបដោយភាពជាអ្នកមានសម្បុរល្អដ៏ក្រៃលែងផង។

សក្កច្চំ ខោ បន ភិក្ខវេ ទានំ ទត្វា យត្ត យត្ត តស្ស ទានស្ស វិបាកោ និព្វត្តតិ អឌ្ឍោ ច ហោតិ មហទ្ធនោ មហាភោគោ យេបិស្ស តេ ហោន្តិ បុត្តាតិ វា ទារាតិ វា ទាសាតិ វា បេស្សាតិ វា កម្មករាតិ វា តេបិ សុស្សូសន្តិ សោតំ ឱទហន្តិ អញ្ញាចិត្តំ ឧបដ្ឋបេន្តិ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលឱ្យទានដោយគោរព ដោយផលទាននោះ កើតក្នុងទីណា ៗ ជាបុគ្គលស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើនផង ពួកជនណា ទោះកូនក្តី ប្រពន្ធក្តី ខ្ញុំក្តី អ្នកបម្រើក្តី អ្នកធ្វើការងារក្តី របស់បុគ្គលនោះ

១-**អនុគ្គហិតចិត្ត** មកពី **ន** + **ឧគ្គហិត** + **ចិត្ត** ប្រែថា អ្នកមិនមានចិត្តដែលតណ្ហា និងទិដ្ឋិកាន់យក, អ្នកមានចិត្តមិនជាប់ជំពាក់, អ្នកមានចិត្តលះបង់ស្រឡះ។ ច្បាប់សីហឡថា **អនគ្គហិតចិត្ត**, ពាក្យនេះមកពី **ន** + **អ** + **គហិត** + **ចិត្ត** ប្រែដូចគ្នានឹងខាងលើដែរ ។ ដូច្នេះទើបយើងសម្រេចប្រែជាថ្មីដូច្នេះវិញ។

ជនទាំងនោះ ចង់ដើម្បីស្តាប់ ផ្ទៀងត្រចៀកតាំងចិត្តដើម្បីដឹងផង។

ការេន ខោ បន តិក្ខវេ ទានំ ទត្វា យត្ត យត្ត តស្ស ទានស្ស វិបាកោ និព្វត្តតិ អឌ្ឍោ ច ហោតិ មហទ្ធនោ មហាភោគោ ករណីយតោ ចស្ស អត្តា បរិបូរ ហោន្តិ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលឱ្យទានតាមកាលដ៏គួរ ដោយផលទាននោះ កើតក្នុងទីណាៗ ជាបុគ្គលសុកសួស្តី មានទ្រព្យច្រើន មានភោគៈច្រើនផង ប្រយោជន៍ គឺភោគៈដ៏ពោរពេញ រមែងមកតាមកាលដ៏គួរដល់បុគ្គលនោះផង។

អនុគ្គហិតចិត្តោ ខោ បន តិក្ខវេ ទានំ ទត្វា យត្ត យត្ត តស្ស ទានស្ស វិបាកោ និព្វត្តតិ អឌ្ឍោ ច ហោតិ មហទ្ធនោ មហាភោគោ ឧឡារេសុ ច បញ្ចសុ កាមគុណេសុ ភោគាយ ចិត្តំ នមតិ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលឱ្យទានដោយចិត្តមិនជាប់ជំពាក់ ដោយផលទាននោះ កើតក្នុងទីណាៗ ជាបុគ្គលសុកសួស្តី មានទ្រព្យច្រើន មានភោគៈច្រើនផង រមែងបង្អោនចិត្តទៅដើម្បីបរិភោគក្នុងកាមគុណ ៥ ដ៏លើសលុបផង។

អត្តានញ្ច បរញ្ច អនុបហច្ច ខោ បន តិក្ខវេ ទានំ ទត្វា យត្ត យត្ត តស្ស ទានស្ស វិបាកោ និព្វត្តតិ អឌ្ឍោ ច ហោតិ មហទ្ធនោ មហាភោគោ ន ចស្ស កុតោចិ ភោគានំ ឧបឃាតោ អាគច្ឆតិ អគ្គិតោ វា ឧទកតោ វា រាជតោ វា ចោរតោ វា អប្បិយតោ វា ទាយាទតោ វា ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលឱ្យទានដោយមិនបានបៀតបៀនខ្លួនឯង និងអ្នកដទៃ ដោយផលទាននោះ កើតក្នុងទីណាៗ ជាបុគ្គលសុកសួស្តី មានទ្រព្យច្រើន មានភោគៈច្រើនផង សេចក្តីអន្តរាយនៃភោគៈទាំងឡាយ មិនមានមកអំពីទីណា

មួយ គឺអំពីភ្លើង អំពីទឹក អំពីស្តេច អំពីចោរ អំពីហេតុមិនជាទីស្រឡាញ់ និងអំពីមនុស្សជាទាយាទ។

ឥមានិ ខោ តិក្ខវេ បញ្ច សប្បុរិសទានានិ *ម្នាលភិក្ខុទាំងឡាយ សប្បុរិសទានមាន ៥ យ៉ាងនេះឯង។*

អាទិយសុត្តគាថា

(គោលការណ៍ប្រទ្រព្យឱ្យជាប្រយោជន៍)

ភុត្តា ភោគា រតា ភច្ចា ខិតិណ្ណោ អាបទាសុ មេ
ខទ្ធគ្គា ទក្ខិណា ទិន្នា អថោ បញ្ចាពលី កតា
ខបដ្ឋិតា សីលវន្តោ សញ្ញតា ព្រហ្មចារិយោ ៗ
យទត្ថំ ភោគមិច្ឆេយ្យ បណ្ឌិតោ ឃរមាវសំ
សោ មេ អត្ថោ អនុប្បត្តោ កតំ អនុតាបិយំ ៗ
ឯតំ អនុស្សរំ មច្ចោ អរិយធម្មេ ឋិតោ នរោ

សត្វ គឺនរជនប្រុសស្រី កាលរឭកឃើញនូវហេតុនេះ(ដូច្នេះ)ហើយឋិតនៅក្នុងអរិយធម៌ គឺសីល ៥ (ហេតុដែលរឭកឃើញនោះដូច្នេះថា) ភោគសម្បត្តិទាំងឡាយ(គឺអញ) បានបរិភោគប្រើប្រាស់ហើយ បុគ្គលដែលអញត្រូវចិញ្ចឹម (អញ) ក៏បានចិញ្ចឹមហើយ អន្តរាយទាំងឡាយ(អញ) ក៏បានការពារហើយ ទក្ខិណាទានមានផលដ៏ខ្ពស់(អញ)ក៏បានឱ្យហើយ មួយវិញទៀត ពលិកម្មគឺបំពេញការកុសល ៥ យ៉ាង (អញ) ក៏បានធ្វើហើយ លោកអ្នកមានសីល ជាព្រហ្មចារី ដែលជាអ្នកសង្រួមទាំងឡាយ (អញ) ក៏បានទំនុកបម្រុងហើយ មនុស្សជាបណ្ឌិត គឺអ្នកដែល

មានប្រាជ្ញាឈ្លាសវៃ កាលដែលនឹងនៅគ្រប់គ្រងនូវផ្ទះ គប្បីប្រាថ្នានូវភោគសម្បត្តិ ដើម្បីប្រយោជន៍ឯណា ប្រយោជន៍នោះ គឺអញបានដល់ហើយដោយលំដាប់ កម្ម ដែលមិនក្តៅក្រហាយតាមក្នុងកាលជាខាងក្រោយ (អញ)ក៏បានធ្វើហើយ។

ឥធេវ នំ បសំសន្តិ បេច្ច សគ្គេ បមោទតិ *អ្នកប្រាជ្ញទាំងឡាយ តែងសរសើរនូវបុគ្គលនោះក្នុងលោកនេះ បុគ្គលនោះ លុះដល់រំលាងខន្ធទៅកាន់បរលោកនាយ នឹងរីករាយសប្បាយក្នុងស្ថានសួគ៌*[1]*។*

សង្គហវត្ថុគាថា

(សង្គហវត្ថុ ៤ យ៉ាង)

ទានញ្ច បេយ្យវជ្ជញ្ច អត្ថចរិយា ច យា ឥធ
សមានត្តតា ច ធម្មេសុ តត្ថ តត្ថ យថារហំ

ការចែកចាយទ្រព្យសម្បត្តិឱ្យ ១ ពោលនូវពាក្យ គឺបុគ្គលគប្បីស្រឡាញ់ ១ ប្រយោជន៍ គឺបុគ្គលគប្បីប្រព្រឹត្ត (ដោយអំណាចញុំាងកិច្ចដែលកើតឡើង ឱ្យសម្រេច) ១ ភាវៈជាអ្នកមានខ្លួនស្មើ គឺមិនប្រកាន់ខ្លួន ១ (ទាំង ៤ នេះ) ណាៗ មានក្នុងលោកនេះ បុគ្គលត្រូវធ្វើក្នុងសង្គហធម៌នោះៗ ក្នុងបុគ្គលនោះៗ តាមសមគួរ។

ឯតេ ខោ សង្គហា លោកេ រថស្សាណីវ យាយតោ *ការសង្គ្រោះទាំង-ឡាយនេះ មាននៅក្នុងលោក (នោះសត្វលោកទើបប្រព្រឹត្តទៅបាន) ដូចជាភ្លៅនៃរថដែលជាស្នូល ជាគ្រឿងញុំាងរថឱ្យប្រព្រឹត្តទៅ,*

ឯតេ ច សង្គហា នាស្សុ ន មាតា បុត្តការណា

១-សេចក្តីប្រែដកពីស្បៃវរភៅអនុមោទនាវិធីរបស់អាចារ្យ ប៉ែន-សុខ។

លភេថ មានំ បូជំ វា បិតា វា បុត្តការណា

បើសង្គហធម៌ទាំងឡាយនេះមិនមានហើយ មាតាក្តី ក៏មិនគប្បីបាននូវសេចក្តីរាប់អាន ឬបូជា ព្រោះហេតុនៃបុត្ត បិតាក្តី ក៏មិនគប្បីបាននូវសេចក្តីរាប់អាន ឬបូជាព្រោះហេតុនៃបុត្តឡើយ។

យស្មា ច សង្គហា ឯតេ សមវេក្ខន្តិ បណ្ឌិតា *ក៏ព្រោះហេតុឯណា បណ្ឌិតទាំងឡាយ សំឡឹងឃើញនូវសង្គហធម៌ទាំងឡាយនេះ,*

តស្មា មហត្តំ បប្បោន្តិ បាសំសា ច ភវន្តិ តេ *ព្រោះហេតុនោះ បានជាបណ្ឌិតទាំងឡាយនោះ លោកបានដល់នូវភាវៈជាអ្នកប្រសើរបំផុត ហើយជាបុគ្គលគួរឱ្យអ្នកផងគេសរសើរ។*

(បិដកលេខ ៤២ ទំព័រ ៨0)

ខេមាខេមសរណទីបិកគាថា

(ទីពឹងដ៏ក្សេម និងមិនក្សេម

ពហុំ វេ សរណំ យន្តិ បព្វតានិ វនានិច
អារាមរុក្ខចេត្យានិ មនុស្សា ភយតជ្ជិតា ។

មនុស្សទាំងឡាយ មានចំនួនច្រើន កាលដែលភ័យគ្រប សង្កត់ហើយ តែងយកភ្នំទាំងឡាយខ្លះ ព្រៃទាំងឡាយខ្លះ អារាម និងដើមឈើដែលជាចេតិយទាំង-ឡាយខ្លះ ជាទីពឹង។

នេតំ ខោ សរណំ ខេមំ នេតំ សរណមុត្តមំ

នេតំ សរណមាគម្ម សព្វទុក្ខា បមុច្ចតិ ។

ទីពឹងនុ៎ះឯង មិនមែនជាទីពឹងដ៏ក្សេមទេ ទីពឹងនុ៎ះ មិនមែនជាទីពឹងដ៏ឧត្តមទេ បុគ្គលមិនដែលរួចស្រឡះចាកទុក្ខទាំងពួង ព្រោះអាស្រ័យនូវទីពឹងនុ៎ះទេ ។

យោ ច ពុទ្ធញ្ច ធម្មញ្ច សង្ឃញ្ច សរណំ គតោ
ចត្តារិ អរិយសច្ចានិ សម្មប្បញ្ញាយ បស្សតិ
ទុក្ខំ ទុក្ខសមុប្បាទំ ទុក្ខស្ស ច អតិក្កមំ
អរិយញ្ចដ្ឋង្គិកំ មគ្គំ ទុក្ខូបសមគាមិនំ ។

បុគ្គលណាមួយ បានដល់នូវព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ជាទីពឹងទីរឭក ហើយ ឃើញនូវអរិយសច្ចទាំង ៤ គឺសេចក្តីទុក្ខ ១ សមុទ័យជាដែនកើតឡើងព្រមនៃសេចក្តីទុក្ខ ១ និរោធជាទីកន្ទងបង់នូវសេចក្តីទុក្ខ ១ មគ្គមានអង្គ ៨ ដ៏ប្រសើរដែលញុំងសត្វឱ្យដល់នូវព្រះនិព្វាន ជាឋានរំងាប់បង់នូវសេចក្តីទុក្ខ ១ ដោយប្រាជ្ញាដ៏ត្រូវ ។

ឯតំ ខោ សរណំ ខេមំ ឯតំ សរណមុត្តមំ
ឯតំ សរណមាគម្ម សព្វទុក្ខា បមុច្ចតិ ។

ទីពឹងនុ៎ះឯង ជាទីពឹងដ៏ក្សេម ទីពឹងនុ៎ះ ជាទីពឹងដ៏ឧត្តម បុគ្គលរមែងរួចស្រឡះចាកទុក្ខទាំងពួង ព្រោះអាស្រ័យនូវទីពឹងនុ៎ះឯង ។

(បិដកលេខ ៥២ ទំព័រ ៦១)

អនឡ្ឍសុត្តគាថា

(ភាពជាអ្នកមិនទ័លក្រ ជីវិតមិនឥតប្រយោជន៍)

យស្ស សទ្ធា តថាគតេ អចលា សុបតិដ្ឋិតា *បុគ្គលឯណា (មាន) សេចក្តីជឿតម្កល់មាំឥតកម្រើកចំពោះព្រះតថាគត*

សីលញ្ច យស្ស កល្យាណំ អរិយកន្តំ បសំសិតំ *បុគ្គលឯណា (មាន) សីលដ៏ល្អ ជាទីត្រេកអរនៃព្រះអរិយៈ ដែលព្រះអរិយៈទាំងឡាយលោកសរសើរ ហើយ*

សង្ឃេ បសាទោ យស្សត្ថិ ឧជុភូតញ្ច ទស្សនំ *បុគ្គលឯណា មានសេចក្តីជ្រះថ្លាចំពោះព្រះសង្ឃផង មានសេចក្តីយល់ឃើញដ៏ត្រូវត្រង់ផង*

អនឡ្ឍោតិ តំ អាហុ អមោឃំ តស្ស ជីវិតំ *បណ្ឌិតទាំងឡាយ លោកហៅបុគ្គលនោះថា មិនមែនជាអ្នកទ័លក្រឡើយ ជីវិតរបស់បុគ្គលនោះ មិនមែនសោះសូន្យឥតប្រយោជន៍ឡើយ។*

តស្មា សទ្ធញ្ច សីលញ្ច បសាទំ ធម្មទស្សនំ
អនុយុញ្ជេថ មេធាវី សរំ ពុទ្ធានសាសនំ ៗ

ព្រោះហេតុនោះ បុគ្គលអ្នកមានប្រាជ្ញា កាលរឭកឃើញនូវសាសនា គឺពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ក៏គួរប្រកបរឿយៗ នូវសេចក្តីជឿផង នូវសីលផង នូវសេចក្តីជ្រះថ្លាផង នូវកិរិយាឃើញនូវធម៌ផង។

(បិដកលេខ ៣០ ទំព័រ ២៨៣ និងលេខ ៤៤ ទំព័រ ១០៩)

អនុមោទនាវគ្គកថា

និងបច្ចេកពុទ្ធានុមោទនាគាថា

យថា វារិវហា បូរា បរិបូរេន្តិ សាគរំ *ផ្លូវទឹកទាំងឡាយ មានទន្លេនិងស្ទឹងជាដើមដ៏ពេញ ដែលញុំងសាគរ គឺសមុទ្រឱ្យពេញព្រៀបដូចម្តេចមិញ។*

ឯវមេវ ឥតោ ទិន្នំ បេតានំ ឧបកប្បតិ *ទានដែលទាយកទាយិកាឧទ្ទិសឱ្យហើយអំពីលោកនេះ រមែងសម្រេចផលដល់អ្នកដែលចែកស្ថានទៅកាន់បរលោកហើយដូច្នោះឯង។*

ឥច្ឆិតំ បត្ថិតំ តុម្ហំ ខិប្បមេវ សមិជ្ឈតុ[1] *សូមឥដ្ឋផល គឺផលជាទីគាប់ចិត្ត ដែលអ្នកប្រាថ្នាហើយ តាំងចិត្តហើយ ចូរឱ្យសម្រេចដល់អ្នក ឱ្យបានឆាប់រួសរាន់ទាន់ចិត្ត,*

សព្វេ បូរេន្តុ សង្កប្បា *សូមតម្រិះត្រូវទាំងពួង ចូរពេញ (ដល់អ្នក),*

ចន្ទោ បណ្ណរសោ យថា *ដូចព្រះចន្ទក្នុងថ្ងៃ ១៥ កើត,*

មណិ ជោតិរសោ យថា *(ពុំនោះសោត) ដូចកែវមណី មានរស្មីដ៏រុងរឿងជាកែវវិសេស អាចញុំងសេចក្តីប្រាថ្នាទាំងពួងឱ្យសម្រេចបាន។*

សព្ជីតិយោ

សព្ជីតិយោ ភវន្តុ *សូមឱ្យចង្រៃទាំងពួងទាំងឡាយប្រាសចេញ គឺថាចូរ*

---

១ -ពាក្យអនុមោទនារបស់ព្រះបច្ចេកពុទ្ធទាំងឡាយ។ (ចាកធម្មបទដ្ឋកថា បាលី ភាគ ២ ទំព័រ៦៨)

ឱ្យចៀសវាងចេញឆ្ងាយទៅ,

សព្វរោគោ វិនស្សតុ *សូមឱ្យរោគទាំងពួង (របស់អ្នក) ជាសះស្បើយទៅ,*

មា តេ ភវត្វន្តរាយោ *អន្តរាយកុំបីមានដល់អ្នកឡើយ*

សុខី ទីឃា យុកោ ភវ *សូមឱ្យអ្នកជាបុគ្គល មានសេចក្តីសុខ មានអាយុវែងៗ*

អភិវាទនសីលិស្ស និច្ចំ វុឌ្ឍាបចាយិនោ

ចត្តារោ ធម្មា វឌ្ឍន្តិ អាយុ វណ្ណោ សុខំ ពលំ[1]ៗ

ធម៌ គឺពរទាំងឡាយ ៤ ប្រការ គឺអាយុ ១ ពណ៌សម្បុរកាយ ១ សេចក្តីសុខ ១ កម្លាំង ១ រមែងចម្រើនអស់កាលជានិច្ច ដល់អ្នកដែលមានសេចក្តីឱនកាយ ថ្វាយបង្គំដល់ព្រះរតនត្រ័យជាប្រក្រតី និងអ្នកដែលមានសេចក្តីគោរពកោតក្រែង ដល់បុគ្គលដែលជាអ្នកមានសេចក្តីចម្រើនដោយគុណ មានសីលគុណជាដើម ឬដែលចម្រើនដោយវ័យ គឺចាស់ព្រឹទ្ធាចារ្យ ។

មង្គលចក្កវាឡ

សព្វពុទ្ធានុភាវេន *ដោយអានុភាពនៃព្រះពុទ្ធគ្រប់ព្រះអង្គ*

សព្វធម្មានុភាវេន *ដោយអានុភាពនៃព្រះធម៌ទាំងពួង*

សព្វសង្ឃានុភាវេន *ដោយអានុភាពនៃព្រះសង្ឃទាំងពួង*

១- ធម្មបទគាថា បិដកលេខ ៥២ ទំព័រ ៤៥ ។

ពុទ្ធរតនំ ធម្មរតនំ សង្ឃរតនំ តិណ្ណំ រតនានំ អានុភាវេន *ដោយអានុភាពនៃព្រះរតនៈទាំង ៣ គឺពុទ្ធរតនៈ ១ ធម្មរតនៈ ១ សង្ឃរតនៈ ១*

ចតុរាសីតិសហស្សធម្មក្ខន្ធានុភាវេន *ដោយអានុភាពនៃព្រះធម្មក្ខន្ធ ៨ ម៉ឺន ៤ ពាន់*

បិដកត្តយានុភាវេន *ដោយអានុភាពនៃព្រះត្រៃបិដក*

ជិនសាវកានុភាវេន *ដោយអានុភាពនៃសាវ័កនៃព្រះជិនស្រី*

សព្ពេតេរោគា *រោគទាំងឡាយទាំងពួងនៃអ្នក*

សព្ពេ តេ ភយា *ភ័យទាំងឡាយទាំងពួងនៃអ្នក*

សព្ពេ តេ អន្តរាយា *អន្តរាយទាំងឡាយទាំងពួងនៃអ្នក*

សព្ពេ តេ ឧបទ្ទវា *ឧបទ្រពទាំងឡាយទាំងពួងនៃអ្នក*

សព្ពេ តេ ទុន្និមិត្តា *និមិត្តអាក្រក់ទាំងឡាយទាំងពួងនៃអ្នក*

សព្ពេ តេ អវមង្គលា *អពមង្គលទាំងឡាយទាំងពួងនៃអ្នក*

វិនស្សន្តុ *សូមឱ្យវិនាសបាត់ទៅ។*

អាយុវឌ្ឍកោ *សេចក្តីចម្រើនដោយអាយុ*

ធនវឌ្ឍកោ *សេចក្តីចម្រើនដោយទ្រព្យ*

សិរីវឌ្ឍកោ *សេចក្តីចម្រើនដោយសិរីសួស្តី*

យសវឌ្ឍកោ *សេចក្តីចម្រើនដោយយសបរិវារ*

ពលវឌ្ឍកោ *សេចក្តីចម្រើនដោយកម្លាំង*

វណ្ណវឌ្ឍកោ *សេចក្តីចម្រើនដោយពណ៌សម្បុរកាយ*

សុខវឌ្ឍកោ *សេចក្តីចម្រើនដោយសុខ*

ហោតុ សព្វទា *សូមឱ្យមានដល់អ្នកឱ្យបានសព្វៗកាល*

ទុក្ខរោគភយា វេរ *សេចក្តីទុក្ខ និងរោគ និងភ័យ និងពៀរទាំងឡាយក្តី*

សោកា សត្តូ ចុបទ្ទវា *សេចក្តីសោកទាំងឡាយក្តី សត្រូវ និងឧបទ្រវទាំង-ឡាយក្តី*

អនេកា អន្តរាយាបិ *អន្តរាយទាំងឡាយដ៏ច្រើនក្តី*

វិនស្សន្តុ ច តេជសា *សូមឱ្យវិនាសបាត់ទៅ ដោយតេជៈ (នៃអានុភាពមានពុទ្ធានុភាពជាដើមនោះ)។*

ជយសិទ្ធិ ធនំ លាភំ *សេចក្តីសម្រេចនៃជ័យជម្នះក្តី ទ្រព្យក្តី លាភក្តី*

សោត្ថិភាគ្យំ សុខំពលំ *សួស្តីក្តី ជោគជ័យល្អក្តី សេចក្តីសុខក្តី កម្លាំងក្តី*

សិរី អាយុ ច វណ្ណោ ច *បុញ្ញសិរីក្តី អាយុក្តី ពណ៌សម្បុរកាយក្តី*

ភោគំតុឡ្ឍំ ច យសវា *ភោគសម្បទាក្តី សេចក្តីចម្រើនក្តី មានយសក្តី*

សតវស្សា ច អាយុ ច *អាយុប្រមាណមួយរយឆ្នាំក្តី*

ជីវសិទ្ធិ ភវន្តុ តេ *សេចក្តីសម្រេចនៃកិរិយាចិញ្ចឹមជីវិតជាសុខក្តី (ទាំងអស់នេះ សូមឱ្យមានដល់អ្នក)។*

ភវតុ សព្វមង្គលំ[1] *មង្គលទាំងពួងចូរមាន (ដល់អ្នក)*

១-ចាកគម្ពីរសទ្ទនីតិ សុត្តមាលា សូត្រទី ៥០៨ ទំព័រ ៣៥៧។

រក្ខន្តុ សព្វទេវតា *សូមទេវតាទាំងអស់បីបាច់រក្សា (នូវអ្នក)*

សព្វពុទ្ធានុភាវេន *ដោយអានុភាពនៃព្រះពុទ្ធជាម្ចាស់រាល់ព្រះអង្គ*

សទា សោត្ថី ភវន្តុ តេ *សួស្តីទាំងឡាយចូរមានដល់អ្នក ឱ្យបានសព្វ កាល សព្វវេលា,*

ភវតុ សព្វមង្គលំ *មង្គលទាំងពួងចូរមាន (ដល់អ្នក)*

រក្ខន្តុ សព្វទេវតា *សូមទេវតាទាំងអស់បីបាច់រក្សា (នូវអ្នក)*

សព្វធម្មានុភាវេន *ដោយអានុភាពនៃព្រះធម៌ទាំងពួង*

សទា សោត្ថី ភវន្តុ តេ *សួស្តីទាំងឡាយ ចូរមាន(ដល់អ្នក) ឱ្យបានសព្វ កាល សព្វវេលា,*

ភវតុ សព្វមង្គលំ *មង្គលទាំងពួងចូរមាន (ដល់អ្នក)*

រក្ខន្តុ សព្វទេវតា *សូមទេវតាទាំងអស់បីបាច់រក្សា (នូវអ្នក)*

សព្វសង្ឃានុភាវេន *ដោយអានុភាពនៃព្រះសង្ឃទាំងពួង*

សទា សោត្ថី ភវន្តុ តេ *សួស្តីទាំងឡាយ ចូរមានដល់អ្នក ឱ្យបានសព្វ កាលសព្វវេលា ។*

សិទ្ធិយាចនគាថា

សិទ្ធមត្តុ សិទ្ធមត្តុ សិទ្ធមត្តុ ឥទំ ផលំ
ឯតស្មឹ រតនត្តយស្មឹ សម្បសាទនចេតសោ ។

សូមផលនៃចិត្ត ដែលជ្រះថ្លាក្នុងព្រះរតនត្រ័យនោះ ផលនេះ ចូរជាផល

សម្រេច ចូរជាផលសម្រេច ចូរជាផលសម្រេច។

តេអត្ថលទ្ធា

តេ អត្ថលទ្ធា សុខិតា ဝိရုဠှာ ពុទ្ធសាសនេ
អរោគា សុខិតា ហោថ សហ សព្ពេហិ ញាតិភិ ខ

អ្នកទាំងឡាយ (ទាំងបុរសទាំងស្ត្រី) នោះ ចូរបាននូវប្រយោជន៍ បាននូវសេចក្តីសុខ ចូរចម្រើនក្នុងព្រះពុទ្ធសាសនា ចូរកុំឱ្យមានរោគ ឱ្យបាននូវសេចក្តីសុខព្រមទាំងញាតិទាំងឡាយគ្រប់គ្នា។

អនុមោទនាភ្លុងការចារអត្ថបត្តលេ

(មានបុណ្យសព និងទក្ខិណានុប្បទានជាដើម)

****

តិរោកុឌ្ឌសូត្រ

(បិដកលេខ ៥២ ទំព័រ ១២ និងលេខ ៥៦ ទំព័រ ៤)

តិរោកុឌ្ឌេសុ តិដ្ឋន្តិ សន្ធិសិឃាដកេសុ ច
ទ្វារពាហាសុ តិដ្ឋន្តិ អាគន្ត្វាន សកំ ឃរំ

ពួកប្រេតទាំងឡាយមកហើយ កាន់ផ្ទះនៃញាតិ ដោយគិតថាជាផ្ទះរបស់ខ្លួន រមែងឈរនៅជិតខាងក្រៅជញ្ជាំងទាំងឡាយខ្លះ នាផ្លូវបែកជា ៤ និងផ្លូវបែកជា ៣ ទាំងឡាយខ្លះ ជិតទ្វារក្រុង និងទ្វារផ្ទះទាំងឡាយខ្លះៗ

បហុតេ អន្នបានម្ហិ ខជ្ជភោជេ ឧបដ្ឋិតេ *នាកាលបាយ និងទឹក និងបង្អែម និងចម្អាបដ៏ល្មមគ្រាន់ គឺពួកញាតិចូលទៅតាំងទុកហើយ*

ន តេសំ កោចិ សរតិ សត្តានំ កម្មបច្ចយា *ញាតិណាមួយ មិននឹកដល់ប្រេតទាំងឡាយនោះ ព្រោះកម្មរបស់សត្វទាំងឡាយជាបច្ច័យ*

ឯវំ ទទន្តិ ញាតីនំ យេ ហោន្តិ អនុកម្បកា
សុចឹ បណីតំ កាលេន កប្បិយំ បានភោជនំ

ញាតិទាំងឡាយឯណា តែងអនុគ្រោះ ញាតិទាំងឡាយនោះ រមែងឧទ្ទិសឱ្យនូវទឹក និងភោជនដ៏ម៉ត់ចត់ ដ៏ប្រសើរ ជារបស់គួរតាមកាលដល់ញាតិទាំងឡាយ ជាអ្នកលះលោកនេះទៅហើយនោះយ៉ាងនេះថា

ឥទំ ខោ ញាតីនំ ហោតុ សុខិតា ហោន្តុ ញាតយោ ទាននេះ ចូរមានដល់ញាតិទាំងឡាយ សូមញាតិទាំងឡាយ ចូរជាអ្នកដល់នូវសេចក្តីសុខ

តេ ច តត្ថ សមាគន្ត្វា ញាតិបេតា សមាគតា ក៏ប្រេតជាញាតិទាំងឡាយនោះ មកប្រជុំគ្នាហើយក្នុងស្ថានដែលឱ្យទាននោះ ជាអ្នកមកហើយដោយបំណងល្អ

បហូតេ អន្នបានម្ហិ សក្កច្ចំ អនុមោទរេ កាលបើថ្វាយបាយ និងទឹកដ៏ល្មមគ្រាន់ ក៏គប្បីអនុមោទនាដោយគោរពថា

ចិរំ ជីវន្តុ នោ ញាតី យេសំ ហេតុ លភាមសេ យើងទាំងឡាយ បានសម្បត្តិនេះ ព្រោះហេតុនៃញាតិទាំងឡាយឯណា សូមញាតិទាំងឡាយនោះរបស់យើងទាំងឡាយ ចូររស់នៅយឺនយូរ

អម្ហាកញ្ច កតា បូជា ក៏បូជា គឺញាតិទាំងឡាយធ្វើហើយដល់យើងទាំង-ឡាយ

ទាយកា ច អនិប្ផលា ឯទាយក គឺអ្នកឱ្យទានក៏មិនឥតផល

ន ហិ តត្ថ កសី អត្ថិ កសិកម្ម គឺការភ្ជួរស្រែចម្ការក៏មិនមានក្នុងភូមិនៃប្រេតនោះ

គោរក្ខេត្ថ ន វិជ្ជតិ គោរក្ខកម្ម គឺការរក្សាគោ ក៏មិនមានក្នុងភូមិនៃប្រេតនោះ

វណិជ្ជា តាទិសី នត្ថិ ពាណិជ្ជកម្ម គឺការជួញដែលជាហេតុបានសម្បត្តិ

ដូច្នោះក៏មិនមាន

ហិរញ្ញោន កយាកយំ *មិនមានការលក់ទិញផ្ទាស់ប្តូរដោយប្រាក់*

ឥតោ ទិន្នេន យាបេន្តិ បេតា កាលកតាតហិ *បុគ្គលទាំងឡាយ ធ្វើកាលកិរិយាទៅកើតជាប្រេត រមែងញុំាងអត្តភាពឱ្យប្រព្រឹត្តទៅក្នុងប្រេតវិស័យនោះ ដោយផលទានដែលញាតិឱ្យហើយអំពីលោកនេះ*

ខន្ធានេ ខន្ធកំ តុដ្ឋំ យថា ទិន្នំ បវត្តតិ
ឯវមេវ ឥតោ ទិន្នំ បេតានំ ខ្បកប្បតិ

ទឹកធ្លាក់ចុះក្នុងទីទួល រមែងហូរទៅកាន់ទីទំនាបដូចម្តេចមិញ ទានដែលបុគ្គលឱ្យហើយអំពីលោកនេះ រមែងសម្រេចផលដល់ប្រេតទាំងឡាយដូច្នោះដែរ

យថា វារិវហា បូរា បរិបូរេន្តិ សាគរំ
ឯវមេវ ឥតោ ទិន្នំ បេតានំ ខ្បកប្បតិ

ជ្រលងផ្លូវទឹកទាំងឡាយ មានទន្លេ និងស្ទឹងជាដើម រមែងញុំាងសាគរឱ្យពេញព្រៀបដូចម្តេចមិញ ទានដែលបុគ្គលឱ្យហើយអំពីលោកនេះ រមែងសម្រេចផលដល់ប្រេតទាំងឡាយដូច្នោះដែរ។

អទាសិ មេ អកាសិ មេ ញាតិមិត្តា សខា ច មេ
បេតានំ ទក្ខិណំ ទជ្ជា បុព្ពេ កតមនុស្សរំ

បុគ្គលកាលរឭកឃើញនូវឧបការគុណ ដែលលោកធ្វើទុកដល់ខ្លួនក្នុងកាលមុនថា អ្នកនេះបានឱ្យរបស់នេះដល់អញ អ្នកនេះបានធ្វើគុណនេះដល់អញ ជនទាំងឡាយនោះ ជាញាតិមិត្ត និងជាសម្ងាញ់របស់អញ ដូច្នេះហើយ គួរឱ្យទក្ខិណា

ទានដើម្បីប្រេតទាំងឡាយ

ន ហិ រុណ្ណំ វា សោកោ វា យាវញ្ញា បរិទេវនា *ការយំ ឬសោកសៅ ឬការខ្សឹកខ្សួលដទៃៗ មិនមានប្រយោជន៍ឡើយ*

ន តំ បេតានមត្ថាយ *ធ្វើដូច្នោះ រកបានជាប្រយោជន៍ដល់ប្រេតទាំងឡាយ គ្មាន*

ឯវំ តិដ្ឋន្តិ ញាតយោ *ញាតិទាំងឡាយ រមែងស្ថិតនៅឥតបានដឹង បានឮយ៉ាងនេះ*

អយញ្ច ខោ ទក្ខិណា ទិន្នា *បើទក្ខិណាទានដែលបុគ្គលបានឱ្យហើយនេះឯង*

សង្ឃម្ហិ សុបតិដ្ឋិតា *ជាទានតម្កល់នៅល្អហើយក្នុងសង្ឃ*

ទីឃរត្តំ ហិតាយស្ស ឋានសោ ឧបកប្បតិ *ទក្ខិណាទាននោះ ទើបចូលទៅសម្រេចតាមស្ថាន[1] ដើម្បីជាប្រយោជន៍ដល់ប្រេតនោះអស់កាលជាអង្វែង*

សោ ញាតិធម្មោ ច អយំ និទស្សិតោ *ក៏ញាតិធម៌នោះ គឺអ្នកបានសម្តែងជាបែបយ៉ាងហើយ*

បេតា នមូទា ច កតា ឧឡារា *ការបូជាដ៏ថ្លៃថ្លា ចំពោះដល់ប្រេតទាំង-ឡាយ គឺអ្នកបានធ្វើហើយ*

១-បទថា **ឋានសោ ឧបកប្បតិ** ដែលប្រែថា "ចូលទៅសម្រេចតាមស្ថាន" នេះ អដ្ឋកថាពន្យល់ទុកពីរន័យ គឺ ១) សម្រេចផលក្នុងខណៈនោះភ្លាមមិនយឺតយូរឡើយ, ២) សម្រេចតែក្នុងឋានៈដែលគួរ ដូចពុទ្ធដីកាថា "ម្នាលព្រាហ្មណ៍ ទាននោះរមែងសម្រេចផលដល់សត្វដែលរស់នៅក្នុងបេត្តិវិស័យណា បេត្តិវិស័យនោះឯង ជាឋានៈដូច្នេះ" ។

ពលញ្ញា ភិក្ខូ ឆមនុប្បត្តិន្នំ *កម្ចាំងកាយនៃភិក្ខុទាំងឡាយ ឈ្មោះថា គឺអ្នកបានបំពេញឱ្យហើយ*

តុម្ហេហិ បុញ្ញំ បសុតំ អនប្បកន្តិ *បុណ្យ គឺអ្នកសន្សំទុកហើយ មិនមែនតិចដូច្នេះ។*

ខេត្តូបមាបេតគាថា

(ព្រះអរហន្តដូចស្រែ ទាយកដូចកសិករ ទេយ្យធម៌ដូចពូជ)

ខេត្តូបមា អរហន្តោ ទាយកា កស្សកូបមា
ពីជូបមំ ទេយ្យធម្មំ ឯត្តោ និព្វត្តតេ ផលំ ។
ឯតំ ពីជំ កសិ ខេត្តំ បេតានំ ទាយកស្ស ច
តំ បេតា បរិភុញ្ជន្តិ ទាតា បុញ្ញេន វឌ្ឍតិ ។
ឥធេវ កុសលំ កត្វា បេតា ច បដិបូជិយ
សគ្គញ្ហា កមតិ ឋានំ កម្មំ កត្វាន តទ្ទកំ ។

ពួកព្រះអរហន្តដូចស្រែ ពួកទាយកដូចអ្នកភ្ជួររាស់ ទេយ្យធម៌ដូចពូជ ផលតែងកើតមកអំពីព្រះអរហន្ត និងទាយក និងទេយ្យធម៌នុ៎ះ។ ឯពូជ និងការភ្ជួររាស់ និងស្រែនុ៎ះ តែងមានដល់ប្រេតទាំងឡាយផង ដល់ទាយកផង ប្រេតទាំងឡាយតែងបរិភោគនូវផលនៃទាននោះ ទាយកអ្នកឱ្យទានតែងចម្រើនដោយបុណ្យ។ បុគ្គលធ្វើកុសលហើយក្នុងអត្តភាពនេះឯង គួរតែបូជាចំពោះប្រេតទាំងឡាយ ព្រោះថាបុគ្គលធ្វើកុសលកម្មដ៏ចម្រើន រមែងទៅកាន់ឋានសួគ៌។

(បិដកលេខ ៥៦ ទំព័រ ១)

បុព្វបេតពលិទានានុមោទនាគាថា

យំ កិញ្ចារម្មណំ កត្វា ទជ្ជា ទានំ អមច្ឆរី
បុព្វេ បេតេទ អារព្ភ អថ វា ទត្តុទេវតា

កុលបុត្រធ្វើនូវហេតុឯណានីមួយឱ្យជាអារម្មណ៍ គឺប្រារព្ធនូវមាតា និងបិតាទាំងឡាយ ដែលរំលាយខន្ធទៅកាន់បរលោកហើយក្នុងកាលមុនបង្អស់រួចហើយ ក្នុងកាលមុនបង្អស់រួចហើយ (គប្បីប្រារព្ធ) នូវទេវតាទាំងឡាយដែលអាស្រ័យនៅក្នុងទីទាំងឡាយ មានទីផ្ទះជាដើមហើយ ត្រូវកុំកំណាញ់ ត្រូវឱ្យនូវទាន។

ចត្តារោ ទ មហារាជេ លោកបាលេ យសស្សិនោ
កុវេរំ ធតរដ្ឋញ្ច វិរូបក្ខំ វិរូឡ្ហកំ

(គប្បីប្រារព្ធ) នូវទេវតាជាលោកបាលទាំងឡាយ ដែលជាស្តេចធំ ៤ គឺព្រះបាទកុវេរៈ ១ ព្រះបាទធតរដ្ឋៈ ១ ព្រះបាទវិរូបក្ខៈ ១ ព្រះបាទវិរូឡ្ហកៈ ១ ដែលជាស្តេចនៃទេវតាមានយសបរិវារ

តេ ចេទ បូជិតា ហោន្តិ ទាយកា ច អនិប្ផលា *ស្តេចទេវតាទាំងឡាយនោះ បើគេបានបូជាហើយ (ដោយឧទ្ទិសផលបុណ្យជូនទៅ) អ្នកដែលឧទ្ទិសផលបុណ្យជូនទៅនោះមិនមែនជាឥតផលទេ គឺបានផលានិសង្សជាប្រាកដ*

ន ហិ រុណ្ណំ វា សោកោ វា យាទញ្ញា បរិទេវនា *ការយំ ឬសោកសៅ ឬការខ្សឹកខ្សួលដទៃៗ មិនមានប្រយោជន៍ឡើយ[1]*

១-សេចក្តីប្រែតាំងពីនេះទៅ យើងយកតាមតិរោកុឌ្ឌសូត្រ ដើម្បីងាយស្រួលដល់អ្នកសិក្សា។

ឆតំ បេតានមត្ថាយ *ធ្វើដូច្នោះរកបានជាប្រយោជន៍ដល់ប្រេតទាំងឡាយគ្មាន*

ឯវំ តិដ្ឋន្តិ ញាតយោ *ញាតិទាំងឡាយ រមែងស្ថិតនៅឥតបានដឹង បានឮយ៉ាងនេះ*

អយញ្ច ខោ ទក្ខិណា ទិន្នា *បើទក្ខិណាទាន ដែលបុគ្គលបានឱ្យហើយនេះឯង*

សង្ឃម្ហិ សុបតិដ្ឋិតា *ជាទានតម្កល់នៅល្អហើយក្នុងសង្ឃ*

ទីឃរត្តំ ហិតាយស្ស ឋានសោ ឧបកប្បតិ *ទក្ខិណាទាននោះ ទើបចូលទៅសម្រេចផលដោយឋាប់រួសរាន់ ដើម្បីជាប្រយោជន៍ដល់ប្រេតនោះអស់កាលជាអង្វែង ។*

(បិដកលេខ ៥៦ ទំព័រ ៣)

ជីវកគ្គាឧមោទនាគាថា

(បិដកលេខ ៥២ ទំព័រ ៧0)

បណ្ឌុបលាសោវ ទានិសិ *ខ្លួនអ្នកក្នុងកាលឥឡូវនេះ ជាបុគ្គលប្រៀបដូចស្លឹកឈើទុំមានពណ៌លឿង,*

យមបុរិសាបិ ច តេ ឧបដ្ឋិតា *បុរស(ជាបម្រើ) នៃយមរាជ គឺមរណៈសោតក៏ប្រាកដដល់អ្នកហើយ,*

ខ្វយេ្យាគមុខេ ច តិដ្ឋសិ *អ្នកជាបុគ្គលស្ថិតនៅក្នុងប្រធាននៃសេចក្តីសាប-*
សូន្យ,

ឃាថេយ្យំបិ ច តេ ន វិជ្ជតិ *ស្បៀង គឺកុសលរបស់អ្នកសោតក៏គ្មាន,*

សោ ករោហិ ទីបមត្តនោ *ចូរធ្វើនូវទីពឹងនៃខ្លួនចុះ,*

ខិប្បំ វាយម បណ្ឌិតោ ភវ *ចូរអ្នកតាំងព្យាយាមរួតរះ ចូរជាអ្នកឈ្លាស*
(កុំជាមនុស្សល្ងង់ខ្លៅឡើយ)

និទ្ធន្តមលោ អនង្គណោ ទិព្ពំ អរិយភូមិមេហិសិ *អ្នក (កាលធ្វើយ៉ាងនេះ)*
នឹងជាបុគ្គលមានមន្ទិល (មានរាគៈជាដើម) ខ្ចាត់ចេញ មិនមានគ្រឿងពួនគឺកិលេស
ហើយនឹងដល់នូវអរិយភូមិដ៏ជាទិព្វ ។

ខ្វបនេយ្យសុត្តំ

(បិដកលេខ ២៩ ទំព័រ ៤)

ទេវតាពោលគាថានេះក្នុងសម្ផាក់ព្រះមានព្រះភាគថា:

ខ្វបនីយតិ ជីវិតមប្បមាយុំ
ជរូបនីតស្ស ន សន្តិ តាណា
ឯតំ ភយំ មរណេ បេក្ខមានោ
បុញ្ញានិ កយិរាថ សុខាវហានិ ។

ជីវិត គឺអាយុ (របស់សត្វទាំងឡាយ) តិចតួចពេកណាស់ ដ្បិតជរាតែងនាំ
ចូលទៅរក (សេចក្តីស្លាប់) កាលបើសត្វ ដែលត្រូវជរានាំចូលទៅជិត (សេចក្តីស្លាប់)

ហើយ នឹងរកអ្វីជ្រកកោនពុំបានឡើយ កាលបើបុគ្គលបានសម្លឹងឃើញភ័យនុ៎ះ ក្នុងសេចក្តីស្លាប់ហើយ គួរតែធ្វើបុណ្យទាំងឡាយដែលជាគុណជាតិនាំសុខមកឱ្យ។

ព្រះមានព្រះភាគទ្រង់ត្រាស់ថា:

ឯបនីយតិ ជីវិតមប្បមាយុំ
ជរូបនីតស្សុន សន្តិ តាណា
ឯតំ ភយំ មរណេ បេក្ខមានោ
លោកាមិសំ បជហេ សន្តិបេក្ខោ ។

ជីវិត គឺអាយុរបស់ (សត្វទាំងឡាយ) តិចតួចពេកណាស់ ដ្បិតជរាតែងនាំចូលទៅរក(សេចក្តីស្លាប់) កាលបើសត្វដែលត្រូវជរានាំចូលទៅជិត (សេចក្តីស្លាប់)ហើយ នឹងរកអ្វីជ្រកកោនពុំបានឡើយ កាលបើបុគ្គលបានសំឡឹងឃើញភ័យនុ៎ះក្នុងសេចក្តីស្លាប់ហើយ ជាអ្នកប្រាថ្នាសេចក្តីសូប ត្រូវលះបង់អាមិស:ក្នុងលោកចេញ។

អច្ចេន្តិសូត្រ

(បិដកលេខ ២៥ ទំព័រ ៥)

ទេវតាពោលគាថានេះក្នុងសម្នាក់ព្រះមានព្រះភាគថា:

អច្ចេន្តិ កាលា តរយន្តិ រត្តិយោ
វយោគុណា អនុបុព្ពំ ជហន្តិ
ឯតំ ភយំ មរណេ បេក្ខមានោ
បុញ្ញានិ កយិរាថ សុខាវហានិ ។

កាលទាំងឡាយតែងកន្លងផុតទៅ រាត្រីទាំងឡាយតែងឆ្លងហួសទៅ ជំនាន់

នៃវ័យទាំងឡាយតែងលះបង់នូវលំដាប់ កាលបើបុគ្គលបានសំឡឹងឃើញភ័យនុ៎ះ ក្នុងសេចក្តីស្ងាប់ហើយ គួរតែធ្វើបុណ្យទាំងឡាយដែលជាគុណជាតនាំសុខមកឱ្យ។

ព្រះមានព្រះភាគទ្រង់ត្រាស់ថា:

អច្ចេន្តិ កាលា តរយន្តិ រត្តិយោ
វយោគុណា អនុបុព្ពំ ជហន្តិ
ឯតំ ភយំ មរណេ បេក្ខមានោ
លោកាមិសំ បជហេ សន្តិបេក្ខោ ៧

កាលទាំងឡាយតែងកន្លងផុតទៅ រាត្រីទាំងឡាយតែងឆ្លងហួសទៅ ជំនាន់នៃវ័យទាំងឡាយតែងលះបង់នូវលំដាប់ កាលបើបុគ្គលបានសម្លឹងឃើញភ័យនុ៎ះ ក្នុងសេចក្តីស្ងាប់ហើយ ជាអ្នកប្រាថ្នាសេចក្តីស្ងប់ ត្រូវលះបង់អាមិស:ក្នុងលោកចេញ។

អាទិត្តសុត្តគាថា

(បិដកលេខ ២៥ ទំព័រ ៧៨)

ទេវតាពោលនូវគាថានេះក្នុងសម្នាក់ព្រះមានព្រះភាគថា:

អាទិត្តស្មឹ អគារស្មឹ យំ នីហរតិ ភាជនំ
តំ តស្ស ហោតិ អត្ថាយ នោ ច យំ តត្ថ ឌយ្ហតិ ៧

បុគ្គលជញ្ជូននូវភាជន៍ណាអំពីផ្ទះដែលភ្លើងកំពុងឆេះ ពុំនោះសោត ភ្លើងមិនទាន់ឆេះនូវវត្ថុណាក្នុងផ្ទះនោះ ភាជន៍ និងវត្ថុនោះជាប្រយោជន៍នៃបុគ្គលនោះឯង។

ឯវមាទិត្តកោ លោកោ ជរាយ មរណេន ច
ទិន្នំ ហោតិ សុនិព្ពុតំ ។

សត្វលោកដែលជរា និងមរណៈឆេះយ៉ាងនេះ ត្រូវតែនាំទ្រព្យចេញដោយទានកុំខាន ទានដែលបុគ្គលឱ្យហើយ ឈ្មោះថានាំចេញដោយល្អ។

ទិន្នំ សុខផលំ ហោតិ នាទិន្នំ ហោតិ តំ តថា
ចោរា ហរន្តិ រាជានោ អគ្គិ ឌយ្ហតិ នស្សតិ ។

វត្ថុដែលបុគ្គលឱ្យហើយ ជាវត្ថុមានសុខជាផល វត្ថុដែលបុគ្គលមិនឱ្យហើយ ជាវត្ថុមិនមានសុខជាផលទេ ពួកចោរតែងនាំទៅ ពួករាជការតែងរឹបយក ភ្លើងតែងឆេះវិនាសទៅ។

អថ អន្តេន ជហតិ សរីរំ សបរិគ្គហំ
ឯតទញ្ញាយ មេធាវី ភុញ្ជេថ ច ទទេថ ច
ទត្វា ច ភុត្វា ច យថានុភាវំ
អនិន្ទិតោ សគ្គមុបេតិ ឋានំ ។

ពុំនោះសោត វេលាស្លាប់ទៅក៏រមែងលះបង់នូវសរីរៈ និងរបស់ដែលបុគ្គលផ្ចាប់ហួងហែង អ្នកប្រាជ្ញដឹងនូវសេចក្តីនេះហើយ គប្បីបរិភោគផងឱ្យទានផង បុគ្គលឱ្យទាន ទាំងបរិភោគឱ្យសមគួរតាមសភាពហើយ គេមិនដែលនិន្ទាទេ តែងបានទៅកើតក្នុងឋានសួគ៌។

បព្វតោបមសុត្តគាថា

(គាថាប្រៀបជរា និងមរណៈទៅនឹងភ្នំថ្មតាន់)

យថាបិ សេលា ឥរិបុលា ឆតំ អាហច្ច បព្វតា
សមន្តា អនុបរិយេយ្យុំ និប្បោថេន្តោ ចតុទ្ទិសា

ប្រសិនណាបើភ្នំទាំងឡាយ សុទ្ធសឹងតែថ្មដ៏ខ្ពស់ពេញអាកាស រមៀលកិន នូវសត្វទាំងឡាយ ដែលមកដោយជុំវិញទាំង ៤ ទិសយ៉ាងណាមិញ,

ឯវំ ជរា ច មច្ចុ ច អធិវត្តន្តិបាណិនោ
ខត្តិយេ ព្រាហ្មណេ វេស្សេ សុទ្ធេ ចណ្ឌាលបុក្កុសេ

សេចក្តីចាស់ សេចក្តីស្លាប់ តែងគ្របសង្កត់នូវសត្វទាំងឡាយ (មិនរើសមុខ) ទោះជាក្សត្រក៏ដោយ ជាព្រាហ្មណ៍ក៏ដោយ ជាអ្នកជំនួញក៏ដោយ ជាពួកគូលីក៏ដោយ ជាពួកចណ្ឌាលក៏ដោយ ជាអ្នកចាក់សម្រាមចោលក៏ដោយ យ៉ាងនោះឯង។

ន កញ្ចិ បរិវជ្ជេតិ សព្វមេវាភិមទ្ទតិ *តតមានវៀរលែងនូវបុគ្គលណាមួយឡើយ តែងគ្របសង្កត់ញាំញីនូវសត្វទាំងអស់មិនឱ្យសល់មួយ,*

ន តត្ថ ហត្ថីនំ ភូមិភូមិ *នៃដំរីទាំងឡាយ មិនមានក្នុងជរា និងមរណៈនោះទេ,*

ន រថានំ ន បត្តិយា *(ភូមិ) នៃរថទាំងឡាយក៏មិនមាន ទាំង (ភូមិ) នៃពលថ្មើរជើងទាំងឡាយក៏មិនមាន(ក្នុងជរានិងមរណៈនោះឡើយ),*

ន ចាបិ មន្តយុទ្ធេន សក្កា ជេតុំ ធនេន វា *ម្យ៉ាងទៀត តតមានអ្នកណាមួយនឹងឈ្នះ (នូវជរា និងមរណានោះ) ដោយការតតាំងច្បាំងដោយវេទមន្ត ឬ*

ដោយទ្រព្យសម្បត្តិបានឡើយ,

តស្មា ហិ បណ្ឌិតោ ឧបាសោ សម្បស្សំ អត្តមត្តនោ
ពុទ្ធេ ធម្មេ ច សង្ឃេ ច ធីរោ សទ្ធំ និវេសយេ

ព្រោះហេតុនោះ បុរសជាបណ្ឌិតអ្នកមានប្រាជ្ញា កាលឃើញនូវប្រយោជន៍របស់ខ្លួន ក៏គួរនឹងបណ្តុះនូវសទ្ធាចំពោះព្រះពុទ្ធ និងព្រះធម៌ និងព្រះសង្ឃ,

យោ ធម្មចារឺ កាយេន វាចាយ ឧទ ចេតសា *បុគ្គលណាមួយ ជាអ្នកប្រព្រឹត្តនូវធម៌ដោយកាយ ដោយវាចា ឬដោយចិត្ត,*

ឥធេវ នំ បសំសន្តិ *បណ្ឌិតទាំងឡាយ តែងសរសើរនូវបុគ្គលនោះក្នុងលោកនេះឯង,*

បេច្ច សគ្គេ បមោទតិ *បុគ្គលនោះ លុះទៅកាន់បរលោកនាយហើយ តែងត្រេកអរក្នុងស្ថានសួគ៌ទៀតៗ*

(បិដកលេខ ២៩ ទំព័រ ២៧៧)

ដកពីស្បៀវភៅអនុមោទាវិធី បិដក និងអដ្ឋកថា

ចប់អនុមោទនាវិធីតែប៉ុណ្ណោះ

សំវេជនីយគាថា

(គាថានាំឱ្យកើតសេចក្តីសង្វេគ)

****

សេចក្តីពន្យល់

ព្រះគាថាទាំងនេះ គឺសុទ្ធតែជាព្រះធម៌ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់នៃយើងព្រះអង្គទ្រង់សម្តែងឡើង ដោយប្រារព្ធរឿងរ៉ាវដែលបានកើតឡើងហើយ ឯបុគ្គលដែលបានស្តាប់ហើយ ក៏បានសម្រេចនូវប្រយោជន៍ដ៏ធំ មានសម្រេចមគ្គផលជាដើម ។

*នៅក្នុងស្រុកខ្មែរ ចាស់ទុំយើងនិយមហៅធម៌នេះថា "**ធម៌បង្សុកូល**" សម្រាប់សូធ្យក្នុងពេលបុណ្យសព ឬក្នុងពេលបូជាសព ។ សេចក្តីនេះឃើញថា សមហេតុផលណាស់ តែកុំគប្បីយល់ថាការសូធ្យធម៌នេះ គឺសូធ្យដើម្បីឱ្យអ្នកស្លាប់ស្តាប់ ឬជូនដំណើរអ្នកស្លាប់ឱ្យបានទៅកើតក្នុងឋានសួគ៌នោះឡើយ ។ សេចក្តីពិតនោះ គឺសូធ្យដើម្បីឱ្យអ្នកដែលកំពុងតែរស់នៅនេះឯងស្តាប់ ដើម្បីឱ្យបានយល់ថា សេចក្តីស្លាប់ក្តី ការព្រាត់ប្រាស់ចាកពួកជនជាទីស្រឡាញ់ពេញចិត្តជាដើមក្តី គឺមានសម្រាប់សព្វសត្វគ្រប់រូប ឥតមានសត្វណាមួយអាចគេចផុតបានឡើយ ព្រោះវាជាច្បាប់ធម្មជាតិ ។ កាលបានយល់ហើយក៏កើតបញ្ញា មានសេចក្តីតក់ស្លុតក្នុងសង្ខារនេះ ហើយក៏ខិតខំខ្ជល់ខ្ជាយបំពេញបុណ្យកុសល សម្រាប់ជាស្ពាន ជាថ្នល់ដើរឆ្ពោះទៅកាន់ទីមិនចាស់ មិនឈឺ មិនស្លាប់ គឺព្រះនិព្វាន។*

មួយទៀត សូមបញ្ជាក់ផងដែរ ត្រង់ដែលយើងនិយមហៅនូវធម៌នេះថា ជា **ធម៌បង្សុកូល** និងទម្លាប់និយាយថា **និមន្តលោកបង្សុកូល**។ សេចក្តីនេះមិនត្រូវទាល់តែសោះ ព្រោះពាក្យថា "**បង្សុកូល**" ប្រែថា **គំនរអាចម៌ដី, គំនរធូលីឬអ្វីៗដែលប្រឡាក់, ដែលសៅហ្មងដោយអាចម៌ដី ដោយធូលី**។ មកពី **បង្សុ** ប្រែថា **អាចម៌ដី** ឬធូលី, **កូល** ប្រែថា **ប្រឡាក់, គួរខ្ពើម**។ គឺសំដៅយកសំពត់ប្រឡាក់ប្រឡូសដោយធូលី ដែលគេចោលលើគំនរសំរាម ពនផ្សារ ឬព្រៃខ្មោចជាដើម។ ហើយនៅក្នុងគម្ពីរវិសុទ្ធិមគ្គ ត្រង់ធុតង្គនិទ្ទេស ដែលនិយាយពីបង្សុកូលធុតង្គនោះ ក៏មិនមានប្រាប់ឱ្យភិក្ខុអ្នកកាន់ធុតង្គត្រូវសូត្រធម៌ទាំងនេះ ឬក៏ធម៌ដទៃណាដែរ។

ឯពាក្យដែលត្រឹមត្រូវនោះ យើងគួរប្រើពាក្យថា "**និមន្តលោកសូត្រសំវេជនីយគាថា**" គឺគាថា ឬធម៌ដែលនាំឱ្យកើតសេចក្តីសង្វេគ នោះទើបសមជាងហើយ មិនខុសទៀងផង។



កិសាគោតមីថេរីគាថា

(ត្រៃលក្ខណ៍ប្រចាំត្រៃលោក)

ន គាមធម្មោ និគមស្ស ធម្មោ
ន ចាបិ យំ ឯកកុលស្ស ធម្មោ
សព្ពស្ស លោកស្ស សទេវកស្ស
ឯសេវ ធម្មោ យទនិច្ចតា[1]**។**

ធម៌ណា ដែលមានឈ្មោះថា អនិច្ចតាធម៌ គឺសភាពប្រែប្រួលមិនទៀងទាត់ អនិច្ចតាធម៌នេះ មិនមែនជាធម៌សម្រាប់អ្នកស្រុក (តែមួយៗ) ទេ មិនមែនជាធម៌សម្រាប់អ្នកនិគម (តែមួយៗ) ទេ ឬនឹងថាជាធម៌សម្រាប់ត្រកូលតែមួយៗ ក៏មិនមែនទេ អនិច្ចតាធម៌នុ៎ះ ជាធម៌សម្រាប់មនុស្សសត្វ ព្រមទាំងទេវតា មារព្រហ្មទាំងអស់គ្រប់រូប ។ (បិដកលេខ ៧៦ ទំព័រ ១៣២)

ន គាមធម្មោ និគមស្សធម្មោ
ន ចាបិ យំ ឯកកុលស្ស ធម្មោ
សព្ពស្សលោកស្ស សទេវកស្ស
ឯសេវ ធម្មោ យទិទញ្ហ ទុក្ខតា

ធម៌ណា ដែលមានឈ្មោះថា ទុក្ខតាធម៌ គឺសភាពជាទុក្ខ ទុក្ខតាធម៌នេះ មិនមែនជាធម៌សម្រាប់អ្នកស្រុក (តែមួយៗ) ទេ មិនមែនជាធម៌សម្រាប់អ្នកនិគម (តែមួយៗ)ទេ ឬនឹងថាជាធម៌សម្រាប់ត្រកូលតែមួយ ៗ ក៏មិនមែនទេ ទុក្ខតាធម៌នុ៎ះ

១-ក្នុងបិដក និងអដ្ឋកថា ឃើញមានត្រឹមតែ ១ គាថានេះប៉ុណ្ណោះ។

ជាធម៌សម្រាប់មនុស្សសត្វព្រមទាំងទេវតា មារ ព្រហ្ម ទាំងអស់ គ្រប់រូប។

ន គាមធម្មោ និគមស្ស ធម្មោ
ន ចាបិយំឯកកុលស្ស ធម្មោ
សព្វស្ស លោកស្ស សទេវកស្ស
ឯសេវ ធម្មោ យទិទំ អនត្តតា ៗ

ធម៌ណា ដែលមានឈ្មោះថា អនត្តាធម៌ គឺសភាពមិនមែនជារបស់ខ្លួន អនត្តាធម៌នេះ មិនមែនជាធម៌សម្រាប់អ្នកស្រុក (តែមួយ ៗ) ទេ មិនមែនជាធម៌សម្រាប់អ្នកនិគម (តែមួយ ៗ) ទេ ឬនឹងថាជាធម៌សម្រាប់ត្រកូលតែមួយ ៗ ក៏មិន-មែនទេ អនត្តាធម៌នុ៎ះ ជាធម៌សម្រាប់មនុស្សសត្វ ព្រមទាំងទេវតា មារ ព្រហ្មទាំងអស់គ្រប់រូប។

មហាសុទស្សនសុត្តគាថា

(បិដកលេខ ១៧ ទំព័រ ៥៩)

អនិច្ចា វត សង្ខារា ឧប្បាទវយធម្មិនោ
ឧប្បជ្ជិត្វា និរុជ្ឈន្តិ តេសំ វូបសមោ សុខោ

សង្ខារធម៌ទាំងឡាយ មិនទៀងមែនពិត មានកិរិយាកើតឡើង នឹងវិនាសទៅវិញជាធម្មតា រមែងតែកើតឡើងហើយ រលត់ទៅវិញ លុះតែរលត់នូវសង្ខារទាំងឡាយនោះហើយ ទើបបាននូវសេចក្តីសុខគ្រប់យ៉ាង[1]។

១-មានក្នុងបិដកលេខ ១៦ ទំព័រ ៣២៧, លេខ ៣២ ទំព័រ ១០៩ និងលេខ ៥៨ ទំព័រ ៤២ ដែរ។

អរិយវិកាសុត្តគាថា

(បុណ្យជាទីពឹងរបស់សត្វលោក)

សព្ពេ សត្តា មរិស្សន្តិ មរណន្តំ ហិ ជីវិតំ
យថា កម្មំ គមិស្សន្តិ បុញ្ញាបាបផលូបគា
និរយំ បាបកម្មន្តា បុញ្ញកម្មា ច សុគ្គតឹ

សត្វទាំងឡាយ ទៀងតែនឹងស្លាប់គ្រប់ៗ គ្នា ព្រោះថាជីវិត (របស់សត្វទាំង-ទាំងឡាយ) សុទ្ធតែមានសេចក្តីស្លាប់នៅខាងចុងបំផុតគ្រប់ៗ ប្រាណ (ម្យ៉ាងទៀត) សត្វទាំងឡាយរមែងកាន់យកនូវផលបុណ្យផលបាប ហើយនឹងទៅតាមយថាកម្ម គឺទៅតាមគួរដល់អំពើល្អ និងអាក្រក់ដែលខ្លួនបានធ្វើ អ្នកដែលធ្វើបាប តែងធ្លាក់ទៅសោយទុក្ខក្នុងនរក ចំណែកខាងអ្នកធ្វើបុណ្យ តែងឡើងទៅកាន់សុគតិភព។

តស្មា ករេយ្យ កល្យាណំ និចយំ សម្បរាយិកំ
បុញ្ញានិ បរលោកស្មឹ បតិដ្ឋា ហោន្តិ បាណិនំ

ព្រោះហេតុដូច្នោះហើយ សាធុជន អ្នកមានចំណង់ចង់បានសេចក្តីសុខ (ដល់ខ្លួន) គួរតែប្រញាប់ប្រញាល់ធ្វើអំពើបុណ្យ ដែលជាគុណ គឺអ្នកប្រាជ្ញតែងរាប់អានឱ្យបានជាកិច្ច គឺខ្លួនត្រូវកសាងសន្សំ (គ្រាន់នឹងបានជាទីពឹង) ទៅក្នុងភពខាងនាយ (ព្រោះថា) បុណ្យទាំងឡាយ តែងជាទីពឹងពំនាក់របស់សត្វទាំងឡាយក្នុងបរលោក ។

(បិដកលេខ ២៩ ទំព័រ ២៦៥)

ផេណបិណ្ឌបមសុត្តគាថា

(ខន្ធ ៥ ឥតខ្លឹមសារ)

ផេណ[1]បិណ្ឌបមំ រូបំ វេទនា បុព្ពុឡូបមា
មរីចិកូបមា សញ្ញា សង្ខារ កទលូបមា
មាយូបមញ្ច វិញ្ញាណំ ទេសិតាទិច្ចពន្ធុនា ៚

រូបមានសេចក្តីប្រៀបធៀបនឹងដុំនៃពពុះទឹក វេទនាមានសេចក្តីប្រៀបធៀបនឹងក្រពេញទឹក ដែលប៉ោងឡើងព្រួច ។ សញ្ញាមានសេចក្តីប្រៀបធៀបនឹងថ្ងៃបណ្តើរកូន សង្ខារទាំងឡាយ មានសេចក្តីប្រៀបធៀបនឹងដើមចេក វិញ្ញាណមានសេចក្តីប្រៀបធៀបនឹងកលមាយា (សេចក្តីប្រៀបធៀបនៃខន្ធទាំង ៥ នេះ) គឺព្រះសម្ពុទ្ធមានផៅពង្សដ៏ខ្ពង់ខ្ពស់ ដូចជាព្រះអាទិត្យ ព្រះអង្គទ្រង់សម្តែងហើយ។

អាយុ ឧស្មា ច វិញ្ញាណំ យទា កាយំ ជហន្តិមំ
អបវិជ្ឈោ តទា សេតិ បរភត្តំ អចេតនំ[2] ៚

អាយុក្តី ភ្លើងជាតុក្តី វិញ្ញាណក្តី តែលះបង់នូវកាយនេះ ដែលជាចំណីនៃសត្វដទៃ មិនមានចេតនា ទៅក្នុងកាលណាហើយ (កាយនេះក៏ដល់នូវសេចក្តីមិនមិនគួរនឹងទុកដាក់ឱ្យលើផ្ទះសម្បែងបានឡើយ) គេតែងនាំយកទៅចោលឱ្យដេកនៅ (លើផែនដី) ក្នុងកាលណោះឯង។

(បិដកលេខ ៣៣ ទំព័រ ៣២៥)

១-ធ្លាប់សូធ្យមកថា **ផេណបិណ្ឌ** ... តែបានពិនិត្យក្នុងបិដក អដ្ឋកថា និងបទានុក្រមបាលី ឃើញថា **ផេណបិណ្ឌ** ដូច្នេះវិញ ទើបសម្រេចយកតាមបិដកវិញ។ ២-ត្រង់បាទថី ៤ នៃគាថានេះ ធ្លាប់សូធ្យកន្លងមកថា **និរត្តំវ កឋិន្នរំ** តែសព្ទទាំងនេះមិនប្រាកដទីមកទេ ព្រោះហេតុនោះ ទើបយើងសម្រេចយកតាមបិដកវិញ។

ព្រះធម្មបទគាថា

អចិរំ វតយំ កាយោ បថវីអធិសេស្សតិ
ឆុទ្ធោ អបេតវិញ្ញាណោ និរត្ថំវ កលិង្គរំ ។

កាយនេះមិននៅយូរប៉ុន្មានទេ្បីយ តែមានវិញ្ញាណទៅច្រាសហើយ ជាកាយ គឺគេបោះបង់ចោល ក៏នឹងដេកសង្កត់នៅលើផែនដី ដូចជាអង្កត់ឧស រកប្រយោជន៍គ្មាន។

យថា ឧណ្ហេន គោចរោ គាវោចារេតិ គោចរំ
ឯវំ ជរា ច មច្ចុ ច អាយុំ ចារេន្តិ ចាណិនំ ។

គង្វាលគោ កៀងគោទាំងឡាយ ទៅកាន់ទីគោចរដោយអាជ្ញា គឺដំបង ឬរំពាត់យ៉ាងណាមិញ ជរា គឺសេចក្តីទ្រុឌទ្រោមគ្រាំគ្រា និងមច្ចុរាជ គឺសេចក្តីស្លាប់ក៏កៀងទៅនូវអាយុរបស់សត្វទាំងឡាយយ៉ាងនោះឯង។

បុច្ឆានិ ហេវ បចិនន្តិ ព្យាសត្តមនសំ នរំ
សុត្តំ គាមំ មហោឃោវ មច្ចុ អាទាយ គច្ឆតិ ។

មច្ចុ គឺសេចក្តីស្លាប់ តែងកៀរយកនូវនរជន អ្នកមានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេង ។ កំពុងជ្រើសរើសនូវផ្កា គឺកាមគុណ ៥ នុ៎ះឯង ដូចទឹកជំនន់ធំដែលនាំយកអ្នកស្រុកកំពុងដេកលក់ដូច្នោះឯង។

បុត្តា មត្ថិ ធនមត្ថិ ឥតិ ពាលោ វិហញ្ញតិ
អត្តា ហិ អត្តនោ នត្ថិ កុតោ បុត្តា កុតោ ធនំ ។

ជនពាលតែងព្រួយលំបាក ដោយសេចក្តីសម្គាល់ថា កូនទាំងឡាយរបស់

អញមាន ទ្រព្យរបស់អញមាន តាមដែលពិត សូម្បីខ្លួនរបស់ខ្លួនក៏មិនមានផង ចំណង់បើកូនទាំងឡាយ នឹងរាប់ថាមានអំពីណាបាន ទ្រព្យនឹងរាប់ថា មានអំពីណាបាន។

ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ ន បព្វតានំ វិវរំ បវិស្ស
ន វិជ្ជតី សោ ជគតិប្បទេសោ យត្រដ្ឋិតំ នប្បសហេយ្យមច្ចុ ។

បុគ្គលទៅឰដ៏អាកាស ក្នុងកណ្តាលសមុទ្រ កាន់ចន្លោះនៃភ្នំទាំងឡាយ ក៏មិនរួចចាកសេចក្តីស្លាប់បាន ព្រោះប្រទេសលើផែនដីដែលបុគ្គលឋិតនៅហើយ សេចក្តីស្លាប់គ្របសង្កត់មិនបាននោះ មិនដែលមានឡើយ។

បស្ស ចិត្តកតំ ពិម្ពំ អរុកាយំ សមុស្សិតំ
អាតុរំ ពហុសង្កប្បំ យស្ស នត្ថិ ធុវំ ឋិតិ ។

អត្តភាពណា មិនទៀងទាត់ឋិតថេរ អ្នកចូរមើលអត្តភាព (នោះ) ដែលកុសលាកុសលកម្មធ្វើឱ្យវិចិត្រហើយ ជាកាយពាសពេញដោយដំបៅ ដែលធ្លឹង ៣០០ កំណាត់ផ្គុំគ្នាហើយ ជាអត្តភាពក្តៅក្រហាយជានិច្ច ជាទីរំពឹងត្រិះរិះរបស់ជនច្រើនគ្នា។

បរិជិណ្ណមិទំ រូបំ រោគនិទ្ធំ បភង្គុណំ
និជ្ជតិ បូតិ សន្ទេហោ មរណន្តំ ហិ ជីវិតំ ។

រូបនេះគ្រាំគ្រាអស់ហើយ ជាទីសម្ងាក់នៃរោគ ជារបស់ពុកផុយ រាងកាយជារបស់ស្អុយ (នេះ) តែងបែកធ្លាយទៅវិញ ព្រោះថា ជីវិតមានសេចក្តីស្លាប់ជាទីបំផុត។

ជីរន្តិ វេ រាជរថា សុចិត្តា អថោ សរីរម្បិ ជរំ ឧបេតិ

សតញ្ច ធម្មោ ន ជរំ ឧបេតិ សន្តោ ហវេ សព្ភិ បវេទយន្តិ ។

រាជរថទាំងឡាយ ដ៏វិចិត្រល្អ រមែងគ្រាំគ្រា សូម្បីសរីរៈក៏ដល់នូវសេចក្តីគ្រាំគ្រាដូចគ្នា ទើបឯធម៌របស់សម្បុរសទាំងឡាយ មិនដល់នូវសេចក្តីគ្រាំគ្រា (ដូច្នេះ) ទេ សម្បុរសទាំងឡាយ តែងនិយាយឱ្យពួកសប្បុរសផងគ្នាដឹងបាន។

តំ បុត្តបសុសម្ផន្នំ ព្យាសត្តមនសំ នរំ
សុត្តំ គាមំ មហោឃោវ មច្ចុ អាទាយ គច្ឆតិ ។

មច្ចុ គឺសេចក្តីស្លាប់ តែងនាំយកនរជអ្នកស្រឹងជ្រប់ក្នុងកូន និងសត្វចិញ្ចឹមមានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេង ៗ នោះ ដូចទឹកជំនន់ធំដែលនាំយកអ្នកស្រុកកំពុងដេកលក់ដូច្នោះឯង។

ន សន្តិ បុត្តា តាណាយ ន បិតា ន(១) ពន្ធវា
អន្តកេនាធិបន្នស្ស នត្ថិ ញាតីសុ តាណតា ។

កាលបុគ្គលត្រូវមច្ចុគ្របសង្កត់ហើយ កូនទាំងឡាយ មិនមានដើម្បីជាទីពឹងបិតាក៏មិនមាន ទាំងផៅពង្សក៏មិនមានដើម្បីជាទីពឹងបានឡើយ សេចក្តីទីពឹងក្នុងញាតិទាំងឡាយក៏មិនមាន។

ឯតមត្ថវសំ ញត្វា បណ្ឌិតោ សីលសំវុតោ
និព្វានគមនំ មគ្គំ ខិប្បមេវ វិសោធយេ ។

បណ្ឌិតដឹងអំណាចប្រយោជន៍នេះហើយ គួរជាអ្នកសង្រួមក្នុងសីល គួរប្រញាប់ជម្រះផ្លូវជាទីទៅកាន់ព្រះនិព្វានឱ្យបាន។

១-បាលីក្នុងច្បាប់ឆដ្ឋសង្គាយនាថា **ន ច** ។

សព្វេ សង្ខារ អនិច្ចាតិ យទា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។

កាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា សង្ខារទាំងពួងមិនទៀងដូច្នេះ កាលណោះ រមែងនឿយណាយក្នុងសេចក្តីទុក្ខ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធិ។

សព្វេ សង្ខារ ទុក្ខាតិ យទា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។

កាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា ទាំងពួងនាំមកនូវសេចក្តីទុក្ខដូច្នេះ កាលណោះ រមែងនឿយណាយក្នុងសេចក្តីទុក្ខ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធិ។

សព្វេ ធម្មា អនត្តាតិ យទា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។

កាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា សង្ខារទាំងពួងមិនមែនជារបស់ខ្លួនដូច្នេះ កាលណោះ រមែងនឿយណាយក្នុងសេចក្តីទុក្ខ នេះជាផ្លូវនៃ-សេចក្តីបរិសុទ្ធិ។ (បិដកលេខ ៥២)

គាថាក្នុងមហាបរិនិព្វានសូត្រ

ទហរាបិ ច យេ វុឌ្ឍា យេ ពាលា យេ ច បណ្ឌិតា
អឌ្ឍា ចេវ ទលិទ្ទា ច សព្វេ មច្ចុបរាយណា ។

ពួកជនណាៗ ទោះបីក្មេងក្តី ចាស់ក្តី ពាលក្តី បណ្ឌិតក្តីអ្នកមានក្តី អ្នកក្រក្តី ជនទាំងអស់នោះ តែងមានសេចក្តីស្លាប់នៅពីខាងមុខ។

យថាបិ កុម្ភការស្ស កតំ មត្តិកភាជនំ
ខុទ្ទកញ្ច មហន្តញ្ច យញ្ច បក្កំ យញ្ច អាមកំ
សព្ពំ តេឆបរិយន្តំ ឯវំ មច្ចាន ជីវិតំ ។

ភាជន៍ដីដែលស្មូនធ្មាំងធ្វើហើយ ទោះបីតូចក្តី ធំក្តី ឆ្អិនក្តី ឆៅក្តី ភាជន៍ទាំងអស់នោះ មានកិរិយាបែកធ្លាយជាទីបំផុត យ៉ាងណា ជីវិតរបស់សត្វទាំងឡាយ ក៏យ៉ាងនោះដែរ ។

(បិដកលេខ ១៦ ទំព័រ ២៥៦)

ធម្មុទ្ទេស ៤ យ៉ាង

(បិដកលេខ ២៤ ទំព័រ ២៩៨)

ឧបនីយតិ លោកោ អទ្ធុវោ *សត្វលោកមិនទៀង តែងចូលដល់នូវជរានិងមរណៈ,*

អតាណោ លោកោ អនភិស្សរោ *សត្វលោកមិនមានគ្រឿងការពារ មិនមានទីពឹងទៀយ,*

អស្សកោ លោកោ សព្ពំ បហាយ គមនីយំ *សត្វលោកសុទ្ធតែមិនមានអ្វីជារបស់ខ្លួន ត្រូវតែលះបង់របស់ទាំងពួងហើយទៅ,*

ឩនោ លោកោ អតិត្តោ តណ្ហាទាសោ *សត្វលោកមានតែសេចក្តីខ្វះខាត មិនចេះឆ្អែត សុទ្ធតែជាខ្ញុំរបស់តណ្ហា ។*

រដ្ឋបាលសុត្តគាថា

(បិដកលេខ ២៤ ទំព័រ ៣០៨)

កន្ទន្តិ នំ ញាតិ បកីរិយំ[1]កេសេ
អហោ ឥតាឧោ អមរាតិ ចាហុ
ឥត្តេន នំ ចារុតំ នីហរិត្វា
ចិតំ សមាធាយ តតោ ឌហន្តិ ។

ពួកញាតិរំសាយសក់ទាំងឡាយ ហើយកន្ទក់កន្ទេញនឹងអ្នកស្លាប់នោះថា ឱហ្ន៎ ញាតិយើងស្លាប់ហើយ យកបុគ្គលស្លាប់នោះដែលរុំដោយសំពត់ នាំទៅដល់ជើងប្តូរហើយដុតក្នុងទីនោះ។

សោ ឌយ្ហតិ សូលេហិ តុជ្ជមាឧោ
ឯកេន ឥត្តេន បហាយ តោគេ
ឧ មិយ្យមានស្ស ឥវត្ថិ តាណា
ញាតី ច មិត្តា អថ វា សហាយា ។
ឋាយាទកា តស្ស ធនំ ហរន្តិ
សត្តោ បឧ គច្ឆតិ យេន កម្មំ
ឧ មិយ្យមានំ ធនមន្វេតិ កិញ្ចិ
បុត្តា ច ឋារ ច ធនញ្ច រដ្ឋំ ។

បុគ្គលស្លាប់នោះ លះបង់កោគៈទាំងឡាយ នៅតែសំពត់មួយ ត្រូវគេចាក់ដោយឈើសូល ត្រូវភ្លើងឆេះ គ្រឿងការពារទាំងឡាយ រមែងមិនមានដល់បុគ្គល

១-ក្នុងច្បាប់រដ្ឋសង្គាយនា ថា **ញាតី បកិរិយ** ។

ស្លាប់ទេ មានតែពួកញាតិមិត្រ ឬពួកសំឡាញ់ជាទាយាទនាំយកទ្រព្យរបស់បុគ្គលស្លាប់នោះទៅ ចំណែកសត្វក៏ទៅតាមយថាកម្ម ទ្រព្យបន្តិចបន្តួចរមែងមិនទៅតាមបុគ្គលស្លាប់ឡើយ ពួកកូនប្រពន្ធ ទ្រព្យ និងដែន ក៏មិនជាប់ទៅតាមទេ។

ន ទីឃមាយុំ លភតេ ធនេន
ន ចាបិ វិត្តេន ជរំ វិហន្តិ
អប្បកញ្ហិទំ ជីវិតមាហុ ធីរា
អបស្សតំ វិប្បរិណាមធម្មំ ។

បុគ្គលមិនបានអាយុវែងព្រោះទ្រព្យទេ ទាំងមិនមែនលះបង់ជរាបានព្រោះទ្រព្យដែរ អ្នកប្រាជ្ញពោលថាជីវិតនេះតិចពេកណាស់ មិនទៀងទាត់ មានសភាពប្រែប្រួលជាធម្មតា។

អឌ្ឍា ធនិន្ទា ច ថុសន្តិ ធស្សុំ
ពាលោ ច ធីរោ ច តថេវ ថុជ្ជោ
ពាលោ ហិ ពាល្យា វធិតោវ សេតិ
ធីរោ ច ន វេធតិ ធស្សុថុជ្ជោ ។

ពួកអ្នកស្តុកស្តម្ភក្តី អ្នកកំសត់ក្តី តែងពាល់ត្រូវនូវសមួស្សស្លាប់ ទាំងពាលទាំងប្រាជ្ញក៏ពាល់ត្រូវដូច្នោះដែរ តែថាមនុស្សពាលរមែងដេកទាំងតក់ស្លុត ព្រោះសេចក្តីល្ងង់ ចំណែកអ្នកប្រាជ្ញ បើទុកជាពាល់ត្រូវសមួស្សស្លាប់ក៏មិនញាប់ញ័រឡើយ។

អភិណ្ហប្បច្ចវេក្ខណធម្មោ

(ធម្មដែលគួរពិចារណារឿយៗ)

ជរាធម្មោម្ហិ ជរំ អនតីតោ *អាត្មាអញមានការចាស់ជរាជាធម្មតា នឹងកន្លងការចាស់ជរាទៅពុំបានឡើយ,*

ព្យាធិធម្មោម្ហិ ព្យាធិ អនតីតោ *អាត្មាអញមានការឈឺថ្កាត់ជាធម្មតា នឹងកន្លងការឈឺថ្កាត់ទៅពុំបានឡើយ,*

មរណធម្មោម្ហិ មរណំ អនតីតោ *អាត្មាអញមានសេចក្តីស្លាប់ជាធម្មតា នឹងកន្លងសេចក្តីស្លាប់ទៅពុំបានឡើយ,*

សព្ពេហិ មេ បិយេហិ មនាបេហិ នានាភាវោ វិនាភាវោ *អាត្មាអញគង់តែព្រាត់ប្រាសនិរាសចាកសត្វ និងសង្ខារ ជាទីស្រឡាញ់ពេញចិត្តទាំងអស់ពុំខាន,*

កម្មស្សកោម្ហិ កម្មទាយាទោ កម្មយោនិ កម្មពន្ធូ កម្មប្បដិសរណោ, យំ កម្មំ ករិស្សាមិ កល្យាណំ វា បាបកំ វា តស្ស ទាយាទោ ភវិស្សាមិ *អាត្មាអញមានកម្មជារបស់ខ្លួន មានកម្មជាអ្នកឱ្យផល មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីពំនាក់អាស្រ័យ, អាត្មាអញនឹងធ្វើនូវកម្មណា ជាកម្មល្អក្តី អាក្រក់ក្តី អាត្មាអញនឹងត្រូវជាអ្នកទទួលនូវផលនៃកម្មនោះពុំខានឯ*

(ចាកអភិណ្ហប្បច្ចវេក្ខិតព្ធឋានសូត្រ បិដកលេខ ៤៤ ទំព័រ ១៤៦)

បព្វជិតអតិណ្ណាបុព្វចេកូណធម្មោ

(ធម៌ ១០ យ៉ាងដែលបព្វជិតគប្បីពិចារណារឿយៗ)

វេវណ្ណិយម្ហិ អជ្ឈុបគតោ *អាត្មាអញមានភេទផ្សេងអំពីគ្រហស្ថ,*

បរបដិពទ្ធា មេ ជីវិកា *ការចិញ្ចឹមជីវិតរបស់អាត្មាអញ ជាប់ដោយសារអ្នកដទៃ,*

អញ្ញោ មេ អាកប្បោ ករណីយោ *អាត្មាអញត្រូវធ្វើអាកប្បកិរិយា (អំពើដោយកាយ និងវាចា) ផ្សេងដទៃប្លែកពីគ្រហស្ថ,*

កច្ចិ នុ ខោ មេ អត្តា សីលតោ ន ឧបវទតិ *ចិត្តរបស់អាត្មាអញមិនតិះដៀលខ្លួនឯង ព្រោះសីល (មិនបរិបូណ៌) ទេឬ?,*

កច្ចិ នុ ខោ មំ អនុវិច្ច វិញ្ញូ សព្រហ្មចារី សីលតោ ន ឧបវទន្តិ *ពួកសព្រហ្មចារីជាអ្នកប្រាជ្ញ ពិចារណាហើយ មិនតិះដៀលអាត្មាអញ ព្រោះសីល (មិនបរិបូណ៌)ទេឬ?,*

សព្ពេហិ មេ បិយេហិ មនាបេហិ នានាភាវោ វិនាភាវោ *អាត្មាអញគង់តែព្រាត់ប្រាស់និវាសចាកសត្វ និងសង្ខារ ជាទីស្រឡាញ់ពេញចិត្តទាំងអស់ពុំខាន,*

កម្មស្សកោម្ហិ កម្មទាយាទោ កម្មយោនិ កម្មពន្ធុ កម្មប្បដិសរណោ, យំ កម្មំករិស្សាមិ កល្យាណំ វា បាបកំ វា តស្ស ទាយាទោ ភវិស្សាមិ *អាត្មាអញមានកម្មជារបស់ខ្លួន មានកម្មជាអ្នកឱ្យផល មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីពំនាក់អាស្រ័យ, អាត្មាអញនឹងធ្វើនូវកម្មណា ជាកម្មល្អក្តី*

អាក្រក់ក្តី អាត្មាអញនឹងត្រូវជាអ្នកទទួលនូវផលនៃកម្មនោះពុំខាន,

កច្ចិម្ភតស្ស មេ រត្តិន្ទិវា ឥតិបតន្តិ *យប់និងថ្ងៃកន្លងទៅ អាត្មាអញបានធ្វើអ្វីខ្លះ?,*

កច្ចិ នុ ខោហំ សុញ្ញាគារេ អភិរមាមិ *អាត្មាអញត្រេកអរក្នុងផ្ទះស្ងាត់ឬទេ?,*

អត្ថិ នុ ខោ មេ ឧត្តរិមនុស្សធម្មោ អលមរិយញ្ញាណទស្សនវិសេសោ អធិគតោ, សោហំ បច្ឆិមេ កាលេ សព្រហ្មចារីហិ បុដ្ឋោ ន មង្កុ ភវិស្សាមិ

អាត្មាអញមានឧត្តរិមនុស្សធម៌ដែរឬទេ? អាត្មាអញបានពន្លះគុណវិសេសគឺញាណទស្សនៈដ៏ប្រសើរ ជាធម៌អាចកម្ចាត់បង់នូវកិលេសដែរឬទេ? បើពួកសព្រហ្មចារីមកសួរក្នុងបច្ឆិមកាល (គឺមរណសម័យ) អាត្មាអញនឹងមិនអៀនខ្មាសទេឬ?។

(ចាកបព្វជិតអភិណ្ហសូត្រ បិដកលេខ ៥០ ទំព័រ ១៨៨)

ភទ្ទេករត្តគាថា

(អ្នកមានរាត្រីមួយដ៏ចម្រើន)

ភគវា ឯតទវោច

អតីតំ នានྭាគមេយ្យ នប្បដិកង្ខេ អនាគតំ
យទតីតប្បហីនន្តំ អប្បត្តញ្ច អនាគតំ ។
បច្ចុប្បន្នញ្ច យោ ធម្មំ តត្ថ តត្ថ វិបស្សតិ
អសំហិរំ អសង្កុប្បំ តំ វិទ្ធា មនុព្រូហយេ ។

អជ្ជេវ កិច្ចមាតប្បំ កោ ជញ្ញា មរណំ សុវេ
ន ហិ នោ សង្គរន្តេន មហាសេនេន មច្ចុនា ។
ឯវំ វិហារិមាតាបី អហោរត្តមតន្ទិតំ
តំ វេ ភទ្ទេករត្តោតិ សន្តោ អាចិក្ខតេ មុនិ ។

ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា:

បុគ្គលមិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធដែលកន្ទងទៅហើយ មិនគប្បីប្រាថ្នាបញ្ចក្ខន្ធដែលមិនទាន់មកដល់ទេ ព្រោះបញ្ចក្ខន្ធណា ជាអតីត បញ្ចក្ខន្ធនោះកន្ទងហួសទៅហើយ បញ្ចក្ខន្ធណា ជាអនាគត បញ្ចក្ខន្ធនោះ ក៏មិនទាន់មកដល់ មួយទៀត បុគ្គលណា ឃើញច្បាស់នូវធម៌ជាបច្ចុប្បន្ន ក្នុងទីនោះៗ បុគ្គលនោះ លុះដឹងច្បាស់នូវព្រះនិព្វាន ដែលមិនរសេមរសាម និងមិនបានកម្រើក (ដោយពួកកិលេស) គប្បីចម្រើនឱ្យរឿយៗ នូវផលសមាបត្តិ ដែលមានព្រះនិព្វាននោះជាអារម្មណ៍ ឯការព្យាយាមជាគ្រឿងដុតកិលេស បុគ្គលគួរតែធ្វើក្នុងថ្ងៃនេះឯង អ្នកណានឹងដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែកបាន ព្រោះថាការតទល់របស់យើងចំពោះមច្ចុដែលមានសេនាដ៏ច្រើននោះ មិនមានសោះឡើយ អ្នកប្រាជ្ញដែលស្ងប់ទុក្ខហើយ តែងហៅបុគ្គលដែលមានវិហារធម៌យ៉ាងនេះ ជាអ្នកមានព្យាយាមដុតកិលេស ជាអ្នកមិនខ្ជិលច្រអូស អស់យប់ និងថ្ងៃនោះឯង ថាជាអ្នកមានរាត្រីមួយដ៏ចម្រើន។

(បិដកលេខ ២៨ ទំព័រ ២)

ជជាសុត្តគាថា

(ការកាប់ឆ្ការនូវជដា គឺតណ្ហា)

ទេវតាទូលសួរព្រះសាស្តាថា:

អន្តោជដា ពហិជដា ជដាយ ជដិតា បជា
តំ តំ គោតម បុច្ឆាមិ កោ ឥមំ វិជជយេ ជដំ ។

តណ្ហាជាគ្រឿងចាក់ស្រែះខាងក្នុងក៏មាន តណ្ហាជាគ្រឿងចាក់ស្រែះខាងក្រៅក៏មាន បពិត្រព្រះគោតម ព្រោះហេតុនោះ ខ្ញុំព្រះអង្គសូមសួរព្រះអង្គថា អ្នកណាអាចកាប់ឆ្ការនូវគ្រឿងចាក់ស្រែះ គឺតណ្ហានេះបាន។

ព្រះសាស្តាឆ្លើយតបនឹងទេវតាថា:

សីលេ បតិដ្ឋាយ នរោ សបញ្ញោ ចិត្តំ បញ្ញញ្ច ភាវយំ
អាតាបី និបកោ ភិក្ខុ សោ ឥមំ វិជជយេ ជដំ ។

នរជនមានប្រាជ្ញា បានតាំងមាំក្នុងសីលហើយ ចម្រើននូវសមាធិចិត្ត និងវិបស្សនាបញ្ញា ជាអ្នកមានព្យាយាមដុតកម្តៅកិលេស ប្រកបដោយបារិហារិយប្បញ្ញា ជាអ្នកឃើញភ័យក្នុងសង្សារ បុគ្គលនោះ ទើបកាប់ឆ្ការនូវតណ្ហាជាគ្រឿងចាក់ស្រែះនេះបាន។

យេសំ រាគោ ច ទោសោ ច អវិជ្ជា ច វិរាជិតា
ខីណាសវា អរហន្តោ តេសំ វិជដិតា ជជា
យត្ត នាមញ្ច រូបញ្ច អសេសំ ឧបរុជ្ឈតិ
បដិឃរូបសញ្ញា ច ឯត្ត សា ឆិជ្ជតេ ជជាឫ

ពួកបុគ្គលណា កម្ចាត់បង់រាគៈ ទោសៈ និងអវិជ្ជាបាន ជាអ្នកអស់អាសវៈ ធ្វើយចាកកិលេស ពួកបុគ្គលនោះ ឈ្មោះថាកាប់ឆ្ការនូវតណ្ហាជាគ្រឿងចាក់ស្រែះ

ហើយ នាម និងរូប ទាំងបដិឃសញ្ញា និងរូបសញ្ញា រលត់ទៅឥតមានសេសសល់ ក្នុងទីណា តណ្ហាជាគ្រឿងចាក់ស្រែះនោះ រមែងរលត់ទៅក្នុងទីនុ៎ះ។

(បិដកលេខ ២៨ ទំព័រ ៣៣)

អច្ឆរាសុត្តគាថា

(យានទៅកាន់ព្រះនិព្វាន)

ព្រះមានព្រះភាគទ្រង់ត្រាស់ថា:

ខុទ្ទកោ នាម សោ មគ្គោ អតយា នាម សា ទិសា
រថោ អក្ខុទ្ធនោ នាម ធម្មចក្កេហិ សំយុត្តោ ។
ហិរិ តស្ស អចាលម្ពោ សតស្ស បរិវារណំ
ធម្មាហំ សារថឹ ព្រូមិ សម្មាទិដ្ឋិបុរេជវំ ។
យស្ស ឯកទិសំ យានំ ឥត្ថិយា បុរិសស្ស វា
ស វេ ឯតេន យានេន និព្វានស្សេវ សន្តិកេ ។

ផ្លូវ គឺអដ្ឋង្គិកមគ្គនោះ ឈ្មោះថាជាផ្លូវត្រង់ ទិស គឺព្រះនិព្វាននោះ ឈ្មោះថាជាទិសគ្មានភ័យ រថ គឺអដ្ឋង្គិកមគ្គ ឈ្មោះថាជារថមិនឮសូរ ប្រកបដោយកង់គឺធម៌ បានដល់សេចក្តីព្យាយាមដោយកាយ និងចិត្ត ហិរិ និងឱត្តប្ប: ជាទ្រពង់នៃរថនោះ សតិជាព្រ័ត្រជ្រាមនៃរថនោះ តថាគតពោលថាធម៌ គឺលោកុត្តរមគ្គ ជាសារថី មានសម្មាទិដ្ឋិជាសន្ទុះទៅខាងមុខ ជនណា ទោះស្រី ឬប្រុស បានយានបែបនោះហើយ ជននោះឯង នឹងដល់នូវទីជិតនៃព្រះនិព្វាន ដោយយានន៎ុះមិនខាន។ (បិដកលេខ ២៩ ទំព័រ ៨៣)

ព្រហ្មាណសុត្តគាថា

(ព្រហ្មយាន គឺអរិយមគ្គមានអង្គ ៨)

យស្ស សទ្ធា ច បញ្ញា ច ធម្មា យុត្តា សទ្ធា ធុរំ
ហិរិ ឪសា មនោ យោត្តំ សតិ អារក្ខសារថិ ៚

ធម៌ទាំងឡាយជាគូគ្នា គឺសទ្ធា និងបញ្ញារបស់រថ គឺអរិយមគ្គឯណា ឯសទ្ធាទុកជានឹម ហិរិជាចន្ទោល មនោជាខ្សែបរ សតិជាសារថីអ្នកថែរក្សា។

រថេ សីលបរិក្ខារេ ឈានក្ខោ ចក្កវីរិយោ
ឧបេក្ខា ធុរសមាធិ អនិច្ឆា បរិចារណំ ៚

រថ គឺអរិយមគ្គ (នោះ) មានសីលជាគ្រឿងពាស មានឈានជាភ្លៅ មានវីរិយជាកង់ មានឧបេក្ខាជាកំណល់នឹម មានអនិច្ឆា (សេចក្តីមិនលោភ) ជារនាំងបាំង។

អព្យាបាទោ អវិហឹសា វិវេកោ យស្ស អាវុធំ
តីតិក្ខា ធម្មសន្ធារោ[1] យោគក្ខេមាយ វត្តតិ ៚

សេចក្តីមិនព្យាបាទ សេចក្តីមិនបៀតបៀន និងសេចក្តីស្ងប់ស្ងាត់ទុកជាអាវុធរបស់កុលបុត្ត (អ្នកស្ថិតនៅក្នុងរថ គឺអរិយមគ្គ) ឯណា (កុលបុត្តនោះ) មានធម៌ គឺអធិវាសនខន្តីជាគ្រឿងក្រោះ ប្រព្រឹត្តទៅដើម្បីព្រះនិព្វានជាទីក្សេមចាកយោគៈ។

ឯតទត្តនិ សម្ភតំ ព្រហ្មយានំ អនុត្តរំ
និយ្យន្តិ ធីរ លោកម្ហា អញ្ញាទត្ថុ ជយំ ជយំ ៚

១-បាលីក្នុងឆដ្ឋសង្គាយនាថា **ធម្មសន្ធារោ ៚**

ព្រហ្មយាននេះ រកគុណជាតដទៃក្រៃលែងជាងគ្មាន កើតព្រមក្នុងខ្លួនអ្នកប្រាជ្ញទាំងឡាយ កាលមានជ័យជំនះ(នូវរាគាទិកិលេស) រមែងចេញចាកលោកបានដោយពិត។

(បិដកលេខ ៣៧ ទំព័រ ១២)

តាយនសុត្តគាថា

តាយនទេវបុត្រពោលនូវគាថាទាំងឡាយនេះ ក្នុងសម្នាក់នៃព្រះមានព្រះភាគថា:

ឆិន្ទ សោតំ បរក្កម្ម កាមេ បនូទ ព្រាហ្មណ
ឧប្បហាយ មុនិ កាមេ ខេមប្បត្តមុបបជ្ជតិ ។
កយិរ ចេ កយិរថេនំ ទឡ្ហមេនំ បរក្កមេ
សិថិលោ ហិ បរិព្ភាជោ ភិយ្យោ អាកិរតេ រជំ ។
អកតំ ទុក្កដំ សេយ្យោ បច្ឆា តប្បតិ ទុក្កដំ
កតញ្ច សុកតំ សេយ្យោ យំ កត្វា នានុតប្បតិ ។
កុសោ យថា ទុគ្គហិតោ ហត្ថមេវានុកន្តតិ
សាមញ្ញំ ទុប្បរាមដ្ឋំ និរយាយុបកឌ្ឍតិ ។
យំកិញ្ចិ សិថិលំ កម្មំ សង្កិលិដ្ឋញ្ច យំ ឥតំ
សង្កស្សរំ ព្រហ្មចរិយំ ន តំ ហោតិ មហប្ផលំ ។

បពិត្រព្រាហ្មណ៍ ចូរអ្នកព្យាយាមកាត់ខ្សែតណ្ហា ចូរអ្នកបន្ទោបង់នូវកាមទាំងឡាយ មុនី(បើ) មិនលះបង់នូវកាមទាំងឡាយទេក៏មិនបាននូវឈាន បុគ្គលបើបានជាធ្វើព្យាយាម កុំគប្បីបន្ធូរបន្ថយព្យាយាមនោះឡើយ គប្បីធ្វើព្យាយាមនោះឱ្យមាំមួនឡើង ព្រោះថាបព្វជ្ជាដែលបុគ្គលកាន់ជូរៗ រមែងរោយនូវធូលី គឺ

កិលេសដ៏ក្រៃលែង អំពើអាក្រក់ដែលបុគ្គលមិនធ្វើហើយ ជាអំពើប្រសើរ អំពើអាក្រក់តែងក្តៅក្រហាយក្នុងកាលជាខាងក្រោយ មួយទៀត បុគ្គលធ្វើនូវអំពើណាតែងមិនក្តៅតាម អំពើនោះ ដែលបុគ្គលធ្វើហើយជាអំពើល្អប្រសើរ ភាពជាសមណៈដែលអ្នកបួសកាន់មិនល្អ តែងប្រទាញចូលទៅក្នុងនរក ដូចជាស្បូវដែលបុគ្គលកាន់មិនល្អ តែងមុតដៃដូច្នោះឯង ការងារណាមួយដ៏ធ្ងរៗក្តី វត្តណាមួយដ៏សៅហ្មងក្តី ព្រហ្មចរិយធម៌ណាមួយ ដែលបុគ្គលប្រព្រឹត្តដោយសេចក្តីរង្គៀសក្តី កិច្ចនោះ ជាកិច្ចមិនមានផលធំឡើយ។

(បិដកលេខ ២៩ ទំព័រ ១៣០)

ភារសុត្តគាថា

(ខន្ធ ៥ ជាភារៈបន្ទុក)

ភារា ហវេ បញ្ចក្ខន្ធា ភារហារោ ច បុគ្គលោ
ភារាទានំ ទុក្ខំ លោកេ ភារនិក្ខេបនំ សុខំ ។
និក្ខិបិត្វា គរុំ ភារំ អញ្ញំ ភារំ អនាទិយ
សមូលំ តណ្ហំ អព្ពុឡ្ហ និច្ឆាតោ បរិនិព្ពុតោ ។

បញ្ចក្ខន្ធជាភារៈបន្ទុកដោយពិត បុគ្គលអ្នកនាំនូវភារៈ គឺបញ្ចក្ខន្ធក្តី ការប្រកាន់មាំនូវភារៈ គឺបញ្ចក្ខន្ធក្តី តែងនាំមកនូវទុក្ខក្នុងលោក ការដាក់ចុះនូវភារៈជាហេតុនាំមកនូវសុខ លុះតែបុគ្គលដាក់ចុះនូវភារៈដ៏ធ្ងន់ គឺបញ្ចក្ខន្ធចេញ មិនកួចកាន់នូវភារៈដទៃទៀត បានដកឡើងនូវតណ្ហាព្រមទាំងឫស ទើបជាអ្នកមិនមានសេចក្តីប្រាថ្នាហើយបរិនិព្វាន ។ (បិដកលេខ ៣៣ ទំព័រ ៥៩)

ទ្វត្តឹសាការ

(អាការ ៣២ ក្នុងរាងកាយ)

អត្ថិ ឥមស្មឹ កាយេ *ក្នុងកាយនេះមាន*

កេសា *សក់*, **លោមា** *រោម*, **នខា** *ក្រចក*, **ទន្តា** *ធ្មេញ*, **តចោ** *ស្បែក*, **មំសំ** *សាច់*, **ន្ហារូ** *សរសៃ*, **អដ្ឋិ** *ឆ្អឹង*, **អដ្ឋិមិញ្ជា** *ខួរក្នុងឆ្អឹង*, **វក្កំ** *ទាប*, **ហទយំ** *បេះដូង*, **យកនំ** *ថ្លើម*, **កិលោមកំ** *រាវ*, **បិហកំ** *ក្រពះ*, **បប្ផាសំ** *សួត*, **អន្តំ** *ពោះវៀនធំ*, **អន្តគុណំ** *ពោះវៀនតូច*, **ឧទរិយំ** *អាហារឋ្មី*, **ករីសំ** *អាហារចាស់*, **បិត្តំ** *ប្រមាត់*, **សេម្ហំ** *ស្លេស្ម*, **បុព្ពោ** *ខ្ទុះ*, **លោហិតំ** *ឈាម*, **សេទោ** *ញើស*, **មេទោ** *ខ្លាញ់ខាប់*, **អស្សុ** *ទឹកភ្នែក*, **វសា** *ខ្លាញ់រាវ*, **ខេឡោ** *ទឹកមាត់*, **សិង្ឃាណិកា** *ទឹកសម្បោរ*, **លសិកា** *ទឹករំអិល*, **មុត្តំ** *ទឹកមូត្រ*, **មត្ថកេ មត្ថលុង្គំ** *ខួរក្នុងក្បាល។*

(បិដកលេខ ៥២ ទំព័រ ២)

បដិច្ចសមុប្បាទ

(ធម៌ជាបច្ច័យដល់គ្នានឹងគ្នាកើតឡើង)

អវិជ្ជាបច្ចយា សង្ខារ *សង្ខារទាំងឡាយ (កើតមាន) ព្រោះបច្ច័យ គឺអវិជ្ជា*

ពោលគឺសេចក្តីល្ងង់,

សង្ខារប្បច្ចយា វិញ្ញាណំ *វិញ្ញាណ (កើតមាន) ព្រោះបច្ច័យ គឺសង្ខារ,*

វិញ្ញាណប្បច្ចយា នាមរូបំ *នាម និងរូប (កើតមាន) ព្រោះបច្ច័យ គឺវិញ្ញាណ,*

នាមរូបប្បច្ចយា សឡាយតនំ *អាយតន:៦ (កើតមាន) ព្រោះបច្ច័យ គឺនាម*

និងរូប,

សឡាយតនប្បច្ចយា ផស្សោ *សម្ផស្ស (កើតមាន) ព្រោះបច្ច័យ គឺអាយតនៈ៦,*

ផស្សប្បច្ចយា វេទនា *វេទនា (កើតមាន) ព្រោះបច្ច័យ គឺសម្ផស្ស,*

វេទនាបច្ចយា តណ្ហា *តណ្ហា (កើតមាន) ព្រោះបច្ច័យ គឺវេទនា,*

តណ្ហាបច្ចយា ឧបាទានំ *ឧបាទាន (កើតមាន) ព្រោះបច្ច័យ គឺតណ្ហា,*

ឧបាទានប្បច្ចយា ភវោ *ភព (កើតមាន) ព្រោះបច្ច័យ គឺឧបាទាន,*

ភវប្បច្ចយា ជាតិ *ជាតិ (កើតមាន) ព្រោះបច្ច័យ គឺភព,*

ជាតិប្បច្ចយា ជរាមរណំ *ជរា និងមរណៈ(កើតមាន) ព្រោះបច្ច័យ គឺជាតិ,*

សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ *សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីលំបាកចិត្ត[1] និងសេចក្តីចង្អៀតចង្អល់ចិត្ត ទាំងឡាយ ក៏រមែងកើតមាន (ព្រោះជាតិជាបច្ច័យដែរ),*

ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ *កិរិយាកើតមាន នៃកងទុក្ខទាំងអស់នេះ មានដោយប្រការដូច្នេះ។*

អវិជ្ជាយត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ *កិរិយារលត់នៃសង្ខារ ព្រោះកិរិយារលត់ដោយអរិយមគ្គ ឥតមានសេសសល់នៃអវិជ្ជាមែនពិត,*

សង្ខារនិរោធា វិញ្ញាណនិរោធោ *កិរិយារលត់នៃវិញ្ញាណ ព្រោះរលត់នៃសង្ខារ,*

វិញ្ញាណនិរោធា នាមរូបនិរោធោ *កិរិយារលត់នៃនាម និងរូប ព្រោះរលត់*

១-សព្ទថា **ទុក្ខ** នេះ អដ្ឋកថាពន្យល់ថា ជាសេចក្តីទុក្ខផ្លូវកាយ ឯ **ទោមស្ស** គឺជាទុក្ខតាមផ្លូវចិត្ត ព្រោះដូច្នេះ ទើបយើងសម្រេចប្រែជាថ្មីតាមន័យរបស់អដ្ឋកថា និងតម្រូវតាមពាក្យប្រែរបស់បិដកលេខ ៦ ទំព័រ ១, លេខ ៨០ ទំព័រ ១៩៦ និងលេខ ៨១ ទំព័រ ៧។

នៃវិញ្ញាណ,

នាមរូបនិរោធា សឡាយតននិរោធោ *កិរិយារលត់នៃអាយតន: ៦ ព្រោះរលត់នៃនាម និងរូប,*

សឡាយតននិរោធា ផស្សនិរោធោ *កិរិយារលត់នៃសម្ផស្ស ព្រោះរលត់នៃអាយតន: ៦,*

ផស្សនិរោធា វេទនានិរោធោ *កិរិយារលត់នៃវេទនា ព្រោះរលត់នៃសម្ផស្ស,*

វេទនានិរោធា តណ្ហានិរោធោ *កិរិយារលត់នៃតណ្ហា ព្រោះរលត់នៃវេទនា,*

តណ្ហានិរោធា ឧបាទាននិរោធោ *កិរិយារលត់នៃឧបាទាន ព្រោះរលត់នៃតណ្ហា,*

ឧបាទាននិរោធា ភវនិរោធោ *កិរិយារលត់នៃភព ព្រោះរលត់នៃឧបាទាន,*

ភវនិរោធា ជាតិនិរោធោ *កិរិយារលត់នៃជាតិ ព្រោះរលត់នៃភព,*

ជាតិនិរោធា ជរាមរណំ *ជរា និងមរណៈ (រលត់) ព្រោះកិរិយារលត់នៃជាតិ,*

សោកបរិទេវទុក្ខទោមនស្សុបាយាសា និរុជ្ឈន្តិ *សេចក្តីសោក សេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីលំបាកចិត្ត និងសេចក្តីចង្អៀតចង្អល់ចិត្តទាំងឡាយ ក៏រមែងរលត់ទៅ (ព្រោះកិរិយារលត់ទៅនៃជាតិដែរ),*

ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ *កិរិយារលត់ទៅនៃកងទុក្ខទាំងអស់នេះ មានដោយប្រការដូច្នេះៗ*

(បិដកលេខ ៦ ទំព័រ ១ និងលេខ ៥២ ទំព័រ ១១៣)

អនេកជាតិ

(ឧទានគាថា ជាបឋមពុទ្ធវនចៈ)

អនេកជាតិសំសារំ សន្ធាវិស្សំ អនិព្ពិសំ
គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ ។
គហការក ទិដ្ឋោសិ បុន គេហំ ន កាហសិ
សព្ពា តេ ផាសុកា ភគ្គា គហកូដំ វិសង្ខតំ
វិសង្ខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគា ។

កាលតថាគតមិនទាន់បានជួបប្រទះ (ពោធិញ្ញាណ រវល់តែ) ស្វះស្វែងរក ជាងផ្ទះ គឺតណ្ហា អ្នកធ្វើផ្ទះ គឺអត្តភាពក៏អន្ទោលទៅកាន់សង្សារវដ្ត មានជាតិ ដ៏ច្រើន សេចក្តីកើតជាទុក្ខរឿយៗ ។ នែជាងផ្ទះ អ្នកឯងធ្វើផ្ទះ គឺអត្តភាព តថាគត ឃើញហើយ អ្នកនឹងធ្វើផ្ទះ(របស់តថាគត)ទៀតមិនបានឡើយ ឆ្អឹងជំនីរ គឺកិលេស របស់អ្នកទាំងអស់ តថាគតកាច់បំបាក់អស់ហើយ ដំបូលផ្ទះ គឺអវិជ្ជា តថាគត កម្ចាត់ចោលហើយ ចិត្តរបស់តថាគតដល់ព្រះនិព្វានដែលមានសង្ខារប្រាសហើយ តថាគតបានដល់ធម៌ជាគ្រឿងក្សយតណ្ហាទាំងឡាយហើយ ។

(បិដកលេខ ៥២ ទំព័រ ៥៤)

ដកស្រង់ពីសៀវភៅសត្តបរិត្ត-ទ្វាទសបរិត្តរបស់ព្រះវិសុទ្ធិវង្ស ហួតតាត-និងបិដក

ចប់សំវេជនីយគាថាតែប៉ុណ្ណោះ

សត្តប្បករណាភិធម្ម

(ព្រះអភិធម្ម ៧ គម្ពីរ)

****

សេចក្តីពន្យល់

សត្តប្បករណាភិធម្មនេះ គឺជាធម៌ដ៏មានជម្រៅក្នុងព្រះពុទ្ធសាសនា ជាសច្ចធម៌ ដែលជាបរមត្តសុទ្ធ ។ មិនមែនជាសត្វបុគ្គលណាឡើយ ប្រព្រឹត្តទៅដើម្បីកម្ចាត់នូវកិលេសតណ្ហា ទិដ្ឋិមាននេះដែលមាននៅក្នុងឧបាទានខន្ធនេះ។

*ធម៌នេះព្រះអង្គទ្រង់សម្តែងប្រោសពុទ្ធមាតា នៅឯទេវលោកជាន់តាវត្តិង្ស ក្នុងវស្សាទី ៧ អស់រយៈពេល ៣ ខែទើបចប់ ។ ធម៌អភិធម្មនេះ ចាស់ទុំខ្មែរយើងនិយមសូត្រនាំមុខនៅពេលហែសពទៅបូជា, ឯលោកអ្នកសូត្រនោះ ហៅ**លោកអភិធម្ម** ឬហៅ**លោកមាតិកា** និងសម្រាប់សូត្រដារវេរបង្សុកូលក្នុងពេលឆ្នងកម្មវិធីបុណ្យផ្សេងៗ ផងដែរ។*

សូមបញ្ជាក់ថា ការសូត្រធម៌នេះ មិនមែនមានន័យថា ដើម្បីនាំអ្នកស្លាប់ឱ្យទៅកើតក្នុងឋានសួគ៌នោះទេ ។ ហើយក៏មិនមែនទាល់តែសូត្រទើបបាន បើមិនសូត្រមិនបាននោះដែរ ។ គឺថាបើពេលវេលាវែងអាចសូត្របានក៏សូត្របុះ តែបើពេលវេលាខ្លីមិនអាចនឹងសូត្របានទេក៏មិនមានទាស់ខុសអ្វីដែរ។ ឯការសូត្រទៀតសោត ខ្ញុំយល់ថា ទោះសូត្រពេលណាក៏បានដែរ ស្រេចហើយតែត្រូវការសូត្រនិងមានអ្នកប្រាថ្នាចង់ស្តាប់, មិនមែនសម្រាប់តែសូត្រនាំមុខសព ឬដារឆ្នងនោះទេ តែក៏ត្រូវស្គាល់កាល និងបុគ្គលផងដែរ...។

ធម្មសង្គណី

(តិកមាតិកា ២២ តិកៈ)

កុសលា ធម្មា អកុសលា ធម្មា អព្យាកតា ធម្មា, សុខាយ វេទនាយ សម្បយុត្តា ធម្មា ទុក្ខាយ វេទនាយ សម្បយុត្តា ធម្មា អទុក្ខមសុខាយ វេទនាយ សម្បយុត្តា ធម្មា, វិតក្កា ធម្មា វិតក្កធម្មធម្មា នេវវិតក្កនវិតក្កធម្ម ធម្មា, ឧបាទិន្នុបាទានិយា ធម្មា អនុបាទិន្នុបាទានិយា ធម្មា អនុបាទិន្នានុបាទានិយា ធម្មា, សង្កិលិដ្ឋសង្កិលេសិកា ធម្មា អសង្កិលិដ្ឋសង្កិលេសិកា ធម្មា អសង្កិលិដ្ឋាសង្កិលេសិកា ធម្មា, សវិតក្កសវិចារ ធម្មា អវិតក្កវិចារមត្តា ធម្មា អវិតក្កាវិចារ ធម្មា, បីតិសហគតា ធម្មា សុខសហគតា ធម្មា ឧបេក្ខាសហគតា ធម្មា, ទស្សនេន បហាតព្ពា ធម្មា ភាវនាយ បហាតព្ពា ធម្មា នេវ ទស្សនេន ន ភាវនាយ បហាតព្ពា ធម្មា, ទស្សនេន បហាតព្ពហេតុកា ធម្មា ភាវនាយ បហាតព្ពហេតុកា ធម្មា នេវ ទស្សនេន ន ភាវនាយ បហាតព្ពហេតុកា ធម្មា, អាចយគាមិនោ ធម្មា អបចយគាមិនោ ធម្មា នេវាចយគាមិនោ នាបចយគាមិនោ ធម្មា, សេក្ខា ធម្មា អសេក្ខា ធម្មា នេវសេក្ខា នាសេក្ខា ធម្មា, បរិត្តា ធម្មា មហគ្គតា ធម្មា អប្បមាណា ធម្មា, បរិត្តារម្មណា ធម្មា មហគ្គតារម្មណា ធម្មា អប្បមាណារម្មណា ធម្មា, ហីនា ធម្មា មជ្ឈិមា ធម្មា បណីតា ធម្មា, មិច្ឆត្តនិយតា ធម្មា សម្មត្តនិយតា ធម្មា អនិយតា ធម្មា, មគ្គារម្មណា ធម្មា មគ្គហេតុកា ធម្មា មគ្គាធិបតិនោ ធម្មា, ឧប្បន្នា ធម្មា អនុប្បន្នា ធម្មា ឧប្បាទិនោ ធម្មា, អតីតា ធម្មា អនាគតា ធម្មា បច្ចុប្បន្នា ធម្មា, អតីតារម្មណា ធម្មា អនាគតារម្មណា ធម្ម បច្ចុប្បន្នារម្មណា ធម្មា, អជ្ឈត្តា ធម្មា ពហិទ្ធា ធម្មា អជ្ឈត្តពហិទ្ធា ធម្មា, អជ្ឈត្តារម្មណា ធម្មា ពហិទ្ធារម្មណា ធម្មា អជ្ឈត្តពហិទ្ធារម្មណា ធម្មា, សនិទស្សនសប្បដិឃា ធម្មា អនិទស្សនសប្បដិឃា ធម្មា អនិទស្សនាប្បដិឃា ធម្មា ។

ពាវីសតិ តិកមាតិកា ធម្មសង្គណិប្បករណំ នាម សមត្តំ ។ (បិ. ៧៨/ ១-៣)

វិភង្គ

ក្នុងអដ្ឋកថា

(តទនន្តរំ វិភង្គប្បករណំ នាមេតំ)

ខន្ធវិភង្គោ អាយតនវិភង្គោ ធាតុវិភង្គោ សច្চវិភង្គោ ឥន្ទ្រិយវិភង្គោ បច្চយាការវិភង្គោ សតិប្បដ្ឋានវិភង្គោ សម្មប្បធានវិភង្គោ ឥទ្ធិបាទវិភង្គោ ពោជ្ឈង្គវិភង្គោ មគ្គវិភង្គោ ឈានវិភង្គោ អប្បមញ្ញាវិភង្គោ សិក្ខាបទវិភង្គោ បដិសម្ភិទាវិភង្គោ ញាណវិភង្គោ ខុទ្দកវត្ថុវិភង្គោ ធម្មហទយវិភង្គោតិ ។

អដ្ឋារសវិធេន វិភត្តំ វិភង្គប្បករណំ នាម សមត្តំ ។

ធាតុកថា

ក្នុងអដ្ឋកថា

(តទនន្តរំ ធាតុកថាបករណំ នាមេតំ)

សង្គហោ អសង្គហោ សង្គហិតេន អសង្គហិតំ អសង្គហិតេន សង្គហិតំ សង្គហិតេន សង្គហិតំ អសង្គហិតេន អសង្គហិតំ សម្បយោគោ វិប្បយោគោ សម្បយុត្តេន វិប្បយុត្តំ វិប្បយុត្តេន សម្បយុត្តំ សម្បយុត្តេន សម្បយុត្តំ វិប្បយុត្តេន វិប្បយុត្តំ សង្គហិតេន សម្បយុត្តំ វិប្បយុត្តំ សម្បយុត្តេន សង្គហិតំ អសង្គហិតំ អសង្គហិតេន សម្បយុត្ត វិប្បយុត្តំ វិប្បយុត្តេន សង្គហិតំ អសង្គហិតន្តិ ។

ចុទ្দសវិធេន វិភត្តំ ធាតុកថាបករណំ នាម សមត្តំ ។

បុគ្គលប្បញ្ញត្តិ

ក្នុងអដ្ឋកថា

(តទនន្តរំ បុគ្គលប្បញ្ញត្តិប្បករណំ នាមេតំ)

ខន្ធប្បញ្ញត្តិ អាយតនប្បញ្ញត្តិ ធាតុប្បញ្ញត្តិ សច្ចប្បញ្ញត្តិ ឥន្ទ្រិយប្បញ្ញត្តិ បុគ្គលប្បញ្ញត្តីតិ ។

ឆវិធេន ឋិតត្តំ បុគ្គលប្បញ្ញត្តិប្បករណំ នាម សមត្តំ ។

កថាវត្ថុ

ក្នុងអដ្ឋកថា

(តទនន្តរំ កថាវត្ថុប្បករណំ នាមេតំ)

សកវាទិបញ្ហាសុត្តសតានិ បរវាទិបញ្ហាសុត្តសតានីតិ សុត្តសហស្សំ សមោធានេត្វានឋិតត្តំ កថាវត្ថុប្បករណំ នាម សមត្តំ ។

យមក

ក្នុងអដ្ឋកថា

(តទនន្តរំ យមកប្បករណំ នាមេតំ)

មូលយមកំ ខន្ធយមកំ អាយតនយមកំ ធាតុយមកំ សច្ចយមកំ សង្ខារយមកំ អនុសយយមកំ ចិត្តយមកំ ធម្មយមកំ ឥន្ទ្រិយយមកន្តិ ។

ទសវិធេន ឋិតត្តំ យមកប្បករណំ នាម សមត្តំ ។

បដ្ឋាន

ក្នុងអដ្ឋកថា

(តទនន្តរំ មហាបដ្ឋានប្បករណំ នាមេតំ)

ហេតុប្បច្ចយោ អារម្មណប្បច្ចយោ អធិបតិប្បច្ចយោ អនន្តរប្បច្ចយោ សមនន្តរប្បច្ចយោ សហជាតប្បច្ចយោ អញ្ញមញ្ញប្បច្ចយោ និស្សយប្បច្ចយោ ឧបនិស្សយប្បច្ចយោ បុរេជាតប្បច្ចយោ បច្ឆាជាតប្បច្ចយោ អាសេវនប្បច្ចយោ កម្មប្បច្ចយោ វិបាកប្បច្ចយោ អាហារប្បច្ចយោ ឥន្ទ្រិយប្បច្ចយោ ឈានប្បច្ចយោ មគ្គប្បច្ចយោ សម្បយុត្តប្បច្ចយោ វិប្បយុត្តប្បច្ចយោ អត្ថិប្បច្ចយោ នត្ថិប្បច្ចយោ វិគតប្បច្ចយោ អវិគតប្បច្ចយោតិ ។

បច្ចយវសេន តា ចតុវីសតិវិធេន វិភត្តំ មហាបដ្ឋានប្បករណំ នាម សមត្តំ ។

វិភង្គ

(បិដកលេខ ៨0 ទំព័រ ១...)

(តទនន្តរំ វិភង្គប្បករណំ នាមេតំ)

បញ្ចក្ខន្ធា រូបក្ខន្ធោ វេទនាខន្ធោ សញ្ញាខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ ។

តត្ថ កតមោ រូបក្ខន្ធោ ។ យំ កិញ្ចិ រូបំ អតីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា អយំ វុច្ចតិ រូបក្ខន្ធោ ។

តត្ថ កតមោ វេទនាខន្ធោ ។ យា កាចិ វេទនា អតីតានាគតប្បច្ចុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមវាហីនា វា បណីតា វា យា ទូរេ

សន្តិកេ វា តទេកជ្ឈំ អតិសញ្ឆាហិត្វា អតិសទ្ធិបិត្វា អយំ ឫច្ចតិ វេទនាខន្ធោ ។

តត្ថ កតមោ សញ្ញាខន្ធោ ។ យា កាចិ សញ្ញា អតីតានាគតបច្ចុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមា វា ហីនា វា បណីតា វា យា ទូរេ សន្តិកេ វា តទេកជ្ឈំ អតិសញ្ឆាហិត្វា អតិសទ្ធិបិត្វា អយំ ឫច្ចតិ សញ្ញាខន្ធោ ។

តត្ថ កតមោ សង្ខារក្ខន្ធោ ។ យេ កេចិ សង្ខារា អតីតានាគតបច្ចុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមា វា ហីនា វា បណីតា វា យេ ទូរេ សន្តិកេ វា តទេកជ្ឈំ អតិសញ្ឆាហិត្វា អតិសទ្ធិបិត្វា អយំ ឫច្ចតិ សង្ខារក្ខន្ធោ ។

តត្ថ កតមោ វិញ្ញាណក្ខន្ធោ ។ យំ កិញ្ចិ វិញ្ញាណំ អតីតានាគតបច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា តទេកជ្ឈំ អតិសញ្ឆាហិត្វា អតិសទ្ធិបិត្វា អយំ ឫច្ចតិ វិញ្ញាណក្ខន្ធោ ។

(អយំ ខន្ធវិភង្គោតិ អដ្ឋារសវិធេន វិភត្តំ វិភង្គប្បករណំ នាម សមត្តំ) ។

ធាតុកថា

(បិដកលេខ ៨៣ ទំព័រ ១-២)

(តទនន្តរំ ធាតុកថាបករណំ នាមេតំ)

សង្គហោ អសង្គហោ សង្គហិតេន អសង្គហិតំ អសង្គហិតេន សង្គហិតំ សង្គហិតេន សង្គហិតំ អសង្គហិតេន អសង្គហិតំ សម្បយោគោ វិប្បយោគោ សម្បយុត្តេន វិប្បយុត្តំ វិប្បយុត្តេន សម្បយុត្តំ សម្បយុត្តេន សម្បយុត្តំ វិប្បយុត្តេន វិប្បយុត្តំ សង្គហិតេន សម្បយុត្តំ វិប្បយុត្តំ សម្បយុត្តេន សង្គហិតំ អសង្គហិតំ អសង្គហិតេន សម្បយុត្តំ វិប្បយុត្តំ វិប្បយុត្តេន

សន្តហិតំ អសន្តហិតន្តិ ។ បញ្ចក្ខន្ធា ទ្វាទសាយតនានិ អដ្ឋារស ធាតុយោ ចត្តារិ សច្ចានិ ពាវីសតិន្ទ្រិយានិ បដិច្ចសមុប្បាទោ ចត្តារោ សតិប្បដ្ឋានា ចត្តារោ សម្មប្បធានា ចត្តារោ ឥទ្ធិបាទា ចត្តារិ ឈានានិ ចតស្សោ អប្បមញ្ញាយោ បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គា អរិយោ អដ្ឋង្គិកោ មគ្គោ ឆឝេឝ្យា វេទនា សញ្ញា ចេតនា ចិត្តំ អធិមោក្ខោ មនសិការោ ។ តីហិ សន្តហោ តីហិ អសន្តហោ ចតូហិ សម្បយោគោ ចតូហិ វិប្បយោគោ ។ សរាគោ វិសរាគោ សព្ពាបិ ធម្មសន្តតិ ធាតុកថាយ មាតិកា ។

(ឆយមាតិកាតិ បញ្ចាវិធេន វិភត្តំ ធាតុកបករណំ នាម សមត្តំ)។

បុគ្គលប្បញ្ញត្តិ

(បិដកលេខ ៨៣ ទំព័រ ២១១-២១៦)

(តទនន្តរំ បុគ្គលប្បញ្ញត្តិប្បករណំ នាមេតំ)

ខន្ធប្បញ្ញត្តិ អាយតនប្បញ្ញត្តិ ធាតុប្បញ្ញត្តិ សច្ចប្បញ្ញត្តិ ឥន្ទ្រិយប្បញ្ញត្តិ បុគ្គលប្បញ្ញត្តីតិ ។

កិត្តាវតា ខន្ធានំ ខន្ធប្បញ្ញត្តិ ។ យាវតា បញ្ចក្ខន្ធា រូបក្ខន្ធោ វេទនា-ខន្ធោ សញ្ញាខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ ឯត្តាវតា ខន្ធានំ ខន្ធប្បញ្ញត្តិ ។

កិត្តាវតា អាយតនានំ អាយតនប្បញ្ញត្តិ ។ យាវតា ទ្វាទសាយតនានិ ចក្ខាយតនំ រូបាយតនំ សោតាយតនំ សទ្ទាយតនំ ឃានាយតនំ គន្ធាយតនំ ជិវ្ហាយតនំ រសាយតនំ កាយាយតនំ ផោដ្ឋព្ពាយតនំ មនាយតនំ ធម្មាយតនំ ឯត្តាវតា អាយតនានំ អាយតនប្បញ្ញត្តិ ។

កិត្តាវតា ធាតូនំ ធាតុប្បញ្ញត្តិ ។ យាវតា អដ្ឋារស ធាតុយោ ចក្ខុធាតុ

រូបធាតុ ចក្ខុវិញ្ញាណធាតុ សោតធាតុ សទ្ទធាតុ សោតវិញ្ញាណធាតុ ឃានធាតុ គន្ធធាតុ ឃានវិញ្ញាណធាតុ ជិវ្ហាធាតុ រសធាតុ ជិវ្ហាវិញ្ញាណធាតុ កាយធាតុ ផោដ្ឋព្វធាតុ កាយវិញ្ញាណធាតុ មនោធាតុ ធម្មធាតុ មនោវិញ្ញាណធាតុ ឯត្តាវតា ធាតូនំ ធាតុបញ្ញត្តិ ។

កិត្តាវតា សច្চានំ សច្চបញ្ញត្តិ ។ យាវតា ចត្តារិ សច្চានិ ទុក្ខសច្চំ សមុទយសច្চំ និរោធសច្চំ មគ្គសច្চំ ឯត្តាវតា សច្চានំ សច្চបញ្ញត្តិ ។

កិត្តាវតា ឥន្ទ្រិយានំ ឥន្ទ្រិយបញ្ញត្តិ ។ យាវតា ពាវីសតិន្ទ្រិយានិ ចក្ខុន្ទ្រិយំ សោតិន្ទ្រិយំ ឃានិន្ទ្រិយំ ជិវ្ហិន្ទ្រិយំ កាយិន្ទ្រិយំ មនិន្ទ្រិយំ ឥត្ថិន្ទ្រិយំ បុរិសិន្ទ្រិយំ ជីវិតិន្ទ្រិយំ សុខិន្ទ្រិយំ ទុក្ខិន្ទ្រិយំ សោមនស្សិន្ទ្រិយំ ឧបេក្ខិន្ទ្រិយំ សទ្ធិន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយំ អញ្ញិន្ទ្រិយំ អញ្ញាតាវិន្ទ្រិយំ ឯត្តាវតា ឥន្ទ្រិយានំ ឥន្ទ្រិយបញ្ញត្តិ ។

កិត្តាវតា បុគ្គលានំ បុគ្គលបញ្ញត្តិ ។ សមយវិមុត្តោ អសមយវិមុត្តោ កុប្បធម្មោ អកុប្បធម្មោ បរិហានធម្មោ អបរិហានធម្មោ ចេតនាភព្វោ អនុរក្ខនាភព្វោ បុថុជ្ជនោ គោត្រភូ ភយូបរតោ អភយូបរតោ ភព្វាគមនោ អភព្វាគមនោ និយតោ អនិយតោ បដិបន្នកោ ផលេឋិតោ សមសីសី ឋិតកប្បី អរិយោ អនរិយោ សេក្ខោ អសេក្ខោ នេវសេក្ខោ នាសេក្ខោ តេវិជ្ជោ ឆឡភិញ្ញោ សម្ភាសម្ភទ្ធោ បច្ចេកពុទ្ធោ ទ្វិតរោតាគវិមុត្តោ បញ្ញាវិមុត្តោ កាយសក្ខី ទិដ្ឋិប្បត្តោ សទ្ធាវិមុត្តោ ធម្មានុសារី សទ្ធានុសារី សត្តក្ខត្តុំបរមោ កោលំកោលោ ឯកពីជីសកទាគាមី អនាគាមី អន្តរាបរិនិព្ពាយី ឧបហច្চបរិនិព្ពាយី អសង្ខារបរិនិព្ពាយី សសង្ខារបរិនិព្ពាយី ឧទ្ធំសោតោ អកនិដ្ឋគាមី សោតាបន្នោ សោតាបត្តិផលសច្ឆិកិរិយាយ បដិបន្នោ សកទាគាមី សកទាគាមិផលសច្ឆិកិរិ-

យាយ បដិបន្នោ អនាគាមី អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ អរហា អរហត្តផលសច្ឆិកិរិយាយ បដិបន្នោតិ ។

(អយំ ខន្ធប្បញ្ញាត្តាតិ ឆឝិធេន ឝិតត្តំ បុគ្គលប្បញ្ញាត្តិប្បករណំនាម សមត្តំ) ។

កថាវត្ថុ

(បិដកលេខ ៨៤ ទំព័រ ១-២)

(តទនន្តរំ កថាវត្ថុប្បករណំ នាមេតំ)

បុគ្គលោ ឧបលព្ភតិ សច្ឆិកដ្ឋបរមដ្ឋេនាតិ[1] អាមន្តា ។ យោ សច្ឆិកដ្ឋោ បរមដ្ឋោ តតោ សោ បុគ្គលោ ឧបលព្ភតិ សច្ឆិកដ្ឋបរមដ្ឋេនាតិ ។ ន ហេវំ វត្តព្ពេ ។

អាជានាហិ និគ្គហំ ហញ្ចិ បុគ្គលោ ឧបលព្ភតិ សច្ឆិកដ្ឋបរមដ្ឋេន តេន ឯត អេ វត្តព្ពេ យោ សច្ឆិកដ្ឋោ បរមដ្ឋោ តតោ សោ បុគ្គលោ ឧបលព្ភតិ សច្ឆិកដ្ឋបរមដ្ឋេនាតិ ។ យំ តត្ត ឝេសិវត្តព្ពេ ខោ បុគ្គលោ ឧបលព្ភតិ សច្ឆិ-កដ្ឋបរមដ្ឋេន នោ ច វត្តព្ពេ យោ សច្ឆិកដ្ឋោ បរមដ្ឋោ តតោ សោ បុគ្គលោ ឧបលព្ភតិ សច្ឆិកដ្ឋបរមដ្ឋេនាតិ មិច្ឆា ។

នោ ចេ បន វត្តព្ពេ យោ សច្ឆិកដ្ឋោ បរមដ្ឋោ តតោ សោ បុគ្គលោ ឧបលព្ភតិ សច្ឆិកដ្ឋបរមដ្ឋេនាតិ នោ ឯត អេ វត្តព្ពេ បុគ្គលោ ឧបលព្ភតិ សច្ឆិកដ្ឋបរមដ្ឋេនាតិ ។ យំ តត្ត ឝេសិ វត្តព្ពេ ខោ បុគ្គលោ ឧបលព្ភតិ សច្ឆិកដ្ឋបរមដ្ឋេន នោ ច វត្តព្ពេ យោ សច្ឆិកដ្ឋោ បរមដ្ឋោ តតោ សោ បុគ្គលោ ឧបលព្ភតិ សច្ឆិកដ្ឋបរមដ្ឋេនាតិ មិច្ឆា ។ អនុលោមបញ្ហាកំ ។

១- ក្នុងច្បាប់អដ្ឋសង្គាយនា មានពាលីថា **សច្ឆិកដ្ឋ** ..., **សច្ឆិកដ្ឋោ** .... គ្រប់កន្លែង ។

(សកវាទិបញ្ហាសុត្តសតានិ បរវាទិបញ្ហាសុត្តសតានីតិ សុត្តសហស្សំ សមោធានេត្វាន ឋិតត្តំ កថាវត្ថុប្បករណំ នាម សមត្តំ) ។

យមក

(បិដកលេខ ៨៧ ទំព័រ ១-៣)

(តទនន្តរំ យមកប្បករណំ នាមេតំ)

យេ កេចិ កុសលា ធម្មា សព្វេ តេ កុសលមូលា យេ វា បន កុសលមូលា សព្វេ តេ ធម្មា កុសលា ។ យេ កេចិ កុសលា ធម្មា សព្វេ តេ កុសលមូលេន ឯកមូលា យេ វា បន កុសលមូលេន ឯកមូលា សព្វេ តេ ធម្មា កុសលា ។ យេ កេចិ កុសលមូលេន ឯកមូលា ធម្មា សព្វេ តេ កុសលមូលេន អញ្ញមញ្ញមូលា យេ វា បន កុសលមូលេន អញ្ញមញ្ញមូលា សព្វេ តេ ធម្មា កុសលា ។

យេ កេចិ កុសលា ធម្មា សព្វេ តេ កុសលមូលមូលា[1] យេ វា បន កុសលមូលមូលា សព្វេ តេ ធម្មា កុសលា ។ យេ កេចិ កុសលា ធម្មា សព្វេ តេ កុសលមូលេន ឯកមូលមូលា យេ វា បន កុសលមូលេន ឯកមូលមូលា សព្វេ តេ ធម្មា កុសលា ។ យេ កេចិ កុសលមូលេន ឯកមូលមូលា ធម្មា សព្វេ តេ កុសលមូលេន អញ្ញមញ្ញមូលមូលា យេ វា បន កុសលមូលេន អញ្ញមញ្ញមូលមូលា សព្វេ តេ ធម្មា កុសលា ។

យេ កេចិ កុសលា ធម្មា សព្វេ តេ កុសលមូលកា យេ វា បន កុសលមូលកា សព្វេ តេ ធម្មា កុសលា ។ យេ កេចិ កុសលា ធម្មា សព្វេ តេ កុសលមូលេន ឯកមូលកា យេ វា បន កុសលមូលេន ឯមូលកា សព្វេ តេ

១-ត្រង់នេះបិដកខ្មែរបាត់ពាក្យ **មូល** ។

ធម្មា កុសលា ។ យេ កេចិ កុសលមូលេន ឯកមូលកា ធម្មា សព្វេ តេ កុសលមូលេន អញ្ញមញ្ញមូលកា យេ វា បន កុសលមូលេន អញ្ញមញ្ញមូលកា សព្វេ តេ ធម្មា កុសលា ។

យេ កេចិ កុសលា ធម្មា សព្វេ តេ កុសលមូលមូលកា យេ វា បន កុសលមូលមូលកា សព្វេ តេ ធម្មា កុសលា ។ យេ កេចិ កុសលា ធម្មា សព្វេ តេ កុសលមូលេន ឯកមូលមូលកា យេ វា បន កុសលមូលេន ឯកមូលមូលកា សព្វេ តេ ធម្មា កុសលា ។ យេ កេចិ កុសលមូលេន ឯកមូលមូលកា ធម្មា សព្វេ តេ កុសលមូលេន អញ្ញមញ្ញមូលមូលកា យេ វា បន កុសលមូលេន អញ្ញមញ្ញមូលមូលកា សព្វេ តេ ធម្មា កុសលាតិ ។

មូលំ ហេតុ និទានញ្ចាសម្ភវោ បភវេន ច សមុដ្ឋានាហារអ្ហណា បច្ច-យោ សមុទយេន ចាតិ ។

(មូលយមកាទិទស យមកប្បដិមណ្ឌិតំ យមកប្បករណំ មាន សមត្តំ) ។

បដ្ឋាន

(បិដកលេខ ៩៤ ទំព័រ ១...)

(តទនន្តរំ មហាបដ្ឋានប្បករណំ នាមេតំ)

ហេតុប្បច្ចយោ អារម្មណប្បច្ចយោ អធិបតិប្បច្ចយោ អនន្តរប្បច្ចយោ សមនន្តរប្បច្ចយោ សហជាតប្បច្ចយោ អញ្ញមញ្ញប្បច្ចយោ និស្សយប្បច្ចយោ ឧបនិស្សយប្បច្ចយោ បុរេជាតប្បច្ចយោ បច្ឆាជាតប្បច្ចយោ អាសេវនប្បច្ចយោ កម្មប្បច្ចយោ វិបាកប្បច្ចយោអាហារប្បច្ចយោ ឥន្ទ្រិយប្បច្ចយោ ឈានប្បច្ចយោ មគ្គប្បច្ចយោ សម្បយុត្តប្បច្ចយោ វិប្បយុត្តប្បច្ចយោ អត្ថិប្បច្ចយោ នត្ថិប្ប-ច្ចយោ វិគតប្បច្ចយោ អវិគតប្បច្ចយោ ។

តិកញ្ច បជ្ជានវរំ ទុកុត្តមំ ទុកត្តិកញ្ចេវ តិកទុកញ្ច
តិកត្តិកញ្ចេវ ទុកទុកញ្ច ឆ អនុលោមម្ហិ នយា សុគម្ហិក ៗ
តិកញ្ច បជ្ជានវរំ ទុកុត្តមំ ទុកត្តិកញ្ចេវ តិកទុកញ្ច
តិកត្តិកញ្ចេវ ទុកទុកញ្ច ឆ បច្ចនីយម្ហិនយា សុគម្ហិក ៗ
តិកញ្ច បជ្ជានវរំ ទុកុត្តមំ ទុកត្តិកញ្ចេវ តិកទុកញ្ច
តិកត្តិកញ្ចេវ ទុកទុកញ្ច ឆ អនុលោមបច្ចនីយម្ហិនយា សុគម្ហិក ៗ
តិកញ្ច បជ្ជានវរំ ទុកុត្តមំ ទុកត្តិកញ្ចេវ តិកទុកញ្ច
តិកត្តិកញ្ចេវ ទុកទុកញ្ច ឆ បច្ចនីយានុលោមម្ហិ នយា សុគម្ហិកតិ ៗ
(ចតុវីសតិប្បច្ចយវសេន អយំ សមន្តបជ្ជានប្បករណេវណ្ណនា និដ្ឋិតា)ៗ

សត្តប្បករណាភិធម្ម បាលី-ប្រែ

ធម្មសង្គណី

តិកមាតិកា ២២ តិក:

កុសលា ធម្មា អកុសលា ធម្មា អព្យាកតា ធម្មា *ពួកធម៌ជាកុសល ពួកធម៌ជាអកុសល ពួកធម៌ជាអព្យាក្រឹត,*

សុខាយ វេទនាយ សម្បយុត្តា ធម្មា ទុក្ខាយ វេទនាយ សម្បយុត្តា ធម្មា អទុក្ខមសុខាយ វេទនាយ សម្បយុត្តា ធម្មា *ពួកធម៌ប្រកបដោយសុខវេទនា ពួកធម៌ប្រកបដោយទុក្ខវេទនា ពួកធម៌ប្រកបដោយវេទនា មិនជាទុក្ខ មិនជាសុខ,*

វិបាកា ធម្មា វិបាកធម្មធម្មា នេវវិបាកនវិបាក ធម្មធម្មា *ពួកធម៌ជាវិបាក ពួកធម៌មានវិបាកជាប្រក្រតី ពួកធម៌មិនមែនជាវិបាក ទាំងមិនមែនមានវិបាកជាប្រក្រតី,*

ឧបាទិន្នុបាទានិយា ធម្មា អនុបាទិន្នុបាទានិយា ធម្មា អនុបាទិន្នានុបាទានិយា ធម្មា *ពួកធម៌ដែលមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន ពួកធម៌ដែលមិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទាន ពួកធម៌ដែលមិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទាន,*

សង្កិលិដ្ឋសង្កិលេសិកា ធម្មា អសង្កិលិដ្ឋសង្កិលេសិកា ធម្មា អសង្កិលិដ្ឋា-សង្កិលេសិកា ធម្មា *ពួកធម៌ដែលសៅហ្មង ទាំងគួរដើម្បីដល់នូវសេចក្តីសៅហ្មង ពួកធម៌ដែលមិនសៅហ្មង តែគួរដើម្បីដល់នូវសេចក្តីសៅហ្មង ពួកធម៌ដែលមិនសៅហ្មង ទាំងមិនគួរដើម្បីដល់នូវសេចក្តីសៅហ្មង,*

សវិតក្កសវិចារា ធម្មា អវិតក្កវិចារមត្តា ធម្មា អវិតក្កាវិចារា ធម្មា *ពួកធម៌ប្រកបដោយវិតក្កៈ ទាំងប្រកបដោយវិចារៈ ពួកធម៌គ្មានវិតក្កៈ មានត្រឹមតែវិចារៈ ពួកធម៌គ្មានវិតក្កៈ ទាំងគ្មានវិចារៈ*

បីតិសហគតា ធម្មា សុខសហគតា ធម្មា ឧបេក្ខាសហគតា ធម្មា *ពួកធម៌ប្រកបដោយបីតិ ពួកធម៌ប្រកបដោយសុខៈ ពួកធម៌ប្រកបដោយឧបេក្ខា,*

ទស្សនេន បហាតព្វា ធម្មា ភាវនាយ បហាតព្វា ធម្មា នេវទស្សនេន ន ភាវនាយ បហាតព្វា ធម្មា *ពួកធម៌ដែលត្រូវលះដោយទស្សនៈ ពួកធម៌ដែលត្រូវលះដោយភាវនា ពួកធម៌ដែលមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា,*

ទស្សនេន បហាតព្វហេតុកា ធម្មា ភាវនាយ បហាតព្វហេតុកា ធម្មា នេវទស្សនេន ន ភាវនាយ បហាតព្វហេតុកា ធម្មា *ពួកធម៌មានហេតុដែលត្រូវលះដោយទស្សនៈ ពួកធម៌មានហេតុដែលត្រូវលះដោយភាវនា ពួកធម៌មានហេតុដែលមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា,*

អាចយគាមិនោ ធម្មា អបចយគាមិនោ ធម្មា នេវាចយគាមិនោ នាបចយគាមិនោ ធម្មា *ពួកធម៌ដល់នូវការសន្សំកពួនឡើងដោយកម្មកិលេស ពួកធម៌មិនដល់នូវការសន្សំកពួនឡើង ពួកធម៌មិនមែនជាដល់នូវការសន្សំកពួនឡើង មិនមែនជាមិនដល់នូវការសន្សំកពួនឡើង,*

សេក្ខា ធម្មា អសេក្ខា ធម្មា នេវសេក្ខា នាសេក្ខា ធម្មា *ពួកធម៌ជារបស់សេក្ខបុគ្គល ពួកធម៌ជារបស់អសេក្ខបុគ្គល ពួកធម៌មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គល,*

បរិត្តា ធម្មា មហគ្គតា ធម្មា អប្បមាណា ធម្មា *ពួកធម៌មានសភាពតូចថ្នារ ពួកធម៌ដល់នូវសភាពធំ ពួកធម៌ប្រមាណមិនបាន,*

បរិត្តារម្មណា ធម្មា មហគ្គតារម្មណា ធម្មា អប្បមាណារម្មណា ធម្មា *ពួកធម៌មានអារម្មណ៍តូចថ្នារ ពួកធម៌មានអារម្មណ៍ដល់នូវសភាពធំ ពួកធម៌មាន*

អារម្មណ៍ប្រមាណមិនបាន,

ហីនា ធម្មា មជ្ឈិមា ធម្មា បណីតា ធម្មា *ពួកធម៌ដ៏ថោកទាប ពួកធម៌យ៉ាងកណ្តាល ពួកធម៌ដ៏ឧត្តម,*

មិច្ឆត្តនិយតា ធម្មា សម្មត្តនិយតា ធម្មា អនិយតា ធម្មា *ពួកធម៌មានសភាពខុស និងទៀង ពួកធម៌មានសភាពត្រូវ និងទៀង ពួកធម៌មិនទៀង,*

មគ្គារម្មណា ធម្មា មគ្គហេតុកា ធម្មា មគ្គាធិបតិនោ ធម្មា *ពួកធម៌មានមគ្គជាអារម្មណ៍ ពួកធម៌មានមគ្គជាហេតុ ពួកធម៌មានមគ្គជាអធិបតី,*

ឧប្បន្នា ធម្មា អនុប្បន្នា ធម្មា ឧប្បាទិនោ ធម្មា *ពួកធម៌កើតឡើងហើយ ពួកធម៌មិនទាន់កើតឡើង ពួកធម៌ប្រុងនឹងកើតឡើង,*

អតីតា ធម្មា អនាគតា ធម្មា បច្ចុប្បន្នា ធម្មា *ពួកធម៌ជាអតីត ពួកធម៌ជាអនាគត ពួកធម៌ជាបច្ចុប្បន្ន,*

អតីតារម្មណា ធម្មា អនាគតារម្មណា ធម្មា បច្ចុប្បន្នារម្មណា ធម្មា *ពួកធម៌មានអារម្មណ៍ជាអតីត ពួកធម៌មានអារម្មណ៍ជាអនាគត ពួកធម៌មានអារម្មណ៍ជាបច្ចុប្បន្ន,*

អជ្ឈត្តា ធម្មា ពហិទ្ធា ធម្មា អជ្ឈត្តពហិទ្ធា ធម្មា *ពួកធម៌ជាខាងក្នុង ពួកធម៌ជាខាងក្រៅ ពួកធម៌ជាខាងក្នុង និងខាងក្រៅ,*

អជ្ឈត្តារម្មណា ធម្មា ពហិទ្ធារម្មណា ធម្មា អជ្ឈត្តពហិទ្ធារម្មណា ធម្មា *ពួកធម៌មានអារម្មណ៍ខាងក្នុង ពួកធម៌មានអារម្មណ៍ខាងក្រៅ ពួកធម៌មាន*

អារម្មណ៍ខាងក្នុង និងខាងក្រៅ,

សនិទស្សនសប្បដិឃា ធម្មា អនិទស្សនសប្បដិឃា ធម្មា អនិទស្សនា-ប្បដិឃា ធម្មា *ពួកធម៌ប្រកបដោយការឃើញ និងប្រកបដោយការប៉ះពាល់ ពួកធម៌មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ ពួកធម៌មិនប្រកបដោយការឃើញ មិនប្រកបដោយការប៉ះពាល់។*

ពាទីសតិ តិកមាតិកា *ចប់ តិកមាតិកា ២២*

ធម្មសង្គណិប្បករណាមនាម សមត្តំ *ធម្មសង្គណិប្បករណ៍ ចប់តែប៉ុណ្ណោះ។*

(ស្រង់ពីប្រជុំភាណវារៈ របស់បណ្ឌិតសែម-សូរ កែសម្រួលតាមបិដកលេខ ៧៨ ទំព័រ ១-៣)

វិភង្គ

ក្នុងអដ្ឋកថា

(**តទនន្តរំ ភង្គប្បករណំ នាមេតំ** *លំដាប់អំពីធម្មសង្គណិប្បករណ៍នោះមក យើងនឹងស្វាធ្យាយនូវវិភង្គប្បករណ៍ដូចតទៅនេះ*)

ខន្ធវិភង្គោ អាយតនវិភង្គោ ធាតុវិភង្គោ សច្চវិភង្គោ ឥន្ទ្រិយវិភង្គោ បច្চយាការវិភង្គោ សតិប្បដ្ឋានវិភង្គោ សម្មប្បធានវិភង្គោ ឥទ្ធិបាទវិភង្គោ ពោជ្ឈង្គវិភង្គោ មគ្គវិភង្គោ ឈានវិភង្គោ អប្បមញ្ញាវិភង្គោ សិក្ខាបទវិភង្គោ បដិសម្ភិទាវិភង្គោ ញាណវិភង្គោ ខុទ្দកវត្ថុវិភង្គោ ធម្មហទយវិភង្គោតិ ៙

(វិភង្គ ១៨) គឺខន្ធវិភង្គ អាយតនវិភង្គ ធាតុវិភង្គ សច្চវិភង្គ ឥន្ទ្រិយវិភង្គ បច្চយាការវិភង្គ សតិប្បដ្ឋានវិភង្គ សម្មប្បធានវិភង្គ ឥទ្ធិបាទវិភង្គ ពោជ្ឈង្គវិភង្គ

មគ្គវិភង្គ ឈានវិភង្គ អប្បមញ្ញាវិភង្គ សិក្ខាបទវិភង្គ បដិសម្ភិទាវិភង្គ ញាណ-វិភង្គ ខុទ្ទកវត្ថុវិភង្គ ធម្មហទយវិភង្គ។

(**អដ្ឋារសវិធេន វិភត្តំ វិភង្គប្បករណំ នាម សមត្តំ** *វិភង្គប្បករណ៍ ចែកចេញដោយវិភង្គ ១៨ ប្រការ ចប់តែប៉ុណ្ណេះ។*

ធាតុកថា

ក្នុងអដ្ឋកថា

(**ឥទានិ ធាតុកថាបករណំ នាមេតំ** *លំដាប់អំពីវិភង្គប្បករណ៍នោះមក យើងនឹងស្វាធ្យាយនូវធាតុកថាបករណ៍ដូចតទៅនេះ)*

សង្គហោ អសង្គហោ (ធាតុ ១៤ គឺ) *ការសង្គ្រោះ និងការមិនសង្គ្រោះ ១*

សង្គហិតេន អសង្គហិតំ *ការមិនសង្គ្រោះ មួយអន្ទើដោយការសង្គ្រោះ ១*

អសង្គហិតេន សង្គហិតំ *ការសង្គ្រោះ មួយអន្ទើដោយការមិនសង្គ្រោះ ១*

សង្គហិតេន សង្គហិតំ *ការសង្គ្រោះ មួយអន្ទើដោយការសង្គ្រោះ ១*

អសង្គហិតេន អសង្គហិតំ *ការមិនសង្គ្រោះ មួយអន្ទើដោយការមិនសង្គ្រោះ ១*

សម្បយោគោ វិប្បយោគោ *ការសមប្រកប និងការប្រាសចេញ ១*

សម្បយុត្តេន វិប្បយុត្តំ *ការប្រាសចេញ មួយអន្ទើដោយការសមប្រកប ១*

វិប្បយុត្តេន សម្បយុត្តំ *ការសមប្រកប មួយអន្ទើដោយការប្រាសចេញ ១*

សម្បយុត្តេន សម្បយុត្តំ *ការសមប្រកប មួយអន្ទើដោយការសមប្រកប ១*

វិប្បយុត្តេន វិប្បយុត្តំ *ការប្រាសចេញ មួយអន្ទើដោយការប្រាសចេញ ១*

សន្តហិតេន សម្បយុត្តំ វិប្បយុត្តំ *ការសមប្រកប និងការប្រាសចេញមួយអន្ទើដោយការសង្គ្រោះ ១*

សម្បយុត្តេន សន្តហិតំ អសន្តហិតំ *ការសង្គ្រោះ និងការមិនសង្គ្រោះមួយអន្ទើដោយការសមប្រកប ១*

អសន្តហិតេន សម្បយុត្តំ វិប្បយុត្តំ *ការសមប្រកប និងការប្រាសចេញមួយអន្ទើដោយការមិនសង្គ្រោះ ១*

វិប្បយុត្តេន សន្តហិតំ អសន្តហិតន្តិ *ការសង្គ្រោះ និងការមិនសង្គ្រោះមួយអន្ទើដោយការប្រាសចេញ ១ ។*

(ចុទ្ទសវិធេន វិភត្តំ ធាតុកថាបករណំ នាម សមត្តំ *ធាតុកថាបករណ៍ចែកចេញដោយធាតុ ១៤ ប្រការ ចប់តែប៉ុណ្ណោះ)។*

បុគ្គលប្បញ្ញត្តិ

ក្នុងអដ្ឋកថា

(តទនន្តរំ បុគ្គលប្បញ្ញត្តិប្បករណំ នាមេសា *លំដាប់អំពីធាតុកថាបករណ៍នោះមក យើងនឹងស្វាធ្យាយនូវបុគ្គលប្បញ្ញត្តិប្បករណ៍ ដូចតទៅនេះ)*

ខន្ធប្បញ្ញត្តិ អាយតនប្បញ្ញត្តិ ធាតុប្បញ្ញត្តិ សច្ចប្បញ្ញត្តិ ឥន្ទ្រិយប្បញ្ញត្តិ បុគ្គលប្បញ្ញត្តីតិ *(បញ្ញត្តិ ៦ គឺ) ខន្ធប្បញ្ញត្តិ អាយតនប្បញ្ញត្តិ ធាតុប្បញ្ញត្តិ សច្ចប្បញ្ញត្តិ ឥន្ទ្រិយប្បញ្ញត្តិ បុគ្គលប្បញ្ញត្តិ។*

(ឆ វិធេន វិភត្តំ បុគ្គលប្បញ្ញត្តិប្បករណំ នាម សមត្តំ *បុគ្គលប្បញ្ញត្តិប្បករណ៍ ចែកចេញដោយបញ្ញត្តិ ៦ ប្រការ ចប់តែប៉ុណ្ណោះ)។*

កថាវត្ថុ

ក្នុងអដ្ឋកថា

(**តទនន្តរំ កថាវត្ថុប្បករណំ នាមេតំ** *លំដាប់អំពីបុគ្គលប្បញ្ញត្តិប្បករណ៍នោះមក យើងនឹងស្វាធ្យាយនូវកថាវត្ថុប្បករណ៍ដូចតទៅនេះ*)

សកវាទិ បញ្ហា សុត្តសតានិ បរវា ទិបញ្ហាសុត្តសតានីតិ សុត្តសហស្សំ សមោធានេត្វាន ឋិតត្តំ កថាវត្ថុប្បករណំ នាម សមត្តំ *កថាវត្ថុប្បករណ៍ដែលប្រជុំចែកជាមួយពាន់សូត្រ គឺប្រាំរយសូត្ររបស់សកវាទី ប្រាំរយសូត្ររបស់បរវាទី ចប់តែប៉ុណ្ណោះ។*

យមក

ក្នុងអដ្ឋកថា

(**តទនន្តរំ យមកប្បករណំ នាមេតំ** *លំដាប់អំពីកថាវត្ថុប្បករណ៍នោះមក យើងនឹងស្វាធ្យាយនូវយមកប្បករណ៍ដូចតទៅនេះ*)

មូលយមកំ ខន្ធយមកំ អាយតនយមកំ ធាតុយមកំ សច្ចយមកំ សង្ខារ-យមកំ អនុសយយមកំ ចិត្តយមកំ ធម្មយមកំ ឥន្ទ្រិយយមកន្តិ (*យមក: ១០ គឺ*) *មូលយមក: ខន្ធយមក: អាយតនយមក: ធាតុយមក: សច្ចយមក: សង្ខារ-យមក: អនុសយយមក: ចិត្តយមក: ធម្មយមក: ឥន្ទ្រិយយមក:។*

(**ឥសិធេន ឋិតត្តំ យមកប្បបករណំ នាមសមត្តំ** *យមកប្បករណ៍ចែកចេញដោយយមក: ១០ ប្រការ ចប់តែប៉ុណ្ណោះ*)។

បដ្ឋាន

ក្នុងអដ្ឋកថា

(**តទនន្តរំ មហាបដ្ឋានប្បករណំ នាមេតំ** *លំដាប់អំពីយមកប្បករណ៍នោះមក យើងនឹងស្វាធ្យាយនូវមហាបដ្ឋានប្បករណ៍ដូចតទៅនេះ*)

ហេតុប្បច្ចយោ អារម្មណប្បច្ចយោ អធិបតិប្បច្ចយោ អនន្តរប្បច្ចយោ សមនន្តរប្បច្ចយោ សហជាតប្បច្ចយោ អញ្ញមញ្ញប្បច្ចយោ និស្សយប្បច្ចយោ ឧបនិស្សយប្បច្ចយោ បុរេជាតប្បច្ចយោ បច្ឆាជាតប្បច្ចយោ អាសេវនប្បច្ចយោ កម្មប្បច្ចយោ វិបាកប្បច្ចយោ អាហារប្បច្ចយោ ឥន្ទ្រិយប្បច្ចយោ ឈានប្ប-ច្ចយោ មគ្គប្បច្ចយោ សម្បយុត្តប្បច្ចយោ វិប្បយុត្តប្បច្ចយោ អត្ថិប្បច្ចយោ នត្ថិប្បច្ចយោ វិគតប្បច្ចយោ អវិគតប្បច្ចយោតិ *(បច្ច័យ ២៤ គឺ) ហេតុប្បច្ច័យ អារម្មណប្បច្ច័យ អធិបតិប្បច្ច័យ អនន្តរប្បច្ច័យសមនន្តរប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឧបនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ បច្ឆាជាត-ប្បច្ច័យ អាសេវនប្បច្ច័យ កម្មប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្ប-ច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ អវិគតប្បច្ច័យ។*

(**បច្ចយវសេន តាវ ចតុវីសតិវិធេន ឥតិ មហាបដ្ឋានប្បករណំ នាម សមត្តំ** *មហាបដ្ឋានប្បករណ៍ ចែកចេញជាធម៌ ២៤ ប្រការ ដោយអំណាចនៃបច្ច័យ ចប់តែប៉ុណ្ណោះ)។*

ខន្ធវិភង្គ

(បិដកលេខ ៨០ ទំព័រ ១)

(**តទនន្តរំ វិភង្គប្បករណំ នាមេតំ** *លំដាប់អំពីធម្មសង្គណីប្បករណ៍នោះមក យើងនឹងស្វាធ្យាយនូវវិភង្គប្បករណ៍ដូចតទៅនេះ*) **បញ្ចក្ខន្ធា រូបក្ខន្ធោ វេទនាខន្ធោ សញ្ញាខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ** *(ខន្ធ៥គឺ) រូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ។*

តត្ថ កតមោ រូបក្ខន្ធោ *បណ្តាខន្ធទាំង៥នោះ រូបខន្ធតើដូចម្តេច?*

យំកិញ្ចិ រូបំ អតីតានាគតបច្চុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វាយំ ទូរេសន្តិកេវា តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា អយំ វុច្ចតិ រូបក្ខន្ធោ *រូបណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ដែលជាអជ្ឈត្តរូប (រូបខាងក្នុង) ក្តី ពហិទ្ធារូប (រូបខាងក្រៅ) ក្តី ឱឡារិករូប (រូបគ្រោតគ្រាត) ក្តី សុខុមរូប (រូបល្អិត) ក្តី ហីនរូប (រូបថោកទាប) ក្តី បណីតរូប (រូបថ្លៃថ្លា) ក្តី ទូរេរូប (រូបក្នុងទីឆ្ងាយ) ក្តី សន្តិកេរូប (រូបក្នុងទីជិត) ក្តី នេះហៅថា រូបក្ខន្ធ ព្រោះប្រមូលរួបរួមនូវរូបទាំងអស់នោះក្នុងទីជាមួយគ្នា។*

តត្ថ កតមោ វេទនាខន្ធោ *បណ្តាខន្ធទាំង៥នោះ វេទនាខន្ធតើដូចម្តេច*

យា កាចិ វេទនា អតីតានាគតបច្চុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមាវា ហីនា វា បណីតា វា យា ទូរេ សន្តិកេ វា តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា អយំ វុច្ចតិ វេទនាខន្ធោ *វេទនាណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ដែលជាអជ្ឈត្តវេទនាក្តី ពហិទ្ធាវេទនាក្តី ឱឡារិកវេទនាក្តី សុខុមវេទនាក្តី ហីនវេទនាក្តី បណីតវេទនាក្តី ទូរេវេទនាក្តី សន្តិកេវេទនាក្តី នេះ*

ហៅថា វេទនាខន្ធ ព្រោះប្រមូលរួបរួមនូវវេទនាទាំងអស់នោះក្នុងទីជាមួយគ្នា។

តត្ថ កតមោ សញ្ញាខន្ធោ *បណ្តាខន្ធទាំង ៥ នោះ សញ្ញាខន្ធតើដូចម្តេច*

យា កាចិ សញ្ញា អតីតានាគតបច្চុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមា វា ហីនា វា បណីតា វា យា ទូរេ សន្តិកេ វា តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា អយំ វុច្ចតិ សញ្ញាខន្ធោ *សញ្ញាណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ដែលជាអជ្ឈត្តសញ្ញាក្តី ពហិទ្ធាសញ្ញាក្តី ឱឡារិកសញ្ញាក្តី សុខុមសញ្ញាក្តី ហីនសញ្ញាក្តី បណីតសញ្ញាក្តី ទូរេសញ្ញាក្តី សន្តិកេសញ្ញាក្តី នេះហៅថា សញ្ញាខន្ធ ព្រោះប្រមូលរួបរួមនូវសញ្ញាទាំងអស់នោះក្នុងទីជាមួយគ្នា។*

តត្ថ កតមោ សង្ខារក្ខន្ធោ *បណ្តាខន្ធទាំង ៥ នោះ សង្ខារខន្ធតើដូចម្តេច*

យេ កេចិ សង្ខារា អតីតានាគតបច្চុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមា វា ហីនា វា បណីតា វា យេ ទូរេសន្តិកេ វា តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា អយំ វុច្ចតិ សង្ខារក្ខន្ធោ *សង្ខារទាំងឡាយណាមួយជាអតីត អនាគត បច្ចុប្បន្ន ដែលជាអជ្ឈត្តសង្ខារក្តី ពហិទ្ធាសង្ខារក្តី ឱឡារិកសង្ខារក្តី សុខុមសង្ខារក្តី ហីនសង្ខារក្តី បណីតសង្ខារក្តី ទូរេសង្ខារក្តី សន្តិកេសង្ខារក្តី នេះហៅថា សង្ខារក្ខន្ធ ព្រោះប្រមូលរួបរួមនូវសង្ខារទាំងអស់នោះក្នុងទីជាមួយគ្នា។*

តត្ថ កតមោ វិញ្ញាណក្ខន្ធោ *បណ្តាខន្ធទាំង ៥ នោះ វិញ្ញាណក្ខន្ធ តើដូចម្តេច*

យំ កិញ្ចិ វិញ្ញាណំ អតីតានាគតបច្চុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា

ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា តទេកជ្ឈំ អភិសញ្ញូហិត្វា អភិសង្ខិបិត្វា អយំ វុច្ចតិ វិញ្ញាណក្ខន្ធោ *វិញ្ញាណណាមួយ ជាអតីតអនាគត បច្ចុប្បន្ន ដែលជាអជ្ឈត្តវិញ្ញាណក្តី ពហិទ្ធាវិញ្ញាណក្តី ឱឡារិកវិញ្ញាណក្តី សុខុមវិញ្ញាណក្តី ហីនវិញ្ញាណក្តី បណីតវិញ្ញាណក្តី ទូរេវិញ្ញាណក្តី សន្តិកេវិញ្ញាណក្តី នេះហៅថា វិញ្ញាណក្ខន្ធ ព្រោះប្រមូលរួបរួមនូវវិញ្ញាណទាំងអស់នោះក្នុងទីជាមួយគ្នា។*

(**អយំ ខន្ធវិភង្គោតិ អជ្ឈាសវិធេន វិភត្តំ វិភង្គបករណំ នាម សមត្តំ** *នេះឈ្មោះខន្ធវិភង្គវិភង្គប្បករណ៍ ចែកចេញដោយធម៌ ១៨ ប្រការចប់តែប៉ុណ្ណោះ)។*

ធាតុកថា

(បិដកលេខ ៨៣ ទំព័រ ១-២)

(**តទនន្តរំ ធាតុកថាបករណំ នាមេតំ** *លំដាប់អំពីវិភង្គប្បករណ៍នោះមក យើងនឹងស្វាធ្យាយនូវធាតុកថាបករណ៍ដូចតទៅនេះ)*

សង្គហោ អសង្គហោ *(ធាតុ ១៨ គឺ) ការសង្គ្រោះ និងការមិនសង្គ្រោះ ១*

សង្គហិតេន អសង្គហិតំ *ការមិនសង្គ្រោះ មួយអន្ទើដោយការសង្គ្រោះ ១*

អសង្គហិតេន សង្គហិតំ *ការសង្គ្រោះ មួយអន្ទើដោយការមិនសង្គ្រោះ ១*

សង្គហិតេន សង្គហិតំ *ការសង្គ្រោះ មួយអន្ទើដោយការសង្គ្រោះ ១*

អសង្គហិតេន អសង្គហិតំ *ការមិនសង្គ្រោះ មួយអន្ទើដោយការមិនសង្គ្រោះ ១*

សម្បយោគោ វិប្បយោគោ *ការប្រកបព្រម និងការច្រាសចេញ ១*

សម្បយុត្តេន វិប្បយុត្តំ *ការប្រាសចេញ មួយអន្ទើដោយការប្រកបព្រម ១*

វិប្បយុត្តេន សម្បយុត្តំ *ការប្រកបព្រម មួយអន្ទើដោយការប្រាសចេញ ១*

សម្បយុត្តេន សម្បយុត្តំ *ការប្រកបព្រម មួយអន្ទើដោយការសមប្រកប ១*

វិប្បយុត្តេន វិប្បយុត្តំ *ការប្រាសចេញ មួយអន្ទើដោយការប្រាសចេញ ១*

សន្តហិតេន សម្បយុត្តំ វិប្បយុត្តំ *ការប្រកបព្រម និងការប្រាសចេញ មួយអន្ទើដោយការសង្រ្គោះ ១*

សម្បយុត្តេន សន្តហិតំ អសន្តហិតំ *ការសង្រ្គោះ និងការមិនសង្រ្គោះ មួយអន្ទើដោយការប្រកបព្រម ១*

អសន្តហិតេន សម្បយុត្តំ វិប្បយុត្តំ *ការសមប្រកប និងការប្រាសចេញ មួយអន្ទើដោយការមិនសង្រ្គោះ ១*

វិប្បយុត្តេន សន្តហិតំ អសន្តហិតន្តិ *ការសង្រ្គោះ និងការមិនសង្រ្គោះ មួយអន្ទើដោយការប្រាសចេញ ១ ។*

បញ្ចក្ខន្ធា ទ្វាទសាយតនានិ អដ្ឋារសធាតុយោ ចត្តារិ សច្চានិ ពាវីស-តិន្ទ្រិយានិ បដិច្ចសមុប្បាទោ ចត្តារោ សតិប្បដ្ឋានា ចត្តារោ សម្មប្បធានា ចត្តារោ ឥទ្ធិបាទា ចត្តារិ ឈានានិ ចតស្សោ អប្បមញ្ញាយោ បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គា អរិយោ អដ្ឋង្គិកោ មគ្គោ ឆសឡ្យា ផស្សា វេទនា សញ្ញា ចេតនា ចិត្តំ អធិមោក្ខោ មនសិការោ *ខន្ធ ៥ អាយតន: ១២ ធាតុ ១៨ សច្ច: ៤ ឥន្ទ្រិយ ២២ បដិច្ចសមុប្បាទ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឈាន ៤ អប្បមញ្ញា ៤ ឥន្ទ្រិយ ៥ ពល: ៥ ពោជ្ឈង្គ: ៧ មគ្គមានអង្គ ៨ ដ៏ប្រសើរ ផស្ស: វេទនា សញ្ញា*

ចេតនា ចិត្ត អធិមោក្ខ: មនសិការ:។

តីហិ សង្គហោ *ការសង្គ្រោះដោយបទ ៣ (គឺ ខន្ធ ធាតុ អាយតន:)*

តីហិ អសង្គហោ *ការមិនសង្គ្រោះដោយបទ ៣*

ចតូហិ សម្បយោគោ *ការសមប្រកបដោយបទ ៤ គឺ អរូបខន្ធទាំង ៤*

ចតូហិ វិប្បយោគោ *ការប្រាសចាកបទ ៤។*

សនិទស្សនោ *ធម៌មានចំណែកស្មើ*

វិសនិទស្សនោ *ធម៌មានចំណែកមិនស្មើ។*

សព្ពាបិ ធម្មសង្គណិ ធាតុកថាយ *មាតិកាធម្មសង្គ្រណីទាំងអស់ ជាមាតិកានៃធាតុកថា។*

ឆយមាតិកាតិ បញ្ហាវិចេន វិភត្តំ ធាតុកថាបករណំ នាម សមត្តំ *នេះឈ្មោះនយមាតិកា ធាតុកថាបករណ៍ ចែកចេញដោយធម៌ ៥ ប្រការ ចប់តែប៉ុណ្ណោះ។*

បុគ្គលប្បញ្ញត្តិ

(បិដកលេខ ៨៣ ទំព័រ ២១១)

(**តទនន្តរំ បុគ្គលប្បញ្ញត្តិប្បករណំ នាមេសោ** *លំដាប់អំពីធាតុកថាបករណ៍នោះមក យើងនឹងសំដែងនូវបុគ្គលប្បញ្ញត្តិប្បករណ៍ដូចតទៅនេះ)*

ខន្ធប្បញ្ញត្តិ អាយតនប្បញ្ញត្តិ ធាតុប្បញ្ញត្តិ សច្ចប្បញ្ញត្តិ ឥន្ទ្រិយប្បញ្ញត្តិ បុគ្គលប្បញ្ញត្តីតិ *(បញ្ញត្តិ ៦ គឺ) ខន្ធប្បញ្ញត្ត ១ អាយតនប្បញ្ញត្តិ ១ ធាតុប្បញ្ញត្តិ ១*

សច្ចប្បញ្ញត្តិ ១ តន្ទ្រិយប្បញ្ញត្តិ ១ បុគ្គលប្បញ្ញត្តិ ១ សច្ចប្បញ្ញត្តិ ១ តន្ទ្រិយប្បញ្ញត្តិ ១ បុគ្គលប្បញ្ញត្តិ ១ ។

កិត្តាវតា ខន្ធានំ ខន្ធប្បញ្ញត្តិ *ខន្ធប្បញ្ញត្តិរបស់ខន្ធទាំងឡាយមានប៉ុន្មាន*

យាវតា បញ្ចក្ខន្ធា រូបក្ខន្ធោ វេទនាខន្ធោ សញ្ញាខន្ធោ សង្ខារក្ខន្ធោ វិញ្ញាណក្ខន្ធោ ឯត្តាវតា ខន្ធានំ ខន្ធប្បញ្ញត្តិ *ខន្ធ ៥ គឺរូបក្ខន្ធ ១ វេទនាខន្ធ ១ សញ្ញាខន្ធ ១ សង្ខារក្ខន្ធ ១ វិញ្ញាណក្ខន្ធ ១ មានប្រមាណប៉ុនណា ខន្ធប្បញ្ញត្តិរបស់ខន្ធទាំងឡាយ មានប្រមាណប៉ុណ្ណោះ។*

កិត្តាវតា អាយតនានំ អាយតនប្បញ្ញត្តិ *អាយតនប្បញ្ញត្តិរបស់អាយតនៈទាំងឡាយ មានប៉ុន្មាន*

យាវតា ឆ្ឌាធសាយតនានិ ចក្ខាយតនំ រូបាយតនំ សោតាយតនំ សទ្ទាយតនំ ឃានាយតនំ គន្ធាយតនំ ជិវ្ហាយតនំ រសាយតនំ កាយាយតនំ ផោដ្ឋព្ពាយតនំ មនាយតនំ ធម្មាយតនំ ឯត្តាវតា អាយតនានំ អាយតនប្បញ្ញត្តិ *អាយតនៈ ១២ គឺ ចក្ខាយនៈ ១ រូបាយតនៈ ១ សោតាយតនៈ ១ សទ្ទាយតនៈ ១ ឃានាយតនៈ ១ គន្ធាយតនៈ ១ ជិវ្ហាយតនៈ ១ រសាយតនៈ ១ កាយាយតនៈ ១ ផោដ្ឋព្ពាយតនៈ ១ មនាយតនៈ ១ ធម្មាយតនៈ ១ មានប្រមាណប៉ុនណា អាយតនប្បញ្ញត្តិរបស់អាយតនៈទាំងឡាយ មានប្រមាណប៉ុណ្ណោះ។*

កិត្តាវតា ធាតូនំ ធាតុប្បញ្ញត្តិ *ធាតុប្បញ្ញត្តិរបស់ធាតុទាំងឡាយមានប៉ុន្មាន*

យាវតា អដ្ឋារស ធាតុយោ ចក្ខុធាតុ រូបធាតុ ចក្ខុវិញ្ញាណធាតុ សោតធាតុ សទ្ទធាតុ សោតវិញ្ញាណធាតុ ឃានធាតុគន្ធធាតុ ឃានវិញ្ញាណធាតុ ជិវ្ហាធាតុ

រសធាតុ ជិវ្ហាវិញ្ញាណធាតុ កាយធាតុ ផោដ្ឋព្វធាតុ កាយវិញ្ញាណធាតុ មនោធាតុ ធម្មធាតុ មនោវិញ្ញាណធាតុ ឯត្តាវតា ធាតូនំ ធាតុបញ្ញត្តិ *ជាតុ ១៨ គឺចក្ខុជាតុ ១ រូបជាតុ ១ ចក្ខុវិញ្ញាណជាតុ ១ សោតជាតុ ១ សទ្ទជាតុ ១ សោតវិញ្ញាណជាតុ ១ ឃានជាតុ ១ គន្ធជាតុ ១ ឃានវិញ្ញាណជាតុ ១ ជិវ្ហាជាតុ ១ រសជាតុ ១ ជិវ្ហាវិញ្ញាណជាតុ ១ កាយជាតុ ១ ផោដ្ឋព្វជាតុ ១ កាយវិញ្ញាណជាតុ ១ មនោជាតុ ១ ធម្មជាតុ ១ មនោវិញ្ញាណជាតុ ១ មានប្រមាណប៉ុនណា ជាតុបញ្ញត្តិរបស់ជាតុទាំងឡាយ មានប្រមាណប៉ុណ្ណោះ។*

កិត្តាវតា សច្ចានំ សច្ចបញ្ញត្តិ *សច្ចបញ្ញត្តិរបស់សច្ចៈទាំងឡាយ មានប៉ុន្មាន*

យាវតា ចត្តារិ សច្ចានិ ទុក្ខសច្ចំ សមុទយសច្ចំ និរោធសច្ចំ មគ្គសច្ចំ ឯត្តាវតា សច្ចានំ *សច្ចបញ្ញត្តិសច្ចៈ ៤ គឺ ទុក្ខសច្ចៈ ១ សមុទយសច្ចៈ ១ និរោធសច្ចៈ ១ មគ្គសច្ចៈ ១ មានប្រមាណប៉ុនណា សច្ចបញ្ញត្តិរបស់សច្ចៈទាំងឡាយ មានប្រមាណប៉ុណ្ណោះ។*

កិត្តាវតា ឥន្ទ្រិយានំ ឥន្ទ្រិយបញ្ញត្តិ *ឥន្ទ្រិយបញ្ញត្តិរបស់ឥន្ទ្រិយទាំងឡាយ មានប៉ុន្មាន*

យាវតា ពាវីសតិន្ទ្រិយានិ ចក្ខុន្ទ្រិយំ សោតិន្ទ្រិយំ ឃានិន្ទ្រិយំ ជិវ្ហិន្ទ្រិយំ កាយិន្ទ្រិយំ មនិន្ទ្រិយំ ឥត្ថិន្ទ្រិយំ បុរិសិន្ទ្រិយំ ជីវិតិន្ទ្រិយំ សុខិន្ទ្រិយំ ទុក្ខិន្ទ្រិយំ សោមនស្សិន្ទ្រិយំ ទោមនស្សិន្ទ្រិយំ ឧបេក្ខិន្ទ្រិយំ សទ្ធិន្ទ្រិយំ វីរិយិន្ទ្រិយំ សតិន្ទ្រិយំ សមាធិន្ទ្រិយំ បញ្ញិន្ទ្រិយំ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយំ អញ្ញិន្ទ្រិយំ អញ្ញាតា-

ទ្វិន្ទ្រិយំ ឯត្តាវតា ឥន្ទ្រិយានំ ឥន្ទ្រិយប្បញ្ញត្តិ *ឥន្ទ្រិយ ២២ គឺ ចក្ខុន្ទ្រិយ ១ សោតិន្ទ្រិយ ១ ឃានិន្ទ្រិយ ១ ជិវ្ហិន្ទ្រិយ ១ កាយិន្ទ្រិយ ១ មនិន្ទ្រិយ ១ ឥត្ថិន្ទ្រិយ ១ បុរិសិន្ទ្រិយ ១ ជីវិតិន្ទ្រិយ ១ សុខិន្ទ្រិយ ១ ទុក្ខិន្ទ្រិយ ១ សោមនស្សិន្ទ្រិយ ១ ទោមនស្សិន្ទ្រិយ ១ ឧបេក្ខិន្ទ្រិយ ១ សទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១ សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ អនញ្ញតញ្ញស្សាមីតិន្ទ្រិយ ១ អញ្ញិន្ទ្រិយ ១ អញ្ញាតាវិន្ទ្រិយ ១ មានប្រមាណប៉ុនណា ឥន្ទ្រិយប្បញ្ញត្តិ របស់ឥន្ទ្រិយទាំងឡាយ មានប្រមាណប៉ុណ្ណោះ។*

កិត្តាវតា បុគ្គលានំ បុគ្គលប្បញ្ញត្តិ *បុគ្គលប្បញ្ញត្តិរបស់បុគ្គលទាំងឡាយ មានប៉ុន្មាន*

សមយវិមុត្តោ អសមយវិមុត្តោ *បុគ្គលរួចស្រឡះចាកកិលេសតាមកាលគួរ បុគ្គលរួចស្រឡះចាកកិលេសតាមកាលមិនគួរ*

កុប្បធម្មោ អកុប្បធម្មោ *បុគ្គលមានធម៌កម្រើក បុគ្គលមានធម៌មិនកម្រើក*

បរិហានធម្មោ អបរិហានធម្មោ *បុគ្គលមានធម៌សាបសូន្យ បុគ្គលមានធម៌មិនសាបសូន្យ*

ចេតនាភព្វោ អនុរក្ខនាភព្វោ *បុគ្គលគួរដល់នូវសេចក្តីមិនសាបសូន្យដោយចេតនា បុគ្គលគួរដល់នូវសេចក្តីមិនសាបសូន្យដោយការរក្សា*

បុថុជ្ជនោ គោត្រភូ *បុគ្គលជាបុថុជ្ជន បុគ្គលជាគោត្រភូ*

ភយូបរតោ អភយូបរតោ *បុគ្គលវៀរចាកបាបដោយភ័យ បុគ្គលវៀរចាក*

បាបដោយមិនមានភ័យ

ភព្វាគមនោ អភព្វាគមនោ *បុគ្គលគួរដល់កិរិយាមកកាន់សន្ទតនិយាម គឺមគ្គ បុគ្គលមិនគួរដល់កិរិយាមកកាន់សន្ទតនិយាម គឺមគ្គ*

និយតោ អនិយតោ *បុគ្គលទៀង បុគ្គលមិនទៀង*

បដិបន្នកោ ឋលេឋិតោ *បុគ្គលប្រតិបត្តិព្រមព្រៀងដោយមគ្គ បុគ្គលឋិតនៅក្នុងផល*

សមសីសី ឋិតកប្បី *បុគ្គលមានធម៌ជាប្រធានស្មើគ្នា បុគ្គលញុំាងកប្បឱ្យឋិតនៅ*

អរិយោ អនរិយោ *បុគ្គលជាអរិយៈ បុគ្គលមិនមែនជាអរិយៈ*

សេក្ខោ អសេក្ខោ *បុគ្គលជាសេក្ខៈ បុគ្គលជាអសេក្ខៈ*

នេវសេក្ខោ នាសេក្ខោ *បុគ្គលមិនមែនសេក្ខៈ ទាំងមិនមែនអសេក្ខៈ*

តេវិជ្ជោ ឆឡភិញ្ញោ *បុគ្គលមានវិជ្ជា ៣ បុគ្គលមានអភិញ្ញា ៦*

សម្មាសម្ពុទ្ធោ បច្ចេកពុទ្ធោ *បុគ្គលជាព្រះសម្មាសម្ពុទ្ធ បុគ្គលជាព្រះបច្ចេកពុទ្ធ*

ឧភតោភាគវិមុត្តោ បញ្ញាវិមុត្តោ *បុគ្គលរួចស្រឡះចាកកិលេសដោយចំណែកទាំងពីរ បុគ្គលរួចស្រឡះចាកកិលេសដោយបញ្ញា*

កាយសក្ខី ទិដ្ឋិប្បត្តោ *បុគ្គលមានកាយជាបន្ទាល់ បុគ្គលសម្រេចដោយទិដ្ឋិ*

សទ្ធាវិមុត្តោ ធម្មានុសារី *បុគ្គលរួចស្រឡះចាកកិលេសដោយសទ្ធា បុគ្គល*

រឭកតាមធម៌

សទ្ធានុសារី សត្តក្ខត្តុំបរមោ កោលំកោលោ *បុគ្គលរឭកតាមសទ្ធា បុគ្គលត្រូវនៅកើតអស់វារៈ ៧ ដងជាយ៉ាងក្រៃលែង បុគ្គលចេញពីត្រកូលទៅកាន់ត្រកូល*

ឯកពីជី សកទាគាមី *បុគ្គលមានពូជ គឺខន្ធតែម្តង បុគ្គលមកកាន់លោកនេះម្តងទៀត*

អនាគាមី អន្តរាបរិនិព្វាយី *បុគ្គលមិនមកកាន់លោកនេះម្តងទៀត បុគ្គលបរិនិព្វានពាក់កណ្តាលអាយុ*

ឧបហច្চបរិនិព្វាយី អសង្ខារបរិនិព្វាយី *បុគ្គលកន្ទងហួសពាក់កណ្តាលអាយុទើបបរិនិព្វាន បុគ្គលបរិនិព្វានដោយមិនបាច់ព្យាយាមខ្លាំង*

សសង្ខារបរិនិព្វាយី ឧទ្ធំសោតោ អកនិដ្ឋគាមី *បុគ្គលបរិនិព្វានដោយព្យាយាមខ្លាំង បុគ្គលមានខ្សែនៃមគ្គទៅខាងលើដរាបដល់អកនិដ្ឋព្រហ្មហើយ ទើបបរិនិព្វាន*

សោតាបន្នោ សោតាបត្តិផលសច្ឆិកិរិយាយ បដិបន្នោ *បុគ្គលជាសោតាបន្ន ប្រតិបត្តិដើម្បីធ្វើឱ្យជាក់ច្បាស់នូវសោតាបត្តិផល*

សកទាគាមី សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ *បុគ្គលជាសកទាគាមី បុគ្គលប្រតិបត្តិដើម្បីធ្វើឱ្យជាក់ច្បាស់នូវសកទាគាមិផល*

អនាគាមី អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ *បុគ្គលជាអនាគាមី បុគ្គលប្រតិបត្តិដើម្បីធ្វើឱ្យជាក់ច្បាស់នូវអនាគាមិផល*

អរហា អរហត្តផលសច្ឆិកិរិយាយ បដិបន្នោតិ *បុគ្គលជាព្រះអរហន្ត បុគ្គលប្រតិបត្តិដើម្បីធ្វើឱ្យជាក់ច្បាស់នូវអរហត្តផល។*

(**អយំ ខន្ធប្បញ្ញត្តាតិ ឆឝិធេន ឝិតត្តំ បុគ្គលប្បញ្ញត្តិប្បករណំ នាម សមត្តំ** *នេះបញ្ញត្តិ មានខន្ធប្បញ្ញត្តិជាដើម បុគ្គលប្បញ្ញត្តិប្បករណ៍ ចែកចេញដោយបញ្ញត្តិ ៦ ប្រការ ចប់តែប៉ុណ្ណេះ)។*

កថាវត្ថុ

(បិដកលេខ ៨៤ ទំព័រ ១-២)

(**តទនន្តរំ កថាវត្ថុប្បករណំ នាមេតំ** *លំដាប់អំពីបុគ្គលប្បញ្ញត្តិប្បករណ៍នោះមក យើងនឹងស្វាធ្យាយនូវកថាវត្ថុប្បករណ៍ ដូចតទៅនេះ)*

បុគ្គលោ ឧបលព្ភតិ សច្ឆិកដ្ឋបរមដ្ឋេនាតិ *(សកវាទីសួរថា) គេដឹងបានដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ។*

អាមន្តា *(បរវាទីឆ្លើយថា) អើ។*

យោ សច្ឆិកដ្ឋោ បរមដ្ឋោ តតោ សោ បុគ្គលោ ឧបលព្ភតិ សច្ឆិកដ្ឋបរមដ្ឋេនាតិ *(សកវាទីសួរថា) បុគ្គលណា មានអត្ថដ៏ពិត និងអត្ថដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេដឹងបានដោយអត្ថដ៏ពិត និងអត្ថដ៏ឧត្តមឬ។*

ន ហេវំ វត្តព្ពេ *(បរវាទីឆ្លើយថា) អ្នកមិនគួរពោលយ៉ាងនេះទេ។*

អាជានាហិ និគ្គហំ ហញ្ចិ បុគ្គលោ ឧបលព្ភតិ សច្ឆិកដ្ឋបមដ្ឋេន តេន ឧត ឯ ឧ វត្តព្ពេ យោ សច្ឆិកដ្ឋោ បរមដ្ឋោ តតោ សោ បុគ្គលោ ឧបលព្ភតិ

សច្ឆិកដ្ឋបរមដ្ឋេនាតិ *(សកវាទីពោលថា) អ្នកចូរដឹងនូវកំហុសចុះ ប្រសិនបើបុគ្គលគេដឹងបានដោយអត្តដ៏ពិត និងអត្តដ៏ឧត្តម ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គលណា មានអត្តដ៏ពិត មានអត្តដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេដឹងបានដោយអត្តដ៏ពិត និងអត្តដ៏ឧត្តម ដូច្នេះដែរ។*

យំ តត្ថ វទេសិ វត្តព្វេ ខោ បុគ្គលោ ឧបលព្ភតិ សច្ឆិកដ្ឋបរមដ្ឋេនោ ច វត្តព្វេ យោ សច្ឆិកដ្ឋោ បរមដ្ឋោ តតោ សោ បុគ្គលោ ឧបលព្ភតិ សច្ឆិកដ្ឋបរមដ្ឋេនាតិ មិច្ឆា *បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បីពោលតែពាក្យនោះថា បុគ្គលគេដឹងបានដោយអត្តដ៏ពិត និងអត្តដ៏ឧត្តម តែអ្នកមិនគួរពោលថា បុគ្គលណាមានអត្តដ៏ពិតមានអត្តដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេដឹងបានដោយអត្តដ៏ពិត និងអត្តដ៏ឧត្តម ដូច្នេះទេ ព្រោះជាពាក្យខុស។*

នោ ចេ បនវត្តព្វេ យោ សច្ឆិកដ្ឋោ បរមដ្ឋោ តតោ សោ បុគ្គលោ ឧបលព្ភតិ សច្ឆិកដ្ឋបរមដ្ឋេនាតិ នោ វត តេ វត្តព្វេ បុគ្គលោ ឧបលព្ភតិ សច្ឆិកដ្ឋបរមដ្ឋេនាតិ *ម្យ៉ាងទៀត ប្រសិនបើអ្នកមិនគប្បីពោលថា បុគ្គលណា មានអត្តដ៏ពិត មានអត្តដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេដឹងបានដោយអត្តដ៏ពិត និងអត្តដ៏ឧត្តមដូច្នេះទេ ម្នាលអ្នកដ៏ចម្រើន អ្នកក៏មិនគប្បីពោលថា បុគ្គលគេដឹងបានដោយអត្តដ៏ពិត និងអត្តដ៏ឧត្តម ដូច្នេះដែរ។*

យំ តត្ថ វទេសិ វត្តព្វេ ខោ បុគ្គលោ ឧបលព្ភតិ សច្ឆិកដ្ឋបរមដ្ឋេនោ ច វត្តព្វេ យោ សច្ឆិកដ្ឋោ បរមដ្ឋោ តតោ សោបុគ្គលោ ឧបលព្ភតិ សច្ឆិកដ្ឋបរមដ្ឋេនាតិមិច្ឆា *បណ្តាពាក្យទាំងពីរនោះ អ្នកពោលនូវពាក្យណា គប្បី*

ពោលតែពាក្យនោះថា បុគ្គលគេដឹងបានដោយអត្តដ៏ពិត និងអត្តដ៏ឧត្តម តែអ្នកមិនគប្បីពោលថា បុគ្គលណា មានអត្តដ៏ពិត មានអត្តដ៏ឧត្តម ព្រោះហេតុនោះ បុគ្គលនោះ គេដឹងបានដោយអត្តដ៏ពិត និងអត្តដ៏ឧត្តម ដូច្នេះទេ ព្រោះជាពាក្យខុស។

អនុលោមបញ្ហាកំ *ចប់អនុលោមបញ្ហក: ។*

(**សកវាទិបញ្ហាសុត្តសតានិ បរវាទិបញ្ហាសុត្តសតានីតិ សុត្តសហស្សំ សមោធានេត្វាន ឯតត្តំ កថាវត្ថុប្បករណំ នាម សមត្តំ** *កថាវត្ថុប្បករណ៍ ដែលប្រជុំចែកជាមួយពាន់សូត្រ គឺ ៥០០ សូត្ររបស់សកវាទី ៥០០ សូត្ររបស់បរវាទី ចប់តែប៉ុណ្ណោះ ។*

យមក

(បិដកលេខ ៨៧ ទំព័រ ១-៣)

(**តទនន្តរំ យមកប្បករណំ នាមេតំ** *លំដាប់អំពីកថាវត្ថុប្បករណ៍នោះមក យើងនឹងស្វាធ្យាយនូវយមកប្បករណ៍ដូចតទៅនេះ*)

យេ កេចិ កុសលា ធម្មា សព្ពេ តេ កុសលមូលា យេ វា បន កុសលមូលា សព្ពេ តេ ធម្មា កុសលា *ពួកធម៌ណាមួយជាកុសល ពួកធម៌ទាំងអស់នោះ មានកុសលជាមូល ឬក៏ពួកធម៌ណា មានកុសលជាមូល ពួកធម៌ទាំងអស់នោះជាកុសល។*

យេ កេចិ កុសលា ធម្មា សព្វេ តេ កុសលមូលេន ឯកមូលា យេ វា បន កុសលមូលេន ឯកមូលា សព្វេ តេ ធម្មា កុសលា *ពួកធម៌ណាមួយ ជាកុសល ពួកធម៌ទាំងអស់នោះ មានមូលតែមួយដោយកុសលមូល ឬក៏ពួកធម៌ណាមានមូលតែមួយដោយកុសលមូល ពួកធម៌ទាំងអស់នោះជាកុសល។*

យេ កេចិ កុសលមូលេន ឯកមូលា ធម្មា សព្វេ តេ កុសលមូលេន អញ្ញមញ្ញមូលា យេ វា បន កុសលមូលេន អញ្ញមញ្ញមូលា សព្វេ តេ ធម្មា កុសលា *ពួកធម៌ណាមួយមានមូលតែមួយ ដោយកុសលមូល ពួកធម៌ទាំងអស់នោះ មានគ្នានឹងគ្នាជាមូល ដោយកុសលមូល ឬក៏ពួកធម៌ណាមានគ្នានឹងគ្នាជាមូល ដោយកុសលមូល ពួកធម៌ទាំងអស់នោះជាកុសល។*

យេ កេចិ កុសលា ធម្មា សព្វេ តេ កុសលមូលមូលា យេ វា បន កុសលមូលមូលា សព្វេ តេ ធម្មា កុសលា *ពួកធម៌ណាមួយជាកុសល ពួកធម៌ទាំងអស់នោះ មានកុសលជាមូល ឬក៏ពួកធម៌ណា មានកុសលមូលជាមូល ពួកធម៌ទាំងអស់នោះជាកុសល។*

យេ កេចិ កុសលា ធម្មា សព្វេ តេ កុសលមូលេន ឯកមូលមូលា យេ វា បន កុសលមូលេន ឯកមូលមូលា សព្វេ តេ ធម្មា កុសលា *ពួកធម៌ណាមួយជាកុសល ពួកធម៌ទាំងអស់នោះ មានមូលតែមួយជាមូល ដោយកុសលមូល ឬក៏ពួកធម៌ណាមានមូលតែមួយជាមូល ដោយកុសលមូល ពួកធម៌ទាំងអស់នោះជាកុសល។*

យេ កេចិ កុសលមូលេន ឯកមូលមូលា ធម្មា សព្វេ តេ កុសលមូលេន

អញ្ញមញ្ញមូលមូលា យេ វា បន កុសលមូលេន អញ្ញមូលមូលា សព្ពេ តេ ធម្មា *កុសលាពួកធម៌ណាមួយមានមូលតែមួយជាមូល ដោយកុសលមូល ពួកធម៌ទាំងអស់នោះ មានមូលនៃគ្នានឹងគ្នាជាមូល ដោយកុសលមូល ឬក៏ពួកធម៌ណា មានមូលនៃគ្នានឹងគ្នាជាមូល ដោយកុសលមូល ពួកធម៌ទាំងអស់នោះ ជាកុសល។*

យេ កេចិ កុសលា ធម្មា សព្ពេ តេ កុសលមូលកា យេ វា បន កុសលមូលកា សព្ពេ តេ ធម្មា *កុសលាពួកធម៌ណាមួយជាកុសល ពួកធម៌ទាំងអស់នោះ មានកុសលជាមូល ឬក៏ពួកធម៌ណា មានកុសលជាមូល ពួកធម៌ទាំងអស់នោះជាកុសល។*

យេ កេចិ កុសលា ធម្មា សព្ពេ តេ កុសលមូលេន ឯកមូលកា យេ វា បន កុសលមូលេន ឯកមូលកា សព្ពេ តេ ធម្មា កុសលា *ពួកធម៌ណាមួយជាកុសល ពួកធម៌ទាំងអស់នោះ មានមូលតែមួយ ដោយកុសលមូល ឬក៏ពួកធម៌ណាមានមូលតែមួយដោយកុសលមូល ពួកធម៌ទាំងអស់នោះជាកុសល។*

យេ កេចិ កុសលមូលេន ឯកមូលកា ធម្មា សព្ពេ តេ កុសលមូលេន អញ្ញមញ្ញមូលកា យេ វា បន កុសលមូលេន អញ្ញមញ្ញមូលកា សព្ពេ តេ ធម្មា កុសលា *ពួកធម៌ណាមួយមានមូលតែមួយដោយកុសលមូល ពួកធម៌ទាំងអស់នោះ មានគ្នានឹងគ្នាជាមូលដោយកុសលមូល ឬក៏ពួកធម៌ណា មានគ្នានឹងគ្នាជាមូលដោយកុសលមូល ពួកធម៌ទាំងអស់នោះជាកុសល។*

យេ កេចិ កុសលា ធម្មា សព្ពេ តេ កុសលមូលមូលកា យេ វា បន កុសលមូលមូលកា សព្ពេ តេ ធម្មា កុសលា *ពួកធម៌ណាមួយជាកុសល ពួក

ធម៌ទាំងអស់នោះមានកុសលមូលជាមូល ឬក៏ពួកធម៌ណាមានកុសលមូលជាមូល ពួកធម៌ទាំងអស់នោះជាកុសល។

យេ កេចិ កុសលា ធម្មា សព្វេ តេ កុសលមូលេន ឯកមូលមូលកា យេ វា បន កុសលមូលេន ឯកមូលមូលកា សព្វេ តេ ធម្មា កុសលា *ពួកធម៌ណាមួយជាកុសល ពួកធម៌ទាំងអស់នោះមានមូលតែមួយជាមូល ដោយកុសលមូល ឬក៏ពួកធម៌ណាមានមូលតែមួយជាមូលដោយកុសលមូល ពួកធម៌ទាំងអស់នោះជាកុសល។*

យេ កេចិ កុសលមូលេន ឯកមូលមូលកា ធម្មា សព្វេ តេ កុសលមូលេន អញ្ញមញ្ញមូលមូលកា យេ វា បន កុសលមូលេន អញ្ញមញ្ញមូលមូលកា សព្វេ តេ ធម្មា កុសលាតិ *ពួកធម៌ណាមួយមានមូលតែមួយជាមូលដោយកុសលមូល ពួកធម៌ទាំងអស់នោះមានគ្នានឹងគ្នាជាមូលដោយកុសលមូល មួយយ៉ាងទៀត ពួកធម៌ណាមានមូលនៃគ្នានឹងគ្នាជាមូលដោយកុសលមូល ពួកធម៌ទាំងអស់នោះជាកុសល។*

មូលំ ហេតុនិទានញ្ច សម្ភវោ បភវេន ច សមុដ្ឋានាហារារម្មណា បច្ច-យោ សមុទយេន ចាតិ *មូល ហេតុ និទាន សម្ភព ប្រភព សមុដ្ឋាន អាហារ អារម្មណ៍ បច្ច័យ និងសមុទ័យ (ធម៌ទាំងនេះមានក្នុងយមក:)។*

(**មូលយមកាទិ ទសយមកប្បដិមណ្ឌិតំ យមកប្បករណំ មាន សមត្តំ** *យមកប្បករណ៍ដ៏ប្រដាប់ដោយយមក: ១០ មានមូលយមក:ជាដើម ចប់តែប៉ុណ្ណោះ)។*

បដ្ឋាន

(បិដកលេខ ៥៤ ទំព័រ ១)

(**តទនន្តរំ មហាបដ្ឋានប្បករណំ នាមេតំ** *លំដាប់អំពីយមកប្បករណ៍នោះមក យើងនឹងស្វាធ្យាយនូវមហាបដ្ឋានប្បករណ៍ដូចតទៅនេះ*)

ហេតុប្បច្ចយោ អារម្មណប្បច្ចយោ អធិបតិប្បច្ចយោ អនន្តរប្បច្ចយោ សមនន្តរប្បច្ចយោ សហជាតប្បច្ចយោ អញ្ញមញ្ញប្បច្ចយោ និស្សយប្បច្ចយោ ឧបនិស្សយប្បច្ចយោ បុរេជាតប្បច្ចយោ បច្ឆាជាតប្បច្ចយោ អាសេវនប្បច្ចយោ កម្មប្បច្ចយោ វិបាកប្បច្ចយោ អាហារប្បច្ចយោ ឥន្ទ្រិយប្បច្ចយោ ឈានប្បច្ចយោ មគ្គប្បច្ចយោ សម្បយុត្តប្បច្ចយោ វិប្បយុត្តប្បច្ចយោ អត្ថិប្បច្ចយោ នត្ថិប្បច្ចយោ វិគតប្បច្ចយោ អវិគតប្បច្ចយោ (*បច្ច័យ ២៤ គឺ*) *ហេតុបច្ច័យ អារម្មណប្បច្ច័យ អធិបតិប្បច្ច័យ អនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ ឧបនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ បច្ឆាជាតប្បច្ច័យ អាសេវនប្បច្ច័យ កម្មប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ ឈានប្បច្ច័យ មគ្គប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ នត្ថិប្បច្ច័យ វិគតប្បច្ច័យ អវិគតប្បច្ច័យ។* (ទំព័រទី ១)

តិកញ្ច បដ្ឋានវរំ ទុកុត្តមំ ទុកត្តិកញ្ចេវ តិកទុកញ្ច
តិកត្តិកញ្ចេវ ទុកទុកញ្ចាឆ អនុលោមម្ហិ នយា សុគម្ភីរ ៗ

នយទាំង ៦ គឺ តិកប្បដ្ឋានដ៏ប្រសើរ ១ ទុកប្បដ្ឋានដ៏ឧត្តម ១ ទុកត្តិកប្បដ្ឋាន ១ តិកទុកប្បដ្ឋាន ១ តិកត្តិកប្បដ្ឋាន ១ ទុកទុកប្បដ្ឋាន ១ ជានយដ៏ជ្រៅ ក្នុងអនុលោម។ (ទំព័រទី ៣0)

តិកញ្ចា បដ្ឋានវរំ ទុកុត្តមំ ទុកត្តិកញ្ចេវ តិកទុកញ្ចា
តិកត្តិកញ្ចេវ ទុកទុកញ្ចាឆ បច្ចនីយម្ហិ នយា សុគម្ហិ ។

ន័យទាំង ៦ គឺ តិកប្បដ្ឋានដ៏ប្រសើរ ១ ទុកប្បដ្ឋានដ៏ឧត្តម ១ ទុកត្តិកប្បដ្ឋាន ១ តិកទុកប្បដ្ឋាន ១ តិកត្តិកប្បដ្ឋាន ១ ទុកទុកប្បដ្ឋាន ១ ជាន័យដ៏ជ្រៅ ក្នុងបច្ចនីយៈ។ (ទំព័រ ៣១)

តិកញ្ចា បដ្ឋានវរំ ទុកុត្តមំ ទុកត្តិកញ្ចេវ តិកទុកញ្ចា
តិកត្តិកញ្ចេវ ទុកទុកញ្ចា ឆ អនុលោមបច្ចនីយម្ហិ នយា សុគម្ហិ ។

ន័យទាំង ៦ គឺ តិកប្បដ្ឋានដ៏ប្រសើរ ១ ទុកប្បដ្ឋានដ៏ឧត្តម ១ ទុកត្តិកប្បដ្ឋាន ១ តិកទុកប្បដ្ឋាន ១ តិកត្តិកប្បដ្ឋាន ១ ទុកទុកប្បដ្ឋាន ១ ជាន័យដ៏ជ្រៅ ក្នុងអនុលោមបច្ចនីយៈ។ (ទំព័រទី ៣៤)

តិកញ្ចា បដ្ឋានវរំ ទុកុត្តមំ ទុកត្តិកញ្ចេវ តិកទុកញ្ចា
តិកត្តិកញ្ចេវ ទុកទុកញ្ចា ឆ បច្ចនីយានុលោមម្ហិ នយា សុគម្ហិកតិ ។

ន័យទាំង ៦ គឺ តិកប្បដ្ឋានដ៏ប្រសើរ ១ ទុកប្បដ្ឋានដ៏ឧត្តម ១ ទុកត្តិកប្បដ្ឋាន ១ តិកទុកប្បដ្ឋាន ១ តិកត្តិកប្បដ្ឋាន ១ ទុកទុកប្បដ្ឋាន ១ ជាន័យដ៏ជ្រៅ ក្នុងបច្ចនីយានុលោម។ (ទំព័រទី ៣៥)

(**ចតុទីសតិប្បច្ចយវសេន អយំ សមន្តប្បដ្ឋានប្បករណវណ្ណនា និដ្ឋិតា** *វណ្ណនានៃបដ្ឋានប្បករណ៍ជាទីបំផុតនេះ ដោយអំណាចនៃបច្ច័យ ២៤ ចប់ តែប៉ុណ្ណោះ)។*

ចប់ សត្តប្បករណាភិធម្មតែប៉ុណ្ណោះ

ពុទ្ធមន្តពិធី

(វិធីចម្រើនព្រះពុទ្ធមន្ត)

****

សេចក្តីពន្យល់

ពុទ្ធមន្តពិធី *នេះ នៅក្នុងសៀវភៅប្រជុំភាណវារច្បាប់ដើម លោកចែកជា ២ យ៉ាង គឺ* ***សត្តបរិត្ត ១ ទ្វាទសបរិត្ត ១*** *ទាំងដែលនៅក្នុងបរិត្តទាំងពីរនេះក៏មានព្រះសូត្រផងដែរ ដូចជា* ***មង្គលសូត្រ*** *និង* ***ធម្មចក្កប្បវត្តនសូត្រ*** *ជាដើម។ ចាស់បុរាណហៅ* ***សត្តបរិត្ត*** *ថា "**ធម៌សូធ្យមន្តតូច**", **ទ្វាទសបរិត្ត** ថា "**ធម៌សូធ្យមន្តធំ**" ហើយនៅខាងចុងនៃសត្តបរិត្ត ដាក់បកិណ្ណកបរិត្ត និងខាងចុងនៃទ្វាទសបរិត្តដាក់វិធគាថាផង។*

ចំណែកក្នុងភាណវារច្បាប់ថ្មីនេះ ខ្ញុំរៀបដូច្នេះគឺចំណងជើង ចំណងជើងធំឱ្យឈ្មោះថា ***ពុទ្ធមន្ត*** *ហើយចែកជាពីរគឺ* ***ព្រះបរិត្ត ១ ព្រះសូត្រ ១***, *ព្រោះពាក្យថា* ***ពុទ្ធមន្ត*** *សំដៅយកទាំងព្រះបរិត្ត និងព្រះសូត្រ។*

- ***ព្រះបរិត្ត*** *គឺខ្ញុំយកព្រះបរិត្តទាំងអស់ ដែលព្រះអដ្ឋកថាចារ្យជាដើមបានចង្អុលប្រាប់ មកដាក់តែ ១ ក្រុមជាមួយគ្នា តែមិនបានចែកជាសត្តបរិត្ត ឬទ្វាទ-សបរិត្តទេព្រោះគម្ពីរមិនបានប្រាប់, ហើយនៅក្នុងគម្ពីរផ្សេងៗ មានអដ្ឋកថាជាដើមដែលមាននិយាយអំពីព្រះបរិត្តនេះក៏លោកមិនបានប្រាប់ថា មានចំនួនប៉ុន្មានឱ្យប្រាកដដែរ តែដែលរាប់ទៅឃើញមានត្រឹមតែ ៩ ប៉ុណ្ណោះ គ្រាន់តែលោកនិយាយ*

តិច ច្រើនជាងគ្នាប៉ុណ្ណោះ ដូចមានខាងក្រោមនេះគឺ ៖

ចំនួនព្រះបរិត្តក្នុងគម្ពីរផ្សេង ៗ

ក្នុងសុមង្គលវិលាសិនី អដ្ឋកថាទីឃនិកាយ ត្រង់សម្បសាទនីយសូត្រ, មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ ឯកនិបាត ត្រង់អដ្ឋានបាលី និងសម្មោហវិនោទនី អដ្ឋកថាព្រះអភិធម្ម ត្រង់ញាណវិភង្គ មាន ៤ បរិត្ត គឺ:

១- អាជ្ញាធេយ្យបរិត្ត, ២- មោរបរិត្ត, ៣-ធជគ្គបរិត្ត, ៤- រតនបរិត្ត ជាដើម ។

ក្នុងបបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ ឧបរិបណ្ណាសក ត្រង់ពហុធាតុកសូត្រ មាន ៥ បរិត្ត គឺ:

១- អាជ្ញាធេយ្យបរិត្ត, ២- មោរបរិត្ត, ៣- ធជគ្គបរិត្ត, ៤- រតនបរិត្ត, ៥- មេត្តបរិត្ត ជាដើម ។

ក្នុងសទ្ធម្មប្បកាសិនី អដ្ឋកថាបដិសម្ភិទាមគ្គ ត្រង់បុព្វេនិវាសានុស្សតិញ្ញាណនិទ្ទេស, គម្ពីរវិសុទ្ធិមគ្គបាលី ភាគ ២ ទំព័រ ៣៤៧ ត្រង់អភិញ្ញានិទ្ទេស និងសារត្ថទីបនី ដីកាព្រះវិនយ ត្រង់វេរញ្ជកណ្ឌ ពណ៌នាអំពីពុទ្ធគុណ មាន ៥ បរិត្តដែរ តែខុសគ្នា ១ គឺ:

១- រតនបរិត្ត, ២- ខន្ធបរិត្ត, ៣- ធជគ្គបរិត្ត, ៤- អាជ្ញាធេយ្យបរិត្ត, ៥- មេត្តបរិត្ត ។

ក្នុងសមន្តប្បាសាទិកា អដ្ឋកថាព្រះវិនយ ត្រង់វេរញ្ជកណ្ឌ ពណ៌នាអំពីពុទ្ធគុណ មាន ៦ បរិត្ត គឺ:

១- រតនបរិត្ត, ២- មេត្តបរិត្ត, ៣- ខន្ធបរិត្ត, ៤- ធជគ្គបរិត្ត, ៥- អាជ្ញាធេយ្យ-

បរិត្ត, ៦- មោរបរិត្ត ៗ

ក្នុងគម្ពីរមិលិន្ទប្បញ្ហា ត្រង់មច្ចុបាសមុត្តិបញ្ហា មាន ៧ បរិត្ត គឺ:

១- រតនបរិត្ត, ២- មេត្តបរិត្ត, ៣- ខន្ធបរិត្ត, ៤- មោរបរិត្ត, ៥- ធជគ្គបរិត្ត, ៦- អាដានាដិយបរិត្ត, ៧- អង្គុលិមាលបរិត្ត ៗ

ក្នុងមនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ ទុកនិបាត ត្រង់ចូឡនីសូត្រ និង សទ្ទម្មប្បជ្ជោតិកា អដ្ឋកថាមហានិទ្ទេស ត្រង់តុវដកសូត្រ មាន ៨ បរិត្ត គឺ:

១- អាដានាដិយបរិត្ត, ២- ឥសិគិលិបរិត្ត, ៣- ធជគ្គបរិត្ត, ៤- ពោជ្ឈង្គបរិត្ត, ៥- ខន្ធបរិត្ត, ៦- មោរបរិត្ត, ៧- មេត្តបរិត្ត, ៨- រតនបរិត្ត[1] **ៗ**

ដូច្នេះ សរុបគ្រប់គម្ពីរមកឃើញថា ព្រះបរិត្តទាំងអស់មានតែ ៩ ប៉ុណ្ណោះ ដូចដែលបានរៀបរាប់មកហើយខាងលើ ។

ការកើតឡើងនៃព្រះបរិត្ត

ព្រះបរិត្ត *ប្រែថា គ្រឿងឃុំគ្រង រក្សា ការពារ គឺការពារសេចក្តីអន្តរាយ ខាងក្រៅមានចោរ យក្ខ សត្វតិរច្ឆាន និងការពារសេចក្តីអន្តរាយខាងក្នុងមានរោគ ជាដើម អានិសង្សដែលទទួលបានអំពីការសូត្រព្រះបរិត្តនេះកើតមកអំពីអានុភាព របស់ព្រះរតនត្រ័យ និងអានិសង្សនៃការផ្សាយមេត្តា ព្រោះព្រះបរិត្តពោលដល់ គុណរបស់ព្រះរតនត្រ័យ និងការចម្រើនមេត្តាភាវនា ដូច្នេះ អ្នកឧស្សាហ៍ព្យាយាម ស្វាធ្យាយព្រះបរិត្តនឹងបានទទួលផលានិសង្សផ្សេង ៗ ដូចជា ប្រសព្វសិរីសួស្តី*

១-ព្រះបរិត្តទាំង ៩ ខាងលើនេះ ជាព្រះសូត្រផង ជាព្រះបរិត្តផង។

សេចក្តីចម្រើនរុងរឿង បានទទួលជ័យជម្នះ ផុតចាកឧបសគ្គអន្តរាយ មានសុខភាពល្អ និងមានអាយុវែង ដូចមានប្រវត្តិរឿងរ៉ាវក្នុងគម្ពីរជាសាធកៈខាងក្រោមនេះ គឺៈ

រតនបរិត្ត *ក្នុងបរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋ ត្រង់រតនសូត្រ និងធម្មបទដ្ឋកថាភាគទី ៧ ត្រង់រឿងអត្តនោបុព្វកម្ម ថាៈ*

កាលក្រុងវេសាលីកើតភ័យ ៣ ប្រការ គឺ ***ទុព្ភិក្ខភ័យ*** *ភ័យពីការអត់បាយ ពួកមនុស្សក្រៗក៏ស្លាប់ដោយអត់បាយជាច្រើន ចោលសាកសពពាសពេញទីក្រុង ក្លិនបដិកូលនោះនាំឱ្យកើត* ***អហិវាតករោគ*** *រោគភ័យ ពួកអមនុស្សជាច្រើនក៏ចូលទីក្រុងធ្វើអន្តរាយដល់ពួកអ្នកនគរ* ***អមនុស្សភ័យ*** *។ ពួកអ្នកនគរប្រជុំគ្នាកែខៃយ៉ាងណាក៏មិនរំងាប់សោះ ទើបនាំគ្នាទៅអារាធនាព្រះបរមសាស្តាដែលទ្រង់ប្រថាប់នៅឯនគររាជគ្រិះ ។ កាលទ្រង់យាងមកដល់ បានចាត់ព្រះអានន្ទឱ្យទៅរំងាប់ភ័យនោះ ដោយទ្រង់បង្រៀនន្ូវ* ***រតនបរិត្ត*** *ដែលប្រកាសន្ូវគុណព្រះរតនត្រ័យជាទីតាំង។ ព្រះអានន្ទក៏និមន្តសូត្រជុំវិញកំពែងព្រះនគរ ពួកមនុស្សដែលឈឺក៏បានសះស្បើយ ពួកបិសាចក៏រត់ខ្ចាត់ខ្ចាយអស់ ភ័យទាំងប៉ុន្មានក៏បានសូប់រំងាប់ទៅ សិរីសួស្តីក៏កើតដល់អ្នកនគរ។*

មេត្តបរិត្ត *ក្នុងបរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋ ត្រង់ករណីយមេត្តសូត្រ និងធម្មបទដ្ឋកថា ភាគទី ២ ត្រង់រឿងអារទ្ធវិបស្សកភិក្ខុ ថាៈ*

កាលព្រះសាស្តាទ្រង់គង់ក្នុងវត្តជេតពន មានភិក្ខុចំនួន ៥០០ រូប បានរៀន

យកនូវកម្មដ្ឋានក្នុងសម្ងាក់ព្រះសាស្តា ហើយក៏នាំគ្នានិមន្តទៅបដិបត្តិកម្មដ្ឋានក្នុងព្រៃមួយ ។ ក្នុងព្រៃនោះឯងមានពួកអមនុស្សដែលជាមិច្ឆាទិដ្ឋិអាស្រ័យនៅ ព្រោះខ្លួនជាអ្នកមិនមានសទ្ធាក្នុងព្រះពុទ្ធសាសនា ក៏មានគំនិតអកុសលកើតឡើងថា ពួកភិក្ខុទាំងនេះមករំខានដល់ខ្លួន ហើយក៏បន្ទាចដោយបណ្តាលឱ្យឃើញនូវរូបឮនូវសំឡេងប្លែក ។ ដែលគួរឱ្យរន្ធត់តក់ស្លុត និងឱ្យធុំក្លិនស្អុយផ្សេងៗ ។ ពួកភិក្ខុទាំងនោះមិនអាចទ្រាំនៅតទៅទៀតបានក៏នាំគ្នាត្រឡប់ទៅកាន់វត្តវិញ ហើយបានក្រាបទូលរឿងរ៉ាវនោះចំពោះព្រះសាស្តា ។ ទ្រង់ពិចារណាដោយព្រះញាណសព្វគ្រប់ក៏មិនឃើញមានទីកន្លែងដទៃណាដែលសមគួរដល់ភិក្ខុទាំងនោះ ក្រៅអំពីព្រៃនោះឡើយ។ គ្រានោះព្រះសាស្តាទ្រង់ណែនាំភិក្ខុទាំងនោះឱ្យត្រឡប់ទៅទីនោះវិញ ដោយទ្រង់បានបង្រៀននូវ**មេត្តបរិត្ត**សម្រាប់ផ្សាយមេត្តាចិត្តដល់សព្វសត្វ និងដើម្បីជាគ្រឿងរក្សាការពារខ្លួនដល់ភិក្ខុទាំងនោះផង ។ កាលពួកលោកនិមន្តទៅដល់ហើយបានផ្សាយមេត្តាចិត្តដល់សព្វសត្វក្នុងទីនោះ និងសូត្រមេត្តបរិត្តនោះ ធ្វើឱ្យពួកអមនុស្សទាំងនោះមានចិត្តទោរទន់រីករាយមករក ថែមទាំងជួយរក្សាការពារដោយយកចិត្តទុកដាក់ទៀតផង ជាហេតុធ្វើឱ្យពួកលោកនៅជាសុខរហូតដល់បានសម្រេចមគ្គផលក្នុងទីនោះទៀតផង ។ល។

ខន្ធបរិត្ត ក្នុងវិនយបិដក លេខ ១០ ទំព័រ ១៣៩ ត្រង់ខុទ្ទកវត្ថុក្ខន្ធក: និង សុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត លេខ ៦២ ទំព័រ ១៧៧ ត្រង់អហិរាជសូត្រ ថា:

សម័យនោះឯង ភិក្ខុ ១ រូបត្រូវពស់ចឹក ហើយក៏ស្លាប់ទៅ ។ ភិក្ខុទាំងឡាយ

ក្រាបទូលសេចក្តីនោះចំពោះព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បានជាដូច្នោះ ព្រោះភិក្ខុនោះមិនបានផ្សាយមេត្តាចិត្តទៅកាន់ត្រកូលស្តេចពស់ទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុនោះបានផ្សាយមេត្តាចិត្តទៅកាន់ត្រកូលស្តេចពស់ទាំង ៤ ភិក្ខុនោះ បើទុកជាពស់ចឹកក៏មិនស្លាប់ទេ។ ហើយក៏ទ្រង់បង្រៀននូវ**ខន្ធបរិត្ត** ដើម្បីឱ្យភិក្ខុផ្សាយមេត្តាចិត្តចំពោះត្រកូលស្តេចពស់ទាំង ៤ និងដល់សព្វសត្វទាំងអស់ ដើម្បីគ្រប់គ្រងខ្លួន រក្សាខ្លួន ការពារខ្លួន។

ចំណែកក្នុងអដ្ឋកថាជាតកត្រង់ខន្ធបរិត្តជាតកថា កាលភិក្ខុនោះត្រូវពស់ចឹក ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយតថាគតធ្លាប់បានបង្រៀន**ខន្ធបរិត្ត** នេះកាលនៅជាពោធិសត្ត គឺកាលសោយព្រះជាតិជាតាបសនៅក្នុងព្រៃហេមពាន្ត ជាមួយពួកតាបសជាច្រើននាក់ ។ ទើបព្រះពោធិសត្តចង់ជាមន្តគាថាបង្រៀនពួកតាបសទាំងឡាយ ដើម្បីសូធ្យការពារខ្លួន។

មោរបរិត្ត ក្នុងអដ្ឋកថាជាតក ត្រង់មោរជាតកថា:

*កាលណោះ ព្រះពោធិសត្តសោយព្រះជាតិជាសត្វក្អែក មានពណ៌ដូចជាមាស រស់នៅលើភ្នំទណ្ឌកហិរញ្ញបព៌តក្នុងព្រៃហេមពាន្ត។ ជាប្រក្រតីមុននឹងចេញទៅស្វែងរកអាហារ ព្រះពោធិសត្តតែងតែក្រោកអំពីព្រឹក សំឡឹងមើលព្រះអាទិត្យដែលកំពុងរះឡើង ហើយក៏រាយមន្តស្វាធ្យាយពីរគាថាដំបូងថា **ឧទេតយញ្ច** ជាដើមដែលជាការនមស្ការចំពោះទេវបុត្រដែលអាស្រ័យនឹងព្រះអាទិត្យផង ព្រះពុទ្ធទាំងឡាយផង ព្រះពោធិញ្ញាណ និងវិមុត្តិធម៌របស់ព្រះពុទ្ធគ្រប់ព្រះអង្គផង ដើម្បី*

ជាគ្រឿងរក្សាការពារខ្លួនឱ្យនៅជាសុខអស់ ១ ថ្ងៃនោះ ទើបត្រាច់ទៅស្វែងរកអាហារ។ កាលត្រឡប់មកពីរកអាហារវិញក្នុងវេលាល្ងាច ព្រះអាទិត្យទៀបអស្តង្គត ក៏សំឡឹងមើលព្រះអាទិត្យ ហើយរាយមន្តស្វាធ្យាយពីរគាថាក្រោយថា **អបេតយញ្ញ** ជាដើម ដើម្បីជាគ្រឿងរក្សាការពារខ្លួនឱ្យនៅជាសុខអស់ ១ យប់នោះ។ ក្លោកពោធិសត្តក៏រួចផុតពីអន្តរាយគ្រប់យ៉ាង ទោះជាជាន់អន្ទាក់ក៏អន្ទាក់មិនភ្ជាត់ដែរ ដោយអានុភាពនៃមន្តគាថានោះ។ល។

ឆជ្ជន្តិបរិត្ត ក្នុងឆជគ្គសូត្រ សំយុត្តនិកាយ សគាថវគ្គ បិដកលេខ ៣០ ទំព័រ ២៤៣ ព្រះអង្គទ្រង់ប្រារព្ធនូវចម្បាំងរបស់ពួកទេវតាឋានតាវត្តិង្ស និងពួកអសុរដែលធ្វើសង្គ្រាមជាមួយគ្នា។ ពេលនោះ ស្តេចសក្កទេវរាជបានហៅពួកទេវតាទាំងឡាយមកប្រាប់ថា “បើសេចក្តីខ្លាច សេចក្តីរន្ធត់ ឬសេចក្តីព្រឺរោមកើតឡើងដល់ពួកទេវតាដែលទៅហើយកាន់សង្គ្រាមក្នុងកាលណា អ្នកទាំងឡាយគប្បីក្រឡេកមើលនូវចុងទង់ជ័យរបស់យើងក្នុងកាលនោះកុំខានឡើយ។ ព្រោះថា កាលបើអ្នកទាំងឡាយក្រឡេកមើលនូវចុងទង់ជ័យរបស់យើងហើយ សេចក្តីខ្លាចជាដើមនោះនឹងសូប់រំងាប់ទៅបាន”។ តែព្រះមានព្រះភាគត្រាស់ថា ការធ្វើយ៉ាងនោះ សេចក្តីខ្លាចជាដើមនោះ អាចសូប់រំងាប់បានខ្លះ មិនបានខ្លះ ព្រោះថា សក្កទេវរាជនោះ ជាអ្នកនៅមានរាគៈ ទោសៈ មោហៈនៅឡើយ។ ឯចំណែកខាងតថាគតវិញ ពោលយ៉ាងនេះថា « បើអ្នកទាំងឡាយនៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី កាលបើសេចក្តីខ្លាចជាដើមនោះ កើតឡើងក្នុងសម័យណា អ្នកទាំង-

ឡាយគប្បីវព្ទកនូវព្រះពុទ្ធថា “**ឥតិ បិសោ ភគវា** ...” ដូច្នេះក៏បាន ឬវព្ទកនូវព្រះធម៌ថា “**স্বাক্খাতো ভគវតা ধম্মো** ...” ដូច្នេះក៏បាន ឬក៏វព្ទកនូវព្រះសង្ឃថា “**সুপটিপন্নো ভគবতো সাবকসঙ্ঘো**...” ដូច្នេះក៏បាន ។ ព្រោះថា កាលបើអ្នកទាំងឡាយវព្ទកនូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃយ៉ាងនេះ សេចក្តីខ្លាចជាដើមនោះនឹងស្ងប់រំងាប់ទៅបាន ។ ព្រោះព្រះពុទ្ធ មានរាគៈ ទោសៈ មោហៈទៅប្រាសហើយ ឥតមានសេចក្តីខ្លាច សេចក្តីរន្ធត់ សេចក្តីស្ងុត មិនមានកិរិយារត់ទៅជាប្រក្រតីឡើយ, ព្រោះព្រះធម៌ ជាធម៌អាចដឹកនាំសត្វឱ្យចេញចាកសង្សារវដ្តបាន, ព្រះសង្ឃជាបុញ្ញក្ខេត្តនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន »។

ក្នុងអដ្ឋកថាលោកប្រាប់ថា បុគ្គលអ្នកវព្ទកដល់ព្រះបរិត្តនេះ រមែងរួចផុតពីទុក្ខ មានយក្ខភ័យ និងចោរភ័យជាដើមរាប់ចំនួនមិនអស់។ មែនពិត អ្នកមានចិត្តជ្រះថ្លាហើយវព្ទកដល់ព្រះបរិត្តនេះ រមែងបាននូវទីពឹងសូម្បីក្នុងអាកាស ។ សេចក្តីនេះ មានរឿងដូច្នេះ ។

បានឮមកថា កាលគេកំពុងលាបកំបោរសលើទីឃរាបិចេតិយ បុរសកម្លោះម្នាក់ធ្លាក់អំពីជើងវេទិកាជាន់លើ មកក្នុងប្រហោងព្រះចេតិយ ។ ភិក្ខុសង្ឃឈរនៅខាងក្រោម ក៏ប្រាប់ថា “**ចូរអ្នកវព្ទកដល់ធជគ្គបរិត្តចុះ**” ។ គេរន្ធត់ចិត្តភ័យខ្លាចស្ងាប់ ទើបផ្ចង់ស្មារតីទៅរកគុណព្រះពុទ្ធ ហើយពោលថា “***ធជគ្គបរិត្តំ មំ រក្ខតុ សូមធជគ្គបរិត្តរក្សានូវខ្ញុំ***” ខណៈនោះ ឥដ្ឋ ២ ដុំចេញពីប្រហោងចេតិយតាំងជាជណ្តើរឱ្យគេបានក្លាម ។ មនុស្សទាំងឡាយក៏ដាក់ជណ្តើរវល្ងិដែលនៅខាងលើ

ឯតដ្ឋនោះក៏តាំងនៅដូចដើមវិញ។

អាដានាដិយបរិត្ត ក្នុងសុត្តន្តបិដក ទីឃនិកាយ លេខ ១៩ ទំព័រ ៩៤ សម្តែងថា: សម័យមួយព្រះមានព្រះភាគទ្រង់គង់លើភ្នំគិជ្ឈកូដជិតក្រុងរាជគ្រឹះ។ កាលរាត្រីបឋមយាមកន្លងទៅហើយ ស្តេចធំទាំង ៤ គឺព្រះបាទធតរដ្ឋ: ជាស្តេចនៃពួកគន្ធព្វ ១ ព្រះបាទវិរុឡ្ហក: ជាស្តេចនៃពួកកុម្ភណ្ឌ ១ ព្រះបាទកុវេរ: ឬវេស្សវ័ណជាស្តេចនៃពួកយក្ខ ១ ព្រះបាទវិរូបក្ខ: ជាស្តេចនៃពួកនាគ ១ បាននាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ។ ហើយបានក្រាបបង្គំទូលដូច្នេះថា "បពិត្រព្រះអង្គដ៏ចម្រើន ពួកយក្ខជាន់ខ្ពស់ ពួកយក្ខជាន់ទាប និងពួកយក្ខជាន់កណ្តាល ជ្រះថ្លាចំពោះព្រះអង្គក៏មាន មិនជ្រះថ្លាក្នុងព្រះអង្គក៏មាន។ ឯពួកយក្ខដែលមិនជ្រះថ្លានោះច្រើនណាស់ ព្រោះថា ព្រះអង្គទ្រង់សម្តែងធម៌ដើម្បីឱ្យវៀរចាកបាណាតិបាត អទិន្នាទាន កាមេសុមិច្ឆាចារ មុសាវាទ វៀរចាកការផឹកទឹកស្រវឹង។ ចំណែកខាងយក្ខទាំងឡាយច្រើនតែមិនវៀរចាកសោះ បពិត្រព្រះអង្គដ៏ចម្រើន ពួកសាវ័ករបស់ព្រះអង្គ អាស្រ័យនៅសេនាសនៈស្ងាត់ ដែលនៅក្នុងព្រៃជាទីគួរដល់ការលាក់ខ្លួនពួនអាត្មាបាន ពួកយក្ខជាន់ខ្ពស់តែងនៅជានិច្ចក្នុងព្រៃនោះ មិនជ្រះថ្លាក៏មានព្រោះហេតុនោះ សូមព្រះអង្គបង្រៀនទូវ**ព្រះបរិត្តសម្រាប់រក្សាក្នុងនគរ ឈ្មោះអាដានាដា** ដល់ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ដើម្បីការគ្រប់គ្រងរក្សា ដើម្បីមិនបៀតបៀនគ្នា ដើម្បីនៅសប្បាយ"។ ការរក្សាជាប់ទាក់ទងក្នុងអាដានាដានគរនេះដែលបុគ្គលណាមួយ ទោះបីភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិការៀនដោយប្រពៃ រៀន

ដោយសព្វគ្រប់ ជម្រះអត្ត និងព្យញ្ជនៈឱ្យបរិបូណ៌ បើអមនុស្ស ទោះបីជាយក្ខក្តី គន្ធព្វក្តី កុម្ភណ្ឌក្តី នាគក្តី ដែលជាអ្នកមានចិត្តប្រទុស្តនូវបុគ្គលនោះ ហើយដើរតាមក្តី ឈរជិតក្តី អង្គុយជិតក្តី ដេកជិតក្តី អមនុស្សទាំងនោះនឹងត្រូវពួកសេនាបតីជាដើមធ្វើទណ្ឌកម្មដោយប្រការផ្សេងៗ។

លុះរាត្រីនោះកន្ទងទៅហើយ ព្រះមានព្រះភាគទ្រង់ហៅភិក្ខុទាំងឡាយមកប្រាប់រឿងព័រនោះទាំងអស់ ហើយក៏ទ្រង់ត្រាស់ថា “***ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទាំងឡាយរៀនព្រះបរិត្តសម្រាប់រក្សាក្នុងអាដានាដានគរ អ្នកទាំងឡាយចូរទន្ទេញឱ្យចាំស្ទាត់ ចូរចងចាំទុក។ ម្នាលភិក្ខុទាំងឡាយ ការរក្សាក្នុងអាដានាដានគរនេះ ប្រកបដោយប្រយោជន៍ ប្រព្រឹត្តទៅដើម្បីគ្រប់គ្រងរក្សា ដើម្បីមិនបៀតបៀន ដើម្បីនៅជាសុខដល់ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា***”។

វិធីសូត្រអាដានាដិយបរិត្ត

ក្នុងអដ្ឋកថា លោកប្រាប់ពីវិធីសម្រាប់សូត្រ ឱ្អកដែលមានអមនុស្សចូលដូច្នេះថា:

តាមដែលពិត មិនគួរសូត្រអាដានាដិយបរិត្តមុនតែម្តងទេ។ គួរសូត្រព្រះសូត្រទាំងនេះ គឺ ***មេត្តសូត្រ ធជគ្គសូត្រ រតនសូត្រ*** រហូតអស់ ៧ ថ្ងៃសិន។ បើ (អមនុស្ស) ចេញជាការល្អ។ តែបើមិនចេញទេ ទើបគួរសូត្រអាដានាដិយបរិត្ត។ ក៏ភិក្ខុអ្នកសូត្រអាដានាដិយបរិត្តនោះ មិនគួរធាន់ម្សៅ ឬសាច់ មិនគួរនៅក្នុងព្រៃស្មសាន (ព្រៃខ្មោច) ទេ។

សួរថា ព្រោះហេតុអ្វី។ ឆ្លើយថា ពួកអមនុស្សនឹងបានឱកាស។ ឯកន្លែងសូត្រ ព្រះបរិត្ត គួរធ្វើឱ្យមានពណ៌ខៀវ ក្រាលអាសនៈឱ្យរៀបរយក្នុងទីនោះ ហើយគប្បីអង្គុយ។

*ជនទាំងឡាយ កាលនិមន្តភិក្ខុអ្នកសូត្រព្រះបរិត្តពីវត្តទៅកាន់ផ្ទះ គួរឡោម-ព័ទ្ធលោកដោយគ្រឿងការពារ មានខែល និងអាវុធ ហើយគប្បីនាំទៅ។ មិនគួរអង្គុយសូត្រក្នុងទីវាលស្រឡះឡើយ។ ភិក្ខុគួរបិទទ្វារ និងបង្អួច ហើយទើបអង្គុយហែហមដោយដៃជាអាវុធ ធ្វើមេត្តាចិត្តជាមុនហើយសឹមសូត្រ។ គួរឱ្យអ្នកដែលអមនុស្សចូលនោះទទួលសិក្ខាបទជាមុន ហើយសឹមសូត្រព្រះបរិត្តដល់អ្នកដែលតាំងនៅក្នុងសីល។ សូម្បីយ៉ាងនេះក៏នៅតែមិនចេញ គួរនាំគេទៅកាន់វត្ត ឱ្យដេកលើទីលានព្រះចេតិយ ឱ្យធ្វើអាសនៈបូជា អុជប្រទីប បោសសម្អាតលានព្រះចេតិ-យ ហើយសូត្រ**មង្គលកថា**។ គួរប្រកាសឱ្យប្រជុំទាំងអស់។ គួរប្រកាសទៅក្នុងទីដែលមានដើមឈើធំជាងគេនៅជិតវិហារនោះថា ពួកភិក្ខុរមែងរង់ចាំការមករបស់ពួកលោក។ ការដែលមិនមកក្នុងទីប្រជុំទាំងអស់នឹងមិនបាន។ បន្ទាប់ពីនោះ គួរសួរអ្នកដែលត្រូវអមនុស្សចូលថា អ្នកឈ្មោះអ្វី។ កាលគេប្រាប់ឈ្មោះហើយ គួរហៅឈ្មោះតែម្តង។ អ្នកគួរដោះលែងបុគ្គលឈ្មោះនេះ ព្រោះចំណែកបុណ្យក្នុងការបូជាដោយផ្កាកម្រង និងគ្រឿងក្រអូបជាដើម ចំណែកបុណ្យក្នុងការបូជាអាសនៈ ចំណែកក្នុងការប្រគេនបិណ្ឌបាតរបស់គេ ពួកភិក្ខុសូត្រមហាមង្គលកថាដើម្បីប្រយោជន៍ដល់បណ្ណាការរបស់គេ, ដោយសេចក្តីគោរពក្នុងពួកភិក្ខុ អ្នកចូរ*

ដោះលែងគេចុះ ដូច្នេះ បើអមនុស្សមិនដោះលែង គួរប្រាប់ដល់ទេវតាទាំងឡាយ ថា ពួកលោកចូរដឹងចុះ អមនុស្សនេះមិនធ្វើតាមពាក្យរបស់ពួកយើងៗ នឹងធ្វើពុទ្ធ-អាជ្ញាដូច្នេះ គួរសូធ្យព្រះបរិត្តចុះ នេះជាបរិកម្មរបស់គ្រហស្ថមុន។

តែប្រសិនបើភិក្ខុត្រូវអមនុស្សចូលវិញ គួរសម្អាតអាសនៈហើយប្រកាស ឱ្យប្រជុំគ្នាទាំងអស់ ឱ្យចំណែកបុណ្យក្នុងការបូជាដោយផ្កាកម្រង និងគ្រឿងក្រអូប ជាដើម ហើយគប្បីសូធ្យនូវព្រះបរិត្ត នេះជាបរិកម្មរបស់ភិក្ខុទាំងឡាយ។

អង្គុលិមាលបរិត្ត គឺព្រះបរិត្តដែលជាសច្ចវាចារបស់ភិក្ខុអង្គុលិមាលត្ថេរ ។ មាននិទានក្នុងអង្គុលិមាលសូត្រ បិដកលេខ ២៤ ទំព័រ ៤៣០ ថា:

កាលលោកចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី បានជួបនឹងស្ត្រីម្នាក់ដែលកំពុងតែលំបាកព្រោះការប្រសូតកូន ក៏កើតសេចក្តីករុណាគឺការអាណិតចំពោះស្ត្រីនោះដ៏ក្រៃលែង ។ លុះលោកត្រឡប់មកវត្តវិញ ក៏ក្រាបបង្គំទូលរឿងនុ៎ះចំពោះព្រះមានព្រះភាគ ព្រះអង្គក៏ទ្រង់ណែនាំឱ្យលោកទៅពោលនូវសច្ចវាចា ដើម្បីឱ្យកើតសិរីសួស្តីដល់នាងផង ដល់គភ៌ផង ។ កាលលោកនិមន្តទៅដល់ គង់លើតាំងសម្រាប់អង្គុយ ហើយបានពោលនូវសច្ចៈនេះ ភ្លាមនោះឯង នាងក៏ប្រសូតកូនដោយសិរីសួស្តី គឺមិនមានសេចក្តីលំបាកឈឺចាប់អ្វីតិចតួចឡើយ។

ព្រះអដ្ឋកថាលោកប្រាប់ថា “ព្រះបរិត្តនេះឯងឈ្មោះថា **មហាបរិត្ត** នឹងមិនមានអន្តរាយណាៗ មកទម្លាយបានឡើយ ។ ឯតាំងដែលលោកគង់សូធ្យព្រះបរិត្តនោះក៏ក្លាយទៅជាតាំងដ៏ស័ក្តសិទ្ធិ ប្រសិនបើស្ត្រីណាសម្រាលកូនមិនរួច ហើយនាំ

យកទៅឱ្យដេកត្រង់តាំងនោះក៏ប្រសូតបានដោយស្រួល ឬពុំនោះទេដោយគ្រាន់តែយកទឹកលាងតាំងនោះទៅស្រោច ឬប្រោះលើក្បាលក៏បានដែរ។ បានឮថា ព្រះបរិត្តនេះមានបាដិហារិយ៍តាំងនៅរហូតអស់កប្ប"។

ពោជ្ឈង្គបរិត្ត គឺជាព្រះបរិត្តដែលពោលអំពីពោជ្ឈង្គ (អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង) ហើយអាងទៅលើសច្ចវាចានោះមកគ្រប់គ្រងថែរក្សា ឱ្យបានជាសះ-ស្បើយពីជំងឺ និងរក្សាឱ្យមានសិរីសួស្តី។ មានប្រវត្តិថា សម័យមួយ ព្រះពុទ្ធជា-ម្ចាស់គង់នៅក្នុងវត្តវេឡុវ័ននាក្រុងរាជគ្រឹះ។ ព្រះមហាកស្សបត្ថេរមានអាពាធធ្ងន់ត្រង់ណ្ហាងបិបួលិគុហា ព្រះពុទ្ធជាម្ចាស់ព្រះអង្គទ្រង់យាងទៅសួរសុខទុក្ខ ហើយក៏ត្រាស់សម្តែងនូវពោជ្ឈង្គទាំង ៧។

ព្រះអដ្ឋកថាបានប្រាប់ថា "កាលព្រះមហាកស្សប:កំពុងស្តាប់ក៏កើតបីតិរីករាយថា ពោជ្ឈង្គ:នេះធ្លាប់ប្រាកដដល់អាត្មាអញក្នុងខណ:ចាក់ធ្លុះនូវសច្ចធម៌ក្រោយអំពីបួសបាន ៧ ថ្ងៃម្ទេះ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ នាំសត្វឱ្យរួចផុតចាកទុក្ខពិតមែន។ កាលព្រះថេរ:ត្រិះរិះយ៉ាងនេះ ក៏កើតបីតិរីករាយចិត្ត ធ្វើឱ្យឈាមក្នុងកាយ និងរូបធម៌ជាដើមផូរផង់។ រោគរបស់លោក ក៏ជាសះស្បើយភ្លាមប្រៀបដូចតំណក់ទឹករអិលធ្លាក់ចេញអំពីស្លឹកឈូកដូច្នោះឯង"។

ក្រៅអំពីព្រះមហាកស្សប: ព្រះពុទ្ធអង្គក៏ទ្រង់បានត្រាស់ពោជ្ឈង្គនេះដល់ព្រះមហាមោគ្គល្លានដែលមានអាពាធនៅឯភ្នំគិជ្ឈកូដទៀតផង។ គ្រាកាលព្រះមហាមោគ្គល្លានស្តាប់នូវពោជ្ឈង្គ:នេះចប់ ក៏ជាសះស្បើយពីអាពាធភ្លាមតែម្តង។

ម្យ៉ាងទៀត ពេលមួយនោះ ព្រះពុទ្ធជាម្ចាស់គង់នៅក្នុងវត្តវេឡុវ័ន ព្រះអង្គទ្រង់មានអាពាធធ្ងន់ ទើបទ្រង់ប្រើឱ្យព្រះបុន្នត្ថេរសម្តែងពោជ្ឈង្គនេះ។ លុះព្រះអង្គទ្រង់ស្តាប់ពោជ្ឈង្គៈនេះហើយព្រះអង្គក៏ជាសះស្បើយពីអាពាធនោះដែរ ។ល។

ពោជ្ឈង្គៈនេះ ព្រះអង្គត្រាស់ទុកជាបទវាយ មានប្រាកដក្នុងបឋមគិលានសូត្រ ទុតិយគិលានសូត្រ និងតតិយគិលានសូត្រ បិដកលេខ ៣៧ ទំព័រ ២០៥-២១១ ។ ចំណែកពោជ្ឈង្គបរិត្តបច្ចុប្បន្ន ជាបែបគាថាដែលព្រះថេរៈនៅសីហឡៈប្រព័ន្ធឡើងដោយនាំខសេចក្តីមកពីព្រះសូត្រដែលព្រះពុទ្ធទ្រង់សម្តែងទុកហើយ។

ឥសិគិលិបរិត្ត *គឺជាព្រះបរិត្តដែលព្រះមានព្រះភាគត្រាស់អំពីប្រវត្តិរបស់ភ្នំឥសិគិលិ, ព្រះនាមរបស់ព្រះបច្ចេកពុទ្ធទាំង ៥០០ អង្គជាបុត្តរបស់ព្រះនាងបទុមវតី និងទ្រង់សម្តែងអំពីគុណសម្បត្តិរបស់ព្រះបច្ចេកពុទ្ធទាំងនោះ ប្រាប់ដល់កិក្ខុទាំងឡាយ ។ ហើយនៅខាងចុងនៃព្រះបរិត្តនេះ ព្រះសាស្តាព្រះអង្គត្រាស់ថា "អ្នកទាំងឡាយចូរថ្វាយបង្គំនូវព្រះបច្ចេកពុទ្ធទាំងឡាយនោះដែលកន្ធងនូវកិលេសជាគ្រឿងជាប់ជំពាក់ទាំងពួង ស្វែងរកនូវគុណដ៏ប្រសើរ មានគុណរកប្រមាណមិនបានដែលបរិនិព្វានទៅហើយ" ។* (បិដកលេខ ២៦ ទំព័រ ៣២៨)

អត្ថរបស់អ្នកសូធ្យ និងអ្នកស្តាប់

អ្នកសិក្សាគប្បីជ្រាបថា ព្រះបរិត្តដែលនឹងអាចមានអានុភាពច្រើនដូចដែលបានរៀបរាប់មកខាងលើនោះ លុះណាតែអ្នកសូធ្យរៀនូវវិបត្តិហើយប្រកបដោយ

សម្បត្តិតាមដែលលោកបានសម្តែងទុកក្នុងអដ្ឋកថានៃអាដានាដិយសូត្រថា:

អត្តម្បិ ចាឡិម្បិ ទិសំវាទេត្វា សព្វសោ ទា បន អប្បគុណំ កត្វា តណ្ហង្គស្ស ហិ បរិត្តំ តេជវន្តំ ន ហោតិ ។ សព្វសោ បគុណំ កត្វា តណ្ហង្គ-ស្សេវ តេជវន្តំ ហោតិ ។

មែនពិត ព្រះបរិត្តរមែងមិនមានតេជៈដល់អ្នកដែលសូត្រខុសអត្ថខ្លះ បាលីខ្លះ ឬថាមិនធ្វើឱ្យស្ទាត់ជំនាញដោយប្រការទាំងពួង ។ តែថាព្រះបរិត្តរមែងមានតេជៈដល់អ្នកដែលធ្វើឱ្យស្ទាត់ជំនាញដោយប្រការទាំងពួង ហើយសូត្រដោយពិតប្រាកដប៉ុណ្ណោះ។

លាភហេតុ ទុគ្គហេត្វា តណ្ហង្គស្សាបិ អត្តំ ន សាធេតិ, និស្សរណបក្ខេ ឋត្វា មេត្តំ បុរេចារិកំ កត្វា តណ្ហង្គស្សេវ អត្ថាយ ហោតីតិ ឧស្សេតិ ។

សូម្បីកាលរៀនព្រោះលាភជាហេតុហើយសូត្រក៏មិនសម្រេចប្រយោជន៍, ព្រះបរិត្ត រមែងមានប្រយោជន៍ដល់អ្នកដែលតាំងនៅក្នុងចំណែកនៃការចេញចាកទុក្ខ ហើយសូត្រដោយធ្វើមេត្តាឱ្យជាប្រធានទុំៈឯង[1]។

ចំណែកខាងអ្នកស្តាប់ ត្រូវប្រកបដោយអង្គ ៣ គឺៈ

១-អកម្ហាវរណេន *មិនមានកម្មជាគ្រឿងរារាំង (មិនធ្លាប់ធ្វើអនន្តរិយកម្ម ទាំង ៥ ណាមួយ),*

២-អកិលេសាវរណេន *មិនមានកិលេសជាគ្រឿងរារាំង (មិនមានមិច្ឆាទិដ្ឋិ យល់ឃើញខុសថា កម្ម និងផលនៃកម្មមិនមាន),*

១- សុមង្គលវិលាសិនីបាលី លេខ ៦ ទំព័រ ៣៣៥។

៣- សទ្ធហានតាយ *ជាអ្នកមានជំនឿ (ជឿជាក់លើអានុភាពនៃព្រះបរិត្តថា មានពិត អាចឃុំគ្រងរក្សាអ្នកស្តាប់បាន)[1]។*

ពាក្យនិមន្តព្រះសង្ឃសូត្រនូវព្រះបរិត្ត

ការអារាធនាព្រះសង្ឃដើម្បីសូត្រនូវព្រះបរិត្តនេះ ក៏គួរតែឧបាសក ឧបាសិកា និងលោកអាចារ្យគ្រប់រូបគប្បីបានយល់ដឹងថា ប្រសិនបើអារាធនាខុស លោកមិនអាចសូត្របានទេ បើសូត្រនឹងត្រូវអាបត្តិទុក្កដ, លុះណាតែអារាធនាបានត្រឹមត្រូវទើបលោកអាចសូត្របាន មិនត្រូវអាបត្តិ។ សេចក្តីពិស្តារមាននៅក្នុងសមន្តប្បាសាទិកា អដ្ឋកថាព្រះវិន័យ ត្រង់តតិយបារាជិកសិក្ខាបទនិងវិនយសង្គហដ្ឋកថា ត្រង់កេសជ្ជាទិករណវិនិច្ឆយកថា ដូចដែលនឹងដកយកតែសេចក្តីខ្លះដោយសង្ខេបមកខាងក្រោមនេះ។

ពាក្យនិមន្តដែលខុស

*"**គិលានស្ស បរិត្តំ ករោថ ភន្តេ** ប្រែថា សូមលោកម្ចាស់គ្រប់ព្រះអង្គមេត្តាធ្វើព្រះបរិត្តដល់អ្នកជំងឺចុះ" ។*

*ពាក្យខាងលើនេះ ទោះបីប្រើតែបាលី ឬតែសម្រាយក៏មិនបានដូចគ្នា ព្រោះពាក្យថា "**សូមធ្វើ ឬចូរធ្វើ**" នេះ គឺជាពាក្យប្រើ ឬពាក្យបង្គាប់បញ្ជា កាលបើភិក្ខុទទួលព្រមហើយសូត្រទៅ បានឈ្មោះថាជាអ្នកទទួលបម្រើដល់គ្រហស្ថ ហើយ*

១- គម្ពីរមិលិន្ទបញ្ហាបាលី ច្បាប់ពុទ្ធិកបណ្ឌិតសភា ទំព័រ ២៩៩។

នៅក្នុងវិនយបានហាមមិនឱ្យភិក្ខុសង្ឃធ្វើការបម្រើដល់គ្រហស្ថទេ។

ពាក្យនិមន្តដែលត្រូវ

*"**បរិត្តំ តណាថ តន្តេ** ប្រែថា សូមលោកម្ចាស់គ្រប់ព្រះអង្គមេត្តាសូត្រនូវព្រះបរិត្ត, ឬថា **បរិត្តំ តណាទ្ធ តន្តេ** ប្រែថា សូមព្រះករុណាគ្រប់ព្រះអង្គមេត្តាសូត្រនូវព្រះបរិត្ត" ដូច្នេះក៏បាន, ឬក៏អាចធនាដោយពាក្យដែលបុរាណលោកនិពន្ធទុក ដូចដែលពុទ្ធបរិស័ទធ្លាប់ប្រើសព្វថ្ងៃនេះ មានពាក្យថា "**វិបត្តិប្បដិពាហា...**" ព្រោះជាពាក្យអាវាធនាដើម្បីពោល ឬសម្តែងធម៌ កុំតែប្រើពាក្យថា "**សូមធ្វើ** ឬ **ចូរធ្វើ**" ព្រោះជាពាក្យដែលមិនគួរ គឺខុសនឹងព្រះវិន័យ។*

*- **ព្រះសូត្រ** ដោយយកព្រះសូត្រផ្សេង ៗ មានមង្គលសូត្រជាដើមមកដាក់តែ១ក្រុមជាមួយគ្នា គឺដាក់បន្ទាប់ពីព្រះបរិត្ត, ឯ **បកិណ្ណកបរិត្ត** មាន **យន្តុន្និមិត្តំ** ជាដើមរហូតដល់ **ពុទ្ធជយមង្គល** គឺ **ពាហុំ** ជាបទនិពន្ធរបស់បូរាណាចារ្យដែលជាអ្នកចេះដឹងក្នុងកាលខាងក្រោយ ទើបខ្ញុំដាក់ខាងចុងគេសម្រាប់សូត្រក្រោយព្រះបរិត្ត ឬព្រះសូត្រផ្សេង ៗ។*

សេចក្តីគួរយល់ដឹងអំពីការសូត្រនូវព្រះពុទ្ធមន្ត

ចំពោះការសូត្រនូវព្រះពុទ្ធមន្តនេះ សូមលោកអ្នកសូត្រ ឬអ្នកផ្តើមធម៌បានយល់ដឹងនិងចងចាំទុកថា ប្រសិនបើគេនិមន្តឱ្យសូត្រនូវពុទ្ធមន្ត នោះគឺយើងសូត្រតែព្រះបរិត្ត ឬតែព្រះសូត្រក៏បាន ឬក៏ចង់សូត្រទាំងពីរលាយគ្នាក៏បានដែរ។ តែបើគេនិមន្តដោយព្រះបរិត្តត្រូវតែសូត្រនូវព្រះបរិត្ត, គេនិមន្តដោយព្រះសូត្រ ត្រូវតែ

សូត្រនូវព្រះសូត្រ មិនត្រូវសូត្រនូវធម៌ផ្សេងឱ្យខុសពីពាក្យគេនិមន្តឡើយ, ប្រសិនបើចង់សូត្រនូវធម៌ផ្សេងផងក៏បានខ្លះដែរ តែត្រូវសូត្រជាខាងក្រោយ គឺត្រូវសូត្រធម៌ដែលគេនិមន្តនោះជាមុខសិន។

មួយទៀត ចំពោះការសូត្រនូវព្រះពុទ្ធមន្តនោះទៀតសោត ប្រសិនបើយើងសូត្រនូវពាក្យប្រារព្ធរបស់ព្រះបរិត្ត ឬព្រះសូត្រណាហើយ ត្រូវតែសូត្រនូវព្រះបរិត្ត ឬព្រះសូត្រនោះ ដូចជាថា បើផ្តើមដោយ **បណិធានេនាហំ** *... ក៏ត្រូវតែសូត្រនូវ* **យានីធភូតានិ សមាគតានិ** *..., តែបើផ្តើមដោយ* **យស្សា** *..., ក៏ត្រូវតែសូត្រនូវ* **ករណីយមត្តកុសលេន** *...។ ល ។ មិនត្រូវទៅសូត្រនូវព្រះបរិត្ត ឬព្រះសូត្រដទៃផ្សេងទេ ហើយក៏មិនត្រូវសូត្រកាត់ពាក់កណ្តាល ឬសូត្រតែត្រង់ខាងចុងដែរ គឺថាត្រូវតែសូត្រព្រះបរិត្ត ឬព្រះសូត្រនោះតាំងពីដើមដរាបដល់ចប់។*





ព្រះបរិត្ត

អញ្ជើញពួកទេវតា

សរេ្វ សសេនំ សពន្ធុំ ឥរិន្ទំ បរិត្តានុភាវោ សទា រក្ខតូតិ
ឥរិត្វាន មេត្តំ សមេត្តា ភទន្តា អវិក្ខិត្តចិត្តា បរិត្តំ ភណន្តុ

អ្នកដ៏ចម្រើនទាំងឡាយ ជាអ្នកប្រកបដោយមេត្តា ចូរផ្សាយនូវមេត្តាចិត្ត ដោយគិតដូច្នេះថា សូមអានុភាពនៃព្រះបរិត្ត រក្សានូវព្រះមហាក្សត្រជាធំជាងនរជន ព្រមទាំងរាជសម្បត្តិ ព្រមទាំងសេនាមាត្យ ព្រមទាំងព្រះរាជវង្សានុវង្ស សព្វៗ កាលរៀងទៅ ហើយកុំមានចិត្តរាយមាយ ចូរសូត្រនូវព្រះបរិត្តៗ

សមន្តា ចក្កវាឡេសុ អត្រាគច្ឆន្តុ ទេវតា
សទ្ធម្មំ មុនិរាជស្ស សុណន្តុ សគ្គមោក្ខទំ

ទេវតាទាំងឡាយក្នុងចក្រវាលទាំងឡាយ ដោយជុំវិញ ចូរមកប្រជុំគ្នាក្នុងទីនេះ ចូរស្តាប់នូវព្រះសទ្ធម្ម ជាធម៌អាចឱ្យនូវសួគ៌ និងព្រះនិព្វាន (របស់ព្រះអនាវរណញ្ញាណ) ជាស្តេចនៃអ្នកប្រាជ្ញៗ

សគ្គេ កាមេ ច រូបេ គិរិសិខរតដេ ចន្ទលិក្ខេ វិមានេ ឯរេ រជ្ជេ ច គាមេ តរុវនគហនេ គេហវត្ថុម្ហិ ខេត្តេ ភុម្មា ចាយន្តុ ទេវា ជលថលវិសមេ យក្ខគន្ធព្វនាគា តិដ្ឋន្តា សន្តិកេ យំ មុនិវរវចនំ សាធវោ មេ សុណន្តុ ៚

ទេវតាទាំងឡាយដែលឋិតនៅក្នុងឋានសួគ៌ ដែលជាកាមភព និងរូបភពក្តី កុម្មទេវតាទាំងឡាយ ដែលឋិតនៅក្នុងទិព្វវិមាន គឺលើកំពូលភ្នំ ឬភ្នំដែលដាច់ក្តី

ឮដ៏អាកាសក្តី នៅនាភោះ និងដែន និងស្រុកក្តី នៅនាដើមព្រឹក្សា និងព្រៃញាត-ស្បាត ឬទីស្រែចម្ការក្តី យក្ខ និងគន្ធព្វ និងនាគទាំងឡាយដែលឋិតនៅនាទីទឹក ទីគោក ឬទីមិនរាបស្មើ ដែលនៅក្នុងទីជិតនេះក្តី សូមអញ្ជើញមកប្រជុំគ្នា (ក្នុងទីនេះ) ពាក្យឯណា ដែលជាពាក្យព្រះសក្យមុនីដ៏សើរ (ដែលយើងខ្ញុំនឹងសូត្រឥឡូវនេះ) លោកអ្នកសប្បុរសទាំងឡាយ ចូរស្តាប់នូវពាក្យនោះ (អំពីសម្នាក់) នៃខ្ញុំ (ដោយគោរព)។

ធម្មស្សវនកាលោ អយម្ភទន្តា *បពិត្រលោកអ្នកដ៏ចម្រើនទាំងឡាយ ពេលនេះ ជាពេលគួរនឹងស្តាប់នូវព្រះធម៌។*

ធម្មស្សវនកាលោ អយម្ភទន្តា *បពិត្រលោកអ្នកដ៏ចម្រើនទាំងឡាយ ពេលនេះ ជាពេលគួរនឹងស្តាប់នូវព្រះធម៌។*

ធម្មស្សវនកាលោ អយម្ភទន្តា *បពិត្រលោកអ្នកដ៏ចម្រើនទាំងឡាយ ពេលនេះ ជាពេលគួរនឹងស្តាប់នូវព្រះធម៌។*

ឧបសគ្គារ

(បិដកលេខ ១៧ ទំព័រ ២៤២)

ឥមេ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។
ឥមេ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។
ឥមេ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស[1] ។

១-បិដកលេខ ២១ ទំ. ១៧៥, បិ. ២៤ ទំ. ៤៥៥, បិ.២៥ ទំ.១៩, ២៥៩, បិ.៣0 ទំ.៨៣, បិ.៤0 ទំ.១៤៩, បិ.៤៥ ទំ. ២២១, ធម្មបទបាលី ភាគ ៨ ទំ១៧៧ ។

វីរិយានមស្ការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃ ចំពោះព្រះអង្គឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ។

សរណគមន៍

(បិដកលេខ ៦ ទំព័រ ២៧៣ និងលេខ ៥២ ទំព័រ ១)

ពុទ្ធំ សរណំ គច្ឆាមិ *ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹងទីរឭក*

ធម្មំ សរណំ គច្ឆាមិ *ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹងទីរឭក*

សង្ឃំ សរណំ គច្ឆាមិ *ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីពឹងទីរឭក។*

ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ *ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹងទីរឭក ជាគម្រប់ពីរដងផង*

ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ *ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹងទីរឭក ជាគម្រប់ពីរដងផង*

ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ *ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីពឹងទីរឭក ជាគម្រប់ពីរដងផង។*

តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ *ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីពឹងទីរឭកជាគម្រប់បីដងផង*

តតិយម្បិ ធម្មំ សរណំ គច្ឆាមិ *ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ជាទីពឹងទីរឭក ជាគម្រប់បីដងផង*

តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ *ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃជាទីពឹងទីរឭក ជាគម្រប់បីដងផង។*

សម្ពុទ្ធេ

សម្ពុទ្ធេ អដ្ឋវីសញ្ច ទ្វាទសញ្ច សហស្សកេ
បញ្ចសតសហស្សានិ នមាមិ សិរសា អហំ

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធទាំងឡាយ ២៨ ព្រះអង្គផង ១ ម៉ឺន ២ ពាន់ព្រះអង្គផង ៥ សែនព្រះអង្គផង[1] ដោយត្បូង (របស់ខ្ញុំព្រះករុណា)

តេសំ ធម្មញ្ច សង្ឃញ្ច អាទរេន នមាមិហំ *ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះធម៌ផង នូវព្រះសង្ឃផង របស់ព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ ដោយគោរព*

នមក្ការានុភាវេន ហន្ត្វា សព្ពេ ឧបទ្ទវេ
អនេកា អន្តរាយាបិ វិនស្សន្តុ អសេសតោ

ដោយអានុភាពនៃកិរិយានមស្ការថ្វាយបង្គំ សូមឱ្យកម្ចាត់បង់នូវឧបទ្រពទាំងឡាយទាំងពួង ទាំងសេចក្តីអន្តរាយទាំងឡាយជាអនេក ក៏ចូរឱ្យវិនាសទៅកុំបីមានសេសសល់ឡើយ។

១-រួមជា ៥ សែន ១ ម៉ឺន ២ ពាន់ ២៨ ព្រះអង្គ។ ២- រួមជា ១ លាន ២ ម៉ឺន ៤ ពាន់ ៥៥ ព្រះអង្គ។

សម្ពុទ្ធេ បញ្ចាបញ្ញាសញ្ញា ចតុវីសតិសហស្សកេ
ទសសតសហស្សានិ នមាមិ សិរសា អហំ

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធទាំងឡាយ ៥៥ ព្រះអង្គផង ២ ម៉ឺន ៤ ពាន់ព្រះអង្គផង ១ លានព្រះអង្គផង[២] ដោយត្បូង (របស់ខ្ញុំព្រះករុណា)

តេសំ ធម្មញ្ច សង្ឃញ្ច អាទរេន នមាមិហំ *ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះធម៌ផង នូវព្រះសង្ឃផង របស់ព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ ដោយគោរព*

នមក្ការានុភាវេន ហន្ត្វា សព្វេ ឧបទ្ទវេ
អនេកា អន្តរាយាបិ វិនស្សន្តុ អសេសតោ

ដោយអានុភាពនៃកិរិយានមស្ការថ្វាយបង្គំ សូមឱ្យកម្ចាត់បង់នូវឧបទ្រពទាំងឡាយទាំងពួង ទាំងសេចក្តីអន្តរាយទាំងឡាយជាអនេក ក៏ចូរឱ្យវិនាសទៅកុំបីមានសេសសល់ឡើយ។

សម្ពុទ្ធេ ទ្វាទសុត្តរសតេ អដ្ឋចត្តាឡីសសហស្សកេ
ទីសតិសតសហស្សានិ នមាមិ សិរសា អហំ

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធទាំងឡាយ ១០៩ ព្រះអង្គផង ៤ ម៉ឺន ៨ ពាន់ព្រះអង្គផង ២ លានព្រះអង្គផង[១] ដោយត្បូង (របស់ខ្ញុំព្រះករុណា)

១- រួមជា ២ លាន ៤ ម៉ឺន ៨ ពាន់ ១០៩ ព្រះអង្គ។

តេសំ ធម្មញ្ច សច្ឆញ្ច អានេន នមាមិហំ *ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំនូវព្រះធម៌ផង នូវព្រះសង្ឃផង របស់ព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ ដោយគោរព*

នមក្ការានុភាវេន ហន្ត្វា សព្ពេ ឧបទ្ទវេ
អនេកា អន្តរាយាបិ វិនស្សន្តុ អសេសតោ[1]។

ដោយអានុភាពនៃកិរិយានមស្ការថ្វាយបង្គំ សូមឱ្យកម្ចាត់បង់នូវឧបទ្រពទាំងឡាយទាំងពួង ទាំងសេចក្តីអន្តរាយទាំងឡាយជាអនេក ក៏ចូរឱ្យវិនាសទៅ កុំបីមានសេសសល់ឡើយ។

រតនបរិត្តារម្ភោ

(ធម្មបទដ្ឋកថាបាលី ភាគ ៧ ទំព័រ ១៣៧)

បណិធានតោ បដ្ឋាយ តថាគតស្ស ទស បារមិយោ ទស ឧបបារមិយោ ទស បរមត្ថបារមិយោ បញ្ច មហាបរិច្চាគេ តិស្សោចរិយា បច្ឆិមភវេ គព្ភាវក្កន្តឹ ជាតឹ អភិនិក្ខមនំ បធានចរិយំ ពោធិបល្លង្កេ មារវិជយំ សព្ពញ្ញុតញ្ញាណប្បដិវេធំ ឆវណោកុត្តរធម្មេតិ សព្ពេបិមេ ពុទ្ធគុណេ អាវជ្ជិត្វា វេសាលិយា តីសុ បាការន្តរេសុ តិយាមរត្តឹ បរិត្តំ ករោន្តោអាយស្មា អានន្ទត្ថេរោវិយ ការុញ្ញចិត្តំ ឧបដ្ឋបេត្វា[2]។

យើងទាំងឡាយតាំងចិត្តប្រកបដោយសេចក្តីករុណា (ចំពោះសត្វទាំងឡាយ) ដូចជាព្រះអានន្ទត្ថេរដ៏មានអាយុ ដែលលោកពិចារណានូវព្រះពុទ្ធគុណ

១-ធម៌នេះនិពន្ធដោយព្រះថេរៈជនជាតិភូមា។ ២-បាលីទាំងនេះ បានផ្សៀងក្នុងអដ្ឋថា ឃើញមានបាត់ខ្លះ លើសខ្លះ។

ទាំងឡាយនេះគ្រប់ទាំងអស់ របស់ព្រះតថាគត ចាប់ដើមអំពីសេចក្តីផ្តើមតាំងប្រាថ្នាជាព្រះពុទ្ធមក គឺបារមី ១០ ឧបបារមី ១០ បរមត្ថបារមី ១០ មហាបរិច្ចាគ ៥ ចរិយា ៣ កិរិយាយាងចុះកាន់គភ៌នៃព្រះមាតាក្នុងបច្ឆិមភព កិរិយាប្រសូត កិរិយាយាងចេញសាងអភិនេស្ក្រមណ៍ កិរិយាបំពេញនូវទុក្ករកិរិយា កិរិយាផ្ចាញ់មារ កិរិយាត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណលើពោធិបល្ល័ង្ក លោកុត្តរធម៌ ៩ ហើយព្រះ(អានន្ទត្ថេរលោក) សូត្រនូវព្រះបរិត្តអស់រាត្រី មានយាម ៣ ក្នុងខាងក្នុងកំពែងទាំងឡាយ ៣ ជាន់នៃក្រុងវេសាលី

កោដិសតសហស្សេសុ ចក្កវាឡេសុទេវតា
យស្សាណម្បដិគណ្ហន្តិ យញ្ច ទេសាលិយម្ហរេ
រោគាមនុស្សទុព្ភិក្ខ - សម្ភូតន្តិវិធម្ភយំ
ខិប្បមន្តរធាបេសិ បរិត្តន្តម្ភណាមហេ ៚

ទេវតាទាំងឡាយក្នុងសែនកោដិចក្រវាល តែងទទួលយកនូវអាជ្ញានៃព្រះបរិត្តឯណា ម្យ៉ាងទៀត ព្រះបរិត្តឯណា ញុំាងភ័យ ៣ ប្រការដែលកើតអំពីរោគនិងអមនុស្ស និងទុព្ភិក្ស គឺគ្រាអំណត់ក្នុងក្រុងវេសាលី ឱ្យអន្តរធានបាត់ទៅដោយឆាប់រហ័ស ម្នាលទេវតាទាំងឡាយ យើងសូត្រឥឡូវនេះ នូវព្រះបរិត្តនោះ។

រតនបរិត្ត

(បិដកលេខ ៥២ ទំព័រ ៦ និងលេខ ៥៤ ទំព័រ ៧៣)

យានីធ ភូតានិ សមាគតានិ
ភុម្មានិ វា យានិ ឥ អន្តលិក្ខេ

ពួកភូតឯណា ជាទេវតាឋិតនៅលើផែនដីក្តី ពួកភូតឯណា ជាទេវតាឋិតនៅឰដអាកាសក្តី ដែលមកប្រជុំគ្នាក្នុងទីនេះ

សព្វេ ភូតា សុមនា ភវន្តុ *សូមពួកភូតទាំងអស់នោះមានចិត្តល្អ*

អថោបិ សក្កច្ច សុណន្តុ ភាសិតំ *ម្យ៉ាងទៀត ចូរស្តាប់នូវភាសិតដោយគោរព*

តស្មា ហិ ភូតា និសាមេថ សព្វេ
មេត្តំ ករោថ មានុសិយា បជាយ

ព្រោះហេតុនោះ អ្នកទាំងឡាយជាភូតទាំងអស់ ចូរស្តាប់នូវព្រះបរិត្ត ចូរធ្វើនូវមេត្តាចិត្តចំពោះពពួកសត្វជាមនុស្សជាតិ

ទិវា ច រត្តោ ច ហរន្តិ យេ ពលឹ *មនុស្សទាំងឡាយឯណា តែងនាំមកនូវពលិកម្មក្នុងពេលថ្ងៃ និងពេលយប់*

តស្មា ហិ នេ រក្ខថ អប្បមត្តា[1] *ព្រោះហេតុនោះ សូមអ្នកទាំងឡាយកុំមើលបំណាំឡើយ សូមរក្សានូវមនុស្សទាំងឡាយនោះ។*

យំ កិញ្ចិ វិត្តំ ឥធ វា ហុរំ វា សគ្គេសុ វា យំ រតនំ បណីតំ
ទ្រព្យឯណាមួយ ក្នុងលោកនេះ និងក្នុងលោកឯទៀតក្តី រតនវត្ថុដ៏ឧត្តមឯណាក្នុងឋានសួគ៌ក្តី

ន នោ សមំ អត្ថិ តថាគតេន *ទ្រព្យ និងរតនវត្ថុទាំងនោះ ស្មើដោយព្រះតថាគត មិនមានឡើយ*

១-បើតាមសព្ទ ពាក្យថា **អប្បមត្តា** ប្រែថា “កុំប្រមាទ, កុំធ្វេសប្រហែស”។

ឥទម្បិ ពុទ្ធេ រតនំ បណីតំ *កែវគឺព្រះពុទ្ធនេះឯង ជាកែវដ៏ឧត្តម*

ឯតេន សច្ចេន សុវត្ថិ ហោតុ *ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន។*

ខយំ វិរាគំ អមតំ បណីតំ

យទជ្ឈគា សក្យមុនី សមាហិតោ

ព្រះសក្យមុនីជាម្ចាស់ មានព្រះទ័យតម្កល់មាំ បានត្រាស់ដឹងហើយនូវព្រះធម៌ឯណា ជាទីក្សីយនៃកិលេស ជាទីប្រាសចាកវាគៈ ជាធម៌មិនស្ងាប់ ជាធម៌ដ៏ឧត្តម

ន តេ ន ធម្មេន សមត្ថិ កិញ្ចិ *របស់អ្វីមួយ ស្មើដោយព្រះធម៌នោះ មិនមានឡើយ*

ឥទម្បិ ធម្មេ រតនំ បណីតំ *កែវគឺព្រះធម៌នេះឯង ជាកែវដ៏ឧត្តម*

ឯតេន សច្ចេន សុវត្ថិ ហោតុ *ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន។*

យម្ពុទ្ធសេដ្ឋោ បរិវណ្ណយី សុចឹ *ព្រះពុទ្ធដ៏ប្រសើរ ទ្រង់សរសើរនូវសមាធិឯណា ថាជាធម៌ដ៏ស្អាត*

សមាធិមានន្តរិកញ្ញមាហុ *បណ្ឌិតទាំងឡាយ ពោលហើយនូវសមាធិឯណា ថាជាធម៌ឱ្យផលដោយលំដាប់*

សមាធិនា តេន សមោ ន វិជ្ជតិ *សមាធិឯទៀត ស្មើដោយសមាធិនោះ*

មិនមានឡើយ

ឥទម្បិ ពុទ្ធេ រតនំ បណីតំ *កែវ គឺព្រះពុទ្ធនេះឯង ជាកែវដ៏ឧត្តម*

ឯតេន សច្ចេន សុវត្ថិ ហោតុ *ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តី កើតមាន។*

យេ បុគ្គលា អដ្ឋ សតំ បសដ្ឋា
ចត្តារិ ឯតានិ យុគានិ ហោន្តិ

បុគ្គលទាំងឡាយឯណា ៨ ចំពូក ដែលសប្បុរសទាំងឡាយសរសើរហើយ បើរាប់ជាគូបាន ៤ គូ

តេ ទក្ខិណេយ្យា សុគតស្ស សាវកា *បុគ្គលទាំងឡាយនោះ ជាសាវ័ក របស់ព្រះសុគត លោកគួរដល់ទក្ខិណាទាន*

ឯតេ សុទិន្នានិ មហប្ផលានិ *ទានទាំងឡាយ ដែលបុគ្គលឱ្យហើយ ដល់ទក្ខិណេយ្យបុគ្គលទាំងឡាយនោះ ជាទានមានផលច្រើន*

ឥទម្បិ សង្ឃេ រតនំ បណីតំ *កែវ គឺព្រះសង្ឃនេះឯង ជាកែវដ៏ឧត្តម*

ឯតេន សច្ចេន សុវត្ថិ ហោតុ *ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តី កើតមាន។*

យេ សុប្បយុត្តា មនសា ទឬ្ហន
និក្កាមិនោ គោតមសាសនម្ហិ

អរិយបុគ្គលទាំងឡាយឯណា ក្នុងសាសនានៃព្រះសម្ពុទ្ធ ទ្រង់ព្រះនាមគោតម ប្រកបត្រូវល្អហើយ មានចិត្តខ្ជាប់ខ្ជួន ឥតមានកាម គឺសេចក្តីប្រាថ្នាឡើយ

តេ បត្តិបត្តា អមតំ វិគយ្ហ លទ្ធា មុធា និព្ពុតឹ ភុញ្ជមានា *អរិយបុគ្គលទាំងឡាយនោះ ដល់ហើយនូវព្រះអរហត្តផល ហើយចូលទៅកាន់ព្រះនិព្វាន បាននូវកិរិយារលត់កិលេសដោយទទេ គឺឥតមានទិញដូរឡើយ ហើយសោយនូវផល*

ឥទម្បិ សង្ឃេ រតនំ បណីតំ *កែវគឺ ព្រះសង្ឃនេះឯង ជាកែវដ៏ឧត្តម*

ឯតេន សច្ចេន សុវត្ថិ ហោតុ *ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន។*

យថិន្ទខីលោ បថវីសិតោ សិយា
ចតុព្ភិ វាតេភិ អសម្បកម្បិយោ

សសរខឿនដែលគេបោះភ្ជាប់នឹងផែនដី ជារបស់មិនកម្រើកញាប់ញ័រដោយខ្យល់ព្យុះ ដែលបក់មកអំពីទិសទាំង ៤ យ៉ាងណាមិញ

តថូបមំ សប្បុរិសំ វទាមិយោ អរិយសច្ចានិ អវេច្ច បស្សតិ *អ្នកណាពិចារណាឃើញនូវអរិយសច្ចទាំងឡាយ តថាគតហៅអ្នកនោះ ថាជាសប្បុរស (មិនញាប់ញ័រដោយលោកធម៌ទាំងឡាយ) ប្រៀបដូចជាសសរខឿនដូច្នោះឯង*

ឥទម្បិ សង្ឃេ រតនំ បណីតំ *កែវ គឺព្រះសង្ឃនេះឯង ជាកែវដ៏ឧត្តម*

ឯតេន សច្ចេន សុវត្ថិ ហោតុ *ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន។*

យេ អរិយសច្ចានិ វិភាវយន្តិ គម្ភីរបញ្ញេន សុទេសិតានិ *អរិយបុគ្គល*

ទាំងឡាយឯណា ធ្វើឱ្យជាក់ច្បាស់នូវអរិយសច្ចទាំងឡាយ ដែលព្រះតថាគត ព្រះអង្គមានប្រាជ្ញាដ៏ជ្រាលជ្រៅ សម្តែងល្អហើយ

កិញ្ចាបិ តេ ហោន្តិ ភុសប្បមត្តា *អរិយបុគ្គលទាំងឡាយនោះ ទុកជាប្រមាទដ៏លើសលន់ក៏ដោយ*

ន តេ ភវំ អដ្ឋមមាទិយន្តិ *អរិយបុគ្គលទាំងឡាយនោះ គង់មិនកាន់យកនូវភពជាគម្រប់ ៨ គឺមិនកើតទៀតហួសពី ៧ ជាតិឡើយ*

ឥទម្បិ សច្ចេ រតនំ បណីតំ *កែវ គឺព្រះសង្ឃនេះឯង ជាកែវដ៏ឧត្តម*

ឯតេន សច្ចេន សុវត្ថិ ហោតុ *ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន។*

សហាវស្ស ទស្សនសម្បទាយ
តយស្សុ ធម្មា ជហិតា ភវន្តិ
សក្កាយទិដ្ឋិ វិចិកិច្ឆិតញ្ច
សីលព្វតំ វាបិ យទត្ថិកិញ្ចិ

(សំយោជនកិលេស ៣ យ៉ាង គឺ) សក្កាយទិដ្ឋិ វិចិកិច្ឆា និងសីលព្វតបរាមាស ឯណាមួយតែងមាន ធម៌ទាំងឡាយ ៣ នោះ សោតាបន្នបុគ្គលនោះបានលះបង់ហើយជាមួយនឹងទស្សនសម្បទ គឺសោតាបត្តិមគ្គ

ចតូហបាយេហិ ច វិប្បមុត្តោ *ម្យ៉ាងទៀត សោតាបន្នបុគ្គល បានរួចស្រឡះចាកអបាយទាំងឡាយ ៤ ហើយ*

ឆចាភិជ្ឈានានិ អភព្វោ ការតុំ *មិនអាចធ្វើនូវឋានដ៏អាក្រក់ទាំង ៦ ឡាយ គឺ អនន្តរិយកម្ម ៥ និងកិរិយាដាក់ចិត្តទៅកាន់សាសនាដទៃឡើយ*

ឥទម្បិ សង្ឃេ រតនំ បណីតំ *កែវ គឺព្រះសង្ឃនេះឯង ជាកែវដ៏ឧត្តម*

ឯតេន សច្ចេន សុវត្ថិ ហោតុ *ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តី កើតមាន។*

កិញ្ចាបិ សោ កម្មំ ករោតិ បាបកំ

ការយេន វាចាយុទ ចេតសា វា

ប្រសិនណាបើសោតាបន្នបុគ្គលនោះ ធ្វើនូវបាបកម្មខ្លះ ដោយកាយ វាចា ឬក៏ដោយចិត្ត (ព្រោះសេចក្តីភ្លាំងភ្លាត់)

អភព្វោ សោ តស្ស បដិច្ឆាទាយ *សោតាបន្នបុគ្គលនោះ មិនអាចបិទបាំងនូវបាបកម្មនោះឡើយ*

អភព្វតា ទិដ្ឋបទស្ស វុត្តា *ភាវៈនៃបុគ្គលមានផ្លូវនៃព្រះនិព្វាន ឃើញហើយ ជាបុគ្គលមិនអាចនឹងបិទបាំងនូវបាបកម្ម ព្រះពុទ្ធទាំងឡាយបានត្រាស់សម្តែងហើយ*

ឥទម្បិ សង្ឃេ រតនំ បណីតំ *កែវ គឺព្រះសង្ឃនេះឯង ជាកែវដ៏ឧត្តម*

ឯតេន សច្ចេន សុវត្ថិ ហោតុ *ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តី កើតមាន។*

វនប្បគុម្ពេ យថា ផុស្សិតគ្គេ គិម្ហានមាសេ បឋមស្មឹ គិម្ហេ *គុម្ពឈើក្នុង*

ព្រៃ មានត្រួយលូតលាស់ក្នុងខាងដើមគិម្ភវដូវ គឺខែក្តៅយ៉ាងណាមិញ

តថូបមំ ធម្មវរំ អទេសយិ និព្វានគាមឹ បរមំ ហិតាយ ព្រះសម្ពុទ្ធបានត្រាស់សម្តែងហើយនូវធម៌ដ៏ប្រសើរ ជាធម៌អាចញុំាងសត្វទាំងឡាយ ឱ្យដល់នូវព្រះនិព្វាន ដើម្បីប្រយោជន៍ដ៏ឧត្តម ប្រៀបដូចជាគុម្ពឈើក្នុងព្រៃដូច្នោះឯង

ឥធម្បិ ពុទ្ធេ រតនំ បណីតំ កែវ គឺព្រះពុទ្ធនេះឯង ជាកែវដ៏ឧត្តម

ឯតេន សច្ចេន សុវត្ថិ ហោតុ ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន។

ឥរោ ឥរញ្ញោ ឥរធោ ឥរាហរោ ព្រះសម្មាសម្ពុទ្ធ ជាបុគ្គលប្រសើរ ទ្រង់ជ្រាបនូវធម៌ដ៏ប្រសើរ ទ្រង់ប្រទាននូវធម៌ដ៏ប្រសើរ ទ្រង់នាំមកនូវធម៌ដ៏ប្រសើរ

អនុត្តរោ ធម្មវរំ អទេសយិ ព្រះអង្គប្រសើរឥតមានអ្នកណាមួយស្មើ ទ្រង់ត្រាស់សម្តែងហើយនូវធម៌ដ៏ប្រសើរ

ឥធម្បិ ពុទ្ធេ រតនំ បណីតំ កែវ គឺព្រះពុទ្ធនេះឯង ជាកែវដ៏ឧត្តម

ឯតេន សច្ចេន សុវត្ថិ ហោតុ ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន។

ខីណំ បុរាណំ នវំ នត្ថិ សម្ភវំ កម្មចាស់ (របស់អរិយបុគ្គលឯណា) អស់ហើយ កម្មថ្មីរមែងមិនកើតជ្រាកដ

វិរត្តចិត្តាយតិកេ ភវស្មឹ អរិយបុគ្គលទាំងឡាយឯណា មានចិត្តនឿយណាយហើយក្នុងភពតទៅ

តេ ខីណាសវា អវិរុឡ្ហឆន្ទា *អរិយបុគ្គលទាំងឡាយនោះ មានពួជអស់ហើយ មានឆន្ទៈគឺសេចក្តីប៉ុនប៉ងក្នុងចិត្តមិនដុះចម្រើនឡើយ*

និព្ពន្តិ ធីរា យថាយមប្បទីបោ *ជាអ្នកមានប្រាជ្ញា តែងរលត់ទៅ ដូចជាប្រទីបដែលរលត់ទៅនេះ*

ឥទម្បិ សង្ឃេ រតនំ បណីតំ *កែវគឺព្រះសង្ឃនេះឯង ជាកែវដ៏ឧត្តម*

ឯតេន សច្ចេន សុវត្ថិ ហោតុ *ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមាន។*

យានីធ ភូតានិ សមាគតានិ ភុម្មានិ វា យានិ វ អន្តលិក្ខេ *ពួកភូតឯណា ជាទេវតាស្ថិតនៅលើផែនដីក្តី ពួកភូតឯណា ជាទេវតាស្ថិតនៅឰដ៏អាកាសក្តី ដែលមកប្រជុំគ្នាក្នុងទីនេះ*

តថាគតំ ទេវមនុស្សបូជិតំ ពុទ្ធំ នមស្សាម សុវត្ថិ ហោតុ *យើងទាំងឡាយ សូមនមស្ការនូវព្រះពុទ្ធជាម្ចាស់ ទ្រង់បានត្រាស់មកហើយដូចគ្នា ដែលទេវតា និងមនុស្សតែងបូជា សូមសិរីសួស្តីកើតមាន។*

យានីធ ភូតានិ សមាគតានិ ភុម្មានិ វា យានិ វ អន្តលិក្ខេ *ពួកភូតឯណា ជាទេវតាស្ថិតនៅលើផែនដីក្តី ពួកភូតឯណា ជាទេវតាស្ថិតនៅឰដ៏អាកាសក្តី ដែលមកប្រជុំគ្នាក្នុងទីនេះ*

តថាគតំ ទេវមនុស្សបូជិតំ ធម្មំ នមស្សាម សុវត្ថិ ហោតុ *យើងទាំងឡាយ សូមនមស្ការនូវព្រះធម៌ មានមកហើយដូចគ្នា ដែលទេវតា និងមនុស្ស*

តែងបូជា សូមសិរីសួស្តីកើតមាន។

យានីធ ភូតានិ សមាគតានិ ភុម្មានិ វា យានិ វ អន្តលិក្ខេ *ពួកភូតឯណា ជាទេវតាស្ថិតនៅលើផែនដីក្តី ពួកភូតឯណា ជាទេវតាស្ថិតនៅឰដ៏អាកាសក្តី ដែលមកប្រជុំគ្នាក្នុងទីនេះ*

តថាគតំ ទេវមនុស្សបូជិតំ សង្ឃំ នមស្សាម សុវត្ថិ ហោតុ *យើងទាំងឡាយ សូមនមស្ការនូវព្រះសង្ឃ មានមកហើយដូចគ្នា ដែលទេវតា និងមនុស្ស តែងបូជា សូមសិរីសួស្តីកើតមាន។*

រតនបរិត្តំ និដ្ឋិតំ

រតនបរិត្ត ចប់

មេត្តបរិត្តរម្ភោ

យស្សានុភាវតោ យក្ខា នេវ ទស្សេន្តិ ភីសនំ *យក្ខទាំងឡាយមិនហ៊ាន សម្តែងនូវអាការៈគួរខ្លាចឡើយ ព្រោះអានុភាពនៃព្រះបរិត្តឯណា*

យម្ហិ ចេវានុយុញ្ជន្តោ រត្តិន្ទិវមតន្ទិតោ *ម្យ៉ាងទៀត បុគ្គលមិនខ្ជិលច្រអូសក្នុងយប់ និងថ្ងៃ ហើយព្យាយាមរៀនសូត្រនូវព្រះបរិត្តឯណា*

សុខំ សុបតិ សុត្តោ ច បាបំ កិញ្ចិ ន បស្សតិ *កំពុងដេកលក់ ឬលក់រួចហើយក៏ជាសុខ រមែងមិនឃើញនូវសុបិនដ៏អាក្រក់តិចតួច*

ឯវមាទិគុណូបេតំ បរិត្តន្តម្ភណាម ហោ *យើងទាំងឡាយ សូត្យតទ្បូវនេះ*

នូវព្រះបរិត្តនោះ ដែលប្រកបដោយគុណទាំងឡាយ មានយ៉ាងនេះជាដើម។

មេត្តបរិត្ត

(បិដកលេខ ៥២ ទំព័រ ១៨ និងលេខ ៥៤ ទំព័រ ៥0)

ករណីយមត្តកុសលេន យន្តំ សន្តំ បទំ អភិសមេច្ច *កិច្ចឯណា (ដែលព្រះអរិយៈ) បានត្រាស់ដឹងនូវកោដ្ឋាសនៃធម៌ដ៏សូប់រំងាប់ គឺព្រះនិព្វាន (បានធ្វើហើយ) កិច្ចនោះ គឺកុលបុអ្នកត្រេកឡាសក្នុងប្រយោជន៍គួរធ្វើ*

សក្កោ ឧជុ ច សុហុជុ ច *(កុលបុត្រនោះ) ជាអ្នកអាចហ៊ានផង ត្រង់ដោយកាយ និងវាចាផង ត្រង់ល្អដោយចិត្តផង*

សុវចោ ចស្ស មុទុ អនតិមានី *ជាអ្នកប្រដៅងាយផង សុភាពទន់ភ្ងន់ផង មិនមានមានៈដ៏ក្រៃលែងផង*

សន្តុស្សកោ ច សុភរោ ច *ជាអ្នកសន្តោសផង គេចិញ្ចឹមងាយផង*

អប្បកិច្ចោ ច សល្លហុកវុត្តិ *ជាអ្នកមានកិច្ចធុរៈតិចផង ប្រព្រឹត្តស្រាល (ក្នុងកាយ និងចិត្ត) ផង*

សន្តិន្ទ្រិយោ ច និបកោ ច *ជាអ្នកមានឥន្ទ្រិយស្រគត់ស្រគំផង មានប្រាជ្ញាចាស់ផង*

អប្បគព្ភោ កុលេសុ អនន្ទុគិទ្ធោ *ជាអ្នកមិនឆ្គងផង មិនជាប់ជំពាក់ក្នុងត្រកូលទាំងឡាយផង*

ន ច ខុទ្ទំ សមាចរេ កិញ្ចិ យេន វិញ្ញូ បរេ ឧបវទេយ្យុំ *វិញ្ញូជនទាំងឡាយ គួរតិះដៀលនូវជនទាំងឡាយដទៃដោយកម្មឯណា មិនគួរប្រព្រឹត្តធ្វើនូវកម្មនោះ ដែលជាកម្មលាមកសូម្បីតិចតួច (ហើយគួរផ្សាយមេត្តាចិត្តចំពោះពពួកសត្វថា)*

សុខិនោ វា ខេមិនោ ហោន្តុសព្ពេ សត្តា ភវន្តុ សុខិតត្តា *សត្វទាំង-ឡាយទាំងពួង សូមឱ្យមានសេចក្តីសុខ ឱ្យមានសេចក្តីក្សេម ឱ្យមានខ្លួនដល់នូវសេចក្តីសុខចុះ*

យេ កេចិ បាណភូតត្ថិ តសា វា ថាវរា វា អនវសេសា *សត្វមានជីវិតទាំងឡាយឯណា តតមានសេសសល់ ទោះសត្វដែលជាអ្នកមានសេចក្តីតក់-ស្លុត គឺនៅមានតណ្ហាក្តី ជាអ្នកមាំមួន គឺតតមានតណ្ហាក្តី*

ទីឃា វា យេ មហន្តា វា *សត្វទាំងឡាយឯណា មានកាយវែងក្តី ធំក្តី*

មជ្ឈិមា រស្សកា អណុកថូលា *មានកាយយ៉ាងកណ្តាលក្តី ខ្លីក្តី មានកាយដ៏ស្គមឬជាត់ក្តី*

ទិដ្ឋា វា យេ ច អទិដ្ឋា *សត្វទាំងឡាយឯណា ដែលយើងឃើញហើយក្តី មិនឃើញក្តី*

យេ ច ទូរេ វសន្តិ អវិទូរេ *សត្វទាំងឡាយឯណា នៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី*

ភូតា វា សម្ភវេសី វា *ដែលកើតរួចមកហើយក្តី ដែលកំពុងស្វែងរកទី*

កើតក្តី

សព្វេ សត្តា ភវន្តុ សុខិតត្តា *សត្វទាំងឡាយទាំងពួង សូមឱ្យមានខ្លួនដល់នូវសេចក្តីសុខចុះ*

ន បរោ បរំ និកុព្វេថ *សត្វដទៃមិនគួរកំហែងបៀតបៀននូវសត្វដទៃឡើយ*

នាតិមញ្ញេថ កត្ថចិ នំ កិញ្ចិ[1] *មិនគួរមើលងាយគេតិចតួចក្នុងទីឯណាមួយឡើយ*

ព្យារោសនា បដិឃសញ្ញា នាញ្ញមញ្ញស្ស ទុក្ខមិច្ឆេយ្យ *មិនគួរប្រាថ្នានូវសេចក្តីទុក្ខដល់គ្នានឹងគ្នា ដោយសេចក្តីក្រេវក្រោធ និងដោយបដិឃសញ្ញា គឺសេចក្តីចង្អៀតចង្អល់ក្នុងចិត្តឡើយ*

មាតា យថា និយំ បុត្តំ អាយុសា ឯកបុត្តមនុរក្ខេ *មាតាថ្នមរក្សាបុត្រដែលកើតអំពីខ្លួន ជាកូនតែមួយ ដោយអាយុ គឺថាសូម្បីជីវិតក៏ហ៊ានលះបង់ក្នុងការរក្សានូវបុត្របានយ៉ាងណាមិញ*

ឯវម្បិ សព្វភូតេសុ មានសម្ភាវយេ អបរិមាណំ *បុគ្គលគួរចម្រើននូវមេត្តាចិត្តមិនមានប្រមាណចំពោះទៅរកសត្វទាំងឡាយទាំងពួងយ៉ាងនោះឯង។*

មេត្តញ្ច សព្វលោកស្មឹ មានសម្ភាវយេ អបរិមាណំ
ឧទ្ធំ អធោ ច តិរិយញ្ច អសម្ពាធំ អវេរំ អសបត្តំ

បុគ្គលគួរចម្រើននូវមេត្តាចិត្ត មិនមានប្រមាណ ជាធម៌មិនចង្អៀត មិនមាន

១-ក្នុងច្បាប់ឆដ្ឋសង្គាយនាមានបាលីថា **កញ្ចិ** បើប្រែឱ្យត្រូវតាមអដ្ឋកថា ប្រែថា មិនគួរមើលងាយបុគ្គលណាមួយក្នុងទីឯណាមួយឡើយ។ ពាក្យថា **កញ្ចិ** នេះរមែងសមនឹងអដ្ឋកថា។

ពៀរ មិនមានសត្រូវទៅក្នុងលោកទាំងអស់ គឺក្នុងខាងលើផង ខាងក្រោមផង ខាងទទឹង គឺត្រង់កណ្តាលផង

តិដ្ឋញ្ចរំ និសិន្នោ វា សយានោ វា យាវតស្សវិគតមិទ្ធោ (បុគ្គលអ្នកចម្រើនទូវមេត្តាចិត្តនោះ) ទោះឈរក្តី ដើរក្តី អង្គុយក្តី ដេកក្តី ជាអ្នកមានសេចក្តីងោកងក់ទៅប្រាស់ហើយ គឺថាជាអ្នកមិនដេកលក់អស់កាលត្រឹមណា

ឯតំ សតឹ អធិដ្ឋេយ្យ គួរតម្កល់នូវមេត្តានុស្សតិនុ៎ះ (អស់កាលត្រឹមនោះ)

ព្រហ្មមេតំ វិហារំ ឥធមាហុ បណ្ឌិតទាំងឡាយពោលនូវកិរិយានុ៎ះ ថាជាព្រហ្មវិហារ[1]ក្នុងសាសនានេះ

ទិដ្ឋញ្ច អនុបគម្ម សីលវា ទស្សនេន សម្បន្នោ
កាមេសុ វិនេយ្យ គេធំ ន ហិ ជាតុគព្ភសេយ្យំ បុន រេតីតិ

(បុគ្គលដែលមានមេត្តាព្រហ្មវិហារ) មិនដល់ស៊ប់នូវទិដ្ឋិ ជាអ្នកមានសីលប្រកបដោយទស្សនសម្បទ គឺសោតាបត្តិមគ្គ បន្ទោបង់នូវសេចក្តីត្រេកអរក្នុងកាមទាំងឡាយហើយ រមែងមិនមកកាន់គព្ភសេយ្យាស គឺថាមិនកើតក្នុងគភ៌ទៀតឡើយ។

មេត្តបរិត្តំ និដ្ឋិតំ

មេត្តបរិត្ត ចប់

๑- ធម៌សម្រាប់នៅរបស់ព្រហ្ម។

ខន្ធបរិត្តារម្ភោ

សព្វាសីវិសជាតីនំ ទិព្វមន្តាគទំ វិយ
យន្ធារេតិ វិសំ ឃោរំ សេសញ្ចាបិ បរិស្សយំ
អាណាក្ខេត្តម្ហិ សព្វត្ថ សព្វទា សព្វបាណិនំ
សព្វសោបិ និវារេតិ បរិត្តន្តម្ភណាម ហេ ៗ

ព្រះបរិត្តឯណា តែងញាំងពិសដ៏ពន្ធឹកនៃពួកសត្វទីឃជាតិទាំងអស់ឱ្យវិនាសទៅ ដូចជាឱសថវិសេសដ៏ប្រកបដោយមន្តទិព្វ ម្យ៉ាងទៀត ព្រះបរិត្តឯណា តែងឃាត់បង់នូវសេចក្តីអន្តរាយដ៏សេសរបស់សត្វទាំងអស់ ក្នុងអាណាខេត្តទាំងមូលដោយប្រការទាំងពួងសព្វ ៗ កាល យើងទាំងឡាយសូត្រឥឡូវនេះ នូវព្រះបរិត្តនោះ។

ខន្ធបរិត្ត[1]

(បិដកលេខ ១០ / ១៣៩, បិ.៤២ / ១៧៩, បិ.៥៨ / ១០២)

វិរូបក្ខេហិ មេ មេត្តំ *ភាវៈជាមិត្តរបស់អាត្មាអញ (ចូរមានជាមួយ) នឹងត្រកូលស្តេចនាគឈ្មោះវិរូបក្ខៈទាំងឡាយផង*

មេត្តំ ឯរាបថេហិ មេ *ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមានជាមួយ) នឹងត្រកូលស្តេចនាគឈ្មោះឯរាបថៈទាំងឡាយផង*

១-ព្រះបរិត្តនេះ ក្នុងបាលីព្រះត្រៃបិដកប្រើឈ្មោះថា **អហិរាជសូត្រ** តែក្នុងបរិត្តដីកា និងភាណវារៈខ្មែរយើងប្រើឈ្មោះថា **ខន្ធបរិត្ត**។ ដែលប្រើឈ្មោះថា **អហិរាជសូត្រ** នោះ លោកបំណងឱ្យសូត្រផ្សាយមេត្តាចិត្តដល់ត្រកូលស្តេចពស់ទាំង ៤, ដែលប្រើឈ្មោះថា **ខន្ធបរិត្ត** នោះ លោកបំណងឱ្យសូត្រដើម្បីជាសិរីមង្គល និងដើម្បីការពារភ័យដល់ខន្ធ ៥ គឺអត្តភាពរាងកាយ។

ឆព្យាបុត្តេហិ មេ មេត្តំ *ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមានជាមួយ) នឹងត្រកូលស្តេចនាគឈ្មោះ ឆព្យាបុត្តទាំងឡាយផង*

មេត្តំ កណ្ហាគោតមកេហិ ច *ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមានជាមួយ) នឹងត្រកូលស្តេចនាគឈ្មោះ កណ្ហាគោតមកៈទាំងឡាយផង*

អបាទកេហិ មេ មេត្តំ *ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមានជាមួយ) នឹងសត្វឥតជើងទាំងឡាយផង*

មេត្តំ ទ្វិបាទកេហិ មេ *ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមានជាមួយ) នឹងសត្វជើងពីរទាំងឡាយផង*

ចតុប្បទេហិ មេ មេត្តំ *ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមានជាមួយ) នឹងសត្វជើងបួនទាំងឡាយផង*

មេត្តំ ពហុប្បទេហិ មេ *ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមានជាមួយ) នឹងសត្វជើងច្រើនទាំងឡាយផង*

មា មំ អបាទកោ ហឹសិ *សត្វឥតជើង កុំបៀតបៀនអាត្មាអញឡើយ*

មា មំ ហឹសិ ទ្វិបាទកោ *សត្វជើងពីរ កុំបៀតបៀនអាត្មាអញឡើយ*

មា មំ ចតុប្បទោ ហឹសិ *សត្វជើងបួន កុំបៀតបៀនអាត្មាអញឡើយ*

មា មំ ហឹសិ ពហុប្បទោ *សត្វជើងច្រើន កុំបៀតបៀនអាត្មាអញឡើយ*

សព្ពេ សត្តា សព្ពេ បាណា សព្ពេ ភូតា ច កេវលា *សព្វសត្វទាំងឡាយផង សព្វប្រាណទាំងឡាយផង សព្វភូតទាំងឡាយផង ទាំងអស់គ្នា*

សព្ពេ សត្តានិ បស្សន្តុ *សូមសព្វសត្វ (ទាំងនោះ) ឃើញនូវសេចក្តីចម្រើនទាំងឡាយ*

មា កិញ្ចិ បាបមាគមា *សេចក្តីលាមកអាក្រក់តិចតួច កុំមកដល់ឡើយ គឺថា កុំកើតមាន (ដល់សត្វទាំងនោះឡើយ)*

អប្បមាណោ ពុទ្ធោ *ព្រះពុទ្ធជាម្ចាស់ទ្រទ្រង់នូវព្រះគុណនឹងប្រមាណមិនបាន*[1]

អប្បមាណោ ធម្មោ *ព្រះធម៌ទ្រទ្រង់នូវព្រះគុណនឹងប្រមាណមិនបាន*

អប្បមាណោ សង្ឃោ *ព្រះសង្ឃទ្រទ្រង់នូវព្រះគុណនឹងប្រមាណមិនបាន*

បមាណវន្តានិ សិរីសបានិ អហិវិច្ឆិកា សតបទី ឧណ្ណានាភី សរពូ មូសិកា *សត្វលូន ឬសត្វវារទាំងឡាយ គឺពស់ ខ្លួយ ក្អែបពីងពាងតុកកែ និងកណ្តុរ សុទ្ធតែមានប្រមាណ (គួររាប់ចំនួនបាន) គឺថាមិនច្រើនដូចគុណនៃព្រះរតនត្រ័យទេ*[2]

កតា មេ រក្ខា កតា មេ បរិត្តា *កិរិយារក្សា អាត្មាអញបានធ្វើហើយ ទាំងកិរិយាការពារ អាត្មាអញក៏បានធ្វើហើយ*

បដិក្កមន្តុ ភូតានិ *ពួកសត្វ (កាច) ទាំងឡាយចូរចៀសចេញទៅ*

សោហំ នមោ ភគវតោ *ខ្ញុំសូមនមស្ការចំពោះព្រះដ៏មានព្រះភាគជាម្ចាស់*[3]

នមោ សត្តន្នំ សម្មាសម្ពុទ្ធានន្តិ *ខ្ញុំសូមនមស្ការចំពោះព្រះសម្មាសម្ពុទ្ធទាំងឡាយ ៧ ព្រះអង្គ*[4]។

១-ព្រោះព្រះពុទ្ធទ្រង់មិនមានកិលេសមានរាគៈជាដើមដែលជាហេតុធ្វើឱ្យមានប្រមាណ (អដ្ឋកថា) ។

២-ព្រោះសត្វទាំងនោះសុទ្ធតែមានកិលេសមានរាគៈជាដើមជាហេតុធ្វើឱ្យមានប្រមាណ (អដ្ឋកថា) ។

៣-៤-ពាក្យប្រែថ្មីនេះ ខ្ញុំយកតាមពាក្យប្រែក្នុងបិដកលេខ ៤២ ទំព័រ ១៨០ ព្រោះជាពាក្យដែលត្រឹមត្រូវជាង។

មោរបរិត្តារម្ភោ

បុរេន្តម្ភោធិសម្ភារេ ទិព្វត្តំ មោរយោនិយំ
យេន សំវិហិតារក្ខំ មហាសត្តំ ឥទេចរ
ចិរស្សំ វាយមន្តាបិ នេវ សក្ខឹសុ គណ្ហិតុំ

ព្រានព្រៃទាំងឡាយ សូម្បីព្យាយាមអស់កាលយូរ ក៏មិនអាចដើម្បីចាប់នូវព្រះមហាសត្វ ដែលកើតហើយក្នុងកំណើតនៃក្អែក ព្រះអង្គកំពុងបំពេញនូវពោធិសម្ភារ មានកិរិយារក្សា(នូវព្រះអង្គ) ចាត់ចែងល្អហើយ ដោយព្រះបរិត្តឯណា

ព្រហ្មមន្តន្តិ អក្ខាតំ បរិត្តន្តម្ភណាម ហេ *យើងទាំងឡាយ សូធ្យឥឡូវនេះនូវព្រះបរិត្តនោះ ដែលព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ហៅថា ព្រហ្មមន្ត គឺមន្តដ៏ប្រសើរ។*

មោរបរិត្ត

(បិដកលេខ ៥៨ ទំព័រ ៧៣)

ឱទេតយញ្ហារុណោ ឯករាជា ហរិស្សវណ្ណោ បឋវិប្បភាសោ *ព្រះអាទិត្យនេះជាដួងភ្នែក (នៃលោក) ជាឯករាជ មានពណ៌ដូចជាពណ៌នៃមាស ញុំាងប្រឹថពីឱ្យភ្លឺស្វាង ហើយរះឡើង*

តំ តំ នមស្សាមិ ហរិស្សវណ្ណំ បឋវិប្បភាសំ *ព្រោះហេតុនោះ ខ្ញុំសូមនមស្ការនូវព្រះអាទិត្យនោះ ដែលមានពណ៌ ដូចជាពណ៌នៃមាស ញុំាងប្រឹថពីឱ្យភ្លឺស្វាង*

តយជ្ជ គុត្តា វិហរេមុ ទិវសំ *យើងទាំងឡាយ ដែលលោកគ្រប់គ្រងរក្សាហើយក្នុងថ្ងៃនេះ គប្បីនៅជាសុខអស់ ១ ថ្ងៃ*

យេ ព្រាហ្មណា វេទគូ សព្វធម្មេ *ព្រាហ្មណ៍ទាំងឡាយឯណា ដល់នូវវេទក្នុងធម៌ទាំងពួង*

តេ មេ នមោ តេ ច មំ បាលយន្តុ *ព្រាហ្មណ៍ទាំងឡាយនោះ (ចូរទទួល) នូវកិរិយានមស្ការរបស់ខ្ញុំ ម្យ៉ាងទៀត ព្រាហ្មណ៍ទាំងឡាយនោះ ចូររក្សានូវខ្ញុំ*

នមត្ថុ ពុទ្ធានំ នមត្ថុ ពោធិយា *សូមនមស្ការថ្វាយបង្គំ ចំពោះព្រះពុទ្ធជាម្ចាស់ទាំងឡាយ សូមនមស្ការថ្វាយបង្គំចំពោះពោធិញ្ញាណ (នៃព្រះពុទ្ធទាំងឡាយនោះ)*

នមោ វិមុត្តានំ នមោវិមុត្តិយា *សូមនមស្ការថ្វាយបង្គំចំពោះ (ព្រះពុទ្ធទាំងឡាយ[1]) ដែលទ្រង់ផុតហើយចាករាគាទិក្កិលេស សូមនមស្ការថ្វាយបង្គំចំពោះវិមុត្តិធម៌ (នៃព្រះពុទ្ធទាំងឡាយនោះ[2])។*

ឥមំ សោ បរិត្តំ កត្វា មោរោ ចរតិ ឯសនា *ក្អែកនោះ លុះតែបានធ្វើនូវព្រះបរិត្តនេះហើយ ទើបចរទៅដើម្បីស្វែងរកអាហារ។*

អបេតយញ្ជុកម្ហា ឯករាជា ហរិស្សវណ្ណោ បឋវិប្បភាសោ *ព្រះអាទិត្យនេះ ជាដួងភ្នែក (នៃលោក) ជាឯករាជ មានពណ៌ដូចជាពណ៌នៃមាស ញុំាងប្រឹថពីឱ្យភ្លឺស្វាង ហើយអស្តង្គតទៅ*

តំ តំ នមស្សាមិ ហរិស្សវណ្ណំ បឋវិប្បភាសំ *ព្រោះហេតុនោះ ខ្ញុំសូមនមស្ការនូវព្រះអាទិត្យនោះ ដែលមានពណ៌ដូចជាពណ៌នៃមាស ញុំាងប្រឹថពីឱ្យ*

១-២-សេចក្តីប្រែថ្មីក្នុងវង់ក្រចកនេះ យើងយកតាមន័យរបស់អដ្ឋកថា។

ភ្លឺស្វាង

តយជ្ជ គុត្តា ទិវារេមុ រត្តឹ *យើងទាំងឡាយ ដែលលោកគ្រប់គ្រងរក្សា ហើយក្នុងថ្ងៃនេះ គប្បីនៅជាសុខអស់ ១ រាត្រី*

យេ ព្រាហ្មណា វេទគូ សព្វធម្មេ *ព្រាហ្មណ៍ទាំងឡាយឯណា ដល់នូវវេទក្នុងធម៌ទាំងពួង*

តេ មេ ឧមោ តេ ច មំ បាលយន្តុ *ព្រាហ្មណ៍ទាំងឡាយនោះ (ចូរទទួល) នូវកិរិយានមស្ការរបស់ខ្ញុំ ម្យ៉ាងទៀត ព្រាហ្មណ៍ទាំងឡាយនោះ ចូររក្សានូវខ្ញុំ*

ឧមត្តុ ពុទ្ធានំ ឧមត្តុ ពោធិយា *សូមនមស្ការថ្វាយបង្គំ ចំពោះព្រះពុទ្ធជាម្ចាស់ទាំងឡាយ សូមនមស្ការថ្វាយបង្គំចំពោះពោធិញ្ញាណ (នៃព្រះពុទ្ធទាំងឡាយនោះ)*

ឧមោ ទិមុត្តានំ ឧមោ ទិមុត្តិយា *សូមនមស្ការថ្វាយបង្គំចំពោះ (ព្រះពុទ្ធទាំងឡាយ) ដែលទ្រង់ផុតហើយចាករាគាទិក្កិលេស សូមនមស្ការថ្វាយបង្គំចំពោះវិមុត្តិធម៌ (នៃព្រះពុទ្ធទាំងឡាយនោះ)*

ឥមំ សោ បរិត្តំ កត្វា មោរោ ឥវ សមកប្បយីតិ *ក្អែកនោះ លុះតែបានធ្វើនូវព្រះបរិត្តនេះហើយ ទើបបានសម្រេចនូវកិរិយានៅ។*

ឆជ្ជគ្គបរិត្តារម្ភោ

យស្សានុស្សរណេនាបិ អន្តលិក្ខេបិ បាណិនោ
បតិដ្ឋមធិគច្ឆន្តិ ភូមិយំ វិយ សព្វទា

សព្ពបទ្ធវជាលម្ហា យក្ខចោរាទិសម្ភវា
គណនា ន ច មុត្តានំ បរិត្តន្តម្ភណាម ហេ ៗ

សត្វទាំងឡាយ តែងបានទូវទីពឹង សូម្បីក្នុងអាកាស ក៏ដូចជាលើផែនដីដែរ សព្វ ៗ កាល សត្វទាំងឡាយ ដែលរួចហើយចាកសំណាញ់ គឺសេចក្តីឧបទ្រពគ្រប់យ៉ាង ដែលកើតអំពីសត្រូវ មានយក្ខនិងចោរជាដើម ដោយកិរិយារឭករឿយៗ នូវព្រះបរិត្តឯណា នឹងគណនាត្រាពប់ពុំបានឡើយ យើងទាំងឡាយសូមឥឡូវនេះនូវព្រះបរិត្តនោះ។

ធជគ្គបរិត្ត

(បិដកលេខ ៣០ ទំព័រ ២៤៣)

ឯវម្មេ សុតំ *(សូត្រនេះ ឈ្មោះធជគ្គសូត្រ) គឺខ្ញុំ (ឈ្មោះអានន្ទ) បានស្តាប់មកហើយយ៉ាងនេះថា*

ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ *សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី។*

តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ *ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅនូវភិក្ខុទាំងឡាយក្នុងទីនោះដូច្នេះថា* ***ភិក្ខវោ*** *ម្នាលភិក្ខុទាំងឡាយ។*

ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ *ភិក្ខុទាំងឡាយនោះ ក៏ទទួលឆ្លើយតបព្រះពុទ្ធដីកានៃព្រះដ៏មានព្រះភាគដូច្នេះថា* ***ភទន្តេ*** *បពិត្រព្រះអង្គដ៏ចម្រើន។*

ភគវា ឯតទវោច ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងនូវធជគ្គសូត្រនេះ ដោយព្រះពុទ្ធដីកាដូច្នេះថា

ភូតបុព្វំ ភិក្ខវេ ម្នាលភិក្ខុទាំងឡាយ ធ្លាប់មានរឿងពីព្រេងនាយមកថា

ទេវាសុរសង្គាមោ សមុបព្យូឡ្ហោ អហោសិ សង្គ្រាមនៃអសុរមួយអន្ទឹងដោយទេវតា ជាសង្គ្រាមតទល់ប្រកៀកគ្នាហើយ

អថខោ ភិក្ខវេ សក្កោ ទេវានមិន្ទោ ទេវេ តាវតឹ្ដសេ អាមន្តេសិ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ទេវរាជឈ្មោះថាសក្ក:ជាធំជាងទេវតាទាំងឡាយ ហៅនូវទេវតាទាំងឡាយក្នុងតាវត្តិង្សពិភពមកប្រាប់ថា

សចេ មារិសា ទេវានំ សង្គាមគតានំ ឧប្បជ្ជេយ្យ ភយំ វា ឆម្ភិតត្តំ វា លោមហំសោ វា ម្នាលអ្នកនិរទុក្ខទាំងឡាយ បើសេចក្តីខ្លាច សេចក្តីរន្ធត់ ឬសេចក្តីព្រឺរោម កើតឡើងដល់ទេវតាទាំងឡាយ ដែលទៅហើយកាន់សង្គ្រាម (ក្នុងកាលណា)

មមេវ តស្មឹ សមយេ ឆជ្ជំ ឧល្លោកេយ្យាថ អ្នកទាំងឡាយ គប្បីក្រឡេកមើលនូវចុងទង់ជ័យរបស់អញក្នុងកាលនោះកុំខានឡើយ

មមំ ហិ វោ ឆជ្ជំ ឧល្លោកយតំ ព្រោះថា កាលបើអ្នកទាំងឡាយគប្បីក្រឡេកមើលនូវចុងទង់ជ័យរបស់អញ

យម្ហិ សិ្សតិ ភយំ វា ឆម្ភិតត្តំ វា លោមហំសោ វា សេចក្តីខ្លាច សេចក្តីរន្ធត់ ឬសេចក្តីព្រឺរោមឯណានឹងកើតមាន

សោ បហិយ្យិស្សតិ *សេចក្តីខ្ជាចជាដើមនោះ នឹងសូប់រំងាប់ទៅបាន*

ឆោ ចេ មេ ឆជ្ជំ ឱលោកេយ្យាថ *បើអ្នកទាំងឡាយ មិនក្រឡេកមើលនូវចុងទង់ជ័យរបស់អញទេ*

អថ បជាបតិស្ស ទេវរាជស្ស ឆជ្ជំ ឱលោកេយ្យាថ *ក៏គប្បីក្រឡេកមើលនូវចុងទង់ជ័យនៃទេវរាជឈ្មោះបជាបតីក្នុងកាលនោះក៏បាន*

បជាបតិស្ស ហិ ឆោ ទេវរាជស្ស ឆជ្ជំ ឱលោកយតំ *ព្រោះថា កាលបើអ្នកទាំងឡាយ ក្រឡេកមើលនូវចុងទង់ជ័យនៃទេវរាជឈ្មោះបជាបតី*

យម្ហិស្សតិ តយំ វា ឆម្ហិតត្តំ វា លោមហំសោ វា *សេចក្តីខ្ជាច សេចក្តីរន្ធត់ ឬសេចក្តីព្រឺរោមឯណានឹងកើតមាន*

សោ បហិយ្យិស្សតិ *សេចក្តីខ្ជាចជាដើមនោះនឹងសូប់រំងាប់ទៅបាន*

ឆោ ចេ បជាបតិស្ស ទេវរាជស្ស ឆជ្ជំ ឱលោកេយ្យាថ *បើអ្នកទាំង-ឡាយ មិនក្រឡេកមើលនូវចុងទង់ជ័យនៃទេវរាជឈ្មោះបជាបតីទេ*

អថ វរុណស្ស ទេវរាជស្ស ឆជ្ជំ ឱលោកេយ្យាថ *ក៏គប្បីក្រឡេកមើលនូវចុងទង់ជ័យនៃទេវរាជឈ្មោះវរុណៈក្នុងកាលនោះក៏បាន*

វរុណស្ស ហិ ឆោ ទេវរាជស្ស ឆជ្ជំ ឱលោកយតំ *ព្រោះថា កាលបើអ្នកទាំងឡាយ ក្រឡេកមើលនូវចុងទង់ជ័យនៃទេវរាជឈ្មោះវរុណៈ*

យម្ហិស្សតិ តយំ វា ឆម្ហិតត្តំ វា លោមហំសោ វា *សេចក្តីខ្ជាច សេចក្តីរន្ធត់ ឬសេចក្តីព្រឺរោមឯណានឹងកើតមាន*

សោ បហិយ្យិស្សតិ *សេចក្តីខ្ជាចជាដើមនោះនឹងសូប់រំងាប់ទៅបាន*

ឆោ ចេ ទេវរាជស្ស ទេវរាជស្ស ឆជ្ជំ ឱលោកេយ្យាថ *បើអ្នកទាំង-ទ្បាយ មិនក្រឡេកមើលនូវចុងទង់ជ័យនៃទេវរាជឈ្មោះវរុណៈទេ*

អថ ឆ្លាវនស្ស ទេវរាជស្ស ឆជ្ជំ ឱលោកេយ្យាថ *ក៏គប្បីក្រឡេកមើលនូវចុងទង់ជ័យនៃទេវរាជឈ្មោះឆ្លាវនក្នុងកាលនោះក៏បាន*

ឆ្លាវនស្ស ហិ ឆោ ទេវរាជស្ស ឆជ្ជំ ឱលោកយតំ *ព្រោះថា កាលបើអ្នកទាំងទ្បាយ ក្រឡេកមើលនូវចុងទង់ជ័យនៃទេវរាជឈ្មោះឆ្លាវនៈ*

យម្ភវិស្សតិ តយំ ឆា ឆម្ភិតត្តំ ឆា លោមហំសោ ឆា *សេចក្តីខ្ជាចសេចក្តីរន្ធត់ ឬសេចក្តីព្រឺរោមឯណានឹងកើតមាន*

សោ បហិយ្យិស្សតីតិ *សេចក្តីខ្ជាចជាដើមនោះនឹងសូប់រំងាប់ទៅបាន*

តំ ឆោ បឆ តិក្ខវេ សក្កស្ស ឆា ទេវានមិន្ទស្ស ឆជ្ជំ ឱលោកយតំ *ម្នាលភិក្ខុទាំងទ្បាយ កាលបើទេវតាទាំងទ្បាយកាលក្រឡេកមើលនូវចុងទង់ជ័យនោះ នៃទេវរាជឈ្មោះសក្កៈជាធំជាងទេវតាទាំងទ្បាយក្តី*

បជាបតិស្ស ឆា ទេវរាជស្ស ឆជ្ជំ ឱលោកយតំ *កាលក្រឡេកមើលនូវចុងទង់ជ័យនោះនៃទេវរាជឈ្មោះបជាបតីក្តី*

វរុណស្ស ឆា ទេវរាជស្ស ឆជ្ជំ ឱលោកយតំ *កាលក្រឡេកមើលនូវ-ចុងទង់ជ័យនោះនៃទេវរាជឈ្មោះវរុណៈក្តី*

ឆ្លាវនស្ស ឆា ទេវរាជស្ស ឆជ្ជំ ឱលោកយតំ *កាលក្រឡេកមើល*

នូវបុងទង់ជ័យនោះនៃទេវរាជឈ្មោះឡៀសាន:ក្តី

យម្ហវិស្សតិ តយំ វា ឆម្ភិតត្តំ វា លោមហំសោ វា *សេចក្តីខ្លាច សេចក្តីរន្ធត់ ឬសេចក្តីព្រឺរោមឯណានឹងកើតមាន*

សោ បហិយ្យេថាបិ នោបិ បហិយ្យេថ *សេចក្តីខ្លាចជាដើមនោះ គប្បីស្រប់រំងាប់បានខ្លះ មិនបានខ្លះ*

តំ កិស្សហេតុ *សេចក្តីខ្លាចជាដើមដែលស្រប់រំងាប់បានខ្លះ មិនបានខ្លះនោះ ព្រោះហេតុអ្វី*

សក្កោ ហិ ភិក្ខវេ ទេវានមិន្ទោ អវីតរាគោ អវីតទោសោ អវីតមោហោ ភីរុ ឆម្ភី ឧត្រាសី បលាយីតិ *ម្នាលភិក្ខុទាំងឡាយ ព្រោះថាទេវរាជឈ្មោះសក្ក:ជាធំជាងទេវតាទាំងឡាយ មានរាគ:មិនទាន់ទៅប្រាសហើយ មានទោស:មិនទាន់ទៅប្រាសហើយ មានមោហ:មិនទាន់ទៅប្រាសហើយ ជាអ្នកនៅមានសេចក្តីខ្លាច មានសេចក្តីរន្ធត់ មានសេចក្តីស្ងុត មានកិរិយារត់ទៅជាប្រក្រតីនៅឡើយ។*

អហញ្ហ ខោ ភិក្ខវេ ឯវំ ឧត្តាមិ *ម្នាលភិក្ខុទាំងឡាយ ឯចំណែកខាងតថាគតពោលយ៉ាងនេះថា*

សចេ តុម្ហាកំ ភិក្ខវេ អរញ្ញគតានំ វា រុក្ខមូលគតានំ វា សុញ្ញាគារគតានំ វា *ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយនៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះដ៏ស្ងាត់ក្តី*

ខ្វប្បជ្ជេយ្យ តយំ វា ឆម្ភិតត្តំ វា លោមហំសោ វា *សេចក្តីខ្លាច សេចក្តីរន្ធត់ ឬសេចក្តីព្រឺរោមកើតឡើង (ក្នុងសម័យឯណា)*

មមេវ តស្មឹ សមយេ អនុស្សរេយ្យាថ *អ្នកទាំងឡាយ គប្បីរឭកតថាគត ក្នុងសម័យនោះកុំខានឡើយថា*

ឥតិបិ សោ ភគវា អរហំ *ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា **អរហំ** ព្រោះព្រះអង្គធ្លាយចាកសេចក្តីសៅហ្មងគ្រប់យ៉ាង*

សម្មាសម្ពុទ្ធោ *ទ្រង់ព្រះនាមថា **សម្មាសម្ពុទ្ធោ** ព្រោះព្រះអង្គត្រាស់ដឹងនូវ-ញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ*

វិជ្ជាចរណសម្បន្នោ *ទ្រង់ព្រះនាមថា **វិជ្ជាចរណសម្បន្នោ** ព្រោះព្រះអង្គ បរិបូណ៌ដោយវិជ្ជា និងចរណៈ*

សុគតោ *ទ្រង់ព្រះនាមថា **សុគតោ** ព្រោះព្រះអង្គមានដំណើរល្អទៅកាន់ ព្រះនិព្វាន*

លោកវិទូ *ទ្រង់ព្រះនាមថា **លោកវិទូ** ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក*

អនុត្តរោ *ទ្រង់ព្រះនាមថា **អនុត្តរោ** ព្រោះព្រះអង្គប្រសើរដោយសីលាទិ-គុណ រកបុគ្គលណាមួយស្មើគ្មាន*

បុរិសទម្មសារថិ *ទ្រង់ព្រះនាមថា **បុរិសទម្មសារថិ** ព្រោះព្រះអង្គជាអ្នក ទូន្មាននូវបុរសដែលគួរទូន្មានបាន*

សត្ថា ទេវមនុស្សានំ *ទ្រង់ព្រះនាមថា **សត្ថាទេវមនុស្សានំ** ព្រោះព្រះអង្គ*

ជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ

ពុទ្ធោ ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌

ភគវាតិ ទ្រង់ព្រះនាមថា **ភគវា** ព្រោះព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ។

មមំ ហិ តោ តិក្ខវេ អនុស្សរតំ ម្នាលភិក្ខុទាំងឡាយ ព្រោះថាកាលបើអ្នកទាំងឡាយរឭកនូវតថាគត

យម្ភទិស្សតិ ភយំ វា ឆម្ភិតត្តំ វា លោមហំសោ វា សេចក្តីខ្លាច សេចក្តីរន្ធត់ ឬសេចក្តីព្រឺពោមឯណានឹងកើតមាន

សោ បហិយ្យិស្សតិ សេចក្តីខ្លាចជាដើមនោះនឹងស្ងប់រំងាប់ទៅបាន

នោ ចេ មំ អនុស្សរេយ្យាថ បើអ្នកទាំងឡាយ មិនរឭកនូវតថាគតទេ

អថ ធម្មំ អនុស្សរេយ្យាថ ក៏គប្បីរឭកនូវព្រះធម៌ក្នុងកាលនោះថា

ស្វាក្ខាតោ ភគវតា ធម្មោ ព្រះធម៌ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងហើយដោយល្អ

សន្ទិដ្ឋិកោ ជាធម៌ គឺព្រះអរិយបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង

អកាលិកោ ជាធម៌ឱ្យផលមិនរង់ចាំកាល

ឯហិបស្សិកោ ជាធម៌គឺព្រះអរិយបុគ្គលគួរហៅអ្នកដទៃឱ្យចូលមកមើលបាន

ឱបនយិកោ ជាធម៌ គឺព្រះអរិយបុគ្គលគួរបង្អោនចូលមកទុកក្នុងចិត្តបាន

បច្ចត្តំ វេទិតព្ពោ វិញ្ញូហីតិ ជាធម៌ គឺវិញ្ញូជនទាំងឡាយគប្បីដឹងច្បាស់

ក្នុងចិត្តនៃខ្លួន ។

ធម្មំ ហិ ភោ ភិក្ខវេ អនុស្សរថ *ម្នាលភិក្ខុទាំងឡាយ ព្រោះថា កាលបើអ្នកទាំងឡាយរឭកនូវព្រះធម៌*

យម្ភវិស្សតិ វចំ វា ឆម្ភិតត្តំ វា លោមហំសោ វា *សេចក្តីខ្លាច សេចក្តីរន្ធត់ ឬសេចក្តីព្រឺពេមឯណានឹងកើតមាន*

សោ បហីយ្យិស្សតិ *សេចក្តីខ្លាចជាដើមនោះនឹងសូប់រំងាប់ទៅបាន*

នោ ចេ ធម្មំ អនុស្សរេយ្យាថ *បើអ្នកទាំងឡាយ មិនរឭកនូវព្រះធម៌ទេ*

អថ សង្ឃំ អនុស្សរេយ្យាថ *ក៏គប្បីរឭកនូវព្រះសង្ឃក្នុងកាលនោះថា*

សុបដិបន្នោ ភគវតោ សាវកសង្ឃោ *ព្រះសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ*

ឧជុបដិបន្នោ ភគវតោ សាវកសង្ឃោ *ព្រះសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយត្រង់*

ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ *ព្រះសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដើម្បីព្រះនិព្វាន*

សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ *ព្រះសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយត្រឹមត្រូវ*

យទិទំ ចត្តារិ បុរិសយុគានិ *ព្រះសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ បើរាប់ជាគូនៃបុរសមាន ៤ គូឯណា*

អដ្ឋបុរិសបុគ្គលា *បើរាប់រៀងជាបុរសបុគ្គលមាន ៨*

ឯស ភគវតោ សាវកសង្ឃោ *ព្រះសង្ឃទាំងនុ៎ះ ជាសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ*

អាហុនេយ្យោ *លោកគួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីលហើយនាំមកអំពីចម្ងាយបង្អោនចូលមកបូជា*

បាហុនេយ្យោ *លោកគួរទទួលនូវអាគន្តុកទាន គឺទានដែលបុគ្គលតាក់តែងដើម្បីញាតិ និងមិត្រ ដែលមកអំពីទិសផ្សេងៗ ហើយបង្អោនចូលមកបូជា*

ទក្ខិណេយ្យោ *លោកគួរទទួលនូវទានដែលបុគ្គលជឿនូវកម្ម និងផលនៃកម្ម ហើយបូជា*

អញ្ជលិករណីយោ *លោកគួរដល់អញ្ជលិកម្មដែលសត្វលោកគប្បីធ្វើ*

អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ *លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជគឺបុណ្យនៃសត្វលោករកខេត្តដទៃក្រៃលែងជាងគ្មាន ។*

សចេ ហិ ភោ ភិក្ខវេ អនុស្សរតំ *ម្នាលភិក្ខុទាំងឡាយ ព្រោះថា កាលបើអ្នកទាំងឡាយរឭកនូវព្រះសង្ឃ*

យម្ភវិស្សតិ ភយំ វា ឆម្ភិតត្តំ វា លោមហំសោ វា *សេចក្តីខ្លាច សេចក្តីរន្ធត់ ឬសេចក្តីព្រឺពេមឯណានឹងកើតមាន*

សោ បហិយ្យិស្សតិ *សេចក្តីខ្លាចជាដើមនោះនឹងសូប់រំងាប់ទៅបាន ។*

តំ កិស្ស ហេតុ *សេចក្តីខ្លាចជាដើមដែលសូប់រំងាប់ទៅបាននោះ ព្រោះ*

ហេតុអ្វី ?

តថាគតោ ហិ ភិក្ខវេ អរហំ សម្មាសម្ពុទ្ធោ ទីតរាគោ ទីតទោសោ ទីតមោហោ អតីរុ អច្ឆម្ភី អនុត្រាសី អបលាយីតិ *ម្នាលភិក្ខុទាំងឡាយ ព្រោះតថាគតជាព្រះអរហន្តសម្មាសម្ពុទ្ធ មានរាគៈទៅប្រាស់ហើយ មានទោសៈទៅប្រាស់ហើយ មានមោហៈទៅប្រាស់ហើយ ឥតមានសេចក្តីខ្លាច ឥតមានសេចក្តីរន្ធត់ ឥតមានសេចក្តីស្ញប់ មិនមានកិរិយារត់ទៅជាប្រក្រតីឡើយ។*

ឥទមវោច ភគវា *ព្រះដ៏មានព្រះភាគបានត្រាស់នូវព្រះពុទ្ធដីកានេះហើយ*

ឥទំ វត្វាន សុគតោ *ព្រះសុគតលុះត្រាស់នូវព្រះពុទ្ធដីកានេះហើយ*

អថបរំ ឯតទវោច សត្ថា *លំដាប់នោះ ព្រះសាស្តាទ្រង់ត្រាស់នូវពុទ្ធដីកានេះតទៅទៀតថា*

អរញ្ញេ រុក្ខមូលេ វា សុញ្ញាគារេ វា ភិក្ខវោ *ម្នាលភិក្ខុទាំងឡាយ អ្នកពាល់គ្នាកាលបើនៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះដ៏ស្ងាត់ក្តី*

អនុស្សរេថ សម្ពុទ្ធំ *គប្បីរឭកនូវព្រះសម្ពុទ្ធ*

ភយំ តុម្ហាក នោ សិយា *សេចក្តីខ្លាចនឹងមិនគប្បីមានដល់អ្នកទាំងឡាយ*

នោ ចេ ពុទ្ធំ សរេយ្យាថ លោកជេដ្ឋំ នរាសភំ
អថ ធម្មំសរេយ្យាថ និយ្យានិកំ សុទេសិតំ

បើអ្នកទាំងឡាយមិនរឭកនូវព្រះសម្ពុទ្ធដែលជាធំជាងលោក ដែលប្រសើរជាងនរជនទេ ក៏គប្បីរឭកនូវព្រះធម៌ ជាធម៌អាចដឹកនាំសត្វលោកឱ្យចេញចាកសង្សារវដ្តបាន ដែលតថាគតសម្តែងហើយដោយល្អក្នុងកាលនោះចុះ

នោ ចេ ធម្មំ សរេយ្យាថ និយ្យានិកំ សុទេសិតំ
អថ សង្ឃំ សរេយ្យាថ បុញ្ញក្ខេត្តំ អនុត្តរំ

បើអ្នកទាំងឡាយមិនរឭកនូវព្រះធម៌ ជាធម៌អាចដឹកនាំសត្វលោកឱ្យចេញចាកសង្សារវដ្តបាន ដែលតថាគតសម្តែងដោយល្អហើយ (នោះ)ទេ ក៏គប្បីរឭកនូវព្រះសង្ឃ ជាបុញ្ញក្ខេត្តនៃសត្វលោករកខេត្តដទៃប្រសើរជាងគ្មាន (នោះ) ចុះ

ឯវម្ភន្តិ សរន្តានំ ធម្មំ សង្ឃញ្ច តិក្ខត្តោ *ម្នាលភិក្ខុទាំងឡាយ អ្នកពាល់គ្នាកាលបើរឭកនូវព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃយ៉ាងនេះ*

តេសំ វា ធម្មិតត្តំ វា លោមហំសោ ន ហោស្សតីតិ *សេចក្តីខ្លាចក្តី សេចក្តីរន្ធត់ក្តី សេចក្តីព្រឺរោមក្តី នឹងមិនកើតមានឡើយ។*

ឆជ្ជគ្គសុត្តំ និដ្ឋិតំ

ឆជ្ជគ្គសូត្រចប់

អាជានាដិយបរិត្តារម្ភោ

អប្បសន្នេហិ នាថស្ស សាសនេ សាធុសម្មតេ
អមនុស្សេហិ ចណ្ឌេហិ សទា អិព្ភិសការិភិ
បរិសានញ្ច តស្សន្ត មហីសាយ ច គុត្តិយា
យន្តេសេសិ មហាវីរោ បរិត្តន្តម្ភណាម ហោ

(ព្រះសម្ពុទ្ធជាម្ចាស់) ព្រះអង្គមានសេចក្តីព្យាយាមធំ ទ្រង់ត្រាស់សម្តែង

ហើយនូវព្រះបរិត្តឯណា ដើម្បីកិរិយាមិនបៀតបៀនផង ដើម្បីគ្រប់គ្រងរក្សាផង ដល់បរិស័ទទាំងឡាយ ៤ អំពីពួកអមនុស្សកាច ៗ ដែលធ្វើតែកម្មដ៏លាមកសព្វកាល ជាអ្នកមិនជ្រះថ្លាក្នុងសាសនានៃព្រះលោកនាថ ដែលសប្បុរសសន្មតហើយថាជាសាសនាដ៏ល្អ យើងទាំងឡាយសូត្រឥឡូវនេះ នូវព្រះបរិត្តនោះ ។

អាជានាដិយបរិត្ត

(បិដកលេខ ១៩ ទំព័រ ៩៧)

វិបស្សិស្ស នមត្ថុ ច- ក្ខុមន្ធស្ស សិរីមតោ
សិខិស្សបិនមត្ថុ សព្វភូតានុកម្បិនោ ៗ

សូមនមស្ការចំពោះព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមវិបស្សី ព្រះអង្គមានចក្ខុ ព្រះអង្គមានសិរី សូមនមស្ការចំពោះព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមសិខី ព្រះអង្គមានសេចក្តីអនុគ្រោះដល់សត្វទាំងពួងជាប្រក្រតី ។

វេស្សភុស្ស នមត្ថុ ន្ហាតកស្ស តបស្សិនោ
នមត្ថុ កកុសន្ធស្ស មារសេនប្បមទ្ទិនោ ៗ

សូមនមស្ការចំពោះព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះនាមវេស្សភូ ព្រះអង្គជម្រះកិលេសចេញហើយ ព្រះអង្គមានតបៈធម៌ សូមនមស្ការចំពោះព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមកកុសន្ធៈ ព្រះអង្គញាំញីនូវមារព្រមទាំងសេនានៃមារ ។

កោនាគមនស្ស នមត្ថុ ព្រាហ្មណស្ស វុសីមតោ

កស្សបស្ស នមត្ថុ វិប្បមុត្តស្ស សព្ពធិ ៗ

សូមនមស្ការចំពោះព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះនាមកោនាគមន: ព្រះអង្គមានបាបបន្សាត់បង់ហើយ មានព្រហ្មចរិយធម៌នៅរួចហើយ សូមនមស្ការចំពោះព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះនាមកស្សប: ព្រះអង្គរួចផុតស្រឡះចាកកិលេសទាំងពួងហើយ ។

អង្គីរសស្ស នមត្ថុ សក្យបុត្តស្ស សិរីមតោ
យោ ឥមំ ធម្មមទេសេសិ សព្ទុក្ខា បនូទនំ ៗ

សូមនមស្ការចំពោះព្រះសម្មាសម្ពុទ្ធជាសក្យបុត្ត ទ្រង់មានព្រះកាយផ្សាយចេញនូវព្រះរស្មី ទ្រង់មានសិរី ដែលសម្តែងធម៌នេះ ជាគ្រឿងបន្ទោបង់សេចក្តីទុក្ខទាំងពួង ។

យេ ចាបិ និព្ពុតាលោកេ យថាភូតំ វិបស្សិសុំ
តេ ជនា អបិសុណា មហន្តា វីតសារទា ៗ

មួយទៀត ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គណា ព្រះអង្គរលត់កិលេសហើយ ទ្រង់ឃើញច្បាស់នូវធម៌តាមសេចក្តីពិតក្នុងលោក ព្រះសម្មាសម្ពុទ្ធទាំងនោះ ជាព្រះខីណាស្រព ព្រះអង្គមិនមានសេចក្តីញុះញង់ស៊ីកសៀត (ទ្រង់ប្រសើរដោយគុណ) មិនក្ងៀវក្ងាវ (ដោយកិលេស)។

ហិតំ ទេវមនុស្សានំ យំ នមស្សន្តិ គោតមំ
វិជ្ជាចរណសម្បន្នំ មហន្តំ វីតសារទំ ៗ

ទេវតា និងមនុស្សទាំងឡាយ តែងនមស្ការព្រះសម្មាសម្ពុទ្ធ ជាគោតមគោត្រ ព្រះអង្គជាប្រយោជន៍ដល់ទេវតានិងមនុស្ស ទាំងឡាយ ទ្រង់បរិបូណ៌ដោយវិជ្ជា និងចរណៈ ទ្រង់ប្រសើរ ដោយគុណ ព្រះអង្គឥតមានសេចក្តីព្រឺស្ញើប ។

យតោ ឧគ្គច្ឆតិ សុរិយោ អាទិច្ចោ មណ្ឌលី មហា
យស្ស ចុគ្គច្ឆមានស្ស សំវរីបិ និរុជ្ឈតិ ៗ

ព្រះអាទិត្យមានរស្មីដ៏ក្លៀវក្លា រះឡើងអំពីទីណា មានមណ្ឌលធំ (ក្នុងទីនោះ) កាលព្រះអាទិត្យរះឡើងហើយ រាត្រីក៏បាត់ទៅ ។

យស្ស ចុគ្គតេ សុរិយេ ទិវសោតិ បវុច្ចតិ
រហទោបិ តត្ត គម្ភីរេ សមុទ្ទោ សរិតោទកោ
ឯវន្តំ តត្ត ជានន្តិ សមុទ្ទោ សរិតោទកោ ៗ

មួយទៀត កាលព្រះអាទិត្យរះឡើងហើយ មហាជននាំគ្នា ហៅថាថ្ងៃ សូម្បីអន្ទង់ទឹកក្នុងទីដែលព្រះអាទិត្យរះឡើង នោះ ជាសមុទ្រដ៏ជ្រៅ មានទឹកហូរទៅ (ពីនទីផ្សេង ។) ជនទាំងឡាយតែងសម្គាល់នូវអន្ទង់ទឹកនោះ ត្រង់កន្លែង ដែលព្រះអាទិត្យរះឡើងនោះថាជាសមុទ្រ មានទឹកហូរ ទៅយ៉ាងនេះ ។

ឥតោ សា បុរិមា ទិសា ឥតិ នំ អាចិក្ខតី ជនោ
យំ ទិសំ អភិបាលេតិ មហារាជា យសស្សិសោ
គន្ធព្ពានំ អាធិបតិ ធតរដ្ឋោ ឥតិ នាមសោ

រមតី ឧច្ចគីតេហិ គន្ធព្វេហិ បុរក្ខតោ ៗ

ស្តេចជាធំដ៏ទ្រង់យសទ្រង់រក្សាទិសណា មហាជនតែង ហៅទិសនោះថាបុរិមទិសអំពីក្នុងសិនេរុនោះ ទ្រង់ជាអធិបតី លើគន្ធព្វទាំងឡាយ មានព្រះនាមថាធតរដ្ឋៈ មានពួក គន្ធព្វហែហម ទ្រង់ត្រេកត្រអាលដោយរបាំ និងចម្រៀង។

បុត្តា បិតស្ស ពហវោ ឯកនាមាតិ មេ សុតំ
អសីតិ ឧស ឯកោ ច ឥន្ទនាមា មហព្ពលា
តេ ចាបិ ពុទ្ធំ ឧិស្វាន ពុទ្ធំ អាទិច្ចពន្ធុនំ
ទូរតោ ឥ ឧមស្សន្តិ មហន្តំ វីតសារទំ ៗ

ព្រះរាជបុត្តរបស់ស្តេចជាធំនោះមានច្រើនដល់ម៉្លោះ ខ្ញុំព្រះអង្គ បានស្តាប់មកថា មាននាមដូច ៗ គ្នា ព្រះរាជបុត្តទាំង ៩១ ព្រះអង្គ សឹងមាននាមថាឥន្ទៈមានកំឡាំងច្រើន ឯព្រះរាជបុត្ត ទាំងនោះ ឃើញព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ភ្លាក់អំពីការ ដេកលក់គឺអវិជ្ជា ទ្រង់ប្រសើរ(ដោយគុណ)ឥតមានសេចក្តី ព្រឺស្ញើប ក៏នមស្ការអំពីចម្ងាយ។

ឧមោ តេ បុរិសាជញ្ញោ ឧមោ តេ បុរិសុត្តម
កុសលេន សមេក្ខសិ អមនុស្សាបិ តំ វន្ទន្តិ ៗ
សុតំ ឧេតំ អភិណ្ហសោ តស្មា ឯវំ វទេម្ហសេ

បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំព្រះអង្គសូមនមស្ការ ចំពោះព្រះអង្គ បពិត្រព្រះអង្គជាបុរសខ្ពង់ខ្ពស់ ខ្ញុំព្រះអង្គ

សូមនមស្ការចំពោះព្រះអង្គ សូម្បីអមនុស្សទាំងឡាយ ក៏រមែងថ្វាយបង្គំព្រះអង្គថា ព្រះអង្គទតព្រះនេត្រមើលមហាជនដោយសព្វញ្ញុតញ្ញាណដ៏ផូរផង់។ ពួកខ្ញុំព្រះអង្គបានស្តាប់មកយ៉ាងនេះរឿយៗ ព្រោះហេតុនោះពួកខ្ញុំព្រះអង្គតែងនិយាយយ៉ាងនេះថា

ជិនំ វន្ទថ គោតមំ ជិនំ វន្ទាម គោតមំ
វិជ្ជាចរណសម្បន្នំ ពុទ្ធំ វន្ទាម គោតមំ ៥

អ្នកទាំងឡាយ ថ្វាយបង្គំព្រះជិនស្រី ដែលជាគោតមគោត្រឬ (ព្រះរាជបុត្រទាំងនោះតបថា) យើងខ្ញុំទាំងឡាយ ថ្វាយបង្គំព្រះជិនស្រីជាគោតមគោត្រ យើងខ្ញុំទាំងឡាយថ្វាយបង្គំព្រះពុទ្ធជាគោតមគោត្រ ទ្រង់បរិបូណ៌ដោយវិជ្ជា និងចរណៈ។

យេន បេតា បតុច្ចន្តិ បិសុណា បិដ្ឋមំសិកា
ឆាឆាតិឆាតិនោ លុទ្ធា ចោរា ឆេកតិកា ជនា ៥

ជនជាអ្នកមានពាក្យញុះញង់ស៊ីកសៀត ជាអ្នកតិះដៀលគេក្នុងទីកំបាំងមុខ ដូចជាជនអ្នកស៊ីសាច់ខ្លែង ជាអ្នកសម្លាប់សត្វ ជាអ្នកធ្វើអំពើអាក្រក់ ជាចោរ ជាមនុស្សមានកលល្បួង ជនទាំងនោះ លុះធ្វើកាលកិរិយាទៅហើយ គេតែងថា (ឱ្យនាំទៅ) តាមទិសណា។

តំតោ សា ឧក្កិណា ឯសា ឥតិ នំ អាចិក្ខតី ជនោ

យំ ទិសំ អភិបាលេតិ មហារាជា យសស្សិនោ
កុម្ភណ្ឌានំ អាធិបតិ វិរុឡ្ហោ តាម សោ
រមតី នច្ចគីតេហិ កុម្ភណ្ឌេហិ បុរក្ខតោ ។

ស្តេចជាធំទ្រង់យស ទ្រង់រក្សានូវទិសណា មហាជនតែងនាំគ្នាហៅទិសនោះថាទក្ខិណាទិស (រាប់) អំពីភ្នំសិនេរុមក ស្តេចនោះជាអធិបតីលើកុម្ភណ្ឌទាំងឡាយ ទ្រង់ព្រះនាមវិរុឡ្ហៈ ដែលមានពួកកុម្ភណ្ឌចោមរោមហើយ ទ្រង់ត្រេកអរដោយរបាំ និងចម្រៀងទាំងឡាយ។

បុត្តាបិ តស្ស ពហវោ ឯកនាមាតិ មេ សុតំ
អសីតិ ទស ឯកោ ច ឥន្ទនាមា មហព្ពលា
តេ ចាបិ ពុទ្ធំ ទិស្វាន ពុទ្ធំ អាទិច្ចពន្ធុនំ
នូរតោ ឥ ឧមស្សន្តិ មហន្តំ វីតសារទំ ។

ព្រះរាជបុត្តរបស់ស្តេចជាធំនោះ មានច្រើនដល់ម៉្លោះ ខ្ញុំព្រះអង្គបានស្តាប់មកថាមាននាមដូចៗគ្នា ព្រះរាជបុត្តទាំង ៩១ ព្រះអង្គសឹងមាននាមថាឥន្ទៈ មានកំឡាំងច្រើន ឯព្រះរាជបុត្តទាំងនោះឃើញព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ភ្លាក់អំពីការដេកលក់ គឺអវិជ្ជា ទ្រង់ប្រសើរ (ដោយគុណ) ឥតមានសេចក្តីព្រឺស្ញើប ក៏នមស្ការអំពីចម្ងាយ ។

ឧមោ តេ បុរិសាជញ្ញ ឧមោ តេ បុរិសុត្តម
កុសលេន សមេក្ខសិ អមនុស្សាបិ តំ វន្ទន្តិ ។
សុតំ ឧេតំ អភិណ្ហសោ តស្មា ឯវំ វទេម្ហសេ

បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំព្រះអង្គសូមមនស្ការ ចំពោះព្រះអង្គ បពិត្រព្រះអង្គជាបុរសឧត្តម សូម្បីអមនុស្ស ទាំងឡាយ ក៏រមែងថ្វាយបង្គំព្រះអង្គថា ព្រះអង្គទតព្រះនេត្រ មើលមហាជនដោយសព្វញ្ញុតញ្ញាណដ៏ផូរផង់។ ខ្ញុំព្រះអង្គ បានស្តាប់មកយ៉ាងនេះរឿយៗ ព្រោះហេតុនោះ ពួកខ្ញុំព្រះអង្គ និយាយយ៉ាងនេះថា

ជិនំ វន្ទថ គោតមំ ជិនំ វន្ទាម គោតមំ
វិជ្ជាចរណសម្បន្នំ ពុទ្ធំ វន្ទាម គោតមំ ។

អ្នកទាំងឡាយ នមស្ការចំពោះព្រះជិនស្រីជាគោតមគោត្រឬ (ព្រះរាជបុត្រទាំងនោះតបថា) យើងទាំងឡាយថ្វាយបង្គំ ព្រះជិនស្រីជាគោតមគោត្រ យើងទាំងឡាយថ្វាយបង្គំព្រះ-សម្ពុទ្ធជាគោតមគោត្រ ទ្រង់បរិបូណ៌ដោយវិជ្ជា និងចរណៈ។

យត្ថ ចោគ្គច្ឆតិ សុរិយោ អាទិច្ចោ មណ្ឌលី មហា
យស្ស ចោគ្គច្ឆមានស្ស ទិវសោបិ និរុជ្ឈតិ
យស្ស ចោគ្គតេ សុរិយេ សំវរីតិ បវុច្ចតិ ។

ព្រះអាទិត្យមានរស្មីដ៏ភ្លឺរុងរឿង អស្តង្គតទៅក្នុងទីណា មានមណ្ឌលដ៏ធំក្នុងទីនោះ កាលដែលព្រះអាទិត្យអស្តង្គតទៅហើយ ពេលថ្ងៃក៏អស់ទៅ កាលបើព្រះអាទិត្យអស្តង្គតទៅហើយ មហាជននាំគ្នាហៅថា យប់។

រហោបិ តត្ត គម្ភីរោ សមុទ្ទោ សរិតោទកោ

ឯវន្តំ តត្ថ ជានន្តិ សមុទ្ទោ សរិតោទកោ ៚

សូម្បីអន្ទង់ទឹកត្រង់កន្លែងដែលព្រះអាទិត្យអស្តង្គតនោះ ជាសមុទ្រដ៏ជ្រៅ មានទឹកហូរទៅ ជនទាំងឡាយ តែងសម្គាល់នូវអន្ទង់ទឹកនោះ ត្រង់កន្លែងដែលព្រះអាទិត្យអស្តង្គតនោះថាជាសមុទ្រ មានទឹកហូរទៅយ៉ាងនេះ។

ឥតោ សា បច្ឆិមា ទិសា ឥតិ នំ អាចិក្ខតី ជនោ
យំ ទិសំ អភិបាលេតិ មហារាជា យសស្សិនោ
នាគានំ អាធិបតិ វិរូបក្ខោ ឥតិ នាមសោ
រមតី ឆច្ចគីតេហិ នាគេហិ បុរក្ខតោ ៚

ស្តេចជាធំទ្រង់យស ទ្រង់រក្សាទិសណា មហាជនតែងហៅទិសនោះថាបច្ឆិម:អំពីភ្នំសិនេរុមក ស្តេចជាធំនោះជាអធិបតីលើនាគទាំងឡាយ ទ្រង់ព្រះនាមថាវិរូបក្ខ: ដែលមានពួកនាគចោមរោមហើយ ទ្រង់ត្រេកអរដោយពួករបាំ និងចម្រៀង។

បុត្តាបិ តស្ស ពហវោ ឯកនាមាតិ មេ សុតំ
អសីតិ ទស ឯកោ ច ឥន្ទនាមា មហាពលា
តេចាបិ ពុទ្ធំ ទិស្វាន ពុទ្ធំ អាទិច្ចពន្ធុនំ
ទូរតោ ឥ ឧបសង្កន្តិ មហន្តំ វីតសារទំ ៚

ព្រះរាជបុត្តរបស់ស្តេចជាធំនោះមានច្រើនដល់ម្ភៃ ខ្ញុំព្រះអង្គបានស្តាប់មកថាមាននាមដូច ៗ គ្នា ព្រះរាជបុត្តទាំង ៩១ ព្រះអង្គសឹងមាននាមថាឥន្ទ: មានកំឡាំងច្រើន ឯព្រះរាជបុត្តទាំងនោះ

ឃើញព្រះពុទ្ធជាអាទិច្ចវង្សទ្រង់ភ្លាក់អំពីការដេកលក់ គឺអវិជ្ជា ទ្រង់ប្រសើរ (ដោយគុណ) ឥតមានសេចក្តីព្រឺស្ញើប ក៏នមស្ការអំពីចម្ងាយ ។

នមោ តេ បុរិសាជញ្ញ នមោ តេ បុរិសុត្តម
កុសលេន សមេក្ខសិ អមនុស្សាបិ តំ វន្ទន្តិ
សុតំ នេតំ អភិណ្ហសោ តស្មា ឯវំ វទេម្ហសេ ។

បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំព្រះអង្គសូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គជាបុរសខ្ពង់ខ្ពស់ ខ្ញុំព្រះអង្គសូមនមស្ការចំពោះព្រះអង្គ សូម្បីអមនុស្សទាំងឡាយក៏រមែងថ្វាយបង្គំព្រះអង្គថា ទ្រង់ទតព្រះនេត្រមើលមហាជន ដោយសព្វញ្ញុតញ្ញាណដ៏ផូរផង់ ។ ពួកខ្ញុំព្រះអង្គបានស្តាប់មកយ៉ាងនេះរឿយៗ ព្រោះហេតុនោះ ខ្ញុំព្រះអង្គតែងនិយាយយ៉ាងនេះថា

ជិនំ វន្ទថ គោតមំ ជិនំ វន្ទាម គោតមំ
វិជ្ជាចរណសម្បន្នំ ពុទ្ធំ វន្ទាម គោតមំ ។

អ្នកទាំងឡាយ នមស្ការចំពោះព្រះជិនស្រីជាគោតមគោត្រឬ (ព្រះរាជបុត្រទាំងនោះតបថា) ខ្ញុំទាំងឡាយ នមស្ការចំពោះព្រះជិនស្រីជាគោតមគោត្រ យើងខ្ញុំទាំងឡាយនមស្ការព្រះពុទ្ធជាគោតមគោត្រ ទ្រង់បរិបូណ៌ដោយវិជ្ជា និងចរណៈ ។

យេន ខ្ត្តរកុរូ រម្មា មហាឆេរូ សុទស្សនោ

មនុស្សា តត្ថ ជាយន្តិ អមមា អបរិគ្គហា ៗ

ឧត្តរកុរុទ្វីប ជាទីរីករាយ មានភ្នំសិនេរុដ៏ធំ គួរជាទីមើល តាំងនៅក្នុងទិសណា ពួកមនុស្សកើតក្នុងឧត្តរកុរុទ្វីបនោះ ឥតមានប្រកាន់របស់អ្វីថាជារបស់ខ្លួនឡើយ ។

ន តេ ពីជំ បវប្បន្តិ នបិ នីយន្តិ ន្តលា
អកដ្ឋបាកិមំ សាលឹ បរិភុញ្ជន្តិ មានុសា
អកណំ អថុសំ សុទ្ធំ សុគន្ធំ តណ្ឌុលប្ផលំ
តុណ្ហីភិរេ បចិត្វាន តតោ ភុញ្ជន្តិ ភោជនំ ៗ

មនុស្សទាំងអម្បាលនោះ មិនបាច់ព្រោះពូជ មិនបាច់នាំនង្គ័លចេញទៅ (ដោយគិតថា អាត្មានឹងភ្ជួរក្នុងទីនោះៗ) បរិភោគតែស្រូវសាលី ដែលកើតឯងក្នុងព្រៃ ជាស្រូវមិនមានកុណ្ឌក មិនមានអង្កាម ស្អាត មានក្លិនក្រអូប ផ្ទៃចេញជាអង្ករ មនុស្សទាំងឡាយដាក់អង្ករនោះក្នុងផ្នាំង ចម្អិនដោយភ្លើងឥតផ្សែង មិនមានរងើក ទើបនាំគ្នាបរិភោគភោជនអំពីផ្នាំងនោះ ។

គាវី ឯកខុរំ កត្វា អនុយន្តិ ឯិសោ ឯិសំ
បសុំ ឯកខុរំ កត្វា អនុយន្តិ ឯិសោ ឯិសំ ៗ

មនុស្សទាំងនោះ ទឹមនូវមេគោមានក្របកតែមួយ (ដូចក្របកសោះ) បរទៅសព្វទិស ទឹមបសុសព្វ (សត្វមានជើងបួនក្រៅពីគោ) មានក្របកតែមួយ បរទៅសព្វទិស។

ឥត្ថី ភាហរំ កត្វា អនុយន្តិ ឯិសោ ឯិសំ

បុរិសំ វាហនំ កត្វា អនុយន្តិ ទិសោ ទិសំ ฯ

យកស្រីធ្វើជាវាហនៈត្រាច់ទៅសព្វទិស យកប្រុសធ្វើជាវាហនៈត្រាច់ទៅសព្វទិស ។

កុមារឹ វាហនំ កត្វា អនុយន្តិ ទិសោ ទិសំ

កុមារំ វាហនំ កត្វា អនុយន្តិ ទិសោ ទិសំ ฯ

យកកុមារីធ្វើជាវាហនៈត្រាច់ទៅសព្វទិស យកកុមារធ្វើជាវាហនៈត្រាច់ទៅសព្វទិស ។

តេ យានេ អភិរុហិត្វា សព្ពា ទិសា អនុបរិយន្តិ

បចារ តស្ស រាជិនោ ฯ

មនុស្សទាំងអម្បាលនោះ នាំគ្នាឡើងយានត្រាច់ទៅក្នុងទិសទាំងពួង ពួកស្រីទាំងឡាយ ជាអ្នកបម្រើស្តេចនោះ ។

ហត្ថិ យានំ អស្សយានំ ទិព្ពំ យានំ ឧបដ្ឋិតំ

ឆាសាឆ សិវិកា ចេវ មហារាជស្ស យសស្សិនោ ฯ

យានដំរី យានសេះ យានជាទិព្វ ប្រាសាទ និងវរ៍[1] ក៏មានសម្រាប់ស្តេចជាធំដ៏ទ្រង់យស ។

តស្ស ច នគរ អហុ អន្តលិក្ខេ សុមាបិតា

អាជានាជ កុសិនាជ បរកុសិនាជ នាដបរិយា បរកុសិតនាជ ฯ

មួយទៀត ស្តេចនោះទ្រង់សាងនគរទុកក្នុងអាកាស គឺអាដានាដានគរ កុសិនាដានគរ បរកុសិនាដានគរ នាដបរិយានគរ បរកុសិតនាដានគរ ។

ឧត្តរេន កបិវណ្ណោ ជនោឃមបរេន ច

๑-ត្រែស្នែង។

ឧឫឧឫវតិយោ អម្ពរអម្ពរវតិយោ អាឡកមន្ទា នាម រាជធានី ។

សាវ័នគរឈ្មោះកបិវន្តក្នុងទិសខាងជើង ក្នុងចំណែកទិសដទៃទៀត បានសាវ័នគរឈ្មោះជនោយៈ ឈ្មោះនវនវតិយៈ ឈ្មោះអម្ពរអម្ពរ-វតិយៈ និងរាជធានីឈ្មោះអាឡកមន្ទា។

កុវេរស្ស ខោ បន មារិស មហារាជស្ស វិសាណា នាម រាជធានី
តស្មា កុវេរោ មហារាជា វេស្សវណោតិ បវុច្ចតិ ។

បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ស្តេចជាធំឈ្មោះកុវេរៈ មានរាជធានីឈ្មោះវិសាណា ព្រោះហេតុនោះ ស្តេចជាធំទ្រង់ព្រះនាមកុវេរៈ មហាជននាំគ្នាហៅថា វេស្សវណ ។

បច្ចេសន្តោ បកាសេន្តិ តគោលា តត្តលា តគោតលា
ឱជសី តេជសី តគោជសី សុវោ រាជា អរិដ្ឋោ នេមិ ។

ពួកយក្ខឈ្មោះ តគោលា តត្តលា តគោតលា ឱជសី តេជសី តគោជសី សុវោ រាជា អរិដ្ឋ នេមិ តែងត្រួតត្រា ប្រកាសនូវប្រយោជន៍ផ្សេងៗ ។

រហទោបិ តត្ត ឆរណី នាម យតោ មេឃា បវស្សន្តិ
វស្សា យតោ បតាយន្តិ សតាបិ តត្ត តគលវតី នាម។

មួយទៀត ភ្លៀងនាំទឹកអំពីស្រះបោក្ខរណីណា ហើយបង្អុរចុះ ភ្លៀងហូរចេញអំពីទីណា ត្រង់ទីនោះឯង មានអន្ទង់ទឹកឈ្មោះឆរណី ពួកយក្ខតែងអង្គុយប្រជុំគ្នាក្នុងទីណា ត្រង់ទីនោះឯងមានសភា ឈ្មោះកគលវតី ។

យត្តយក្ខា បយិរុឃាសន្តិ
តត្ត និច្ចផលា រុក្ខា
នានា ទិជគណា យុតា
មយូរកោញ្ចាភិរុទា
កោកិលាភិហិ ឥត្តភិ ។

ត្រង់ទីនោះមានដើមឈើផ្លែជានិច្ច ដេរដាសដោយហ្វូងបក្សីផ្សេងៗ កងរំពងដោយសំឡេងសត្វក្អែក សត្វក្រៀល (ព្រមទាំង) ពួកសត្វតារៅ មានសំឡេងពីពោះ ។

ជីវញ្ជីវកសទ្ទេត្ត អថោ ឱដ្ឋវចិត្តកា
កុក្កុដកា កុឡីរកា ឥណេ ចោក្ខរសាតកា ។

សំឡេងបក្សីឈ្មោះជីវញ្ជីវក: ក៏មានក្នុងទីនុ៎ះ មួយទៀត ពួកបក្សីឈ្មោះឱដ្ឋវចិត្តក: ហ្វូងមាន់ព្រៃ ក្តាម និងហ្វូងសត្វចោក្ខរសាតក: ក៏អាស្រ័យនៅក្នុងត្រពាំងឈូក ។

សុកសារិកសទ្ទេត្ត ទណ្ឌមានវកានិ ច
សោភតិ សព្វកាលំ សា កុវេរនឡិនី សទា ។

ម្យ៉ាងទៀត សំឡេងសត្វសេក និងសារិកាក៏មានក្នុងទីនោះ មានទាំងពួកបក្សីឈ្មោះទណ្ឌមានវក: ស្រះឈូករបស់ស្តេចកុវេរៈនោះ ជាស្រះល្អសព្វកាលឥតចន្លោះ ។

ឥតោ សា ឱត្តរា ទិសា ឥតិ នំ អាចិក្ខតី ជនោ
យំ ទិសំ អតិបាលេតិ មហារាជា យសស្សិ សោ
យក្ខានំ អធិបតិ កុវេរោ ឥតិ នាមសោ

រមតី នច្ចគីតេហិ យក្ខេហិ បុរក្ខតោ ។

ស្តេចជាធំទ្រង់យស ទ្រង់អភិបាលទិសណា មហាជនតែងនាំគ្នា ហៅទិសនោះថា ឧត្តរទិស រាប់អំពីភ្នំសិនេរុមក។ ព្រះអង្គជាអធិបតីលើពួកយក្ខ ទ្រង់ព្រះនាមថា កុវេរៈ ដែលមានពួកយក្ខចោមរោមហើយ ទ្រង់ត្រេកត្រអាលដោយពួករបាំនិងចម្រៀង។

បុត្តាបិ តស្ស ពហវោ ឯកនាមាតិ មេ សុតំ
អសីតិ ទស ឯកោ ច តំនាមា មហព្ពលា ។
តេ ចាបិ ពុទ្ធំ និស្សាន ពុទ្ធំ អាទិច្ចពន្ធនំ
ទូរតោវ នមស្សន្តិ មហន្តំ វីតសារទំ ។

ព្រះរាជបុត្តរបស់ស្តេចជាធំនោះមានច្រើនដល់ម៉្លោះ ខ្ញុំព្រះអង្គបានស្តាប់មកថាមាននាមដូច ៗ គ្នា ព្រះរាជបុត្តទាំង ៩១ ព្រះអង្គសឹងមាននាមថាតន្ទៈ មានកំឡាំងច្រើន។ ឯព្រះរាជបុត្តទាំងនោះឃើញព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ភ្លាក់អំពីការដេកលក់ គឺអវិជ្ជា ទ្រង់ប្រសើរ (ដោយគុណ) ឥតមានសេចក្តីព្រឺស្ញើប ក៏នមស្ការអំពីចម្ងាយ។

នមោ តេ បុរិសាជញ្ញ នមោ តេ បុរិសុត្តម
កុសលេន សមេក្ខសិ អមនុស្សាបិ តំ វន្ទន្តិ
សុតំ នេតំ អភិណ្ហសោ តស្មា ឯវំ វទេមសេ ។

បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំព្រះអង្គសូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គជាបុរសឧត្តម ខ្ញុំព្រះអង្គ

សូមនមស្ការចំពោះព្រះអង្គ សូម្បីអមនុស្សទាំងឡាយ ក៏រមែងថ្វាយបង្គំព្រះអង្គថា ព្រះអង្គទតព្រះនេត្រមើលមហាជន ដោយសព្វញ្ញុតញ្ញាណដ៏ធូរធង់។ ពួកខ្ញុំព្រះអង្គបានស្តាប់មកយ៉ាងនេះរឿយ។ ព្រោះហេតុនោះ ពួកខ្ញុំព្រះអង្គតែងនិយាយយ៉ាងនេះថា

ជិនំ វន្ទថ គោតមំ ជិនំ វន្ទាម គោមតមំ
វិជ្ជាចរណសម្បន្នំ ពុទ្ធំ វន្ទាម គោតមន្តិ ៗ

អ្នកទាំងឡាយនមស្ការចំពោះព្រះជិនស្រី ជាគោតមគោត្រឬ ព្រះរាជបុត្តទាំងនោះតបថា យើងទាំងឡាយនមស្ការចំពោះព្រះជិនស្រី ជាគោតមគោត្រ យើងទាំងឡាយនមស្ការចំពោះព្រះពុទ្ធជាគោតមគោត្រ ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ។

អាជានាជិយបរិត្តំ និដ្ឋិតំ

អាជានាដិយបរិត្ត ចប់

អង្គុលិមាលបរិត្តារម្ភោ

បរិត្តំ យម្ភណន្តស្ស និសិន្នដ្ឋានចោទនំ
ខ្ទកម្បិ វិនាសេតិ សព្ពមេវ បរិស្សយំ

ទឹកដែលលាងនូវទីអង្គុយនៃព្រះអង្គុលិមាលត្ថេរ ដែលលោកពោលនូវ

ព្រះបរិត្តឯណា អាចញុំាងសេចក្តីអន្តរាយគ្រប់យ៉ាងឱ្យវិនាសទៅ

សោត្ថិនា គព្ភភុជ្ជានំ យញ្ច សាធេតិ តំខណេ
ថេរស្សង្គុលិមាលស្ស លោកនាថេន ភាសិតំ

ម្យ៉ាងទៀត ព្រះបរិត្តឯណា ដែលព្រះលោកនាថត្រាស់សម្តែងហើយដល់ព្រះអង្គុលិមាលត្ថេរ ញុំាងកិរិយាប្រសូតបុត្តឱ្យសម្រេចដោយសិរីសួស្តី ក្នុងខណៈនោះបាន

កប្បដ្ឋាយិមហាតេជំ បរិត្តន្តម្ភណាម ហេ *យើងទាំងឡាយសូត្រឥឡូវនេះនូវព្រះបរិត្តនោះ ដែលជាធម៌តាំងនៅអស់កប្ប ជាធម៌មានតេជៈច្រើន ។*

អង្គុលិមាលបរិត្ត

(បិដកលេខ ២៤ ទំព័រ ៤៣២)

យតោហំ ភគិនិ អរិយាយ ជាតិយា ជាតោ *ម្នាលប្អូនស្រី តាំងអំពីអាត្មាកើតហើយដោយអរិយជាតិ*

នាភិជានាមិ សញ្ចិច្ច បាណំ ជីវិតា វោរោបេតា *មិនចេះក្លែងផ្តាច់ផ្តិលជីវិតសត្វឡើយ ។*

តេន សច្ចេន សោត្ថិ តេ *ដោយពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមានដល់អ្នក*

ហោតុ សោត្ថិ គព្ភស្ស *សូមសិរីសួស្តីកើតមានដល់គភ៌ (នៃនាង) ។*

ពោជ្ឈង្គបរិត្តរម្ភោ

សំសារេ សំសរន្តានំ សព្វទុក្ខវិនាសនេ
សត្ត ធម្មេ ច ពោជ្ឈង្គេ មារសេនប្បមទ្ទិនោ
ពុជ្ឈិត្វា យេបិមេ សត្តា តិភវា មុត្តកុត្តមា

សត្វទាំងឡាយឯណា ជាបុគ្គលឧត្តម រួចផុតចាកត្រៃភព ព្រោះត្រាស់ដឹងនូវធម៌ទាំងឡាយ ៧ ឈ្មោះពោជ្ឈង្គ គឺធម៌ជាអង្គនៃកិរិយាត្រាស់ដឹង ជាធម៌អាចញុំាងទុក្ខទាំងពួងរបស់សត្វទាំងឡាយដែលកំពុងអន្ទោលទៅក្នុងសំសារវដ្ត ឱ្យវិនាស ជាធម៌អាចញុំាញីនូវមារ និងសេនានៃមារ

អថាតឺ អថរញ្ជាឆឺ អមតំ និព្ពុយំ គតា (*សត្វទាំងឡាយនោះ*) *ឈ្មោះថាដល់នូវព្រះនិព្វាន ជាគុណជាតិឥតមានកំណើត ឥតមានជរ និងព្យាធិ ឥតមានសេចក្តីស្លាប់ ឥតមានភ័យ*

ឯវមាទិគុណូបេតំ អនេកគុណសង្គហំ
ឱសថញ្ច ឥមំ មន្តំ ពោជ្ឈង្គន្តម្ភណាម ហោ

យើងទាំងឡាយ សូមឥឡូវនេះ នូវមន្តនេះ ឈ្មោះថាពោជ្ឈង្គបរិត្ត ទុកដូចជាថ្នាំរំងាប់រោគដ៏ប្រាកដ សង្គ្រោះយកនូវគុណជាអនេក ប្រកបដោយគុណមានយ៉ាងនេះជាដើម។

ពោជ្ឈង្គបរិត្ត[1]

(បិដកលេខ ៣៧ ទំព័រ ២០៥)

ពោជ្ឈង្គោ សត្តិសង្ខាតោ ធម្មានំ វិចយោ តថា
វីរិយម្បីតិបស្សទ្ធិ ពោជ្ឈង្គា ច តថាបរេ
សមាធុបេក្ខាពោជ្ឈង្គា សត្តេតេ សព្ពទស្សិនា
មុនិនា សម្មទក្ខាតា ភាវិតា ពហុលីកតា

ពោជ្ឈង្គទាំងឡាយ ៧ ប្រការនេះ គឺសតិសម្ពោជ្ឈង្គ ១ ធម្មវិចយសម្ពោជ្ឈង្គ ១ វីរិយសម្ពោជ្ឈង្គ ១ បីតិសម្ពោជ្ឈង្គ ១ បស្សទ្ធិសម្ពោជ្ឈង្គ ១ សមាធិសម្ពោជ្ឈង្គ ១ ឧបេក្ខាសម្ពោជ្ឈង្គ ១ ដែលព្រះមុនីជាម្ចាស់ទ្រង់ជ្រាបនូវធម៌ទាំងពួងត្រាស់សម្តែងហើយដោយប្រពៃ គឺបុគ្គលចម្រើនហើយ ធ្វើឱ្យច្រើនហើយ

សំវត្តន្តិ អភិញ្ញាយ និព្វានាយច ពោធិយា *តែងប្រព្រឹត្តទៅដើម្បីសេចក្តីដឹងក្រៃពេកផង ដើម្បីកិរិយាចេញចាកតណ្ហាផង ដើម្បីកិរិយាត្រាស់ដឹងផង*

ឯតេន សច្ចវជ្ជេន សោត្ថិ តេ ហោតុ សព្ពទា *ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមានដល់អ្នកសព្វ ៗ កាល*

ឯកស្មឹ សមយេ នាថោ មោគ្គល្លានញ្ច កស្សបំ
គិលានេ ទុក្ខិតេ ទិស្វា ពោជ្ឈង្គេ សត្ត ទេសយិ

ក្នុងសម័យមួយ ព្រះលោកនាថជាម្ចាស់ ទ្រង់ឃើញនូវព្រះមោគ្គល្លាននិងព្រះកស្សបៈមានជំងឺ ដល់នូវទុក្ខវេទនា ហើយទ្រង់សម្តែងនូវពោជ្ឈង្គទាំងឡាយ

១-ពាក្យដើមឈ្មោះថា **គិលានសូត្រ** មាន ៣ សូត្រ គឺបឋមគិលានសូត្រ ទុតិយគិលានសូត្រ និងតតិយគិលានសូត្រ ។

៧ ប្រការ

តេ ចតំ អភិនន្ទិត្វា រោគា មុញ្ចិំសុ តំខណេ *ព្រះថេរៈទាំងពីរអង្គនោះ ក៏រីករាយចំពោះព្រះពុទ្ធភាសិតនោះ ហើយបានជាសះស្បើយចាករោគក្នុងមួយរំពេចនោះ*

ឯតេន សច្ចវជ្ជេន សោត្ថិ តេ ហោតុ សព្វទា *ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមានដល់អ្នកសព្វ ៗ កាល ។*

ឯកទា ធម្មរាជាបិ គេលញ្ញេនាតិបីឡិតោ *ក្នុងគ្រាមួយ ព្រះសម្ពុទ្ធជាព្រះធម្មរាជ ដែលគិលានរោគបៀតបៀនហើយ*

ចុន្ទត្ថេរេន តញ្ញេវ តណាបេត្វាន សាទរំ *ទ្រង់ត្រាស់ប្រើព្រះចុន្ទត្ថេរឱ្យសម្តែងនូវពោជ្ឈង្គនោះដែរ ដោយអើពើហើយ*

សម្ពោធិត្វា ច អាពាធា តម្ហា ឧដ្ឋាសិ ឋានសោ *ទ្រង់រីករាយហើយជា-សះស្បើយចាកអាពាធនោះក្នុងមួយរំពេចនោះ*

ឯតេន សច្ចវជ្ជេន សោត្ថិតេ ហោតុ សព្វទា *ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមានដល់អ្នកសព្វ ៗ កាល ។*

បហីនា តេ ច អាពាធា តិណ្ណន្នម្បិ មហេសិនំ *ក៏អាពាធទាំងឡាយនោះ ដែលព្រះអរិយបុគ្គលទាំង ៣ ព្រះអង្គ លោកជាអ្នកស្វែងរកនូវគុណធម៌ដ៏ធំលះបង់ គឺថាលោកបានជាសះស្បើយហើយ*

មគ្គាហតកិលេសា ច បត្តានុប្បត្តិធម្មតំ *ដល់ហើយនូវធម្មតា គឺកិរិយាមិន*

កើត (ទៀត) ដូចជាកិលេសដែលព្រះអរិយបុគ្គលកម្ចាត់ហើយដោយព្រះអរិយមគ្គ

ឯតេន សច្ចវជ្ជេន សោត្ថិ តេ ហោតុ សព្វទា *ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ សូមសិរីសួស្តីកើតមានដល់អ្នកសព្វ ៗ កាល ។*

ឥសិគិលិបរិត្ត

(បិដកលេខ ២៦ ទំព័រ ៣២៨)

ឯវម្មេ សុតំ *សូត្រនេះ (ឈ្មោះឥសិគិលិសូត្រ) គឺខ្ញុំ (ឈ្មោះអានន្ទ) បានស្តាប់មកហើយយ៉ាងនេះថា*

ឯកំ សមយំ ភគវា រាជគហេ វិហរតិ ឥសិគិលិស្មឹ បព្ពតេ *សម័យមួយព្រះដ៏មានព្រះភាគទ្រង់គង់នៅលើភ្នំឥសិគិលិទៀបក្រុងរាជគ្រឹះ ។*

តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ *ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅនូវភិក្ខុទាំងឡាយក្នុងទីនោះដូច្នេះថា* ***ភិក្ខវោ*** *ម្នាលភិក្ខុទាំងឡាយ ។*

ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ *ភិក្ខុទាំងឡាយនោះ ក៏ទទួលធ្វើយតបព្រះពុទ្ធដីកានៃព្រះមានព្រះភាគដូច្នេះថា* ***ភទន្តេ*** *បពិត្រព្រះអង្គដ៏ចម្រើន ។*

ភគវា ឯតទវោច *ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងនូវឥសិគិលិសូត្រនេះ ដោយព្រះពុទ្ធដីដូច្នេះថា*

បស្សថ ណោ តុម្ហេ ភិក្ខវេ ឯតំ វេភារំ បព្ពតន្តិ *ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញភ្នំវេភារៈនុ៎ះឬទេ*

ឯវំ ភន្តេ *ភិក្ខុទាំងឡាយនោះ ក្រាបទូលដូច្នេះថា* **ភន្តេ** *បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញ។*

ឯតស្ស ខោ[1] ភិក្ខវេ វេភារស្ស បព្វតស្ស អញ្ញោ ច សមញ្ញោ អហោសិ អញ្ញោ បញ្ញត្តិ *ម្នាលភិក្ខុទាំងឡាយ ភ្នំវេភារៈនុ៎ះឯង មានឈ្មោះផ្សេង មានបញ្ញត្តិផ្សេង។*

បស្សថ នោ តុម្ហេ ភិក្ខវេ ឯតំ បណ្ឌវំ បព្វតន្តិ *ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញភ្នំបណ្ឌវៈនុ៎ះឬទេ*

ឯវំ ភន្តេ *ភិក្ខុទាំងឡាយនោះ ក្រាបទូលដូច្នេះថា* **ភន្តេ** *បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញ។*

ឯតស្ស ខោ[2] ភិក្ខវេ បណ្ឌវស្ស បព្វតស្ស អញ្ញោ ច សមញ្ញោ អហោសិ អញ្ញោ បញ្ញត្តិ *ម្នាលភិក្ខុទាំងឡាយ ភ្នំបណ្ឌវៈនុ៎ះឯង ក៏មានឈ្មោះផ្សេង មានបញ្ញត្តិផ្សេងដែរ។*

បស្សថ នោ តុម្ហេភិក្ខវេ ឯតំ វេបុល្លំ បព្វតន្តិ *ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញភ្នំវេបុល្លៈនុ៎ះឬទេ*

ឯវំ ភន្តេ *ភិក្ខុទាំងឡាយនោះ ក្រាបទូលដូច្នេះថា* **ភន្តេ** *បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញ។*

ឯតស្ស ខោ[3] ភិក្ខវេ វេបុល្លស្ស បព្វតស្ស អញ្ញោ ច សមញ្ញោ អហោសិ អញ្ញោ បញ្ញត្តិ *ម្នាលភិក្ខុទាំងឡាយ ភ្នំវេបុល្លៈនុ៎ះឯង មានឈ្មោះ*

๑-๒-๓-បាលីក្នុងច្បាប់ឆដ្ឋសង្គាយនាថា **ឯតស្សបិ ខោ**។

ផ្សេង មានបញ្ញត្តិផ្សេងដែរ។

បស្សថ នោ តុម្ហេ ភិក្ខវេ ឯតំ គិជ្ឈកូដំ បព្វតន្តិ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញភ្នំគិជ្ឈកូដនេះឬទេ

ឯវំ ភន្តេ ភិក្ខុទាំងឡាយនោះ ក្រាបទូលដូច្នេះថា **ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញ។

ឯតស្ស ខោ ភិក្ខវេ គិជ្ឈកូដស្ស បព្វតស្ស អញ្ញោ ច សមញ្ញោ អហោសិ អញ្ញា បញ្ញត្តិ ម្នាលភិក្ខុទាំងឡាយ ភ្នំគិជ្ឈកូដនុ៎ះឯង មានឈ្មោះផ្សេង មានបញ្ញត្តិផ្សេងដែរ។

បស្សថ នោ តុម្ហេ ភិក្ខវេ ឥមំ ឥសិគិលឹ បព្វតន្តិ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញភ្នំឥសិគិលិនេះឬទេ

ឯវំ ភន្តេ ភិក្ខុទាំងឡាយនោះ ក្រាបទូលដូច្នេះថា **ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញ។

ឥមស្ស ខោ បន ភិក្ខវេ ឥសិគិលិស្ស បព្វតស្ស ឯសា ច សមញ្ញោ អហោសិ ឯសា បញ្ញត្តិ ម្នាលភិក្ខុទាំងឡាយ ឯភ្នំឥសិគិលិនេះឯង មានឈ្មោះយ៉ាងហ្នឹង មានបញ្ញត្តិយ៉ាងហ្នឹងតែម្យ៉ាង។

ភូតបុព្វំ ភិក្ខវេ ម្នាលភិក្ខុទាំងឡាយ ធ្លាប់មានរឿងពីព្រេងនាយមកថា

បញ្ច បច្ចេកពុទ្ធសតានិ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសិនោ អហេសុំ មានព្រះបច្ចេកពុទ្ធ ៥០០ អង្គ នៅនាភ្នំឥសិគិលិនេះអស់កាលដ៏យូរ។

តេ ឥមំ បព្វតំ បវិសន្តា ឱតរន្តិ បវិដ្ឋា ច ឱតរន្តិ ព្រះបច្ចេកពុទ្ធ

ទាំងឡាយនោះ កាលចូលទៅកាន់ភ្នំនេះ មនុស្សទាំងឡាយឃើញប្រាកដ លុះចូលស៊ប់ទៅហើយ មនុស្សទាំងឡាយមិនឃើញឡើយ។

តមេនំ មនុស្សា ទិស្វា ឯវមាហំសុ *លុះមនុស្សទាំងឡាយ បានឃើញនូវហេតុនោះហើយ ក៏នាំគ្នានិយាយយ៉ាងនេះថា*

អយំ បព្វតោ ឥមេ ឥសី គិលតីតិ ឥសិគិលិ ឥសិគិលិ ត្វេវ សមញ្ញា ខ្វទធាទិ *ភ្នំនេះលេបនូវឥសីទាំងឡាយនេះ ព្រោះហេតុនោះ បានជាមានឈ្មោះកើតឡើងថា ឥសិគិលិ ឥសិគិលិ(ភ្នំលេបឥសី។) ដូច្នេះ។*

អាចិក្ខិស្សាមិ ភិក្ខវេ បច្ចេកពុទ្ធានំ នាមានិ *ម្នាលភិក្ខុទាំងឡាយ តថាគតនឹងប្រាប់ឈ្មោះព្រះបច្ចេកពុទ្ធទាំងឡាយ។*

កិត្តយិស្សាមិ ភិក្ខវេ បច្ចេកពុទ្ធានំ នាមានិ *ម្នាលភិក្ខុទាំងឡាយ តថាគតនឹងចង្អុលបង្ហាញឈ្មោះព្រះបច្ចេកពុទ្ធទាំងឡាយ។*

ឧទ្ទេសិស្សាមិ ភិក្ខវេ បច្ចេកពុទ្ធានំ នាមានិ *ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងឈ្មោះព្រះបច្ចេកពុទ្ធទាំងឡាយ។*

តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ *អ្នកទាំងឡាយចូរប្រុងស្តាប់នូវរឿងនោះចុះ ចូរធ្វើទុកក្នុងចិត្តឱ្យប្រពៃចុះ តថាគតនឹងសម្តែងប្រាប់។*

ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ *ភិក្ខុទាំងឡាយនោះ ក៏ទទួលធ្វើយតបព្រះពុទ្ធដីកានៃព្រះមានព្រះភាគដូច្នេះថា **ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន។*

ភគវា ឯតទវោច *ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងយ៉ាងនេះថា*

អរិដ្ឋោ នាម ភិក្ខវេ បច្ចេកសម្ពុទ្ធោ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសី អហោសិ *ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធឈ្មោះអរិដ្ឋៈ បាននៅនាភ្នំឥសិគិលិនេះអស់កាលដ៏យូរ។*

ឧបរិដ្ឋោ នាម ភិក្ខវេ បច្ចេកសម្ពុទ្ធោ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសី អហោសិ *ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធឈ្មោះឧបរិដ្ឋៈ បាននៅនាភ្នំឥសិគិលិនេះអស់កាលដ៏យូរ។*

តគរសិខី នាម ភិក្ខវេ បច្ចេកសម្ពុទ្ធោ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសី អហោសិ *ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធឈ្មោះតគរសិខី បាននៅនាភ្នំឥសិគិលិនេះអស់កាលដ៏យូរ។*

យសស្សី នាម ភិក្ខវេ បច្ចេកសម្ពុទ្ធោ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសី អហោសិ *ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធឈ្មោះយសស្សី បាននៅនាភ្នំឥសិគិលិនេះអស់កាលដ៏យូរ។*

សុទស្សនោ នាម ភិក្ខវេ បច្ចេកសម្ពុទ្ធោ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសី អហោសិ *ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធឈ្មោះសុទស្សនៈ បាននៅនាភ្នំឥសិគិលិនេះអស់កាលដ៏យូរ។*

បិយទស្សី នាម ភិក្ខវេ បច្ចេកសម្ពុទ្ធោ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសី អហោសិ *ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធឈ្មោះបិយទស្សី បាននៅនាភ្នំឥសិគិលិនេះអស់កាលដ៏យូរ។*

គន្ធារោ នាម ភិក្ខវេ បច្ចេកសម្ពុទ្ធោ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសី អហោសិ *ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធឈ្មោះគន្ធារៈ បាន*

នៅនាក្នុងឥសិគិលិនេះអស់កាលជ័យូរ។

បិណ្ឌោលោ នាម ភិក្ខវេ បច្ចេកសម្ពុទ្ធោ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសី អហោសិ *ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធឈ្មោះ បិណ្ឌោលៈ បាននៅនាក្នុងឥសិគិលិនេះអស់កាលជ័យូរ។*

ឧបាសភោ នាម ភិក្ខវេ បច្ចេកសម្ពុទ្ធោ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសី អហោសិ *ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធឈ្មោះ ឧបាសភៈ បាននៅនាក្នុងឥសិគិលិនេះអស់កាលជ័យូរ។*

នីថោ[1] **នាម ភិក្ខវេ បច្ចេកសម្ពុទ្ធោ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសី អហោសិ** *ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធឈ្មោះនិថៈ[2] បាននៅនាក្នុងឥសិគិលិនេះអស់កាលជ័យូរ។*

តថោ នាម ភិក្ខវេ បច្ចេកសម្ពុទ្ធោ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសី អហោសិ *ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធឈ្មោះតថៈ បាននៅនាក្នុងឥសិគិលិនេះអស់កាលជ័យូរ។*

សុតវា នាម ភិក្ខវេ បច្ចេកសម្ពុទ្ធោ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសី អហោសិ *ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធឈ្មោះសុតវា បាននៅនាក្នុងឥសិគិលិនេះអស់កាលជ័យូរ។*

តាវិតក្ខោ នាម ភិក្ខវេ បច្ចេកសម្ពុទ្ធោ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសី អហោសិ *ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធឈ្មោះតាវិតក្ខៈ បាននៅនាក្នុងឥសិគិលិនេះអស់កាលជ័យូរ។*

๑-๒-បាលីឆដ្ឋសង្គាយនាថា **នីតោ**។

យេ សត្តសារ អនីឃា និរាសា
បច្ចេកមេវជ្ឈគមុំ[1] ពោធឹ
តេសំ ឥសិស្ថាន នរុត្តមានំ
នាមានិ មេ កិត្តយតោ សុណាថ ៗ

ព្រះបច្ចេកពុទ្ធទាំង៧ព្រះអង្គណា ជាខ្លឹមរបស់សត្វ អស់ទុក្ខ អស់ចំណង់ បានត្រាស់ដឹងហើយនូវបច្ចេកសុពោធិញ្ញាណ កាលបើតថាគតសម្តែងឈ្មោះរបស់ព្រះបច្ចេកពុទ្ធទាំង៧នោះ ដែលមានសរដកចេញហើយ ដ៏ឧត្តមជាងជន អ្នកទាំង៧ព្រះអង្គចូរស្តាប់ចុះ ។

អរិដ្ឋោ ឧបរិដ្ឋោ តគរសិខី យសស្សី
សុទស្សនោ បិយទស្សី ចពុទ្ធោ[2]
គន្ធារោ បិណ្ឌោលោ ឧបាសភោ ច
នីចោ តចោ[3] សុតវា ភារិតណ្ហោ ៗ
សុម្ភោ សុភោ មេថុលោ[4] អដ្ឋមោ ច
អថស្សុមេយ្យោ អនីឃោ សុទាឋោ
បច្ចេកពុទ្ធា ភវនេត្តិខីណា
ហិន្តុ ច ហិង្គោ ច មហានុភាវា ៗ

ព្រះបច្ចេកពុទ្ធទាំង៧ព្រះអង្គ ឈ្មោះអរិដ្ឋៈ ១ ឧបរិដ្ឋៈ ១ តគរសិខី ១ យសស្សី ១ សុទស្សនៈ ១ បច្ចេកពុទ្ធឈ្មោះ បិយទស្សី ១ គន្ធារៈ ១ បិណ្ឌោលៈ ១ ឧបាសភៈ ១ និចៈ ១ តចៈ ១ សុតវា ១ ភារិតត្តៈ ១ សុម្ភៈ ១ សុភៈ ១ មេថុលៈ ១ អដ្ឋមៈ ១

១-បាលីឆដ្ឋសង្គាយនាថា **គមិសុ**។ ២-បាលីឆដ្ឋសង្គាយនាថា **សុសម្ភទ្ធោ**។ ៣-បាលីឆដ្ឋសង្គាយនាថា **នីតោ តចោ**។ ៤-បាលីឆដ្ឋសង្គាយនាថា **មតុលោ** ។

អស្សុមេឃៈ ១ អនិឃៈ ១ សុទាឋៈ ១ ជាបច្ចេកពុទ្ធមានតណ្ហានាំទៅកាន់ភពអស់ហើយ ព្រះបច្ចេកពុទ្ធឈ្មោះ ហិង្គុ ១ ហិង្គៈ ១ មានអានុភាពច្រើន ។

ទ្វេ ជាលិនោ មុនិនោ អដ្ឋកោ ច
អថ កោសល្លោ ពុទ្ធោ អថោ សុពាហុ
ឧបនេមិសោ នេមិសោ សន្តចិត្តោ
សច្ចោ តថោ វិរជោ បណ្ឌិតោ ច ៗ

ព្រះបច្ចេកពុទ្ធឈ្មោះជាលី ២ គឺចុល្លជាលី ១ មហាជាលី ១ ជាអ្នកប្រាជ្ញ ឈ្មោះអដ្ឋកៈ ១ ព្រះបច្ចេកពុទ្ធឈ្មោះ កោសល្លៈ ១ សុពាហុ ១ ឧបនេមិសៈ ១ នេមិសៈ ១ សន្តចិត្តៈ ១ សច្ចៈ ១ តថៈ ១ វិរជៈ ១ បណ្ឌិតៈ ១ ។

កាឡុបកាឡា ឥជិតោ ជិតោ ច
អង្គោ ច បង្គោ ច គុតិច្ឆិតោ ច[1]
បស្សិ ជហិ ឧបធិទុក្ខមូលំ
អបរាជិតោ មារពលំ អជេសិ ៗ

ព្រះបច្ចេកពុទ្ធឈ្មោះ កាឡៈ ១ ឧបកាឡៈ ១ វិជិតៈ ១ ជិតៈ ១ អង្គៈ ១ បង្គៈ ១ គុតិច្ឆិតៈ ១ ព្រះបច្ចេកពុទ្ធឈ្មោះ បស្សី ១ បានលះបង់ឧបធិកិលេស ជាឫសនៃសេចក្តីទុក្ខហើយ ព្រះបច្ចេកពុទ្ធឈ្មោះ អបរាជិតៈ បានផ្ចាញ់នូវមារនិងពលនៃមារហើយ ។

សត្តា បឋត្តា សរតង្គោ លោមហំសោ
ឧច្ចង្គមាយោ អសិតោ អនាសវោ
មនោមយោ មានច្ឆិទោ ចពន្ធុមា

១-បាលីឆដ្ឋសង្គាយនាថា **គុត្តិជិតោ ច** តែវចនានុក្រមព្រះត្រៃបិដកថា **គុត្តិជិត ច** ។

តទាធិមុត្តោ វិមលោ ច កេតុមា ៙

ព្រះបច្ចេកពុទ្ធឈ្មោះ សត្តា ១ បវត្តា ១ សរកង្គៈ ១ លោមហង្សៈ ១ ឧច្ចង្គមាយៈ ១ អសិតៈ ១ អនាសវៈ ១ មនោមយៈ ១ ពន្ធុមា ជាអ្នកផ្តាច់បង់នូវមាន ១ ឈ្មោះតទាធិមុត្តៈ ១ វិមលៈ ១ កេតុមា ១ ។

កេតុម្ភរាគោ ច មាតង្គោ អរិយោ
អថច្ចុតោ អច្ចុតគាមព្យាមកោ
សុមង្គលោ ទព្វិលោ សុបតិដ្ឋិតោ
អសយ្ហោខេមាភិរតោ ច សោរតោ ៙
ទុរន្ទយោ សង្ឃ អថោបិ ខជ្ជយោ
អបរោ មុនិ សយ្ហោ អនោមនិក្កមោ
អានន្ទនន្ទោ[1] ខបនន្ទោ ទ្វាទស
តារង្ហោ អន្តិមទេហធារី ៙
ពោធិ មហានាមោ អថោបិ ខត្តរោ
កេសី សិខី សុទ្ធរោ ទ្វារគារវោ
តិស្សុបតិស្សា តវពន្ធនច្ឆិទា
ខបសិខិ តណ្ហច្ឆិទោ ច សិខរិ ៙

ព្រះបច្ចេកពុទ្ធឈ្មោះ កេតុម្ភរាគៈ ១ មាតង្គៈ ១ អរិយៈ ១ អថច្ចុត ១ អច្ចុតគាមព្យាមកៈ ១ សុមង្គលៈ ១ ទព្វិលៈ ១ សុបតិដ្ឋិតៈ ១ អសយ្ហៈ ១ ខេមាភិរតៈ ១ សោរតៈ ១ ទុរន្ទយៈ ១ សង្ឃៈ ១ ឧជ្ជយៈ ១ និងបច្ចេកពុទ្ធដទៃទៀតឈ្មោះ សយ្ហៈ ជាអ្នកប្រាជ្ញ មានសេចក្តីព្យាយាមមិនថោកថយ ១ ព្រះបច្ចេកពុទ្ធ ១២ អង្គទៀត

១-បាលីឆដ្ឋសង្គាយនាថា **អានន្ទោ នន្ទោ** ។

ឈ្មោះ អានន្ទៈ (៤ អង្គ) នន្ទៈ (៤ អង្គ) ឧបនន្ទៈ (៤ អង្គ) ភារទ្វាជៈ ជាអ្នកទ្រទ្រង់នូវរាងកាយមានក្នុងទីបំផុតកព ១ ពោធិ ១ មហានាមៈ ១ ឧត្តរៈ ១ កេសី ១ សិខី ១ សុន្ទរៈ ១ ភារទ្វាជៈ ១ តិស្សៈ ១ ឧបតិស្សៈ ១ ជាអ្នកផ្តាច់បង់នូវចំណង គឺកព ឈ្មោះ ឧបសីទរី ១ សីទរី ជាអ្នកផ្តាច់បង់តណ្ហា ១ ។

ពុទ្ធោ អហុ មង្គលោ ទីឃរាគោ
ទ្វេសតច្ឆិនោ ជាលិនី ទុក្ខមូលំ
សន្តិំ បទំ អជ្ឈគមោបនីតោ
ទ្វេចោសថោ សុន្ទរោ សច្ចនាមោ ៗ

បច្ចេកពុទ្ធឈ្មោះ មង្គលៈ មានរាគៈទៅប្រាស់ហើយ ១ ឈ្មោះឧសភៈ បានផ្តាច់បង់នូវតណ្ហា ជាឫសនៃទុក្ខ ១ ឧបណីតៈ បានដល់នូវចំណែកសូប៌រំងាប់ ១ ឧបោសថៈ ១ សុន្ទរៈ ១ សច្ចនាមៈ ១ ។

ជេតោ ជយន្តោ បទុមោ ទ្វេបុល្លោ ច
បទុមុត្តរោ រក្ខិតោ បព្ភតោ ច
មានត្ថទ្ធោ សោភិតោ វីតរាគោ
កណ្ហោ ច ពុទ្ធោ សុវិមុត្តចិត្តោ ៗ

បច្ចេកពុទ្ធឈ្មោះ ជេតៈ ១ ជយន្តៈ ១ បទុមៈ ១ ឧប្បលៈ ១ បទុមុត្តរៈ ១ រក្ខិតៈ ១ បព្ភតៈ ១ មានត្ថទ្ធៈ ១ សោភិតៈ ១ វីតរាគៈ ១ កណ្ហៈ ១ បានត្រាស់ដឹងហើយ មានចិត្តរួចវិសេសហើយ ។

ឯតេ ច អញ្ញេ ច មហានុភាវា
បច្ចេកពុទ្ធា ភវនេត្តិខីណា
តេ សព្ពសង្ខាតិគតេ មហេសី

បរិនិព្វុតេ ភន្តេ អប្បមេយ្យេតិ ។

ព្រះបច្ចេកពុទ្ធមានឈ្មោះប៉ុណ្ណោះ និងនៅមានឈ្មោះដទៃទៀត មានអានុភាពច្រើន មានតណ្ហាជាគ្រឿងនាំទៅកាន់កពអស់ហើយ អ្នកទាំងឡាយចូរថ្វាយបង្គំនូវព្រះបច្ចេកពុទ្ធទាំងឡាយនោះ ដែលកន្ទងនូវកិលេសជាគ្រឿងជាប់ចំពាក់ទាំងពួង ស្វែងរកនូវគុណដ៏ប្រសើរ មានគុណរកប្រមាណមិនបាន ដែលបរិនិព្វានទៅហើយ ។

ឥសិគិលិសុត្តំ និដ្ឋិតំ

ឥសិគិលិសូត្រ ចប់

ចប់ ព្រះបរិត្តតែប៉ុណ្ណោះ

ព្រះសូត្រ

សេចក្តីពន្យល់

*ព្រះសូត្រទាំងអស់នេះ គឺសុទ្ធតែជាព្រះពុទ្ធដីកា មាននៅក្នុងព្រះត្រៃបិដក ដែលបុរាណលោកដកយកមកចងក្រងទុកជាក្បួន សម្រាប់ព្រះសង្ឃសូត្រស្វាធ្យាយ-ពេលមានពិធីក្នុងសាសនា ដែលនិយមហៅថា "**ចម្រើនពុទ្ធមន្ត**" ។ ហើយកិច្ចចម្រើនពុទ្ធមន្តនេះមាន ២ យ៉ាងគឺ សូត្រក្នុងពេលមានទុក្ខធុរៈ ១ យ៉ាង សូត្រក្នុងពេលធ្វើបុណ្យទានផ្សេងៗ ១ យ៉ាង ។*

ឯការចម្រើនពុទ្ធមន្តទាំង ២ យ៉ាងនោះ គឺ:

១-សូត្រក្នុងពេលមានទុក្ខធុរៈ *គឺពេលមានមនុស្សឈឺធ្ងន់ តែងសូត្រគិរិមានន្ទសូត្រ, អនត្តលក្ខណសូត្រ និងអាទិត្តបរិយាយសូត្រ ។ ព្រោះប្រារព្ធនឹងរឿងរ៉ាវកាលដែលគិរិមានន្ទកិក្ខុលោកមានជំងឺ ព្រះអង្គក៏ទ្រង់សម្តែងនូវព្រះគិរិមានន្ទសូត្រនេះ ដែលនិយាយពីទុក្ខទោសនៃរូបកាយ ក៏ធ្វើឱ្យលោកបានជាសះស្បើយពីជំងឺភ្លាម, ចំណែកអនត្តលក្ខណសូត្រ និងអាទិត្តបរិយាយសូត្រ ក៏និយាយអំពីទុក្ខទោស-នៃរូបកាយដែរ ដែលជារបស់ក្តៅ ឥតខ្លឹមសារ ព្រោះជារបស់មិនទៀង ជាទុក្ខ ជាអនត្តា, កាលបានស្តាប់យល់ចូលចិត្តច្បាស់ហើយក៏ជាហេតុធ្វើឱ្យអ្នកជំងឺបានសូប់ចិត្ត ព្រោះមិនមានការប្រកាន់ហួងហែងនូវរូបកាយនេះ... ។*

ហើយម្យ៉ាងទៀត ក៏អាចសូត្រធម៌ផ្សេងៗ ទៀតបានដែរ ស្រេចហើយតែ

អ្នកជំងឺចង់ស្តាប់ ដូចជារឿងធម្មិកឧបាសក ដែលមានសម្តែងក្នុងគម្ពីរធម្មបទត្រង់យមកវគ្គថា កាលគាត់មានជំងឺធ្ងន់ បានប្រើកូនឱ្យទៅនិមន្តភិក្ខុសង្ឃមកសូត្រនូវមហាសតិប្បដ្ឋានសូត្រឱ្យស្តាប់.. ។ នឹងអាចសូត្រក្នុងពេលផ្សេងដទៃទៀតក៏បានដូចគ្នាដែរ ។

២-សូត្រក្នុងពិធីបុណ្យទានផ្សេងៗ ដូចជាបុណ្យចូលឆ្នាំ ភ្ជុំបិណ្ឌ កឋិនទាន កតញ្ញូ ឬពេលមានពិធីមង្គលការជាដើម គួរសូត្រមង្គលសូត្រ បរាភវសូត្រ និងមហាសមយសូត្រ ។ ព្រោះមង្គលសូត្រជាសូត្រដែលនិយាយអំពីមង្គល គឺសិរីស្តី មាន ៣៨ ប្រការ, ឯបរាភវសូត្រ និយាយអំពីហេតុដែលនាំឱ្យវិនាស មាន ១២ ប្រការ ដែលព្រះពុទ្ធអង្គទ្រង់បានប្រកាសសម្តែងប្រាប់ឱ្យសព្វសត្វបានស្គាល់នូវផ្លូវនៃសេចក្តីចម្រើន និងវិនាស កាលដឹងហើយក៏ខំព្យាយាមដើរទៅរកផ្លូវសេចក្តីចម្រើន ដោយចៀសវាងពីផ្លូវនៃសេចក្តីវិនាស...។ ឯមហាសមយសូត្រនោះ ក្នុងអដ្ឋកថាលោកប្រាប់ថា “ គឺជាសូត្រដែលជាទីស្រឡាញ់ ជាទីពេញចិត្តនៃទេវតាទាំងឡាយ ព្រោះដូច្នោះ ក្នុងស្ថានទីថ្មី ៗ កាលនឹងពោលនូវមង្គល ក៏គប្បីពោលតែព្រះសូត្រនេះប៉ុណ្ណោះ” ។ ព្រោះកាលដែលពោលនូវព្រះសូត្រនេះទៅហើយ ពួកទេវតាតែងសម្គាល់ថា ព្រះសូត្រនេះជារបស់យើង ។ ហើយក៏នាំគ្នាមកដោយសេចក្តីស្រឡាញ់ពេញចិត្ត កាលពួកទេវតាដែលមានស័ក្តិធំមកប្រជុំគ្នាដូច្នេះ ពួកអមនុស្សណាមានចិត្តអាក្រក់ដែលមាននៅក្នុងទីនោះ ក៏នាំគ្នាគេចចេញទៅ ជាហេតុឱ្យកើតសិរីសួស្តីដល់ទីកន្លែង និងម្ចាស់កន្លែងនោះ...។

អញ្ជើញទេវតា

យេ សន្តា សន្តចិត្តា តិសរណសរណា ឯត្ថ លោកន្តរេ វា
ភុម្មាភុម្មា ច ទេវា គុណគណគណមាណព្យាវដា សព្វកាលំ

ទេវតាទាំងឡាយឯណា ជាកុម្មទេវតាក្តី មិនមែនជាកុម្មទេវតាក្តី ជាអ្នកមានចិត្តស្ងប់ មានព្រះរតនត្រ័យជាទីពឹង ទីរឭក ដែលមាននៅក្នុងលោកនេះ ឬក្នុងចន្លោះនៃលោក ជាអ្នកខ្វល់ខ្វាយក្នុងកិរិយាកាន់យកនូវពពួកនៃគុណសព្វៗកាល។

ឯតេ អាយន្តុ ទេវា ឥរកនកមយេ មេរុរាជេ ឥសន្តោ
សន្តោ សន្តោសហេតុំ មុនិឥរវចនំ សោតុមគ្គំ សមគ្គំ ៙

សូមទេវតាទាំងឡាយនោះ អញ្ជើញមក ម្យ៉ាងទៀត ទេវតាដែលឋិតនៅលើភ្នំមេរុរាជ សុទ្ធសឹងតែមានសព្ទដ៏ប្រសើរ សូមអញ្ជើញមកផង សូមទេវតាជាសប្បុរសទាំងឡាយ អញ្ជើញមកកាន់ទីសមាគម ដើម្បីស្តាប់នូវពាក្យនៃព្រះមុនីដ៏បវរ ជាធម៌ដ៏ប្រសើរលើស ជាហេតុនាំឱ្យកើតនូវសេចក្តីត្រេកអរ។

សព្វេសុ ចក្កវាឡេសុ យក្ខា ទេវា ច ព្រហ្មុនោ
យំ អម្ហេហិ កតំ បុញ្ញំ សព្វសម្បត្តិសាធកំ

បុណ្យឯណា ដែលយើងបានធ្វើហើយ ជាបុណ្យអាចឱ្យសម្រេចនូវសម្បត្តិទាំងពួង សូមយក្ខទាំងឡាយផង ទេវតាទាំងឡាយផង ព្រហ្មទាំងឡាយផង ក្នុងចក្រវាឡទាំងអស់ (អនុមោទនាត្រេកអរនឹងបុណ្យនោះ)។

សព្ពេ តំ អនុមោទិត្វា សមគ្គា សាសនេ រតា
បមាទរហិតា ហោន្តុ អារក្ខាសុ វិសេសតោ

យក្ខ និងទេវតា និងព្រហ្មទាំងអស់ កាលបើបានអនុមោទនានូវបុណ្យនោះ ហើយ ចូរព្រមព្រៀងគ្នាត្រេកអរក្នុងព្រះពុទ្ធសាសនា ហើយចូរប្រាសចាកសេចក្តីប្រហែសធ្វេសក្នុងការរក្សា (នូវព្រះពុទ្ធសាសនា) ដោយឧបាយដ៏វិសេស

សាសនស្ស ច លោកស្ស វុឌ្ឍី ភវតុ សព្វទា
សាសនម្បិ ច លោកញ្ច ទេវា រក្ខន្តុ សព្វទា

សូមឱ្យសេចក្តីចម្រើន កើតមានដល់ព្រះពុទ្ធសាសនាផង ដល់សត្វលោកផង ឱ្យបានសព្វៗកាលទៅ សូមទេវតាទាំងឡាយ អភិបាលរក្សានូវព្រះពុទ្ធ-សាសនាផង នូវសត្វលោកផង ឱ្យបានសព្វៗកាលរៀងទៅ

សទ្ធី ហោន្តុ សុខី សព្វេ បរិវារេហិ អត្តនោ
អនីឃា សុមនា ហោន្តុ សហ សព្វេហិ ញាតិភិ

សព្វសត្វទាំងអស់ ព្រមទាំងបរិវារទាំងឡាយរបស់ខ្លួន សូមឱ្យមានសេចក្តីសុខស្រួល សូមឱ្យជាអ្នកឥតមានសេចក្តីទុក្ខភ័យ ជាអ្នកមានចិត្តល្អព្រមទាំងជនជាញាតិសន្តានទាំងអស់គ្នា។

មង្គលសុត្តារម្ភោ

យញ្ច ទ្វាទស វស្សានិ ចិន្តយឹសុ សទេវកា
ចិរស្សំ ចិន្តយន្តាបិ នេវ ជានឹសុ មង្គលំ

ចក្កវាឡសហស្សេសុ ទសសុ យេន តត្តកំ
ការេ កោលហលំ ជាតំ យាវ ព្រហ្មនិវេសនា

មនុស្សព្រមទាំងទេវតាទាំងឡាយ បាននាំគ្នាគិតរកនូវមង្គលឯណា អស់ ១២ ឆ្នាំ មនុស្ស និងទេវតាទាំងនោះក្នុង ១ ម៉ឺនចក្រវាឡ ទោះខំប្រឹងគិតអស់កាលយូរម៉្លេះ ក៏នៅតែមិនដឹងនូវមង្គលនោះត្រឹមណា រីកោលាហលក៏កើតរហូតដល់កពជាទីនៅនៃព្រហ្មអស់កាលត្រឹមនោះឯង ។

យំ លោកនាថោ នេសេសិ សព្វបាបវិនាសនំ
យំ សុត្វា សព្វទុក្ខេហិ មុច្ចន្តាសំខិយា ជនា
ឯវមាទិគុណូបេតំ មង្គលន្តម្ភណាម ហោ

ព្រះបរមលោកនាថ ទ្រង់ត្រាស់សម្តែងហើយនូវមង្គលឯណា ដែលជាគ្រឿងញាំងបាបទាំងពួងឱ្យវិនាស នរជនទាំងឡាយរាប់ចំនួនមិនបាន ស្តាប់នូវមង្គលឯណាហើយ បានរួចចាកទុក្ខទាំងពួង ម្នាលទេវតាទាំងឡាយ យើងពោលឥឡូវនេះ នូវមង្គលនោះដ៏ប្រកបដោយគុណមានយ៉ាងនេះជាដើម ។

មង្គលសូត្រ

(បិដកលេខ ៥២ ទំព័រ ៤ និងលេខ ៥៤ ទំព័រ ៨៥)

ឯវមេ សុតំ *សូត្រនេះ (ឈ្មោះមង្គលសូត្រ) គឺខ្ញុំ (ឈ្មោះអានន្ទ) បានស្តាប់មកហើយយ៉ាងនេះថា*

ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស

អារាមេ *សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថី។*

អថខោ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ *លំដាប់នោះឯង ទេវតាអង្គ ១ កាលដែលវេលារត្រីបឋមយាមកន្ទងទៅហើយ មានរស្មីដ៏ល្អ ញុំាងវត្តជេតពនជុំវិញទាំងអស់ ឱ្យភ្លឺស្វាងហើយ ព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងទីណា ក៏ចូលទៅក្នុងទីនោះ លុះចូលទៅដល់ហើយ ទើបថ្វាយបង្គំចំពោះអង្គព្រះដ៏មានព្រះភាគ ហើយឈរនៅក្នុងទីដ៏សមគួរ*

ឯកមន្តំ ឋិតា ខោ សា ទេវតា ភគវន្តំ គាថាយ អជ្ឈភាសិ *កាលទេវតានោះឈរក្នុងទីដ៏សមគួរហើយ ទើបក្រាបទូលព្រះដ៏មានព្រះភាគ ដោយពាក្យជាគាថា (យ៉ាងនេះ) ថា*

ពហូ ទេវា មនុស្សា ច មង្គលានិអចិន្តយុំ
អាកង្ខមានា សោត្ថានំ ព្រូហិ មង្គលមុត្តមំ

ទេវតា និងមនុស្សទាំងឡាយ ជាច្រើនប្រាថ្នានូវសេចក្តីសួស្តី បានគិតរកនូវមង្គលទាំងឡាយ សូមព្រះអង្គទ្រង់ព្រះមេត្តាសម្តែងប្រាប់នូវមង្គលដ៏ឧត្តម។

(ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងតបពាក្យទេវតានោះ ដោយពុទ្ធភាសិតជាគាថាយ៉ាងនេះ)

អសេវនា ច ពាលានំ បណ្ឌិតានញ្ច សេវនា
បូជា ច បូជនីយានំ ឯតម្មង្គលមុត្តមំ

កិរិយាមិនសេពគប់នូវបុគ្គលពាលទាំងឡាយ ១ កិរិយាសេពគប់នូវបុគ្គលជាបណ្ឌិតទាំងឡាយ ១ កិរិយាបូជាដល់បុគ្គលដែលគួរបូជាទាំងឡាយ ១ ទាំង ៣ នេះ ជាមង្គលដ៏ឧត្តម។

បដិរូបទេសវាសោ ច បុព្ពេ ច កតបុញ្ញតា
អត្តសម្មាបណីធិ ច ឯតម្មង្គលមុត្តមំ

កិរិយានៅក្នុងប្រទេសដ៏សមគួរ ១ ភាវៈនៃបុគ្គលបានធ្វើបុណ្យទុកហើយក្នុងកាលមុន ១ កិរិយាតម្កល់ខ្លួនដោយប្រពៃ ១ ទាំង៣ នេះ ជាមង្គលដ៏ឧត្តម។

ពាហុសច្ចញ្ច សិប្បញ្ច វិនយោ ច សុសិក្ខិតោ
សុភាសិតា ច យា វាចា ឯតម្មង្គលមុត្តមំ

ភាវៈនៃបុគ្គលបានស្តាប់បានរៀនហើយដោយច្រើន ១ សិល្បៈសាស្ត្រ គឺសេចក្តីឆ្លៀវឈ្លាសក្នុងហត្ថកម្មរបស់អ្នកបួស និងគ្រហស្ថ ១ វិន័យដែលបុគ្គលសិក្សាដោយប្រពៃ ១ វាចាដែលបុគ្គលពោលត្រឹមត្រូវ ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម។

មាតាបិតុឧបដ្ឋានំ បុត្តទារស្ស សង្គហោ
អនាកុលា ច កម្មន្តា ឯតម្មង្គលមុត្តមំ

កិរិយាបម្រើនូវមាតា ១ កិរិយាបម្រើនូវបិតា ១ សេចក្តីសង្គ្រោះដល់បុត្រនិងភរិយា ១ ការងារទាំងឡាយដែលមិនច្របូកច្របល់ ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម។

ទានញ្ច ធម្មចរិយា ច ញាតកានញ្ច សង្គហោ
អនវជ្ជានិ កម្មានិ ឯតម្ងគ្គលមុត្តមំ

កិរិយាបរិច្ចាគទាន ១ កិរិយាប្រព្រឹត្តនូវធម៌ ១ សេចក្តីសង្គ្រោះដល់ញាតិទាំងឡាយ ១ ការងារទាំងឡាយដែលមិនមានទោស ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម ។

អារតី វិរតី បាបា មជ្ជបានា ច សញ្ញមោ
អប្បមាទោ ច ធម្មេសុ ឯតម្ងគ្គលមុត្តមំ

កិរិយាមិនត្រេកអរក្នុងបាប និងកិរិយាវៀរចាកបាប ១ សេចក្តីសង្រួមចាកកិរិយាផឹកនូវទឹកស្រវឹង ១ សេចក្តីមិនប្រមាទក្នុងធម៌ទាំងឡាយ ១ ទាំង ៣ នេះ ជាមង្គលដ៏ឧត្តម ។

គារវោ ច និវាតោ ច សន្តុដ្ឋី ច កតញ្ញុតា
កាលេន ធម្មស្សវនំ ឯតម្ងគ្គលមុត្តមំ

សេចក្តីគោរពចំពោះបុគ្គលដែលគួរគោរព ១ កិរិយាប្រព្រឹត្តបន្ទាបនូវខ្លួន ១ សេចក្តីត្រេកអរចំពោះរបស់ដែលមាន ១ ភាវៈនៃបុគ្គលអ្នកដឹងនូវឧបការៈ ដែលអ្នកដទៃធ្វើហើយដល់ខ្លួន ១ កិរិយាស្តាប់នូវធម៌តាមកាល ១ ទាំង ៥ នេះ ជាមង្គលដ៏ឧត្តម ។

ខន្តិ ច សោវចស្សតា សមណានញ្ច ទស្សនំ
កាលេន ធម្មសាកច្ឆា ឯតម្ងគ្គលមុត្តមំ

សេចក្តីអត់ធន់ ១ ភាវៈនៃបុគ្គលដែលគេប្រដៅបានដោយងាយ ១ កិរិយា

បានឃើញបានជួបនូវសមណៈទាំង៤ប្រាយ ១ ធម្មសាកច្ឆា គឺកិរិយាសន្ទនាទៅវិញ ទៅមកនូវធម៌តាមកាល ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម។

តថោ ច ព្រហ្មចរិយញ្ហា អរិយសច្ចាន ទស្សនំ
និព្វានសច្ឆិកិរិយា ច ឯតម្មង្គលមុត្តមំ

សេចក្តីព្យាយាមដុតនូវបាបធម៌ ១ កិរិយាប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ១ កិរិយាឃើញនូវអរិយសច្ចទាំង៤ប្រាយ ១ កិរិយាធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម។

ផុដ្ឋស្ស លោកធម្មេហិ ចិត្តំ យស្ស ន កម្បតិ
អសោកំ វិរជំ ខេមំ ឯតម្មង្គលមុត្តមំ

ចិត្តនៃបុគ្គលឯណា ដែលលោកធម៌ទាំង៤ប្រាយពាល់ត្រូវហើយ មិនរំភើប ញាប់ញ័រ ១ មិនមានសេចក្តីសោក ១ មានធូលី គឺរាគៈទៅប្រាសហើយ ១ ជាចិត្តក្សេមក្សាន្ត ១ ទាំង ៤ នេះ ជាមង្គលដ៏ឧត្តម។

ឯតាទិសានិ កត្វាន សព្វត្ថមបរាជិតា
សព្វត្ថ សោត្ថឹ គច្ឆន្តិ តន្តេសំ មង្គលមុត្តមន្តិ

ទេវតា និងមនុស្សទាំង៤ប្រាយ ធ្វើនូវមង្គលទាំង៤ប្រាយប្រាកដដូច្នេះហើយ ជាអ្នកមិនចាលចាញ់ក្នុងទីទាំងពួង តែងដល់នូវសិរីសួស្តីក្នុងទីទាំងពួង (ម្នាលទេវតា អ្នកចូរប្រកាន់ជឿថា) មង្គលទាំង ៣៨ ប្រការ មានកិរិយាមិនសេពគប់នូវបុគ្គលពាលជាដើមនោះ របស់ទេវតា និងមនុស្សទាំងអម្បាលនោះ ជាមង្គលដ៏ឧត្តម។

បរាភវសូត្រ

បទបឋមវត្ត

(ទេវតាទូលសួរព្រះសាស្តាថា)

បរាភវន្តំ បុរិសំ មយំ បុច្ឆាមគោតមំ
ភវន្តំ បុដ្ឋុមាគម្ម កីបរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយ មកសូមទូលសួរ នូវហេតុដែលគួរ ចម្រើនវិនាស
ប្រុសស្រីក្នុងលោ- កសន្និវាស ដែលនឹងវិនាស សាបសូន្យចាកគុណ។
ឆ្ពោះព្រះគោតម ព្រះអង្គមានបុណ្យ មេត្តានិមន្ត សម្តែងឱ្យទាន
ធម្មជាតដូចម្តេច ដែលជាប្រធាន នាំសត្វឱ្យមាន សេចក្តីវិនាស ។

(ព្រះសាស្តា ឆ្លើយតបនឹងទេវតាថា)

សុវិជានោ ភវំ ហោតិ សុវិជានោ បរាភវោ
ធម្មការោ ភវំ ហោតិ ធម្មទេស្សី បរាភវោ ។

អ្នកដែលចម្រើន គេក៏អាចស្គាល់ងាយ អ្នកដែលអន្តរាយ គេក៏អាចស្គាល់ពិត
អ្នកប្រាថ្នាធម៌ ល្អិតល្អក្នុងចិត្ត ហើយខំប្រព្រឹត្ត នឹងបានចម្រើន ។
អ្នកដែលទ្រុស្តធម៌ ស្អប់ធម៌ឥតកើន ឥតកើតចម្រើន វិនាសទៅមុខ ។

ឥតិ ហេតំ វិជានាម បឋមោ សោ បរាភវោ
ទុតិយំ ភគវា ព្រូហិ កី បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ
ក្តីវិនាសនេះ បើរាប់សង្ក្រោះ វិនាសនោះឈ្មោះ ទី ១ ទាន់ហន់ ។

បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្តែងឱ្យទាន
វិនាសទី ២ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្តីវិនាស ។

អសន្តស្ស បិយា ហោន្តិ សន្តេន កុរុតេបិយំ
អសតំ ធម្ម រោចេតិ[1] តំបរាភវតោ មុខំ ៗ

អ្នកដែលស្រឡាញ់ ពេញចិត្តស្នេហា តែនឹងមនុស្សណា អសប្បុរស
តែងមិនស្រឡាញ់ ពេញចិត្តទាំងអស់ នឹងអ្នកសប្បុរស មកធ្វើជាមិត្រ។
សេចក្តីស្រឡាញ់ ពេញចិត្តគំនិត ហើយទៅគប់មិត្រ អសប្បុរស
គាប់ចិត្តក្នុងធម៌ ឬមួយរបស់ ហេតុនោះទាំងអស់ នាំឱ្យវិនាស ។

ឥតិ ហេតំ វិជានាម ទុតិយោ សោ បរាភវោ
តតិយំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ៗ

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ
ក្តីវិនាសនេះ បើរាប់សង្ក្រោះ វិនាសនោះឈ្មោះ ទី ២ ទាន់ហន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្តែងឱ្យទាន
វិនាសទី ៣ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្តីវិនាស ។

ឆិទ្ទាសីលី សតាសីលី អទុដ្ឋាតា ច យោ នរោ
អលសោ កោធបញ្ញាណោ តំ បរាភវតោ មុខំ ៗ

អ្នកដេកច្រើន ១ និយាយច្រើន ១ និងអ្នកឥតព្រួយ ឥតគិតប្រឹងប្រែង
អ្នកខ្ជិលច្រអូស មិនមានខ្នះខ្នែង ខឹងច្រើនសម្តែង ឱ្យគេឃើញបាន ។

១-បាលីក្នុងច្បាប់រដ្ឋសង្គាយនាថា **អសតំ ធម្មំ រោចេតិ** ។

ហេតុធម៌ទាំងនោះ មិនជាកល្យាណ នាំឱ្យខកខានខាត ខូចប្រយោជន៍
មានជាប្រធាន តិចច្រើនដោយហោច នាំបង់ប្រយោជន៍ ហើយឱ្យវិនាស ។

ឥតិ ហេតំ វិជានាម តតិយោ សោ បរាភវោ
ចតុត្ថំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ
ក្តីវិនាសនេះ បើរាប់សង្ក្រោះ វិនាសនោះឈ្មោះ ទី ៣ ទាន់ហន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្តែងឱ្យទាន
វិនាសទី ៤ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្តីវិនាស ។

យោ មាតរំ វា បិតរំ វា ជិណ្ណកំ គតយោព្វនំ
បហុសន្តោឝ តរតិ តំ បរាភវតោ មុខំ ។

នរជនណា មានទ្រព្យធនធាន ហើយខ្ជិនមិនបាន ចិញ្ចឹមរក្សា
មាតាបិតា ដែលចាស់ជរា ហេតុនោះទៅជា នាំឱ្យវិនាស ។

ឥតិ ហេតំ វិជានាម ចតុត្ថោ សោ បរាភវោ
បញ្ចមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ
ក្តីវិនាសនេះ បើរាប់សង្ក្រោះ វិនាសនោះឈ្មោះ ទី ៤ ទាន់ហន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្តែងឱ្យទាន
វិនាសទី ៥ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្តីវិនាស ។

យោ ព្រាហ្មណំ វា សមណំ វា អញ្ញំ វាបិ វនិព្វកំ

មុសាវាទេន វញ្ឆោតិ តំ បរាភវតោ មុខំ ។

ជនបញ្ឆោតព្រាហ្មណ៍ ឬពួកសមណៈ ពួកស្មូម ឬអ្នកដទៃ ។
ដោយមុសាវាទ ឃ្លាតពាក្យប្រពៃ នោះប្រធាននៃ សេចក្តីវិនាស ។

ឥតិ ហេតំ វិជានាម បញ្ញាមោ សោ បរាភវោ
ឆដ្ឋំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ
ក្តីវិនាសនេះ បើរាប់សង្ក្រោះ វិនាសនោះឈ្មោះ ទី ៥ ទាន់ហន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្តែងឱ្យទាន
វិនាសទី ៦ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្តីវិនាស ។

បហូតវិត្តោ បុរិសោ សហិរញ្ញោ សភោជនោ
ឯកោ ភុញ្ជតិ សាទូនិតំ បរាភវតោ មុខំ ។

បុរសអ្នកមាន ទ្រព្យធនជានច្រើន មាសប្រាក់ចម្រើន និងគ្រឿងអាហារ
លបលាក់របស់ ដែលឆ្ងាញ់ពិសារ ស៊ីម្នាក់ឯងជា ប្រធានវិនាស ។

ឥតិ ហេតំ វិជានាម ឆដ្ឋមោ សោ បរាភវោ
សត្តមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ
ក្តីវិនាសនេះ បើរាប់សង្ក្រោះ វិនាសនោះឈ្មោះ ទី ៦ ទាន់ហន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្តែងឱ្យទាន
វិនាសទី ៧ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្តីវិនាស ។

ជាតិត្តង្ហោ ឆនត្តង្ហោ គោត្តត្តង្ហោ ច យោ នរោ
សញ្ញាតឹ អតិមញ្ញោតិ តំ បរាភវតោ មុខំ ៗ

អ្នកដែលប្រកាន់ ជាតិទ្រព្យត្រកូល ហើយមិនប្រមូល សាច់ញាតិសន្តាន
មើលងាយញាតិខ្លួន ដោយអាងខ្លួនមាន នោះជាប្រធាន សេចក្តីវិនាស ។

ឥតិ ហេតំ វិជានាម សត្តមោ សោ បរាភវោ
អដ្ឋមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ៗ

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ
ក្តីវិនាសនេះ បើរាប់សង្ក្រោះ វិនាសនោះឈ្មោះ ទី ៧ ទាន់ហន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្តែងឱ្យទាន
វិនាសទី ៨ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្តីវិនាស ។

ឥត្ថីធុត្តោ សុរាធុត្តោ អក្ខធុត្តោ ច យោ នរោ
លទ្ធំ លទ្ធំ វិនាសេតិ តំ បរាភវតោ មុខំ ៗ

ជនអ្នកប្រព្រឹត្ត ល្បែងបីប្រការ ល្បែងស្រីល្បែងស្រា ល្បែងភ្នាល់ទាំងឡាយ
ធ្វើទ្រព្យខ្លួនមាន ឱ្យអន្តរាយ ការល្បែងទាំងឡាយ នោះនាំវិនាស ។

ឥតិ ហេតំ វិជានាម អដ្ឋមោ សោ បរាភវោ
នវមំ ភគវា ព្រូហិ កឹ បរាភវតោ មុខំ ៗ

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ
ក្តីវិនាសនេះ បើរាប់សង្ក្រោះ វិនាសនោះឈ្មោះ ទី ៨ ទាន់ហន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្តែងឱ្យទាន

វិនាសទី ៩ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្តីវិនាស ។

សេហិ ឆារេហិ អសង្ខ្ជេ ខេសិយាសុ បទុស្សតិ
ទុស្សតិ បរទារេសុ តំ បរាភវតោ មុខំ ។

ប្រុសមិនត្រេកអរ នឹងប្រពន្ធខ្លួន ហើយទៅជាប់ជួន នឹងស្រីពេស្យា
ទ្រុស្តនឹងប្រពន្ធ កូនជនទាទា ហេតុនោះទៅជា នាំឱ្យវិនាស ។

ឥតិ ហេតំ វិជានាម ឆវមោ សោ បរាភវោ
ឆសមំ តគតា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ
ក្តីវិនាសនេះ បើរាប់សង្ខ្រោះ វិនាសនោះឈ្មោះ ទី ៩ ទាន់ហន់ ។
បពិត្រព្រះអង្គ ព្រះនាមភគវន្ត សូមទ្រង់និមន្ត សម្តែងឱ្យទាន
វិនាសទី ១០ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្តីវិនាស ។

អតីតយោព្វនោ ឋោសោ អាឆេតិ តិម្ពរុត្តឆឺ
តសា្ស ឥសា្ស ឆ សុបតិ តំ បរាភវតោ មុខំ ។

បុរសមានវ័យ ដែលចាស់ហួសពេក ហើយមានតម្រេក ដោយក្តីតណ្ហា
នាំយកស្រីក្មេង មកធ្វើភរិយា ហេតុនោះទៅជា នាំឱ្យវិនាស ។

ឥតិ ហេតំ វិជានាម ឆសមោ សោ បរាភវោ
ឯកាឆសមំ តគតា ព្រូហិ កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ
ក្តីវិនាសនេះ បើរាប់សង្ខ្រោះ វិនាសនោះឈ្មោះ ទី ១០ ទាន់ហន់ ។

បពិត្រព្រះអង្គ ព្រះនាមកគវ័ន្ត សូមទ្រង់និមន្ត សម្តែងឱ្យទាន
វិនាសទី ១១ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្តីវិនាស ។

ឥត្ថី សោណ្ឌី ឥតិរណី បុរិសំ វាបិ តាទិសំ
ឥស្សរិយស្មឹ ឋបេតិ តំ បវាតវតោ មុខំ ២

បុរសតាំងស្រី អ្នកលេងខ្លះខ្លាយ ឬស្រីទាំងឡាយ តាំងបុរសនោះ
ដែលជាអ្នកលេង ខ្លះខ្លាយដូច្នោះ អំពើទាំងនោះ នាំឱ្យវិនាស ។

ឥតិ ហេតំ វិជានាម ឯកាទសមោ សោ បវាតវោ
ទ្វាទសមំ វតវា ព្រូហិ កឹ បវាតវតោ មុខំ ២

យើងខ្ញុំទាំងឡាយ បានដឹងជាក់ស្តែង វិនាសនេះឯង ព្រោះហេតុដូច្នោះ
ក្តីវិនាសនេះ បើរាប់សង្ក្រាះ វិនាសនោះឈ្មោះ ទី ១១ ទាន់ហន់។
បពិត្រព្រះអង្គ ព្រះនាមកគវ័ន្ត សូមទ្រង់និមន្ត សម្តែងឱ្យទាន
វិនាសទី ១២ អ្វីជាប្រធាន នាំសត្វឱ្យមាន សេចក្តីវិនាស ។

អប្បភោគោ មហាតណ្ហោ ខត្តិយេ ជាយតេ កុលេ
សោ ច រជ្ជំ បត្ថយតិ តំ បវាតវតោ មុខំ ២

ជនណាកើតក្នុង ត្រកូលជាក្សត្រ អ្នកខ្សត់សម្បត្តិ ហើយប្រាថ្នាធំ
ចង់បានជាស្តេច សោយរាជ្យសុកសម្ភ ហេតុនោះនឹងនាំ ឱ្យដល់វិនាស ។

ឯតេ បវាតវេ លោកេ បណ្ឌិតោ សមវេក្ខិយ
អរិយទស្សនសម្បន្នោ[1] ស លោកំ ភជតេ សិវំ[2] ២

១-បាលីក្នុងច្បាប់រដ្ឋសង្គាយនាថា **អរិយោ ទស្សនសម្បន្នោ** ។ ២-បាលីថា **សិវំ** ក្នុងទីឯទៀត ។ បានដល់-

ជនជាបណ្ឌិត គំនិតប្រសើរ បានឃើញដំណើរ នៃហេតុវិនាស
ដល់សត្វក្នុងលោ- កសន្និវាស គេចពីវិនាស គប់រកចម្រើន ។

បរាភវសុត្តំ និដ្ឋិតំ

បរាភវសូត្រ ចប់

(បិដកលេខ ៥៤ ទំព័រ ៣៦)

ប្រែជាពាក្យកាព្យដោយ**ព្រះធម្មិស្សរោ ឯក-ញឹម**
អតីតព្រះវិន័យធរស្រុកសូទ្រនិគម ខេត្តស្បៃមរាប ។

មហាសមយសុត្តារម្ភោ

ទុល្លភំ ទស្សនំ យស្ស សម្ពុទ្ធស្ស អភិណ្ហសោ
លោកម្ហិ អន្ធភូតស្មិំ ទុល្លភុប្បាទសត្តនោ
សក្កាសុ កបិលវត្ថុស្មិំ វិហរន្តំ មហាវនេ
តន្ទស្សនាយ សម្ពុទ្ធំ ភិក្ខុសង្ឃញ្ច និម្មលំ
ទសធា សន្តឈោយ្យាសុ លោកធាតូសុ ទេវតា
អនេកា អប្បមេយ្យា ច មោទមានា សមាគតា
តាសំ បិយំ មនាបញ្ច ចិត្តស្បោទគ្គិយាវហំ
យំ សោ ទេសេសិ សម្ពុទ្ធោ ហាសយន្តោតិ មេ សុតំ
ទេវកាយប្បហាសត្តំ តំ សុត្តន្តំ ភណាម សេ ។

ព្រះនិព្វាន តែក្នុងទីនេះ អដ្ឋកថាប្រាប់ថា បានដល់សេចក្តីសុខក្សេមក្សាន្តក្នុងមនុស្ស និងទេវតា ។

មហាសមយសូត្រ

(បិដកលេខ ១៧ ទំព័រ ១៦៨)

ឯវម្មេ សុតំ *សូត្រនេះ (ឈ្មោះមហាសមយសូត្រ) គឺខ្ញុំ (ឈ្មោះអានន្ទ) បានស្តាប់មកហើយយ៉ាងនេះថា ។*

ឯកំ សមយំ ភគវា សក្កេសុ វិហរតិ កបិលវត្ថុស្មឹ មហាវនេ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ សព្ពេហេវ អរហន្តេហិ *សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងមហាវ័នជិតក្រុងកបិលវត្ថុ ក្នុងសក្កជនបទ ព្រមទាំងភិក្ខុសង្ឃច្រើនចំនួន ៥០០ រូប សុទ្ធតែជាព្រះអរហន្តទាំងអស់ ។*

ឧសហិ ច លោកធាតូហិ ទេវតា យេភុយ្យេន សន្និបតិតា ហោន្តិ ភគវន្តំ ឧស្សុឝាយ ភិក្ខុសង្ឃញ្ច *ទេវតាទាំងឡាយក៏មកអំពីលោកធាតុទាំង ១០ ប្រជុំគ្នាជាច្រើនដើម្បីឃើញនូវព្រះមានព្រះភាគ និងភិក្ខុសង្ឃ ។*

អថ ខោ ចតុន្នំ សុទ្ធាវាសកាយិកានំ ទេវតានំ ឯតទហោសិ *គ្រានោះឯង ទេវតាទាំងឡាយដែលនៅក្នុងជាន់សុទ្ធាវាស ៤ អង្គមានសេចក្តីត្រិះរិះដូច្នេះថា*

អយំ ខោ ភគវា សក្កេសុ វិហរតិ កបិលវត្ថុស្មឹ មហាវនេ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ សព្ពេហេវ អរហន្តេហិ *ព្រះមានព្រះភាគនេះ ព្រះអង្គគង់នៅក្នុងមហាវ័នជិតក្រុងកបិលវត្ថុ ក្នុងសក្កជនបទព្រមទាំងភិក្ខុសង្ឃច្រើនចំនួន ៥០០ រូប សុទ្ធតែជាព្រះអរហន្តទាំងអស់ ។*

ឧសហិ ច លោកធាតូហិ ទេវតា យេភុយ្យេន សន្និបតិតា ហោន្តិ ភគវន្តំ ឧស្សុឝាយ ភិក្ខុសង្ឃញ្ច *ទេវតាទាំងឡាយក៏មកអំពីលោកធាតុទាំង ១០ ប្រជុំគ្នាជាច្រើន ដើម្បីឃើញនូវព្រះមានព្រះភាគ និងភិក្ខុសង្ឃ*

យន្នូន មយម្បិ យេន ភគវា តេនុបសង្កមេយ្យាម ឧបសង្កមិត្វា ភគវតោ សន្តិកេ បច្ចេកំ គាថំ ភាសេយ្យាមាតិ *បើដូច្នេះ គួរយើងទាំងអស់គ្នា ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ គប្បីពោលនូវគាថាមួយ ម្នាក់ ៗ ក្នុងសម្នាក់នៃព្រះមានព្រះភាគ ។*

អថ ខោ តា ទេវតា សេយ្យថាបិ នាម ពលវា បុរិសោ សមិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សមិញ្ជេយ្យ ឯវមេវ សុទ្ធាវាសេសុ ទេវេសុ អន្តរហិតា ភគវតោ បុរតោ បាតុរហេសុំ *លំដាប់នោះ ទេវតាទាំងនោះឯង ក៏បាត់អំពីសុទ្ធាវាសព្រហ្មលោក មកប្រាកដក្នុងទីចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ (ដោយឆាប់រហ័ស) គួរនាដូចជាបុរសមានកម្លាំងលាដៃដែលបត់ចូល ឬបត់នូវដៃដែលលាចេញ ។*

អថ ខោ តា ទេវតា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ *គ្រានោះ ពួកទេវតានោះក៏ថ្វាយបង្គំព្រះមានព្រះភាគហើយឋិតនៅក្នុងទីដ៏សមគួរ។*

ឯកមន្តំ ឋិតា ខោ ឯកា ទេវតា ភគវតោ សន្តិកេ ឥមំ គាថំ អភាសិ *លុះទេវតាទាំងនោះ ឋិតនៅក្នុងទីដ៏សមគួរហើយទើបទេវតា ១ អង្គពោលនូវគាថានេះក្នុងសម្នាក់នៃព្រះមានព្រះភាគថា*

មហាសមយោ បវនស្មឹ ទេវកាយា សមាគតា
អាគតម្ហ ឥមំ ធម្មសមយំ ទក្ខិតាយេ អបរាជិតសង្ឃន្តិ ៗ

ថ្ងៃនេះជាថ្ងៃប្រជុំធំក្នុងដងព្រៃ ពួកទេវតាក៏មកប្រជុំគ្នាហើយ យើងទាំងឡាយ (លុះឃើញពួកទេវតាប្រជុំគ្នាយ៉ាងនេះហើយ) ក៏នាំគ្នាមកកាន់ទីប្រជុំប្រកបដោយធម៌នេះ ដើម្បីឃើញនូវអបរាជិតសង្ឃ គឺសង្ឃដែលមារផ្ចាញ់មិនបាន ។

អថ ខោ អបរ ទេវតា ភគវតោ សន្តិកេ គាថំ អភាសិ *លំដាប់នោះ ទេវតា ១ អង្គទៀត ក៏ពោលនូវគាថានេះក្នុងសម្នាក់នៃព្រះមានព្រះភាគថា*

តត្រ ភិក្ខវោ សមាទហំសុ ចិត្តមត្តនោ ទ្វជុកំ អកំសុ
សារថីវ ទេត្តានិ គហេត្វា ឥន្ទ្រិយានិ រក្ខន្តិ បណ្ឌិតាតិ ។

ពួកភិក្ខុក្នុងទីប្រជុំនោះ ប្រកបដោយសមាធិធ្វើចិត្តរបស់ខ្លួន (ដែលវៀចកោង) ឱ្យជាចិត្តស្ងួតត្រង់ ភិក្ខុជាបណ្ឌិតទាំងឡាយតែងរក្សានូវឥន្ទ្រិយ (ដោយល្អ) ដូចជានាយសារថីដែលកាន់ទប់នូវខ្សែបរទុកដូច្នោះឯង ។

អថ ខោ អបរ ទេវតា ភគវតោ សន្តិកេ គាថំ អភាសិ *លំដាប់នោះ ទេវតា ១ អង្គទៀត ក៏ពោលនូវគាថានេះក្នុងសម្នាក់នៃព្រះមានព្រះភាគថា*

ឆេត្វា ខីលំ ឆេត្វា បលិឃំ ឥន្ទខីលំ ឧហច្ច មនេជា
តេ ចរន្តិ សុទ្ធា វិមលា ចក្ខុមតា សុទន្តា សុសុនាគាតិ ។

ពួកភិក្ខុទាំងនោះ កាត់បង់នូវដែកគោល (គឺរាគៈ ទោសៈ មោហៈ) កាត់បង់នូវនុកទ្វារ (គឺរាគៈ ទោសៈ មោហៈ) គាល់រំលើងនូវសសរគោល (គឺរាគៈ ទោសៈ មោហៈ) ជាអ្នកមិនមានតណ្ហាជាគ្រឿងញាប់ញ័រ ជាអ្នកបរិសុទ្ធស្អាតប្រាសចាកមន្ទិល ជានាគកំលោះដែលព្រះពុទ្ធជាម្ចាស់ប្រកបដោយចក្ខុ ៥ ទ្រង់ទូន្មានល្អហើយ តែងត្រាច់ទៅបានក្នុងទិសទាំង ៤ មិនមានទើសទាល់ ។

អថ ខោ អបរ ទេវតា ភគវតោ សន្តិកេ គាថំ អភាសិ *លំដាប់នោះ ទេវតា ១ អង្គទៀត ក៏ពោលនូវគាថានេះក្នុងសម្នាក់នៃព្រះ មានព្រះភាគថា*

យេកេចិ ពុទ្ធំ សរណំ គតាសេ ន តេ គមិស្សន្តិ អបាយភូមឹ
បហាយ មានុសំ ទេហំ ទេវកាយំ បរិបូរេស្សន្តីតិ ។

ពួកជនណាមួយ បានដល់នូវព្រះពុទ្ធជាទីពឹងទីរលឹកហើយ ពួកជននោះ ឯងនឹងមិនទៅកាន់អបាយភូមិឡើយ លុះលះបង់រាងកាយជារបស់មនុស្សទៅ ហើយនឹងទៅបំពេញពពួកនៃទេវតាមិនខាន ។

អថ ខោ ភគវា ភិក្ខូ អាមន្តេសិ យេភុយ្យេន ភិក្ខវេ ទសសុ លោក-ធាតូសុ ទេវតា សន្និបតិតា ហោន្តិ តថាគតំ ទស្សនាយ ភិក្ខុសច្ឆញ្ហា ។

លំដាប់នោះ ព្រះមានព្រះភាគទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ពួកទេវតាជាច្រើនអង្គក្នុងលោកធាតុទាំង ១០ មកប្រជុំគ្នាដើម្បីឃើញនូវតថាគត និងភិក្ខុសង្ឃ

យេបិ តេ ភិក្ខវេ អហេសុំ អតីតមទ្ធានំ អរហន្តោ សម្មាសម្ពុទ្ធា តេសម្បិ ភគវន្តានំ ឯតំ បរមាយេវ ទេវតា សន្និបតិតា អហេសុំ សេយ្យ-ថាបិ មយ្ហំ ឯតរហិ ។

ម្នាលភិក្ខុទាំងឡាយ ព្រះមានព្រះភាគទាំងឡាយណា ជាអរហន្តសម្ម-សម្ពុទ្ធដែលបានត្រាស់ដឹងហើយក្នុងអតីតកាល ពួកទេវតាមានប្រមាណប៉ុណ្ណោះ ដូចគ្នាមកប្រជុំគ្នាដើម្បីឃើញនូវព្រះមានព្រះភាគទាំងនោះ ដូចជាពួកទេវតា ដែលមកប្រជុំគ្នាដើម្បីឃើញតថាគតក្នុងកាលឥឡូវនេះដែរ ។

យេបិ តេ ភិក្ខវេ អនាគតមទ្ធានំ អរហន្តោ សម្មាសម្ពុទ្ធា តេសម្បិ ភគវន្តានំ ឯតំ បរមាយេវ ទេវតា សន្និបតិតា អនាគតា សេយ្យ-ថាបិ មយ្ហំ ឯតរហិ ។

ម្នាលភិក្ខុទាំងឡាយ ព្រះមានព្រះភាគទាំងឡាយណា ជាអរហន្តសម្ម-សម្ពុទ្ធនឹងបានត្រាស់ដឹងក្នុងអនាគតកាល ពួកទេវតាមានប្រមាណប៉ុណ្ណោះដូចគ្នា

នឹងមកប្រជុំគ្នាដើម្បីឃើញនូវព្រះមានព្រះភាគទាំងនោះ ដូចពួកទេវតាដែលមកប្រជុំគ្នាដើម្បីឃើញតថាគតក្នុងកាលឥឡូវនេះដែរ។

អាចិក្ខិស្សាមិ តិក្ខវេ ទេវកាយានំ នាមានិ កិត្តយិស្សាមិ តិក្ខវេ ទេវ-កាយានំ នាមានិ ទេសេស្សាមិ តិក្ខវេ ទេវកាយានំ នាមានិ ។

ម្នាលភិក្ខុទាំងឡាយ តថាគតនឹងប្រាប់នូវនាម និងគោត្ររបស់ពួកទេវតាទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងពោលនូវនាម និងគោត្ររបស់ពួកទេវតាទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវនាម និងគោត្ររបស់ពួកទេវតាទាំងឡាយ។

តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ *ចូរអ្នកទាំងឡាយប្រុងស្តាប់រឿងនោះចុះ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសម្តែងឱ្យស្តាប់។*

ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ *ភិក្ខុទាំងនោះទទួលធ្វើតបព្រះពុទ្ធដីកានៃព្រះមានព្រះភាគដូច្នេះថា ព្រះករុណាព្រះអង្គ។*

ភគវា ឯតទវោច *ទើបព្រះមានព្រះភាគទ្រង់សម្តែងនូវភាសិតនេះថា*

សិលោកមនុកស្សាមិ យត្ត ភុម្មា តទស្សិតា
យេ សិតា គិរិគព្ភរំ បហិតត្តា សមាហិតា ។

តថាគតនឹងធ្វើនូវស្មោកភូមទេវតា (បិតនៅ) ក្នុងទីណា ពួកភិក្ខុក៏អាស្រ័យនូវទីនោះ ពួកភិក្ខុណាដែលនៅអាស្រ័យនឹងផ្ទៃភ្នំ បញ្ជូនចិត្តទៅកាន់អារម្មណ៍ល្អ មានចិត្តតម្កល់នឹង (តថាគតនឹងសម្តែងគុណនៃភិក្ខុទាំងនោះ)។

បុថុសីហាវ សល្លីនា ឈោមហំសាតិសម្ភនោ
ឱទាតមនសា សុទ្ធា ឥប្បសន្នមនាវិលា ៗ

ពួកភិក្ខុច្រើនរូបសម្ងំនៅក្នុងកម្មដ្ឋាន គ្របសង្កត់នូវការព្រឺរោមព្រឺស្បែក (ឥតមានភ័យខ្លាច) ដូចសត្វសីហៈ មានចិត្តផូរផង់បរិសុទ្ធជ្រះថ្លា ឥតមានល្អក់ឡើយ ។

អិយ្យោ បញ្ចសតេ ញត្វា ឥនេ កាបិលវត្ថវេ
តតោ អាមន្តយី សត្ថា សាវកេ សាសនេ រតេ ៗ
ឧទកាយា អតិក្កន្តា តេ ឥជ្ឈានាថ តិក្ខវោ
តេ ច អាតប្បមករុំ សុត្វា ពុទ្ធស្ស សាសនំ ៗ

លំដាប់នោះ ព្រះសាស្តាទ្រង់ជ្រាបនូវពួកព្រះអរហន្តជាង ៥០០ រូប[1] នៅក្នុងដងព្រៃជិតក្រុងកបិលវត្ថុ ទើបទ្រង់ត្រាស់នឹងពួកភិក្ខុជាសាវ័កដែលត្រេកអរក្នុងសាសនាថា ម្នាលភិក្ខុទាំងឡាយ ពួកនៃទេវតាមានពន្លឺរស្មីដ៏រុងរឿង (មកហើយ) អ្នករាល់គ្នាចូរស្តាប់នូវពួកទេវតាទាំងនោះ (ដោយទិព្វចក្ខុញ្ញាណ) ចុះ ឯពួកភិក្ខុទាំងនោះបានស្តាប់នូវពាក្យប្រដៅនៃព្រះពុទ្ធជាម្ចាស់ហើយ ក៏ធ្វើនូវការព្យាយាម (ដើម្បីទិព្វចក្ខុញ្ញាណនោះ) ។

តេសំ ចាតុរហុ ញ្ញាណំ អមនុស្សាឆទស្សនំ
អប្បេកេ សតមទ្ទក្ខុំ សហស្សំ អថ សត្តរឹ ៗ

ទិព្វចក្ខុញ្ញាណសម្រាប់មើលឃើញនូវពួកអមនុស្ស (ទេវតា) ក៏កើតមានប្រាកដដល់ពួកភិក្ខុទាំងនោះ ពួកភិក្ខុខ្លះបានឃើញនូវអមនុស្ស ១០០ ខ្លះបាន

១-អដ្ឋកថាថា ជាង ៥00 រូប ព្រោះរាប់ព្រះសម្មាសម្ពុទ្ធបញ្ចូលផង ។

ឃើញនូវអមនុស្ស ១០០០ ខ្លះបានឃើញនូវអមនុស្ស ៧០ ពាន់។

សតំ ឯកេ សហស្សានំ អមនុស្សានមទ្ទសុំ
អប្បេកេនន្តមទ្ទក្ខុំ និសាសព្វា ផុដា អហុំ ៗ

ពួកភិក្ខុខ្លះបានឃើញនូវអមនុស្ស ១ សែន ខ្លះបានឃើញនូវអមនុស្សច្រើន (មិនមានកំណត់) អមនុស្សទាំងនោះ ក៏ផ្សាយទៅពាសពេញក្នុងទិសទាំងពួង ។

តញ្ច សព្វំ អភិញ្ញាយ ឥឥត្តិឝ្ឋាន ចក្ខុមា
តតោ អាមន្តយី សត្ថា សាឥកេ សាសនេ រតេ ៗ
ទេវកាយា អភិក្កន្តា តេ ទិជានាថ តិក្ខតោ
យេ ខោហំ កិត្តយិស្សាមិ តិរហិ អនុបុព្វសោ ៗ

លំដាប់នោះ ព្រះសាស្តាប្រកបដោយចក្ខុ ៥ ទ្រង់ពិចារណាហើយជ្រាបនូវហេតុនោះទាំងអស់ ទើបទ្រង់ត្រាស់នឹងពួកភិក្ខុជាសាវ័កអ្នកត្រេកអរក្នុងសាសនាថា ម្នាលភិក្ខុទាំងឡាយ ពួកទេវតាមានពន្ធឹរស្មើរុងរឿង (មកហើយ) អ្នករាល់គ្នាចូរស្គាល់នូវពួកទេវតាទាំងនោះចុះ តថាគតនឹងប្រាប់ (នូវទេវតាទាំងនោះ) ដល់អ្នករាល់គ្នាដោយពាក្យតាមលំដាប់ហូរហែ ។

សត្តសហស្សា តេ យក្ខា ភុម្មា ការិលវត្តិនា
ឥទ្ធិមន្តោ ជុតិមន្តោ ឥឥណ្ណវន្តោ យសស្សិនោ
មោឝមានា អតិក្កាមុំ តិក្ខុនំ សមិតីឥនំ ៗ

យក្សទាំង ៧ ពាន់ ជាភូមិទេវតាអាស្រ័យនៅនាក្រុងកបិលវត្ថុ មានឫទ្ធិ មានអានុភាព មានសម្បុរកាយ មានយស មានចិត្តរីករាយនាំគ្នាមកកាន់មហាវ័នជាទី

ប្រជុំនៃភិក្ខុទាំង៥ឡាយ ។

ឆសហស្សា ហោមវតា យក្ខា ឆានត្តវណ្ណោ
ឥទ្ធិមន្តោ ជុតិមន្តោ វណ្ណវន្តោ យសស្សិនោ
មោឝមានា អតិក្កាមុំ តិក្ខុនំ សមិតឹ ឥនំ ៥

ពួកយក្ស ៦ ពាន់ដែលកើតនៅនាភ្នំហិមវន្ត មានសម្បុរផ្សេង១ គ្នា មានឫទ្ធិ មានអានុភាព មានវស្មី មានយស មានចិត្តរីករាយ នាំគ្នាមកកាន់មហាវ័នជាទីប្រជុំនៃភិក្ខុទាំង៥ឡាយ ។

សាតាគិរ តិសហស្សា យក្ខា ឆានត្តវណ្ណោ
ឥទ្ធិមន្តោ ជុតិមន្តោ វណ្ណវន្តោ យសស្សិនោ
មោឝមានា អតិក្កាមុំ តិក្ខុនំ សមិតឹ ឥនំ ៥

ពួកយក្ស ៣ ពាន់ដែលនៅអាស្រ័យនឹង៥ភ្នំសាតាគិរី មានសម្បុរផ្សេង ១ គ្នា មានឫទ្ធិ មានអានុភាព មានវស្មី មានយស មានចិត្តរីករាយនាំគ្នាមកកាន់មហាវ័នជាទីប្រជុំនៃភិក្ខុទាំង៥ឡាយ ។

ឥច្ឆេតេ សោឡសសហស្សា យក្ខា ឆានត្តវណ្ណោ
ឥទ្ធិមន្តោ ជុតិមន្តោ វណ្ណវន្តោ យសស្សិនោ
មោឝមានា អតិក្កាមុំ តិក្ខុនំ សមិតឹឥនំ ៥

ពួកយក្ស ១៦ ពាន់នេះ មានសម្បុរផ្សេង១ គ្នា មានឫទ្ធិ មានអានុភាព មានវស្មី មានយស មានចិត្តរីករាយ នាំគ្នាមកកាន់មហាវ័នជាទីប្រជុំនៃភិក្ខុទាំង៥ឡាយ ដោយប្រការដូច្នេះ ។

ទេសប្បាមិក្ខា បញ្ចាសតា យក្ខា ឆានត្តវណ្ណោ
ឥទ្ធិមន្តោ ជុតិមន្តោ វណ្ណវន្តោ យសស្សិនោ

មោទមានា អតិក្កាមុំ គិក្ខនំ សមិតឹ ឥនំ ។

ពួកយក្សដែលកើតនៅនាវេស្សាមិត្តបព៌ត មានសម្បុរផ្សេង ៗ គ្នា មានឫទ្ធិ មានអានុភាព មានរស្មី មានយស មានចិត្តរីករាយ នាំគ្នាមកកាន់មហាវ័នជាទីប្រជុំនៃភិក្ខុទាំង៤ឡាយ ។

កុម្ភីរោ រាជគហិកោ វេបុល្លស្ស ន្ទិវេសនំ
គិយ្យោ នំ សតសហស្សំ យក្ខានំ បយិរុបាសតិ
កុម្ភីរោ រាជគហិកោ សោបាគា សមិតឹឥនំ ។

កុម្ភីរយក្សដែលកើតនៅនានគររាជគ្រឹះ ឯភ្នំឈ្មោះវេបុល្ល ជាទីនៅរបស់កុម្ភីរយក្សនោះ មានយក្សជាង ១ សែននាក់ តែងចូលទៅសេពគប់នឹងកុម្ភីរយក្សនោះ កុម្ភីរយក្សដែលកើតក្នុងនគររាជគ្រឹះនោះ (ព្រមទាំងបរិវារ) ក៏មកកាន់មហាវ័នជាទីប្រជុំ (នៃភិក្ខុទាំង៤ឡាយដែរ) ។

បុរិមញ្ញា ទិសំ រាជា ឆតរដ្ឋោ បសាសតិ
គន្ធព្វានំ អធិបតិ មហារាជា យសស្សិសោ ។

ព្រះបាទធតរដ្ឋៈ ទ្រង់ប្រៀនប្រដៅក្នុងទិសខាងកើត ទ្រង់ជាធំលើគន្ធព្វទាំង៤ឡាយ ព្រះអង្គជាមហារាជមានយសធំ ។

បុត្តាបិតស្ស ពហវោ ឥន្ទនាមា មហព្ពលា
ឥទ្ធិមន្តោ ជុតិមន្តោ វណ្ណវន្តោ យសស្សិនោ
មោទមានា អតិក្កាមុំ គិក្ខនំ សមិតឹ ឥនំ ។

ព្រះរាជបុត្រទាំង៤ឡាយរបស់ព្រះបាទធតរដ្ឋៈនោះ មានច្រើនរូប មានឈ្មោះថាឥន្ទៈ មានកម្លាំងច្រើន មានឫទ្ធិ មានអានុភាព មានរស្មី មានយស មានចិត្ត

រីករាយ នាំគ្នាមកកាន់មហាវ័នជាទីប្រជុំនៃភិក្ខុទាំងឡាយ។

ទក្ខិណាយ ទិសំ រាជា វិរូឡ្ហោ តំ បសាសតិ
កុម្ភណ្ឌានំ អធិបតិ មហារាជា យសស្សិសោ ៗ

ព្រះបាទវិរូឡ្ហៈ ទ្រង់ប្រៀនប្រដៅក្នុងទិសខាងត្បូង ជាធំលើពួកកុម្ភណ្ឌ ព្រះអង្គជាមហារាជមានយសធំ។

បុត្តាបិ តស្ស ពហវោ ឥន្ទនាមា មហព្ពលា
ឥទ្ធិមន្តោ ជុតិមន្តោ វណ្ណវន្តោ យសស្សិនោ
មោទមានា អតិក្កាមុំ តិក្ខុនំ សមិតឹ វនំ ៗ

ព្រះរាជបុត្រទាំងឡាយរបស់ព្រះបាទវិរូឡ្ហៈនោះ មានច្រើនរូប មាននាមថា ឥន្ទៈ មានកម្លាំងច្រើន មានឫទ្ធិ មានអានុភាព មានរស្មី មានយស មានចិត្តរីក-រាយ នាំគ្នាមកកាន់មហាវ័នជាទីប្រជុំនៃភិក្ខុទាំងឡាយ។

បច្ឆិមញ្ច ទិសំ រាជា វិរូបក្ខោ បសាសតិ
នាគានញ្ច អធិបតិ មហារាជា យសស្សិសោ ៗ

ព្រះបាទវិរូបក្ខៈ ទ្រង់ប្រៀនប្រដៅក្នុងទិសខាងលិច ទ្រង់ជាធំលើពួកនាគ ព្រះអង្គជាមហារាជមានយសធំ។

បុត្តាបិ តស្ស ពហវោ ឥន្ទនាមា មហព្ពលា
ឥទ្ធិមន្តោ ជុតិមន្តោ វណ្ណវន្តោ យសស្សិនោ
មោទមានា អតិក្កាមុំ តិក្ខុនំ សមិតឹ វនំ ៗ

ព្រះរាជបុត្រទាំងឡាយរបស់ព្រះបាទវិរូបក្ខៈនោះ មានច្រើនរូប មាននាមថាឥន្ទៈ មានកម្លាំងច្រើន មានឫទ្ធិ មានអានុភាព មានរស្មី មានយស មានចិត្តរីករាយ នាំគ្នាមកកាន់មហាវ័នជាទីប្រជុំនៃភិក្ខុទាំងឡាយ។

ទ្វត្តរញ្ញោ ទិសំ រាជា កុវេរោ តំ បសាសតិ
យក្ខានញ្ញោ អធិបតិ មហារាជា យសស្សិសោ ៥

ព្រះបាទកុវេរៈ ទ្រង់ប្រៀនប្រដៅក្នុងទិសខាងជើងនោះ ទ្រង់ជាធំលើពួកយក្ស ព្រះអង្គជាមហារាជមានយសធំ។

បុត្តាបិ តស្ស ពហវោ ឥន្ទនាមា មហព្ពលា
ឥទ្ធិមន្តោ ជុតិមន្តោ វណ្ណវន្តោ យសស្សិនោ
មោទមានា អតិក្កាមុំ ភិក្ខូនំ សមិតឹ វនំ ៥

ព្រះរាជាបុត្រទាំងឡាយរបស់ព្រះបាទកុវេរៈនោះ មានច្រើនរូប មាននាមថាឥន្ទៈ មានកម្លាំងច្រើន មានឫទ្ធិ មានអានុភាព មានរស្មី មានយស មានចិត្តរីករាយ នាំគ្នាមកកាន់មហាវ័នជាទីប្រជុំនៃភិក្ខុទាំងឡាយ។

បុរិមំ ទិសំ ធតរដ្ឋោ គន្ធិណេន ទិរុឡ្ហកោ
បច្ឆិមេន ទិរូបក្ខោ កុវេរោ ទ្វត្តរំ ទិសំ ៥
ចត្តារោ តេ មហារាជា សមន្តា ចតុរោ ទិសា
ឧទ្ធលុមានា អដ្ឋំសុ ទវេ ការចិលវត្តវេ ៥

ព្រះបាទធតរដ្ឋៈ ជាធំក្នុងទិសខាងកើត ព្រះបាទវិរូឡ្ហកៈ ជាធំក្នុងទិសខាងត្បូង ព្រះបាទវិរូបក្ខៈ ជាធំក្នុងទិសខាងលិច ព្រះបាទកុវេរៈ ជាធំក្នុងទិសខាងជើង មហារាជទាំង ៤ ព្រះអង្គនោះ បានញុំាងទិសទាំង ៤ ដោយជុំវិញឱ្យភ្លឺព្រោងព្រាត (ដោយរស្មីរបស់ខ្លួន) ឋិតនៅក្នុងមហាវ័នជិតក្រុងកបិលវត្ថុ។

តេសំ មាយាទិនោ ឆាសា អាគុំ ទញ្ញានិកា សហា
មាយា កុដេណ្ឌា ទិដេណ្ឌា ទិដ្ឋិ ទិដ្ឋិ សហ ៥
ចន្ទនោ កាមសេដ្ឋោ ច កិន្ទិយណ្ឌា និយណ្ឌា ច

បនាទោ ឱបមញ្ញោ ច ទេវសូតោ ច មាតលិ ។
ចិត្តសេនោ ច គន្ធព្ពោ នឡោរាជា ជនេសភោ
អាគា បញ្ចសិខោ ចេវ តិម្ពរូ សូរិយវច្ឆសា ។

ពួកទាស:នៃមហារាជទាំង ៤ ព្រះអង្គនោះគឺ កុដេណ្ឌ ១ វេដេណ្ឌ ១ វិដូ ១ វិដូដ: ១ ចន្ទន: ១ កាមសេដ្ឋ: ១ កិន្នុយណ្ឌ ១ និយណ្ឌ ១ សុទ្ធតែជាអ្នកមានមាយា ជាអ្នកល្បួងបញ្ឆោត ជាអ្នកអួតអាង តែងធ្វើនូវមាយាមកជាមួយគ្នាដែរ ។ ទាំងទេវរាជអម្បាលនេះគឺ បនាទ: ១ ឱបមញ្ញ: ១ ទេវសូត ១ មាតលី ១ ចិត្តគន្ធព្វ ១ សេនគន្ធព្វ ១ នឡោរាជ: ១ ជនោសភ: ១ បញ្ចសិខ: ១ តិម្ពរុ ១ នាងសុរិយវច្ឆសា (ជាធីតារបស់តិម្ពរុនោះ) ១ ក៏នាំគ្នាមកដែរ ។

ឯតេ ចញ្ញេ ច រាជានោ គន្ធព្វា សហ រាជុភិ
មោទមានា អតិក្កាមុំ តិក្ខុំ សមិតីវនំ ។

គន្ធព្វរាជទាំងឡាយនេះផង ពួកជនៃទេវផង ព្រមទាំងទេវរាជទាំងឡាយ មានចិត្តរីករាយ នាំគ្នាមកកាន់មហាវ័នជាទីប្រជុំនៃភិក្ខុទាំងឡាយ ។

អថាគុំ នាគសា នាគា វេសាលា សហតច្ឆកា
កម្ពលស្សតរា អាគុំ ឆាយាគា សហ ញ្ញាតិភិ ។

មួយទៀត នាគទាំងឡាយនៅក្នុងស្រះឈ្មោះនាគស: និងនាគនៅក្នុងក្រុងវេសាលី ក៏នាំគ្នាមកជាមួយនឹងនាគបរិស័ទឈ្មោះតច្ឆក: កម្ពលនាគ និងអស្សតរនាគ (ដែលនៅនាជើងភ្នំសិនេរុ) ក៏នាំគ្នាមក នាគទាំងឡាយនៅក្នុងកំពង់បយាគ: ព្រមទាំងពពួកញាតិក៏បាននាំគ្នាមកដែរ ។

យាមុនា ឆតរជ្ជា ច អាគូ នាគា យសស្សិនោ

ឯរាវណោ មហានាគោ សោចាគា សមិតីវនំ ។

ពួកនាគដែលនៅក្នុងទន្លេយមុនាក្តី នាគដែលកើតក្នុងត្រកូលស្តេចធតរដ្ឋ: មានបរិវារដ៏ច្រើនក្តី ក៏បាននាំគ្នាមក សូម្បីតែឯរាវណទេវបុត្តជាដំរីធំនោះសោត ក៏បានមកកាន់មហាវ័នជាទីប្រជុំ (នៃភិក្ខុទាំងឡាយដែរ) ។

យេ នាគរាជេ សហសា ហរន្តិ
ទិព្វា ទិជា បក្ខិ វិសុទ្ធចក្ខូ
វេហាយសា តេ វនមជ្ឈបត្តា
ចិត្រា សុបណ្ណា ឥតិ តេស នាមំ ។

ពួកគ្រុឌណា ជាសត្វស្លាបមានកំណើតពីរដង មានអានុភាពជាទិព្វ មានភ្នែកដ៏បរិសុទ្ធ (អាចមើលឃើញនូវពួកនាគអំពីចម្ងាយចំនួន ១០០ យោជន៍ ១០០០ យោជន៍) តែងចាប់យកនូវស្តេចនាគទៅដោយធាប់រហ័ស គ្រុឌទាំងនោះក៏ហើរមកតាមអាកាស បានមកដល់ពាក់កណ្តាលនៃមហាវ័ន គ្រុឌទាំងនោះ មានឈ្មោះថាចិត្រសុបណ្ណៈដូច្នេះ ។

អតយំ តទា នាគរាជានមាសិ
សុបណ្ណតោ ខេមមកាសិ ពុទ្ធោ
សណ្ហាហិ វាចាហិ ឧបត្ថយន្តា
នាគា សុបណ្ណា សរណមកំសុ ពុទ្ធំ ។

គ្រានោះ ស្តេចនាគទាំងឡាយក៏មិនមានសេចក្តីភ័យខ្លាចឡើយ ព្រះសម្ពុទ្ធជាម្ចាស់ក៏បានធ្វើ (ស្តេចនាគ) ឱ្យក្សេមក្សាន្តអំពីគ្រុឌ នាគ និងគ្រុឌទាំងឡាយក៏ត្រឡប់និយាយរកគ្នាដោយសម្តីដ៏ពីរោះ (ហាក់ដូចជាមិត្តសំឡាញ់នឹងគ្នា) បានធ្វើ

នូវព្រះពុទ្ធឱ្យជាទីពឹងទីរឭក ។

ជិតា ឥជិរហេឞ្ដេន សមុទ្ទំ អសុរាសិតា
ភាតរោ ទាសទស្សេតេ ឥទ្ធិមន្តោ យសស្សិនោ ៤

ពួកអសុរ (ណា) ដែលព្រះឥន្ទ្រឈ្នះហើយ អាស្រ័យនៅក្នុងសមុទ្រ ពួកអសុរទាំងនោះ ជាបងប្អូន(ជាប់ពន្ធ) នឹងព្រះឥន្ទ្រ ជាអ្នកមានឫទ្ធិ មានយស ។

កាលកញ្ជា មហាតិស្សា អសុរា ឆានវេយ្យសា
វេបចិត្តិ សុចិត្តិ ច បហារាទោ នមុចិ សហ ៤

កាលកញ្ជអសុរទាំងឡាយ មានកាយធំសម្បើមក្តី ទានវេយ្យសអសុរទាំង-ឡាយក្តី វេបចិត្តិអសុរក្តី សុចិត្តិអសុរក្តី បហារាទអសុរក្តី នមុចិទេវបុត្តមារក្តី ក៏មកជាមួយគ្នាដែរ ។

សតញ្ញា ពលិបុត្តានំ សព្ពេ វេរោចនាមកា
សន្នយ្ហិត្វា ពលិសេនំ រាហុភទ្ទមុបាគមុំ
សមយោឆានិ ភទ្ទន្តេ ភិក្ខូនំ សមិតីឥនំ ៤

កូនរបស់ពលិអសុរទាំង ១០០ នាក់មានឈ្មោះថា វេរោចៈទាំងអស់ ចងសៀតនូវគ្រឿងពលិសេនា ចូលមកគាល់រាហុអសុរិន្ទដ៏ចម្រើន ដោយពាក្យថា ឥឡូវនេះជាសម័យគួរនឹងប្រជុំគ្នា សេចក្តីចម្រើនចូរមានដល់ព្រះអង្គដូច្នេះហើយ ទេវតាទាំងនោះក៏នាំគ្នាមកកាន់មហាវ័នជាទីប្រជុំនៃភិក្ខុទាំងឡាយ ។

អាបោ ច ឥទា បថវី តេជោ វាយោ តទាគមុំ
វរុណា វារណា ឥទា សោមោ ច យសសា សហ ៤

អាបោទេវតាក្តី បឋវីទេវតាក្តី តេជោទេវតាក្តី វាយោទេវតាក្តី វរុណទេវតាក្តី

វរណទេវតាក្តី សោមទេវតាព្រមទាំងយសទេវតាក្តី ក៏បាននាំគ្នាមកក្នុងកាលនោះ។

មេត្តា ករុណា កាយិកា អាគុំ ទេវា យសស្សិនោ
ឧសេតេ ឧសធា កាយា សព្វេ ឆានត្តវណ្ណិនោ ៥
ឥទ្ធិមន្តោ ជុតិមន្តោ វណ្ណវន្តោ យសស្សិនោ
មោទមានា អតិក្កាមុំ ភិក្ខុនំ សមិតឹ វនំ ៥

ទេវតាទាំងឡាយ ដែលកើតដោយអំណាចមេត្តាឈាន និងករុណាឈាន ជាអ្នកមានយសក៏បាននាំគ្នាមក ទេវតាទាំង ១០ ពួកនេះ

បិតនៅដោយចំណែក ១០ សុទ្ធតែមានសម្បុរផ្សេងៗ គ្នាទាំងអស់ មានឫទ្ធិ មានអានុភាព មានរស្មី មាន

យស មានចិត្តរីករាយ នាំគ្នាមកកាន់មហាវនៈជាទីប្រជុំនៃភិក្ខុទាំងឡាយ។

វេណ្ហូទេវា សហលិ ច អសមា ច ឃុវេ យមា
ចន្ទស្សូបនិសា ទេវា ចន្ទមាគុំ បុរក្ខត្វា ៥

ពួកទេវតាឈ្មោះវេណ្ហូក្តី ឈ្មោះសហលីក្តី ឈ្មោះអសមាក្តី និងឈ្មោះយមៈទាំងពីរក្តី ពួកទេវតាដែលអាស្រ័យនូវព្រះចន្ទក្តី បានហែហម ព្រះចន្ទក៏មកដែ។

សូរិយស្សូបនិសា ទេវា សូរិយមាគុំ បុរក្ខត្វា
នក្ខត្តានិ បុរក្ខត្វា អាគុំ មន្ទវលាហកា ៥

ពួកទេវតាដែលអាស្រ័យនូវព្រះអាទិត្យ បានហែហមព្រះអាទិត្យមក ពួកទេវតាដែលអាស្រ័យនូវផ្កាយ ក៏ហែហមផ្កាយមក ទាំងមន្ទវលាហកទេវតាទាំង-ឡាយក៏មក។

វសូនំ វាសវោ សេដ្ឋោ សក្កោ ចាគា បុរិន្ទទោ

ឯសេតេ ឯសភា ភាយា សព្វេ ឆានឆ្តវណ្ណិនោ ៤
ឥទ្ធិមន្តោ ជុតិមន្តោ វណ្ណវន្តោ យសស្សិនោ
មោឝមានា អតិក្កាមុំ តិក្ខុនំ សមិតឺ ឝនំ ៤

សូម្បីសក្កទេវរាជទ្រង់ព្រះនាមវាសវបុរិន្ទទៈដ៏ប្រសើរជាងពួកទេវតា ក៏មកដែរ។ ទេវតាទាំង ១០ ពួកនេះបិតនៅដោយចំណែក ១០ សុទ្ធតែមានសម្បុរផ្សេងៗគ្នាទាំងអស់ មានឫទ្ធិ មានអានុភាព មានរស្មី មានយស មានចិត្តរីករាយក៏នាំគ្នាមកកាន់មហាវ័នជាទីប្រជុំនៃភិក្ខុទាំងឡាយ។

អថាគុំ សហភូ ឝេឝា ជលមគ្គិសិខារិវ
អរិដ្ឋកា ច រោជា ច ឧមាបុប្ផនិភាសិនោ ៤
វរុណា សហធម្មា ច អច្ចុតា ច អនេជកា
សុលេយ្យរុចិរា អាគុំ អាគុំ វាសវឝេសិនោ
ឯសេតេ ឯសភា ភាយា សព្វេ ឆានឆ្តវណ្ណិនោ ៤
ឥទ្ធិមន្តោ ជុតិមន្តោ វណ្ណវន្តោ យសស្សិនោ
មោឝមានា អតិក្កាមុំ តិក្ខុនំ សមិតឺ ឝនំ ៤

មួយទៀត ទេវតាទាំងឡាយឈ្មោះសហភូដ៏រុងរឿង បីដូចជាអណ្តាតភ្លើងក៏បានមក ពួកទេវតាឈ្មោះអរិដ្ឋកៈក្តី រោជៈក្តី ឧមាបុប្ផនិភាសីក្តី វរុណៈក្តី សហធម្មៈក្តី អច្ចុតៈក្តី អនេជកៈក្តី សុលេយ្យៈក្តី រុចិរៈក្តី ក៏បានមក ទាំងពួកទេវតាឈ្មោះវាសវនេសីក៏បានមក។ ទេវតាទាំង ១០ ពួកនេះបិតនៅដោយចំណែក ១០ សុទ្ធតែមានសម្បុរផ្សេងៗ គ្នាទាំងអស់ មានឫទ្ធិ មានអានុភាព មានរស្មី មានយស មានចិត្តរីករាយក៏នាំគ្នាមកកាន់មហាវ័នជាទីប្រជុំនៃភិក្ខុទាំងឡាយ។

សមានា មហាសមានា មានុសា មានុសុត្តមា
ខិឌ្ឌាបទោសិកា អាគុំ អាគុំ មនោបទោសិកា ៗ
អថាគុំ ហារយោ ទេវា យេ ច លោហិតវាសិនោ
បារគា មហាបារគា អាគុំ ទេវា យសស្សិនោ
ឥសេតេ ឥសឆា កាយា សព្ពេ ឆានត្តវណ្ណិនោ ៗ

ទេវតាទាំងឡាយឈ្មោះសមាន:ក្តី មហាសមាន:ក្តី មានុស:ក្តី មានុសុត្តម:ក្តី ខិឌ្ឌាបទូសិក:ក្តី ក៏បានមក ពួកទេវតាឈ្មោះមនោបទូសិក:ក៏បានមក ទាំងពួកទេវតាឈ្មោះហរិក្តី ឈ្មោះលោហិតវាសីក្តី ក៏បានមក ទេវតាទាំងឡាយឈ្មោះបារគ:ក្តី ឈ្មោះមហាបារគ:ក្តី ជាអ្នកមានយសក៏បានមក ។

ឥទ្ធិមន្តោ ជុតិមន្តោ វណ្ណវន្តោ យសស្សិនោ
មោទមានា អតិក្កាមុំ តិក្ខុនំ សមិតឹ វនំ ៗ

ទេវតាទាំង ១០ ពួកនេះ បិតនៅដោយចំណែក ១០ សុទ្ធតែមានសម្បុរផ្សេងៗគ្នាទាំងអស់ មានឫទ្ធិ មានអានុភាព មានរស្មី មានយស មានចិត្តរីករាយ ក៏បាននាំគ្នាមកកាន់មហាវ័នជាទីប្រជុំនៃភិក្ខុទាំងឡាយ ។

សុក្កា ករម្ភា អរុណា អាគុំ វេយនសា សហ
ឱទាតគយ្ហា បាមោក្ខា អាគុំ ទេវា ទិចក្ខណា ៗ
សទាមត្តា ហារគជា មិស្សកា ច យសស្សិនោ
ថនយំ អាគ បជ្ជុន្នោ យោ ទិសា អតិវស្សតិ ៗ

ទេវតាទាំងឡាយឈ្មោះសុក្ក:ក្តី ករម្ភ:ក្តី អរុណ:ក្តី ក៏បានមកជាមួយនឹងវេយនទេវតា ។ ពួកទេវតាឈ្មោះឱទាតគយ្ហ:ជាប្រធានក្តី ឈ្មោះវិចក្ខណ:ក្តី ក៏បានមក ពួកទេវតាឈ្មោះសទាមត្ត:ក្តី ឈ្មោះហារគជ:ក្តី ឈ្មោះមិស្សក:ក្តី សុទ្ធតែជា

អ្នកមានយស (ក៏បានមក) បជុន្នទេវរាជដែលញុំាងមេឃឱ្យគ្រហឹមកម្ហរ ហើយបង្អុរភ្លៀងឱ្យធ្លាក់ចុះគ្រប់ទិសក៏បានមក។

ឯសេតេ ឯសធា កាយា សព្វេ ឆានវុតវណ្ណិនោ
ឥទ្ធិមន្តោ ជុតិមន្តោ វណ្ណវន្តោ យសស្សិនោ
មោទមានា អតិក្កាមុំ ភិក្ខូនំ សមិតឹ ឋនំ ។

ទេវតាទាំង ១០ ពួកនេះបិតនៅដោយចំណែក ១០ សុទ្ធតែមានសម្បុរផ្សេងៗគ្នាទាំងអស់ មានឫទ្ធិ មានអានុភាព មានរស្មី មានយស មានចិត្តរីករាយ ក៏បាននាំគ្នាមកកាន់មហាវ័នជាទីប្រជុំនៃភិក្ខុទាំងឡាយ។

ខេមិយា តុសិតា យាមា កដ្ឋកា ច យសស្សិនោ
លម្ពីតកា លាមសេដ្ឋា ជោតិនាមា ច អាសវា
និម្មានរតិនោ អាគុំ អថាគុំ បរនិម្មិតា ។

ពួកខេមិយទេវតាដែលបិតនៅក្នុងតុសិតបុរីក្តី បិតនៅក្នុងយាមទេវលោកក្តី ពួកកដ្ឋកទេវតាដែលមានយសក្តី ពួកលម្ពិតកទេវតាក្តី ពួកលាមសេដ្ឋទេវតាក្តី ពួកទេវតាឈ្មោះជោតិក្តី ឈ្មោះអាសវៈក្តី ពួកនិម្មានរតីទេវតាក្តី ក៏បានមក ទាំងពួកបរនិម្មិតទេវតាក៏បានមក។

ឯសេតេ ឯសធា កាយា សព្វេ ឆានវុតវណ្ណិនោ
ឥទ្ធិមន្តោ ជុតិមន្តោ វណ្ណវន្តោ យសស្សិនោ
មោទមានា អតិក្កាមុំ ភិក្ខូនំ សមិតឹ ឋនំ ។

ទេវតាទាំង ១០ ពួកនេះបិតនៅដោយចំណែក ១០ សុទ្ធតែមានសម្បុរផ្សេងៗគ្នាទាំងអស់ មានឫទ្ធិ មានអានុភាព មានរស្មី មានយស មានចិត្តរីករាយ

ក៏បាននាំគ្នាមកកាន់មហាវ័នជាទីប្រជុំនៃភិក្ខុទាំងឡាយ ។

សជ្ជេតេ ទេវនិកាយា សព្ពេ នានត្តវណ្ណិនោ
នាមន្វយេន អាគច្ឆុំ យេ ចញ្ញេ សទិសា សហ ៗ
បវុដ្ឋជាតិមខិលំ ទ្វិយតិណ្ណមនាសវំ
ទក្ខេមោយតរំ នាគំ ចន្ទំវ អសិតាតិគំ ៗ

ពួកទេវតាទាំង ៦០ មានអាបោទេវតាជាដើមនេះ សុទ្ធតែមានសម្បុរផ្សេង ៗ គ្នាទាំងអស់ មកហើយដោយចំណែកនាម សូម្បីពួកទេវតាណាក្រៅពីនោះ ដែលមានរស្មីប្រហែលគ្នាក៏មកព្រមគ្នាដោយគិតថា យើងទាំងឡាយនឹងទៅមើលព្រះអរិយសង្ឃដែលជ្រាសចាកជាតិ ឥតមានកិលេសដូចជាដែកគោល លោកឆ្លងចាកអន្ទង់ទាំង ៤ ហើយ មិនមានកិលេសជាគ្រឿងត្រាំ រួចស្រឡះចាកឱឃៈទាំង ៤ ហើយ លោកមិនបានធ្វើនូវបាប មួយទៀត យើងនឹងបានឃើញនូវព្រះទសពលដែលរុងរឿងដោយសិរី ដូចព្រះចន្ទឆ្លងផុតអំពីពពក ។

សុព្រហ្មោ បរមត្តោ ច បុត្តា តស្ស មហេសិនោ
សនង្កុមារោ តិស្សោ ច សោឃាគ សមិតឹ ឥធំ ៗ

អរិយព្រហ្មទាំងឡាយគឺ សុព្រហ្ម និងបរមត្តព្រហ្ម ជាបុត្តរបស់ព្រះសម្មាសម្ពុទ្ធទ្រង់មានឫទ្ធិ ក៏មកជាមួយគ្នាសនង្កុមារមហាព្រហ្មក្តីតិស្សមហាព្រហ្មក្តី ក៏នាំគ្នាមកកាន់មហាវ័នជាទីប្រជុំនៃភិក្ខុទាំងឡាយ ។

សហស្សិ ព្រហ្មលោកានំ មហាព្រហ្មាតិជុតិ
ទ្វាទសយោ ជុតិមន្តោ តិស្សាភាយោ យសស្សិនោ ៗ

មហាព្រហ្មទាំង ១ ពាន់ក៏មកហើយ មហាព្រហ្ម ១ អង្គគ្របសង្កត់នូវព្រហ្ម

ឯទៀតបាន មហាព្រហ្មនោះកើតក្នុងព្រហ្មលោក មានអានុភាព មានកាយសម្បើម មានយសក៏មកដែរ ។

ឯសេត្ត ឥស្សរ អាគុំ បច្ចេកឥសវត្តិនោ
តេសញ្ច មជ្ឈតោ អាគ ហារិតោ បរិវារិតោ ៤

មហាព្រហ្មទាំង ១០ ជាឥស្សរៈលើព្រហ្មទាំង ១ ពាន់នេះ តែងផ្សាយអំណាចផ្សេងៗ ក៏បានមកហារិតមហាព្រហ្ម (ដែលមានព្រហ្មទាំង ១ សែន) ហៃហមក្នុងកណ្តាលនៃពួកព្រហ្មទាំងនោះក៏បានមក ។

តេ ច សព្ពេ អតិក្កន្តេ សតិន្ទេ ទេវេ សព្រហ្មកេ
មារសេនា អតិក្កាមិ បស្ស កណ្ហស្ស មទ្ទិយំ ៥

សេនារបស់មារបានឃើញនូវពួកទេវតាព្រមទាំងព្រះឥន្ទព្រមទាំងព្រះព្រហ្មទាំងអស់នោះមកដូច្នោះហើយក៏បានមក ហើយពោលថា អ្នកទាំងឡាយចូរមើលនូវសេចក្តីលួងលំនៃមារ ។

ឯថ គណ្ហថ ពន្ធថ រាគេន ពន្ធមត្តុ នោ
សមន្តា បរិវារេថ មា នោ មុញ្ចិត្ថ កោចិ នំ ៥

(ឯសេនារបស់មារក៏ពោលថា) អ្នកទាំងឡាយចូរមក ចូរចាប់ចងពួកទេវតាទាំងនេះទុក ការចងដោយរាគៈចូរមានដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរព័ទ្ធឱ្យជុំវិញ បណ្តាអ្នកទាំងអស់គ្នា អ្នកណាមួយក៏កុំបណ្តោយឱ្យទេវតា ១ អង្គរួចទៅបានឡើយ ។

ឥតិ តត្ត មហាសេនោ កណ្ហោ សេនំ អបេសយិ
ចាណិនា តលមាហច្ច សរំ កត្វាន តេរវំ ៥

យថា ចាតុស្សរកោ មេឃោ ថនយន្តោ សវិជ្ជុកោ
តថា សោ បច្ចុទាវត្តិ សទ្ទេន អសយំវសេ ៥

មារជាសេនាធំក្នុងទីប្រជុំធំនោះក៏ទះនូវផ្ទៃនៃផែនដីដោយបាតដៃ ធ្វើនូវសំឡេងគំរាមមុខគួរខ្លាច ដូចជាមហាមេឃគ្រហឹមបង្អុរភ្លៀង មានទាំងផ្លេកបន្ទោរក្នុងកាលនោះ មារនោះមិនអាចនឹងធ្វើ (ទេវតាណាមួយ) ឱ្យប្រព្រឹត្តទៅក្នុងអំណាចខ្លួនបានក៏ក្រេវក្រោធថយចេញបាត់ទៅ។

តញ្ច សព្វំ អភិញ្ញាយ ភវត្តិគ្គាន ចក្ខុមា
តតោ អាមន្តយី សត្ថា សាវកេ សាសនេ រតេ ៥

លំដាប់នោះ ព្រះសាស្តាទ្រង់មានចក្ខុពិចារណាហើយជ្រាបហេតុនោះទាំងអស់ ទើបទ្រង់ត្រាស់នឹងភិក្ខុជាសាវ័កទាំងឡាយដែលត្រេកអរក្នុងសាសនាថា។

មារសេនា អភិក្កន្តា តេ ទិជានាថ ភិក្ខវោ
តេ ច អាគច្ឆមករុំ សុត្វា ពុទ្ធស្ស សាសនំ
ខីតរាគេហិ បក្កាមុំ ឆេសំ លោមាបិ ឥញ្ជយុំ ៥

ម្នាលភិក្ខុទាំងឡាយ មារសេនាមកដល់ហើយ អ្នកទាំងឡាយចូរស្គាល់នូវមារសេនាទាំងនោះចុះ ឯពួកភិក្ខុទាំងនោះ លុះបានស្តាប់ពាក្យប្រដៅព្រះពុទ្ធជាម្ចាស់ហើយ ក៏ធ្វើព្យាយាម(ដើម្បីចូលកាន់ផលសមាបត្តិ)។ មារព្រមទាំងពួកសេនារបស់មារក៏ចៀសចេញឆ្ងាយទៅអំពីពួកអរិយសាវ័កដែលជ្រាសចាករាគៈ សូម្បីតែរោមរបស់ព្រះអរិយៈទាំងនោះក៏មិនបានព្រឺព្រួចឡើយ។

សព្វេ ខិជិតសង្កាមា តយាតីតា យសស្សិនោ
មោទន្តិ សហ ភូតេហិ សាវកា តេ ជនេសុតាតិ ៥

(ទើបមារពោលសរសើរភិក្ខុសង្ឃថា) ពួកសាវ័កទាំងនោះ លោកឈ្នះសឹក-សង្គ្រាមហើយ កន្ទងបង់នូវសេចក្តីភ័យខ្លាចបានហើយ មានយសល្បីទូរទៅក្នុងប្រជុំជន តែងរីករាយជាមួយនឹងព្រះអរិយៈដែលកើតហើយ (ក្នុងសាសនាព្រះទសពល)។

មហាសមយសុត្តំ និដ្ឋិតំ

មហាសមយសូត្រ ចប់

(ក្នុងសូត្រនេះមាន ៧៧ គាថាកន្លះ)

ធម្មចក្កប្បវត្តនសុត្តារម្ភោ

អនុត្តរំ អភិសម្ពោធឹ សម្ភុជ្ជិត្វា តថាគតោ
បឋមំ យំ អទេសេសិ ធម្មចក្កំ អនុត្តរំ
សម្មទេវ បវត្តេន្តោ លោកេ អប្បដិវត្តិយំ

ព្រះតថាគតជាម្ចាស់ ទ្រង់បានត្រាស់ដឹងនូវអនុត្តរាភិសម្ពោធិញ្ញាណហើយ កាលព្រះអង្គនឹងញុំាងធម៌ ដែលឥតមានអ្នកណានឹងឱ្យប្រព្រឹត្តទៅបានក្នុងលោក ព្រះអង្គអាចឱ្យប្រព្រឹត្តទៅបានដោយប្រពៃពិត ទ្រង់បានសម្តែងហើយនូវធម៌ណាដែលហៅថាធម្មចក្កដ៏ប្រសើរ ជាមុនដំបូងបំផុត

យត្តាក្ខាតា ទ្វយេ អន្តា បដិបត្តិ ច មជ្ឈិមា
ចតុស្សារិយសច្ចេសុ ទិសុទ្ធំ ញាណទស្សនំ

អន្តធម៌ គឺធម៌ជាផ្លូវប្រតិបត្តិអមខាងដ៏លាមកអាក្រក់ ២ ប្រការ និងផ្លូវប្រតិ-

បត្តិជាកណ្តាល និងប្រាជ្ញាដែលដឹងច្បាស់ ឃើញច្បាស់ ក្នុងអរិយសច្ចទាំងឡាយ ៤ ជាប្រាជ្ញាដ៏បរិសុទ្ធដែលព្រះសម្ពុទ្ធទ្រង់ត្រាស់សម្តែងហើយ ក្នុងព្រះធម៌ដែលហៅថា ធម្មចក្កឯណា

ទេសិតំ ធម្មរាជេន សម្មាសម្ពោធិកិត្តនំ
ឆាមេនវស្សុតំ សុត្តំ ធម្មចក្កប្បវត្តនំ
វេយ្យាករណចាបេន សង្គីតន្តម្ពណាម សេ ៗ

យើងទាំងឡាយ សូធ្យតឡូវនេះ នូវធម្មចក្កនោះ ដែលព្រះសម្មាសម្ពុទ្ធជាធម្មរាជទ្រង់សម្តែងហើយ ប្រាកដដោយឈ្មោះថាធម្មចក្កប្បវត្តនសូត្រ ជាព្រះសូត្រប្រកាសនូវសម្មាសម្ពោធិញ្ញាណដែលព្រះសង្គីតិកាចារ្យ បានប្រជុំគ្នាសង្គាយនារៀបរៀងដោយរបៀបជាវេយ្យាករណចាប គឺជាចាលីបទភាយ តតមានគាថាលាយផងឡើយ ។

ធម្មចក្កប្បវត្តនសូត្រ

(បិដកលេខ ៦ ទំព័រ ៣៩ និងលេខ ២៩ ទំព័រ ២១៩)

ឯវម្មេ សុតំ *សូត្រនេះ (ឈ្មោះធម្មចក្កប្បវត្តនសូត្រ) គឺខ្ញុំ (ឈ្មោះអានន្ទ) បានស្តាប់មកហើយ យ៉ាងនេះថា*

ឯកំ សមយំ ភគវា ពារាណសិយំ វិហរតិ ឥសិបតនេ មិគទាយេ *សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងព្រៃឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ។*

តត្រ ខោ ភគវា បញ្ចវគ្គិយេ ភិក្ខូ អាមន្តេសិ *ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅនូវបញ្ចវគ្គី[1] ភិក្ខុទាំងឡាយក្នុងទីនោះឯង (ឱ្យនាំគ្នាតាំងចិត្តស្តាប់) នូវភាសិតនេះថា*

ទ្វេមេ ភិក្ខវេ អន្តា បព្វជិតេន ន សេវិតព្វា *ម្នាលភិក្ខុទាំងឡាយ អន្តធម៌ គឺធម៌ជាផ្លូវប្រតិបត្តិអមខាងដ៏លាមកអាក្រក់ទាំងឡាយពីរប្រការនេះ បព្វជិតមិនគួរសេពគប់ គឺថាមិនគួរប្រព្រឹត្តឡើយ។*

កតមេ ទ្វេ[2] *អន្តធម៌ទាំងឡាយពីរយ៉ាងនោះដូចម្តេច?*

យោ ចាយំ កាមេសុ កាមសុខល្លិកានុយោគោ *ធម៌ណាដែលប្រកបខ្លួនឱ្យជាប់ជំពាក់ដោយកាមក្នុងកាមទាំងឡាយ*

ហីនោ *ជាធម៌ថោកទាប*

គម្មោ *ជាធម៌របស់អ្នកស្រុក*

បោថុជ្ជនិកោ *ជាធម៌របស់បុថុជ្ជន,*

អនរិយោ *មិនមែនជារបស់អរិយបុគ្គលទេ*

អនត្ថសញ្ហិតោ *មិនប្រកបដោយប្រយោជន៍ឡើយ។*

យោ ចាយំ អត្តកិលមថានុយោគោ *ធម៌ណាដែលប្រកបសេចក្តីលំបាកដល់ខ្លួន*

ទុក្ខោ *ជាហេតុនាំឱ្យលំបាកកាយទេ។*

๑- ភិក្ខុមានគ្នាចំនួន ៥ រូប គឺភិក្ខុឈ្មោះ កោណ្ឌញ្ញៈ ๑ វប្បៈ ๑ មហានាម ๑ អស្សជិ ๑។ ๒- ក្នុងបិដកច្បាប់សីឡ មិនមានបាលីថា **កតមេ ទ្វេ** នេះទេ។

អនរិយោ *មិនមែនជារបស់អរិយបុគ្គលទេ*

អនត្ថសញ្ហិតោ *មិនប្រកបដោយប្រយោជន៍ឡើយ។*

ឯតេតេ ខោ[1] **ភិក្ខវេ ទ្វេអោ អន្តេ អនុបគម្ម មជ្ឈិមា បដិបទា, តថាគតេន អភិសម្ពុទ្ធា ចក្ខុករណី ញាណករណី, ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ** *ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រតិបត្តិជាកណ្តាល មិនលាយច្រឡំដោយអន្តធម៌ទាំងឡាយពីរយ៉ាងនោះឯង ដែលតថាគតបានត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិធ្វើឱ្យកើតបញ្ញាចក្ខុ (ភ្នែកគឺប្រាជ្ញា) ធ្វើឱ្យកើតសេចក្តីដឹងច្បាស់ប្រាកដ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រំងាប់ ដើម្បីសេចក្តីដឹងចំពោះ ដើម្បីសេចក្តីដឹងដោយប្រពៃ ដើម្បីសេចក្តីរំលត់ទុក្ខ។*

កតមា ច សា ភិក្ខវេ មជ្ឈិមា បដិបទា, តថាគតេន អភិសម្ពុទ្ធា ចក្ខុករណី ញាណករណី, ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ *ម្នាលភិក្ខុទាំងឡាយ ក៏សេចក្តីប្រតិបត្តិជាកណ្តាល ដែលតថាគតបានត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិធ្វើឱ្យកើតបញ្ញាចក្ខុ ធ្វើឱ្យកើតសេចក្តីដឹងច្បាស់ប្រាកដ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រំងាប់ ដើម្បីសេចក្តីដឹងចំពោះ ដើម្បីសេចក្តីដឹងដោយប្រពៃ ដើម្បីសេចក្តីរំលត់ទុក្ខនោះ តើដូចម្តេច?*

អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ *អដ្ឋង្គិកមគ្គ គឺធម៌ដូចជាផ្លូវមានអង្គ ៨ ដ៏ប្រសើរនេះឯង (ហៅថាសេចក្តីប្រតិបត្តិជាកណ្តាល)*

១-ក្នុងបិដកច្បាប់សីហឡមិនមានសព្ទថា **ខោ** នេះទេ។

សេយ្យថីទំ *អដ្ឋង្គិកមគ្គនោះ ដូចម្តេចខ្លះ?*

សម្មាទិដ្ឋិ *ប្រាជ្ញាយល់ឃើញត្រូវ*

សម្មាសង្កប្បោ *សេចក្តីត្រិះរិះត្រូវ,*

សម្មាវាចា *សម្តីត្រូវ*

សម្មាកម្មន្តោ *ការងារត្រូវ*

សម្មាអាជីវោ *កិរិយាចិញ្ចឹមជីវិតត្រូវ,*

សម្មាវាយាមោ *ព្យាយាមត្រូវ*

សម្មាសតិ *សេចក្តីរឭកត្រូវ*

សម្មាសមាធិ *កិរិយាតម្កល់ចិត្តឱ្យនឹងត្រូវ,*

អយំ ខោ សា ភិក្ខវេ មជ្ឈិមា បដិបទា, តថាគតេន អភិសម្ពុទ្ធា ចក្ខុ-ករណី ញាណករណី, ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ *ម្នាលភិក្ខុទាំងឡាយ អដ្ឋង្គិកមគ្គនេះឯង ដែលហៅថាសេចក្តីប្រតិបត្តិជាកណ្តាល ដែលតថាគតបានត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិធ្វើឱ្យកើតបញ្ញាចក្ខុ ធ្វើឱ្យកើតសេចក្តីដឹងច្បាស់ច្រាកដ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រំងាប់ ដើម្បីសេចក្តីដឹងចំពោះ ដើម្បីសេចក្តីដឹងដោយប្រពៃ ដើម្បីសេចក្តីរំលត់ទុក្ខ។*

ឥទំ ខោ បន ភិក្ខវេ ទុក្ខំ អរិយសច្ចំ, ជាតិបិ ទុក្ខា ជរាបិ ទុក្ខា (ព្យាធិបិ[1] ទុក្ខោ) មរណម្បិ ទុក្ខំ, សោកបរិទេវទុក្ខទោមនស្សុបាយាសាបិ ទុក្ខា អប្បិយេហិ សម្បយោគោ ទុក្ខោ, បិយេហិ វិប្បយោគោ ទុក្ខោ, យម្បិច្ឆំ ន

๑- **ព្យាធិបិ ទុក្ខោ** ក្នុងភាណវារបាលីឮ្ចានទេ។

ឯតតិ តម្បិ ទុក្ខំ, សង្ខិត្តេន បញ្ចុបាទានក្ខន្ធា ទុក្ខា *ម្នាលភិក្ខុទាំងឡាយ ជាតិ គឺកិរិយាកកើតនៃខន្ធ ជាហេតុនាំមកនូវទុក្ខ ជរាគឺកិរិយាចាស់គ្រាំគ្រានៃខន្ធ ក៏ជាហេតុនាំមកនូវទុក្ខ (ព្យាធិ គឺជំងឺតម្កាត់ទាំងឡាយ ក៏ជាហេតុនាំមកនូវទុក្ខ) មរណៈ គឺកិរិយាបែកធ្លាយនៃខន្ធ ក៏ជាហេតុនាំមកនូវទុក្ខ សេចក្តីសោកខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតអង្អល់ចិត្តទាំងឡាយ ក៏ជាហេតុនាំមកនូវទុក្ខ កិរិយាប្រកបដោយសត្វនិងសង្ខារទាំងឡាយដែលមិនជាទីស្រឡាញ់ពេញចិត្ត ក៏ជាហេតុនាំមកនូវទុក្ខ កិរិយាព្រាត់ប្រាសចាកសត្វ និងសង្ខារទាំងឡាយដែលជាទីស្រឡាញ់ពេញចិត្ត ក៏ជាហេតុនាំមកនូវទុក្ខកាល បើចង់បាននូវវត្ថុណាមួយហើយ មិនបាននូវវត្ថុនោះ កិរិយាមិនបាននោះ ក៏ជាហេតុនាំមកនូវទុក្ខ ឧបាទានក្ខន្ធទាំងឡាយ ៥ ដែលតថាគតសម្តែងហើយដោយបំព្រួញ ក៏ជាហេតុនាំមកនូវទុក្ខ កងទុក្ខមានជាតិជាដើមនេះ ឈ្មោះថា ទុក្ខអរិយសច្ច។*

ឥទំ ខោ បន ភិក្ខវេ ទុក្ខសមុទយោ អរិយសច្ចំ, យាយំ តណ្ហា បោនោព្ភវិកា នន្ទិរាគសហគតា តត្រតត្រាភិនន្ទិនី, សេយ្យថីទំ, កាមតណ្ហា ភវតណ្ហា វិភវតណ្ហា *ម្នាលភិក្ខុទាំងឡាយ តណ្ហាឯណា ដែលរមែងតាក់តែងនូវកំពើតថ្មី ប្រកបដោយតម្រេក ដោយអំណាចនៃសេចក្តីត្រេកត្រអាល មានកិរិយារីករាយក្នុងអារម្មណ៍នោះៗជាប្រក្រតី តណ្ហានោះ ដូចម្តេចខ្លះ ? (តណ្ហានោះ) គឺកាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ តណ្ហាទាំង ៣ នេះ ឈ្មោះថា ទុក្ខសមុទយអរិយសច្ច។*

ឥទំ ខោ បន ភិក្ខវេ ទុក្ខនិរោធោ អរិយសច្ចំ, យោ តស្សា យេវ តណ្ហាយ អសេសវិរាគនិរោធោ ចាគោ បដិនិស្សគ្គោ មុត្តិអនាលយោ *ម្នាលភិក្ខុទាំងឡាយ កិរិយារំលត់បង់នូវតណ្ហានោះ ដោយអរិយមគ្គមិនឱ្យមានសេសសល់ កិរិយាលះបង់នូវតណ្ហានោះ កិរិយារលាស់ចោលនូវតណ្ហានោះ កិរិយារួចផុតចាកតណ្ហានោះ កិរិយាមិនមានអាល័យក្នុងតណ្ហានោះឯណា កិរិយារំលត់បង់នូវតណ្ហាដោយអរិយមគ្គមិនឱ្យមានសេសសល់ជាដើមនេះឯង ឈ្មោះថា ទុក្ខនិរោធអរិយសច្ច។*

ឥទំ ខោ បន ភិក្ខវេ ទុក្ខនិរោធគាមិនីបដិបទា អរិយសច្ចំ, អយមេវ អរិយោ អដ្ឋង្គិកោមគ្គោ, សេយ្យថីទំ, សម្មាទិដ្ឋិ សម្មាសង្កប្បោ, សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ, សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ *ម្នាលភិក្ខុទាំងឡាយ អដ្ឋង្គិកមគ្គដ៏ប្រសើរនេះឯង ដូចម្តេចខ្លះ? គឺប្រាជ្ញាយល់ឃើញត្រូវ សេចក្តីត្រិះរិះត្រូវ សម្តីត្រូវ ការងារត្រូវ កិរិយាចិញ្ចឹមជីវិតត្រូវ ព្យាយាមត្រូវ សេចក្តីរឭកត្រូវ កិរិយាតម្កល់ចិត្តឱ្យនឹងត្រូវ អដ្ឋង្គិកមគ្គដ៏ប្រសើរនេះឯង ឈ្មោះថា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច។*

(កាលត្រាស់ទេសនានូវលក្ខណៈនៃអរិយសច្ច ៤ ប្រការដូច្នេះហើយ ទើបត្រាស់ទេសនានូវលក្ខណ ៣ ប្រការ គឺសច្ចញ្ញាណ កិច្চញ្ញាណ កតញ្ញាណ ឱ្យទូទៅក្នុងអរិយសច្ច ៤ តទៅទៀត)

ឥទំ ទុក្ខំ អរិយសច្চន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ, চក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ,

ម្នាលភិក្ខុទាំងឡាយ ចក្ខុ[១]កើតឡើងហើយ ញាណ[២]កើតឡើងហើយ បញ្ញា[៣]កើតឡើងហើយ វិជ្ជា[៤]កើតឡើងហើយ ពន្លឺភ្លឺស្វាង[៥]កើតឡើងហើយដល់តថាគតក្នុងធម៌ទាំងឡាយ ដែលពីដើម[៦]តថាគតមិនធ្លាប់បានឮ បានស្តាប់ថា នេះជាទុក្ខអរិយសច្ចដូច្នេះឡើយ។

**តំ ខោ បនិទំ ទុក្ខំ អរិយសច្ចំ បរិញ្ញេយ្យន្តិ មេ ភិក្ខវេបុព្វេ អននុ-
ស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ
អាលោកោ ឧទបាទិ** *ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយដល់តថាគតក្នុងធម៌ទាំងឡាយ ដែលពីដើមតថាគតមិនធ្លាប់បានឮ បានស្តាប់ថា ទុក្ខអរិយសច្ចនេះឯង គួរតែកំណត់ដឹងដោយបញ្ញាដូច្នេះឡើយ។*

**តំ ខោ បនិទំ ទុក្ខំ អរិយសច្ចំ បរិញ្ញាតន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ
ធម្មេសុ,ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោ-
កោ ឧទបាទិ** *ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគតក្នុងធម៌ទាំងឡាយ ដែលពីដើមតថាគតមិនធ្លាប់បានឮ បានស្តាប់ថា ទុក្ខអរិយសច្ចនេះឯង តថាគតកំណត់ដឹងបានហើយដូច្នេះឡើយ។*

ឥទំ ទុក្ខសមុទយោ អរិយសច្ចន្តិមេ ភិក្ខវេ បុព្វេ អនុស្សុតេសុ ធម្មេ-

---

១-បញ្ញាដែលឃើញច្បាស់ ។ ២-បញ្ញាដែលដឹងច្បាស់ ។ ៣-បញ្ញាដែលដឹងមិនខុស មិនភ្លាត់ ។ ៤-បញ្ញាដែលកាត់បង់នូវសេចក្តីសង្ស័យ ។ ៥-បញ្ញាដែលកម្ចាត់សេចក្តីងងឹត គឺសេចក្តីល្ងង់។ ៦-ពាក្យថា “ពីដើម” នេះ ចំពោះយកកាលក្នុងបច្ឆិមភពនេះឯង ចាប់ដើមតាំងអំពីប្រសូត្រមក ។

សុ, ចក្ខុំ ខ្ទបាទិ ញ្ញាណំ ខ្ទបាទិ បញ្ញា ខ្ទបាទិ វិជ្ជា ខ្ទបាទិ អាលោកោ ខ្ទបាទិ *ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគតក្នុងធម៌ទាំងឡាយ ដែលពីដើមតថាគតមិនធ្លាប់បានឮ បានស្តាប់ថា នេះជាទុក្ខសមុទយអរិយសច្ច ដូច្នេះឡើយ។*

តំ ខោ បនិទំ ទុក្ខសមុទយោ អរិយសច្ចំ បហាតព្ពន្តិ មេ ភិក្ខវេ បុព្ពេ អនន្តុស្សុតេសុ ធម្មេសុ, ចក្ខុំ ខ្ទបាទិ ញ្ញាណំ ខ្ទបាទិ បញ្ញា ខ្ទបាទិវិជ្ជា ខ្ទបាទិ អាលោកោ ខ្ទបាទិ *ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគតក្នុងធម៌ទាំងឡាយ ដែលពីដើមតថាគតមិនធ្លាប់បានឮ បានស្តាប់ថា ទុក្ខសមុទយអរិយសច្ចនេះឯង គួរតែលះបង់ ដូច្នេះឡើយ។*

តំ ខោ បនិទំ ទុក្ខសមុទយោ អរិយសច្ចំ បហីនន្តិ មេ ភិក្ខវេ បុព្ពេ អនន្តុស្សុតេសុ ធម្មេសុ, ចក្ខុំ ខ្ទបាទិ ញ្ញាណំ ខ្ទបាទិ បញ្ញា ខ្ទបាទិ វិជ្ជា ខ្ទបាទិ អាលោកោ ខ្ទបាទិ *ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគតក្នុងធម៌ទាំងឡាយ ដែលពីដើមតថាគតមិនធ្លាប់បានឮ បានស្តាប់ថា ទុក្ខសមុទយអរិយសច្ចនេះឯង តថាគតលះបង់បានហើយដូច្នេះឡើយ។*

ឥទំ ទុក្ខនិរោធោ អរិយសច្ចន្តិ មេ ភិក្ខវេ បុព្ពេ អនន្តុស្សុតេសុ ធម្មេសុ ចក្ខុំ ខ្ទបាទិ ញ្ញាណំ ខ្ទបាទិ បញ្ញា ខ្ទបាទិ វិជ្ជា ខ្ទបាទិ អាលោកោ ខ្ទបាទិ

ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺក្លឹស្វាងកើតឡើងហើយ ដល់តថាគតក្នុងធម៌ទាំងឡាយ ដែលពីដើមតថាគត មិនធ្លាប់បានឮ បានស្តាប់ថា នេះជាទុក្ខនិរោធអរិយសច្ច ដូច្នេះឡើយ។

តំ ខោ បនិទំ ទុក្ខនិរោធោ អរិយសច្ចំ សច្ឆិកាតព្ពន្តិ មេ ភិក្ខវេ បុព្ពេ អនន្តុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ *ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺក្លឹស្វាងកើតឡើងហើយ ដល់តថាគតក្នុងធម៌ទាំងឡាយ ដែលពីដើមតថាគតមិនធ្លាប់បានឮ បានស្តាប់ថា ទុក្ខនិរោធអរិយសច្ចនេះឯង គួរតែធ្វើឱ្យជាក់ច្បាស់ ដូច្នេះឡើយ។*

តំ ខោ បនិទំ ទុក្ខនិរោធោ អរិយសច្ចំ សច្ឆិកតន្តិ មេ ភិក្ខវេ បុព្ពេ អនន្តុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ *ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺក្លឹស្វាងកើតឡើងហើយ ដល់តថាគតក្នុងធម៌ទាំងឡាយ ដែលពីដើមតថាគតមិនធ្លាប់បានឮ បានស្តាប់ថា ទុក្ខនិរោធអរិយសច្ចនេះឯង តថាគតធ្វើឱ្យជាក់ច្បាស់បានហើយ ដូច្នេះឡើយ។*

ឥទំ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចន្តិ មេ ភិក្ខវេ បុព្ពេ អនន្តុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ

អាលោកោ ឧទបាទិ *ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើយហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគតក្នុងធម៌ទាំងឡាយ ដែលពីដើមតថាគតមិនធ្លាប់បានឮ បានស្តាប់ថា នេះជាទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ដូច្នេះឡើយ។*

តំ ខោ បនិទំ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ ភាវេតព្ពន្តិ មេ ភិក្ខវេ បុព្ពេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ *ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគតក្នុងធម៌ទាំងឡាយ ដែលពីដើមតថាគតមិនធ្លាប់បានឮ បានស្តាប់ថា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចនេះឯង គួរតែចម្រើនឱ្យកើតឡើង ដូច្នេះឡើយ។*

តំ ខោ បនិទំ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ ភាវិតន្តិ មេ ភិក្ខវេ បុព្ពេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ *ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺភ្លឺស្វាងកើតឡើងហើយ ដល់តថាគតក្នុងធម៌ទាំងឡាយ ដែលពីដើមតថាគតមិនធ្លាប់បានឮ បានស្តាប់ថា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចនេះឯង តថាគតចម្រើនឱ្យកើតបានហើយ ដូច្នេះឡើយ។*

យាវកីវញ្ច មេ ភិក្ខវេ ឥមេសុ ចតូសុ អរិយសច្ចេសុ, ឯវន្តបរិវដ្ដំ

ទ្វាទសាការំ យថាភូតំ ញាណទស្សនំ ទសុទ្ធិសុទ្ធំ អហោសិ *ម្នាលភិក្ខុទាំងឡាយ ប្រាជ្ញាដែលដឹងច្បាស់ ឃើញច្បាស់តាមពិត មានបរិវដ្ដ:(១)៣ មានអាការៈ(២)១២ យ៉ាងនេះ (ប្រព្រឹត្តទៅ) ក្នុងអរិសច្ចទាំងឡាយ ៤ នេះ នៅមិនទាន់បរិសុទ្ធល្អ មានដល់តថាគត អស់កាលត្រឹមណា ។*

នេវ តាវាហំ ភិក្ខវេ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អនុត្តរំ សម្មាសម្ពោធិំ អភិសម្ពុទ្ធោ បច្ចញ្ញាសឹ *ម្នាលភិក្ខុទាំងឡាយ តថាគតក៏មិនទាន់ប្ដេជ្ញាខ្លួន ថាជាអ្នកត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ ឥតមានសេចក្ដីដឹងឯទៀតក្រៃលែងជាងក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស អស់កាលត្រឹមណោះនៅឡើយទេ ។*

យតោ ច ខោ មេ ភិក្ខវេ ឥមេសុ ចតូសុ អរិយសច្ចេសុ ឯវន្តិបរិវដ្ដំ ទ្វាទសាការំ យថាភូតំ ញាណទស្សនំ សុទ្ធិសុទ្ធំ អហោសិ *ម្នាលភិក្ខុទាំងឡាយ ក៏បញ្ញាដែលដឹងច្បាស់ ឃើញច្បាស់តាមពិត មានបរិវដ្ដ: ៣ មានអាការៈ១២យ៉ាងនេះ (ប្រព្រឹត្តទៅ) ក្នុងអរិយសច្ចទាំងឡាយ ៤ នេះ បរិសុទ្ធល្អ មានដល់តថាគតក្នុងកាលឯណា ។*

១-បរិវដ្ដៈ ៣ គឺសច្ចញ្ញាណ ១ កិច្ចញ្ញាណ ១ កតញ្ញាណ ១ ។ ២-បរិវដ្ដ ៣ នោះឯង វិលទៅដូចជាចក្រក្នុងសច្ចៈទាំង ៤ គឺក្នុងទុក្ខសច្ច ៣ ទុក្ខសមុទយសច្ច ៣ ទុក្ខនិរោធសច្ច ៣ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ៣ ផ្សំគ្នាជា ១២ ហៅថា អាការៈ ១២ ។

អថាហំ ភិក្ខវេ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណ-ព្រាហ្មណិយា បជាយ សទេវមនុស្សាយ អនុត្តរំ សម្មាសម្ពោធិំ អភិសម្ពុទ្ធោ បច្ចញ្ញាសឹ *ម្នាលភិក្ខុទាំងឡាយ តថាគតប្តេជ្ញាខ្លួនថាជាអ្នកត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ ឥតមានសេចក្តីដឹងឯទៀតក្រៃលែងជាង ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ព្រមទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសក្នុងកាលណោះឯង។*

ញាណញ្ច បន មេ ទស្សនំ ឧទបាទិ អកុប្បា មេ វិមុត្តិ អយមន្តិមា ជាតិ នត្ថិទានិ បុនព្ភវោតិ *ក៏បញ្ញាដែលដឹងច្បាស់ ឃើញច្បាស់ កើតឡើងហើយដល់តថាគតដូច្នេះថា សេចក្តីរួចផុតវិសេសរបស់តថាគត មិនប្រែត្រឡប់កម្រើកទៀតឡើយ ជាតិនេះក៏ជាទីបំផុតត្រឹមនេះហើយ ឥឡូវនេះ ភពថ្មី គឺការត្រឡប់កើតទៀត ក៏មិនមានឡើយ។*

ឥទមវោច ភគវា *ព្រះដ៏មានព្រះភាគ បានត្រាស់ទេសនាព្រះធម្មចក្កប្បវត្តនសូត្រនេះ ចប់ហើយ)*

អត្តមនា បញ្ចវគ្គិយា ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ *បញ្ចវគ្គិយភិក្ខុទាំងឡាយ ក៏មានចិត្តត្រេកអរឥតឆ្អែតនឹងភាសិតរបស់ព្រះដ៏មានព្រះភាគ ដោយក្រៃពេក។*

ឥមស្មិញ្ច បន វេយ្យាករណស្មិំ ភញ្ញមានេ អាយស្មតោ កោណ្ឌញ្ញស្ស វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ *នាកាលវេយ្យាករណ៍ គឺព្រះសូត្រដែលឥតមានគាថានេះ ដែលព្រះដ៏មានព្រះភាគកំពុងត្រាស់ទេសនា ធម្មចក្ខុគឺសោតាបត្តិមគ្គ*

ដ៏ប្រាសចាកធូលី គឺរាគៈ ប្រាសចាកមន្ទិល គឺអកុសល កើតឡើងហើយ ដល់ព្រះកោណ្ឌញ្ញៈដ៏មានអាយុថា

យំ កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ *ធម្មជាតិណាមួយ មានកិរិយាកើតឡើងជាធម្មតា ធម្មជាតិនោះទាំងអស់មានកិរិយារលត់ទៅជាធម្មតា។*

បវត្តិតេ ច ភគវតា[1] ធម្មចក្កេ *ក៏នាកាលព្រះធម្មចក្កប្បវត្តនសូត្រ គឺព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទេសនាចប់ហើយ*

ភុម្មា ទេវា សទ្ទមនុស្សាវេសុំ ឯតម្ភគវតា ពារាណសិយំ ឥសិបតនេ មិគទាយេ អនុត្តរំ ធម្មចក្កំ បវត្តិតំ អប្បដិវត្តិយំ សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មិន្តិ *កុម្មទេវតាទាំងឡាយ ក៏ញុំាងសំឡេងឱ្យលាន់ឮឡើងដូច្នេះថា ចក្រ គឺធម៌នេះ ឥតមានចក្រឯណាមួយក្រៃលែងជាង គឺសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី អ្នកឯណានីមួយក្តីក្នុងលោក សម្តែងពុំបានឡើយ មានតែព្រះដ៏មានព្រះភាគព្រះអង្គត្រាស់សម្តែងហើយ ក្នុងឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី។*

ភុម្មានំ ទេវានំ សទ្ទំ សុត្វា ចាតុម្មហារាជិកា ទេវាសទ្ទមនុស្សាវេសុំ[2] *ទេវតាទាំងឡាយក្នុងជាន់ចាតុម្មហារាជ បានឮសំឡេងនៃកុម្មទេវតាទាំងឡាយហើយ ក៏ញុំាងសំឡេងឱ្យលាន់ឮឡើង (ដោយសេចក្តីសរសើរដូចគ្នា)។*

១- បាលីក្នុងច្បាប់ឆដ្ឋសង្គាយនាថា **បវត្តិតេ ច បន ភគវតា**។ ២- ចាប់ពីត្រង់នេះតទៅក្នុងច្បាប់ឆដ្ឋសង្គាយនាមានបាលីថា “**ឯតំ ភគវតា ពារាណសិយំ ឥសិបតនេ មិគទាយេ អនុត្តរំ ធម្មចក្កំ បវត្តិ តំ អប្បដិវត្តិយំ សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មិន្តិ**” សូម្បីក្នុងឋានទេវតាគ្រប់ជាន់ថ្នាក់ក៏មានបាលីទាំងនេះដូចគ្នាដែរ។

ចាតុម្មហារាជិកានំ ទេវានំ សទ្ទំ សុត្វា តាវតឹ្តសា ទេវាសទ្ទមនុស្សាវេសុំ *ទេវតាទាំងឡាយ ក្នុងជាន់តាវត្តិង្ស បានឮសំឡេងនៃទេវតាក្នុងជាន់ចាតុម្មហារាជ ហើយ ក៏ញុំាងសំឡេងឱ្យលាន់ឮឡើង (ដោយសេចក្តីសរសើរដូចគ្នា)។*

តាវតឹ្តសានំ ទេវានំ សទ្ទំ សុត្វា យាមា ទេវា សទ្ទមនុស្សាវេសុំ *ទេវតាទាំងឡាយ ក្នុងជាន់យាមា បានឮសំឡេងនៃទេវតាក្នុងជាន់តាវត្តិង្សហើយ ក៏ញុំាងសំឡេងឱ្យលាន់ឮឡើង (ដោយសេចក្តីសរសើរដូចគ្នា)។*

យាមានំ ទេវានំ សទ្ទំ សុត្វា តុសិតាទេវា សទ្ទមនុស្សាវេសុំ *ទេវតាទាំងឡាយ ក្នុងជាន់តុសិត បានឮសំឡេងនៃទេវតាក្នុងជាន់យាមាហើយ ក៏ញុំាងសំឡេងឱ្យលាន់ឮឡើង (ដោយសេចក្តីសរសើរដូចគ្នា)។*

តុសិតានំ ទេវានំ សទ្ទំសុត្វា និម្មានរតី ទេវា សទ្ទមនុស្សាវេសុំ *ទេវតាទាំងឡាយ ក្នុងជាន់និម្មានរតី បានឮសំឡេងនៃទេវតាក្នុងជាន់តុសិតហើយ ក៏ញុំាងសំឡេងឱ្យលាន់ឮឡើង (ដោយសេចក្តីសរសើរដូចគ្នា) ។*

និម្មានរតីនំ ទេវានំ សទ្ទំ សុត្វា បរនិម្មិតវសវត្តី ទេវាសទ្ទមនុស្សាវេសុំ *ទេវតាទាំងឡាយ ក្នុងជាន់បរនិម្មិតវសវត្តី បានឮសំឡេងនៃទេវតាក្នុងជាន់និម្មាន-រតីហើយ ក៏ញុំាងសំឡេងឱ្យលាន់ឮឡើង (ដោយសេចក្តីសរសើរដូចគ្នា)។*

បរនិម្មិតវសវត្តីនំ ទេវានំ សទ្ទំ សុត្វា ព្រហ្មកាយិកា ទេវា សទ្ទមនុ-សា្សវេសុំ ឯតម្ភគវតា ពារាណសិយំ ឥសិបតនេ មិគទាយេ អនុត្តរំ ធម្មចក្កំ បវត្តិតំ អប្បដិវត្តិយំ សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មិន្តិ *ទេវតាទាំងឡាយ ក្នុងពួកព្រហ្មបានឮសំឡេង*

នៃទេវតាក្នុងជាន់បរនិម្មិតវសវត្តីហើយ ក៏ញុំាងសំឡេងឱ្យលាន់ឮឡើងដូច្នេះថា ចក្រ គឺធម៌នេះ ឥតមានចក្រឯណាមួយក្រៃលែងជាង គឺសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី អ្នកឯណានីមួយក្តីក្នុងលោក សម្តែងពុំបានឡើយ មានតែព្រះដ៏មានព្រះភាគ ព្រះអង្គត្រាស់សម្តែងហើយក្នុងឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី។

ឥតិហ តេន ខណេន តេន មុហុត្តេន យាវ ព្រហ្មលោកា សទ្ទោ អព្ភុគ្គច្ឆិ *សំឡេងសាធុការលាន់ឮឡើងទៅដរាបដល់ព្រហ្មលោក ក្នុងខណៈនោះ ក្នុងមួយរំពេចនោះ ដោយអាការលាន់ឮតៗគ្នាដូច្នេះ។*

អយញ្ច ទសសហស្សី លោកធាតុ សង្កម្បិ សម្បកម្បិ សម្បវេធិ *ទាំងមុឺនលោកធាតុនេះ ក៏កក្រើកញាប់ញ័រទាំងខាងលើ ទាំងខាងក្រោម និងញាប់ញ័រក្នុងទិសទាំងពួង។*

អប្បមាណោ ច ឱឡារិកោ ទិវាសោ លោកេ បាតុរហោសិ អតិក្កម្ម ទេវានំ ទេវានុភាវន្តិ *ទាំងរស្មីដ៏រុងរឿងក្រៃពេក នឹងប្រមាណមិនបាន កន្ទងលើសទេវានុភាពនៃទេវតាទាំងឡាយ ក៏កើតឡើងប្រាកដក្នុងលោក។*

អថ ខោ ភគវា ឧទានំ[1] ឧទានេសិ អញ្ញាសិ វត អោ កោណ្ឌញ្ញោ អញ្ញាសិ វត អោ កោណ្ឌញ្ញោតិ *លំដាប់នោះ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់បន្ទឺនូវឧទានវាចាថា ឱកោណ្ឌញ្ញៈ បានចេះដឹងហើយហ្ន៎ ឱកោណ្ឌញ្ញៈ បានចេះដឹងហើយហ្ន៎។*

១-ក្នុងច្បាប់ឆដ្ឋសង្គាយនា មានបាលីថា **អថ ខោ ភគវា ឥមំ ឧទានំ**...។

ឥតិ ហិទំ អាយស្មតោ កោណ្ឌញ្ញស្ស អញ្ញាកោណ្ឌញ្ញោត្វេវ[๑] **នាមំ អហោសីតិ** *ព្រោះហេតុនោះ ពាក្យថាអញ្ញាកោណ្ឌញ្ញៈនេះឯង បានមកជាឈ្មោះនៃព្រះកោណ្ឌញ្ញៈដ៏មានអាយុ ។*

ធម្មចក្កប្បវត្តនសុត្តំ និដ្ឋិតំ

ព្រះធម្មចក្កប្បវត្តនសូត្រចប់

អនត្តលក្ខណសុត្តវណ្ណនា

យន្តំ សត្ថេហិទុក្ខេនញ្ញេយ្យំ អនត្តលក្ខណំ *អនត្តលក្ខណៈឯណាដែលសត្វទាំងឡាយគប្បីដឹងដោយកម្រ*

អត្តាទាត្តសញ្ញានំ សម្មទេវ វិមោចនំ
សម្មុទ្ធោ តំ បកាសេសិ ទិដ្ឋសច្ចាន យោគិនំ

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ប្រកាសហើយដោយប្រពៃ នូវអនត្តលក្ខណៈនោះ ជាធម៌ដោះនូវអត្តវាទុបាទាន គឺកិរិយាប្រកាន់មាំដោយសម្គាល់ថាខ្លួន ។ និងអត្តសញ្ញា គឺកិរិយាសម្គាល់ថាខ្លួនៗ ដល់ព្រះយោគី គឺភិក្ខុមានគ្នា ៥ នាក់ ជាពួកដែលមានសច្ចៈឃើញហើយ ។

ឯត្តរី បដិវេធាយ តាវតេតុំ ញាណមុត្តមំ *ដើម្បីចម្រើននូវញាណដ៏ឧត្តម ដើម្បីនឹងឱ្យត្រាស់ដឹងនូវធម៌ដ៏ខ្ពស់ក្រៃលែង*

យន្តេសំ ទិដ្ឋធម្មានំ ញាណេនុបបរិក្ខតំ

๒- ក្នុងឆដ្ឋសង្គាយនា មានបាលីថា **អញ្ញាសិ កោណ្ឌញ្ញោ ត្វេវ**...។

សព្វាសវេហិ ចិត្តានិ វិមុច្ចឹសុ អសេសតោ

ចិត្តរបស់បញ្ចវគ្គិយភិក្ខុទាំងឡាយនោះ ជាអ្នកមានធម៌ឃើញហើយ ដែលពិចារណាដោយញាណ ក៏រួចផុតហើយចាកអាសវៈទាំងពួង ឥតមានសេសសល់ដោយសូត្រឯណា

តថា ញាណានុសារេន សាសនំ ភាតុមិច្ឆតំ

សាធូនំ អត្តសិទ្ធត្ថំ តំ សុត្តន្តម្ភណាម សេ

យើងទាំងឡាយសូធ្យឥឡូវនេះ នូវព្រះសូត្រនោះ ដើម្បីឱ្យសម្រេចប្រយោជន៍ដល់អស់សាធុជន ដែលត្រូវការចង់ធ្វើតាមនូវពាក្យប្រដៅ(នៃព្រះពុទ្ធ) តាមទំនងនៃញាណយ៉ាងនោះ។

អនត្តលក្ខណសូត្រ

(បិដកលេខ ៦ ទំព័រ ៤០)

ឯវម្មេ សុតំ *សូត្រនេះ (ឈ្មោះអនត្តលក្ខណសូត្រ) គឺខ្ញុំ (ឈ្មោះអានន្ទ) បានស្តាប់មកហើយយ៉ាងនេះថា*

ឯកំ សមយំ ភគវា ពារាណសិយំ វិហរតិ ឥសិបតនេ មិគទាយេ *សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងព្រៃឥសិបតនមិគទាយវ័នជិតក្រុងពារាណសី។*

តត្រ ខោ ភគវា បញ្ចវគ្គិយេ ភិក្ខូ អាមន្តេសិ *ព្រះដ៏មានភាគព្រះភាគទ្រង់ត្រាស់ហៅនូវបញ្ចវគ្គិយភិក្ខុទាំងឡាយ ក្នុងទីនោះឯង (ឱ្យនាំគ្នាតាំងចិត្តស្តាប់

នូវភាសិតនេះថា)

រូបំ តិក្ខវេ អនត្តា *ម្នាលភិក្ខុទាំងឡាយ រូបគឺរាងកាយជាអនត្តា មិនមែនជារបស់ខ្លួនឡើយ*

រូបញ្ហា ហិទំ តិក្ខវេ អត្តា អភវិស្ស *ម្នាលភិក្ខុទាំងឡាយ ប្រសិនណាបើរូបនេះជារបស់ខ្លួនពិតមែន*

ន យិទំ រូបំ អាពាធាយ សំវត្តេយ្យ *រូបនេះក៏មិនគប្បីប្រព្រឹត្តទៅដើម្បីអាពាធ គឺជំងឺតម្កាត់ឡើយ*

លព្ភេថ ច រូបេ ឯវំ មេ រូបំ ហោតុ ឯវំ មេ រូបំ មា អហោសីតិ *ម្យ៉ាងទៀត បុគ្គលគប្បីបាន (នូវអំណាច) ក្នុងរូបថា សូមឱ្យរូបរបស់អញយ៉ាងនេះទៅ សូមកុំឱ្យរូបរបស់អញយ៉ាងនេះឡើយ*

យស្មា ច ខោ តិក្ខវេ រូបំ អនត្តា តស្មា រូបំ អាពាធាយ សំវត្តតិ *ម្នាលភិក្ខុទាំងឡាយ រូបជាអនត្តាពិតមែន ព្រោះហេតុនោះ បានជារូបចេះតែប្រព្រឹត្តទៅដើម្បីអាពាធ*

ន ច លព្ភតិ រូបេ ឯវំ មេ រូបំ ហោតុ ឯវំ មេ រូបំ មា អហោសីតិ *ម្យ៉ាងទៀត បុគ្គលមិនបាន (នូវអំណាច) ក្នុងរូបថា សូមឱ្យរូបរបស់អញយ៉ាងនេះទៅ សូមកុំឱ្យរូបរបស់អញយ៉ាងនេះឡើយ។*

វេទនា អនត្តា *វេទនាមិនមែនជារបស់ខ្លួនឡើយ*

វេទនា ច ហិទំ តិក្ខវេ អត្តា អភវិស្ស *ម្នាលភិក្ខុទាំងឡាយ ប្រសិន*

ណាបើវេទនានេះជារបស់ខ្លួនពិតមែន

ន យិទំ វេទនា អាពាធាយ សំវត្តេយ្យ *វេទនានេះ ក៏មិនគប្បីប្រព្រឹត្តទៅដើម្បីអាពាធឡើយ*

លព្ភេថ ច វេទនាយ ឯវំ មេ វេទនា ហោតុ ឯវំ មេ វេទនា មា អហោសីតិ *ម្យ៉ាងទៀត បុគ្គលគប្បីបាន (នូវអំណាច) ក្នុងវេទនាថា សូមឱ្យវេទនារបស់អញយ៉ាងនេះទៅ សូមកុំឱ្យវេទនារបស់អញយ៉ាងនេះឡើយ*

យស្មា ច ខោ ភិក្ខវេ វេទនា អនត្តា តស្មា វេទនា អាពាធាយ សំវត្តតិ *ម្នាលភិក្ខុទាំងឡាយ វេទនាជាអនត្តាពិតមែន ព្រោះហេតុនោះ បានជាវេទនាចេះតែប្រព្រឹត្តទៅដើម្បីអាពាធ*

ន ច លព្ភតិ វេទនាយ ឯវំ មេ វេទនា ហោតុ ឯវំ មេ វេទនា មា អហោសីតិ *ម្យ៉ាងទៀត បុគ្គលមិនបាន (នូវអំណាច) ក្នុងវេទនាថា សូមឱ្យវេទនារបស់អញយ៉ាងនេះទៅ សូមកុំឱ្យវេទនារបស់អញយ៉ាងនេះឡើយ។*

សញ្ញា អនត្តា *សញ្ញាមិនមែនជារបស់ខ្លួនឡើយ*

សញ្ញា ច ហិទំ ភិក្ខវេ អត្តា អភវិស្ស *ម្នាលភិក្ខុទាំងឡាយ ប្រសិនណាបើសញ្ញានេះជារបស់ខ្លួនពិតមែន*

ន យិទំ សញ្ញា អាពាធាយ សំវត្តេយ្យ *សញ្ញានេះក៏មិនគប្បីប្រព្រឹត្តទៅដើម្បីអាពាធឡើយ*

លព្ភេថ ច សញ្ញាយ ឯវំ មេ សញ្ញា ហោតុ ឯវំ មេសញ្ញា មា

អហោសីតិ *ម្យ៉ាងទៀត បុគ្គលគប្បីបាន (នូវអំណាច) ក្នុងសញ្ញាថា សូមឱ្យសញ្ញារបស់អញយ៉ាងនេះទៅ សូមកុំឱ្យសញ្ញារបស់អញយ៉ាងនេះឡើយ*

យស្មា ច ខោ ភិក្ខវេ សញ្ញា អនត្តា តស្មា សញ្ញា អាពាធាយ សំវត្តតិ *ម្នាលភិក្ខុទាំងឡាយ សញ្ញាជាអនត្តាពិតមែន ព្រោះហេតុនោះ បានជាសញ្ញាចេះតែប្រព្រឹត្តទៅដើម្បីអាពាធ*

ន ច លព្ភតិ សញ្ញាយ ឯវំ មេ សញ្ញា ហោតុ ឯវំ មេសញ្ញា មា អហោសីតិ *ម្យ៉ាងទៀត បុគ្គលមិនបាន (នូវអំណាច) ក្នុងសញ្ញាថា សូមឱ្យសញ្ញារបស់អញយ៉ាងនេះទៅ សូមកុំឱ្យសញ្ញារបស់អញយ៉ាងនេះឡើយ។*

សង្ខារ អនត្តា *សង្ខារទាំងឡាយ មិនមែនជារបស់ខ្លួនឡើយ*

សង្ខារ ច ហិទំ ភិក្ខវេ អត្តា អភវិស្សុ *ម្នាលភិក្ខុទាំងឡាយ ប្រសិនណាបើសង្ខារទាំងឡាយនេះជារបស់ខ្លួនពិតមែន*

ន យិទំ សង្ខារ អាពាធាយ សំវត្តេយ្យុំ *សង្ខារទាំងឡាយ នេះក៏មិនគប្បីប្រព្រឹត្តទៅដើម្បីអាពាធឡើយ*

លព្ភេថ ច សង្ខារេសុ ឯវំ មេ សង្ខារ ហោន្តុ ឯវំ មេ សង្ខារ មា អហេសុន្តិ *ម្យ៉ាងទៀត បុគ្គលគប្បីបាន (នូវអំណាច) ក្នុងសង្ខារទាំងឡាយថា សូមឱ្យសង្ខារទាំងឡាយរបស់អញយ៉ាងនេះទៅ សូមកុំឱ្យសង្ខារទាំងឡាយរបស់អញយ៉ាងនេះឡើយ*

យស្មា ច ខោ ភិក្ខ ខេសង្ខារ អនត្តា តស្មា សង្ខារ អាពាធាយ សំវត្តន្តិ *ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយជាអនត្តាពិតមែន ព្រោះហេតុ*

នោះ បានជាសង្ខារទាំងឡាយ ចេះតែប្រព្រឹត្តទៅដើម្បីអាពាធ

ន ច លព្ភតិ សង្ខារេសុ ឯវំ មេ សង្ខារា ហោន្តុ ឯវំ មេ សង្ខារា មា អហេសុន្តិ *ម្យ៉ាងទៀត បុគ្គលមិនបាន (នូវអំណាច) ក្នុងសង្ខារទាំងឡាយថា សូមឱ្យសង្ខារទាំងឡាយរបស់អញយ៉ាងនេះទៅ សូមកុំឱ្យសង្ខារទាំងឡាយរបស់អញយ៉ាងនេះឡើយ។*

វិញ្ញាណំ អនត្តា *វិញ្ញាណ មិនមែនជារបស់ខ្លួនឡើយ*

វិញ្ញាណញ្ច ហិទំ អភវេ អត្តា អភវិស្ស *ម្នាលភិក្ខុទាំងឡាយ ប្រសិនណាបើវិញ្ញាណនេះជារបស់ខ្លួនពិតមែន*

ន យិទំ វិញ្ញាណំ អាពាធាយ សំវត្តេយ្យ *វិញ្ញាណនេះ ក៏មិនគប្បីប្រព្រឹត្តទៅដើម្បីអាពាធឡើយ*

លព្ភេថ ច វិញ្ញាណេ ឯវំ មេ វិញ្ញាណំ ហោតុ ឯវំ មេ វិញ្ញាណំ មា អហោសីតិ *ម្យ៉ាងទៀត បុគ្គលគប្បីបាន (នូវអំណាច) ក្នុងវិញ្ញាណថា សូមឱ្យវិញ្ញាណរបស់អញយ៉ាងនេះទៅ សូមកុំឱ្យវិញ្ញាណរបស់អញយ៉ាងនេះឡើយ*

យស្មា ច ខោ ភិក្ខវេ វិញ្ញាណំ អនត្តា តស្មា វិញ្ញាណំ អាពាធាយ សំវត្តតិ *ម្នាលភិក្ខុទាំងឡាយ វិញ្ញាណជាអនត្តាពិតមែន ព្រោះហេតុនោះ បានជាវិញ្ញាណចេះតែប្រព្រឹត្តទៅដើម្បីអាពាធ*

ន ច លព្ភតិ វិញ្ញាណេ ឯវំ មេ វិញ្ញាណំ ហោតុ ឯវំ មេ វិញ្ញាណំ មា អហោសីតិ *ម្យ៉ាងទៀត បុគ្គលមិនបាន (នូវអំណាច) ក្នុងវិញ្ញាណថា សូមឱ្យ*

វិញ្ញាណរបស់អញយ៉ាងនេះទៅ សូមកុំឱ្យវិញ្ញាណរបស់អញយ៉ាងនេះឡើយ។

តំ កឹ មញ្ញថ ភិក្ខវេ រូបំ និច្ចំ វា អនិច្ចំ វាតិ *ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់នូវសេចក្តីនោះថាដូចម្តេច រូបទៀង ឬមិនទៀង?*

អនិច្ចំ តន្តេ *បពិត្រព្រះអង្គដ៏ចម្រើន រូបមិនទៀងទេ។*

យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ *ក៏របស់ឯណា ដែលមិនទៀង របស់នោះជាទុក្ខ ឬជាសុខ?*

ទុក្ខំ តន្តេ *បពិត្រព្រះអង្គដ៏ចម្រើន របស់នោះជាទុក្ខ។*

យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ *ក៏របស់ឯណា ដែលមិនទៀង ដែលជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរឬដើម្បីនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ?*

នោ ហេតំ តន្តេ *បពិត្រព្រះអង្គដ៏ចម្រើន មិនគួរដើម្បីនឹងយល់ឃើញយ៉ាងនុ៎ះទេ។*

តំ កឹ មញ្ញថ ភិក្ខវេ វេទនា និច្ចា វា អនិច្ចា វាតិ *ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់នូវសេចក្តីនោះថាដូចម្តេច វេទនាទៀងឬមិនទៀង?*

អនិច្ចា តន្តេ *បពិត្រព្រះអង្គដ៏ចម្រើន វេទនាមិនទៀងទេ។*

យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ *ក៏របស់ឯណា ដែលមិនទៀង របស់នោះជាទុក្ខ ឬជាសុខ?*

ទុក្ខំ ភន្តេ *បពិត្រព្រះអង្គដ៏ចម្រើន របស់នោះជាទុក្ខ។*

យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ *ក៏របស់ឯណា ដែលមិនទៀង ដែលជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរឬដើម្បីនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ?*

នោ ហេតំ ភន្តេ *បពិត្រព្រះអង្គដ៏ចម្រើន មិនគួរដើម្បីនឹងយល់ឃើញយ៉ាងនុ៎ះទេ។*

តំ កឹ មញ្ញថ ភិក្ខវេ សញ្ញា និច្ចា វា អនិច្ចា វាតិ *ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់នូវសេចក្តីនោះថាដូចម្តេច សញ្ញាទៀង ឬមិនទៀង?*

អនិច្ចា ភន្តេ *បពិត្រព្រះអង្គដ៏ចម្រើន សញ្ញាមិនទៀងទេ។*

យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ *ក៏របស់ឯណា ដែលមិនទៀង របស់នោះជាទុក្ខ ឬជាសុខ?*

ទុក្ខំ ភន្តេ *បពិត្រព្រះអង្គដ៏ចម្រើន របស់នោះជាទុក្ខ។*

យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ *ក៏របស់ឯណា ដែលមិនទៀង ដែលជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរឬដើម្បីនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ?*

នោ ហេតំ ភន្តេ *បពិត្រព្រះអង្គដ៏ចម្រើន មិនគួរដើម្បីនឹងយល់ឃើញ*

យ៉ាងនុ៎ះទេ ។

តំ កឹ មញ្ញថ ភិក្ខវេ សង្ខារ និច្ចា វា អនិច្ចា វាតិ *ម្នាលភិក្ខុទាំង-ឡាយ អ្នកទាំងឡាយសម្គាល់នូវសេចក្តីនោះថាដូចម្តេច សង្ខារទាំងឡាយទៀង ឬមិនទៀង ?*

អនិច្ចា ភន្តេ *បពិត្រព្រះអង្គដ៏ចម្រើន សង្ខារទាំងឡាយ មិនទៀងទេ ។*

យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ *ក៏របស់ឯណា ដែលមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ?*

ទុក្ខំ ភន្តេ *បពិត្រព្រះអង្គដ៏ចម្រើន របស់នោះជាទុក្ខ ។*

យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ *ក៏របស់ឯណា ដែលមិនទៀង ដែលជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរឬដើម្បីនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ។*

នោ ហេតំ ភន្តេ *បពិត្រព្រះអង្គដ៏ចម្រើន មិនគួរដើម្បីនឹងយល់ឃើញ យ៉ាងនុ៎ះទេ ។*

តំ កឹ មញ្ញថ ភិក្ខវេ វិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ *ម្នាលភិក្ខុទាំង-ឡាយ អ្នកទាំងឡាយសម្គាល់នូវសេចក្តីនោះថាដូចម្តេច វិញ្ញាណទៀង ឬមិនទៀង ?*

អនិច្ចំ ភន្តេ *បពិត្រព្រះអង្គដ៏ចម្រើន វិញ្ញាណមិនទៀងទេ ។*

យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ *ក៏របស់ឯណាដែលមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ?*

ទុក្ខំ ភន្តេ *បពិត្រព្រះអង្គដ៏ចម្រើន របស់នោះជាទុក្ខ ។*

យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ *ក៏របស់ឯណា ដែលមិនទៀង ដែលជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរឬដើម្បីនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ?*

នោ ហេតំ ភន្តេ *បពិត្រព្រះអង្គដ៏ចម្រើន មិនគួរដើម្បីនឹងយល់ឃើញយ៉ាងនុ៎ះទេ ។*

តស្មាតិហ ភិក្ខវេ យំ កិញ្ចិ រូបំ អតីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យន្ទូរេ សន្តិកេ វា សព្វំ រូបំ *ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ រូបឯណាមួយ ដែលជាអតីតក្តី ជាអនាគតក្តី ជាបច្ចុប្បន្នក្តី ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រោតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី រូបឯណាដែលមានក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី អ្នកទាំងឡាយ គួរឃើញនូវរូបទាំងអស់នោះថាត្រឹមតែជារូប (ប៉ុណ្ណោះឯង)*

នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្ម-ប្បញ្ញាយ ទដ្ឋព្វំ *អ្នកទាំងឡាយ គួរឃើញនូវសេចក្តីនុ៎ះ ដោយប្រាជ្ញាដ៏ល្អ តាមសេចក្តីពិតយ៉ាងនេះដូច្នេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិន*

មែនជាខ្លួនរបស់អញឡើយ។

យា កាចិ វេទនា អតីតានាគតប្បច្ចុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមា វា ហីនា វា បណីតា វា យាទូរេ សន្តិកេ វា សព្វា វេទនា *វេទនាឯណាមួយ ដែលជាអតីតក្តី ជាអនាគតក្តី ជាបច្ចុប្បន្នក្តី ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រោតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី វេទនាឯណាដែលមានក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី អ្នកទាំងឡាយគួរឃើញនូវវេទនាទាំងអស់នោះ ថាត្រឹមជាវេទនា (ប៉ុណ្ណោះឯង)*

នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្ម-ប្បញ្ញាយ ទដ្ឋព្ពំ *អ្នកទាំងឡាយ គួរឃើញនូវសេចក្តីនុ៎ះដោយប្រាជ្ញាដ៏ល្អ តាមសេចក្តីពិតយ៉ាងនេះដូច្នេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ។*

យា កាចិ សញ្ញា អតីតានាគតប្បច្ចុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមា វា ហីនា វា បណីតា វា យាទូរេ សន្តិកេ វា សព្វា សញ្ញា *សញ្ញាឯណាមួយ ដែលជាអតីតក្តី ជាអនាគតក្តី ជាបច្ចុប្បន្នក្តី ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រោតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី សញ្ញាឯណា ដែលមានក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី អ្នកទាំងឡាយគួរឃើញនូវសញ្ញាទាំងអស់នោះ ថាត្រឹមជាសញ្ញា (ប៉ុណ្ណោះឯង)។*

នេតំ មម នេសោហមស្មិ នមេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្ម-ប្បញ្ញាយ ទដ្ឋព្ពំ *អ្នកទាំងឡាយ គួរឃើញនូវសេចក្តីនុ៎ះ ដោយប្រាជ្ញាដ៏ល្អ តាម*

សេចក្តីពិត យ៉ាងនេះដូច្នេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិន-មែនជាខ្លួនរបស់អញឡើយ ។

យេ កេចិ សង្ខារ អតីតានាគតបច្ចុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមា វា ហីនា វា បណីតា វា យេ ទូរេ សន្តិកេ វា សព្ពេ សង្ខារ *សង្ខារទាំងឡាយឯណាមួយ ដែលជាអតីតក្តី ជាអនាគតក្តី ជាបច្ចុប្បន្នក្តី ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រោតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី សង្ខារទាំងឡាយឯណា ដែលមានក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី អ្នកទាំងឡាយគួរឃើញនូវសង្ខារទាំង-ឡាយនោះថាត្រឹមជាសង្ខារ (ប៉ុណ្ណោះឯង)*

នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្ម-ប្បញ្ញាយ ទដ្ឋព្ពំ *អ្នកទាំងឡាយ គួរឃើញនូវសេចក្តីនុ៎ះដោយប្រាជ្ញាដ៏ល្អ តាមសេចក្តីពិតយ៉ាងនេះដូច្នេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិន-មែនជាខ្លួនរបស់អញឡើយ ។*

យំ កិញ្ចិ វិញ្ញាណំ អតីតានាគតបច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យទ្ទូរេ សន្តិកេ វា សព្ពំ វិញ្ញាណំ *វិញ្ញាណឯណាមួយ ដែលជាអតីតក្តី ជាអនាគតក្តី ជាបច្ចុប្បន្នក្តី ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រោតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី វិញ្ញាណឯណា ដែលមានក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី អ្នកទាំងឡាយ គួរឃើញនូវវិញ្ញាណទាំងអស់នោះថាត្រឹមជាវិញ្ញាណ (ប៉ុណ្ណោះឯង)*

នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្ម-

ប្បញ្ញាយ ទដ្ឋព្វំ *អ្នកទាំងឡាយ គួរឃើញនូវសេចក្តីនុ៎ះដោយប្រាជ្ញាដ៏ល្អ តាមសេចក្តីពិត យ៉ាងនេះដូច្នេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញឡើយ ។*

ឯវំ បស្សំ តិក្ខវេ សុតវា អរិយសាវកោ រូបស្មិម្បិ និព្វិន្ទតិ វេទនាយបិ និព្វិន្ទតិ សញ្ញាយបិ និព្វិន្ទតិ សង្ខារេសុបិ និព្វិន្ទតិ វិញ្ញាណស្មិម្បិ និព្វិន្ទតិ *ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កបានស្តាប់ហើយយល់ឃើញយ៉ាងនេះ ក៏នឿយណាយក្នុងរូបផង នឿយណាយក្នុងវេទនាផង នឿយណាយក្នុងសញ្ញាផង នឿយណាយក្នុងសង្ខារទាំងឡាយផង នឿយណាយក្នុងវិញ្ញាណផង*

និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ *កាលបើនឿយណាយ (យ៉ាងនេះហើយ) ក៏ប្រាសចាកម្រេក ចិត្តក៏ផុតស្រឡះ (ចាកអាសវៈទាំងឡាយ) ព្រោះកិរិយាប្រាសចាកតម្រេក*

វិមុត្តស្មឹ វិមុត្តមីតិ ញាណំ ហោតិ *កាលដែលចិត្តផុតស្រឡះ (ចាកអាសវៈទាំងឡាយ) ហើយ ញាណ (របស់អរិយសាវ័កនោះ) ក៏កើតឡើងជ្រាកដថា ចិត្ត (របស់អញ) ផុតស្រឡះ (ចាកអាសវៈទាំងឡាយ) ហើយ ។*

ខីណា ជាតិ ខុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ *(អរិយសាវ័កនោះ) ក៏ដឹងច្បាស់ដូច្នេះថា ជាតិ (របស់អញ) អស់ហើយ មគ្គព្រហ្មចរិយធម៌ អញបាននៅរួចហើយ កិច្ចដែលគួរធ្វើ អញក៏បានធ្វើរួចហើយ កិច្ចឯទៀតក្រៅពីនេះ មិនមាន (ដល់អញ) ឡើយ ។*

ឥទមវោច ភគវា *ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់បានត្រាស់សម្តែងនូវសូត្រនេះចប់ហើយ*

អត្តមនា បញ្ចវគ្គិយា ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុំ *បញ្ចវគ្គិយភិក្ខុទាំងឡាយ ក៏មានចិត្តត្រេកអរវីរភាយ ចំពោះភាសិតនៃព្រះដ៏មានព្រះភាគជាម្ចាស់ ។*

ឥមស្មិញ្ច បន វេយ្យាករណស្មឹ ភញ្ញាមានេ បញ្ចវគ្គិយានំ ភិក្ខូនំ អនុបាទាយ អាសវេហិ ចិត្តានិ វិមុច្ចឹសូតិ *ក៏កាលដែលព្រះដ៏មានព្រះភាគជាម្ចាស់កំពុងត្រាស់សម្តែងនូវវេយ្យាករណ៍នេះ ចិត្តរបស់ភិក្ខុទាំង ៥ រូប បានរួចស្រឡះហើយ ចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ (ថាអញ ថាយើងទៀតឡើយ)។*

អនត្តលក្ខណសុត្តំ និដ្ឋិតំ

អនត្តលក្ខណសូត្រ ចប់

អាទិត្តបរិយាយសុត្តវណ្ណោ

វេនេយ្យទមនោបាយេ សព្ពសោ បារមឹ គតោ
អមោឃវចនោ ពុទ្ធោ អតិញ្ញាយានុសាសកោ

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់បានសម្រេចនូវព្រះបារមី ដោយសព្វគ្រប់ហើយ ព្រះអង្គមានវាចាមិនឥតអំពើ ទ្រង់ប្រៀនប្រដៅឧបាយទូន្មាននូវវេនេយ្យសត្វ ដើម្បីបានត្រាស់ដឹង

ចិណ្ណានុរូបតោ ចាបិ ធម្មេន ទិនយំ បដិ *ទ្រង់ណែនាំពន្យល់នូវពពួកសត្វ ដោយធម៌តាមសមគួរដល់ឧបនិស្សយដែលសត្វសន្សំទុកមក*

ចិណ្ណាភិរិចរិយានំ សម្ពោជ្ឈារហយោគិនំ
យមាទិត្តបរិយាយំ ទេសយន្តោមនោរមំ

ទ្រង់ត្រាស់សម្តែងនូវសូត្រឯណា ឈ្មោះថាអាទិត្តបរិយាយសូត្រ ជាគ្រឿងនាំចិត្តនៃពួកព្រះយោគី ជាអ្នកគួរនឹងត្រាស់ដឹង ដែលជាជដិលធ្លាប់សន្សំខាងកិច្ចបម្រើក្នើង

តេ សោតារោ ទិមោចេសិ អសេក្ខាយ ទិមុត្តិយា *ទ្រង់ញុំាងព្រះយោគីទាំងនោះ ដែលជាអ្នកស្តាប់ ឱ្យបានរួចផុតស្រឡះហើយ ចាកអាសវៈទាំងឡាយ ដោយអសេក្ខវិមុត្តិ*

តថេវោបបរិក្ខាយ ទិញ្ញានំ សោតុមិច្ឆតំ
ទុក្ខតាលក្ខណោបាយំ តំ សុត្តន្តម្ភណាម សេ

យើងទាំងឡាយ សូម្បីឥឡូវនេះ នូវព្រះសូត្រនោះ ជាឧបាយ ជាគ្រឿងកំណត់នូវភាវៈនៃសេចក្តីទុក្ខ ដើម្បីវិញ្ញជនទាំងឡាយ ដែលត្រូវការចង់ស្តាប់ដោយកិរិយាពិចារណា យ៉ាងនោះឯង ។

អាទិត្តបរិយាយសូត្រ

(បិដកលេខ ៦ ទំព័រ ១០៤)

ឯវម្មេ សុតំ *សូត្រនេះ (ឈ្មោះអាទិត្តបរិយាយសូត្រ) គឺខ្ញុំ (ឈ្មោះអានន្ទ) បានស្តាប់មកហើយយ៉ាងនេះថា*

ឯកំ សមយំ ភគវា គយាយំ វិហរតិ គយាសីសេ សទ្ធឹ ភិក្ខុសហស្សេន *សម័យមួយ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់គង់នៅក្នុងគយាសីសប្រទេស ជិតស្នឹងឈ្មោះគយា ជាមួយនឹងភិក្ខុ ១ ពាន់អង្គ ។*

តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ *ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយ ក្នុងគយាសីសប្រទេសនោះ (ឱ្យនាំគ្នាតាំងចិត្តស្តាប់នូវភាសិតដូច្នេះថា)*

សព្ពំ ភិក្ខវេ អាទិត្តំ *ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងពួងជារបស់ក្តៅ*

កិញ្ច ភិក្ខវេ សព្ពំ អាទិត្តំ *ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងពួងជារបស់ក្តៅ គឺអ្វីខ្លះ?*

ចក្ខុំ ភិក្ខវេ អាទិត្តំ *ម្នាលភិក្ខុទាំងឡាយ ភ្នែកជារបស់ក្តៅ*

រូបា អាទិត្តា *រូបទាំងឡាយ ជារបស់ក្តៅ*

ចក្ខុវិញ្ញាណំ អាទិត្តំ *វិញ្ញាណអាស្រ័យនឹងភ្នែក ជារបស់ក្តៅ*

ចក្ខុសម្ផស្សោ អាទិត្តោ *សម្ផស្សអាស្រ័យនឹងភ្នែក ជារបស់ក្តៅ*

យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា *សេចក្តីដឹងច្បាស់នូវអារម្មណ៍ គឺវេទនាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខ មិនមែនសុខក្តី កើតឡើងព្រោះចក្ខុសម្ផស្សជាបច្ច័យឯណា*

តម្បិ អាទិត្តំ *សេចក្តីដឹងច្បាស់នូវអារម្មណ៍នោះ ក៏ជារបស់ក្តៅ ។*

កេន អាទិត្តំ *ក្តៅដោយអ្វី?*

រាគគ្គិនា ទោសគ្គិនា មោហគ្គិនា អាទិត្តំ, ជាតិយា ជរាមរណេន

សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ អាទិត្តន្តិវទាមិ[1] *តថាគតពោលថា ភ្លៅដោយភ្លើង គឺរាគៈ ដោយភ្លើង គឺទោសៈ ដោយភ្លើង គឺមោហៈ, ភ្លៅដោយសេចក្តីកើត ដោយសេចក្តីចាស់គ្រាំគ្រា និងសេចក្តីស្លាប់ ដោយសេចក្តីសោក ដោយសេចក្តីខ្សឹកខ្សួល ដោយសេចក្តីទុក្ខក្នុងកាយ ដោយសេចក្តីទុក្ខក្នុងចិត្ត ដោយសេចក្តីចង្អៀតចង្អល់ក្នុងចិត្តទាំងឡាយ។*

សោតំ អាទិត្តំ *ត្រចៀក ជារបស់ភ្លៅ*

សទ្ទា អាទិត្តា *សំឡេងទាំងឡាយ ជារបស់ភ្លៅ*

សោតវិញ្ញាណំ អាទិត្តំ *វិញ្ញាណអាស្រ័យនឹងត្រចៀក ជារបស់ភ្លៅ*

សោតសម្ផស្សោ អាទិត្តោ *សម្ផស្សអាស្រ័យនឹងត្រចៀក ជារបស់ភ្លៅ*

យម្បិទំ សោតសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា *សេចក្តីដឹងច្បាស់នូវអារម្មណ៍ គឺវេទនាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខ មិនមែនសុខក្តី កើតឡើងព្រោះសោតសម្ផស្សជាបច្ច័យឯណា*

តម្បិ អាទិត្តំ *សេចក្តីដឹងច្បាស់នូវអារម្មណ៍នោះ ក៏ជារបស់ភ្លៅ។*

កេន អាទិត្តំ *ភ្លៅដោយអ្វី?*

រាគគ្គិនា ទោសគ្គិនា មោហគ្គិនា អាទិត្តំ, ជាតិយា ជរាមរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ អាទិត្តន្តិវទាមិ *តថាគតពោលថា ភ្លៅដោយភ្លើង គឺរាគៈ ដោយភ្លើង គឺទោសៈ ដោយភ្លើង គឺ*

១-បាលីត្រង់នេះ យើងបានកែតម្រូវតាមបិដកលេខ ៦ ទំព័រ ១០៤ និងបាលីច្បាប់ឆដ្ឋសង្គាយនា។

មោហៈ, ក្តៅដោយសេចក្តីកើត ដោយសេចក្តីចាស់គ្រាំគ្រានិងសេចក្តីស្លាប់ ដោយសេចក្តីសោក ដោយសេចក្តីខ្សឹកខ្សួល ដោយសេចក្តីទុក្ខក្នុងកាយ ដោយសេចក្តីទុក្ខក្នុងចិត្ត ដោយសេចក្តីចង្អៀតចង្អល់ក្នុងចិត្តទាំងឡាយ។

ឃានំ អាទិត្តំ *ច្រមុះ ជារបស់ក្តៅ*

គន្ធា អាទិត្តា *ក្លិនទាំងឡាយ ជារបស់ក្តៅ*

ឃានវិញ្ញាណំ អាទិត្តំ *វិញ្ញាណអាស្រ័យនឹងច្រមុះ ជារបស់ក្តៅ*

ឃានសម្ផស្សោ អាទិត្តោ *សម្ផស្សអាស្រ័យនឹងច្រមុះ ជារបស់ក្តៅ*

យម្បិទំ ឃានសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា *សេចក្តីដឹងច្បាស់នូវអារម្មណ៍ គឺវេទនាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខ មិនមែនសុខក្តី កើតឡើងព្រោះឃានសម្ផស្សជាបច្ច័យឯណា*

តម្បិ អាទិត្តំ *សេចក្តីដឹងច្បាស់នូវអារម្មណ៍នោះ ក៏ជារបស់ក្តៅ។*

កេន អាទិត្តំ *ក្តៅដោយអ្វី?*

រាគគ្គិនា ទោសគ្គិនា មោហគ្គិនា អាទិត្តំ, ជាតិយា ជរាមរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ អាទិត្តន្តិវទាមិ *តថាគតពោលថា ក្តៅដោយភ្លើង គឺរាគៈ ដោយភ្លើង គឺទោសៈ ដោយភ្លើង គឺមោហៈ, ក្តៅដោយសេចក្តីកើត ដោយសេចក្តីចាស់គ្រាំគ្រានិងសេចក្តីស្លាប់ ដោយសេចក្តីសោក ដោយសេចក្តីខ្សឹកខ្សួល ដោយសេចក្តីទុក្ខក្នុងកាយ ដោយសេចក្តីទុក្ខក្នុងចិត្ត ដោយសេចក្តីចង្អៀតចង្អល់ក្នុងចិត្តទាំងឡាយ។*

ជិវ្ហា អាទិត្តា *អណ្តាត ជារបស់ក្តៅ*

រសា អាទិត្តា *រសទាំងឡាយ ជារបស់ក្តៅ*

ជិវ្ហាវិញ្ញាណំ អាទិត្តំ *វិញ្ញាណអាស្រ័យនឹងអណ្តាត ជារបស់ក្តៅ*

ជិវ្ហាសម្ផស្សោ អាទិត្តោ *សម្ផស្សអាស្រ័យនឹងអណ្តាត ជារបស់ក្តៅ*

យម្បិទំ ជិវ្ហាសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា *សេចក្តីដឹងច្បាស់នូវអារម្មណ៍ គឺវេទនាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខ មិនមែនសុខក្តី កើតឡើងព្រោះជិវ្ហាសម្ផស្សជាបច្ច័យឯណា*

តម្បិ អាទិត្តំ *សេចក្តីដឹងច្បាស់នូវអារម្មណ៍នោះ ក៏ជារបស់ក្តៅ។*

កេន អាទិត្តំ *ក្តៅដោយអ្វី?*

រាគគ្គិនា ទោសគ្គិនា មោហគ្គិនា អាទិត្តំ, ជាតិយា ជរាមរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ អាទិត្តន្តិវទាមិ *តថាគតពោលថា ក្តៅដោយភ្លើង គឺរាគៈ ដោយភ្លើង គឺទោសៈ ដោយភ្លើង គឺមោហៈ, ក្តៅដោយសេចក្តីកើត ដោយសេចក្តីចាស់គ្រាំគ្រានិងសេចក្តីស្លាប់ ដោយសេចក្តីសោក ដោយសេចក្តីខ្សឹកខ្សួល ដោយសេចក្តីទុក្ខក្នុងកាយ ដោយសេចក្តីទុក្ខក្នុងចិត្ត ដោយសេចក្តីចង្អៀតចង្អល់ក្នុងចិត្តទាំងឡាយ។*

កាយោ អាទិត្តោ *កាយ ជារបស់ក្តៅ*

ផោដ្ឋព្វា អាទិត្តា *ផោដ្ឋព្វៈ គឺអារម្មណ៍ដែលប៉ះពាល់ត្រូវដោយកាយទាំងឡាយ ជារបស់ក្តៅ*

កាយវិញ្ញាណំ អាទិត្តំ *វិញ្ញាណអាស្រ័យនឹងកាយ ជារបស់ក្តៅ*

កាយសម្ផស្សោ អាទិត្តោ *សម្ផស្សអាស្រ័យនឹងកាយ ជារបស់ក្តៅ*

យម្បិទំ កាយសម្ផស្សប្បច្ចយា ទ្វិប្បដិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា *សេចក្តីដឹងច្បាស់នូវអារម្មណ៍ គឺវេទនាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខ មិនមែនសុខក្តី កើតឡើងព្រោះកាយសម្ផស្សជាបច្ច័យឯណា*

តម្បិ អាទិត្តំ *សេចក្តីដឹងច្បាស់នូវអារម្មណ៍នោះ ក៏ជារបស់ក្តៅ។*

កេន អាទិត្តំ *ក្តៅដោយអ្វី ?*

រាគគ្គិនា ទោសគ្គិនា មោហគ្គិនា អាទិត្តំ, ជាតិយ ជរាមរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ អាទិត្តន្តិវទាមិ *តថាគតពោលថា ក្តៅដោយភ្លើង គឺរាគៈ ដោយភ្លើង គឺទោសៈ ដោយភ្លើង គឺមោហៈ, ក្តៅដោយសេចក្តីកើត ដោយសេចក្តីចាស់គ្រាំគ្រានិងសេចក្តីស្លាប់ ដោយសេចក្តីសោក ដោយសេចក្តីខ្សឹកខ្សួល ដោយសេចក្តីទុក្ខក្នុងកាយ ដោយសេចក្តីទុក្ខក្នុងចិត្ត ដោយសេចក្តីចង្អៀតចង្អល់ក្នុងចិត្តទាំងឡាយ។*

មនោ អាទិត្តោ *ចិត្ត ជារបស់ក្តៅ*

ធម្មា អាទិត្តា *ធម៌ទាំងឡាយ គឺអារម្មណ៍ដែលកើតក្នុងចិត្ត ជារបស់ក្តៅ*

មនោវិញ្ញាណំ អាទិត្តំ *វិញ្ញាណអាស្រ័យនឹងចិត្ត ជារបស់ក្តៅ*

មនោសម្ផស្សោ អាទិត្តោ *សម្ផស្សអាស្រ័យនឹងចិត្ត ជារបស់ក្តៅ*

យម្បិទំ មនោសម្ផស្សប្បច្ចយា ទ្វិប្បដិ វេទយិតំ សុខំ វា ទុក្ខំ វា

អទុក្ខមសុខំ វា *សេចក្តីដឹងច្បាស់នូវអារម្មណ៍ គឺវេទនាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី កើតឡើងព្រោះមនោសម្ផស្សជាបច្ច័យឯណា*

តម្បិ អាទិត្តំ *សេចក្តីដឹងច្បាស់នូវអារម្មណ៍នោះក៏ជារបស់ក្តៅ។*

កេន អាទិត្តំ *ក្តៅដោយអ្វី?*

រាគគ្គិនា ទោសគ្គិនា មោហគ្គិនា អាទិត្តំ, ជាតិយា ជរាមរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ អាទិត្តន្តិវទាមិ *តថាគតពោលថា ក្តៅដោយភ្លើង គឺរាគៈ ដោយភ្លើង គឺទោសៈ ដោយភ្លើង គឺមោហៈ, ក្តៅដោយសេចក្តីកើត ដោយសេចក្តីចាស់គ្រាំគ្រានិងសេចក្តីស្លាប់ ដោយសេចក្តីសោក ដោយសេចក្តីខ្សឹកខ្សួល ដោយសេចក្តីទុក្ខក្នុងកាយ ដោយសេចក្តីទុក្ខក្នុងចិត្ត ដោយសេចក្តីចង្អៀតចង្អល់ក្នុងចិត្តទាំងឡាយ។*

ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ ចក្ខុស្មិម្បិ និព្វិន្ទតិ រូបេសុម្បិ និព្វិន្ទតិ ចក្ខុវិញ្ញាណេម្បិ និព្វិន្ទតិ ចក្ខុសម្ផស្សេម្បិ និព្វិន្ទតិ *ម្នាលភិក្ខុទាំងឡាយ អរិយសាវ័ក កាលបើបានស្តាប់ហើយយល់ឃើញយ៉ាងនេះ ក៏នឿយណាយក្នុងភ្នែកផង នឿយណាយក្នុងរូបទាំងឡាយផង នឿយណាយក្នុងវិញ្ញាណអាស្រ័យនឹងភ្នែកផង នឿយណាយក្នុងសម្ផស្សអាស្រ័យនឹងភ្នែកផង*

យម្បិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តស្មិម្បិ និព្វិន្ទតិ *សេចក្តីដឹងច្បាស់នូវអារម្មណ៍ គឺវេទនាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី កើតឡើងព្រោះចក្ខុសម្ផស្សជាបច្ច័យឯណា ក៏នឿយណាយក្នុងសេចក្តីដឹងច្បាស់នូវអារម្មណ៍នោះ។*

សោតស្មឹបិ និព្វិន្ទតិ សទ្ទេសុបិ និព្វិន្ទតិ សោតវិញ្ញាណេបិ និព្វិន្ទតិ សោតសម្ផស្សេបិ និព្វិន្ទតិ *នឿយណាយក្នុងត្រចៀកផង នឿយណាយក្នុងសំឡេងទាំងឡាយផង នឿយណាយក្នុងវិញ្ញាណអាស្រ័យនឹងត្រចៀកផង នឿយណាយក្នុងសម្ផស្សអាស្រ័យនឹងត្រចៀកផង*

យម្បិទំ សោតសម្ផស្សប្បច្ចយា ទុក្ខជ្ឈតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តស្មឹបិ និព្វិន្ទតិ *សេចក្តីដឹងច្បាស់នូវអារម្មណ៍ គឺវេទនាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី កើតឡើងព្រោះសោតសម្ផស្សជាបច្ច័យឯណា ក៏នឿយណាយក្នុងសេចក្តីដឹងច្បាស់នូវអារម្មណ៍នោះ។*

ឃានស្មឹបិ និព្វិន្ទតិ គន្ធេសុបិ និព្វិន្ទតិ ឃានវិញ្ញាណេបិ និព្វិន្ទតិ ឃានសម្ផស្សេបិ និព្វិន្ទតិ *នឿយណាយក្នុងច្រមុះផង នឿយណាយក្នុងក្លិនទាំងឡាយផង នឿយណាយក្នុងវិញ្ញាណអាស្រ័យនឹងច្រមុះផង នឿយណាយក្នុងសម្ផស្សអាស្រ័យនឹងច្រមុះផង*

យម្បិទំ ឃានសម្ផស្សប្បច្ចយា ទុក្ខជ្ឈតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តស្មឹបិ និព្វិន្ទតិ *សេចក្តីដឹងច្បាស់នូវអារម្មណ៍ គឺវេទនាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី កើតឡើងព្រោះឃានសម្ផស្សជាបច្ច័យឯណា ក៏នឿយណាយក្នុងសេចក្តីដឹងច្បាស់នូវអារម្មណ៍នោះ។*

ជិវ្ហាយបិ និព្វិន្ទតិ រសេសុបិ និព្វិន្ទតិ ជិវ្ហាវិញ្ញាណេបិ និព្វិន្ទតិ ជិវ្ហាសម្ផស្សេបិ និព្វិន្ទតិ *នឿយណាយក្នុងអណ្តាតផង នឿយណាយក្នុងរសទាំងឡាយផង នឿយណាយក្នុងវិញ្ញាណអាស្រ័យនឹងអណ្តាតផង នឿយណាយក្នុងសម្ផស្ស*

អាស្រ័យនឹងអណ្តាតផង

យម្បិទំ ជិវ្ហាសម្ផស្សប្បច្ចយា ទ្វប្បដ្ឋតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តស្មឹបិ និព្វិន្ទតិ *សេចក្តីដឹងច្បាស់នូវអារម្មណ៍ គឺវេទនាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី កើតឡើងព្រោះជិវ្ហាសម្ផស្សជាបច្ច័យឯណា ក៏នឿយណាយក្នុងសេចក្តីដឹងច្បាស់នូវអារម្មណ៍នោះ។*

កាយស្មឹបិ និព្វិន្ទតិ ផោដ្ឋព្វេសុបិ និព្វិន្ទតិ កាយវិញ្ញាណេបិ និព្វិន្ទតិ កាយសម្ផស្សេបិ និព្វិន្ទតិ *នឿយណាយក្នុងកាយផង នឿយណាយក្នុងផោដ្ឋព្វៈទាំងឡាយផង នឿយណាយក្នុងវិញ្ញាណអាស្រ័យនឹងកាយផង នឿយណាយក្នុងសម្ផស្សអាស្រ័យនឹងកាយផង*

យម្បិទំ កាយសម្ផស្សប្បច្ចយា ទ្វប្បដ្ឋតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តស្មឹបិ និព្វិន្ទតិ *សេចក្តីដឹងច្បាស់នូវអារម្មណ៍ គឺវេទនាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី កើតឡើងព្រោះកាយសម្ផស្សជាបច្ច័យឯណា ក៏នឿយណាយក្នុងសេចក្តីដឹងច្បាស់នូវអារម្មណ៍នោះ។*

មនស្មឹបិ និព្វិន្ទតិ ធម្មេសុបិ និព្វន្ទតិ មនោវិញ្ញាណេបិ និព្វិន្ទតិ មនោ-សម្ផស្សេបិ និព្វន្ទតិ *នឿយណាយក្នុងចិត្តផង នឿយណាយក្នុងធម៌ទាំងឡាយផង នឿយណាយក្នុងវិញ្ញាណអាស្រ័យនឹងចិត្តផង នឿយណាយក្នុងសម្ផស្សអាស្រ័យនឹងចិត្តផង*

យម្បិទំ មនោសម្ផស្សប្បច្ចយា ទ្វប្បដ្ឋតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តស្មឹបិ និព្វិន្ទតិ *សេចក្តីដឹងច្បាស់នូវអារម្មណ៍ គឺវេទនាជាសុខក្តី*

ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី កើតឡើងព្រោះមនោសម្ផស្សជាបច្ច័យឯណា ក៏នឿយណាយក្នុងសេចក្តីដឹងច្បាស់នូវអារម្មណ៍នោះ។

និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ *កាលបើនឿយណាយ (យ៉ាងនេះហើយ) ក៏ប្រាសចាកតម្រេក ចិត្តក៏ផុតស្រឡះ (ចាកអាសវៈ) ព្រោះកិរិយាប្រាសចាកតម្រេក*

វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ *កាលដែលចិត្តផុតស្រឡះ (ចាកអាសវៈ) ហើយ ញាណ (របស់អរិយសាវ័កនោះ) ក៏កើតឡើងប្រាកដថា ចិត្ត (របស់អញ) ផុតស្រឡះ (ចាកអាសវៈ) ហើយ*

ខីណា ជាតិ ខុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ *(អរិយសាវ័កនោះ) ក៏ដឹងច្បាស់ដូច្នេះថា ជាតិ (របស់អញ) អស់ហើយ មគ្គព្រហ្មចរិយធម៌អញបាននៅរួចហើយ កិច្ចដែលគួរធ្វើ អញក៏បានធ្វើរួចហើយ កិច្ចឯទៀតក្រៅពីនេះ មិនមាន (ដល់អញ) ឡើយ។*

ឥទមវោច ភគវា *ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់បានត្រាស់សម្តែងនូវព្រះសូត្រនេះចប់ហើយ*

អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុំ *ភិក្ខុទាំងឡាយនោះ ក៏មានចិត្តត្រេកអរវីកវាយចំពោះភាសិតនៃព្រះដ៏មានព្រះភាគជាម្ចាស់។*

ឥមស្មិញ្ច បន វេយ្យាករណស្មឹ ភញ្ញមានេ ឥសស្ស ភិក្ខុសហស្សស្ស អនុបាទាយ អាសវេហិ ចិត្តានិ វិមុច្ចឹសូតិ *ក៏កាលដែលព្រះដ៏មានព្រះភាគជាម្ចាស់ កំពុងត្រាស់សម្តែងនូវវេយ្យាករណ៍នេះ ចិត្តរបស់ភិក្ខុទាំង ១,០០០ រូប*

នោះ បានរួចស្រឡះហើយចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ (ថាអញ ថាយើងទៀតឡើយ) ។

អាទិត្តបរិយាយសុត្តំ និដ្ឋិតំ

អាទិត្តបរិយាយសូត្រ ចប់

គិរិមានន្ទសូត្រ

(បិដកលេខ ៥០ ទំព័រ ២៣៤)

ឯវមេ សុតំ *សូត្រនេះ (ឈ្មោះគិរិមានន្ទសូត្រ) គឺខ្ញុំ (ឈ្មោះអានន្ទ) បានស្តាប់មកហើយយ៉ាងនេះថា*

ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ *សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី*

តេន ខោ បន សមយេន អាយស្មា គិរិមានន្ទោ អាពាធិកោ ហោតិ ទុក្ខិតោ ពាឡ្ហគិលានោ *ក៏ក្នុងសម័យនោះឯង ព្រះគិរិមានន្ទដ៏មានអាយុ លោកមានអាពាធ ប្រកបដោយទុក្ខវេទនា ជាជំងឺធ្ងន់*

អថ ខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ *គ្រានោះឯង ព្រះអានន្ទត្ថេរដ៏មានអាយុ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ ត្រង់ទីដែលព្រះអង្គគង់ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។*

ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច *ព្រះអានន្ទត្ថេរដ៏មានអាយុ កាលអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលនូវពាក្យនេះនឹងព្រះដ៏មានព្រះភាគថា*

អាយស្មា ភន្តេ គិរិមានន្ទោ អាពាធិកោ[1] ទុក្ខិតោ ពាឡ្ហគិលានោ *បពិត្រព្រះអង្គដ៏ចម្រើន គិរិមានន្ទដ៏មានអាយុ មានអាពាធប្រកបដោយទុក្ខវេទនា ជាជំងឺធ្ងន់*

សាធុ ភន្តេ ភគវា យេនាយស្មា គិរិមានន្ទោ តេនុបសង្កមតុ អនុកម្បំ ឧបាទាយាតិ *បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ទ្រង់ព្រះមេត្តាអនុគ្រោះ (ចំពោះគិរិមានន្ទ) សូមស្តេចយាងចូលទៅ ត្រង់កន្លែងដែលគិរិមានន្ទដ៏មានអាយុអាស្រ័យនៅ។*

(ព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់តបនថា)

សចេ ខោ ត្វំ អានន្ទ គិរិមានន្ទស្ស ភិក្ខុនោ ឧបង្កមិត្វា ទស សញ្ញា ភាសេយ្យាសិ *ម្នាលអានន្ទ ប្រសិនបើអ្នកចូលទៅកាន់សម្នាក់នៃគិរិមានន្ទភិក្ខុហើយ សម្តែងប្រាប់នូវសញ្ញាទាំង ១០ ប្រការ*

ឋានំ ខោ បនេតំ វិជ្ជតិ យំ គិរិមានន្ទស្ស ភិក្ខុនោ ទស សញ្ញា សុត្វា សោ អាពាធោ ឋានសោ បដិប្បស្សម្ភេយ្យ *ដំណើរនេះ ជាហេតុនឹងឱ្យអាពាធរបស់គិរិមានន្ទភិក្ខុនោះបានរំងាប់សះស្បើយទៅដោយមួយរំពេច ព្រោះ*

1- ក្នុងច្បាប់ឆដ្ឋសង្គាយនា មានបាលី **ហោតិ** ត្រង់ចន្លោះនេះផង។

គិរិមានន្ទភិក្ខុបានស្តាប់នូវសញ្ញាទាំង ១០ ប្រការ

កតមា ទស *សញ្ញា ១០ ប្រការនោះ ដូចម្តេចខ្លះ?*

អនិច្ចសញ្ញា អនត្តសញ្ញា អសុភសញ្ញា អាទីនវសញ្ញា បហានសញ្ញា វិរាគសញ្ញា និរោធសញ្ញា សព្វលោកេ អនភិរតសញ្ញា សព្វសង្ខារេសុ អនិច្ច-សញ្ញា អានាបានសតិ *(សញ្ញា ១០ ប្រការនោះ) គឺ អនិច្ចសញ្ញា ១ អនត្តសញ្ញា ១ អសុភសញ្ញា ១ អាទីនវសញ្ញា ១ បហានសញ្ញា ១ វិរាគសញ្ញា ១ និរោធសញ្ញា ១ សព្វលោកេ អនភិរតសញ្ញា ១ សព្វសង្ខារេសុ អនិច្ចសញ្ញា១ អានាបាណស្សតិ១។*

កតមា ចានន្ទ អនិច្ចសញ្ញា *ម្នាលអានន្ទ អនិច្ចសញ្ញា (នោះ) ដូចម្តេច?*

ឥធានន្ទ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា ឥតិបដិសញ្ចិក្ខតិ *ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះដ៏ស្ងាត់ក្តី ពិចារណាឃើញដូច្នេះថា*

រូបំ អនិច្ចំ *រូបមិនទៀង*

វេទនា អនិច្ចា *វេទនាមិនទៀង*

សញ្ញា អនិច្ចា *សញ្ញាមិនទៀង*

សង្ខារ អនិច្ចា *សង្ខារទាំងឡាយមិនទៀង*

វិញ្ញាណំ អនិច្ចន្តិ *វិញ្ញាណមិនទៀង*

ឥតិ ឥមេសុ បញ្ចសុ ខន្ធេសុ អនិច្ចានុបស្សីវិហរតិ *ភិក្ខុពិចារ-ណាឃើញរឿយៗ ថាមិនទៀង ក្នុងឧបាទានក្ខន្ធទាំងឡាយ ៥ នេះ ដោយប្រការ*

ដូច្នេះ

អយំ ភុច្ចតានន្ទ អនិច្ចសញ្ញា ម្នាលអានន្ទ នេះហើយដែលតថាគតហៅថា អនិច្ចសញ្ញា ។

កតមា ចានន្ទ អនត្តសញ្ញា ម្នាលអានន្ទ អនត្តសញ្ញា (នោះ) ដូចម្តេច ?

ឥធានន្ទ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា ឥតិ បដិសញ្ចិក្ខតិ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះនៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះដ៏ស្ងាត់ក្តី ពិចារណាឃើញដូច្នេះថា

ចក្ខុំ អនត្តា ភ្នែក មិនមែនជារបស់ខ្លួនទេ

រូបា អនត្តា រូបទាំងឡាយ មិនមែនជារបស់ខ្លួនទេ

សោតំ អនត្តា ត្រចៀក មិនមែនជារបស់ខ្លួនទេ

សទ្ទា អនត្តា សំឡេងទាំងឡាយ មិនមែនជារបស់ខ្លួនទេ

ឃានំ អនត្តា ច្រមុះ មិនមែនជារបស់ខ្លួនទេ

គន្ធា អនត្តា ក្លិនទាំងឡាយ មិនមែនជារបស់ខ្លួនទេ

ជិវ្ហា អនត្តា អណ្តាត មិនមែនជារបស់ខ្លួនទេ

រសា អនត្តា រសទាំងឡាយ មិនមែនជារបស់ខ្លួនទេ

កាយោ អនត្តា កាយ មិនមែនជារបស់ខ្លួនទេ

ផោដ្ឋព្វា អនត្តា សម្ផស្សទាំងឡាយ មិនមែនជារបស់ខ្លួនទេ

មនោ អនត្តា ចិត្ត មិនមែនជារបស់ខ្លួនទេ

ធម្មា អនត្តាតិ *ធម៌ទាំងឡាយ ក៏មិនមែនជារបស់ខ្លួនទេ។*

ឥតិ ឥមេសុ ឆសុ អជ្ឈត្តិកពាហិរេសុ អាយតនេសុ អនត្តានុបស្សី វិហរតិ *កិក្ខុពិចារណាឃើញរឿយៗថា មិនមែនជារបស់ខ្លួន ក្នុងអាយតនៈខាងក្នុង ៦ និងអាយតនៈខាងក្រៅ ៦ នេះ ដោយប្រការដូច្នេះ*

អយំ ខុច្ចតានន្ទ អនត្តសញ្ញា *ម្នាលអានន្ទ នេះហើយដែលតថាគតហៅថា អនត្តសញ្ញា។*

កតមា ចានន្ទ អសុភសញ្ញា *ម្នាលអានន្ទ អសុភសញ្ញា (នោះ) ដូចម្តេច?*

ឥធានន្ទ ភិក្ខុ ឥមមេវ កាយំ ឧទ្ធំ បាទតលា អធោ កេសមត្ថកា តចបរិយន្តំ បូរន្តានប្បការស្ស អសុចិនោ បច្ចវេក្ខតិ *ម្នាលអានន្ទ កិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយនេះឯង ខាងលើអំពីផ្ទៃនៃបាទជើងឡើងទៅ ខាងក្រោមអំពីចុងនៃសក់ចុះមក ពាសជុំវិញដោយស្បែក ពេញដោយគ្រឿងមិនស្អាត មានប្រការផ្សេងៗដូច្នេះថា*

អត្ថិ ឥមស្មឹ កាយេ *មានក្នុងរូបកាយនេះ*

កេសា *សក់ទាំងឡាយ* **លោមា** *រោមទាំងឡាយ* **នខា** *ក្រចកទាំងឡាយ* **ទន្តា** *ធ្មេញទាំងឡាយ* **តចោ** *ស្បែក* **មំសំ** *សាច់* **ន្ហារូ** *សរសៃទាំងឡាយ* **អដ្ឋី** *ឆ្អឹងទាំងឡាយ* **អដ្ឋិមិញ្ជា** *ខួរក្នុងឆ្អឹង* **វក្កំ** *ទាច[1]* **ហទយំ** *បេះដូង* **យកនំ** *ថ្លើម* **កិលោមកំ** *វាវ* **បិហកំ** *ក្រពះ* **បប្ផាសំ** *សួត* **អន្តំ** *ពោះវៀនធំ* **អន្តគុណំ** *ពោះ-*

១-ប្រែថា តម្រងបស្សាវៈ សមជាង។

វៀនតូច **ខ្ចរិយំ** *អាហារថ្មី* **ករីសំ** *អាហារចាស់* **បិត្តំ** *ប្រមាត់* **សេម្ហំ** *ស្លេស្ម* **បុព្ពោ** *ខ្ទុះ* **លោហិតំ** *ឈាម* **សេទោ** *ញើស* **មេទោ** *ខ្លាញ់ខាប់* **អស្សុ** *ទឹកភ្នែក* **វសា** *ខ្លាញ់ពពរ* **ខេឡោ** *ទឹកមាត់* **សិង្ឃាណិកា** *ទឹកសម្បោរ* **លសិកា** *ទឹករំអិល* **មុត្តន្តិ** *ទឹកមូត្រ ។*

ឥតិ ឥមស្មឹ កាយេ អសុភានុបស្សី វិហរតិ *ភិក្ខុពិចារណាឃើញរឿយៗ ថាជាគ្រឿងមិនស្អាតក្នុងរូបកាយនេះ ដោយប្រការដូច្នេះ*

អយំ ភុច្ចតានន្ទ អសុភសញ្ញា *ម្នាលអានន្ទ នេះហើយដែលតថាគត ហៅថា អសុភសញ្ញា ។*

កតមា ចានន្ទ អាទីនវសញ្ញា *ម្នាលអានន្ទ អាទីនវសញ្ញា (នោះ) ដូចម្តេច ?*

ឥធានន្ទ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា ឥតិ បដិសញ្ចិក្ខតិ *ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះដ៏ស្ងាត់ក្តី ពិចារណាឃើញដូច្នេះថា*

ពហុទុក្ខោ ខោ អយំ កាយោ ពហុអាទីនវោតិ *រូបកាយនេះ មានទុក្ខច្រើន មានទោសច្រើនមែនពិត ។*

ឥតិ ឥមស្មឹ កាយេ ទិវិធា អាពាធា ខ្ចប្បដ្ឋន្តិ អាពាធ *គឺជំងឺតម្កាត់ទាំងឡាយផ្សេងៗ តែងតែកើតឡើងក្នុងកាយនេះដូច្នេះ ។*

សេយ្យថីទំ *អាពាធនោះ ដូចម្តេច ?*

ចក្ខុរោគោ *គឺរោគក្នុងភ្នែក* **សោតរោគោ** *រោគក្នុងត្រចៀក* **ឃានរោគោ**

រោគក្នុងប្រមុះ **ឯឡារោគោ** *រោគក្នុងអណ្តាត* **ភាយរោគោ** *រោគក្នុងកាយ* **សីស-រោគោ** *រោគក្នុងក្បាល* **កណ្ណរោគោ** *រោគខាងក្រៅត្រចៀក* **មុខរោគោ** *រោគក្នុងមាត់* **ទន្តរោគោ** *រោគត្រង់គល់ធ្មេញ* **ភាសោ** *រោគក្អក* **សាសោ** *រោគហឺត* **ឋិនា-សោ** *រោគខាងក្រៅប្រមុះ* **ឌាហោ** *រោគក្តៅក្រហាយ* **ជរោ** *រោគស្តាំងស្គម* **កុច្ឆិ-រោគោ** *រោគក្នុងផ្ទៃ* **មុច្ឆា** *រោគខ្យល់ចាប់វិលមុខ* **បក្ខន្ទិកា** *រោគជ្រាក់ឈាម* **សូលា** *រោគចុកសៀត* **ឱសូចិកា** *រោគចុះរាគ* **កុដ្ឋី** *រោគឃ្លង់* **គណ្ឌោ** *រោគពក* **កិលា-សោ** *រោគស្រែង* **សោសោ** *រោគរីងរៃ* **អបមារោ** *រោគធ្លុតជ្រួក* **ទទ្ទុ** *រោគដំណ្ងាចពិស* **កណ្ឌូ** *រោគរមាស់* **កច្ឆូ** *រោគកមក្រិន* **រខសា** [1] *រោគកើតត្រង់ទីដែលខ្វារដោយក្រចក* **វិតច្ឆិកា** *រោគកមរលាយ* **លោហិតំ** *រោគឈាម* **បិត្តំ** *រោគប្រមាត់* **មធុមេហោ** *រោគទឹកនោមផ្អែម* **អំសា** *រោគឫសដូងបាតជុំវិញទ្វារធំ* **បិឡកា** *រោគរលកកែវ* **ភគណ្ឌលា** *រោគឫសដូងបាតដុះខាងក្នុង*[2] **បិត្តសមុដ្ឋានា អាពាធា** *អាពាធកើតអំពីប្រមាត់* **សេម្ហសមុដ្ឋានា អាពាធា** *អាពាធកើតអំពីស្លេស្ម* **វាត-សមុដ្ឋានា អាពាធា** *អាពាធកើតអំពីខ្យល់* **សន្និបាតិកា អាពាធា** *អាពាធកើតអំពីសន្និបាតគឺកម្រើកប្រមាត់ស្លេស្ម និងខ្យល់ប្រជុំគ្នា* **ឧតុបរិណាមជា អាពាធា** *អាពាធកើតអំពីរដូវប្រែប្រួល* **វិសមបរិហារជា អាពាធា** *អាពាធកើតអំពីការផ្ងាស់ប្តូរ*

១-**រខសា** ក្នុងភាណវារៈចាស់ប្រែថា "**រោគកញ្ជ្រិល**" តែច្បាប់ថ្មីនេះយើងប្រែថា "**រោគកើតត្រង់ទីដែលខ្វារដោយក្រចក** ដូច្នេះវិញ ព្រោះក្នុងច្បាប់ឆដ្ឋសង្គាយនា មានបាលីថា **ឧខសា** ហើយក្នុងអដ្ឋកថាពន្យល់ថា **ឧខសាតិ ឧខេហិ ខិលិខិត-ដ្ឋានេ រោគោ** បទថា **ឧខសា** បានដល់រោគដែលកើតត្រង់ទីដែលខ្វារដោយក្រចក, សូម្បីក្នុងបិដកលេខ ៥០ ទំព័រ ២៣៨ ក៏ប្រែដូច្នេះដែរ ។ ២- អដ្ឋកថាពន្យល់ថា ឫសដូងបាតដែលដុះខាងក្នុង ត្រង់ចន្លោះទ្វារធំ និងទ្វារតូច ។

ឥរិយាបថមិនស្មើគ្នា **ឱបក្កមិកា អាពាធា** *អាពាធកើតអំពីសេចក្តីព្យាយាម (របស់អ្នកឯទៀត មានចាប់ចងវាយកាប់ជាដើម)* **កម្មវិបាកជា អាពាធា** *អាពាធកើតអំពីវិបាករបស់កម្ម* **សីតំ** *អាពាធកើតអំពីត្រជាក់* **ឧណ្ហំ** *អាពាធកើតអំពីក្តៅ* **ជិឃច្ឆា** *អាពាធកើតអំពីសេចក្តីឃ្លាន* **បិបាសា** *អាពាធកើតអំពីសេចក្តីស្រេក* **ឧច្ចារោ** *អាពាធកើតអំពីឧច្ចារៈ* **បស្សាវោតិ** *អាពាធកើតអំពីបស្សាវៈ។*

ឥតិ ឥមស្មឹ កាយេ អាទីនវានុបស្សី វិហរតិ *ភិក្ខុពិចារណាឃើញរឿយៗ ថាជាទោសក្នុងរូបកាយនេះ ដោយប្រការដូច្នេះ*

អយំ ភុច្ចតានន្ទ អាទីនវសញ្ញា *ម្នាលអានន្ទ នេះហើយដែលតថាគតហៅថា អាទីនវសញ្ញា។*

កតមា ចានន្ទ បហានសញ្ញា *ម្នាលអានន្ទ បហាន (នោះ) ដូចម្តេច?*

ឥធានន្ទ ភិក្ខុ ឧប្បន្នំ កាមវិតក្កំ នាធិវាសេតិ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវំ គមេតិ *ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ មិនតាំងចិត្តទទួល គឺលះបង់ បន្ទោបង់ ធ្វើឱ្យវិនាស ធ្វើមិនឱ្យកើតតទៅទៀត នូវកាមវិតក្កៈ គឺសេចក្តីត្រិះរិះក្នុងកាម ដែលកើតឡើងហើយ*

ឧប្បន្នំ ព្យាបាទវិតក្កំ នាធិវាសេតិ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវំ គមេតិ *មិនតាំងចិត្តទទួល គឺលះបង់ បន្ទោបង់ ធ្វើឱ្យវិនាស ធ្វើមិនឱ្យកើតតទៅទៀត នូវព្យាបាទវិតក្កៈគឺសេចក្តីត្រិះរិះក្នុងកិរិយាញុំាងសត្វដទៃឱ្យវិនាស ដែលកើតឡើងហើយ*

ឧប្បន្នំ អហិសាវិតក្កំ នាធិវាសេតិ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវំ គមេតិ *មិនតាំងចិត្តទទួល គឺលះបង់ បន្ទោបង់ ធ្វើឱ្យវិនាស ធ្វើមិនឱ្យកើតតទៅទៀត នូវវិហឹសាវិតក្កៈ គឺសេចក្តីត្រិះរិះក្នុងការបៀតបៀនសត្វ ដែលកើតឡើងហើយ*

ឧប្បន្នុប្បន្នេ បាបកេ អកុសលេ ធម្មេ នាធិវាសេតិ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវំ គមេតិ *មិនតាំងចិត្តទទួល គឺលះបង់ បន្ទោបង់ ធ្វើឱ្យវិនាស ធ្វើមិនឱ្យកើតតទៅទៀតនូវធម៌ដែលជាបាបអកុសល ដែលកើតឡើងហើយរឿយៗ*

អយំ ភុច្ចតានន្ទ បហានសញ្ញា *ម្នាលអានន្ទ នេះហើយដែលតថាគតហៅថា បហានសញ្ញា ។*

កតមា ចានន្ទ វិរាគសញ្ញា *ម្នាលអានន្ទ វិរាគសញ្ញា (នោះ) ដូចម្តេច?*

ឥធានន្ទ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា ឥតិ បដិសញ្ចិក្ខតិ *ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះដ៏ស្ងាត់ក្តី ពិចារណាឃើញដូច្នេះថា*

ឯតំ សន្តំ ឯតំ បណីតំ យទិទំ សព្វសង្ខារសមថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និព្វានន្តិ *វិរាគធម៌ គឺព្រះនិព្វានឯណា ដែលរំងាប់បង់នូវសង្ខារទាំងពួង លះចោលនូវកិលេសទាំងពួង អស់តណ្ហាហើយ វិរាគធម៌ គឺព្រះនិព្វានន៎ះ ជាគុណជាតសូប់រំងាប់ វិរាគធម៌ គឺព្រះនិព្វាននុ៎ះជាគុណជាតដ៏ឧត្តម*

អយំ ភុច្ចតានន្ទ វិរាគសញ្ញា *ម្នាលអានន្ទ នេះហើយដែលតថាគតហៅថា វិរាគសញ្ញា ។*

កតមា ចានន្ទ និរោធសញ្ញា *ម្នាលអានន្ទ និរោធសញ្ញា (នោះ) ដូចម្តេច?*

ឥធានន្ទ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា ឥតិ បដិសញ្ចិក្ខតិ *ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះដ៏ស្ងាត់ក្តី ពិចារណាឃើញដូច្នេះថា*

ឯតំ សន្តំ ឯតំ បណីតំ យទិទំ សព្ពសង្ខារសមថោ សព្ពូបធិប្បដិនិស្សគ្គោ តណ្ហក្ខយោ និរោធោ និព្ពានន្តិ *និរោធធម៌ គឺព្រះនិព្វានឯណា ដែលរំងាប់បង់នូវសង្ខារទាំងពួង លះចោលនូវកិលេសទាំងពួង អស់តណ្ហាហើយ និរោធធម៌ គឺព្រះនិព្វាននុ៎ះ ជាគុណជាតស្ងប់រំងាប់ និរោធធម៌ គឺព្រះនិព្វាននុ៎ះ ជាគុណជាតដ៏ឧត្តម*

អយំ ខុច្ចតានន្ទ និរោធសញ្ញា *ម្នាលអានន្ទ នេះហើយ ដែលតថាគតហៅថា និរោធសញ្ញា។*

កតមា ចានន្ទ សព្ពលោកេ អនភិរតសញ្ញា *ម្នាលអានន្ទ សព្វលោកេ អនភិរតសញ្ញា (នោះ) ដូចម្តេច?*

ឥធានន្ទ ភិក្ខុ យេ លោកេ ខ្វជ្ជបុជ្ជធម្មា[1] ចេតសោ អធិដ្ឋានាភិនិវេសានុសយា តេ បជហន្តោ វិរមតិ[2] ន ខ្វជ្ជនីយន្តោ *ម្នាលអានន្ទ ឧបាយគឺតណ្ហា និងទិដ្ឋិឯណា ឧបាទាន គឺសេចក្តីប្រកាន់មាំឯណា អភិនិវេស: គឺសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ជាទីអាស្រ័យនៅនៃចិត្តឯណា អនុស័យ គឺកិលេសដែលដេកនៅរឿយៗ ក្នុងសត្តសន្តានឯណាក្នុងលោក ភិក្ខុក្នុងសាសនានេះកាលបើលះបង់*

១-បាលីឆដ្ឋសង្គាយនាថា **ខ្វជ្ជធម្មា**។ ២-បាលីឆដ្ឋសង្គាយនាថា **វិហរតិ**។

នូវបាបទាំងនោះ (ដោយតទង្គទិប្បហាន) មិនបានប្រកាន់មាំដោយចិត្តក៏រមែងវៀរ (ចាកបាបធម៌ទាំងនោះ) បាន

អយំ ភុច្ចតានន្ទ សព្ពលោកេ អនភិរតសញ្ញា *ម្នាលអានន្ទនេះ ហើយដែលតថាគត ហៅថា សព្វលោកេ អនភិរតសញ្ញា ។*

កតមា ចានន្ទ សព្ពសង្ខារេសុ អនិច្ចសញ្ញា *ម្នាលអានន្ទ សព្វសង្ខារេសុ អនិច្ចសញ្ញា (នោះ) ដូចម្តេច ?*

ឥធានន្ទ ភិក្ខុ សព្ពសង្ខារេហិ អដ្ដិយតិ ហរាយតិ ជិគុច្ឆតិ *ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ នឿយណាយ ធុញទ្រាន់ ស្អប់ខ្ពើមសង្ខារទាំងពួង*

អយំ ភុច្ចតានន្ទ សព្ពសង្ខារេសុ អនិច្ចសញ្ញា *ម្នាលអានន្ទ នេះហើយដែលតថាគត ហៅថា សព្វសង្ខារេសុ អនិច្ចសញ្ញា[1] ។*

កតមា ចានន្ទ អានាបានស្សតិ *ម្នាលអានន្ទ អានាបានស្សតិ (នោះ) ដូចម្តេច ?*

ឥធានន្ទ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំកាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា *ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះដ៏ស្ងាត់ក្តី អង្គុយផ្គត់ភ្នែន តាំងកាយឱ្យត្រង់ តម្កល់ស្មារតី ឱ្យឆ្ពោះត្រង់ទៅរកព្រះកម្មដ្ឋាន*

๑-ប្រែថា សេចក្តីសម្គាល់ក្នុងកិរិយាមិនប្រាថ្នា ឬមិនលុះលង់ទៅក្នុងសង្ខារទាំងពួង ។

សោ សតោវ អស្សសតិ *កិក្ខុនោះ មានស្មារតីចាំជាក់ ដកដង្ហើមចេញ*[1]

សតោ បស្សសតិ *មានស្មារតីចាំជាក់ ដកដង្ហើមចូល*

ទីឃំ វា អស្សសន្តោ ទីឃំ អស្សសាមីតិ បជានាតិ *កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង*

ទីឃំ វា បស្សសន្តោ ទីឃំ បស្សសាមីតិ បជានាតិ *កាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង*

រស្សំ វា អស្សសន្តោ រស្សំ អស្សសាមីតិ បជានាតិ *កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញខ្លី*

រស្សំ វា បស្សសន្តោ រស្សំ បស្សសាមីតិ បជានាតិ *កាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលខ្លី*

សព្ពកាយប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ *កិក្ខុសិក្សា*[2]*ដូច្នេះថា អាត្មាអញនឹងជាអ្នកដឹងច្បាស់នូវកាយ*[3] *គឺដង្ហើមចេញទាំងអស់ឱ្យប្រាកដ ទើបដកដង្ហើមចេញ*

សព្ពកាយប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ *កិក្ខុសិក្សាដូច្នេះថា អាត្មាអញនឹងជាអ្នកដឹងច្បាស់នូវកាយ គឺដង្ហើមចូលទាំងអស់ឱ្យប្រាកដ ទើបដកដង្ហើមចូល*

១-តាមន័យព្រះអភិធម្ម និងការបដិបត្តិ គួរប្រែសព្ទ **អស្ស** នេះថា ដង្ហើមចូល, **បស្ស** ថា ដង្ហើមចេញ ។ ២-អដ្ឋកថាថា ព្យាយាម ។ ៣- អដ្ឋកថាពន្យល់ថា ធ្វើខាងដើម ខាងកណ្តាល និងទីបំផុតនៃកាយ គឺដង្ហើមចេញទាំងអស់ឱ្យប្រាកដ ។

បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ *កិក្ខុសិក្សាដូច្នេះថា អាត្មាអញនឹងជាអ្នករំងាប់នូវកាយសង្ខារ[1] គឺអស្សាសបស្សាស: ទើបដកដង្ហើមចេញ*

បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ *កិក្ខុសិក្សាដូច្នេះថា អាត្មាអញនឹងជាអ្នករំងាប់នូវកាយសង្ខារ គឺអស្សាសបស្សាស: ទើបដកដង្ហើមចូល*

បីតិប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ *កិក្ខុសិក្សាដូច្នេះថា អាត្មាអញនឹងជាអ្នកដឹងច្បាស់នូវបីតិ ទើបដកដង្ហើមចេញ*

បីតិប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ *កិក្ខុសិក្សាដូច្នេះថា អាត្មាអញនឹងជាអ្នកដឹងច្បាស់នូវបីតិ ទើបដកដង្ហើមចូល*

សុខប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ *កិក្ខុសិក្សាដូច្នេះថា អាត្មាអញនឹងជាអ្នកដឹងច្បាស់នូវសេចក្តីសុខ ទើបដកដង្ហើមចេញ*

សុខប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ *កិក្ខុសិក្សាដូច្នេះថា អាត្មាអញនឹងជាអ្នកដឹងច្បាស់នូវសេចក្តីសុខ ទើបដកដង្ហើមចូល*

ចិត្តសង្ខារប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ *កិក្ខុសិក្សាដូច្នេះថា អាត្មាអញនឹងជាអ្នកដឹងច្បាស់នូវចិត្តសង្ខារ[2] ទើបដកដង្ហើមចេញ*

ចិត្តសង្ខារប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ *កិក្ខុសិក្សាដូច្នេះថា អាត្មាអញនឹងជាអ្នកដឹងច្បាស់នូវចិត្តសង្ខារ ទើបដកដង្ហើមចូល*

๑-អដ្ឋកថាពន្យល់ថា កាយសង្ខារដ៏គ្រោតគ្រាត ។ ๒-ចិត្តសង្ខារ គឺវេទនាខន្ធ និងសញ្ញាខន្ធ ។

បស្សម្ភយំ ចិត្តសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ *កិក្ខុសិក្សាដូច្នេះថា អាត្មាអញនឹងជាអ្នករំងាប់នូវចិត្តសង្ខារ ទើបដកដង្ហើមចេញ*

បស្សម្ភយំ ចិត្តសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ *កិក្ខុសិក្សាដូច្នេះថា អាត្មាអញនឹងជាអ្នករំងាប់នូវចិត្តសង្ខារ ទើបដកដង្ហើមចូល*

ចិត្តប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ *កិក្ខុសិក្សាដូច្នេះថា អាត្មាអញនឹងជាអ្នកដឹងច្បាស់នូវចិត្ត ទើបដកដង្ហើមចេញ*

ចិត្តប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ *កិក្ខុសិក្សាដូច្នេះថា អាត្មាអញនឹងជាអ្នកដឹងច្បាស់នូវចិត្ត ទើបដកដង្ហើមចូល*

អភិប្បមោទយំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ *កិក្ខុសិក្សាដូច្នេះថា អាត្មាអញនឹងធ្វើចិត្តឱ្យរីករាយ ទើបដកដង្ហើមចេញ*

អភិប្បមោទយំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ *កិក្ខុសិក្សាដូច្នេះថា អាត្មាអញនឹងធ្វើចិត្តឱ្យរីករាយ ទើបដកដង្ហើមចូល*

សមាទហំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ *កិក្ខុសិក្សាដូច្នេះថា អាត្មាអញនឹងតម្កល់ចិត្តឱ្យស្មើក្នុងអារម្មណ៍ ទើបដកដង្ហើមចេញ*

សមាទហំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ *កិក្ខុសិក្សាដូច្នេះថា អាត្មាអញនឹងតម្កល់ចិត្តឱ្យស្មើក្នុងអារម្មណ៍ ទើបដកដង្ហើមចូល*

វិមោចយំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ *កិក្ខុសិក្សាដូច្នេះថា អាត្មាអញ*

នឹងដោះចិត្តឱ្យរួចចាកនីវរណធម៌ជាដើម[1] ទើបដកដង្ហើមចេញ

វិមោចយំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ *កិក្ខុសិក្សាដូច្នេះថា អាត្មាអញនឹងដោះចិត្តឱ្យរួចចាកនីវរណធម៌ជាដើម ទើបដកដង្ហើមចូល*

អនិច្ចានុបស្សី អស្សសិស្សាមីតិ សិក្ខតិ *កិក្ខុសិក្សាដូច្នេះថា អាត្មាអញនឹងជាអ្នកឃើញរឿយៗនូវបញ្ចក្ខន្ធថាមិនទៀង ទើបដកដង្ហើមចេញ*

អនិច្ចានុបស្សី បស្សសិស្សាមីតិ សិក្ខតិ *កិក្ខុសិក្សាដូច្នេះថា អាត្មាអញនឹងជាអ្នកឃើញរឿយៗ នូវបញ្ចក្ខន្ធថាមិនទៀង ទើបដកដង្ហើមចូល*

វិរាគានុបស្សី អស្សសិស្សាមីតិ សិក្ខតិ *កិក្ខុសិក្សាដូច្នេះថា អាត្មាអញនឹងជាអ្នកឃើញរឿយៗ នូវធម៌ដែលប្រាសចាករាគៈទើបដកដង្ហើមចេញ*

វិរាគានុបស្សី បស្សសិស្សាមីតិ សិក្ខតិ *កិក្ខុសិក្សាដូច្នេះថា អាត្មាអញនឹងជាអ្នកឃើញរឿយៗ នូវធម៌ដែលប្រាសចាករាគៈ ទើបដកដង្ហើមចូល*

និរោធានុបស្សី អស្សសិស្សាមីតិ សិក្ខតិ *កិក្ខុសិក្សាដូច្នេះថា អាត្មាអញនឹងជាអ្នកឃើញរឿយៗ នូវធម៌ដែលរំលត់បង់នូវកងទុក្ខ ទើបដកដង្ហើមចេញ*

និរោធានុបស្សី បស្សសិស្សាមីតិ សិក្ខតិ *កិក្ខុសិក្សាដូច្នេះថា អាត្មាអញនឹងជាអ្នកឃើញរឿយៗ នូវធម៌ដែលរំលត់បង់នូវកងទុក្ខ ទើបដកដង្ហើមចូល*

---

១ -អដ្ឋកថា ពន្យល់ថា ភិក្ខុដោះចិត្តឱ្យរួចចាកនីវរណធម៌ដោយបឋមជ្ឈាន, ឱ្យរួចចាកវិតក្កៈ និងវិចារៈ ដោយទុតិយ-ជ្ឈាន, ឱ្យរួចចាកបីតិដោយតតិយជ្ឈាន, ឱ្យរួចចាកសុខនិងទុក្ខដោយចតុត្ថជ្ឈាន, ឱ្យរួចចាកនិច្ចសញ្ញាដោយអនិច្ចានុបស្សនា, ឱ្យរួចចាកសុខសញ្ញាដោយទុក្ខានុបស្សនា, ឱ្យរួចចាកអត្តសញ្ញាដោយអនត្តានុបស្សនា, ឱ្យរួចចាកនន្ទិដោយនិព្វិទានុបស្សនា, ឱ្យរួចចាករាគៈ ដោយវិរាគានុបស្សនា, ឱ្យរួចចាកសមុទយៈដោយនិរោធានុបស្សនា, ឱ្យរួចចាកអាទានៈដោយបដិនិស្សគ្គា-នុបស្សនា។

បជិនិស្សគ្គានុបស្សី អស្សសិស្សាមីតិ សិក្ខតិ *កិក្ខុសិក្សាដូច្នេះថា អាត្មា*

អញនឹងជាអ្នកឃើញរឿយៗ នូវធម៌ជាគ្រឿងលះចោលនូវកិលេស ទើបដកដង្ហើមចេញ

បជិនិស្សគ្គានុបស្សី បស្សសិស្សាមី តិសិក្ខតិ *កិក្ខុសិក្សាដូច្នេះថា អាត្មា អញនឹងជាអ្នកឃើញរឿយៗ នូវធម៌ជាគ្រឿងលះចោលនូវកិលេស ទើបដកដង្ហើមចូល*

អយំ ខុច្ចតានន្ទ អានាបានស្សតិ *ម្នាលអានន្ទ នេះហើយដែលតថាគតហៅថា អានាបានស្សតិ ។*

សចេ ខោ ត្វំ អានន្ទ គិរិមានន្ទស្ស ភិក្ខុនោ ឆ្ឌបសន្ថម្ភិត្វា ឥមា ទស សញ្ញា តរេយ្យាសិ *ម្នាលអានន្ទ បើអ្នកចូលទៅ(កាន់សម្នាក់) នៃគិរិមានន្ទភិក្ខុហើយ គប្បីសម្តែងនូវសញ្ញាទាំង១ឡាយ ១០ ប្រការនេះ*

ឋានំ ខោ បនេតំ វិជ្ជតិ យំ គិរិមានន្ទស្ស ភិក្ខុនោ ឥមា ទស សញ្ញា សុត្វា សោ អាពាធោ ឋានសោ បដិប្បស្សម្ភេយ្យាតិ *ដំណើរនេះ ជាហេតុនឹងឱ្យអាពាធរបស់គិរិមានន្ទភិក្ខុនោះរំងាប់សះស្បើយទៅដោយមួយរំពេច ព្រោះគិរិមានន្ទភិក្ខុបានស្តាប់នូវសញ្ញាទាំង១ឡាយ ១០ ប្រការនេះ ។*

អថ ខោ អាយស្មា អានន្ទោ ភគវតោ សន្តិកេ ឥមា ទស សញ្ញា ឧគ្គហេត្វា យេនាយស្មា គិរិមានន្ទោ តេនុបសង្កមិ ឆ្ឌបសន្ថម្ភិត្វា អាយស្មតោ គិរិមានន្ទស្ស ឥមា ទស សញ្ញាអភាសិ *លំដាប់នោះ ព្រះអានន្ទត្ថេរដ៏មានអាយុ*

ក៏រៀននូវសញ្ញាទាំង១ឋាយ ១០ ប្រការនេះក្នុងសម្នាក់នៃព្រះដ៏មានព្រះភាគ ហើយចូលទៅត្រង់កន្លែងដែលគិរិមានន្ទលោកគង់នៅ លុះចូលទៅដល់ហើយ ទើបសម្តែងនូវសញ្ញាទាំង១ឋាយ ១០ ប្រការនេះដល់គិរិមានន្ទដ៏មានអាយុ ។

អថ ខោ អាយស្មតោ គិរិមានន្ទស្ស ឥមា ទស សញ្ញា សុត្វា សោ អាពាធោ ឋានសោ បដិប្បស្សម្ភិ *លំដាប់នោះឯង អាពាធរបស់ព្រះគិរិមានន្ទដ៏មានអាយុនោះ ក៏រំងាប់សះស្បើយទៅដោយមួយរំពេច ព្រោះបានស្តាប់នូវសញ្ញាទាំង១ឋាយ ១០ ប្រការនេះ*

វុដ្ឋហិ ចាយស្មា គិរិមានន្ទោ តម្ហា អាពាធា *ឯព្រះគិរិមានន្ទដ៏មានអាយុក៏បានជាសះស្បើយចាកអាពាធនោះ*

តថា បហីនោ ច បនាយស្មតោ គិរិមានន្ទស្ស សោ អាពាធោ អហោសីតិ *ក៏អាពាធនោះ គឺព្រះគិរិមានន្ទដ៏មានអាយុលះបង់បានហើយ ដោយកិរិយាបានស្តាប់នូវសញ្ញាទាំង ១០ ប្រការដែលព្រះអានន្ទត្ថេរសម្តែងហើយដូច្នោះ ដោយប្រការដូច្នេះហោង ។*

គិរិមានន្ទសុត្តំ និដ្ឋិតំ

គិរិមានន្ទសូត្រចប់

(ដកស្រង់ពីសត្តបរិត្ត-ទ្វាទសបរិត្ត របស់ព្រះវិសុទ្ធិវង្ស ហួត-តាត និងបិដកផង)

ចប់ព្រះសូត្រតែប៉ុណ្ណេះ

វិវិធគាថា[1]

(គាថាផ្សេង ៗ)

បកិណ្ណកបរិត្តគាថា

(សម្រាប់សូត្បបន្តខាងចុងនៃព្រះបរិត្តឬព្រះសូត្រ)

ឆទ្ទន្តបរិត្តគាថា

(បិដកលេខ ៦០ ទំព័រ ១៧៦)

វធិសេ្សមេនន្តិ បរាមសន្តោ កាសាវមទ្ទក្ខិ ឆដ្ឋំ ឥសីនំ (ព្រះពោធិសត្វ) ជាស្តេចនៃដំរី កាលចាប់ព្រានព្រៃដោយបំណងថា អញនឹងសម្លាប់វាដូច្នេះ លុះទ្រង់បានឃើញនូវសំពត់កាសាវៈដ៏ជាទង់ជ័យនៃឥសីគឺលោកអ្នកស្វែងរកនូវសីលាទិគុណទាំងឡាយ

ទុក្ខេន ផុដ្ឋស្សុទបាទិ សញ្ញា អរហទ្ធជោ សព្ភិ អវជ្ឈរូបោ សញ្ញាក៏កើតឡើងដល់ព្រះពោធិសត្វ ដែលសេចក្តីទុក្ខពាល់ត្រូវហើយថា ទង់ជ័យរបស់ព្រះអរហន្ត មានសភាព គឺសប្បុរសទាំងឡាយមិនគួរនឹងសម្លាប់

សល្លេន វិទ្ធោ ព្យថិតោបិ សន្តោ កាសាវវត្ថស្មិ មនំ ន ទុស្សយិ ព្រះពោធិសត្វ ដែលព្រួញមុតហើយ គួរនឹងកក្រើកញាប់ញ័រ តែព្រះអង្គស្ងប់រំងាប់បាន មិនធ្វើចិត្តប្រទូស្តទៅរកកាសាវព័ស្ត្រឡើយ

១-ជាគាថាដែលបុរាណនិពន្ធផ្សំនឹងពុទ្ធវចនៈក្នុងព្រះសូត្រផ្សេង ៗ ។

សចេ ឥមំ ឆាគវរេន សច្ចំ មា មំ វទេ ពាលមិគា អគញ្ឆា *បើពាក្យដែលស្តេចដំរីដ៏ប្រសើរពោលហើយនេះ ជាពាក្យពិតមែន សូមពួកម្រឹគកាចក្នុងព្រៃ កុំមកជួបប្រទះនឹងខ្ញុំឡើយ។*

ឥដ្ឋកបរិត្តារម្ភោ

បូរេន្តម្ភោធិសម្ភារេ និព្ឋត្តំ ឥដ្ឋជាតិយំ
យស្ស តេជេន ឆាឥត្តិ មហាសត្តំ ឥិវជ្ជយិ

ភ្លើងព្រៃចៀសវាងហើយ នូវព្រះមហាសត្តដែលកំពុងបំពេញនូវពោធិសម្ភារ ព្រះអង្គកើតក្នុងកំណើតនៃសត្វក្រួច ដោយតេជៈនៃព្រះបរិត្តឯណា

ថេរស្ស សារីបុត្តស្ស លោកនាថេន តាសិតំ
កប្បដ្ឋាយិមហាតេជំ បរិត្តន្តម្ភណាម ហេ

យើងទាំងឡាយ សូមឥឡូវនេះ នូវព្រះបរិត្តនោះ ដែលមានតេជៈច្រើនអាចតាំងនៅអស់កប្ប ដែលព្រះលោកនាថទ្រង់ត្រាស់សម្តែងហើយ ដល់ព្រះសារីបុត្តត្ថេរ។

ឥដ្ឋកបរិត្ត

(បិដកលេខ ៥៨ ទំព័រ ១៦ និងលេខ ៧៧ ទំព័រ ២៩៧)

អត្ថិ លោកេ សីលគុណោ សច្ចំ សោចេយ្យនុទ្ទយា *គុណនៃសីល ពាក្យពិត សេចក្តីស្អាតកាយ និងសេចក្តីករុណា (ទាំងនេះ) សឹងមានក្នុងលោក*

តេន សច្ចេន ការោមិ សច្ចកិរិយមនុត្តរំ ដោយពាក្យសច្ចៈនេះ ខ្ញុំនឹងធ្វើនូវសច្ចកិរិយាដែលឥតមានអ្វីស្មើឡើយ

អាវជ្ជិត្វា ធម្មពលំ សរិត្វា បុព្វកេ ជិនេ
សច្ចពលមវស្សាយ សច្ចកិរិយមកាសហំ

ខ្ញុំពិចារណានូវកម្លាំងនៃធម៌ហើយ រឭកនូវព្រះសម្ពុទ្ធទ្រង់ឈ្នះមារទាំងឡាយក្នុងកាលមុន អាស្រ័យនូវកម្លាំងនៃសច្ចៈហើយ បានធ្វើនូវសច្ចកិរិយា

សន្តិបក្ខា អបត្តនា សន្តិ បាទាអវញ្ឆនា
មាតាបិតា ច និក្ខន្តា ជាតវេទ បដិក្កម

ស្លាបទាំងឡាយរបស់ខ្ញុំមាន តែហើរមិនបាន ជើងទាំងឡាយរបស់ខ្ញុំមានតែដើរមិនបាន មាតានិងបិតារបស់ខ្ញុំ បានចេញទៅហើយ (ព្រោះភ័យនឹងសេចក្តីស្លាប់[1]) ម្នាលភ្លើងចូរអ្នកចៀសចេញទៅ

សហ សច្ចេ កតេ មយ្ហំ មហាបជ្ជលិតោ សិខី
វជ្ជេសិ សោឡស ករីសានិ ទ្វទកំ បត្វា យថា សិខី

នាកាលសច្ចៈដែលខ្ញុំបានធ្វើហើយ អណ្តាតភ្លើងដ៏រុងរឿងធំចៀសចេញទៅហើយអស់ចម្ងាយទី ១៦ ករីសៈ ព្រមជាមួយនឹងពាក្យសច្ចៈរបស់ខ្ញុំ ដូចជាអណ្តាតភ្លើងធ្លាក់ចុះដល់ទឹក

១- ត្រង់បាទនៃគាថា ថា "**មាតា បិតា ច និក្ខន្តា**" នេះ ក្នុងប្រជុំភាណវារៈចាស់ លោកប្រែដាក់ក្នុងវង់ក្រចកថា "មាតានិងបិតារបស់ខ្ញុំចេញទៅរកអាហារហើយ" តែក្នុងអដ្ឋកថា លោកពន្យល់ថា "**មាតា បិតា ច និក្ខន្តាតិ យេ មំ អញ្ញត្ថ នេយ្យុំ, តេបិ មរណភយេន មម មាតាបិតរោ និក្ខន្តា**" បទថា **មាតា បិតា ច និក្ខន្តា** សេចក្តីថា សូម្បីមាតាបិតាដែលនឹងនាំខ្ញុំទៅកាន់ទីដទៃនោះ ក៏ហើរទៅហើយ ព្រោះភ័យអំពីសេចក្តីស្លាប់ (គឺខ្លាចស្លាប់)។ ហេតុនេះ ទើបយើងសម្រេចប្រែជាថ្មីតាមន័យរបស់អដ្ឋកថាវិញ បើយកតាមពាក្យប្រែដើមនុ៎ះ ក្រែងមិនមែនជាពាក្យសច្ចៈ។

សច្ចេន មេ សមោ នត្ថិ ឯសា មេ សច្ចបារមីតិ *អ្វីមួយស្មើដោយសច្ចៈរបស់ខ្ញុំមិនមានឡើយ នេះជាសច្ចបារមីរបស់ខ្ញុំ។*

អាជានាដិយបរិត្តគាថា

(**ទិបសទ្វិស្ស នមត្ថុ ។បេ។ មហន្តំ ទីតសារទំ** *មានពិស្តារនៅទំព័រ ២៦២ ហើយ*)

នមោ មេ សព្វពុទ្ធានំ ទ្វប្បន្នានំ មហេសិនំ *ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំចំពោះព្រះពុទ្ធជាម្ចាស់គ្រប់ព្រះអង្គ ដែលបានត្រាស់រួចមកហើយ ព្រះអង្គស្វែងរកនូវគុណដ៏ធំ (ព្រះសម្ពុទ្ធទាំងនោះ គឺ)*

តណ្ហង្ករោ មហាវីរោ *ព្រះតណ្ហង្ករៈ ព្រះអង្គមានព្យាយាមធំ*

មេធង្ករោ មហាយសោ *ព្រះមេធង្ករៈ ព្រះអង្គមានយសធំ*

សរណង្ករោ លោកហិតោ *ព្រះសរណង្ករៈ ព្រះអង្គធ្វើឱ្យជាប្រយោជន៍ដល់សត្វលោក*

ទីបង្ករោ ជុតិន្ធរោ *ព្រះទីបង្ករៈ ព្រះអង្គទ្រទ្រង់នូវបញ្ញាដ៏រុងរឿង*

កោណ្ឌញ្ញោ ជនបាមោក្ខោ *ព្រះកោណ្ឌញ្ញៈ ព្រះអង្គជាប្រធាននៃពពួកជន*

មង្គលោ បុរិសាសភោ *ព្រះមង្គលៈ ព្រះអង្គជាបុរសដ៏ប្រសើរ*

សុមនោ សុមនោធីរោ *ព្រះសុមនៈ ព្រះអង្គជាអ្នកប្រាជ្ញមានព្រះហឫទ័យដ៏ល្អ*

រេវតោ រតិវឌ្ឍនោ *ព្រះរេវតៈ ព្រះអង្គញុំាងសេចក្តីត្រេកអរឱ្យចម្រើន*

សោភិតោ គុណសម្បន្នោ *ព្រះសោភិតៈ ព្រះអង្គបរិបូណ៌ដោយព្រះគុណ*

អនោមទស្សី ជនុត្តមោ *ព្រះអនោមទស្សី ព្រះអង្គឧត្តមជាងពពួកជន*

បទុមោ លោកបជ្ជោតោ *ព្រះបទុមៈ ព្រះអង្គញុំាងលោកឱ្យភ្លឺស្វាង*

នារទោ ទារសារថី *ព្រះនារទៈ ព្រះអង្គដូចជាសារថីដ៏ប្រសើរ*

បទុមុត្តរោ សត្តសារោ *ព្រះបទុមុត្តរៈ ព្រះអង្គជាខ្លឹមសារនៃពួកសត្វ*

សុមេធោ អប្បដិបុគ្គលោ *ព្រះសុមេធៈ ព្រះអង្គរកបុគ្គលប្រៀបដូចគ្មាន*

សុជាតោ សព្វលោកគ្គោ *ព្រះសុជាតៈ ព្រះអង្គប្រសើរលើសជាងសត្វលោកទាំងពួង*

បិយទស្សី នរាសភោ *ព្រះបិយទស្សី ព្រះអង្គប្រសើរជាងនរជន*

អត្ថទស្សី ការុណិកោ *ព្រះអត្ថទស្សី ព្រះអង្គប្រកបដោយករុណា*

ធម្មទស្សី តមោនុទោ *ព្រះធម្មទស្សី ព្រះអង្គបន្ទោបង់នូវងងឹត*

សិទ្ធត្ថោ អសមោ លោកេ *ព្រះសិទ្ធត្ថៈ ព្រះអង្គឥតមានអ្នកណាស្មើក្នុងលោក*

តិស្សោ ច ទទតំ ទរោ *ព្រះតិស្សៈ ព្រះអង្គប្រសើរជាងអ្នកប្រាជ្ញខាងសម្តីទាំងឡាយ*

ផុស្សោ ច ទរទោ ពុទ្ធោ *ព្រះពុទ្ធទ្រង់ព្រះនាមផុស្សៈ ព្រះអង្គប្រទាននូវធម៌ដ៏ប្រសើរ*

វិបស្សី ច អនុបមោ *ព្រះវិបស្សី ព្រះអង្គឥតមានអ្នកណាប្រៀបផ្ទឹមបានឡើយ*

សិខី សព្វហិតោ សត្ថា *ព្រះសិខី ព្រះអង្គជាគ្រូប្រៀនប្រដៅធ្វើឱ្យជាប្រ-យោជន៍ដល់សត្វទាំងពួង*

វេស្សភូ សុខទាយកោ *ព្រះវេស្សភូ ព្រះអង្គប្រទាននូវសេចក្តីសុខ*

ករុសន្ធោ សត្តវាហោ *ព្រះកកុសន្ធៈ ព្រះអង្គនាំសត្វចេញចាកផ្លូវឆ្ងាយដាច់ស្រយាល គឺកិលេស*

កោនាគមនោ រណញ្ជហោ *ព្រះកោនាគមៈ ព្រះអង្គបំបាក់បង់នូវសត្រូវ គឺកិលេស*

កស្សបោ សិរិសម្បន្នោ *ព្រះកស្សបៈ ព្រះអង្គបរិបូណ៌ដោយសិរី*

គោតមោ សក្យបុង្គវោ *ព្រះគោតមៈ ព្រះអង្គប្រសើរចម្បងជាងពួកសក្យ ភជ ។*

ឯតេ ចញ្ញេ ច សម្ពុទ្ធា អនេកសតកោដិយោ *ព្រះសម្ពុទ្ធទាំងនុ៎ះផង ព្រះសម្ពុទ្ធទាំងឡាយអង្គឯទៀតផង ច្រើនជាងរយកោដិ*

សព្ពេ ពុទ្ធា អសមសមា សព្ពេ ពុទ្ធា មហិទ្ធិកា *ព្រះសម្ពុទ្ធទាំងឡាយ គ្រប់ព្រះអង្គនោះ សុទ្ធតែស្មើដោយព្រះពុទ្ធដូចគ្នា ឥតមានបុគ្គលណាមួយស្មើឡើយ ព្រះសម្ពុទ្ធទាំងឡាយគ្រប់ព្រះអង្គនោះសុទ្ធតែមានឫទ្ធិច្រើន*

សព្ពេ ទសពលូបេតា វេសារជ្ជេហុបាគតា *ព្រះសម្ពុទ្ធទាំងឡាយគ្រប់ព្រះអង្គនោះ សុទ្ធតែប្រកបដោយទសពលញ្ញាណ និងប្រកបដោយវេសារជ្ជញ្ញាណទាំងឡាយ*

សព្វេ តេ បដិជានន្តិ អាសភណ្ឋានមុត្តមំ *ព្រះសម្ពុទ្ធទាំងឡាយគ្រប់ ព្រះអង្គនោះ សុទ្ធតែត្រាស់ដឹងនូវធម៌ជាទីតាំងដ៏ខ្ពង់ខ្ពស់គឺព្រះសព្វញ្ញុតញ្ញាណដ៏ឧត្តម*

សីហនាទំ នទន្តេតេ បរិសាសុ វិសារទា *ព្រះសម្ពុទ្ធទាំងឡាយនោះ ព្រះអង្គក្លៀវក្លា បន្ទឺនូវសីហនាទ គឺព្រះសូរសំឡេងដ៏ប្រសើរក្នុងពពួកនៃបរិស័ទ*

ព្រហ្មចក្កំ បវត្តេន្តិ លោកេ អប្បដិវត្តិយំ *ព្រះអង្គត្រាស់សម្តែងនូវព្រះធម៌ដូចជាចក្កដ៏ប្រសើរ ដែលឥតមានអ្នកណាមួយឱ្យប្រព្រឹត្តទៅក្នុងលោកបានឡើយ*

ទ្វេបតា ពុទ្ធធម្មេហិ អដ្ឋារសហិ នាយកា *ព្រះអង្គប្រកបដោយពុទ្ធធម៌[1] ទាំងឡាយ ១៨ ព្រះអង្គជានាយកដឹកនាំសត្វចេញចាកសង្សារវដ្ត*

ទ្វត្តឹសលក្ខណូបេតា- សីត្យានុព្យញ្ជនាធរា *ព្រះអង្គប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការ ព្រមទាំងទ្រទ្រង់នូវអនុព្យញ្ជនៈ ៨០ គត់*

ព្យាមប្បភាយ សុប្បភា សព្វេ តេ មុនិកុញ្ជរា *ព្រះសម្ពុទ្ធទាំងឡាយគ្រប់ព្រះអង្គនោះ សុទ្ធតែជាអ្នកប្រាជ្ញដ៏ប្រសើរ ទ្រង់មានរស្មីដ៏ល្អ ដោយរស្មីដែលផ្សាយចេញទៅដូចជាព្យាម[2]*

១-ពុទ្ធធម៌ គឺធម៌ដែលធ្វើបុគ្គលឱ្យបានត្រាស់ជាព្រះពុទ្ធមាន ១៨ គឺបារមីទាំង ១០ មានទានបារមីជាដើម មានឧបេក្ខាបារមីជាទីបំផុត ព្រមទាំងសម្បត្តិ ៨ ប្រការ គឺ **មនុស្សត្តំ** មានជាតិជាមនុស្ស ១ **លិង្គសម្បត្តិ** មានភេទជាបុរស ១ **ហេតុ** មានឧបនិស្ស័យគួរបានដល់ព្រះអរហត្តផល ១ **សត្ថារទស្សនំ** បានជួបបានឃើញព្រះសាស្តា ១ **បព្វជ្ជា** បានទ្រទ្រង់ភេទជាបព្វជ្ជា ១ **គុណសម្បត្តិ** បាននូវគុណមានលោកិយឈានជាដើម ១ **អធិការោ** បានបំពេញបរិច្ចាគទាំង ៥ មានបុត្តបរិច្ចាគជាដើម **ឆន្ទតា** មានសេចក្តីស្រឡាញ់ព្រះសព្វញ្ញុតញ្ញាណ ១ រួមជា ១៨ ។ ២- រស្មីរបស់ព្រះពុទ្ធទាំងឡាយផ្សាយចេញទៅជិត ឬឆ្ងាយផ្សេងគ្នា តែរស្មីដែលផ្សាយចេញទៅនោះដូចជាព្យាម ។

ពុទ្ធា សព្វញ្ញូនោ ឯតេ- សព្វេ ខីណាសវា ជិនា *ព្រះសម្ពុទ្ធទាំងឡាយគ្រប់ព្រះអង្គនោះ សុទ្ធតែជាព្រះសព្វញ្ញូអស់អាសវៈហើយ ឈ្នះហើយ (នូវបញ្ចពិធមារ)*

មហប្បភា មហាតេជា មហាបញ្ញា មហាពលា *ព្រះអង្គមានរស្មីច្រើន មានតេជៈច្រើន មានប្រាជ្ញាច្រើន មានកម្លាំងច្រើន*

មហាការុណិកា ធីរា សព្វេសានំ សុខាវហា *ព្រះអង្គជាអ្នកប្រាជ្ញ មានសេចក្តីករុណាច្រើន នាំមកនូវសេចក្តីសុខដើម្បីសព្វសត្វទាំងឡាយ*

ទីបា តាថា បតិដ្ឋា ច តាណា លេណា ច ចាណិនំ *ព្រះអង្គជាទីពឹង ជាទីអាស្រ័យ ដូចជាកោះ ជាទីជ្រកកោន ជាទីពួនរបស់សត្វទាំងឡាយ*

គតី ពន្ធូ មហាសត្ថា សរណា ច ហិតេសិនោ

សទេវកស្ស លោកស្ស សព្វេ ឯតេ បរាយនា

ព្រះសម្ពុទ្ធទាំងឡាយគ្រប់ព្រះអង្គនោះ ដូចជាផ្លូវ ជាផៅពង្ស ជាទីត្រេកអរច្រើន និងជាទីពឹងទីរឭក ព្រះអង្គស្វែងរកប្រយោជន៍ ជាទីប្រព្រឹត្តទៅក្នុងខាងមុខរបស់សត្វលោក ព្រមទាំងទេវលោក

តេសាហំ សិរសា ចាទេ វន្ទាមិ បុរិសុត្តមេ *ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំដោយត្បូងចំពោះព្រះបាទទាំងឡាយនៃព្រះសម្ពុទ្ធទាំងនោះ*

វចសា មនសា ចេវ វន្ទាមេតេ តថាគតេ

សយនេ អាសនេ ឋានេ គមនេ ចាបិ សព្វទា

ក្នុងឥរិយាបថដេកក្តី អង្គុយក្តី ឈរក្តី សូម្បីក្នុងឥរិយាបថដើរក្តី ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំដោយវាចា និងចិត្តសព្វៗ កាល ចំពោះព្រះតថាគតទាំងឡាយ នោះ

សង្ឃា សុខេន រក្ខន្តុ ពុទ្ធា សន្តិករា តុវំ *ព្រះសម្ពុទ្ធទាំងឡាយ ព្រះអង្គជាអ្នកធ្វើនូវសេចក្តីរំងាប់ សូមរក្សានូវអ្នកដោយសេចក្តីសុខសព្វៗ កាល*

តេហិ ត្វំ រក្ខិតោ សន្តោ មុត្តោ សព្វភយេន ច *ខ្លួនអ្នកកាលបើព្រះសម្ពុទ្ធទាំងឡាយនោះទ្រង់រក្សាហើយ ចូរជាអ្នកស្ងប់រំងាប់ផង ចូររួចចាកភ័យទាំងពួងផង*

សព្វរោគវិនីមុត្តោ សព្វសន្តាបវជ្ជិតោ
សព្វវេរមតិក្កន្តោ និព្ភយោ ច តុវំ ភវ

សូមឱ្យអ្នកជាបុគ្គលផុតចាករោគទាំងពួងផង ជាអ្នកចៀសចាកសេចក្តីក្តៅក្រហាយទាំងពួងផង ជាអ្នកកន្ទងបង់នូវពៀរទាំងពួងផង ជាអ្នករលត់ទុក្ខព្រួយផង។

តេសំ សច្ចេន សីលេន ខន្តិមេត្តាពលេន ច *ដោយសច្ចៈផង ដោយសីលផង ដោយកម្លាំងនៃខន្តី និងមេត្តាផង នៃព្រះសម្ពុទ្ធទាំងឡាយនោះ*

តេបិ តុម្ហេ អនុរក្ខន្តុ អារោគ្យេន សុខេន ច *ព្រះសម្មាសម្ពុទ្ធទាំងឡាយនោះ សូមបីបាច់រក្សានូវអ្នកទាំងឡាយដោយមិនឱ្យមានរោគផង ឱ្យមានសេចក្តីសុខផង*

បុរត្ថិមស្មឹ ទិសាភាគេ សន្តិ ភូតា មហិទ្ធិកា *ភូត គឺគន្ធព្វទាំងឡាយ មាន*

ឫទ្ធិច្រើន មានក្នុងទិសភាគខាងកើត

តេបិ តុម្ហេ អនុរក្ខន្តុ អារោគ្យេន សុខេន ច *គន្ធព្វទាំងឡាយនោះ ចូរបីបាច់រក្សានូវអ្នកទាំងឡាយដោយមិនឱ្យមានរោគផង ឱ្យមានសេចក្តីសុខផង*

ទក្ខិណស្មឹ ទិសាភាគេ សន្តិ ទេវា មហិទ្ធិកា *ទេវតាទាំងឡាយ មានឫទ្ធិច្រើន មានក្នុងទិសភាគខាងត្បូង*

តេបិ តុម្ហេ អនុរក្ខន្តុ អារោគ្យេន សុខេន ច *ទេវតាទាំងឡាយនោះ ចូរបីបាច់រក្សានូវអ្នកទាំងឡាយដោយមិនឱ្យមានរោគផង ឱ្យមានសេចក្តីសុខផង*

បច្ឆិមស្មឹ ទិសាភាគេ សន្តិនាគា មហិទ្ធិកា *នាគទាំងឡាយមានឫទ្ធិច្រើន មានក្នុងទិសភាគខាងលិច*

តេបិ តុម្ហេ អនុរក្ខន្តុ អារោគ្យេន សុខេន ច *នាគទាំងឡាយ ចូរបីបាច់រក្សានូវអ្នកទាំងឡាយដោយមិនឱ្យមានរោគផង ឱ្យមានសេចក្តីសុខផង*

ឧត្តរស្មឹ ទិសាភាគេ សន្តិ យក្ខា មហិទ្ធិកា *យក្ខទាំងឡាយមានឫទ្ធិច្រើន មានក្នុងទិសភាគខាងជើង*

តេបិ តុម្ហេ អនុរក្ខន្តុ អារោគ្យេន សុខេន ច *យក្ខទាំងឡាយនោះ ចូរបីបាច់រក្សានូវអ្នកទាំងឡាយដោយមិនឱ្យមានរោគផង ឱ្យមានសេចក្តីសុខផង*

បុរិមទិសំ ធតរដ្ឋោ *ស្តេចធតរដ្ឋៈ (នៅរក្សា) ខាងបុរិមៈទិស*

ទក្ខិណេន វិរុឡ្ហកោ *ស្តេចវិរុឡ្ហកៈ (នៅរក្សា) ខាងទក្ខិណទិស*

បច្ឆិមេន វិរូបក្ខោ *ស្តេចវិរូបក្ខៈ (នៅរក្សា) ខាងបច្ឆិមទិស*

កុវេរោ ទ្វត្តរំ ឋិសំ *ស្តេចកុវេរៈ (នៅរក្សា) ខាងឧត្តរទិស*

ចត្តារោ តេ មហារាជា លោកបាលា យសស្សិនោ *មហារាជទាំង ៤ នោះ សុទ្ធតែមានយសជាអ្នករក្សានូវលោក*

តេបិ តុម្ហេ អនុរក្ខន្តុ អារោគ្យេន សុខេន ច *មហារាជទាំងឡាយនោះ ចូរបីបាច់រក្សានូវអ្នកទាំងឡាយដោយមិនឱ្យមានរោគផង ឱ្យមានសេចក្តីសុខផង*

អាកាសដ្ឋា ច ភុម្មដ្ឋា ទេវា នាគា មហិទ្ធិកា *ទេវតា និងនាគទាំងឡាយ មានឫទ្ធិច្រើនដែលឋិតនៅក្នុងអាកាសក្តី ឋិតនៅលើផែនដីក្តី*

តេបិ តុម្ហេ អនុរក្ខន្តុ អារោគ្យេន សុខេន ច *ទេវតា និងនាគទាំងឡាយនោះ ចូរបីបាច់រក្សានូវអ្នកទាំងឡាយដោយមិនឱ្យមានរោគផង ឱ្យមានសេចក្តីសុខផង ។*

នត្ថិ មេសរណំ អញ្ញំ ពុទ្ធោ មេ សរណំ វរំ *ទីពឹងដទៃរបស់ខ្ញុំ មិនមានឡើយ មានតែព្រះពុទ្ធជាម្ចាស់ ជាទីពឹងដ៏ប្រសើររបស់ខ្ញុំ*

ឯតេន សច្ចវជ្ជេន ហោតុ តេ ជយមង្គលំ *ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ សូមជយមង្គលកើតមានដល់អ្នក ។*

នត្ថិ មេសរណំ អញ្ញំ ធម្មោ មេ សរណំ វរំ *ទីពឹងដទៃរបស់ខ្ញុំ មិនមានឡើយ មានតែព្រះធម៌ជាទីពឹងដ៏ប្រសើររបស់ខ្ញុំ*

ឯតេន សច្ចវជ្ជេន ហោតុ តេ ជយមង្គលំ *ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ សូមជយមង្គលកើតមានដល់អ្នក ។*

ឯត្ថិ មេ សរណំ អញ្ញំ សច្ចេ មេ សរណំ វរំ *ទីពឹងដទៃរបស់ខ្ញុំ មិនមានឡើយ មានតែព្រះសង្ឃជាទីពឹងដ៏ប្រសើររបស់ខ្ញុំ*

ឯតេន សច្ចវជ្ជេន ហោតុ តេ ជយមង្គលំ *ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ សូមជយមង្គលកើតមានដល់អ្នក ។*

យំកិញ្ចិ រតនំ លោកេ វិជ្ជតិ វិវិធំ បុថុ
រតនំ ពុទ្ធសមំ ឯត្ថិ តស្មា សោត្ថីភវន្តុ តេ

រតនៈឯណាមួយក្នុងលោក មានច្រើនបែបច្រើនយ៉ាង (រតនៈទាំងនោះ) ពុំស្មើនឹងព្រះពុទ្ធរតនៈឡើយ ព្រោះហេតុនោះ សូមសិរីសួស្តីទាំងឡាយកើតមានដល់អ្នក ។

យំកិញ្ចិ រតនំ លោកេ វិជ្ជតិ វិវិធំបុថុ
រតនំ ធម្មសមំ ឯត្ថិ តស្មា សោត្ថីភវន្តុ តេ

រតនៈឯណាមួយក្នុងលោក មានច្រើនបែបច្រើនយ៉ាង (រតនៈទាំងនោះ) ពុំស្មើនឹងព្រះធម្មរតនៈឡើយ ព្រោះហេតុនោះ សូមសិរីសួស្តីទាំងឡាយកើតមានដល់អ្នក ។

យំកិញ្ចិ រតនំ លោកេ វិជ្ជតិ វិវិធំ បុថុ
រតនំ សង្ឃសមំ ឯត្ថិ តស្មា សោត្ថី ភវន្តុ តេ

រតនៈឯណាមួយក្នុងលោក មានច្រើនបែបច្រើនយ៉ាង (រតនៈទាំងនោះ) ពុំស្មើនឹងព្រះសង្ឃរតនៈឡើយ ព្រោះហេតុនោះ សូមសិរីសួស្តីទាំងឡាយកើតមានដល់អ្នក ។

សក្កត្វា ពុទ្ធរតនំ ឥសភំ ខត្តមំ វរំ
ហិតំ ទេវមនុស្សានំ ពុទ្ធតេជេន សោត្ថិនា
ឧស្សន្តុបទ្ទវា សព្ពេ ទុក្ខា វូបសមេន្តុ តេ

សូមឱ្យឧបទ្រពទាំងឡាយទាំងពួងវិនាសបាត់ទៅ សូមឱ្យសេចក្តីទុក្ខទាំង-ឡាយរបស់អ្នកសូប់រំងាប់ទៅដោយសិរីសួស្តី ដោយតេជានុភាពនៃព្រះពុទ្ធជាម្ចាស់ ព្រោះធ្វើគោរពនូវព្រះពុទ្ធរតន៍ ដូចជាឱសថដ៏ឧត្តមប្រសើរ ជាប្រយោជន៍ដល់ទេវតា និងមនុស្សទាំងឡាយ ។

សក្កត្វា ធម្មរតនំ ឥសភំ ខត្តមំ វរំ
បរិឡាហូបសមនំ ធម្មតេជេន សោត្ថិនា
ឧស្សន្តុបទ្ទវា សព្ពេ ភយា វូបសមេន្តុ តេ

សូមឱ្យឧបទ្រពទាំងឡាយទាំងពួងវិនាសបាត់ទៅ សូមឱ្យភ័យទាំងឡាយរបស់អ្នកសូប់រំងាប់ទៅដោយសិរីសួស្តី ដោយតេជានុភាពនៃព្រះធម៌ ព្រោះធ្វើគោរពនូវព្រះធម្មរតន៍ ដូចជាឱសថដ៏ឧត្តមប្រសើរ ជាគ្រឿងរំងាប់នូវសេចក្តីក្រវល់ក្រវាយ ។

សក្កត្វា សង្ឃរតនំ ឥសភំ ខត្តមំ វរំ
អាហុនេយ្យំ បាហុនេយ្យំ សង្ឃតេជេន សោត្ថិនា
ឧស្សន្តុបទ្ទវា សព្ពេ រោគា វូបសមេន្តុ តេ

សូមឱ្យឧបទ្រពទាំងឡាយទាំងពួងវិនាសបាត់ទៅ សូមឱ្យរោគទាំងឡាយរបស់អ្នកសូប់រំងាប់ទៅដោយសិរីសួស្តី ដោយតេជានុភាពនៃព្រះសង្ឃ ព្រោះធ្វើ

គោរពនូវព្រះសង្ឃរតន៍ ដូចជាឱសថដ៏ឧត្តមប្រសើរ ជាវត្ថុគួរគេនាំមកបូជា ជាវត្ថុគួរគេទទួលរាក់ទាក់ ។

សព្វិតិយោ វិវជ្ជន្តុ *សូមឱ្យចង្រៃទាំងពួងទាំងឡាយប្រាសចេញ គឺថាចូរឱ្យចៀសវៀងចេញឆ្ងាយទៅ*

សព្វរោគោ វិនស្សតុ *សូមឱ្យរោគទាំងពួង (របស់អ្នក) ជាសះស្បើយទៅ*

មា តេ ភវត្វន្តរាយោ *អន្តរាយកុំបីមានដល់អ្នកឡើយ*

សុខី ទីឃាយុកោ ភវ *សូមឱ្យអ្នកជាបុគ្គលមានសេចក្តីសុខ មានអាយុវែង*

អភិវាទនសីលិស្ស និច្ចំ វុឌ្ឍាបចាយិនោ
ចត្តារោ ធម្មា វឌ្ឍន្តិ អាយុ វណ្ណោ សុខំ ពលំ

ធម៌ គឺពរទាំងឡាយ ៤ ប្រការ គឺអាយុ ១ ពណ៌សម្បុរកាយ ១ សេចក្តីសុខ ១ កម្លាំង ១ រមែងចម្រើនអស់កាលជានិច្ច ដល់អ្នកដែលមានសេចក្តីឱនកាយថ្វាយបង្គំដល់ព្រះរតនត្រ័យជាប្រក្រតី និងអ្នកដែលមានសេចក្តីគោរពកោតក្រែងដល់បុគ្គល ដែលជាអ្នកមានសេចក្តីចម្រើនដោយគុណ មានសីលគុណជាដើម ឬដែលចម្រើនដោយវ័យ គឺចាស់ព្រឹទ្ធាចារ្យ ។

អាជានាដិយបរិត្តគាថា និដ្ឋិតា

អាជានាដិយបរិត្តគាថា ចប់

អតិយបរិត្តគាថារម្ភោ

បុញ្ញាលាភំ មហាតេជំ វណ្ណកិត្តិមហាយសំ
សព្ពសត្តហិតំ ជាតំ តំ សុណន្តុ អសេសតោ

សាធុជនទាំងឡាយ ចូរស្តាប់ឱ្យសព្វគ្រប់នូវព្រះបរិត្តនោះ ជាគុណជាតអាចនឹងឱ្យបាននូវបុណ្យ មានតេជៈច្រើន មានគុណ និងកិត្តិយសដ៏ធំ ជាប្រយោជន៍ដល់សព្វសត្វ

អត្តបរហិតំ ជាតំ បរិត្តន្តម្ភណាម ហេ *យើងទាំងឡាយសូត្រឥឡូវនេះ នូវព្រះបរិត្តនោះ ដែលជាប្រយោជន៍ដល់ខ្លួន និងអ្នកដទៃ ។*

អតិយបរិត្តគាថា

យន្ទុន្និមិត្តំ អវមង្គលញ្ច យោចាមនាបោ សកុណស្ស សទ្ទោ
បាបគ្គហោ ទុស្សុបិនំ អកន្តំ ពុទ្ធានុភាវេន វិនាសមេន្តុ

និមិត្តអាក្រក់ឯណាក្តី អពមង្គលឯណាក្តី សំឡេងសត្វមិនជាទីគាប់ចិត្តឯណាក្តី បាបគ្រោះឯណាក្តី សុបិនអាក្រក់មិនជាទីពេញចិត្តឯណាក្តី ដោយអានុភាពនៃព្រះពុទ្ធជាម្ចាស់ សូមឱ្យនិមិត្តអាក្រក់ជាដើមនោះ ដល់នូវសេចក្តីវិនាសបាត់បង់ទៅ ។

យន្ទុន្និមិត្តំ អវមង្គលញ្ច យោចាមនាបោ សកុណស្ស សទ្ទោ
បាបគ្គហោ ទុស្សុបិនំ អកន្តំ ធម្មានុភាវេន វិនាសមេន្តុ

និមិត្តអាក្រក់ឯណាក្តី អពមង្គលឯណាក្តី សំឡេងសត្វមិនជាទីគាប់ចិត្តឯណាក្តី បាបគ្រោះឯណាក្តី សុបិនអាក្រក់មិនជាទីពេញចិត្តឯណាក្តី ដោយអានុភាពនៃព្រះធម៌ សូមឱ្យនិមិត្តអាក្រក់ជាដើមនោះ ដល់នូវសេចក្តីវិនាសបាត់បង់ទៅ។

យន្ទុន្និមិត្តំ អវមង្គលញ្ច យោចាមនាបោ សកុណាសុ្ស សទ្ទោ
បាបគ្គហោ ទុសុ្សបិនំ អកន្តំ សច្ចានុភាវេន វិនាសមេន្តុ

និមិត្តអាក្រក់ឯណាក្តី អពមង្គលឯណាក្តី សំឡេងសត្វមិនជាទីគាប់ចិត្តឯណាក្តី បាបគ្រោះឯណាក្តី សុបិនអាក្រក់មិនជាទីពេញចិត្តឯណាក្តី ដោយអានុភាពនៃព្រះសង្ឃ សូមឱ្យនិមិត្តអាក្រក់ជាដើមនោះ ដល់នូវសេចក្តីវិនាសបាត់បង់ទៅ។

ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា
សោកប្បត្តា ច និសេ្សាកា ហោន្តុ សព្ពេបិ បាណិនោ

សត្វទាំងឡាយទាំងពួង ដែលកំពុងដល់នូវសេចក្តីទុក្ខ សូមឱ្យជាសត្វបាត់សេចក្តីទុក្ខទៅ, ដែលកំពុងដល់នូវភ័យ សូមឱ្យជាសត្វបាត់ភ័យទៅ, ដែលកំពុងដល់នូវសេចក្តីសោក សូមឱ្យជាសត្វបាត់សេចក្តីសោកទៅ!។

ឯត្តាវតា ច អម្ហេហិ សម្ភតំ បុញ្ញសម្បទំ
សព្ពេ ទេវានុមោទន្តុ សព្ពសម្បត្តិសិទ្ធិយា

សូមទេវតាទាំងឡាយទាំងពួង អនុមោទនានូវសម្បទា គឺបុណ្យដែលយើងទាំងឡាយបានកសាងហើយទាំងប៉ុណ្ណោះ ដើម្បីឱ្យបានសម្រេចនូវសម្បត្តិទាំងពួង។

ទានំ ទទន្តុ សទ្ធាយ សីលំ រក្ខន្តុ សព្ពទា
ភាវនាភិរតា ហោន្តុ គច្ឆន្តុ ទេវតា គតា

មនុស្សទាំងឡាយ ចូរនាំគ្នាឱ្យទានដោយសទ្ធា ចូរនាំគ្នារក្សាសីល ចូរជាអ្នកត្រេកអរចំពោះភាវនាសព្វៗ កាលទៅ ទេវតាទាំងឡាយដែលមកហើយ សូមអញ្ជើញត្រឡប់ទៅវិញចុះ ។

សព្ពេ ពុទ្ធា ពលប្បត្តា បច្ចេកានញ្ច យម្ពលំ
អរហន្តានញ្ច តេជេន រក្ខំ ពន្ធាមិ សព្ពសោ

ព្រះសម្មាសម្ពុទ្ធទាំងឡាយគ្រប់ព្រះអង្គ សុទ្ធតែទ្រទ្រង់នូវកម្លាំង ទាំងព្រះបច្ចេកពុទ្ធទាំងឡាយក៏មានកម្លាំង ព្រះអរហន្តទាំងឡាយក៏មានកម្លាំង ខ្ញុំសូមចងនូវការរក្សាដោយតេជៈ (នៃកម្លាំងទាំងឡាយនោះ) ដោយប្រការទាំងពួង ។

ជយបរិត្តគាថារម្ភោ

ជយ៑ ទេវមនុស្សានំ ជយោ ហោតុ បរាជិតោ *ជ័យជម្នះ ចូរកើតមានដល់ទេវតា និងមនុស្សទាំងឡាយ អ្នកដែលចាញ់ហើយ ចូរត្រឡប់ទៅជាមានជ័យជម្នះ*

មារសេនា អតិក្កន្តា សមន្តា ទ្វាទសយោជនា
ខន្តិមេត្តា អធិដ្ឋានា វិទ្ធំសេត្វាន ចក្ខុមា
តថាគតេ សំសរន្តោ ទិព្វចក្ខុំ វិសោធយិ

ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់មានបញ្ញាចក្ខុ កាលដែលអន្ទោលទៅក្នុងភពតូច

កពធំ ទ្រង់កម្ចាត់បង់នូវមារ និងសេនានៃមារឱ្យកន្ធងផុតទៅអំពី ១២ យោជន៍ ដោយជុំវិញ ដោយខន្តិបារមី មេត្តាបារមី និងអធិដ្ឋានបារមី ហើយទ្រង់ជម្រះនូវទិព្វចក្ខុ

បរិយោបន្នាធិសោត្តានំ ហិតាយ ច សុខាយ ច
ពុទ្ធកិច្ចំ វិសោធេត្វា បរិត្តន្តម្ពណាម ហោ

ព្រះសាស្តាទ្រង់បំពេញនូវពុទ្ធកិច្ចដើម្បីប្រយោជន៍ផង ដើម្បីសេចក្តីសុខផង ដល់សត្វទាំងឡាយ ដែលបាននូវសេចក្តីចម្រើនដ៏ក្រៃលែង យើងទាំងឡាយសូធ្យឥឡូវនេះ នូវព្រះបរិត្តនោះ។

ជយបរិត្តគាថា

មហាការុណិកោ នាថោ ហិតាយ សព្វបាណិនំ
បូរេត្វា បារមី សព្វា បត្តោ សម្ពោធិមុត្តមំ

ព្រះសម្មាសម្ពុទ្ធជាទីពឹងនៃសត្វលោក ទ្រង់ប្រកបដោយមហាករុណា ព្រះអង្គបំពេញនូវបារមីទាំងឡាយទាំងពួង ដើម្បីប្រយោជន៍ដល់សត្វទាំងអស់ ហើយទ្រង់បានដល់នូវសម្ពោធិញ្ញាណដ៏ឧត្តមហើយ

ឯតេន សច្ចវជ្ជេន ហោតុ តេ ជយមង្គលំ *ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ សូមជយមង្គលកើតមានដល់អ្នក។*

ជយន្តោ ពោធិយា មូលេ សក្យានំ នន្ទិវឌ្ឍនោ
ឯវំ ត្វំ វិជយោ ហោហិ ជយស្សុ ជយមង្គលេ

អបរាជិតបល្លង្កេ សីសេ បឋវិយោភវេ
អភិសេកេ សព្ពពុទ្ធានំ អគ្គប្បត្តោ បមោទតិ ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់ញុាំងសេចក្តីត្រេកអរនៃសត្វទាំងឡាយឱ្យចម្រើន ព្រះអង្គឈ្នះមារហើយ បានដល់នូវភាពជាបុគ្គលប្រសើរបំផុត ទ្រង់រីករាយ (ចំពោះធម៌ដែលព្រះអង្គត្រាស់ដឹង) លើអបរាជិតបល្ង័ង្ក ជាជយមង្គល ទៀបគល់ពោធិព្រឹក្ស ត្រង់ផ្ចិតផែនដី ដូចជាស្តឹកឈូកជាទីអភិសេកនៃព្រះពុទ្ធគ្រប់ព្រះអង្គ (យ៉ាងណាមិញ) សូមឱ្យអ្នកជាបុគ្គល មានជម្នះឈ្នះ (អស់សត្រូវ) យ៉ាងនោះឯង ។

សុនក្ខត្តំ សុមង្គលំ សុបភាតំ សុហុដ្ឋិតំ[1]
សុខណោ សុមុហុត្តោ ច សុយិដ្ឋំ ព្រហ្មចារិសុ

(ពេលណាដែលសត្វទាំងឡាយ ប្រព្រឹត្តល្អដោយកាយ វាចា ចិត្ត ពេលនោះ) ឈ្មោះថានក្ខត្តឫក្សល្អ ជាមង្គលល្អ ជាពេលភ្លឺស្វាងល្អ ជាពេលនៃអរុណរះល្អ ជាខណៈល្អ ជាយាមល្អ (ទានដែលបុគ្គលបានបូជាហើយ) ដល់ព្រហ្មចារីបុគ្គលទាំងឡាយ (ក្នុងពេលនោះ) ឈ្មោះថាជាគ្រឿបូជាល្អ

បឋវិណំ កាយកម្មំ វាចាកម្មំ បឋវិណំ
បឋវិណំ មនោកម្មំ បណិធី តេ បឋវិណា

(ក្នុងថ្ងៃនោះ) កាយកម្មក៏ឈ្មោះថានាំឱ្យមានសេចក្តីចម្រើន វចីកម្មក៏ឈ្មោះថានាំឱ្យមានសេចក្តីចម្រើន មនោកម្មក៏ឈ្មោះថានាំឱ្យមានសេចក្តីចម្រើន សេចក្តីប្រាថ្នាទាំងឡាយរបស់អ្នកទាំងនោះ ក៏ឈ្មោះថានាំឱ្យមានសេចក្តីចម្រើន

១-ស្រង់ចាកបុព្វណ្ហសូត្រ បិដកលេខ ៤១ ទំព័រ ៤៧៦ ។

បុគ្គលិកោនិ កត្វាន លភន្តេ បុគ្គលេ *បុគ្គលដែលបានធ្វើនូវកាយកម្ម វចីកម្ម មនោកម្ម គួរដល់សេចក្តីចម្រើន (យ៉ាងនេះ) ហើយ ក៏រមែងបាននូវប្រយោជន៍ដ៏ចម្រើនទាំងឡាយ។*

សោ អត្តលទ្ធោ សុខិតោ ទិរុទ្ធោ ពុទ្ធសាសនេ
អរោគោ សុខិតោ ហោហិ សហ សព្ពេហិ ញាតិភិ

អ្នក (ជាបុរស) នោះ ចូរបាននូវប្រយោជន៍ បាននូវសេចក្តីសុខ ចូរចម្រើនក្នុងព្រះពុទ្ធសាសនា ចូរកុំឱ្យមានរោគ ឱ្យបាននូវសេចក្តីសុខ ព្រមទាំងញាតិទាំងឡាយគ្រប់គ្នា។

សា អត្តលទ្ធា សុខិតា ទិរុទ្ធា ពុទ្ធសាសនេ
អរោគា សុខិតា ហោហិ សហ សព្ពេហិ ញាតិភិ

អ្នក (ជាស្ត្រី) នោះ ចូរបាននូវប្រយោជន៍ បាននូវសេចក្តីសុខ ចូរចម្រើនក្នុងព្រះពុទ្ធសាសនា ចូរកុំឱ្យមានរោគ ឱ្យបាននូវសេចក្តីសុខ ព្រមទាំងញាតិទាំងឡាយគ្រប់គ្នា។

តេ អត្តលទ្ធា សុខិតា ទិរុទ្ធា ពុទ្ធសាសនេ
អរោគា សុខិតា ហោថ សហ សព្ពេហិ ញាតិភិ[1]**។**

អ្នកទាំងឡាយ (ទាំងបុរសទាំងស្ត្រី) នោះ ចូរបាននូវប្រយោជន៍ បាននូវសេចក្តីសុខ ចូរចម្រើនក្នុងព្រះពុទ្ធសាសនា ចូរកុំឱ្យមានរោគ ឱ្យបាននូវសេចក្តីសុខ ព្រមទាំងញាតិទាំងឡាយគ្រប់គ្នា។

១-ក្នុងបុព្វណ្ហសូត្រ បិដកលេខ ៤១ ទំព័រ៤៧៦ ឃើញមានតែ **តេ អត្តលទ្ធា** ម៉្យាងនេះទេ។

អាជានាដិយបរិត្តគាថា

សក្កត្វា ពុទ្ធរតនំ ឱសថំ ឧត្តមំ វរំ
ហិតំ ទេវមនុស្សានំ ពុទ្ធតេជេន សោត្ថិនា
ឧស្សន្តុបទ្ធវា សព្ពេ ទុក្ខា វូបសមេន្តុ តេ

សូមឱ្យឧបទ្រពទាំងឡាយទាំងពួងវិនាសបាត់ទៅ សូមឱ្យសេចក្តីទុក្ខទាំង-ឡាយរបស់អ្នកសូប់រំងាប់ទៅដោយសិរីសួស្តី ដោយតេជានុភាពនៃព្រះពុទ្ធជាម្ចាស់ ព្រោះធ្វើគោរពនូវព្រះពុទ្ធរតន៍ ដូចជាឱសថដ៏ឧត្តមប្រសើរ ជាប្រយោជន៍ដល់ទេវតា និងមនុស្សទាំងឡាយ។

សក្កត្វា ធម្មរតនំ ឱសថំ ឧត្តមំ វរំ
បរិឡាហូបសមនំ ធម្មតេជេន សោត្ថិនា
ឧស្សន្តុបទ្ធវា សព្ពេ ភយា វូបសមេន្តុ តេ

សូមឱ្យឧបទ្រពទាំងឡាយទាំងពួងវិនាសបាត់ទៅ សូមឱ្យភ័យទាំងឡាយរបស់អ្នកសូប់រំងាប់ទៅ ដោយសិរីសួស្តី ដោយតេជានុភាពនៃព្រះធម៌ ព្រោះធ្វើគោរពនូវព្រះធម្មរតន៍ ដូចជាឱសថដ៏ឧត្តមប្រសើរ ជាគ្រឿងរំងាប់នូវសេចក្តីក្រវល់ក្រវាយ។

សក្កត្វា សង្ឃរតនំ ឱសថំ ឧត្តមំ វរំ
អាហុនេយ្យំ បាហុនេយ្យំ សង្ឃតេជេន សោត្ថិនា
ឧស្សន្តុបទ្ធវា សព្ពេ រោគា វូបសមេន្តុ តេ

សូមឱ្យឧបទ្រពទាំងឡាយទាំងពួងវិនាសបាត់ទៅ សូមឱ្យរោគទាំងឡាយ

របស់អ្នកសូប៌រំងាប់ទៅ ដោយសិរីសួស្តី ដោយតេជានុភាពនៃព្រះសង្ឃ ព្រោះធ្វើគោរពនូវព្រះសង្ឃរតន៍ ដូចជាឱសថដ៏ឧត្តមប្រសើរ ជាវត្ថុគួរគេនាំមកបូជា ជាវត្ថុគួរគេទទួលរាក់ទាក់ ។

ឝត្ថិ មេសរណំ អញ្ញំ ពុទ្ធោ មេ សរណំ វរំ *ទីពឹងដទៃរបស់ខ្ញុំ មិនមានឡើយ មានតែព្រះពុទ្ធជាម្ចាស់ ជាទីពឹងដ៏ប្រសើររបស់ខ្ញុំ*

ឯតេឝ សច្ចវជ្ជេឝ ហោតុ តេ ជយមង្គលំ *ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ សូមជយមង្គលកើតមានដល់អ្នក ។*

ឝត្ថិ មេសរណំ អញ្ញំ ធម្មោ មេ សរណំ វរំ *ទីពឹងដទៃរបស់ខ្ញុំ មិនមានឡើយ មានតែព្រះធម៌ជាទីពឹងដ៏ប្រសើររបស់ខ្ញុំ*

ឯតេឝ សច្ចវជ្ជេឝ ហោតុ តេ ជយមង្គលំ *ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ សូមជយមង្គលកើតមានដល់អ្នក ។*

ឝត្ថិ មេ សរណំ អញ្ញំ សង្ឃោ មេ សរណំ វរំ *ទីពឹងដទៃរបស់ខ្ញុំ មិនមានឡើយ មានតែព្រះសង្ឃជាទីពឹងដ៏ប្រសើររបស់ខ្ញុំ*

ឯតេឝ សច្ចវជ្ជេឝ ហោតុ តេ ជយមង្គលំ *ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ សូមជយមង្គលកើតមានដល់អ្នក ។*

យំកិញ្ចិ រតនំ លោកេ វិជ្ជតិ វិវិធំ បុថុ
រតនំ ពុទ្ធសមំ ឝត្ថិ តស្មា សោត្ថីភវន្តុ តេ

រតនៈឯណាមួយក្នុងលោក មានច្រើនបែបច្រើនយ៉ាង (រតនៈទាំងនោះ) ពុំស្មើនឹងព្រះពុទ្ធរតនៈឡើយ ព្រោះហេតុនោះ សូមសិរីសួស្តីទាំងឡាយកើតមាន

ដល់អ្នក ។

យំកិញ្ចិ រតនំ លោកេ ឥជ្ជតិ ឥវិធំ បុថុ
រតនំ ធម្មសមំ នត្ថិ តស្មា សោត្ថីភវន្តុ តេ

រតន:ឯណាមួយក្នុងលោក មានច្រើនបែបច្រើនយ៉ាង (រតន:ទាំងនោះ) ពុំស្មើនឹងព្រះធម្មរតន:ឡើយ ព្រោះហេតុនោះ សូមសិរីសួស្តីទាំងឡាយកើតមានដល់អ្នក ។

យំកិញ្ចិ រតនំ លោកេ ឥជ្ជតិ ឥវិធំ បុថុ
រតនំ សង្ឃសមំ នត្ថិ តស្មា សោត្ថី ភវន្តុ តេ

រតន:ឯណាមួយក្នុងលោក មានច្រើនបែបច្រើនយ៉ាង (រតន:ទាំងនោះ) ពុំស្មើនឹងព្រះសង្ឃរតន:ឡើយ ព្រោះហេតុនោះ សូមសិរីសួស្តីទាំងឡាយកើតមានដល់អ្នក ។

មង្គលចក្កវាឡ

សិរីធិតិមតិតេជោជយសិទ្ធិមហិទ្ធិមហាគុណាបរិមិតបុញ្ញាធិការស្ស សព្វញ្ញុ-រាយនិវារណសមត្ថស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ទ្វត្តឹំសមហាបុរិស-លក្ខណានុភាវេន *ដោយអានុភាពនៃមហាបុរិសលក្ខណៈ ៣២ ប្រការនៃព្រះដ៏មានព្រះភាគ ជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ទ្រង់មានបុញ្ញាធិការនឹងកំណត់មិនបាន ដោយឫទ្ធិដ៏ធំនិងគុណដ៏ធំ ដ៏សម្រេចដោយសិរី ដោយបញ្ញាជាគ្រឿងតម្កល់មាំ ដោយ*

បញ្ញាជាគ្រឿងដឹង ដោយតេជៈ ដោយជ័យជម្នះ ព្រះអង្គអាចក្នុងកិរិយាឃាត់បង់នូវអន្តរាយគ្រប់យ៉ាង

អសីត្យានុព្យញ្ជានានុភាវេន *ដោយអានុភាពនៃអនុព្យញ្ជនៈ ៨០*

អដ្ឋង្គរសតមង្គលានុភាវេន *ដោយអានុភាពនៃមង្គល ១០៨*

ឆព្ភណ្ណរំសྱានុភាវេន *ដោយអានុភាពនៃរស្មីមានពណ៌ ៦*

កេតុមាលានុភាវេន *ដោយអានុភាពនៃព្រះកេតុមាលា*

ទសបារមិតានុភាវេន *ដោយអានុភាពនៃបារមី ១០*

ទសឧបបារមិតានុភាវេន *ដោយអានុភាពនៃឧបបារមី ១០*

ទសបរមត្ថបារមិតានុភាវេន *ដោយអានុភាពនៃបរមត្ថបារមី ១០*

សីលសមាធិបញ្ញានុភាវេន *ដោយអានុភាពនៃសីលសមាធិបញ្ញានៃព្រះអង្គ*

ពុទ្ធានុភាវេន *ដោយអានុភាពនៃព្រះពុទ្ធ*

ធម្មានុភាវេន *ដោយអានុភាពនៃព្រះធម៌*

សង្ឃានុភាវេន *ដោយអានុភាពនៃព្រះសង្ឃ*

តេជានុភាវេន *ដោយអានុភាពនៃតេជៈ*

ឥទ្ធានុភាវេន *ដោយអានុភាពនៃឫទ្ធិ*

ពលានុភាវេន *ដោយអានុភាពនៃកម្លាំង*

ញេយ្យធម្មានុភាវេន *ដោយអានុភាពនៃញេយ្យធម៌*

ចតុរាសីតិសហស្សធម្មក្ខន្ធានុភាវេន *ដោយអានុភាពនៃព្រះធម្មក្ខន្ធ ៨ ម៉ឺន*

៤ ពាន់

នវលោកុត្តរធម្មានុភាវេន *ដោយអានុភាពនៃលោកុត្តរធម៌ ៩*

អដ្ឋង្គិកមគ្គានុភាវេន *ដោយអានុភាពនៃព្រះអរិយមគ្គមានអង្គ ៨*

អដ្ឋសមាបត្តានុភាវេន *ដោយអានុភាពនៃសមាបត្តិ ៨*

ឆឡភិញ្ញានុភាវេន *ដោយអានុភាពនៃអភិញ្ញា ៦*

ចតុសច្ចញ្ញាណានុភាវេន *ដោយអានុភាពនៃសច្ចញ្ញាណ ៤*

ទសពលញ្ញាណានុភាវេន *ដោយអានុភាពនៃពលញ្ញាណ ១០*

សព្វញ្ញុតញ្ញាណានុភាវេន *ដោយអានុភាពនៃសព្វញ្ញុតញ្ញាណ*

មេត្តាករុណាមុទិតាឧបេក្ខានុភាវេន *ដោយអានុភាពនៃមេត្តា ករុណា មុទិតា ឧបេក្ខា*

សព្វបរិត្តានុភាវេន *ដោយអានុភាពនៃព្រះបរិត្តទាំងពួង*

រតនត្តយសរណានុភាវេន *ដោយអានុភាពនៃកិរិយារឭកដល់ព្រះរតនត្រ័យ*

តុយ្ហំ សព្វរោគសោកុបទ្ទវទុក្ខទោមនស្សុបាយាសា ខិនសន្តុ *រោគ សោក ឧបទ្រព ទុក្ខ ទោមនស្ស និងឧបាយាស:ទាំងពួងរបស់អ្នក ចូរវិនាសបាត់ទៅ*

សព្វអន្តរាយាបិ ខិនសន្តុ *សេចក្តីអន្តរាយទាំងពួង (របស់អ្នក) ចូរវិនាសបាត់ទៅ*

សព្វសម្ប្បត្តិ តុយ្ហំ សមិជ្ឈន្តុ *សេចក្តីត្រិះរិះគ្រប់យ៉ាងរបស់អ្នក ចូរសម្រេចដោយល្អ*

ឌីឃាយុកា តុយ្ហំ ហោតុ *ភាវៈជាអ្នកមានអាយុវែង ចូរមានដល់អ្នក*

សតវស្សជីវេន សមង្គិកោ ហោតុ សព្វទា *សូមឱ្យអ្នកជាបុគ្គល មានសេចក្តីសមប្រកបដោយកិរិយារស់នៅអស់រយនៃឆ្នាំសព្វ ៗ កាល*

អាកាសបព្វតវនភូមិគង្គាមហាសមុទ្ទា អារក្ខកា ទេវតា *ទេវតាទាំងឡាយជាអ្នករក្សាដោយយកចិត្តទុកដាក់ ដែលឋិតនៅក្នុងអាកាស បព៌ត វនស្ថាន ភូមិស្ថាន និងទន្លេ និងមហាសមុទ្រ*

សទា តុម្ហេ អនុរក្ខន្តុ *ចូរបីបាច់រក្សានូវអ្នកទាំងឡាយសព្វ ៗ កាល*

ភវតុ សព្វមង្គលំ *មង្គលទាំងពួងចូរមាន (ដល់អ្នក)*

រក្ខន្តុ សព្វទេវតា *សូមទេវតាទាំងអស់បីបាច់រក្សា (នូវអ្នក)*

សព្វពុទ្ធានុភាវេន *ដោយអានុភាពនៃព្រះពុទ្ធជាម្ចាស់រាល់ព្រះអង្គ*

សទា សោត្ថី ភវន្តុ តេ *សូមសិរីសួស្តីទាំងឡាយ កើតមានដល់អ្នក ឱ្យបានសព្វកាល សព្វវេលា ។*

ភវតុ សព្វមង្គលំ *មង្គលទាំងពួងចូរមាន (ដល់អ្នក)*

រក្ខន្តុ សព្វទេវតា *សូមទេវតាទាំងអស់បីបាច់រក្សា (នូវអ្នក)*

សព្វធម្មានុភាវេន *ដោយអានុភាពនៃព្រះធម៌ទាំងពួង*

សទា សោត្ថី ភវន្តុតេ *សូមសិរីសួស្តីទាំងឡាយ កើតមានដល់អ្នក ឱ្យបានសព្វកាលសព្វវេលា ។*

ភវតុ សព្វមង្គលំ *មង្គលទាំងពួងចូរមាន (ដល់អ្នក)*

រក្ខន្តុ សព្វទេវតា *សូមទេវតាទាំងអស់បីបាច់រក្សា (នូវអ្នក)*

សព្វសង្ឃានុភាវេន *ដោយអានុភាពនៃព្រះសង្ឃទាំងពួង*

សទា សោត្ថីភវន្តុ តេ *សូមសិរីសួស្តីទាំងឡាយ កើតមានដល់អ្នក ឱ្យបានសព្វកាលសព្វវេលា ។*

នក្ខត្តយក្ខភូតានំ បាបគ្គហនិវារណា *កិរិយាការពារនូវបាបគ្រោះទាំងឡាយ (ដែលកើតអំពីសម្ពាក់) នៃនក្ខត្តឫក្ស នឹងយក្ខ នឹងភូតបិសាចទាំងឡាយ*

បរិត្តស្សានុភាវេន ហន្ទា តេសំ ឧបទ្ទវេ *ដោយអានុភាពនៃព្រះបរិត្ត សូមកម្ចាត់បង់នូវឧបទ្រពទាំងឡាយ (ដែលកើតអំពីសម្ពាក់) នៃនក្ខត្តឫក្ស នឹងយក្ខ នឹងភូតបិសាចទាំងឡាយនោះ ។*

(ចាប់ពី ***នក្ខត្តយក្ខភូតានំ*** *ដល់* ***តេសំ ឧបទ្ទវេ*** *សូធ្យ ១ ចប់ក៏បាន ៣ ចប់ក៏បាន)*

ពុទ្ធជយមង្គលគាថា

១-ពាហុំ សហស្សមភិនិម្មិត សាវុធន្តំ
គ្រីមេខលំ ទ្វិតយោរសសេនមារំ
ទានាទិធម្មវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទលោកាចារ្យ ផ្ចាញ់ក្រុងមារចិត្តមោហន្ធ
និម្មិតដៃមួយពាន់ កាន់សស្ត្រាវុធនានា ។

ជិះគ្រីមេខលជាតិ កោញ្ញានាទខ្ចរពសុធា
ព្រមដោយមារសេនា ពន្ធឹកលន់កង៏ស័ព្ទស្ទាន ។
ដោយធម្មពិធី ទានបារមីជាប្រធាន
ក្រុង៏មារចាញ់ទ្រង់ញាណ ប្រណម្យកាយថ្វាយវន្ទា ។
វីជយមង្គល ចូរមានដល់អ្នកវាល់គ្នា
ដោយតេជះជយា ព្រះឈ្នះមារគ្រានោះហោង ។

២-មារាតិរេកមតិយុជ្ឈិតសព្វរត្តឹ
យោរម្បនាឡ្យវកមក្ខមថទ្ធយក្ខំ
ខន្តីសុទន្តវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទពិនាយក: ផ្ចាញ់អាឡវ័កយក្ខឃោរឃៅ
រឹង៏រូសមិនតាំង៏នៅ ក្នុង៏ខន្តីគុណសត្យា ។
រហូតអស់រាត្រី ព្រះជិនស្រីទ្រង់យុទ្ធនា
ក្រៃលែង៏ក្រុង៏មារ ក្នុង៏បឋមសម្ពោធី ។
ដោយព្រះពិធីញាណ ទ្រង់ទូន្មានដោយខន្តី
ញ៉ាំង៏ចិត្តអសុរី ឱ្យបង់ព្យសន៍[1] ចុះវន្ទា ។
វីជយមង្គល ចូរមានដល់អ្នកវាល់គ្នា
ដោយតេជះជយា ព្រះឈ្នះអាឡវ័កយក្ខហោង ។

១-អានថា **ព្យស់** ប្រែថា អំពើអាក្រក់, ពុតត្បុត, ពុតកំណាច។ (វចនានុក្រមខ្មែរ)

៣-នាឡាគិរឹ គជវរំ អតិមត្តភូតំ
នាវគ្គិចក្កមសនីវ សុទារុណន្តំ
មេត្តម្ពុសេកវិធិនា ជិតវា មុនិន្ទោ
តន្តេជសាភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទពិនជិនស្រី ផ្ចាញ់ដំរីឈ្មោះនាឡា
គិរីវរគជា ដ៏ហានក្លាចុះប្រេងព្រេច ។
សាហាវធាវឆេះក្រៃ ដូចភ្លើងព្រៃឆេះកម្ចេច
មុតដូចចក្រក្រុតពេជ្រ ខ្លាំងដូចកាំអសនី ។
ដោយព្រះពិធីស្រេព ស្រោចទឹកអប់គឺបារមី
មេត្តាព្រះជិនស្រី ញាំងដំរីឱ្យជ្រះថ្លា ។
វីជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា ព្រះឈ្នះនាឡាគិរី ។

៤ - ខ្វិត្តខគ្គមតិហត្ថសុទារុណន្តំ
ឆវន្តិ យោជនបថង្គុលិមាលវន្តំ
ឥទ្ធីភិសង្ខតមនោ ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទពិនលោកត្រៃ មានព្រះទ័យធ្វើបាដិហារ្យ
ផ្ចាញ់ចោរអង្គុលិមាល មានកម្រងគឺម្រាមដៃ។
នៃមនុស្សដែលគាត់កាត់ មកដោតចាក់ជាមាល័យ

អង់អាចកំណាចក្រៃ ដ៏មានដៃស្ទាត់ប្រហារ ។
កាន់ដាវដ៏គ្រើ ដេញព្រះមុនីសាស្តាចារ្យ
ចម្ងាយផ្លូវកន្តារ កណ្តាលព្រៃបីយោជន៍ណា ។
វីជយមង្គល ចូរមានដល់អ្នកវាល់គ្នា
ដោយតេជៈជយា ព្រះឈ្នះអង្គុលីមាល ។

៥- កត្វានកដ្ឋមុទរំ ឥវ គព្ភិនីយា
ចិញ្ចាយ ទុដ្ឋវចនំ ជនកាយមជ្ឈេ
សន្តេន សោមវិធិនា ជិតវា មុនិន្ទោ
តន្តេជសា តវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទមានព្រះភាគ ផ្ចាញ់ទ្រុះពាក្យនាងចិញ្ចា
អំពើធ្វើដូចជា ស្រីមានគភ៌ចាស់ចើសពោះ ។
យកឈើធ្វើជាកូន ព័ន្ធពោះខ្លួនពោលទ្រគោះ
ព្រះពុទ្ធឈ្នះកាលនោះ ដោយសមាចារពិធី ។
រំងាប់ពាក្យចណ្ឌាល នាកណ្តាលជនប្រុសស្រី
ចិញ្ចាចាញ់បារមី គឺសច្ចំពាក្យសត្យា ។
វីជយមង្គល ចូរមានដល់អ្នកវាល់គ្នា
ដោយតេជៈជយា ព្រះសាស្តាឈ្នះចិញ្ចា ។

៦- សច្ចំ វិហាយមតិសច្ចកវាទកេតុំ
វាទាភិរោបិតមនំ អតិអន្ធភូតំ

បញ្ញាបនីបជលិតោ ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទពិនអ្នកប្រាជ្ញ រុងរឿងស្វាចដោយបញ្ញា
ផ្ចាញ់សច្ចក:ជា- និគ្រន្ថក្រៅពុទ្ធវេនេយ្យ ។
អធ្យាស្រ័យលះបង់ ពាក្យសត្យត្រង់តាមគាប់ចៃ
សរសើរខ្លួនឯងក្រៃ លើកកម្ពស់ដូចដងទង់ ។
បង្កើតមោហ៍ងងឹត ដោយពោលឥតពាក្យទៀងត្រង់
ព្រះទ្រង់កម្ចាត់បង់ ដោយប្រទីបគឺបញ្ញា ។
វីជយមង្គល ចូរមានដល់អ្នករាល់គ្នា
ដោយតេជះជយា ព្រះឈ្នះសច្ចក:និគ្រន្ថ ។

៧- ឧន្មោបឧន្មុជគំ វិពុធំ មហិទ្ធឹ
បុត្តេន ថេរភុជគេន ឧមាបយន្តោ
ឥទ្ធបទេសវិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទពិនទ្រង់ញាណ ញុំាងមោគ្គល្លានមានអំណាច
ឱ្យប្លែងជានាគរាជ ទៅទូន្មានព្យសន៍កុជង្គ ។
ឈ្មោះនន្ទោបនន្ទ ចិត្តមោហន្ធរឿងរឹទ្ធិវង្គ
ទិដ្ឋិកាចទ្រនង់ ទ្រង់ផ្ចាញ់ដោយពិធីឈាន ។
គឺឱ្យឧបទេស រឹទ្ធិវិសេសដល់មោគ្គល្លាន

រីទ្ធិនាគអន្តរធាន ខិនចុះចាញ់ព្រះចេស្តា ។
រីជយមង្គល ចូរមានដល់អ្នកវាល់គ្នា
ដោយតេជៈជយា ព្រះកគវាឈ្នះនាគហោង ។

៨-ឯគ្គាហទិដ្ឋិភុជគេន សុទន្ថហត្តំ
ព្រហ្មំ ទិសុទ្ធិជុតិមិទ្ធិពកាភិធានំ
ញាណាគទេន ទិធិនា ជិតវា មុនិន្ទោ
តន្តេជសា ភវតុ តេ ជយមង្គលានិ

ព្រះមុនិន្ទពិនគោតម ផ្ចាញ់មហាព្រហ្មឈ្មោះពកា
សម្គាល់ថាអាត្មា រុងរឿងដោយគុណបរិសុទ្ធ ។
ដៃកាន់អាសិវិស គឺចិត្តទ្រឹស្តិដ៏មោះមុត
កាន់ខុសផ្លូវសម្ពុទ្ធ មិនលើកលាកលះបង់ច្រាណ ។
ទ្រង់ឈ្នះដោយពិធី ខិសថវិសេសសម្រាន្ត
ផ្សំត្រូវគាប់សន្តាន គឺព្រះញាណច្រាសទេសនា ។
រីជយមង្គល ចូរមានដល់អ្នកវាល់គ្នា
ដោយតេជៈជយា ឈ្នះព្រហ្មឥតមានហ្មង ។

ឯតាបិ ពុទ្ធជយមង្គលអដ្ឋគាថា
យោ ខាចនោ ទិនទិនេ សរតេ មតន្ទី
ហិត្វានវេកវិវិធានិ ចុបទ្ទវានិ
មោក្ខំសុខំ អធិគមេយ្យ នរោ សបញ្ញោ

យោន ពោ ជនឯណា កបបញ្ញាប្រាសក្តីខ្ជិល
ឧស្សាហ៍សាងទានសីល សូធ្យរំឭកព្រះធម៌ថ្ងៃ ។
គាថាប្រាំបីបទ នេះកំណត់ឈ្មោះពុទ្ធជ័យ
ខំសូធ្យសឭៗ ថ្ងៃ កើតមង្គលជានិរន្តរ៍ ។
សោ នពោ រីជននោះ បានរដោះពោគអាសន្ន
ឧបទ្រពអនេកលន់ មានប្រការផ្សេងៗ ផង ។
នឹងដល់ធម៌ក្សេមក្សាន្ត គឺនិព្វានសុខកន្ទង
លែងទុក្ខទាំងបួនកង ដោយពុទ្ធជ័យមង្គលនេះ ។

ចប់ ពុទ្ធជ័យមង្គលគាថាតែប៉ុណ្ណោះ

(ឧកញ៉ាសុត្តន្តប្រីជាឥន្ត ប្រែចេញពីបាលី ហើយចងក្រងជាពាក្យកាព្យ
ពិនិដោយ ព្រះសង្ឃសត្ថា ជួន-ណាត និងព្រះគ្រូវិមលបញ្ញោ អ៊ុម-ស៊ូរ)

ការឧសុត្តគាថា

(បិដកលេខ ៣០ ទំព័រ ៣៥)

យេ ច អតីតា សម្ពុទ្ធា យេ ច ពុទ្ធា អនាគតា
យោ ចេតរហិ សម្ពុទ្ធោ ពហុន្នំ សោកនាសនោ

ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលបានត្រាស់កន្ទងហួសទៅហើយ ក្តី ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គឯណា ដែលមិនទាន់បានត្រាស់ក្តី ព្រះសម្មា-

សម្ពុទ្ធអង្គឯណា ជាអ្នកញុំាងសេចក្តីសោករបស់ជនទាំងឡាយច្រើនឱ្យវិនាសទៅ (មាន) ក្នុងកាលឥឡូវនេះក្តី

សព្ពេ សទ្ធម្មគរុនោ *ព្រះសម្មាសម្ពុទ្ធ (ទាំងឡាយនោះ) គ្រប់ព្រះអង្គ សុទ្ធតែមានសេចក្តីគោរពចំពោះព្រះសទ្ធម្ម*

វិហរឹសុ វិហរន្តិ ច *ព្រះអង្គគង់នៅរួចទៅហើយក្តី គង់នៅក្នុងកាលឥឡូវនេះក្តី*

អថាបិ វិហរិស្សន្តិ *នឹងគង់នៅតទៅទៀតក្តី*

ឯសា ពុទ្ធាន ធម្មតា *កិរិយាបែបនេះ ជាធម្មតារបស់ព្រះពុទ្ធទាំងឡាយ*

តស្មា ហិ អត្តកាមេន មហត្តមភិកង្ខតា
សទ្ធម្មោ គរុកាតព្ពោ សរំ ពុទ្ធានសាសនំ

ក៏ព្រោះហេតុដូច្នោះ បុគ្គលអ្នកស្រឡាញ់នូវខ្លួន អ្នកប្រាថ្នានូវភាវៈជាធំ កាលរឭកឃើញនូវពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ គួរតែធ្វើនូវសេចក្តីគោរពចំពោះព្រះសទ្ធម្ម។

ភាសិតោទានវណ្ណនា

ឱកាស *ខ្ញុំសូមគោរព !*

យោ បន[1] ធម្មានុធម្មប្បដិបន្នោ វិហរតិ សាមីចិប្បដិបន្នោ អនុធម្មចារី

១-ច្បាប់ភាណវារៈខ្លះថា **យោ បន ភិក្ខុ**, ច្បាប់ខ្លះមានត្រឹមតែប៉ុណ្ណេះ ។

សោ តថាគតំ សក្ករោតិ គរុករោតិ មានេតិ បូជេតិ បរមាយ បូជាយ បដិបត្តិ បូជាយ ។

អ្នកឯណាមួយ ជាអ្នកប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ជាអ្នកប្រតិបត្តិដោយត្រឹមត្រូវ ជាអ្នកប្រតិបត្តិតាមធម៌ជាប្រក្រតី អ្នកនោះឈ្មោះថា ធ្វើសក្ការៈ ធ្វើសេចក្តីគោរពរាប់អាន បូជានូវព្រះតថាគត ដោយបដិបត្តិបូជា ជាបូជាដ៏ឧត្តម[1] ។

សព្វបាបស្ស អករណំ កុសលស្សូបសម្បទា
សចិត្តបរិយោទបនំ ឯតំ ពុទ្ធាន សាសនំ

កិរិយាមិនធ្វើនូវបាបទាំងពួង កិរិយាបំពេញកុសល កិរិយាធ្វើចិត្តរបស់ខ្លួនឱ្យផូរផង់ ទាំងនេះជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ ។

ខន្តិ បរមំ តបោ តីតិក្ខា
និព្វានំ បរមំ វទន្តិពុទ្ធា
ន ហិ បព្វជិតោ បរូបឃាតី
សមណោ ហោតិ បរំ វិហេឋយន្តោ

អំណត់ គឺសេចក្តីអត់ធន់ ជាតបធម៌ដ៏ឧត្តម ព្រះពុទ្ធទាំងឡាយទ្រង់ត្រាស់ថា ព្រះនិព្វានជាគុណជាតដ៏ឧត្តម អ្នកបួសដែលបៀតបៀនសត្វដទៃ សម្លាប់សត្វដទៃ មិនមែនជាបព្វជិត មិនមែនជាសមណៈឡើយ ។

អនូបវាទោ អនូបឃាតោ បាដិមោក្ខេ ច សំវរោ
មត្តញ្ញុតា ច ភត្តស្មិំ បន្តញ្ច សយនាសនំ
អធិចិត្តេ ច អាយោគោ ឯតំ ពុទ្ធាន សាសនំ[2]

១-បិដកលេខ ១៦ ទំព័រ ២៩១ ។ ២-បិដកលេខ ១៦ ទំព័រ ១០៣ និងលេខ ៥២ ទំព័រ ៦០។

កិរិយាមិនតិះដៀល (អ្នកដទៃ) ១ កិរិយាមិនបៀតបៀន (អ្នកដទៃ) ១ កិរិយាសង្រួមក្នុងបាដិមោក្ខ ១ ភាវៈដឹងប្រមាណក្នុងភត្តាហារ ១ ទីដេកនិងទីអង្គុយដ៏ស្ងាត់ ១ កិរិយាបំពេញព្យាយាមក្នុងអធិចិត្ត ១ ទាំងនេះ ជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ ។

សីលសមាធិគុណានំ ខន្តិបធានការណំ
សព្ពេបិ កុសលា ធម្មា ខន្ត្យាយេវ វឌ្ឍន្តិ តេ

សេចក្តីអត់ធន់ ជាហេតុ ជាទីតាំងនៃគុណ គឺសីល និងសមាធិទាំងឡាយ ធម៌ទាំងឡាយជាកុសលទាំងអស់នោះ តែងចម្រើនដោយសេចក្តីអត់ធន់មែនពិត។

កេវលានំបិ បាបានំ ខន្តិ មូលំ និកន្តតិ
គរហេកលហានីនំ មូលំ ខណតិ ខន្តិកោ

សេចក្តីអត់ធន់ តែងកាត់បង់បាននូវឫសនៃបាបទាំងឡាយទាំងអស់ បុគ្គលអ្នកអត់ធន់ ឈ្មោះថាជីករំលើងនូវឫសនៃទោសទាំងឡាយ មានពាក្យតិះដៀលនិងការឈ្លោះប្រកែកជាដើម ។

ខន្តិ ធីរស្សលង្ការោ ខន្តិ តបោ តបស្សិនោ
ខន្តិ ពលំវ យតីនំ ខន្តិ ហិតសុខាវហា

សេចក្តីអត់ធន់ ជាគ្រឿងអលង្ការរបស់អ្នកប្រាជ្ញ សេចក្តីអត់ធន់ជាគ្រឿងដុតបង់នូវបាបរបស់អ្នកដែលមានតបធម៌ សេចក្តីអត់ធន់ ជាកម្លាំងរបស់អ្នកប្រព្រឹត្តធម៌ សេចក្តីអត់ធន់ ជាគុណជាតនាំមកនូវប្រយោជន៍ និងសេចក្តីសុខ ។

ខន្តិកោ មេត្តវា លោកេ យសស្សី សុខសីលវា

បិយោ ទេវមនុស្សានំ មនាបោហោតិ ខត្តិកោ

អ្នកអត់ធន់ ជាអ្នកមានមិត្រសម្លាញ់ ជាអ្នកមានលាភ ជាអ្នកមានយស ជាអ្នកមានសេចក្តីសុខជាប្រក្រតី អ្នកអត់ធន់ រមែងជាទីស្រឡាញ់ ជាទីគាប់ចិត្ត នៃទេវតា និងមនុស្សទាំងឡាយ។

អត្តនោបិ បរេសញ្ច អត្ថាវហោវ ខត្តិកោ

សគ្គមោក្ខគមំ មគ្គំ អារុឡ្ហោហោតិ ខត្តិកោ

អ្នកអត់ធន់ ជាអ្នកនាំមកនូវប្រយោជន៍ដល់ខ្លួនផង ដល់ជនទាំងឡាយឯទៀតផង អ្នកអត់ធន់ ជាអ្នកឡើងកាន់ផ្លូវជាទីទៅឋានសួគ៌ និងព្រះនិព្វាន។

សត្តោ ឥចនោនាមំ ករោតិយេវ ខត្តិកោ

បរោយ ច បូជាយ ជីនំ បូជេតិ ខត្តិកោ

អ្នកអត់ធន់ ឈ្មោះថាធ្វើតាមនូវព្រះពុទ្ធដីកា ជាឱវាទនៃព្រះសាស្តាមែនពិត អ្នកអត់ធន់ ឈ្មោះថាបូជានូវព្រះវិជិតមារ ដោយការបូជាដ៏ឧត្តម។

ទុល្លភញ្ច មនុស្សត្តំ ពុទ្ធុប្បាទោ ច ទុល្លភោ

ទុល្លភា ខណសម្បត្តិ សទ្ធម្មោ បរមទុល្លភោ

ភាវៈកើតជាមនុស្ស គឺសត្វទាំងឡាយបានដោយកម្រ កិរិយាត្រាស់ជាព្រះពុទ្ធ គឺសត្វទាំងឡាយបានដោយកម្រ កិរិយាដល់ព្រមដោយខណៈ គឺបានកើតជួបនឹងព្រះពុទ្ធ ឬនឹងព្រះពុទ្ធសាសនា គឺសត្វទាំងឡាយបានដោយកម្រ ធម៌របស់សប្បុរស គឺសត្វទាំងឡាយបានដោយកម្រក្រៃលែង។

សុខោ ពុទ្ធានមុប្បាទោ សុខា សទ្ធម្មទេសនា

សុខា សច្ឆវស្ស សាមគ្គី សមគ្គានំ តបោ សុខោ

កិរិយាបានត្រាស់នៃព្រះពុទ្ធទាំងឡាយ នាំមកនូវសេចក្តីសុខ កិរិយាសម្តែងនូវធម៌របស់សប្បុរស នាំមកនូវសេចក្តីសុខ សេចក្តីព្រមព្រៀងគ្នារបស់សង្ឃ ឬពួកក្រុម នាំមកនូវសេចក្តីសុខ សេចក្តីព្យាយាមរបស់អ្នកដែលព្រមព្រៀងគ្នាទាំងឡាយ នាំមកនូវសេចក្តីសុខ[1] ។

សុខោ វិវេកោ តុដ្ឋស្ស សុតធម្មស្ស[2] បស្សតោ
អព្យាបជ្ជំ សុខំ លោកេ បាណភូតេសុ សញ្ញមោ

សេចក្តីស្ងប់ស្ងាត់ចាកកិលេស របស់អ្នកដែលត្រេកអរ (ដោយមគ្គញ្ញាណ) ជាអ្នកមានសច្ចធម៌ប្រាកដហើយ ពិចារណាឃើញ (នូវធម៌ដោយញាណ) នាំមកនូវសេចក្តីសុខ កិរិយាមិនបៀតបៀន និងកិរិយាសង្រួមចំពោះសត្វទាំងឡាយ នាំមកនូវសេចក្តីសុខក្នុងលោក ។

សុខា វិរាគតា លោកេ កាមានំ សមតិក្កមោ
អស្មិមានស្ស វិនយោ ឯតំ វេ បរមំ សុខំ

๑-បិដកលេខ ๕๒ ទំព័រ ๖๒ ។ ๒-បាទគាថា ថា “**សុតធម្មស្ស**” នេះ ក្នុងប្រជុំភាណវារៈចាស់លោកប្រែថា “ជាអ្នកមានធម៌បានស្តាប់ហើយ” តែអដ្ឋកថាពន្យល់ថា **សុតធម្មស្សាតិ បកាសិតធម្មស្ស** បទថា **សុតធម្មស្ស** បានដល់ ជាអ្នកមានធម៌ប្រាកដហើយ ។ សារត្ថទីបនីដីកាក៏ពន្យល់ដែរថា **សុតធម្មស្សាតិវិស្សុតធម្មស្ស ៗ តេនាហ “បកាសិតធម្មស្សា”តិ ៗ** បទថា **សុតធម្មស្ស** ប្រែថា អ្នកមានធម៌ប្រាកដហើយ ដូច្នោះទើបលោកពោលថា **បកាសិត** អ្នកមានធម៌ប្រាកដហើយ។ ក្នុងបាចិត្យាទិយោជនាបានបន្ថែមទៀតថា **សុតធម្មស្សាតិ ឯត្ថ សុតសទ្ទោ វិស្សុតបរិយាយោតិ វុត្តោ “បកាសិតធម្មស្សា”តិ, បាកដសច្ចធម្មស្សាតិ អត្ថោ** ។ បទថា **សុតធម្មស្ស** ក្នុងទីនេះ ប្រែថា ជាអ្នកមានធម៌ប្រាកដហើយ ព្រោះដូច្នោះទើបលោកពោលថា សេចក្តីថា **សុតធម្មស្ស** ព្រោះទ្រង់មានសច្ចធម៌ប្រាកដហើយ ។ ហេតុនេះទើបយើងសម្រេចប្រែជាថ្មីដើម្បីតម្រូវតាមអដ្ឋកថា និងដីកា ក្នុងបិដកក៏ប្រែយ៉ាងនេះដែរ ។

ការៈប្រាសចាកវាគៈ គឺកិរិយាកន្ធងនូវកាមទាំងឡាយ (ដោយអនាគាមិមគ្គ) នាំមកនូវសេចក្តីសុខក្នុងលោក កិរិយាធ្វើឱ្យវិនាសនូវអស្មិមានៈ (ដោយព្រះអរហត្តមគ្គ) នេះឯង នាំមកនូវសេចក្តីសុខដ៏ឧត្តម[1]។

កិច្ឆោ មនុស្សប្បដិលាភោ កិច្ឆំ មច្ចាន ជីវិតំ
កិច្ឆំ សទ្ធម្មស្សវនំ កិច្ឆោ ពុទ្ធានមុប្បាទោ

កិរិយាត្រឡប់បានអត្តភាពជាមនុស្ស ជាការលំបាក សេចក្តីរស់នៅរបស់សត្វទាំងឡាយ ជាការលំបាក កិរិយាស្តាប់នូវព្រះសទ្ធម្ម ជាការកម្រ កិរិយាបានត្រាស់នៃព្រះពុទ្ធទាំងឡាយ ជាការលំបាក[2]។

សត្តានោ សទ្ធម្មំ សុត្វា សព្វេ្ចំ ជិនសាសនេ
កប្បានិ សតសហស្សានិ ទុគ្គតឹ សោ ន គច្ឆតិ[3]

បុគ្គលឯណា បានស្តាប់នូវព្រះសទ្ធម្មរបស់ព្រះសាស្តា (ដែលរាប់បញ្ចូល) ក្នុងពាក្យប្រៀនប្រដៅនៃព្រះវិជិតមារទាំងពួង បុគ្គលនោះរមែងមិនទៅកាន់ទុគ្គតិអស់សែននៃកប្ប។

បុព្វណ្ហេ បិណ្ឌបាតញ្ច សាយណ្ហេ ធម្មទេសនំ
បទោសេ តិក្ខត្តិំ អត្តរត្តេ ទេវបញ្ហានំ
បច្ចូសេវ គតេ កាលេ តញ្ចតញ្ចេ ទិលោកនំ
ឯតេ បញ្ចវិធេ កិច្ចេ ទិសោធេតិ មុនិបុង្គវោតិ

១-បិដកលេខ ៦ ទំព័រ ១០ និងលេខ ៥២ ទំព័រ ១៣៤។ ២-បិដកលេខ ៥២ ទំព័រ ៦០។ ៣-ខ្ញុំស្វែងរកក្នុងច្បាប់ឆដ្ឋសង្គាយនា មិនបានឃើញទីមកនៃគាថានេះឡើយ គាថានេះទំនងជាគេតែងជាខាងក្រោយទេ?, ឯសេចក្តីក្នុងគាថានេះក៏មិនមែនយ៉ាងនោះដោយចំណែកមួយដែរ។ ឯចំណែកត្រង់បាទទី ៣ ជារូបសព្ទដែលគួរពិចារណា។

ព្រះសម្មាសម្ពុទ្ធជាចម្បងជាងអស់អ្នកប្រាជ្ញ ទ្រង់ជម្រះនូវពុទ្ធកិច្ចទាំង៥ប្រការ នេះ គឺក្នុងពេលព្រឹក ទ្រង់ស្តេចទៅបិណ្ឌបាត ១ ក្នុងពេលល្ងាចទ្រង់សម្តែងធម៌ទេសនា ១ ក្នុងពេលព្រលប់ ទ្រង់ប្រទានឱវាទដល់ពួកភិក្ខុ ១ ក្នុងពេលអធ្រាត្រ ទ្រង់ដោះប្រស្នានៃទេវតា ១ ក្នុងពេលជិតភ្លឺ[1] ទ្រង់ប្រមើលមើលនូវសត្វលោកដែលគួរត្រាស់ដឹង និងមិនគួរត្រាស់ដឹង ១ ។

កុក្កុដេ គព្ភវាសោ ច សោឡេ ចុទនិក្កមិ
ទ្វាសត្តេ រាជសម្បត្តិ សត្តេ បព្ជិតោ ជិនោ

ព្រះវិជិតមារ ទ្រង់យាងចុះមកអាស្រ័យនៅក្នុងព្រះគភ៌(នៃព្រះវរមាតា) ក្នុងឆ្នាំរកា ទ្រង់ប្រសូតចាកព្រះគភ៌ក្នុងឆ្នាំច ទ្រង់សោយរាជសម្បត្តិក្នុងឆ្នាំឆ្លូវ ទ្រង់ព្រះផ្នួសក្នុងឆ្នាំថោះ ។

កុក្កុដេ សព្ពញ្ញូ ពុទ្ធោ តត្ត ចក្កំបវត្តយិ
និព្វានគមនំ សប្បេ សហស្សំបញ្ច មូសិកេ

ទ្រង់ត្រាស់ដឹងជាព្រះសព្វញ្ញុពុទ្ធក្នុងឆ្នាំរកា ទ្រង់សម្តែងនូវព្រះធម្មចក្រក្នុងឆ្នាំនោះ ទ្រង់យាងចូលកាន់ព្រះនិព្វានក្នុងឆ្នាំម្សាញ់ ព្រះពុទ្ធសាសនានឹងគ្រប់ ៥០០០ គត់ក្នុងឆ្នាំជូត ។

ឱក្កន្តោ ច គរុវារស្មិំ សុក្កវារេ ច និក្ខមិ
សម្ពុទ្ធោ ពុធវារស្មិំ អង្គារេ បរិនិព្វុតោ

១-ក្នុងអដ្ឋកថាធម្មបទសម្តែងថា ព្រះអង្គប្រមើលមើលឧបនិស្ស័យសត្វក្នុង ១ ថ្ងៃ ១ យប់ពីរដង គឺក្នុងពេលជិតភ្លឺម្តង ពេលល្ងាចម្តង, ពេលជិតភ្លឺ ទ្រង់ប្រមើលមើលពីកណ្តាប់មាត់ចក្រវាលរហូតដល់មកគន្ធកុដិ, ពេលល្ងាច ទ្រង់ប្រមើលមើលពីគន្ធកុដិរហូតដល់កណ្តាប់មាត់ចក្រវាល ។

ទ្រង់យាងចុះកាន់ព្រះគភ៌ (នៃព្រះវរមាតា) ក្នុងថ្ងៃព្រហស្បតិ៍ ប្រសូតក្នុងថ្ងៃសុក្រ បានត្រាស់ជាព្រះសម្ពុទ្ធក្នុងថ្ងៃពុធ បរិនិព្វានក្នុងថ្ងៃអង្គារ ។

អាសាឡ្ហបុណ្ណមោក្កន្តោ វិសាខេយេវ និក្ខមិ
វិសាខបុណ្ណមី សម្ពុទ្ធោ វិសាខេ បរិនិព្វុតោ

ព្រះអង្គយាងចុះកាន់ព្រះគភ៌ (នៃព្រះវរមាតា) ក្នុងថ្ងៃពេញបូណ៌មីខែអាសាធ ប្រសូតក្នុងថ្ងៃពេញបូណ៌មីខែវិសាខ បានត្រាស់ជាព្រះសម្ពុទ្ធក្នុងថ្ងៃពេញបូណ៌មីខែវិសាខ បរិនិព្វានក្នុងថ្ងៃពេញបូណ៌មីខែវិសាខ ។

និព្វុតេ លោកនាថម្ហិ សម្ពុទ្ធេ អគ្គបុគ្គលេ
បដិមា ពោធិរុក្ខា ច ថូបា ច ជិនធាតុយោ
ចតុរាសីតិសហស្ស- ធម្មក្ខន្ធា សុទេសិតា
អគ្គប្បវត្តនដ្ឋានេ ឋបិតា ហោន្តិ ឋានិនំ

កាលព្រះសម្មាសម្ពុទ្ធ ជាអគ្គបុគ្គល ជាទីពឹងនៃសត្វលោក បរិនិព្វានទៅហើយ ព្រះបដិមាផង ពោធិព្រឹក្សផង ព្រះស្តូបផង ព្រះជិនធាតុផង ព្រះធម៌ ៨ មឺន ៤ ពាន់ធម្មក្ខន្ធ ដែលព្រះអង្គទ្រង់សម្តែងហើយដោយប្រពៃផង ជាវត្ថុ គឺព្រះសម្មាសម្ពុទ្ធទ្រង់ប្រតិស្ឋានទុកក្នុងឋានដ៏ប្រព្រឹត្តទៅ ដើម្បីជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វទាំងឡាយ ។

ឥតិ សម្មាសម្ពុទ្ធេន ទេសិតំ ឱវាទំ ចិត្តេ ឋបេត្វា សម្មាសម្ពុទ្ធេន ពុទ្ធប្បការេន បដិបត្តិបូជាយ បូជំ ករោន្តេន លោកិយ លោកុត្តរសម្បត្តិសិទ្ធិំ ភាតព្វំ ខ្វាសរ អារាធនំ ករោមិ បុគ្គលគួរតម្កល់នូវឱវាទ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែង

ហើយទុកក្នុងចិត្ត ហើយធ្វើការបូជា ដោយបដិបត្តិបូជា ដោយនូវប្រការដែលព្រះសម្មាសម្ពុទ្ធត្រាស់សម្តែងហើយ គួរធ្វើឱ្យសម្រេចនូវសម្បត្តិជាលោកិយៈ និងលោកុត្តរៈ ខ្ញុំសូមគោរពអាពាធនាទុកដោយប្រការដូច្នេះ ។

ឯកាស សិរីសក្យមុនិសព្វញ្ញាពុទ្ធស្ស ពលវប្បច្ចូសសមយេ កុសិនារាយ យមកសាលានមន្តរេ អមុម្ហិ សប្បសំវច្ឆរេ គិម្ហឯតុម្ហិ វិសាខមាសេ សុក្កបក្ខេ បណ្ណរសិយា តិថិយំ តុម្ហភារេ តុម្ហយាមេ អនុរាធនក្ខត្តនិវសេ បរិនិព្វានំអហោសិ អនុបាទិសេសាយ និព្វានធាតុយា *ខ្ញុំសូមគោរព សម្តេចព្រះសិរីសក្យមុនីសព្វញ្ញុពុទ្ធជាម្ចាស់ ទ្រង់បរិនិព្វានហើយ ដោយអនុបាទិសេសនិព្វានធាតុ ក្នុងចន្លោះដើមសាលព្រឹក្សទាំងគូ ជិតក្រុងកុសិនារា ក្នុងបច្ចូសសម័យដ៏មានកម្លាំង ក្នុងថ្ងៃនៃនក្ខត្តឫក្សឈ្មោះអនុរាធា ក្នុងថ្ងៃអង្គារ យាមអង្គារ ជាតិបីពេញបូណ៌មីខាងខ្នើត ខែវិសាខ ក្នុងគិម្ហរដូវ ឆ្នាំម្សាញ់ឯណោះហោង ។*

វិធីបកសរាជ

ឯកាស សិរីសក្យមុនិសព្វញ្ញាពុទ្ធស្ស ពលវប្បច្ចូសសមយេ កុសិនារាយ យមកសាលានមន្តរេ អមុម្ហិ សប្បសំវច្ឆរេ គិម្ហឯតុម្ហិ វិសាខមាសេ សុក្កបក្ខេ បណ្ណរសិយា តិថិយំ តុម្ហភារេ តុម្ហយាមេ អនុរាធនក្ខត្តនិវសេ បរិនិព្វានំអហោសិ អនុបាទិសេសាយ និព្វានធាតុយា ៚

សូមគោរពរំឭកដល់កាលដែលព្រះសក្យមុនីសព្វញ្ញុពុទ្ធ ទ្រង់មានសិរី ព្រះអង្គចូលបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ ក្នុងថ្ងៃប្រកបដោយអនុរាធន-

ក្នុត្តឫក្ស នាថ្ងៃអង្គារ យាមអង្គារ នៅថ្ងៃ ១៥ កើត ខែពិសាខ ក្នុងគិម្ហរដូវ ឆ្នាំម្សាញ់ ឯណោះ ក្រោមចន្ទោះដើមសាលព្រឹក្សទាំងគូ (នាសាសលវ័នឧទ្យាន) ជិតក្រុងកុសិនារ ក្នុងសម័យជិតភ្លឺ ។

តស្ស ភគវតោ សម្មាសម្ពុទ្ធស្ស បរិនិព្វុតទិវសតោ បដ្ឋាយ យាវជ្ជតនា *រាប់ចាប់ដើមតាំងអំពីថ្ងៃដែលព្រះសម្មាសម្ពុទ្ធដ៏មានព្រះភាគអង្គនោះ ទ្រង់ចូលបរិនិព្វានទៅដរាបមកដល់ថ្ងៃនេះ ព្រះពុទ្ធសករាជព្រះសាសនាកន្លងទៅហើយបាន (.....) ឆ្នាំ និង (.....) ខែ (.....) ថ្ងៃ ។*

ឥមស្មឹ បច្ចុប្បន្នកាលេ *ឥឡូវនេះ ឆ្នាំ..... .....ស័ក .....រដូវ ខែ..... ..... ពោធ ឬខ្នើត ថ្ងៃ..... (ថ្ងៃ ខែ ឆ្នាំនេះ ជាបច្ចុប្បន្នកាល) ។*

អនាគតេ កាលេ *ឯព្រះពុទ្ធសាសនកាលចំណែកខាងអនាគត នៅសល់.....ឆ្នាំ និង.....ខែ .....ថ្ងៃ រួបរួមថ្ងៃ ខែ ឆ្នាំទាំងបីកាលចូលគ្នា ត្រូវជាព្រះពុទ្ធសាសនកាល ៥០០០ វស្សាដោយបរិបូណ៌ ។*

ពាក្យសម្រាប់ក្រើនរកឋិនទី ១

ភន្តេ *បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើន រីអង្គកឋិនទាននេះ ជារបស់អស់លោកអ្នកពុទ្ធបរិស័ទសប្បុរសទាំងឡាយ.....ជាប្រធាន, សុទ្ធសឹងតែជាពុទ្ធមាមកជនប្រកបដោយបសាទសទ្ធា និងកុសលចេតនាជាអស្ឋារិក ជ្រះថ្លាចំពោះគុណព្រះរតនត្រ័យ បានបំពេញនូវបុញ្ញកិរិយាវត្ថុ ចេះលែលកយកធន*

ជានដែលគ្មានខ្វឹមសារ ធ្វើឱ្យជារបស់មានខ្វឹមសារ កប់ទុកក្នុងព្រះពុទ្ធសាសនា ដើម្បីជាទ្រព្យមត៌កសម្រាប់ប្រើប្រាស់ទៅក្នុងភពខាងមុខទៀត បានស្រុះស្រួលបបួលគ្នាផ្ចងផ្តើមបង្កើតជាអង្គកឋិនទាននេះឡើង ព្រមទាំងហែហមដ៏ជាឱឡារិកគគ្រឹកគគ្រេងតាមមាគ៌ា ដើម្បីនឹងយកមកវេរថ្វាយព្រះសង្ឃដែលគង់ចាំវស្សាអស់ត្រៃមាសក្នុងទីវត្ត.....នេះ ហាក់ដូចជាសំពត់កោសេយ្យពស្ត្រអណ្តែតត្រសែតឰដ៏អាកាសវេហានកាល័យ ហើយធ្លាក់ចុះមកក្នុងកណ្តាលជំនុំសង្ឃ ជាសង្ឃទានស្មោះ, ឥតមានចំពោះព្រះករុណាអង្គណាមួយឡើយ។

ហេតុនេះហើយ បើព្រះករុណាអង្គណា មានត្រៃចីវរទុព្វលភាពដាច់ដាច មិនអាចនឹងប្រើប្រាស់បាន ហើយចេះនូវអានិសង្ស ៥ ចាំនូវមាតិកា ៨ បលិពោធ ២ អនត្តតាការៈ ២ អត្តតាការៈ ១៧ អាចញុំាងសង្ឃឱ្យត្រេកអរដោយកឋិនត្តារកិច្ចបានក៏សូមមានព្រះថេរដីកាឆ្វើយមកចុះ, ព្រះសង្ឃនឹងប្រគល់សំពត់កឋិននេះដល់ព្រះករុណាអង្គនោះដោយញត្តិទុតិយកម្មវាចាក្រាលគ្រងតទៅ។

(កិក្ខុទី ១ ប្រកាសសង្ឃចប់ហើយត្រូវឈប់បង្អង់ ២-៣ នាទីសិន សឹមកិក្ខុទី ២ ប្រកាសសង្ឃតទៅទៀត)

ពាក្យសម្រាប់ក្រើនកឋិនទី ២

ភន្តេ បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើន ខ្ញុំព្រះករុណាជាអ្នកដំណាងព្រះសង្ឃគ្រប់អង្គក្នុងឱកាសនេះ សូមពិត្រព្រះថេរដីកាចំពោះព្រះសង្ឃគ្រប់ព្រះអង្គ

សូមទានជ្រាប ។

យើងខ្ញុំទាំងអស់ សុទ្ធសឹងតែមានត្រៃចីវរល្មមគ្រប់គ្រាន់ប្រើប្រាស់ហើយ ប៉ុន្តែតាមយោបល់របស់ខ្ញុំព្រះករុណាយល់ឃើញតែព្រះ.....ទើបសមគួរនឹងក្រាលគ្រងនូវសំពត់កឋិននេះ ដោយលោកជាអ្នកចេះនូវអានិសង្ស ៥ ចាំនូវមាតិកា ៨ បលិពោធ ២ អនត្តតាការៈ ២៤ អត្តតាការៈ ១៧ ហើយឆ្លៀវឆ្លាតក្នុងកឋិនត្ថារកិច្ច អាចញុំាងសង្ឃឱ្យត្រេកអរបាន ។

ហេតុនេះហើយ បើព្រះសង្ឃគ្រប់អង្គយល់ឃើញថា សមគួរដូចជាបកាសនវាចាដែលខ្ញុំព្រះករុណាបានថ្លែងមកនេះ ក៏សូមបញ្ចេញនូវសទ្ទសញ្ញាថាសាធុឱ្យព្រមៗ គ្រប់ព្រះអង្គទៅហោង ។

បាលីសម្រាប់សូធ្យប្រគល់សំពត់កឋិន

សុណាតុ មេ ភន្តេ សង្ឃោ ឥទំ សង្ឃស្ស កឋិនទុស្សំ ទ្វប្បន្នំ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥមំ កឋិនទុស្សំ[1] (ឥត្ថន្នាមស្ស)[2] តិក្ខត្តុំ ទទេយ្យ កឋិនំ អត្ថរិតុំ ។ ឯសា ញត្តិ ។

សុណាតុ មេភន្តេ សង្ឃោ ឥទំ សង្ឃស្ស កឋិនទុស្សំ ទ្វប្បន្នំ ។ សង្ឃោ ឥមំ កឋិនទុស្សំ (ឥត្ថន្នាមស្ស) តិក្ខត្តុំ ទេតិ កឋិនំ អត្ថរិតុំ ។ យស្សាយស្មតោ ខមតិ ឥមស្ស កឋិនទុស្សស្ស (ឥត្ថន្នាមស្ស) តិក្ខត្តុំ ទានំ កឋិនំ អត្ថរិតុំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទិន្នំ ឥទំ សង្ឃេន កឋិនទុស្សំ

១-បាលីថា **ចីវរំ, ទុស្សំ, វត្ថំ** ប្រែថា សំពត់ដូចគ្នា។ ២-បាលីត្រង់នេះ ត្រូវផ្លាស់ដាក់នាមរបស់ភិក្ខុអ្នកក្រាលឱ្យរាល់បទ ។

(ឥត្ថន្នាមស្ស) ភិក្ខុនោ កឋិនំ អត្ថរិតុំ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ[1] ។

បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ សំពត់កឋិននេះកើតឡើងដល់សង្ឃហើយ។ បើ (ការនេះ) មានកាលគួរដល់សង្ឃហើយសង្ឃគួរឱ្យសំពត់កឋិននេះទៅភិក្ខុ (ឈ្មោះនេះ) ដើម្បីក្រាលកឋិន។ នេះជាពាក្យផ្តៀងសង្ឃ។

បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ពាក្យខ្ញុំ សំពត់កឋិននេះកើតឡើងដល់ព្រះសង្ឃហើយ ។ (ឥឡូវនេះ) សង្ឃឱ្យសំពត់នេះទៅភិក្ខុ (ឈ្មោះនេះ) ដើម្បីក្រាលកឋិន ការដែលឱ្យសំពត់កឋិនទៅភិក្ខុឈ្មោះនេះ ដើម្បីក្រាលកឋិន គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះ ត្រូវនិយាយឡើង។ សំពត់កឋិននេះ សង្ឃឱ្យទៅភិក្ខុ (ឈ្មោះ)នេះ ដើម្បីក្រាលកឋិន។ (ការនេះ) គួរដល់សង្ឃហើយ ព្រោះហេតុនោះ បានជាសង្ឃស្ងៀម ខ្ញុំសូមចាំទុកនូវការនេះ ដោយអាការដែលសង្ឃស្ងៀមយ៉ាងនេះ។

(កាលបើសង្ឃសូធ្យប្រគល់សំពត់កឋិន ដោយញត្តិទុតិយកម្មវាចាដូច្នេះហើយ, បើសំពត់កឋិននោះ ទាយកធ្វើបរិកម្មសម្រេចមកជាស្បង់ចីពរ សង្ឃាដិ រួចហើយ ភិក្ខុត្រូវការក្រាលដោយស្បង់ ឬចីពរ ឬសង្ឃាដិ គប្បីបច្ចុទ្ធរដកស្បង់ចីពរ សង្ឃាដិចាស់ចេញ ហើយធ្វើកប្បពិន្ទុ អធិដ្ឋានស្បង់ចីពរ សង្ឃាដិថ្មីឡើង)។

๑-វិនយបិដកលេខ ៨ ទំព័រ ៤។

ឯពិធីដកដូច្នេះ

ដកសង្ឃាដិថា: **ឥមំ សង្ឃាដឹ បច្ចុទ្ធរាមិ** *"អាត្មាអញដកនូវសង្ឃាដីនេះ" ។*

ដកឧត្តរាសង្គ:(ចីពរ)ថា: **ឥមំ ឧត្តរាសង្គំ បច្ចុទ្ធរាមិ** *"អាត្មាអញ ដកនូវឧត្តរាសង្គ:(ចីពរ) នេះ" ។*

ដកអន្តរវាសក:(សព្វង់) ថា: **ឥមំ អន្តរាវាសកំ បច្ចុទ្ធរាមិ** *"អាត្មាអញ ដកនូវអន្តរាវាសក:(សព្វង់)នេះ" ។*

ដកចីពរ-សព្វង់-សង្ឃាដិរួចហើយ ត្រូវធ្វើកប្បពិន្ទុចីវរឬ្ម ដែលបម្រុងក្រាលកឋិនោះ ត្រង់ជ្រុង ឬមុមចីពរ ដោយពណ៌ ៣ យ៉ាង ពណ៌ណាមួយដែលមានសម្តែងក្នុងសិក្ខាបទស្រាប់ ។(សូមមើលបិដកលេខ ៤ទំព័រ ២៣៨)

ឯពិធីពិន្ទុកប្បជ្ជូច្នេះ

ឥមំ ពិន្ទុកប្បំ ករោមិ *"អាត្មាអញ ធ្វើនូវពិន្ទុនេះ" ។ (តពីនេះ ត្រូវអធិដ្ឋានចីវរឡើង), វិធីអធិដ្ឋាននោះដូច្នេះ ៖*

អធិដ្ឋានសង្ឃាដិថា: **ឥមំ សង្ឃាដឹ អធិដ្ឋាមិ ។ ទុតិយម្បិ...។ តតិយម្បិ...។** *"អាត្មាអញអធិដ្ឋាននូវសង្ឃាដីនេះ ។... អស់វារៈពីរដងផង ...អស់វារៈបីដងផង"។*

អធិដ្ឋានឧត្តរាសង្គ:ថា: **ឥមំ ឧត្តរាសង្គំ អធិដ្ឋាមិ ។ ទុតិយម្បិ . . ., តតិយម្បិ .... ។** *"អាត្មាអញ អធិដ្ឋាននូវចីពរនេះ ។... អស់វារៈពីរដងផង, ...អស់វារៈបីដងផង" ។*

អធិដ្ឋានអន្តរវាសក:ថា: **ឥមំ អន្តរាវាសកំ អធិដ្ឋាមិ ។ ទុតិយម្បិ . . ., តតិយម្បិ. . . ។** *"អាត្មាអញអធិដ្ឋាននូវស្បង់នេះ"។ ... អស់វារៈពីរដងផង, ...អស់វារៈបីដងផង" ។*

វិធីក្រាលកឋិន

កាលបើធ្វើអធិដ្ឋានរួចហើយ ត្រូវក្រាលកឋិនដោយចីវរណាមួយតាមត្រូវការ ហើយគប្បីបញ្ចេញវាចាឱ្យជំនុំសង្ឃបានឮច្បាស់។

បើចង់ក្រាលដោយសង្ឃដ៏ថា: **ឥមាយ សង្ឃាដិយា កឋិនំ អត្ថរាមិ** *"ខ្ញុំក្រាលកឋិនដោយសង្ឃាដីនេះ"។*

បើចង់ក្រាលដោយចីពរថា: **ឥមិនា ឧត្តរាសង្គេន កឋិនំអត្ថរាមិ** *"ខ្ញុំក្រាលកឋិនដោយចីពរនេះ" ។*

បើចង់ក្រាលដោយស្បង់ថា: **ឥមិនា អន្តរវាសកេន កឋិនំអត្ថរាមិ** *"ខ្ញុំក្រាលកឋិនដោយស្បង់នេះ" ។*

កាលបើភិក្ខុបានក្រាលកឋិនបែបនេះហើយ ត្រូវចូលទៅជិតសង្ឃ ឬគណៈ ឬបុគ្គល គ្រងចីពរអង្គុយច្រហោង ប្រណម្យអញ្ជលីឡើង ពោលប្រាប់ឱ្យលោកទាំងនោះអនុមោទនាថា:

អត្ថតំ អាវុសោ[1] សង្ឃស្ស កឋិនំ ធម្មិកោ កឋិនត្ថារោ អនុមោទថ[2]

១-បើភិក្ខុអ្នកក្រាលខ្ចីជាងត្រូវថា **ភន្តេ** ប្រែថា " បពិត្រលោកទាំងឡាយដ៏ចម្រើន" ។ ២-ពាក្យថា **អនុមោទថ** នេះសម្រាប់ប្រើជាមួយភិក្ខុចាស់ជាង ឬទោះខ្ចីជាងក៏ដោយ តែមានច្រើនរូបដ៏ដូចគ្នា, បើភិក្ខុអ្នកអនុមោទនាខ្ចីជាងហើយមានតែ ១ រូប ត្រូវថា **អនុមោទាហិ** ប្រែថា "ចូរលោកអនុមោទនា" ដូច្នេះ។

“ម្នាលលោកដ៏មានអាយុ កឋិនរបស់សង្ឃ ខ្ញុំបានក្រាលរួចហើយ ការក្រាលកឋិន (នេះ) ប្រកបដោយធម៌ សូមលោកទាំងឡាយ អនុមោទនាចុះ” ។


ចំណែកភិក្ខុអ្នកអនុមោទនាវិញត្រូវគ្រងចីពរធៀងស្មាងម្ខាងអង្គុយច្រហោងប្រណាម្យអញ្ជលីឡើងពោលអនុមោទនាថា:

“អត្តតំ តន្តេ(១) សង្ឃស្ស កឋិនំ ធម្មិកោ កឋិនត្ថារោ អនុមោទាម(២)

បពិត្រព្រះករុណាដ៏ចម្រើន កឋិនរបស់សង្ឃ លោកបានក្រាលហើយ ការក្រាលកឋិន (នេះ) ប្រកបដោយធម៌ យើងវាល់គ្នាសូមអនុមោទនា” ។

ប្រជុំភាណវារចារលី-ប្រែ និងសេចក្តីពន្យល់

ចប់



កែចប់ក្នុងថ្ងៃសៅរ៍ ១៥ កើត ខែអាសាធ ឆ្នាំវក នព្វស័ក ព.ស.២៥៦១
ត្រូវនឹងថ្ងៃទី ៨ ខែកក្កដា ឆ្នាំ ២០១៧

១-បើភិក្ខុអ្នកអនុមោទនាចាស់ជាងត្រូវថា **អាវុសោ** ប្រែថា “ ម្នាលលោកដ៏មានអាយុ ” ។ ២ -បើភិក្ខុអ្នកអនុមោទនាមានតែមួយរូបត្រូវថា **អនុមោទាមិ** ប្រែថា“ខ្ញុំសូមអនុមោទនា” ។

ឯកសារស្រាវជ្រាវ ពិគ្រោះ ជកស្រង់

-ប្រជុំភាណវារៈ បាលី-ប្រែ របស់បណ្ឌិត សែម-សូរ

-ប្រជុំភាណវារៈ បាលី-ប្រែ របស់បណ្ឌិត កៅ-ឈឺន

-ភាណវារបាលី របស់ពុទ្ធសាសនបណ្ឌិត្យ

-ភាណវារៈ កិច្ចវត្តព្រឹកល្ងាច របស់ព្រះធម្មប្បញ្ញា មាស-កន

-សត្តបរិត្ត-ទ្វាទសបរិត្ត របស់ព្រះវិសុទ្ធិវង្ស ហួត-តាត

-ព្រះបរិត្ត បាលី-ប្រែ របស់ធម្មានន្ទ វ៉ាន់-ចាន់សាវ៉ែន

-ចតុភាណវារ របស់ព្រះអនោមទស្សីថេរ ជនជាតិស្រីលង្កា (ជាភាសាថៃ)

មន្តពិធី របស់ព្រះគ្រូអរុណធម្មរង្សី (ភាសាថៃ)

ព្រះពុទ្ធមន្ត របស់ភិក្ខុមួយរូបនៅវត្តចាកដែង (ភាសាថៃ)

-ព្រះបរិត្តចាកព្រះត្រៃបិដក របស់ភិក្ខុមួយរូបនៅវត្តចាកដែង (ភាសាថៃ)

-ព្រះបរិត្តធម៌ របស់ព្រះគន្ធសារាភិវង្ស (ភាសាថៃ)

-អនុមោទនាវិធី រសប់លោកអាចារ្យ ប៉ែន-សុខ

-ប្រជុំពិធីបុណ្យ របស់ឧត្តមប្រីជា ចាប-ពិន

-អនុមោទនាវិធី របស់វត្តខៅសនាមឆែ (ភាសាថៃ)

-គិហិតបដិបត្តិ របស់ព្រះវិមលប្បញ្ញា អ៊ុំ-ស៊ូរ ព្រះគ្រូសង្ឃសត្ថា ជួន-ណាត

-គិហិតបដិបត្តិពិស្តារ របស់ព្រះគ្រូវិសុទ្ធិញ្ញាណ រស់-កែវ

-គិហិតបដិបត្តិពិស្តារ របស់បណ្ឌិត កៅ-ឈឺន

-កម្ពុជសុរិយា ក្បាលទី ៥ ឆ្នាំ ១៩២៦-២៧

-គ្រហស្ថជាសាវ័កល្អ របស់ព្រះភិក្ខុសុវណ្ណជោតោ ភួងសុវណ្ណ

-សាមណេរវិន័យ របស់ព្រះគ្រូសង្ឃសត្ថា ជួន-ណាត និងព្រះគ្រូសង្ឃវិជ្ជា ហួត-តាត

-អធិប្បាយចតុប្បារិសុទ្ធិសីល របស់ព្រះគ្រូសិរីសោភ័ណ កិម-តូរ ជាដើម

-ព្រះត្រៃបិដក

-អដ្ឋកថាព្រះវិន័យ ព្រះសូត្រ និងព្រះអភិធម្ម

-សារត្ថទីបនីដីកា

-វិមតិវិនៅទនីដីកា

-វិនយវិនិច្ឆយដីកា

-គម្ពីរវិសុទ្ធិមគ្គ

-គម្ពីរមិលិន្ទបញ្ហា

-គម្ពីរមង្គលត្ថទីបនី

-គម្ពីរសទ្ធនីតិ សុត្តមាលា

-វចនានុក្រមពុទ្ធសាសន៍ (ភាសាថៃ)

-វចនានុក្រមព្រះពុទ្ធសាសនា របស់ឧបាសក ស៊ីមរតនៈ

-វចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឃរាជ ជួនណាត (ជោតញ្ញានោ)

និងឯកសារមួយចំនួនផ្សេងទៀត ។ ល។

បុរាណភាសិត

ឫស្សីរអាងបន្លាការពារខ្លួន
ប្រាជ្ញារអាងច្បាប់ក្បួនការពារខុស
ជនពាលគ្មានអ្វីរអាងទាំងអស់
រអាងតែរណ្តៅទាស់តទល់កម្លាំងបាយ ។



នាមអ្នកចូលរួមបោះពុម្ពសៀវភៅនេះ

១-ភិក្ខុរតនបុត្តោ **បុត្ត-សំបាន**	១00$
២-ភិក្ខុ**ធិន -ផង់**	៣0 ក្បាល
៣-ភិក្ខុវីរិយបណ្ឌិតោ **លឿត-វរលក្ខណ៍**	១១ ក្បាល
៤-សាមណេរ សមថវីរិយ**រ៉ូ-ម៉ាវីទ្ធិ**	១0 ក្បាល
៥-ភិក្ខុ**សាន-សុខឿន**	៩ ក្បាល
៦-ភិក្ខុ**វាម-អឿត**	៧ ក្បាល
៧-សាមណេរ **ថូយ-សុប៊ុនធឿន**	៥ ក្បាល
៨-សាមណេរ **ខាន់-ទីន**	៥ ក្បាល
៩-សា.**ភឿង-ភាត់**	៥ ក្បាល
១0-សា. **រឿន-សារាត់**	៤ ក្បាល
១១-ភិក្ខុ**ឡឿង-អួច**	២ ក្បាល
១២-ភិក្ខុ**ស័ក្ត-ចាន់សុខ**	២ ក្បាល
១៣-ភិក្ខុ **ឌៀ-ដួងពេជ្រ**	២ ក្បាល
១៤-ភិក្ខុ**ស៊ើង-សុជាត**	២ ក្បាល
១៥- ភិក្ខុ **ផាន-គីមហាង**	២ ក្បាល
១៦-សា. **សាយ-គិមហេង**	២ ក្បាល
១៧-សា. **ចន្ទ-ពិសិដ្ឋ**	២ ក្បាល
១៨-សា. **សែត-តក់**	២ ក្បាល
១៩-សា. **សែត-បញ្ញា**	២ ក្បាល
២0-សា.**ស៊ីម-ពិសិដ្ឋ**	២ ក្បាល
២១-សា.**សាន-រស្មី**	២ ក្បាល
២២-សា.**ឈន-ថា**	២ ក្បាល
២៣-សា.**អួន-វីទ្ធី**	២ ក្បាល
២៤-សា.**យឿម-កែងិត**	២ ក្បាល

២៥-សា. **សូ-ឆក**	២ ក្បាល
២៦-សា.**ប្រាក់-ដា**	១ ក.
២៧-សា.**វុន-វ៉ាន់និត**	១ ក.
២៨-សា.**យ៉ាង-នៅ**	១ ក.
២៩-សា.**គីះ-សី**	១ ក.
៣0-សា.**ចិត្ត-ពិសិដ្ឋ**	១ ក.
៣១-សា.**សាន់-សីង**	១ ក.
៣២-សា.**ពេជ្រ-សាវង់**	១ ក.
៣៣-សា. **យិប-សុកាយ**	១ ក.
៣៤-សា. **អេង-ម៉ុងហេង**	១ ក.
៣៥-សា. **យឿន-សុបិន**	១ ក.
៣៦-សា. **អួង-រឿន**	១ ក.
៣៧-សា. **ស្បៃប-កាយ**	១ ក.
៣៨-សា. **រ៉ង-សេងលី**	១ ក.
៣៩-សា. **ឈួង-គួន**	១ ក.
៤0-សា. **ភី-សុខឃី**	១ ក.
៤១-សា. **ម៉ុក-ម៉ាច**	១ ក.
៤២-សា. **ចាន់-សុមុនី**	១ ក.
៤៣-សា. **ពៅ-អែម**	១ ក.
៤៤-សា. **ភី-ភិចឈ័រ**	១ ក.
៤៥-សា. **ហ៊ាប-មេសា**	១ ក.
៤៦-សា.**ហុ-ដា**	១ ក.
៤៧-ភិក្ខុ**គិម-តេង**	៦២000រ
៤៨-ភិក្ខុរក្ខិតមនោ **ជី-សុភាព**	៥0000រ
៤៩-ភិក្ខុ **សាង-ពេជ្រ**	៥0000រ

៥០-ភិក្ខុ **ឡាំ-សុផាត**	២៥000រ
៥១-សា. **ចេត្រ-ធារ៉ា**	៤0000រ
៥0-សា. **ញឹម-ញ៉ែន**	២២000រ
៥២-សា. **វ៉ែន-សម្បត្តិ**	១២000រ
៥៣-សា. **លិម-ពន្លឺ**	១២000រ
៥៤-សា. **ហិស-ក្លៃ**	១២000រ
៥៥-លោកឯកឧត្តម **ហេង-បូរា**	១00$
៥៦-លោកគ្រូឧទ្ទេសាចារ្យ **ស៊ឹម-រតនៈ**	១0 ក្បាល

ឥទំ នោ ធម្មទានំ និព្វានបច្ចយោ ហោតុ អនាគតេ ការលេ

ទីធម្មទាននៃយើងទាំងឡាយនេះ ចូរជាបច្ច័យនៃព្រះនិព្វាន ក្នុងកាលជាអនាគត ។

សព្វទានំ ធម្មទានំ ជិនាតិ

ការឱ្យធម៌ ឈ្នះអស់អំណោយទាំងពួង ។

ធម្មបូជា មហាបញ្ញោ

បូជាព្រះធម៌មានបញ្ញាច្រើន ។

សូមអនុមោទនាធម្មទាន !!!

សារីបុត្តសុត្តនិទ្ទេស

និធីនំវ បវត្តារំ យំ បស្សេ វជ្ជទស្សិនំ
និគ្គយ្ហវាទឹ មេធាវឹ តាទិសំ បណ្ឌិតំ ភជេ
តាទិសំ ភជមានស្ស សេយ្យោ ហោតិ ន បាបិយោ
ឱវទេយ្យា នុសាសេយ្យ អសព្ភា ច និវារយេ
សតញ្ហិ សោ បិយោ ហោតិ អសតំ ហោតិ អប្បិយោ ។

បុគ្គលបើឃើញនូវអ្នកប្រាជ្ញណា ដែលមានប្រក្រតីបង្ហាញទោស
ដែលឧស្សាហ៍ពោលផ្តុំញុំផ្តាល់ ដូចជនអ្នកបង្ហាញកំណប់ទ្រព្យ
គួរតែគប់រកនូវបណ្ឌិត ប្រាកដដូច្នោះ កាលបើបុគ្គលគប់រក
បណ្ឌិតប្រាកដដូច្នោះ សេចក្តីល្អ រមែងកើតមាន មិនមែនជាការ
អាក្រក់ទេ ជនគួរទូន្មានគេ គួរប្រៀនប្រដៅគេ ទាំងគួរជួយរារាំង
ចាកអសប្បុរស ដ្បិតថា ជនអ្នកទូន្មានគេនោះ រមែងជាទីស្រឡាញ់
នៃពួកសប្បុរស តែមិនជាទីស្រឡាញ់នៃពួកអសប្បុរសទេ ។

(សុត្តន្តបិដក ខុទ្ទកនិកាយ មហានិទ្ទេស លេខ ៦៦/៣៣១)

រោងពុម្ព គីម ឡុង
KIM LONG PRINTING HOUSE
012 200 787 / 012 77 44 40
សីតវន នៅវត្តវិសុទ្ធិមគ្គ

9 789924 908609